# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



បដិមាលើភ្នំបន្ទាយនាង ( ខេត្តបន្ទាយមានជ័យ )


ឆ្នាំទី ៥៧ លេខ ១ ខែ មករា - កុម្ភៈ - មីនា

ព.ស. ២៥៤៦ គ.ស. ២០០៣

ភ្នំពេញ

រូបក្របខាងក្រៅ : *រូបសំណាក បដិមា មានកំពស់ ៩ ម៉ែត្រកន្លះ (ពីភ្នែនទៅព្រះកេស) ស្ថិតនៅលើភ្នំបន្ទាយនាង ឃុំបន្ទាយនាង ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ កសាងក្នុងអំឡុងឆ្នាំ ១៩៩៦ - ២០០២។*


**សូមថ្លែងអំណរគុណ**

ចំពោះមហាឧបាសិកា **ញឹក ម៉ុនថា** ដែលបានឧបត្ថម្ភក្នុងការចុះយកពត៌មាន និងថតរូបភាព ដើម្បីបោះពុម្ពទស្សនាវដ្តីកម្ពុជសុរិយា លេខ ១ ឆ្នាំ ២០០៣ នេះ។

សូមមហាឧបាសិកា ជួបតែពុទ្ធពរទាំងប្រាំប្រការ កុំបីឃ្លាងឃ្លាតឡើយ។



LIBRARY
BUDDHIST INSTITUTE

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : **ខួន វ៉ាន់ចន្ធី**

និពន្ធនាយក : **ខៀវ បញ្ញាវុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យឺហ៊ាង** លោក **ម៉ែន ច្រាង**

លោក **ទង់ សុធារ៉ា** លោក **ឆន់ ហ៊ិន**.

លោក **មៀច ប៉ុណ្ណ** លោក **ពិ ប៊ុន្នីន**

## គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ខាវ សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ. ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **ឆេត ចារ៉ឹម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# មាតិកាអត្ថបទ


## I. អក្សរសិល្បព្ុទ្ធសាសនា :

- ជីវិតមនុស្ស និងបញ្ហា (ត) ............... (ឈន អៀម) ១

## II. អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ :

- ច្បាប់ធម្មជាតិ និងច្បាប់សកល ....... (ព្រឹទ្ធាចារ្យ ឆេង ផុន ) ១២
- សីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន(ត) ......(ឆយ យីហ៊ាង) ២២
- ការរីកចម្រើននៃព្រះពុទ្ធសាសនា (ត) ..........(ខ្លួត ធីតា) ៣៤
- ប្រវត្តិរបាំក្បាច់បុរាណ (តចប់) .......... (ពេជ្រ ទុំក្រវិល) ៤០
- ប្រវត្តិប្រាសាទជាហោ..........................(សុខ ចេង ) ៥០
- ហេតុអ្វីបានជាអ្នកស្រុកបាកានមិនដាំថ្នាំជក់.. (ម៉ៅ សោភ័ណ) ៥៥
- របាំត្រុដិ ..... ............................(ហ៊ីង ទីម ) ៦២
- ល្បែងចោលឈូង ឬបោះឈូង ................(ជួប ឃាន) ៧០
- កំណាព្យខ្មែរ............................(យ៉ាន់ បូរិន) ៧៥
- កំណាព្យ " កើតមកជាមនុស្ស " ..........(សៅ ដារឿន) ៧៩

## III. កំណត់ និងប្រវត្តិការណ៍ :

- សេចក្តីជូនដំណឹងរបស់ក្រសួងធម្មការ និងសាសនា.. ....... ៨១
- ព្រះរាជក្រឹត្យតែងតាំងព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ...... ៨២
- វឌ្ឍនភាពថ្មីៗ នៃវិទ្យាសាស្ត្រទំនើប លើកកំពស់វិសេសភាព នៃពុទ្ធសាសនា....(ព្រះតេជព្រះគុណ វេរគោទ សាទរមហាថេរ) ៨៣

## IV. ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា

- លិខិតឆ្លើយតបរបស់លោក ម៉ៅ សោភ័ណ...(ម៉ៅ សោភ័ណ) ៨៧

# ជីវិតមនុស្ស និង បញ្ហា (ត)

បណ្ឌិត ក. ស្រី ធម្មានន្ទ

បកប្រែ : ឈន អឿម

## គ្រួសារមានសុភមង្គល

វាជាហេតុការណ៍ពិតក្នុងសង្គមនិមួយៗ ដែលថាគ្រួសារមួយ គឺជាឯកតាសង្គមដ៏តូចបំផុតមួយ។ បើគ្រួសារនិមួយៗ នៅក្នុងប្រទេសមួយមានសុភមង្គល នោះប្រជាជនទាំងមូលនឹងមានសុភមង្គ។ តើអ្វីខ្លះកផ្ដុំជាគ្រួសារមួយមានសុភមង្គល ? គ្រួសារមានសុភមង្គល ត្រូវបានគេឱ្យនិយមន័យថា ជាគ្រួសារមួយមានស្ថេរភាពក្នុងន័យទាក់ទងនឹងទិដ្ឋភាពទាំងឡាយនៃជីវិតរស់នៅខាងសង្គមកិច្ច, សេដ្ឋកិច្ច, ផ្លូវចិត្ត និងផ្លូវកាយ, និងទីឋានដែលមានសេចក្ដីស្រឡាញ់ថ្នាក់ថ្នម និងសុខដុមភាព ក្នុងចំណោមសមាជិកគ្រួសារ។ គ្រួសារមួយដែលអាចបង្កើតឱ្យមានតុល្យភាពមួយរវាងកត្តាទាំងឡាយនេះ គឺជាគ្រួសារមួយមានសុភមង្គលដោយពិត។

ប៉ុន្តែ កាលណាបើយើងក្រឡេកមើលស្ថានភាពជុំវិញយើង នៅក្នុងផ្នែកជាច្រើននៃពិភពលោក, តើយើងឃើញអ្វី ? ក្មេងៗកំពុងដើរប៉ោឡែនៅតាមផ្លូវក្នុងទីក្រុង និងនៅតាមទីកន្លែងបញ្ចាំងវីដេអូ។ ពួកគេគេចវេះពីសាលា។ កូនក្មេងត្រូវគេរំលោភបំពាន, ស្រីមេផ្ទះជាភរិយាត្រូវគេវាយធ្វើបាប ហើយឪពុកម្ដាយចាស់ៗ ត្រូវគេបណ្ដេញឱ្យចុះចេញពីផ្ទះទៅនៅផ្ទះសម្រាប់មនុស្សចាស់ ដោយមិនគិតគូពីអារម្មណ៍របស់ពួកគាត់ឡើយ។ ទាំងអស់នេះ គឺជាសញ្ញាប្រាប់អាថិកំបាំងថាទាំងអស់មិនល្អទេ នៅក៏រិតមូលដ្ឋាននៃសង្គម : ទាំងនេះ គឺជាសញ្ញានៃការស្រុតចុះនៃសង្គម។

វាជាស្ថានភាពគួរឱ្យសោកស្តាយមួយ កាលណាតម្លៃ និងប្រពៃណីល្អៗ មិនត្រូវបានគេប្រតិបត្តិទៀតឡើយ។ មានប្រតិកម្មតិចតួចក្នុងចំណោមសមាជិកគ្រួសារ និងមិត្រភក្តិ ហើយស្មារតីនៃការទទួលខុសត្រូវចំពោះសមាជិកឯទៀតៗនៃគ្រួសារ គឺកាន់តែចុះខ្សោយទៅៗ។ អព្វមង្គលក្នុងគ្រួសារមួយ អាចឱ្យគេចោទប្រកាន់ថាកើតមកពីភាពក្រីក្រ. ប៉ុន្តែ ការមានទ្រព្យធនជាសម្ភារៈក៏មិនប្រាកដធានាបានសុភមង្គលដែរ ប្រសិនបើទ្រព្យធនទាំងនោះគ្រាន់តែចិញ្ចឹមអាត្មានិយម. ភាពកំណាច និងលោភៈ ។

កូនយល់ដឹងសេចក្តីស្រឡាញ់ និងសេចក្តីស្នេហាអំពីឪពុកម្តាយវា ហើយរួមជាមួយគ្នា ពួកគេបង្កើតបានជាឯកតាគ្រួសារមួយមានសុភមង្គល។ តាមជីវត្តភាព (microcosm ) នៃសង្គមនេះ, កូនចេះដឹងការថែទាំ ការចែករំលែក, សេចក្តីអាណិតអាសូរ (មេត្តា) និងសេចក្តីព្រួយបារម្ភ ចំពោះមនុស្សឯទៀត ។ ឆ្លងកាត់សម័យកាលកន្លងមក សាសនាបង្ហាញឱ្យឃើញថា គឺជាកម្លាំងដ៏សំខាន់មួយ ដើម្បីចាត់តាំងតម្លៃទាំងអស់នេះ ទៅក្នុងប្រព័ន្ធមួយ ដែលងាយទទួលស្គាល់ និងងាយបង្រៀន ។ ដូច្នេះគ្រួសារ និងសាសនា គឺជាសមាសភាគជាអាយុជីវិត ក្នុងការចែករំលែក និងចិញ្ចឹមបំប៉នតម្លៃទាំងឡាយនេះ ។

គ្រួសារដើរតួសំខាន់មួយ ក្នុងការអភិវឌ្ឍន៍សមាជិករបស់ខ្លួន ។ វប្បធម៌ដ៏ល្អប្រសើររបស់អាស៊ី និងលោកខាងលិច បង្រៀននិងបង្ហាត់ឱ្យមានសេចក្តីគោរពចំពោះចាស់ព្រឹទ្ធាចារ្យ. សេចក្តីមេត្តាចំពោះអ្នកជំងឺ. និងជនទីទាល់ក្រ. ការថែទាំឪពុកម្តាយចាស់ជរា និងការយកចិត្តទុកដាក់ចំពោះយុវជន។

កូនៗ ធំពេញវ័យឡើងនៅក្នុងគ្រួសារទាំងឡាយ ដែលហ្វឹកហាត់តម្លៃទាំងឡាយនេះ នឹងប្រកួតប្រជែងគ្នាអនុវត្តនូវគុណធម៌ទាំងនោះយ៉ាងសមស្រប ចំពោះ

មនុស្សឯទៀត។ ប៉ុន្តែ ដោយហេតុតែមានការជឿនលឿនខាងបច្ចេកវិជ្ជាដ៏ទូលំទូលាយ នៅក្នុងអារ្យធម៌សម័យថ្មី, យើងឆាប់បាត់បង់តម្លៃទាំងឡាយនេះ។ គេត្រូវតែធ្វើអ្វីមួយ ដើម្បីនាំយកគ្រួសារមកវិញជាមួយគ្នា ហើយសង្គ្រោះសង្គម។

យើងត្រូវការពារ និងឧបត្ថម្ភការអភិវឌ្ឍន៍គ្រួសារ ទុកដូចជាស្ថាប័នមួយក្រោមពន្លឺនៃការប្រែប្រួលយ៉ាងឆាប់ខាងកំណើនប្រជាជន និងខាងសង្គម-សេដ្ឋកិច្ចក្នុងពិភពលោក។ មហាគ្រួសារ (Extended family = គឺគ្រួសារដែលរាប់បញ្ចូលមារ, មីង, ជីដូនមួយ រួមជាមួយឪពុក, ម្តាយ និងកូន ) ត្រូវបានជំនួសដោយខុទ្ទកគ្រួសារ (Nuclear family = គឺគ្រួសារដែលមានតែឪពុក, ម្តាយ និងកូនប៉ុណ្ណោះ)។ យើងអាចធ្វើបានតិចតួចណាស់ ដើម្បីបញ្ឈប់ទំនោរនេះ ប៉ុន្តែ តម្លៃនៃសេចក្តីគោរព, សេចក្តីកង្វល់ និងសេចក្តីអាណិតអាសូរ (មេត្តា) ត្រូវតែរក្សាឱ្យបាន។ តម្លៃល្អៗទាំងរបស់លោកខាងកើត ទាំងរបស់លោកខាងលិច, ត្រូវរក្សាទុក ទោះបីមានការប្រែប្រួល នៅក្នុងបែបបទរស់នៅកើតមកពីទំនើបឧបនីយកម្ម ឧស្សាហូបនីយកម្ម និងនគរូបនីយកម្មក្តី។

ម្តាយ គឺជាតួអង្គសំខាន់មួយក្នុងការអភិវឌ្ឍន៍គ្រួសារ។ ដោយហេតុថាការថែទាំ, សេចក្តីស្នេហា, សេចក្តីថ្នាក់ថ្នម និងសេចក្តីអាណិតអាសូរ គឺជាគុណសម្បត្តិពីកំណើតរបស់ម្តាយ, គាត់បានចែករំលែកតម្លៃដ៏ថ្លៃថ្លាទាំងនេះទៅឱ្យកូនៗ របស់គាត់ក្នុងពេលពួកគេចម្រើនវ័យធំឡើង។ ម្តាយដោយសារគាត់មានសេចក្តីស្នេហា, សេចក្តីកង្វល់, សេចក្តីអាណិតអាសូរ, ខន្តី និងសន្តោស ទើបអាចទ្រទ្រង់គ្រួសារឱ្យគង់វង្សបាន។ ការឧបត្ថម្ភគាំទ្រ របស់គាត់នូវតម្លៃទាំងឡាយនេះ អាចបន្តទៅដល់កូនៗរបស់គាត់ ដែលពួកែគ្រាប់តាម ហើយដែលរៀនសូត្រតាមគំរូ។ យើងទាំងឡាយក្នុងឋានៈជាក្រុមគ្រួសារមួយ ត្រូវរក្សាមុខងារជាប្រពៃណីរបស់ម្តាយឡើង

វិញ ប៉ុន្តែត្រូវប្រព្រឹត្តឱ្យសមស្រប ទៅនឹងសេចក្តីត្រូវការ និងសម្ភាធសម័យកាលថ្មីនេះ ។

សាសនាផងដែរ លើកស្ទួយតម្លៃល្អៗ របស់មនុស្ស ។ ដោយហេតុនេះ, គ្រួសារដ៏ខ្លាំងឆាប់ស្តារបានឡើងវិញ, ហើយការប្រតិបត្តិសាសនា គឺជាកត្តាចាំបាច់ណាស់ ក្នុងការលើកស្ទួយការអភិវឌ្ឍន៍គ្រួសារ ។

គេអាចនិយាយបានថា គ្រួសារមានសុភមង្គល គឺជាក្រុមមនុស្សមួយក្រុមរស់នៅជាមិត្រភ័ក្តិ និងដោយសុខសាន្តជាមួយគ្នា ដោយឱ្យតម្លៃលើសាសនា, វិន័យ និងភាពជាឪពុកម្តាយ ដើម្បីបង្កើតបរិយាកាសគ្រួសារមួយមានសុភមង្គល ។ តម្លៃទាំងឡាយ ដូចតម្លៃទាំងនេះ គម្បីនាំគ្នាលើកស្ទួយ ហើយការពារដោយសេចក្តីគោរពស្រឡាញ់ ដើម្បីកុំឱ្យគ្រួសារទទួលឥទ្ធិពលអំពីតម្លៃប្រឆាំងសង្គម និងនិយាមដែលមិនអាចទទួលយកបាន ។

ឪពុកម្តាយប្រាកដនិយម និងមានវិចារណញ្ញាណ កសាងបាននូវគ្រួសារមួយមានសុភមង្គល ។ ហើយមាគ៌ាតែមួយគត់ ដែលឪពុកម្តាយអាចកសាងគ្រួសារមានសុភមង្គលមួយបាន គឺតាមរយៈស្ថាប័នអាពាហ៍ពិពាហ៍ ។ ស្ថាប័ននេះ បានធ្វើការប្រកបដោយជោគជ័យក្នុងអតីតកាល ។ វាក៏អាចធ្វើការបានជោគជ័យទៀតក្នុងពេលឥឡូវនេះ ឱ្យតែយើងធ្វើវាឱ្យមានទំនាក់ទំនងទៅនឹងសេចក្តីត្រូវការនៃជីវភាពរស់នៅសព្វថ្ងៃនេះ ។

## បញ្ហាអាពាហ៍ពិពាហ៍

ស្ទើរតែរៀងរាល់ថ្ងៃ យើងតែងឮមនុស្សត្អូញត្អែរអំពីរឿងអាពាហ៍ពិពាហ៍របស់ខ្លួន ។ ពួកមនុស្សក្មេងៗ ដែលចូលចិត្តអានរឿងប្រលោមលោកអណ្តែតអណ្តូង និងមើលរឿងកុន លន្លង់លន្លោច ច្រើនសន្និដ្ឋានថា អាពាហ៍ពិពាហ៍គឺ ជាសេយ្យាសនៈ

ផ្កាកុឡាប ( a bed of roses ) ។ ជាអកុសល, អាពាហ៍ពិពាហ៍ មិនមែនផ្អែមល្ហែមដូច គេគិតនោះទេ។ អាពាហ៍ពិពាហ៍ និងបញ្ហាអាពាហ៍ពិពាហ៍ មានទំនាក់ទំនងចាក់ស្រេះជាមួយគ្នា, ហើយមនុស្សត្រូវចងចាំថា កាលណាគេរៀបអាពាហ៍ពិពាហ៍, គេនឹងត្រូវប្រឈមមុខនឹងបញ្ហាមួយចំនួន និងការទទួលខុសត្រូវ ដែលគេមិនធ្លាប់បានគិតទុក ឬមិនធ្លាប់បានពិសោធពីមុនមក។

ក្រោយពេលបានក្រេបសុភមង្គលនៃអាពាហ៍ពិពាហ៍, តថភាពនៃជីវិតរស់នៅរួមគ្នា នឹងរំកិលខ្លួនចូលមកដល់សម្រាប់គូស្រករ, ហើយសម្រាប់គូស្រករខ្លះ, ទិដ្ឋភាពអនាគតបានធ្វើឱ្យគេអស់សេចក្តីក្លាហាន។ ការខ្វះទំនាក់ទំនងឆ្លើយឆ្លង ឬអន្តរកម្មជាមួយសមាជិកទាំងឡាយក្នុងគ្រួសារ គឺជាកត្តាខ្លះៗ ដែលអាចផ្តល់ចំណែកដល់អាពាហ៍ពិពាហ៍ខ្វះសុភមង្គល។ ស្ថានភាពនេះឈានដល់កម្រិតខ្ពស់បំផុត កាលណាប្តីនិងប្រពន្ធ សូម្បីតែនិយាយឆ្លើយឆ្លងជាមួយគ្នា ក៏មិនបានដែរ។

ឧទាហរណ៍ទូទៅ ដែលប្តី និងប្រពន្ធមិននិយាយឆ្លើយឆ្លងរកគ្នាគឺ (ក) នៅពេលស្រស់ស្រូបអាហារពេលព្រឹក ប្តីជក់ចិត្តអានសារពត៌មានស្ងប់ពេក, (ខ) ពេលត្រឡប់មកពីធ្វើការវិញ ប្តីជក់ចិត្តនឹងល្បែងកំសាន្ត ឬមើលទូរទស្សន៍, ហើយនៅចុងសប្តាហ៍ ទៅវាយកូនគោល (the golf) ឬជក់ចិត្តនឹងចំណាយពេលកំសាន្តផ្សេងៗ, (គ) ប្តីមិនសំដែងឱ្យឃើញអារម្មណ៍ណាមួយ ឬសេចក្តីកង្វល់តិចតួចចំពោះប្រពន្ធ, សូម្បីតែនឹកឃើញដល់ខួបកំណើត ឬថ្ងៃកំណើតសំខាន់ៗក៏មិនគិតគូរផង។

ចំណែកឯប្រពន្ធវិញ, ក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ, មិនបានយកចិត្តទុកដាក់ថែរក្សាមុខមាត់ និងខ្លួនប្រាណទូទៅទេ។ នាងតែងស្លៀកពាក់ខ្ជីខ្ជា។ ដោយហេតុតែនាងលែងរវល់ ឬលែងរក្សាក្រុមមិត្តភក្តិស្រើបស្រាលហើយ, ប្តីយល់ឃើញថាគេមិនអាចចូលរួមក្នុងការសន្ទនាស្រើបស្រាលជាមួយនាងទៀតទេ ។ បន្ទាប់មកជីវិត

រស់នៅក្លាយទៅជាសភាពធុញទ្រាន់ ហើយរឿងនេះអូសទាញប្តីឱ្យទៅរកផឹកស៊ី ហើយស្វែងរកសេចក្តីសុខសាន្ត ក្រៅផ្ទះអាពាហ៍ពិពាហ៍។

តើពេលណាសេចក្តីថ្នាំងថ្នាក់ចិត្ត ជ្រែកចូលក្នុងអាពាហ៍ពិពាហ៍ជាដំបូង? សម្រាប់គូស្រករភាគច្រើន, ឆ្នាំទីមួយ គឺតាមធម្មតាជាឆ្នាំល្អ។ សម្រាប់គូស្រករខ្លះវិញ, ការកែតម្រូវជីវភាពរស់នៅជាមួយគ្នា ជាប្តីប្រពន្ធ ប្រែក្លាយទៅជាបទពិសោធន៍ប្រកបដោយភាពតានតឹងចិត្ត។ ការបង្កើតបានកូនដំបូង អាចបង្កឱ្យមានបញ្ហាផងដែរ នៅពេលប្តី និងប្រពន្ធខិតខំយ៉ាងខ្លាំង ដើម្បីជំនះតថភាព ដើម្បីធ្វើខ្លួនជាឪពុកម្តាយជាលើកដំបូង។

មនុស្សខ្លះ និយាយថា ឆ្នាំដំបូងបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍របស់គេ, ប្តីធ្លាប់តែស្តាប់ប្រពន្ធរបស់ខ្លួន, ចាប់ពីឆ្នាំទីពីរទៅ ប្រពន្ធធ្លាប់តែស្តាប់ប្តីរបស់ខ្លួនវិញ។ ចាប់តាំងពីឆ្នាំទីបីទៅ អ្នកជិតខាងធ្លាប់តែស្តាប់អ្នកទាំងពីរ នៅពេលដែលពួកគេស្រែកដាក់គ្នាទៅវិញទៅមក។

តាមធម្មតា, សេចក្តីថ្នាំងថ្នាក់នឹងកាន់តែមានធំឡើង, ប្រសិនបើគ្មានការរៀបចំអាពាហ៍ពិពាហ៍ឱ្យបានត្រឹមត្រូវទេ។ ជាឧទាហរណ៍, ការផ្តល់ដំបូន្មានមុនអាពាហ៍ពិពាហ៍ នឹងជួយគូស្រករទាំងឡាយឱ្យរៀបចំការពញ្ញាក់អារម្មណ៍ជាច្រើន, ជាទីរីករាយ ឬជារឿងផ្សេង ដែលពួកគេអាចរកឃើញ នៅក្នុងដំណើរប្រព្រឹត្តទៅនៃអាពាហ៍ពិពាហ៍របស់ពួកគេ។

សេចក្តីទោមនស្ស ដែលត្រូវប៉ះពាល់ដល់មនុស្សភាគច្រើនក្រោយពេលបានរៀបអាពាហ៍ពិពាហ៍អស់ពេលច្រើនឆ្នាំហើយ រមែងកើតចេញមកពីទស្សនៈខុសឆ្គងថា " ស្មៅមានពណ៌បៃតងខ្ចីជាង នៅឯផ្នែកម្ខាងទៀតនៃរបង "។ ទំនោរដែលទោរទន់ទៅរកសមាជិកទាំងឡាយមានភេទដូចគ្នា មិនមានកំណត់ព្រំដែនអាយុ

ទេ។ ភាពរសាប់រសល់បែបនេះ អាចកើតឡើងពេលណាមួយ ក្នុងអំឡុងអាពាហ៍ពិពាហ៍ សូម្បីសម្រាប់ស្ត្រីក៏មានដែរ។

សេចក្តីអផ្សុក គឺជាមូលហេតុមួយ.ចំណែកការអាក់អន់ចិត្តជាមួយដៃគូក៏ជាការត្អូញត្អែទូទៅមួយដែរ។ កាលណាសេចក្តីប៉ងប្រាថ្នាមិនបានបំពេញ, សេចក្តីខ្ញក់ខ្ញាញ់នឹងចាប់ផ្តើមរីកធំធាត់។ ក្នុងករណីខ្លះ កាលណាគ្មានការប្តេជ្ញាចិត្តម៉ឹងម៉ាត់ចំពោះអាពាហ៍ពិពាហ៍ ហើយគ្មានឫសគល់សាសនាទេ, រឿងហេតុអ្វីមួយ អាចកើតមាននៅពេលណាមួយ ធ្វើឱ្យអន្តរាយអាពាហ៍ពិពាហ៍នោះមិនខាន។

តើអ្វីជាឫគល់នៃទោមនស្ស ? ស្ត្រីមេផ្ទះជាច្រើននិយាយថា ពួកគេប្រាថ្នាឱ្យប្តីរបស់ពួកគេស្តាប់ពួកគេឱ្យច្រើន. យកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការរបស់ពួកគេ ឬប្តីរបស់ពួកគេសំដែងអារម្មណ៍របស់ខ្លួនឱ្យបានប្រសើរចំពោះពួកគេ។ ទាំងអស់នេះអាចសង្ខេបទៅជាករណីមួយនៃការសន្ទនាឆ្លើយឆ្លងគ្នា ដែលខ្វះខាតច្រើនណាស់ក្នុងអាពាហ៍ពិពាហ៍សម័យថ្មីភាគច្រើន។ នៅក្នុងអតីតកាល ដោយសារការចិញ្ចឹមបីបាច់របស់ពួកគេ, ស្ត្រីទាំងឡាយត្រេតអរដើម្បីឋិតនៅក្នុងជួរក្រោយ ហើយទទួលយកប្រព្រឹត្តិកម្មប្រភេទណាក៏ដោយអំពីដៃរបស់ប្តីនាង។ ប៉ុន្តែពេលវេលាបានប្រែប្រួល។ ស្ត្រីទាំងឡាយបានទទួលការអប់រំប្រសើរឡើង, កាន់ការងារទទួលខុសត្រូវ, យល់ដឹងអំពីសិទ្ធិរបស់ខ្លួន។ បុរសទាំងឡាយ ត្រូវទទួលស្គាល់នូវតថភាពទាំងឡាយនេះ ហើយត្រូវចាត់ទុកប្រពន្ធរបស់ខ្លួនជាដៃគូស្មើមុខគ្នានៅក្នុងអាពាហ៍ពិពាហ៍។ គេមិនត្រូវមើលរំលងតម្លៃរបស់ភរិយាឡើយ។

ចំពោះបុរសទាំងឡាយ អាពាហ៍គឺជាគោលដៅមួយ ដែលពួកគេបានកំណត់ដើម្បីសម្រេច។ ដោយបានកំណត់យ៉ាងដូច្នេះ, ពួកគេត្រូវបង្វែរថាមពល និងពេលវេលារបស់ពួកគេ ទៅក្នុងទិដ្ឋភាពដ៏សំខាន់បំផុតផ្សេងទៀតនៃជីវភាពរបស់

ពួកគេ ពោលគឺមុខរបរ ឬធុរកិច្ចរបស់ពួកគេ។

ចំណែកសេចក្ដីសង្ឃឹមរបស់ស្ត្រីវិញគឺ ផ្សេងពីគ្នាទាំងស្រុងក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ. នាងសង្ឃឹមចង់បានសេចក្ដីស្នេហា និងភាពជិតស្និតឱ្យបានច្រើន ហើយដោយហេតុនេះ នាងស្វះស្វែងចំណាយពេលវេលាយ៉ាងច្រើន នៅជាមួយប្ដីរបស់នាង។

ការនាំយកបញ្ហាពីខាងក្រៅរបស់ខ្លួន ទៅក្នុងគ្រួសារ និងការខ្ទាក់កំហឹងមួរម៉ៅទៅលើប្រពន្ធ និងកូន គឺបង្កអន្តរាយដល់ស្ថេរភាពគ្រួសារ ហើយបង្កើតភាពតានតឹងឈានឡើង។

នៅក្នុងសង្គមជនជាតិអាស៊ី, បញ្ហានៃការអន្តរាគមន៍របស់ញាតិសាច់ថ្លៃ គឺជាបញ្ហាទូទៅមួយ។ រឿងនេះ កើតមានជាពិសេសប្រសិនបើញាតិសាច់ថ្លៃ អាចជះឥទ្ធិពលលើសេចក្ដីសម្រេចចិត្តរបស់កូនពួកគេបាន។ សេចក្ដីត្អូញត្អែរទូទៅមួយដែលភរិយាទាំងឡាយបានលើកឡើងគឺថា ប្ដីទាំងឡាយស្ដាប់តែឪពុកម្ដាយរបស់គេជាជំនួសការស្ដាប់ប្រពន្ធ។ អន្តរាគមន៍របស់ញាតិសាច់ថ្លៃ ក្នុងការចិញ្ចឹមបីបាច់កូន ក៏ជាបញ្ហាទូទៅមួយដែរ។ នៅពេលដែល ជីដូន ជីតា យកពេលសម្រាកលំហែប្រឡែងលេងជាមួយចៅៗ មានពេលខ្លះធ្វើឱ្យក្មេងខូច. ទំនាស់អំពីតម្លៃ (values) រវាងជំនាន់ទាំងឡាយ ជាញឹកញាយច្រើនឆេះសន្ធោសន្ធៅ នៅក្នុងករណីបែបនេះ។

គូស្រករក្មេងៗខ្លះ មិនសប្បាយចិត្តអនុញ្ញាតឱ្យកូនរបស់ពួកគេ ទៅនៅក្បែរកកិតជាមួយជីដូនជីតារបស់វាទេ ដោយគេគិតថា កូនៗនឹងរៀនត្រាប់យករបៀបរស់នៅហួសសម័យរបស់ជីដូន ជីតា ពួកវា។

ក្នុងប្រទេសឥណ្ឌា និងប្រទេសស្រីលង្កា ហើយនៅក្នុងប្រទេសម៉ាឡេស៊ី ក៏មានខ្លះដែរ. ប្រព័ន្ធជំនូនខាងកូនស្រី យកទៅជូនកូនប្រុស គឺជាឧបសគ្គមួយក្នុង

បណ្តាឧបសគ្គចម្បងៗ ចំពោះការរួមរស់នៅជាសុខដុម។ ជំនូនខាងកូនស្រីទៅជូនកូនប្រុស អាចរួមមានចំនួនទឹកប្រាក់ដ៏ច្រើន, ផ្ទះមួយខ្នង ( a bungalow ), រថយន្តប្រណីតមួយ, ទាំងអស់នេះ ឬលើសនេះទៀតអាស្រ័យលើឪពុកម្តាយ មានទ្រព្យធនប៉ុណ្ណា។ ហើយដោយសារតែឪពុកម្តាយចង់ខ្លាំងពេក ដើម្បីរៀបអាពាហ៍ពិពាហ៍ កូនស្រីៗ របស់គេឱ្យផុតៗទៅ, ឪពុកម្តាយទាំងនេះ ក៏តាំងធ្វើពាក្យសន្យា ដែលពួកគេមិនអាចរក្សាបាន ហើយអាពាហ៍ពិពាហ៍ ចាប់ផ្តើមដួលរលំទៅ។

ប្រព័ន្ធជំនូនខាងស្រី ជូនទៅកូនប្រុស ត្រូវបានគេបំពារបំពាន។ ក្នុងសម័យបុរាណ, ជំនូនខាងស្រីជូនទៅកូនប្រុស ត្រូវបានផ្តល់ឱ្យទៅកូនស្រីរក្សាទុក ក្នុងករណីមានគ្រោះថ្នាក់បន្ទាន់។ ក្រោយមក, មិនដូចសព្វថ្ងៃនេះទេ, ស្ត្រីទាំងឡាយ ត្រូវពឹងផ្អែកទាំងស្រុងលើប្តីរបស់គេ ហើយជំនូនស្រីជូនទៅកូនប្រុស គឺជាការធានារ៉ាប់រងមួយប្រភេទ ក្នុងករណីដែលប្តី ក្លាយទៅជាមនុស្សមិនអាចឧបត្ថម្ភគាំទ្រនាងបាន។ ក្រោយមកទៀតជំនូនខាងស្រី ជូនទៅកូនប្រុស ត្រូវបានប្រគល់ទៅឱ្យញាតិសាច់ថ្លៃរក្សាទុកហើយ ឥឡូវនេះ រឿងនេះបានក្លាយទៅជាកាតព្វកិច្ច សម្រាប់ឪពុកម្តាយរបស់កូនប្រសាស្រី ជូនជំនូនទៅឱ្យញាតិសាច់ថ្លៃអនាគតរបស់នាង។

មនុស្សទាំងឡាយច្រើនគិតថា វាជាករណីកិច្ចមួយ ដើម្បីរៀបអាពាហ៍ពិពាហ៍ ហើយអាពាហ៍ពិពាហ៍ គឺជាផ្នែកមួយដ៏សំខាន់ណាស់ នៃជីវភាពរបស់គេ។ ប៉ុន្តែ ដើម្បីធានាអាពាហ៍ពិពាហ៍ឱ្យបានជោគជ័យ, គូស្រករត្រូវធ្វើឱ្យជីវភាពរបស់ពួកគេមានសុខដុមភាព ដោយបន្ថយឱ្យនៅតិចបំផុត នូវគំនិតខ្វែងគ្នាទោះជាអ្វីក៏ដោយ ដែលគេអាចមានរវាងគ្នា និងគ្នា។ គូស្រករមួយ ត្រូវចេះទទួលស្គាល់ផងដែរនូវចំណុចខ្វះខាត និងភាពទន់ខ្សោយផ្ទាល់ខ្លួន របស់ផងគ្នាទៅវិញទៅមក។ សូម្បីតែគូស្រករដ៏មានសុភមង្គលត្រូវរ៉ូវគ្នា ក៏អាចជួបប្រទះនឹងការប៉ះទង្គិច, ទំនាស់,

សេចក្ដីថ្នាំងថ្នាក់ចិត្ត និងការក្រោធខឹង។ គេអាចទទួលស្គាល់ចំណុចខ្វះខាតក្នុងវិស័យទាំងឡាយបែបនេះ គឺបង្ហាញសេចក្ដីសរសើររបស់ផងគ្នាទៅវិញទៅមក, ចំណង់ដើម្បីសន្ទនាគ្នា និងការសំដែងអារម្មណ៍រំភើបដោយច្បាស់លាស់។ ចូរកុំអៀនខ្មាស់គេចចេញការប៉ះទង្គិច។ ការមិនព្រមព្រៀងគ្នា អាចនាំទៅដល់ការដុះដាលធំធាត់ចំណងអាពាហ៍ពិពាហ៍, មិនមែនបំបែកគ្នាទេ។ ជម្លោះឈ្លោះប្រកែក ក៏មានសារសំខាន់ដល់ការរស់រាន ក្នុងចំណងអាពាហ៍ពិពាហ៍ ប្រកបដោយសុខភាពល្អ។ ប៉ុន្តែ ជម្លោះឈ្លោះប្រកែកមួយ អាចត្រូវបានបញ្ចប់ដោយជោគជ័យ បើភាគីទាំងពីរអាចបំភ្លេច និងអត់ឱនឱ្យគ្នាបានតែប៉ុណ្ណោះ។

ចូរស្រឡាញ់ការងារ ដើម្បីចំណងអាពាហ៍ពិពាហ៍របស់អ្នក។ ចូរកុំស្មានថាតាំងពីដប់ឆ្នាំ ឬម្ភៃឆ្នាំមុនមានដំណើរការល្អ, ដប់ឆ្នាំ ឬម្ភៃឆ្នាំក្រោយ ក៏នឹងមានដំណើរការល្អដែរ។ ស្នេហាត្រូវការថែបំប៉ន ដោយបទពិសោធន៍, សេចក្ដីសប្បាយ និងសេចក្ដីទុក្ខព្រួយជាមួយគ្នា។ នេះទាមទារពេលវេលា, ការយកចិត្តទុកដាក់, សេចក្ដីក្លាហាន, និងសេក្ដីយោគយល់គ្នា។

មូលហេតុមួយ ក្នុងបណ្ដាមូលហេតុចម្បងៗ នៃបញ្ហាអាពាហ៍ពិពាហ៍គឺសេចក្ដីសង្ស័យ និងកង្វះទុកចិត្តគ្នា។ ទាំងប្ដី ទាំងប្រពន្ធត្រូវបង្ហាញទំនុកចិត្តគ្នាដោយត្រង់ៗចំពោះគ្នាទៅវិញទៅមក ហើយខិតខំបំបាត់កុំឱ្យមានការសម្ងាត់រវាងគ្នា និងគ្នា។ ការលាក់សម្ងាត់បង្កើតឱ្យមានសេចក្ដីសង្ស័យ, សេចក្ដីសង្ស័យបង្កើតឱ្យមានសេចក្ដីច្រណែនប្រច័ណ្ឌ, ច្រណែនប្រច័ណ្ឌបង្កើតចេញនូវកំហឹង, កំហឹងបណ្ដាលឱ្យមានអរិភាព (ភាពជាសត្រូវ), ហើយអរិភាពអាចបង្កើតជាលទ្ធផលបែកបាក់គ្នា ឬលែងលះគ្នា, ធ្វើអត្តឃាត ឬរហូតដល់ធ្វើមនុស្សឃាតដោយចេតនា។

ប្រសិនបើប្តីប្រពន្ធ អាចចែករំលែកសេចក្តីឈឺចាប់ និងសេចក្តីសប្បាយក្នុងជីវភាពប្រចាំថ្ងៃរបស់គេ, គេអាចលួងលោមគ្នាទៅវិញទៅមក ហើយបន្ថយសេចក្តីទុក្ខសោករបស់គេឱ្យនៅតិច។ ដូច្នេះប្តី ឬប្រពន្ធមិនគប្បីសង្ឃឹមទទួលគ្រប់សេចក្តីសប្បាយប៉ុណ្ណោះទេ នៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ។ វាប្រាកដជាមានរឿងឈឺចាប់ ខ្វោចផ្សា, មានបន្ទុកធ្ងន់ធ្ងរ, និងមានការខ្វែងគំនិតគ្នា ច្រើនប្រការណាស់។ ការពិភាក្សាវែកញែកបញ្ហាជាមួយគ្នាទៅវិញទៅមក នឹងផ្តល់ឱ្យប្តីនិងប្រពន្ធ នូវជំនឿទុកចិត្តគ្នា ដើម្បីដោះស្រាយឧបសគ្គណាមួយ ដែលពួកគេនឹងត្រូវប្រឈមមុខ។ ពួកគេត្រូវមានមនោមយិទ្ធិខ្លាំងក្លា ដើម្បីបន្ថយភាពតានតឹងហើយអភិវឌ្ឍទំនុកចិត្តគ្នា ដើម្បីរួមរស់នៅជាមួយគ្នា ប្រកបដោយសេចក្តីយោគយល់ និងអត់ឱនគ្នាទៅវិញទៅមក កាលណាប្រឈមមុខនឹងបញ្ហា ហើយនឹងការពិបាក។ អារម្មណ៍មិនមានសន្តិសុខ និងរសាប់រសល់ នឹងរលាយបាត់ទៅ ហើយជីវិតនឹងមានន័យ, មានសេចក្តីសុខ និងមានអត្ថប្រយោជន៍ច្រើន ប្រសិនបើមានអ្នកណាមួយ ដែលស្មោះស្ម័គ្រចែករំលែកបន្ទុករបស់អ្នកឯទៀត។

បញ្ហាអាពាហ៍ពិពាហ៍ ញ៉ាំងឱ្យមានអ្នកចាំតែថ្កោលទោសគេ ពោលថា វាអាចមានជីវិតអាពាហ៍ពិពាហ៍ដ៏សុខសាន្តមួយបាន ប្រសិនបើអាពាហ៍ពិពាហ៍ កសាងឡើងលើមូលដ្ឋានប្រពន្ធខ្វាក់ ប្តីថ្លង់ ពិព្រោះប្រពន្ធខ្វាក់មិនអាចមើលឃើញកំហុសរបស់ប្តី ហើយប្តីថ្លង់មិនអាចស្តាប់ឮពាក្យជេរប្រទេចរបស់ប្រពន្ធ។

(នៅមានត)

# ច្បាប់ធម្មជាតិ និងច្បាប់សកល

ដោយ: ព្រឹទ្ធាចារ្យ ឆេង ផុន

## I-សច្ចធម៌ :

- សច្ចះកើតរលត់ៗ លឿនណាស់ ។ នេះជាច្បាប់ប្រែប្រួល សត្យានុម័ត កើតមានឯងៗនៅក្នុងធម្មជាតិនៅក្នុងសង្គម នៅក្នុងចិត្តរបស់មនុស្ស។

- សច្ចះកើតរលត់ៗ ព្រោះហេតុនិងបច្ច័យដែលនាំឱ្យកើតសច្ចះក៏កើតរលត់ៗដែរ ។

- ខ្លាចសច្ចះ គេចសច្ចះ មួលបង្កាច់សច្ចះ គឺជាការមិនទទួលស្គាល់ការប្រែប្រួលផ្លាស់ប្តូររាល់បាតុភូត និងវត្ថុក្នុងលោកនេះ។ តែការទទួលស្គាល់ការរលឹកទាន់ ដឹងទាន់រាល់សច្ចះកំពុងកើតមិនជាការធម្មតាទេ ។ ធ្វើឱ្យជីវិតសច្ចះជានិច្ច ក៏មិនធម្មតាដែរ ។

- សុភមង្គល សេចក្តីសុខសាន្តរបស់មនុស្ស ស្ថិតនៅត្រង់មនុស្សដឹងទាន់ រលឹកទាន់សច្ចះគ្រប់កាល ។

-ហេតុនៃទុក្ខទាំងឡាយ ឧបសគ្គទាំងឡាយ គឺមកពីមនុស្សទទូចចង់ធ្វើអ្វីជាធម្មតា ឱ្យទៅជាមិនធម្មតា ។

*ឧទាហរណ៍ :* មិនចង់ចាស់ មិនចង់ឱ្យឈឺ មិនចង់ឱ្យស្លាប់ មិនចង់ឱ្យបែក គឺជាអសច្ចះ ! មិនធម្មតាទេ ! ព្រោះកើតជាហេតុនាំឱ្យស្លាប់ ។ បើខ្លាចស្លាប់

ត្រូវលែងកើត ។ ទាល់តែលែងកើតទើបអត់បញ្ហាជីវិត ។ នេះជាសច្ចៈ !

-ជីវិតកើតមកហើយ ព្រមទទួលបញ្ហា សុខខ្លះ ទុក្ខខ្លះ ដោះស្រាយបានខ្លះ មិនបានខ្លះ ជាសច្ចៈ ។ ទាមទារសុក្រិតឥតខ្ចោះ សុខឥតទុក្ខ ជាអសច្ចៈ ។

- អសច្ចៈ ធ្វើឱ្យបាត់លក្ខណៈប្រាកដនិយម បាត់ទីនេះ កន្លែងនេះ ជាតិនេះ ពេលនេះ ឥឡូវនេះ ។

- រស់នៅក្នុងសកម្មភាពជានិច្ច ចៀសវាងកុំរស់នៅតែក្នុងគំនិត (Entre dans l'act et non dans l'idée) ។

- ធ្វើយ៉ាងណាកុំឱ្យអតីត និងអនាគត មករំខានបច្ចុប្បន្នឱ្យសោះ ព្រោះផលថ្ងៃស្អែក បានមកដោយហេតុថ្ងៃនេះ ។ ត្រូវយកចិត្តទុកដាក់កម្ម ជាងផលរបស់កម្ម ។

*បើមានទស្សនៈយ៉ាងនេះ ពិភពលោកនឹងបន្ថយបានគំនុំអតីតកាល រវាងជាតិសាសន៍ និងជាតិសាសន៍ រវាងពូជសាសន៍ និងពូជសាសន៍ រវាងបុគ្គល និងបុគ្គល ។ ការសងសឹកក៏បានធូរស្រាល ។ អរិភាពជាតិក៏ត្រូវបានកាត់បន្ថយ ។ លើកលែងទោសអតីតកាលទៅ! អ្វីដែលកន្លងទៅហើយសូមទុកឱ្យវារសាត់ទៅតាមពេលវេលាទៅចុះ ! ចង់បានផលថ្ងៃស្អែកល្អ គួរខំធ្វើថ្ងៃនេះឱ្យបានល្អ ។*

*ចង់បានអាស៊ី អនាគតអាស៊ី សន្តិភាពសម្បូររុងរឿង គួរតែប្រជាជាតិអាស៊ីទាំងអស់ ស្វែងយល់ពីបំណងប្រាថ្នាប្រទេសនីមួយៗឱ្យបានច្បាស់លាស់ ព្រោះមានលក្ខណៈដោយឡែក និងលក្ខណៈរួម នៃជនជាតិនីមួយៗ ។ អ្វីៗដែល*

*ជនជាតិអាស៊ីមានដូចគ្នា និងអ្វីៗដែលជនជាតិនីមួយៗមានដោយឡែក ។*

*"រួមជួយពង្រីកដោយឡែក ដោយឡែកជួយពង្រឹងរួម" ។*

*"បុគ្គលិកលក្ខណៈរួម ជួយពង្រីកបុគ្គលិកលក្ខណៈដោយឡែក បុគ្គលិកលក្ខណៈដោយឡែក ជួយពង្រឹង បុគ្គលិកលក្ខណៈរួម" ។*

## II-**ធម្មជាតិខាងក្រៅ :**

-ជីវិតជោរនាចៗ ទៅដោយក្ដីខឹងក្រោធ និងចិត្តភ័យខ្លាច ។

-ជីវិតមនុស្សមិនស្ថិតនៅក្រោមបញ្ជា និងការគ្រប់គ្រងរបស់មនុស្សឡើយ ។ ម្ចាស់ជីវិតគឺច្បាប់ធម្មជាតិ គឺការប្រែប្រួលផ្លាស់ប្ដូរជានិច្ច ពីក្មេងទៅចាស់-ជរា-ព្យាធិ-មរណៈ ជាធម្មតា ។

-ជីវិតគឺជាការដើរចោលគ្នាទៅវិញទៅមក តាដើរចោលចៅ ! ឪដើរចោលកូន ! ប្ដីដើរចោលប្រពន្ធ ! បងដើរចោលប្អូន ! ជាធម្មតា ! ជាធម្មជាតិ !

-ធម្មជាតិបង្កើតមនុស្សផង ចិញ្ចឹមមនុស្សផង សម្លាប់មនុស្សផង ។ *ឧទាហរណ៍* : ភ្នំភ្លើងផ្ទុះ ផែនដីរញ្ជួយ ទឹកជំនន់ ភាពរាំងស្ងួត ជម្ងឺដម្កាត់... ទាំងអស់នេះ គឺជាការគម្រាមកំហែង ដ៏ធ្ងន់ធ្ងរបំផុតពីធម្មជាតិ ។

-មនុស្សលំបាកនឹងរកពេលរស់ឱ្យបានសុខស្ងប់យូរអង្វែងណាស់ ។

-សេចក្ដីវិនាសមួយចំនួនធំ ក៏កើតមកពីស្នាដៃរបស់មនុស្ស ដោយមនុស្សខ្លួនឯង : បំផ្លាញបរិស្ថាន ព្រៃឈើ ជម្រកសត្វទាំងឡាយកាន់តែរេចរឹលទៅៗទន្លេបឹងបួរកាន់តែរីងស្ងួត ត្រីទឹកសាប ត្រីទឹកប្រៃ កាន់តែវិនាស

ទៅៗ ព្រោះតែកំណើនមនុស្សច្រើនឡើងៗ ។ ព្រោះតែការចិញ្ចឹមកាយការថែរក្សារូបឱ្យបានល្អតលាស់ធំធាត់ល្អ មនុស្សមិនញញើត នឹងបំផ្លាញអ្វីៗ ឡើយ !

## III-ធម្មជាតិខាងក្នុង : (ផ្លូវចិត្ត)

-ជម្ងឺផ្លូវចិត្តមានច្រើនប្រភេទណាស់ ។ មេរោគក៏ប្លែកៗ គ្នាដែរ ហើយមានគ្រោះថ្នាក់ជាងមេរោគផ្លូវកាយទៅទៀត ។

-ភ្លើងឆេះពីឧសណា រមែងកំទេចឧសនោះឱ្យទៅជាផេះ ។ ភ្លើងកើត ភ្លើងចាស់ ភ្លើងជរា ភ្លើងព្យាធិ មរណៈ កើតពីកាយ តែងដុតកាយឱ្យទៅជាផេះ ។

-ច្រេះកើតពីដែកណា តែងស៊ីដែកនោះ ឱ្យទៅជាផេះ ។

-កិលេសតណ្ហាកើតពីចិត្ត តែងដុតចិត្តឱ្យផុយរលួយទៅជាផេះ (កិលេស ១៥០០ តណ្ហា ១០៨) ។

-ភារៈជីវិតធ្ងន់ធ្ងរណាស់ :

- ធ្ងន់ព្រោះចង់រស់ រស់ល្អ រស់ប្រពៃ ។
- ធ្ងន់ព្រោះចង់រស់យូរ រស់លើសគេ ដែលនាំឱ្យមានការប្រកួតប្រជែងគ្នា ដណ្តើមគ្នា សម្លាប់គ្នា ព្រោះការពារខ្លះ ការពារក្រ ការពារល្ងង់ ការពារការបៀតបៀន ការប្រមាថមើលងាយពីខាងក្រៅ ។

-បំណងកាន់តែច្រើន ប្រាថ្នាកាន់តែក្រាស់ ។ ចំណង់កាន់តែកើន តណ្ហាកាន់តែខ្លាំង ។ ប្រណាំងប្រជែងកាន់តែស្រួចស្រាល់ សង្គ្រាមកាន់តែកើត ។ ជនភៀសខ្លួនចេះតែមាន ។ ភាពរំជើបរំជួល ភាពតានតឹង ភាពតក់ស្លុត

ភាពភ័យខ្លាចនៅតែមាន ។ ផលវិបាកទាំងនេះ កើតមកពីស្នាដៃរបស់មនុស្ស ខ្លួនឯង មកពីផ្លូវចិត្តរបស់មនុស្សគ្មានលំនឹង ឥតមានកិច្ចធានា រ៉ាប់រង-រស់នៅខ្វះគុណ ។

-ជម្ងឺផ្លូវកាយ បូកនឹងជម្ងឺផ្លូវចិត្ត ដូចព្រួញពីរបាញ់ត្រូវមុខរបួសតែមួយ ។ តើការឈឺចាប់ទ្វេឡើងប៉ុណ្ណា ?

-សភាពចិត្តទាំងនេះ ជាសត្រូវខាងក្នុងខ្លួនរបស់មនុស្ស ។

-សង្គ្រាមខាងក្នុងកើតឡើងរាល់នាទី រាល់ទីកន្លែង-ច្បាំងមិនងាយឈ្នះ-មិនងាយចាញ់-មិនងាយចប់ទេ ព្រោះសត្រូវខាងក្នុង ខ្លាំងណាស់ មានទ័ពច្រើនណាស់ ប្រសប់ប្រើល្បិចសង្គ្រាមណាស់ ។

-សត្វលោកទទួលបរាជ័យច្រើនណាស់ ដោយល្បិចលួងលោមបបោសអង្អែលរបស់សត្រូវខាងក្នុង ។

## IV-**លក្ខណៈពិសេសនៅអាស៊ី :**

-ទស្សនវិទូធំៗនៅអាស៊ី បានទូន្មានអប់រំមនុស្សឱ្យទៅជាសត្វឈ្នះ: ឈ្នះលើធម្មជាតិ ឈ្នះលើសង្គម ឈ្នះលើអាត្មាខ្លួន ។

-ស្គាល់ច្បាស់ក្រឹត្យក្រមកើតឡើង ស្ថិតស្ថេរ វិវត្តរីកចម្រើន និងសាបសូន្យទៅវិញនូវរាល់បាតុភូត និងវត្ថុក្នុងធម្មជាតិ ក្នុងសង្គម និងក្នុងសតិអារម្មណ៍របស់មនុស្ស ។

*ឧទាហរណ៍ :*

១-ក្រឹត្យក្រម ហេតុផល (cause et Effect)

២-កម្ម និងប្រតិកម្ម (Actions et Reactions)

៣-ឯកភាពក្នុងពហុភាព (L'unité dans la Diversité)

៤-ឯកភាពក្នុងភាពផ្ទុយគ្នា (L'unité des Contraires)

៥-ឯកភាពក្នុងភាពទំនាស់ (L'unité des Dualités)

-មនុស្សជាម្ចាស់ប្រវត្តិសាស្ត្រ នៅពេលដែលមនុស្សក្តាប់ក្រឹត្យក្រមបាន ប្រើប្រាស់ក្រឹតក្រម្យត្រូវក្នុងពេលកសាងប្រវត្តិសាស្ត្រ ។

-មនុស្សជាម្ចាស់សង្គម នៅពេលដែលមនុស្សក្តាប់ក្រឹត្យក្រមបាន ប្រើប្រាស់ក្រឹតក្រមត្រូវ ក្នុងពេលអភិវឌ្ឍសង្គម ។

-មនុស្សនឹងក្លាយជាផលិតផលប្រវត្តិសាស្ត្រ និងជាផលិតផលសង្គម នៅពេលដែលមនុស្សស្គាល់ក្រឹត្យក្រមមិនច្បាស់ និងប្រើក្រឹត្យក្រមមិនត្រូវ ។

-ការលួតលាស់ខ្វះស្មារតី នាំឱ្យបាត់តុល្យភាព រវាងសេចក្តីត្រូវការ និងការផ្គត់ផ្គង់ នាំឱ្យកើតវិបត្តិដែលជាហេតុនៃសេចក្តីវិនាស ។

-មនុស្សខ្វះបេះដូង សង្គមខ្វះមនសិការ គ្រប់គ្រងខ្វះយុត្តិធម៌ ខ្វះគតិធម៌ ខ្វះគុណធម៌ រស់នៅខ្វះសីលធម៌ ទំនាក់ទំនងខ្វះចរិយាធម៌ ខ្វះសមធម៌ ដឹកនាំខ្វះឧត្តមគតិ ខ្វះជំនឿ អត់សេចក្តីសង្ឃឹម សុទ្ធតែជាប្រធាននៃសេចក្តីវិនាស ។

*យុគសម័យថ្មី គឺយុគសម័យធម៌ និងវិន័យ ជាយុគសម័យ សណ្តាប់ធ្នាប់ក្នុង និងសណ្តាប់ធ្នាប់ក្រៅ (Ordre intérieur et extérieur) និងជាយុគសម័យ សន្តិភាព ក្នុង និងសន្តិភាពក្រៅ ។ តាមប្រពៃណីដូនតា*

*ចាស់ទុំ នៅអាស៊ី តែងខិតខំ អប់រំកូនចៅឱ្យខំប្រឹងធ្វើល្អ ចៀសវាងអំពើអាក្រក់* ។ ប្រឹងសំអាតចិត្តខ្លួន ដោយខ្លួនឯង ប្រឹងរស់នៅឱ្យបានស្អាត រៀបចំស្លាប់ទៅវិញក៏ឱ្យស្អាត ដើម្បីកើតមកវិញស្អាត ធ្វើឱ្យស្អាតបរិសុទ្ធកើតឡើងជាលំដាប់រៀងរាល់ម៉ោង រាល់ឆ្នាំ រាល់ជាតិ ។ ផលស្អាតព្រោះហេតុស្អាត ផលទៅជាហេតុ ហេតុទៅជាផល ។

-ខំប្រឹងធ្វើសង្គ្រាមនឹងខ្លួនឯង ស្វែងរកជ័យជំនះលើសត្រូវក្នុងខ្លួនឯង រកខ្លួនឯងឱ្យឃើញ មើលខ្លួនឯងឱ្យត្រង់ ហើយត្រូវម៉ឺងម៉ាត់តឹងរ៉ឹងនឹងខ្លួនឯងជាងអ្នកដទៃ ។

-ជ័យជំនះដែលឥតត្រឡប់ទៅបរាជ័យវិញនោះ គឺជាជ័យជំនះលើខ្លួនឯង ។

-ចិត្តថ្លាបរិសុទ្ធ អាចមើលឃើញបាតនៃចិត្ត ចិត្តថ្លាមន្ទិលសៅហ្មងគឺចិត្តឥតមានភាពល្អក់កករ ឥតមានភាពស្មោកគ្រោក : កញ្ចក់ល្អ ឆ្លុះបញ្ចាំងការពិតបានល្អ ។ គ្មានអ្វីស្មោកគ្រោក ជាងចិត្តអាក្រក់ ឡើយ ។

-អ្វីៗនៅលើលោកនេះ ផ្លាស់ប្តូរប្រែប្រួលរហ័សណាស់ ។

-ដង្ហើមចូលភ័យ ដង្ហើមចេញខ្លាច ព្រោះខ្លាចចេញហើយលែងចូលវិញ បញ្ចោមិនបាន ហាមមិនកើត ព្រោះយើងពុំមែនជាម្ចាស់ខ្យល់ ។

-ចិត្តស្រឡាញ់ ឬ ស្អប់ អរ ខឹង ភ័យ ខ្លាច គំនុំគុំកួន អួតអាងកើតរាល់ពេលក្នុងចិត្តខ្លួនឯងក៏ត្រួតមិនបាន ហាមមិនកើត ។ ដូច្នេះ ការឈានទៅបញ្ចោធម្មជាតិទាំងមូល គ្រប់គ្រងសង្គមទាំងស្រុង ធ្វើម្ចាស់លើចិត្ត

ខ្លួនឯងឱ្យបាន ជាការលំបាកណាស់ ។ ទាមទារពេលវេលាយូរអង្វែង និងការព្យាយាមដ៏ប្ដូរផ្ដាច់ ។ មិនគួរស្លន់ស្លោរពេកទេ តែក៏មិនគួរខ្ជិលច្រអូសពេកនោះដែរ ។ ព្រោះចិត្តជាអ្នកដឹង ឯកាយគ្រាន់តែជាដុំលុងមួយដុំប៉ុណ្ណោះ ។ កុសលកាយកម្ម ឬអកុសលកាយកម្ម ស្ថិតនៅក្រោមបញ្ជាចិត្តទាំងស្រុង ។

-ក្នុងច្របូកច្របល់ ធ្វើឱ្យក្រៅច្របូកច្របល់ ។

-សន្តិភាពផ្លូវចិត្តរបស់បុគ្គលម្នាក់ៗ នាំដល់សន្តិភាពពិភពលោក ។

-ស្មារតីយុត្តិធម៌ និងស្មារតីមេត្តាធម៌ នាំដល់ស្មារតីអហិង្សានិងស្មារតីវីភាគៈ ។

-ផ្លូវកណ្ដាល ផ្លូវសណ្ដោស (Modération) សណ្ដោសបញ្ចកាមគុណ សណ្ដោសបច្ច័យបួន ។ ផ្លូវសណ្ដោសនេះធ្វើឱ្យមនុស្សចេះល្មម ចេះស្កប់ស្កល់ បន្ថយចិត្តលោភលន់ ។

-សត្វលោកកើតពីកាម អាស្រ័យដោយកាម និងវត្ថុកាម ដើម្បីធំធាត់ ។ ពេលវត្ថុមានវិបត្តិ សង្គ្រាមកាមគុណក៏កើត ជម្ងឺសង្គមក៏កាន់តែច្រើនណាស់ដែរ ។

-ស្ដេចកាមប្រសប់កៀរគរមនុស្សលោកមកធ្វើទាសករកាម ដោយរីករាយ ដោយស្ម័គ្រចិត្ត ។

-លោភៈ ជាស្ដេចក្រ ធ្វើឱ្យមនុស្សមិនចេះមាន គឺនៅតែក្ររហូត ។

-ឧបសគ្គ ភាពតានតឹង ភាពស្មុគស្មាញ ភាពរំជើបរំជួល ការភ័យព្រួយ និងកង្វល់ទាំងឡាយរបស់មនុស្ស កើតមកពីបំណងទាំងឡាយ សេចក្ដី

ប្រាថ្នាទាំងឡាយ ចំណង់ទាំងឡាយរបស់មនុស្សមិនបានសម្រេច ។

-មូលហេតុនៃឃាតកម្ម និងអត្តឃាតកម្មរបស់មនុស្សមកពីមនុស្សច្បាំងចាញ់អសីលធម៌ខាងក្រៅ និងអសីលធម៌ខាងក្នុង ។

-សង្គមរៀបរយ ធ្វើឱ្យចិត្តគំនិតមនុស្សរៀបរយ ។

-សង្គមមានការធានារ៉ាប់រង ធ្វើឱ្យចិត្តគំនិតមនុស្សមានលំនឹង និងជីវិតរស់នៅមិនភ្ញាក់ផ្អើល ។

**យុគសម័យថ្មី :**

-យើងឱ្យឈ្មោះ *យុគសម័យថ្មី* នេះថាជា *យុគសម័យស្មារតី* ។

-យើងទាំងអស់គ្នាគួរនាំគ្នាពិចារណាពីស្មារតីរបស់សត្វលោក តើមានសុខភាពរឹងមាំ មានជម្ងឺអ្វីខ្លះ ព្យាបាលយ៉ាងណា ? មានថ្នាំអ្វីខ្លះ ? តើចំណីអាហារអ្វីខ្លះដែលនាំឱ្យស្មារតីមានសុខភាពល្អ ? តើការបណ្តុះបណ្តាលយ៉ាងណាដែលនាំឱ្យស្មារតីមានសុខភាពល្អ ?

## V-ការមកដល់នៃយុគសម័យស្មារតី និងអនាគតរបស់អាស៊ី :

ទឹកដីអាស៊ីបានឱ្យកំណើតដល់ទស្សនវិទូ និងអ្នកប្រាជ្ញជាច្រើន ។ មេលទ្ធិទាំងឡាយនោះ តែងឱ្យតម្លៃយ៉ាងខ្លាំងទៅលើថាមពលខាងស្មារតី ។ អ្នកទាំងនោះយល់ថា :

-គ្មានអ្វីកើតឡើង ហើយក៏គ្មានអ្វីរលត់ទៅវិញក្រៅពីហេតុ និងផលឡើយ ។

-យុគសម័យមុនៗ អ្នកទាំងនោះច្រើនតែសិក្សាអំពីទុក្ខ អំពីហេតុ

ដែលនាំឱ្យកើតទុក្ខ និងផ្លូវរំលត់ទុក្ខ ។

-រំដោះមនុស្សឱ្យរួចផុតពីការគំរាមកំហែងរបស់ធម្មជាតិ គឺជាតួនាទីរបស់អ្នកវិទ្យាសាស្ត្រ ។ រំដោះមនុស្សឱ្យរួចផុតពីភាពក្រីក្រ ខ្វះខាតបច្ច័យបួន ឬធ្វើកុំឱ្យមានគម្លាត រវាងក្រនិងមានខ្លាំងពេក ជាតួនាទីរបស់អ្នកសេដ្ឋកិច្ច។ រំដោះមនុស្សឱ្យផុតពីគម្លាតសង្គម ពីការជិះជាន់កេងប្រវ័ញ្ចរវាងមនុស្ស និងមនុស្ស គឺជាតួនាទី របស់អ្នកនយោបាយ ។ រំដោះមនុស្សឱ្យផុតពីកញ្ចះតណ្ហា គឺជាតួនាទីរបស់អ្នកធ្វើការងារខាងវប្បធម៌ស្មារតីទាំងឡាយ គឺធ្វើឱ្យជីវិតរស់នៅមានតុល្យភាពរវាងជីវភាពសម្ភារៈ និងជីវភាពស្មាតី-រស់នៅសមរម្យ ថ្លៃថ្នូរ-រស់នៅដោយគ្មានពហុចិត្ត (Complexe) រស់នៅដោយគ្មានឧបាទាន (Sans Obsession) រស់នៅដោយ គ្មានឆ្មើងឆ្មៃ និងអំនួត (Sans l'orgueil et Vanité) ។

-ប្រាថ្នាចង់បានជីវិតមួយសប្បាយរីករាយ ស្កប់ស្កល់ សុខស្ងប់សន្តិភាព ស្អាតបរិសុទ្ធ (Paix, Tranguilité, Sérénité, Purité) ។

-ជាជីវិតមួយពោរពេញដោយចិត្តសណ្តោស និងក្តីមេត្តា ។

*អ្វីៗដែលបានសរសេរនេះ គ្រាន់តែជាគំនិតក្នុងពិភពគំនិតប៉ុណ្ណោះ។ ធម៌ទាំងឡាយគ្រាន់តែជាធម៌ប៉ុណ្ណោះ ។*

# សីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន
# ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស

(ត)

ឆយ យីហាង
(បណ្ឌិត ឧស្សាហ៍នវិជ្ជា)

គ្រូបង្រៀនត្រូវមានតួនាទីជាច្រើនដូចខាងក្រោម ÷

**ក‸ តួនាទីជាមាតាបិតា**

គ្រូបង្រៀនត្រូវចាត់ទុកសិស្ស និងនិស្សិតជាកូនរបស់ខ្លួន។ បើនរណាម្នាក់ ឥតស្រឡាញ់សិស្ស និងនិស្សិតជាកូនទេ អ្នកនោះមិនអាចធ្វើជាគ្រូបង្រៀនបាន ឡើយ។ ប៉ុន្តែ ប្រសិនបើគេនៅតែធ្វើជាគ្រូបង្រៀន ដោយមិនស្រឡាញ់សិស្ស និស្សិត គេនឹងមានអារម្មណ៍ធុញថប់ចំពោះមុខរបរនេះ។ ផ្តើមចេញពីសេចក្តី ស្រឡាញ់សិស្ស និស្សិត គ្រូបង្រៀនតែងមានសេចក្តីអាណិតអាសូរ និងមានការអត់ ឱនជារឿយៗ ចំពោះកំហុសឆ្គងតិចតួចដែលសិស្ស និស្សិតបានប្រព្រឹត្ត។ សេចក្តី ស្និទ្ធស្នាលក្នុងឋានៈជាឪពុកម្តាយ និងជាកូននោះ ត្រូវស្ថិតនៅក្នុងរង្វង់នៃការគោរព គ្នាទៅវិញទៅមក។ ហេតុនេះ គ្រូបង្រៀនត្រូវបានសិស្ស និស្សិតមានទំនុកចិត្ត និង គោរពស្រឡាញ់វិញ។ តើគ្រូបង្រៀនមានមោទនភាពប៉ុណ្ណា នៅពេលដែលសិស្ស ចាត់ទុកខ្លួនជាឪពុកម្តាយរបស់គេ ? តើគ្រូបង្រៀនអាប់ឱនបែបណា នៅពេលដែល សិស្សចាត់ទុកខ្លួនជាសត្រូវរបស់គេ ?

### ខ. តួនាទីជាមិត្តភក្តិ

ក្នុងលំហ និងកាលមួយចំនួន ដូចជាក្នុងពេលដើរកំសាន្តជាដើម គ្រូត្រូវចាត់ទុកខ្លួនជាមិត្តជិតស្និទ្ធរបស់សិស្ស និស្សិត។ និយាយបែបនេះ ពុំមែនមានន័យថា គ្រូបង្រៀនបន្ទាបបន្ថោកខ្លួនទេ តែមានន័យថា គេលើកតម្កើងខ្លួនគេ ហើយត្រូវបានសិស្ស និស្សិតកាន់តែគោរពស្រឡាញ់ឡើង។

ឧទាហរណ៍ : ក្នុងពិធីបុណ្យចូលឆ្នាំថ្មី មានលោកគ្រូ អ្នកគ្រូខ្លះលេងល្បែងប្រជាប្រិយជាមួយសិស្ស ដូចជា ចោលឈូង បោះអង្គុញ ចាប់កូនខ្លែង ...ជាដើម។

នៅឆ្នាំ ១៩៩៩ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី នៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល II លោកសាស្ត្រាចារ្យ **អង់តូនីញ៉ូស វិឌីយ៉ាសូណូ** (Antonius Widyarsono) ជនជាតិឥណ្ឌូនេស៊ី បានសុំលេងល្បែងជាមួយនិស្សិត ដូចជា ហ៊ូបប៉ិតក់ប្រណាំងគ្នា ឬច្រកខ្លួនក្នុងបាវរត់ប្រណាំងគ្នាជាដើម។ ការណ៍នេះធ្វើឱ្យនិស្សិតសង្គមវិជ្ជា ទស្សនវិជ្ជា និងប្រវត្តិវិទ្យារឹតតែគោរពស្រឡាញ់គាត់ឡើង។ ការប្រកាន់ឫកពាថ្លៃថ្នូរពេក តែងនាំទៅដល់ការឆ្មើងកន្ត្រើង ដែលធ្វើឱ្យសិស្ស និស្សិតខ្លាច តែខ្លាចក្នុងការពេបជ្រាយទៅវិញ។

### គ. តួនាទីជាមគ្គុទេសក៍ និងទីប្រឹក្សា

សភាពជាមគ្គុទេសក៍នៃគ្រូបង្រៀន ជាកត្តាចាំបាច់បំផុត។ កត្តានេះតម្រូវឱ្យគ្រូបង្រៀនមិនមែនជាមនុស្សព្រហើន (téméraire) និងមិនមែនជាមនុស្សកំសាក (timide) តែជាមនុស្សក្លាហាន (courageux) ។ មនុស្សព្រហើន ជាមនុស្ស

រឹងត្អឹង ក្លាហានហួសហេតុ។ មនុស្សកំសាកជាមនុស្សស្ទក់ ខ្លបខ្លាច មិនអាចសម្រេចការងារអ្វីមួយ។ មនុស្សក្លាហាន ជាមនុស្សដែលហ៊ានដើរទៅមុខ និងចេះដកជំហានថយក្រោយ ចេះថ្លឹងថ្លែងសភាពការណ៍គួរឱ្យកក់ក្ដៅបំផុត។ កំសាក និងព្រហើនជាកត្តាដែលត្រូវជៀសវាង។ សម្ព័ន្ធកាយវិទ្ធក្នុងពិភពលោក ជាឧទាហរណ៍ គឺជាសម្ព័ន្ធដែលបង្ហាត់មនុស្សឱ្យមានសេចក្ដីក្លាហាន។ បើតាម **អារីស្តូត** (Aristotle) គំនូសបំព្រួញស្ដីពីសេចក្ដីក្លាហាន មានដូចខាងក្រោម ÷

**គំនូសបំព្រួញទី៣**




ក្នុងឋានៈជាមគ្គុទេសក៍ មិនត្រូវឃ្លាតឆ្ងាយពីមហាជនទេ។ អ្នកដឹកនាំជាអ្នកបំភ្លឺផ្លូវ ឯមហាជនជាកត្តាកំណត់បំផុត ដែលធ្វើឱ្យអ្នកដឹកនាំឈានឡើង។ អភិបាលកិច្ចល្អ តម្លាភាព សេចក្ដីស្មោះត្រង់ ... ជាវិធីដ៏ល្អសម្រាប់អ្នកដឹកនាំ។ **អាយ ជីញ** (I Ching) បានសរសេរថា *"សេចក្ដីស្មោះត្រង់ផ្ដល់ជោគជ័យ និងផលប្រយោជន៍ជាច្រើន ប្រសិនបើអនុវត្តឱ្យបានត្រឹមត្រូវ។ ប្រសិនបើអ្នកបដិសេធអ្វីដែលត្រូវ អ្នកពិតជាខុស ហើយអ្នកឥតបានទទួលផលប្រយោជន៍ពីគ្រប់ទីកន្លែងទោះទៅដល់ទីណាក៏ដោយ"* *(Fidelity is very successful, beneficial if correct. If you deny what is right, you are mistaken and will not*

*benefit from going anywhere.)*(១) ។ បើមន្ត្រីទេសក៍ ឬអ្នកដឹកនាំមានសេចក្ដីស្មោះត្រង់ មន្ត្រីទេសក៍នោះត្រូវបានមហាជនគោរពស្រឡាញ់វិញ។ នៅពេលដែលមហាជនគោរពស្រឡាញ់ហើយ ការងារទាំងឡាយនឹងអាចសម្រេចបាន ទោះការងារនោះលំបាកស្មុគស្មាញយ៉ាងណាក៏ដោយ។ **អាយ ជិញ** (I Ching) បានបន្ថែមទៀតថា *"នៅក្នុងសេចក្ដីស្មោះត្រង់ កម្លាំងដែលមកពីក្រៅបានក្លាយជាចំណុចដឹកនាំនៅខាងក្នុង។ កម្លាំងដ៏ស្វាហាប់ សកម្ម និងរឹងមាំ ពោរពេញដោយតុល្យភាព និងការឆ្លើយតបដែលចូលមកជំនួសបន្តបន្ទាប់ក្នុងផ្លូវត្រូវ គឺជាបញ្ហារបស់ធម្មជាតិ"* *(In fidelity, strength comes from outside and becomes the guiding focus within. Being active and robust, firm strength balanced and responsive, succeeding greatly in the right way is the order of Nature. If you deny what is right, you are mistaken and will not benefit from going anywhere.)*(២) ។

អ្នកដឹកនាំត្រូវអប់រំចិត្តគំនិតឱ្យបានប្រកបដោយគុណធម៌ខ្ពស់ និងឧត្តមគតិជឿនលឿន ដើម្បីឱ្យមហាជនមានជំនឿទុកចិត្ត។ *"ព្រះភិរុណាវមែងស្រក់ចូលក្នុងគេហដ្ឋានដែលមានដំបូលប្រក់មិនបានល្អ ; យ៉ាងណាមិញ ការបែកបាក់ អំពើពុករលួយ និងសង្គ្រាមវិនាសកម្ម ក៏រមែងជ្រាបចូលទៅក្នុងចិត្តគំនិតរបស់អ្នកដឹកនាំ ឬអ្នកតំណាងដែលពុំបានអប់រំចិត្តគំនិតខ្លួនឱ្យប្រកបដោយគុណធម៌ខ្ពស់ និងឧត្តមគតិជឿនលឿនដូច្នោះដែរ"*(៣) ។ អ្នកដឹកនាំ គប្បីរក្សាបុគ្គលិកលក្ខណៈរបស់ខ្លួនឱ្យ

---

១ I Ching, *The book of Change,* translated by Thomas Clearly, Shambhala, Boston and London, 1992, page 54.

២ I Ching, Ibid, page 54.

៣ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម. *ព្រឹត្តិប័ត្រស្រាវជ្រាវ ឆ្នាំទី២ លេខ០២៣.* ភ្នំពេញ. ខែសីហា ១៩៩៦. ទំព័រ១២

បានល្អ ពោលគឺមិនធ្វើឱ្យកាយវិការរបស់ខ្លួនឥតរបបឥតរបៀបឡើយ ប្រសិនបើចង់ឱ្យមហាជន ដូចជាសិស្សានុសិស្សជឿជាក់។

### ឃ‿ គ្រូនាធិជាអ្នកស្រាវជ្រាវ អ្នកបង្កើត និងអ្នកផ្តល់ទស្សនវិស័យ

គ្រូបង្រៀន ជាអ្នកស្រាវជ្រាវ។ គ្រូបង្រៀនតែងចាត់ទុកថា ខ្លួនជាមនុស្សល្ងង់ ហើយដឹងច្បាស់ថា ខ្លួនជាមនុស្សឥតចេះនូវចំណុចជាច្រើន។ ជូនកាលគ្រូបង្រៀនចាត់ទុកខ្លួនឯង ជាប្រធានបទល្អមួយសម្រាប់បង្រៀន។ **សូក្រាត** (Socrates) បានពោលថា *"ខ្ញុំដឹងច្បាស់ថាខ្ញុំឥតចេះអ្វីសោះ" (I know well that I do not know anything)*។ ជីវិតជាពិសេស ជីវិតទំនើបក្នុងសម័យសាកលភាវូបនីយកម្មនេះមានលក្ខណៈស្មុគស្មាញណាស់។ ជីវិតបែបនេះកំពុងជំរុញឱ្យមនុស្សរត់តាមកម្លាំងសម្ភារៈ ដោយបោះបង់ចោលជាបណ្តើរៗ នូវកម្លាំងសីលធម៌។ នោះហើយជាការលំបាកស្មុគស្មាញក្នុងការស្វែងយល់។

គ្រូបង្រៀន ជាអ្នកបង្កើតស្នាដៃ និងជាអ្នកជំរុញឱ្យអ្នកដទៃក្លាយជាអ្នកបង្កើតស្នាដៃដែរ។ **អឺរល៍ វី ពុលីយ៉ាស់** និង **ជែម ឌី យ៉ង់** (Earl V. Pullias and James D. Young) បានសរសេរថា *" ដំណើរកសាងស្ថិតនៅលើការងារគ្រប់ទីកន្លែងក្នុងពិភពជីវិតរស់នៅ។ យើងអាចមើលឃើញដំណើរកសាងនៃធម្មជាតិក្នុងការរីកដុះដាលនៃរុក្ខជាតិ និងក្នុងសកម្មភាពនៃសត្វ។ នៅមានការកសាងមួយទៀត ដែលស្ថិតនៅក្នុងខ្យល់ និងក្នុងភ្លៀងដែលចោះថ្ម និងចោះភ្នំ។ មនុស្សរួមចំណែកនៅក្នុងនោះ និងក្នុងទិដ្ឋភាពផ្សេងទៀតនៃដំណើរកសាង" (The creative process is at work everywhere in the living world. We can see the creative process of nature in the growth of plants and the*

*activities of animals. Also, there is a kind of creativity in the wind and the rain that shape the rocks and hills. Man shares in these and other aspects of the creative process.)*[៤] ។

សកម្មភាពរបស់ខ្យល់ និងភ្លៀង ជាសកម្មភាពមេកានិចងងឹតងងល់។ សកម្មភាពរបស់សត្វ ជាសកម្មភាពដែលកើតឡើងដោយសភាវគតិ។ រីឯសកម្មភាពរបស់មនុស្ស ជាសកម្មភាពដែលកើតឡើងដោយញាណ ដែលក្នុងនោះមានសុឆន្ទៈ និងការពិចារណាផងដែរ។ ហេតុនេះ សកម្មភាពរបស់មនុស្សមិនមានលក្ខណៈងងឹតងងល់ ដូចសកម្មភាពរបស់ខ្យល់ និងភ្លៀងទេ ហើយក៏មិនផ្អែកលើសភាវគតិដូចសកម្មភាពសត្វដែរ។ ប៉ុន្តែ ទោះបីសកម្មភាពរបស់មនុស្សខ្ពស់យ៉ាងណាក៏ដោយ ក៏ត្រូវបែងចែកថា មនុស្សខ្លះមានញាណខ្មៅក្រខ្វក់ និងខ្លះទៀតមានញាណល្អប្រពៃ។ បើមនុស្សមានញាណខ្មៅក្រខ្វក់ ឬអសីលញាណ សកម្មភាពរបស់គេមានលក្ខណៈព្រៃផ្សៃឥតព្រំដែន។ បើមនុស្សមានញាណល្អប្រពៃ ឬសីលញាណ គេជាវិស្វករព្រលឹងជាតិ។

---

៤ Earl V. Pullias and James D. Young, *A teacher is many things,* Indiana University Press, the United States of America,1968, page 75.

## គំនូសបំព្រួញទី៤

**ដេការត** (Descartes) យល់ថា មនុស្សមានលក្ខណៈដូចខាងក្រោម ÷




**អឺរល៍ វី ពុលីយ៉ាស់** និង **ជែម ឌី យ៉ង់** (Earl V. Pullias and James D. Young) បានគូសបញ្ជាក់បន្ថែមថា *"ការកសាងវត្ថុផ្សេងៗ របស់មនុស្សមានលក្ខណៈល្អប្រសើរជាងច្រើនណាស់ បើប្រៀបធៀបនឹងសកម្មភាពរបស់សត្វ ដោយមនុស្សបានធ្វើសំណង់ ឧបករណ៍ល្បែងផ្លូវថ្នល់ និងរបកគំហើញ។ រីឯអំណាចកសាង នៅក្នុងវិស័យចិត្តគំនិតរបស់មនុស្សស្ទើរតែមិនគួរឱ្យជឿបាន ហើយមានលក្ខណៈសាមញ្ញតាំងពីពេលចាប់ផ្ដើម ដូចជាអក្សរសិល្ប៍ សិល្បៈ តន្ត្រី ទស្សនវិជ្ជា ច្បាប់ និងវិទ្យាសាស្ត្រជាដើម។ អ្វីៗទាំងអស់នេះ ផ្អែកលើការកសាងដ៏ធំធេង នៃអ្វីដែលស្ថិតនៅក្នុងវិស័យចិត្តគំនិត : នោះគឺភាសា"* *(His making of physical things has been greatly extended beyond animal activity, as seen in buildings, tools, games, roads, inventions. The creativity in the mental area has been almost unbelievable and perhaps is merely in*

*its beginning: literature, art, music, philosophy, law, science. These all depend on the greatest creation of all in the mental area: language.)*[៥] ។

គ្រូបង្រៀន ជាអ្នកផ្តល់ទស្សនវិស័យដល់សិស្ស ធ្វើឱ្យសិស្សមើលឃើញពីអតីតកាលរបស់មនុស្សជាតិ មើលឃើញសកម្មភាពក្នុងបច្ចុប្បន្នកាល និងចេះប្រមើលទៅដល់អនាគតកាល ។ អ្វីដែលមាននៅក្នុងបច្ចុប្បន្នកាល អាចជះឥទ្ធិលទៅដល់អនាគតកាល ។ បើមើលឃើញបែបនេះ សិស្សអាចជ្រើសរើសផ្លូវមួយសម្រាប់ដើរ សម្រាប់កសាងអនាគតរបស់ខ្លួន ។ **អឺរល៍ វី ពុលីយ៉ាស់** និង **ជែម ឌី យ៉ង់** (Earl V. Pullias and James D. Young) បានបញ្ជាក់ថា *"គ្រូធានាផ្តល់ទស្សនវិស័យទូលំទូលាយដល់សិស្ស ។ គ្រូយល់ថា សក្តានុពលនានារបស់សិស្សត្រូវបានចាត់ទុកជាមនុស្ស ។ គ្រូជឿជាក់លើលទ្ធភាពជាច្រើននៃសម្ភារៈមនុស្សដែលគេកំពុងធ្វើការជាមួយ ។ គេគិតថា ការបង្រៀនយ៉ាងល្អនោះ ជាសំខាន់ គឺជាការគូសវាស ការធ្វើឱ្យសម្រេច និងអភិវឌ្ឍន៍នូវអ្វីដែលស្ថិតនៅ ក្នុងអ្នកសិក្សា"* *(The teacher provides a vision of greatness for his students. He sees their varied potential as human beings. He believes in the great possibilities of this human material with which he works. He is inspired by the thought that teaching at its best has always been mainly the drawing out, releasing, and development of that which is in the learner)*[៦] ។

ម្យ៉ាងទៀត គ្រូជាអ្នកធ្វើឱ្យសិស្សមើលឃើញខ្លួនថា ជាអនាគតពលរដ្ឋដ៏រឹងមាំសម្រាប់ប្រទេសជាតិ ។ **សាពួរ រ៉ាសិច** (Shapour Rassekh) យល់ថា

---

៥ Earl V. Pullias and James D. Young, Ibid, page 75.

៦ Earl V. Pullias and James D. Young, Ibid, page 85.

ការអប់រំត្រូវ *"បណ្តុះបណ្តាលពលរដ្ឋរឹងមាំ មានទំនួលខុសត្រូវ មានចិត្តទូលំទូលាយ ចំពោះវប្បធម៌ផ្សេងៗ មានសមត្ថភាពលើកតម្កើងតម្លៃសេរីភាព គោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស និងគោរពអ្នកដែលមានចិត្តគំនិតមិនដូចខ្លួន និងអាចបាន់ស្មានអំពីជម្លោះ និងចេះដោះស្រាយជម្លោះនោះ តាមមាគ៌ាអហិង្សា" (Former un citoyen solidaire et responsable qui présente une ouverture sur les autres cultures, capable d'apprécier la valeur de la liberté, respectueux de la dignité humaine et des differences, et capable de prévenir les conflits ou de les résoudre par des voies non-violentes)*[៧] ។

## ខ‐ តួនាទីជាសិល្បករ

គ្រូបង្រៀនត្រូវយល់ច្បាស់អំពីពាក្យ វិធីសាស្ត្រ (methodology) វិធី (method) និងល្បិច (procedure) ។ គេត្រូវសិក្សាគ្រប់វិធីនានា និងធ្វើឱ្យវិធីដែលត្រូវប្រើប្រាស់បានសម្រេច។ ប៉ុន្តែ ដើម្បីធ្វើឱ្យវិធីបានសម្រេច លុះត្រាតែគ្រូបង្រៀនមានល្បិចប៉ិនប្រសប់ជាច្រើន ហើយប្រើវាសមស្របតាមលំហ និងកាលដែលគួរប្រើ។ ហេតុនេះ គ្រូបង្រៀនទោះតិច ឬច្រើន ត្រូវចេះគរុកោសល្យ និងចិត្តវិទ្យា។ មិនមែនសម្រាប់តែការបង្រៀនទេ ដែលគ្រូត្រូវការគរុកោសល្យ និងចិត្តវិទ្យានោះ។ ប៉ុន្តែ គ្រូត្រូវការមុខវិជ្ជានេះសម្រាប់ទាក់ទងជាមួយសមាជិកគ្រួសារ ឬជាមួយសង្គមទាំងមូល។

ការនិយាយរឿងផ្សេងៗ ដែលពាក់ព័ន្ធនឹងមេរៀនប្រកបដោយកាយវិការ

---

៧ Shapour Rassekh, *Éducation et Culture de la Paix*, IBE data, UNESCO, 1996, page 13-14.

ដ៏ប៉ិនប្រសប់ អាចចេះរាំ អាចចេះច្រៀង និងនាំឱ្យសិស្ស និស្សិតច្រៀងរាំកំសាន្តជាប្រការចាំបាច់ ដែលបង្ហាញថា គ្រូជាសិល្បករ។

មនុស្សពូកែនិយាយរឿងយល់ច្បាស់ អំពីការប្រើប្រាស់សម្លេងរបស់ខ្លួនឱ្យបានល្អ ថាតើពេលណាត្រូវនិយាយញាប់ ពេលណាត្រូវនិយាយយឺត ពេលណាត្រូវនិយាយខ្លាំង ពេលណាត្រូវនិយាយតិច។ គេយល់ផងដែរថា តើត្រូវមើលអ្នកស្តាប់យ៉ាងដូចម្តេច។ គេសម្លឹងមើលភ្នែកអ្នកស្តាប់ ហើយយល់ថា អ្នកស្តាប់កំពុងគិតអ្វី។ គេត្រូវយល់ពីអ្វីដែលអ្នកស្តាប់មានប្រតិកម្មតបវិញ។ ដើម្បីបំពេញសេចក្តីត្រូវការនៃការសម្តែង គ្រូបង្រៀនត្រូវពិនិត្យ និងពិចារណាឡើងវិញអំពីការប៉ិនប្រសប់ផ្ទាល់ខ្លួន កែលំអចំណុចខ្សោយរបស់ខ្លួន ធ្វើឱ្យទិដ្ឋភាពផ្សេងៗនៃការសម្តែងរបស់ខ្លួនមានលក្ខណៈសុក្រឹតថែមទៀត។

## ច‐ តួនាទីជាអ្នកវាយតម្លៃ

ការវាយតម្លៃអាចជាទិដ្ឋភាពស្មុគស្មាញបំផុតនៃដំណើរបង្រៀន ព្រោះវាទាក់ទងនឹងអ្វីៗច្រើនបែបច្រើនយ៉ាង។ ថ្វីបើគ្រូមិនអាចវាយតម្លៃបានល្អទាំងស្រុងក៏ដោយ ក៏គេត្រូវតែវាយតម្លៃជាបន្តបន្ទាប់ យោលតាមប្រតិកម្ម ដែលសិស្សនិស្សិតបានប្រព្រឹត្តនៅក្នុងស្ថានភាពសិក្សា។ គ្រូអាចវិនិច្ឆ័យខុសអំពីអ្វីដែលសិស្ស និស្សិតមានប្រតិកម្ម ដោយសារគេវាយតម្លៃភ្លាមៗ ចំពោះប្រតិកម្មរបស់សិស្ស និស្សិត។

នៅក្នុងការវាយតម្លៃ គ្រូត្រូវស្គាល់សិស្ស និស្សិតនៅក្នុងទំនាក់ទំនងជាមួយអ្នកជិតខាង ត្រូវស្គាល់តួនាទីរបស់គេក្នុងផ្ទះ ក្នុងសហគមន៍ និងក្នុងគ្រឹះស្ថានសិក្សា។ គ្រូត្រូវតែយល់អំពីអ្វីៗ ដែលជះឥទ្ធិពលដល់ការងាររបស់សិស្ស និស្សិត។ ចំណែក

សិស្ស និស្សិតវិញ ពួកគេក៏ចង់ដឹងពីអ្វីដែលគ្រូគិតចំពោះខ្លួនវិញដែរ ។

គោលបំណងរបស់គ្រូមិនមែនដើម្បីវាយតម្លៃសិស្សទេ។ គោលបំណងរបស់គ្រូ គឺការបំពេញការងារយ៉ាងប្រុងប្រយ័ត្ន ដោយធ្វើឱ្យសិស្ស និស្សិតក្លាហាន ជួយពន្យល់ ជួយណែនាំ លើកសរសើរចំណុចខ្លាំង និងទូន្មានឱ្យសិស្ស និស្សិតជំរុះចោលចំណុចខ្សោយ ...។ ប៉ុន្តែ គ្រូត្រូវតែខិតខំវាយតម្លៃសិស្ស និស្សិតដោយគ្មានគតិលំអៀង ដោយផ្អែកលើទស្សនៈគ្រប់ជ្រុងជ្រោយ គឺ ÷

- ពិនិត្យមើលអតីតកាលរបស់សិស្ស និស្សិត
- ពិនិត្យមើលបច្ចុប្បន្នកាលរបស់សិស្ស និស្សិត
- ពិនិត្យមើលការសេពគប់របស់សិស្ស និស្សិត
- ពិនិត្យមើលស្ថានភាពគ្រួសាររបស់សិស្ស និស្សិត
- ពិនិត្យមើលឥរិយាបថរបស់សិស្ស និស្សិត
- ពិនិត្យមើលចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្ស និស្សិត
- ...ល...។

ចូរចងចាំថា ការវាយតម្លៃដោយគតិលំអៀង ដោយសញ្ចេតនាស្អប់ខ្ពើម អាចធ្វើឱ្យសិស្សខូចអនាគតរបស់ខ្លួន។ ឯពិន្ទុដែលគ្រូវាយតម្លៃចែកចេញជាពីរបែប : ពិន្ទុជាលេខ និងពិន្ទុជាអក្សរ។ គឺពិន្ទុជាអក្សរដែលដាក់លើកិរិយាមាយាទនោះហើយ ដែលអាចធ្វើខូចអនាគតសិស្ស និស្សិត ប្រសិនបើគ្រូមានគំនិតលំអៀងក្នុងការវាយតម្លៃ។

ជាសេចក្តីសង្ខេប យើងឃើញថា គ្រូបង្រៀនមានតួនាទីជាច្រើនក្នុងទំនាក់ទំនងជាមួយសិស្ស។ ការដើរតួនាទីបែបនេះ ជាតម្រូវការចាំបាច់ ព្រោះគ្រូជាអ្នក

រួមចំណែកយ៉ាងសកម្មបំផុតក្នុងការបណ្តុះបណ្តាលសារជាតិ របស់មនុស្ស។ សំនួរសំខាន់បំផុត គឺសំនួរស្តីពីធម្មជាតិរបស់មនុស្ស។ **លេសលី ស្ទីវិនសុន** (Leslie Stevenson) បានសរសេរថា " *ន័យ និងគោលបំណងនៃជីវិតមនុស្ស អ្វីដែលយើងគួរធ្វើ និងអ្វីដែលយើងអាចសង្ឃឹមថាសម្រេចបាន - អ្វីៗទាំងអស់នោះត្រូវផ្សារភ្ជាប់ដោយអ្វីដែលយើងគិតថាជាធម្មជាតិ "ពិត" ឬធម្មជាតិ "សច្ចៈ" របស់មនុស្ស" (The meaning and purpose of human life, what we ought to do, and what we can hope to achieve – all these are fundamentally affected by whatever we think is the "real" or "true" nature of man.)*[៨] ។

ដើម្បីរក្សាឋានៈមនុស្សឱ្យនៅតែជាមនុស្ស មនុស្សពឹងផ្អែកជាច្រើនលើមុខរបរគ្រូបង្រៀន។ ការណ៍នេះ បញ្ជាក់ច្បាស់ថា "*ល្មមសង្គមយល់ហើយអំពីសារៈសំខាន់ដែលគ្មានអ្វីប្រៀបនឹងមុខរបរនេះ*" ព្រោះអ្នកនយោបាយសេដ្ឋវិទូ អ្នកវិទ្យាសាស្ត្រ បណ្ឌិត អ្នកប្រាជ្ញ ... សុទ្ធសឹងចាប់ប្រភពពីការច្នៃប្រឌិតនៃគ្រូបង្រៀន។

**គំនូសព្រាងទី ៥**

**តួនាទីរបស់គ្រូបង្រៀន ក្នុងទំនាក់ទំនងជាមួយ សិស្ស និស្សិត**

- ❶ មាតាបិតា
- ❷ មិត្តភក្តិ
- ❸ មគ្គុទេសក៍ និងទីប្រឹក្សា
- ❹ អ្នកស្រាវជ្រាវអ្នកបង្កើត និងអ្នកផ្តល់ទស្សនវិស័យ
- ❺ សិល្បករ
- ❻ អ្នកវាយតម្លៃ

→ **មានឋានៈជាវិស្វករព្រលឹងជាតិ**

---

៨ Leslie Stevenson, *Seven theories of human nature,* Second edition, Oxford University Press, 1987, page 3.

# ការរីកចម្រើននៃព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ

(ត)

ដោយ : **បណ្ឌិត ខួត ធីតា**

## ៣-ព្រះពុទ្ធសាសនា និងច្បាប់រដ្ឋធម្មនុញ្ញ

មាត្រា ៨ នៃច្បាប់រដ្ឋធម្មនុញ្ញបានថ្លែងថា: "ព្រះពុទ្ធសាសនា សាសនារបស់រដ្ឋ"[១] ។ សម្តេចព្រះឧបយុវរាជ កាលព្រះអង្គទ្រង់ជាព្រះមហាក្សត្រិយ៍ប្រទេសកម្ពុជា ទ្រង់ជ្រាបច្បាស់នូវសន្តានចិត្ត ជនជាតិខ្មែរបានជាទ្រង់ប្រកាសក្នុងមាត្រា ៨ ខាងលើនេះថា: ព្រះពុទ្ធសាសនា ជាសាសនា នៃជនជាតិខ្មែរទាំងមូល ជាសាសនាផ្លូវការពេញលក្ខណៈ ជាសាសនាស្របទៅតាម លទ្ធិប្រជាធិបតេយ្យ ។

លទ្ធិប្រជាធិបតេយ្យ ជាលទ្ធិស្ថាបនានូវរដ្ឋាភិបាលរាស្ត្រ ដោយឆន្ទៈប្រជារាស្ត្រ ដើម្បីប្រយោជន៍ប្រជារាស្ត្រ មានបំណងចង់បំបាត់នូវសេចក្តីលំបាកវេទនាប្រជារាស្ត្រ តស៊ូដើម្បីអនាគត ប្រជារាស្ត្រ ដោយយកសមភាព សេរីភាព ភាតរភាព សម្បូណ៌ភាព វឌ្ឍនភាព ជាមូលដ្ឋាននៃការប្រតិបត្តិ ។ លទ្ធិប្រជាធិបតេយ្យ ជាច្បាប់របស់រដ្ឋខាងអាណាចក្រ ចម្រើនពេញលេញបំណងទៅកាន់វឌ្ឍនភាព ដោយជឿជាក់ថា សេចក្តីព្យាយាមរបស់មនុស្សក្នុងកិច្ចការទាំងឡាយ ដោយយកយុត្តិធម៌ជាមូលដ្ឋាន ឬផលប្រយោជន៍រាស្ត្រជាវត្ថុបំណង មុខជានឹងបានសម្រេចនូវលទ្ធផលដ៏ប្រសើរមិនខាន ។ ចំណែកឯព្រះពុទ្ធសាសនា ជាលទ្ធិរចនាបុគ្គល ឱ្យចម្រើនខាង

---

១- រ៉ាយប៊ុក ព្រះពុទ្ធសាសនា នៃប្រទេសកម្ពុជាភ្នំពេញ ១៩៥៧ ទំព័រ ១៧-៧៩

សីលធម៌ គុណធម៌ លះបង់នូវ បាបធម៌ គ្រប់យ៉ាង ដើម្បីបំបាត់នូវទុក្ខលំបាកវេទនា ដូចលទ្ធិប្រជាធិបតេយ្យដែរ ប៉ុន្តែសំដៅទៅលើមោក្ខធម៌ច្រើនជាង (ចំពោះខន្ធប្រាំ ឱ្យផុតជាតិ ជរា ព្យាធិ មរណៈដើម្បីព្រះនិព្វាន )។ បើដូច្នេះ ព្រះពុទ្ធសាសនា មិនសំដៅយកសុខ ចំពោះខ្លួនឬ ? (មានន័យថា ខ្លួនជាអ្នកខិតខំកសាងខ្លួនជា អ្នកទទួល) ។

ព្រះពុទ្ធសាសនាទូន្មានប្រដៅថា : ត្រូវរកសុខចំពោះខ្លួន ឱ្យឃើញសិន ទើបរកសុខជូនអ្នកដ៏ទៃបាន ។ ម្យ៉ាងវិញទៀតព្រះធម៌ ព្រះពុទ្ធក្នុងន័យថា: យើង គប្បីរំដោះខ្លួន ឱ្យផុតពីសេចក្ដីវាយមាយទាំងនេះ ប្រសិនបើយើងចង់សោយ បរមសុខ ។ កាលណាយើងធ្វើឱ្យចិត្តរបស់យើងរីកចម្រើនតាមរយៈភាវនា យើងទប់ ស្កាត់បានអារម្មណ៍ វាយមាយ ដែលវិញ្ញាណទាំងប្រាំបានបង្កើតឡើង ។

បើតាមប្រៀបធៀបលទ្ធិពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យ មានបំណងធ្វើ មនុស្សឱ្យបានសុខ ញ៉ាំងលោកឱ្យចម្រើនដូចគ្នា ។ លទ្ធិទាំងពីរសុទ្ធតែជាជាងជំនាញ សម្រាប់រចនាមនុស្ស និងលោកឱ្យចម្រើនទៅរកសន្តិភាព ធ្វើមនុស្សលោកឱ្យមាន សមភាព ភាតរភាព សេរីភាព សម្បូណ៌ភាព វឌ្ឍនភាព ជាគ្រូពេទ្យយ៉ាងប្រសើរ ចេះផ្សំនូវឱសថទិព្វ បំបាត់មនុស្សឱ្យបាត់ឈ្លោះទាស់ទែងគ្នា ឱ្យទៅរកសេចក្ដីស្ងប់ ។

ក- ព្រះពុទ្ធសាសនា ឱ្យប្រព្រឹត្តប្រតិបត្តិតាមធម៌ ដើម្បីធ្វើនាម នឹងរូប របស់ខ្លួនឱ្យអស់ លោភៈ ទោសៈ មោហៈ ចំពោះខ្លួនសិន ទើបទៅរកសុខឱ្យអ្នក ដទៃជាខាងក្រោយ ។ លទ្ធិប្រជាធិបតេយ្យពុំបានរចនាបុគ្គល ឱ្យផុតពីលោភៈ ទោសៈ មោហៈ មិនបានកែប្រែបុគ្គល ឱ្យរួចពីកណ្ដាប់ដៃនៃតណ្ហា គឺបុគ្គលស្ថិតនៅ តែក្នុងកិលេសពេញល្បុង ហើយឱ្យទៅរកប្រយោជន៍ ដើម្បីសង្គមជាតិមនុស្សធម៌ ដល់លោកទាំងមូល ។ បើចិត្តរបស់ខ្លួនមិនទាន់ស្ងប់ធ្វើម្ដេចនឹង ឱ្យសង្គមជាតិ

មនុស្សលោកស្ងប់ទៅបាន ? បើចិត្តនេះមិនស្គាល់សីលប្រាំ សិលប្រាំបីផង តើនឹងធ្វើឱ្យសង្គម ជាតិពិភពលោក មានរបៀបរៀបរយយ៉ាងណាបាន បើបុគ្គល នីមួយ១ជាភ្លើងគប់ ឆេះ ក្តៅ រោលរាល ខ្លួនឯង តើនឹងឱ្យបុគ្គលដទៃត្រជាក់កាយ សប្បាយចិត្តមកពីណា ? ម្យ៉ាងទៀតប្រសិនបើអ្នកអប់រំមិនទាន់ជាគំរូ តើអ្នកប្រតិបត្តិសង្ឃឹមទៅអ្នកណាវិញ ? ។

**__កំណត់:__** *" ប្រជាធិបតេយ្យ គ្រហស្ថក្តី អ្នកបួសក្តី ធ្វើទៅបានល្អដូចគ្នានៅពេលដែលបុគ្គលទាំងនោះ ស្គាល់ច្បាប់រដ្ឋច្បាប់ប្រទេស ស្គាល់សីលវិទ្យាសាកលលោក ស្គាល់ធម៌ ស្គាល់វិន័យ "* ។

ព្រោះហេតុដូច្នេះបានគេប្រៀបធៀបថា ព្រះពុទ្ធសាសនា គឺលោកកាប់ក្របែលឫសតូច ឆ្ការគាស់កកាយឫសធំតូច ទាំងអស់ ទើបរំលំដើមឈើនោះលែងដុះតទៅទៀតបានលទ្ធិប្រជាធិបតេយ្យ គឺលោកទុកឫសតូចធំនៅជាប់នឹងព្រះធរណី ហើយលោកយកពូថៅក្របែលគល់ងណោះ ពិតមែនតែដើមឈើរំលំតែគល់វានៅលុះមានទឹកភ្លៀងជ្រួតជ្រាប អាកាសបួរធាតុទៅមកក៏គល់នោះដុះឡើងជាថ្មីបញ្ចេញជាដើមផង បែកមែកសាខាទៅជារុក្ខជាតិមួយដើមថ្មីតទៅទៀត។ បើខ្លួនមានចិត្តពេញដោយលោភៈ ទោសៈ មោហៈ ម្តេចក៏នឹងធ្វើឱ្យអ្នកឯទៀតស្ងប់រម្ងាប់ទៅបានម្តេចក៏នឹងធ្វើលោក ឱ្យចម្រើនទៅរកសន្តិភាពបាន! [២] ។

**កំណត់ :** *"នេះជាទស្សនៈមួយល្អណាស់ ប៉ុន្តែបច្ចុប្បន្នពិភពលោកមិនអាចរកឃើញអ្វីដែលត្រូវកាត់ខ្ទេះទេ គ្រាន់តែបង្ហួរមិនដាច់ខាតបាន ។ ទ្រឹស្តីអាចថែងជាដាច់ខាតតាមអនុវត្តមិនអាចដាច់ខាតបានទេ "* ។

---

២- ក៉ាយ - ប៊ុក ព្រះពុទ្ធសាសនា នៃប្រទេសកម្ពុជា ឆ្នាំ ១៩៥៧ ទំព័រ ៨០

បើដូច្នេះ លទ្ធិប្រជាធិបតេយ្យ និងលទ្ធិពុទ្ធសាសនា មានសភាពមិនខុសគ្នាស្រឡះទៅហើយ ឬ ? មិនមែនទេ លទ្ធិប្រជាធិបតេយ្យ ជាលទ្ធិសម្រាប់អនុវត្តទៅខាងអាណាចក្រ គឺសម្រាប់រចនាបុគ្គល ឱ្យចេះស្រឡាញ់ជាតិ ញ៉ាំងសង្គមឱ្យចម្រើនដុះដាលឡើងតាមលំដាប់ ធ្វើមនុស្សធម៌ឱ្យចម្រើនទៅរកសេចក្ដីសុខជាភិយ្យោភាពតទៅធ្វើលោកឱ្យឡើងទៅកាន់វឌ្ឍនភាពសម្បូណ៌ភាព ។ ចំណែកឯលទ្ធិពុទ្ធសាសនាជាលទ្ធិសម្រាប់អនុវត្តទាំងខាងអាណាចក្រ ឬពុទ្ធចក្រ គឺសម្រាប់រចនាបុគ្គលឱ្យមានគុណធម៌ សីលធម៌ ញ៉ាំងសង្គមឱ្យចម្រើន លះបង់នូវទុក្ខសោក រោគភ័យគ្រប់យ៉ាងគឺញ៉ាំងទុក្ខ ចំពោះខ្លួនឱ្យអស់ទៅធ្វើជាតិ ជរា ព្យាធិ មរណៈ ឱ្យសាបរលាបទៅធ្វើឱ្យទុក្ខសង្គមរលត់រលាយជាលំដាប់ រចនាមនុស្សធម៌ ឱ្យកាត់បន្ថយពីទុក្ខ កែប្រែលោកឱ្យរួចចាកទុក្ខគឺធ្វើបុគ្គល សង្គម មនុស្សលោក ឱ្យបានដល់ព្រះនិព្វាន ជាស្ថានក្សេមក្សាន្តផុតចាកទុក្ខទាំងពួង ។

**កំណត់ :** *" នេះក៏ជាទស្សនៈមួយប្រពៃណាស់ដែរ ប៉ុន្តែអត្ថន័យនៃទស្សនៈហាក់ដូចជ្រាលជ្រៅណាស់ ។ ព្រោះបញ្ញត្តិនៃព្រះពុទ្ធសាសនា មានអត្ថន័យជ្រាលជ្រៅណាស់ យើងគួរទាញយកជីវិតប្រចាំថ្ងៃទើបល្អជាង "* ។

លទ្ធិប្រជាធិបតេយ្យ នឹងលទ្ធិពុទ្ធសាសនា នាំមនុស្សទៅរកសុខដូចគ្នាគ្រាន់តែលទ្ធិប្រជាធិបតេយ្យ ដឹកនាំមនុស្សទៅកាន់លោកិយ ឬសាមិសសុខ គឺសុខជាលោកិយ ឬសុខប្រកបដោយអាមិសនៅលាយច្រឡំ ដោយទុក្ខ.ឯលទ្ធិពុទ្ធសាសនាក៏ដឹកនាំមនុស្សទៅកាន់ លោកុត្តរឬសុខប្រាសចាកអាមិស សុខដ៏បរិសុទ្ធផុតពីទុក្ខទាំង ១៣ កង ថែមសុខក្នុងព្រះនិព្វាន ។ ( ព្រះនិព្វានមានន័យច្រើនណាស់ )

## ព្រះពុទ្ធសាសនា និងអនាគតប្រទេសកម្ពុជា

ចំពោះអនាគតប្រទេសកម្ពុជា មានបញ្ហាព្រះពុទ្ធសាសនាច្រើនអនេក

កប្បការ ដែលត្រូវដោះស្រាយតែនៅទីនេះ យើងសូមពណ៌នាតែអំពីបញ្ហាដូចខាងក្រោម :

ក. បញ្ហាកម្មវិធីសិក្សាទាំងគ្រហស្ថ-បព្វជិត

ខ. បញ្ហាយុវជន ចំពោះព្រះពុទ្ធសាសនា

គ. បញ្ហាវរជន ចំពោះព្រះពុទ្ធសាសនា

ឃ. បញ្ហាព្រះសង្ឃ ចំពោះព្រះពុទ្ធសាសនា បព្វជិតចំពោះព្រះពុទ្ធសាសនា

## ក/ បញ្ហាកម្មវិធីសិក្សាទាំងគ្រហស្ថ-បព្វជិត

**ក.** កម្មវិធីសិក្សាខាងគ្រហស្ថ តាំងពីបឋមភូមិមកគួរមានការបញ្ចូលធម៌នមស្ការព្រះរតនត្រ័យ និងប្រវត្តិព្រះបរមសម្មាសម្ពុទ្ធ ព្រមទាំងវិធីប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ឱ្យបានច្បាស់លាស់ ។

ធ្វើយ៉ាងនេះ ដើម្បីនឹងអប់រំ និស្សិត និង យុវជនឱ្យមានសេចក្តីជ្រះថ្លាខាងព្រះពុទ្ធសាសនា ប្រៀបដូចជាត្រូវការពត់ឫស្សី ដើម្បីនឹងធ្វើព្រួញដូច្នោះ ធម្មតាជាងធ្វើព្រួញត្រូវបិទឫស្សី ឱ្យមានទ្រង់ទ្រាយជាព្រួញសិន ទើបយកឫស្សីនោះ ទៅរោលភ្លើងពត់ម្តងបន្តិចៗ យូរៗទៅគង់បានជាព្រួញមិនខាន។

ចំណែកកម្មវិធីសិក្សាខាងបព្វជិត មានកម្មវិធីខាងសាលាបាលីរង សាលាធម្មវិន័យ ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ្យ ក៏ត្រូវបញ្ចូលអត្ថបទខ្លះនៃកម្មវិធីសិក្សាខាងគ្រហស្ថ ដើម្បីឱ្យមានការប្រាស្រ័យទាក់ទងទៅវិញទៅមក ធ្វើវិធីសិក្សាទាំងពីរផ្នែក ឱ្យមានតុល្យភាពគ្នានឹងគ្នា ដើម្បីឱ្យចេះដឹងផ្លូវលោក ផ្លូវធម៌ជាហេតុញុំាងអាណាចក្រ និងពុទ្ធចក្រឱ្យវិលទៅព្រមៗគ្នា ព្រមទាំងប្រយោជន៍ទាំងពីរផ្នែកថែមទៀតផង ។

បញ្ហានេះ មិនជាលំបាកដោះស្រាយប៉ុន្មានទៅអនាគត តែស្រេចលើ

បណ្ឌិត ទាំងឡាយពិនិត្យទៅតាមវិចារណញ្ញាណចុះ ព្រោះបញ្ហានេះ បើនឹងដោះស្រាយបាន លុះត្រាតែខិតខំពុះពារនូវឧបសគ្គគ្រប់យ៉ាង ដើម្បីនឹងញ៉ាំងវិជ្ជាទាំងខាងផ្លូវលោកនឹងផ្លូវធម៌ ឱ្យស្របគ្នាតាមកម្មវិធីសិក្សាទាំងពីរផ្នែក ។ ជាងនេះទៅទៀតចាំបាច់ណាស់ដែល "ពុទ្ធចក្រនិងអាណាចក្រ" គួរតែយើងគិតគូរយ៉ាងណា ឱ្យពុទ្ធសាសនិកខ្មែរយើងបានចេះដឹងប្រហាក់ប្រហែលគ្នា ទើបអាចដោះស្រាយបានងាយស្រួល ។ ប៉ុន្តែចំពោះមនុស្សសតវត្សទី ២១ នេះ មិនមែនងាយពន្យល់នូវអ្វីដែលអ្នកពន្យល់ខ្វះគំរូល្អដល់អ្នកស្តាប់នោះទេ ។

(នៅមានត)

*រូបកាយតែងចាស់ជរា. ឯកេរ្តិ៍ឈ្មោះល្អមិនចេះចាស់ជរាឡើយ.*
*ទាំងធម៌របស់សប្បុរស ក៏មិនចេះចាស់ជរាដែរ ។*

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ

ជោតញ្ញាណោ **ជួន ណាត**

# ប្រវត្តិរបាំក្បាច់បុរាណ

(តចប់)

ដោយ : ពេជ្រ ទុំក្រវិល

មិនត្រឹមតែប៉ុណ្ណោះទេ រហូតមកដល់ពេលដែលព្រះពុទ្ធសាសនាមហាយានបានឡើងជាសាសនាធំនៅក្នុងប្រទេសកម្ពុជា ពិសេសក្នុងព្រះរាជព្រះបាទជ័យវរ្ម័នទី VII (១១៨១-១២១៨) ? ដែលជាព្រះមហាក្សត្រដ៏មានមហិទ្ធិឫទ្ធិបំផុតក្នុងរាជពង្សាវតារ នៃប្រទេសកម្ពុជា ហើយក៏ជាព្រះមហាក្សត្រ ដែលបានសាងសាលាសំណាក់មន្ទីរព្យាបាលរោគ និងប្រាសាទជាច្រើនមានប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម ប្រាសាទព្រះខ័ន បន្ទាយក្ដី នាគព័ន្ធ តាសោម ក្រោលគោ បន្ទាយឆ្មារ (បាត់ដំបង) វត្តនគរ (កំពង់ចាម) តាព្រហ្ម បាទី (តាកែវ) ប្រាសាទ ប្រាសាទបានប៊ូ ប្រាសាទកុដិមហាឫស្សី (ខេត្តបុរីរម្យ) ប្រាសាទគូកែវ (ខេត្តឧត្តរធានី) ប្រាសាទវត្តមហាធាតុ (ខេត្តលពបុរី) ប្រាសាទ តាមាន់ (ខេត្តសុរិន្ទ) ប្រាសាទភិមាយ (ខេត្តនគរ-រាជសីមា) ប្រាសាទកំពែងតូច (ខេត្តស៊ីសាកេត) ប្រាសាទកំផែងលែង (ខេត្តពេជ្របុរី) (លនិងល) ជាដើម ។ នោះរបាំក្បាច់បុរាណ ឬទម្រង់ល្ខោនស្រីនេះ ទំនងជាកាន់តែរុងរឿងនិងរីកសាយថែមទៀតផង ព្រោះថ្វីត្បិតតែមានការដោះដូរជំនឿសាសនានៅក្នុងព្រះនគរមែន ប៉ុន្តែរបាំក្បាច់បុរាណដែលជាកេរ្តិ៍ដំណែលរបស់បុព្វបុរសដូនតាខ្មែរ ត្រូវបានគេថែរក្សាទុកយ៉ាងល្អប្រពៃ ហើយប្រហែលជាបានបង្វែរ ឬបន្ថែមតួនាទីឱ្យទម្រង់សិល្បៈនេះពីអ្នកបម្រើដ៏គាប់ព្រះទ័យ "ទេវទាសី " របស់អាទិទេពខាងព្រហ្មញ្ញសាសនា "ទេវរាជ" ,មកជាអ្នកបម្រើខាងវិហារព្រះពុទ្ធសាសនា "ពុទ្ធរាជ " ថែមទៀតផង? ។ ជាក់ស្តែងដូចមានសិលាចារឹកនៅប្រាសាទតាព្រហ្ម ឬរាជវិហារដែលព្រះអង្គចាត់ចែងកសាងឡើងនៅឆ្នាំ ១១៨៦ ដើម្បីឧទ្ទិសចំពោះ

ព្រះមាតា និងព្រះរាជគ្រូឈ្មោះ " ជ័យមង្គលាថិ " នោះបានបញ្ជាក់ថា ក្នុងប្រាសាទនេះ មានស្រីរបាំចំនួន ៦១៥ នាក់ ។ ចំណែកខាងប្រាសាទព្រះខ័ន ឬជ័យស្រី សាងឡើងក្នុងឆ្នាំ ១១៩១ ដើម្បីឧទ្ទិសចំពោះព្រះបិតា ព្រះអង្គវិញ មានអ្នករបាំរហូតដល់ ១000នាក់ ឯណោះសម្រាប់រៀបចំរាំថ្វាយក្នុងពិធីសក្ការៈបូជាផ្សេងៗ នៅក្នុងប្រាសាទនេះ ។

មិនត្រឹមតែប៉ុណ្ណោះទេ ព្រះនាងឥន្ទ្រទេវី ដែលព្រះបាទជ័យវរ្ម័នទី VII ទ្រង់អភិសេកជាមហេសីបន្ទាប់ពីព្រះនាងជ័យរាជទេវី ព្រះអនុជរបស់ព្រះនាង និងជាអគ្គមហេសីទ្រង់សោយទិវាល័យទៅ... ហើយព្រះនាងឥន្ទ្រទេវី ត្រូវបានព្រះរាជាជាស្វាមី ទ្រង់តែងតាំងជាបរិនាយកាចារ្យនៅមហាវិទ្យាល័យជ័យស្រីនេះ ... ទ្រង់ទាំងបាននាំពពួកស្រីដែលជាព្រះរាជបរិពាររបស់ព្រះនាងសម្តែងរឿងជាតកផ្សេងៗថែមទៀតផង ។

ក្រោយពីព្រះបាទ ជ័យវរ្ម័នទី VII សោយទិវង្គតទៅ ព្រះបាទឥន្ទ្រវរ្ម័នទីII ជាព្រះរាជបុត្រទ្រង់បានឡើងសោយរាជ្យបន្តពីព្រះបិតា ( ១២១០ ឬ ១២១៨ ? ដល់១២៤៣ ) ព្រឹត្តការណ៍ចំឡែកៗ កើតមានឡើងនៅក្នុងរាជនេះដូចជា : ប្រគល់ឯករាជ្យឱ្យនគរចម្ប៉ា ដោយលើកព្រះអង្គម្ចាស់អង្សរាជស្តេចចាមឱ្យឡើងសោយរាជ្យនៅចម្ប៉ានោះ និងព្រឹត្តការណ៍វាយលុកទឹកដីខ្មែរ របស់ជនជាតិសៀម "ថៃ" ដំបូងនៅវាលទំនាបទន្លេមេណាមត្រង់តំបន់សុខោទ័យ ។

ប៉ុន្តែដែលជាអកុសលបំផុតនោះ ថែមលើការវាយលុករបស់បរទេស គឺវិបត្តិសាសនា ស្នាមបែកបាក់ផ្ទៃក្នុង ដែលអូសបន្លាយយូរអង្វែងនៅសម័យអង្គរតាំងពីរាជជ័យវរ្ម័នទី VIII (១២៤៣-១២៩៥) ព្រះបាទស្រិន្ទ្រវរ្ម័ន ឬឥន្ទ្រវរ្ម័នទី III (១២៩៥-១៣០៧) ព្រះបាទស្រិន្ទ្រជ័យវរ្ម័ន ឬឥន្ទ្រជ័យវរ្ម័ន (១៣០៨-១៣២៧)

និងព្រះបាទជ័យវរ្ម័នទីIX( ១៣២៧-១៣៣៦) ដែលមានប្រតិកម្មជះកំសួលជាអំពើអាក្រក់ទៅលើគ្នាទៅវិញទៅមក... ជូនកាលព្រះពុទ្ធសាសនាប៉ះពារទៅលើព្រហ្មញ្ញសាសនា ..... ហើយភាគច្រើនខាងព្រហ្មញ្ញសាសនាបានបំផ្លាញព្រះពុទ្ធសាសនា ដែលមានអ្នកគោរពបូជាកាន់តែច្រើនលើសលុបណាស់ទៅហើយ នៅក្នុងទូទាំងប្រទេសនោះ ... បានជំរុញប្រទេសកម្ពុជាឱ្យធ្លាក់ចូលក្នុងវិបត្តិមួយយ៉ាងធំ ដោយប្រវត្តិសាស្ត្រប្រទេសកម្ពុជា ត្រូវកាត់ផ្តាច់មួយរយៈកាល .... ហើយភ្ជាប់មកវិញ ដោយព្រឹត្តការណ៍ប្តូររាជវង្ស ពីវង្សវរ្ម័នមកវង្សត្រសក់ផ្អែម (ជាកសិករកាន់ព្រះពុទ្ធសាសនាហីនយាន ) ដែលប្រវត្តិវិទូនិងអ្នកស្រាវជ្រាវភាគច្រើនយល់ថា: នេះជាបដិវត្តន៍ខាងនយោបាយ និងសាសនារបស់នាយត្រសក់ផ្អែម ។ ហើយចំណុចមួយសំខាន់ទៀត ដែលត្រូវកត់សម្គាល់នោះ គឺថា : តាំងពីការប្តូររាជវង្សវរ្ម័នមកវង្សត្រសក់ផ្អែម ... ចាប់ពីរាជ្យត្រសក់ផ្អែមមករាជ្យព្រះនិពាន្តបាទជាព្រះរាជបុត្ររបស់ព្រះអង្គនេះ ហើយដែលប្រទេសខ្មែរហាក់បាត់បង់ភាពជាម្ចាស់ទាំងស្រុង លើទឹកដីភាគខាងលិចរបស់ខ្លួន ដែលត្រូវជនជាតិសៀម "ថៃ" ចូលមកលុកលុយរុករានទន្ទ្រានយកនោះ ។

ពីដំបូងជនជាតិសៀម "ថៃ" ដែលជាកុលសម្ព័ន្ធមួយនៅប្រទេសចិនភាគខាងត្បូងបានច្រាលចុះមកក្រោមកាន់តែច្រើនឡើងៗ ហើយទីបំផុតក៏បានវាយខ្មែរម្ចាស់ស្រុកនៅសុខោទ័យ រួចប្រកាសជារដ្ឋសៀម ដំបូងនៅអំឡុងឆ្នាំ ១២២០ ។ បន្ទាប់មកពួកនេះ បានបន្តរុករានទន្ទ្រានយកទឹកដីខ្មែរចុះមក ក្រោមមកដល់តំបន់ព្ធយុធ្យា រួចទីបំផុតបានសម្រេចបំណងដោយបានវាយបែកអង្គរក្នុងអំឡុងឆ្នាំ ១៣៥៣ ? ក្នុងរាជស្តេចខ្មែរមួយអង្គនាមលំពង់រាជា ដែលមានជំនោរអំនួតអួតអាងដោយសារឃើញសៀមដែលពីដំបូងចូលមកវាយក្រុងអង្គរមិនបាន ហើយទទួល

បរាជ័យយ៉ាងដំណំ ។ ព្រះអង្គទ្រង់គិតថា: គ្មានសត្រូវណាអាចឈ្លានពានរាជធានី នៃមហានគរបានឡើយ ... ក៏ទ្រង់រំសាយទ័ពឱ្យវិលត្រឡប់ទៅស្រុកភូមិវិញអស់ ។ ចុងបញ្ចប់មហានគរក៏ត្រូវរលំ ដោយសារមហិច្ឆតា នៃសត្រូវដ៏ក្មេងខ្ចី ដែលខ្មែរមាក់ងាយនេះ ។

នៅក្នុងជោគជ័យរបស់គេជាបន្តបន្ទាប់ សៀមបានឆក់ប្លន់និងរឹបអូសយកសម្បត្តិដ៏មានតម្លៃឯកសារសព្វបែបយ៉ាង ទាំងធនធានមនុស្សថែមទៀតផង ។ ចុះចំណែករបាំបុរាណដែលយើងឃើញមាននៅប្រទេសសៀមសព្វថ្ងៃ ដែលមានលំនាំប្រហាក់ប្រហែលគ្នា នឹងរបាំបុរាណ ដែលមានប្រភពជាសិល្បៈទេវៈនៅគ្រប់ប្រាសាទទេវស្ថានរបស់ខ្មែរ ពិសេសនៅក្នុងប្រាសាទទាំងឡាយដែលសៀមវាយដណ្តើមបានយកទៅកាន់កាប់នោះ ។ តើពួកសៀមមានបានបង្ខិតបង្ខំរឹបអូសយកឬក៏ចំឡងយកឬទេ ? ពិសេសក្នុងពេលដែលពួកនេះវាយបែកក្រុងអង្គរក្នុងអំឡុងឆ្នាំ ១៣៥៣? ដែលឯកសារជាច្រើនបានរៀបរាប់ប្រាប់យើងពីការដឹកជញ្ជូនប្លន់យកសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌របស់ខ្មែរដ៏ច្រើនសន្ធឹក និងកៀរគ្រូខ្មែរវាល់សែនគ្រូនោះ ។ តើអ្នកប្រាជ្ញរាជបណ្ឌិតខ្មែរ លើគ្រប់វិស័យត្រូវសៀមកៀរយកទៅឬទេ ? តើគ្រូរបាំ និងសិល្បការិនី (ទេវទាសី) គ្រូតន្ត្រី និងសិល្បករដ៏ចំណាន១លើគ្រប់វិស័យត្រូវសៀមបង្ខំចាប់យកទៅស្រុកគេដែរ ឬក៏អត់ ?

ចំណែកខាងប្រទេសឡាវវិញ ឯកសារមួយចំនួនបានរៀបរាប់ប្រាប់យើងថា ដោយសារចំណងជាមិត្តភក្តិផង និងជាសាច់សាលោហិតផង សំណល់វប្បធម៌ នៃប្រទេសទាំងពីរគឺឡាវ និងកម្ពុជាមានទំនាក់ទំនងនឹងគ្នាតាំងពីយូរលង់មកហើយពោលគឺតាំងពីសម័យមហានគរមកម្ល៉េះ ។ យ៉ាងណាមិញព្រះចៅហ្វាង៉ុម ដែលជាព្រះរាជាដំបូង ហើយល្បីល្បាញជាងគេក្នុងប្រវត្តិ នៃអាណាចក្រឡានសាង គឺជា

បុត្រសុណិសា (កូនប្រសារ) របស់ព្រះចៅក្រុងកម្ពុជានាសម័យអង្គរ ដោយកាល នៅពីកុមារព្រះអង្គត្រូវបានគេបណ្តែតពោងពាយតាមដងទន្លេមេគង្គទើរនៅត្រង់ តំបន់ចម្ប៉ាសាក់ ហើយត្រូវបានព្រះចៅអធិការវត្តមួយនៅចម្ប៉ាសាក់រើសយកមក បីបាច់ថែរក្សា រួចនាំទៅថ្វាយព្រះរាជនាទីក្រុងអង្គរ។ ព្រះរាជាខ្មែរនៅអង្គរទ្រង់សព្វ ព្រះរាជហឫទ័យយ៉ាងខ្លាំង ក៏ទ្រង់ផ្តត់ផ្គង់ទំនុកបំរុង ហើយផ្ទុងផ្តើមឱ្យចៅហ្វាង៉ុម សាងផ្នួសបួសរៀន នូវវិជ្ជាសព្វសារពើ រហូតមានការចេះដឹងកិរិតខ្ពស់ ។ លុះលាចាក សិក្ខាបទព្រះរាជាខ្មែរនាសម័យអង្គរនេះ ក៏បានរៀបអភិសេកបុត្រីសំណាប់ព្រះទ័យ របស់ព្រះអង្គ ព្រះនាមក្សត្រីកែវឡតហ្វាឱ្យទៅចៅហ្វាង៉ុម ។ រួចបានជួយផ្តល់ កម្លាំងព័ទយ៉ាងច្រើន ដើម្បីឱ្យចៅហ្វាង៉ុមយាងទៅរំដោះទឹកដីកំណើត (ទំនងជា សាមន្តរដ្ឋ ) ពីសត្រូវឈ្លានពានមកវិញ ។ ក្នុងដំណើរវិលត្រឡប់នេះ ចៅហ្វាង៉ុម បាននាំទៅជាមួយនូវទំនៀមទម្លាប់ប្រពៃណីសិល្បៈមួយចំនួន និងទាំងផ្នែកសាសនា ផង ។ ហើយទីបំផុតព្រះអង្គទ្រង់បានទទួលជោគជ័យ និងឡើងសោយរាជ្យនៅហ្លួង ប្រាបាងក្នុងអំឡុងឆ្នាំ ១៣៥៣ ? គឺជំណាលគ្នានិងកាលបរិច្ឆេទ នៃការបែកក្រុង អង្គរនេះឯង ។ តាមរយៈឯកសារទាំងនេះ គួបផ្សំដោយការពិនិត្យជាក់ស្តែងផង យើងអាចយល់បានថា : វប្បធម៌ឡាវ និងកម្ពុជាមួយភាគធំ ដែលសេសសល់ដល់ សព្វថ្ងៃជាបងប្អូននឹងគ្នាយ៉ាងពិតប្រាកដ ។ ម្យ៉ាងទៀតបើយើងពិនិត្យមើលរបាំក្បាច់ បុរាណវិញ ដែលសព្វថ្ងៃ ឡាវក៏មាន ខ្មែរក៏មាន ក្នុងរូបភាពប្រហាក់ប្រហែលគ្នាទាំង តន្ត្រីជូនសិល្បៈរបាំនេះ ក៏ដូចគ្នាទៀតផង ហើយដែលនៅប្រទេសឡាវគេមានការ និយមឱ្យឈ្មោះថា : "ណាងកែវ១ " គឺ "នាងកែវ " រហូតមកដល់សព្វថ្ងៃនេះទៀត ផង នោះឈ្មោះនាងកែវនេះ ក៏ប្រហែលអាចជាភស្តុតាងបញ្ជាក់បន្ថែមពីទំនាក់ ទំនងរវាងទម្រង់សិល្បៈរបាំ ឬល្ខោនក្បាច់បុរាណឡាវទៅនឹងសិល្បៈទេវៈរបស់

មហានគរដែរ ។ ឯក្សត្រីកែវឡេតហ្វា បុត្រីព្រះចៅក្រុងកម្ពុជានាសម័យអាណាចក្រ ខ្មែរដែលបានក្លាយជាមហេសីរបស់ព្រះចៅហ្វាង៉ុម ក៏ប្រហែលអាចជាសិល្បការិនី នៃទម្រង់សិល្បៈរបាំបុរាណខ្មែរដ៏ចំណាន "Star" ថែមទៀតផង ។

ចំណែកនៅឯកម្ពុជាឯណេះវិញ ក្រោយពីបែកអង្គរ ឬក៏ចាប់តាំងពីមាន វិបត្តិសាសនា ពោលគឺពីរាជ្យព្រះបាទជ័យវរ្ម័នទី VII មកម្លេះ ដែលរបាំស្រី (ទេវ ទាសី) នៃប្រាសាទនានាហាក់ត្រូវខ្ទេចខ្ទាំរួចបោះបង់ចោលព្រះវិហារ (ប្រាសាទ) ? វិលត្រឡប់មករស់ក្បែរព្រះរាជារហូតមកដល់ព្រះបាទពញាយ៉ាត (១៣៩៣- ១៤៦៣) ទ្រង់ប្តូររាជធានីពីក្រុងអង្គរមកនៅទួលបាសាន (១៤៣១) ? រួចមកភ្នំ ពេញចតុមុខ (១៤៣២)? ហើយគឺប្រហែលពីពេលនោះមកហើយ ដែលខ្មែរនិយម ហៅរបាំស្រី (Ballet Girl) ដែលជាប្រភេទសិល្បៈទេវៈនេះថា ជារបាំឬល្ខោនព្រះ រាជទ្រព្យជារៀងរហូតមក ។ យើងមិនបានដឹងពិតប្រាកដទេ អំពីការវិវត្តនីរីក ចម្រើនឬស្រុតចុះរបស់ទម្រង់ល្ខោនក្បាច់បុរាណនេះ នៅក្នុងសម័យក្រោយរាជ្យព្រះ បាទពញាយ៉ាតនៅចតុមុខនោះ ។ តែបើតាមឯកសារមហាបុរសខ្មែរ យើងអាចដឹង បានថា ទម្រង់សិល្បៈរបាំស្រី ឬល្ខោនព្រះរាជទ្រព្យនេះ ត្រូវបានរីកចម្រើនយ៉ាងខ្លាំង នៅក្នុងរជ្ជកាលព្រះបាទអង្គច័ន្ទរាជា ឬអង្គច័ន្ទទី I (គ.ស ១៥១៦-១៥៦៦) ដែល ជាព្រះរាជាដ៏ខ្លាំងពូកែមួយអង្គក្រោយសម័យអង្គរ ។ ព្រះអង្គទ្រង់គង់នៅព្រះរាជ វាំងបន្ទាយលង្វែក ។ ទ្រង់បានខិតខំការពារមាតុភូមិឱ្យបានសុខសន្តិភាពយ៉ាងយូរ សត្រូវទាំងឆ្វេងស្តាំមិនហ៊ានឈ្លានពានឡើយ ហើយទ្រង់បានរៀបចំប្រទេសជាតិ ឱ្យរីកចម្រើនលើគ្រប់វិស័យ ទាំងវិស័យវប្បធម៌ សាសនា និងសេដ្ឋកិច្ច ក្នុងនោះ សិល្បៈគ្រប់ផ្នែកក៏បានរីកចម្រើនយ៉ាងខ្លាំងក្លាណាស់ដែរ ។ ឯកសារបានរៀបរាប់ថា ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់សំអិតសំអាងសិល្បៈមហោស្រព របាំតន្ត្រី ទម្រង់

ល្ខោនប្រុស ល្ខោនស្រី ដើម្បីទុកជាគុរង្វាន់សម្តែងក្នុងពិធីការជូនជាកិត្តិយស ចំពោះមន្ត្រីជាន់ខ្ពស់ទាំងឡាយ ដែលបានទទួលជោគជ័យធំធេងក្នុងការបម្រើជាតិមាតុភូមិរបស់ខ្លួន។ ហើយឯកសារក៏បានកត់ត្រាទុកយ៉ាងច្រើនផងដែរ អំពីទំនាក់ទំនងក្នុងភាពស្និទ្ធស្នាល និងសន្តោសប្រណីរវាងព្រះរាជា និងសិល្បករសំណប់ព្រះទ័យរបស់ព្រះអង្គ ។

ប៉ុន្តែជាអកុសលមិនបានយូរប៉ុន្មាន ក្រោយពីរាជព្រះអង្គច័ន្ទរាជា រាជធានីលង្វែក ដែលជាបន្ទាយដ៏រឹងមាំចុងក្រោយរបស់កម្ពុជា ក៏ត្រូវរលំរលាយដោយសៀមប្រើល្បិចយកប្រាក់ដួងធ្វើជាគ្រាប់កាំភ្លើងបាញ់ចូលក្នុងគុម្ពឫស្សី ..... ជំរុញចិត្តមន្ត្រីខ្មែរដែលលោភលន់ និងល្ងង់ខ្លៅមួយចំនួនឱ្យកាប់រំភ្ការ អស់កំពែងឫស្សីដ៏ក្រាស់របស់បន្ទាយលង្វែក ហើយទីបំផុតរាជធានីនេះ ក៏ត្រូវរលាយជាផេះផង់ ដោយស្នាដៃសត្រូវសៀមសារជាថ្មីនៅឆ្នាំ ១៥៩៣ នៃគ.ស ។

ក្រោយសម័យលង្វែកយើងអាចដឹងបានថា សិល្បៈរបាំព្រះរាជទ្រព្យនេះមានវត្តមានជានិច្ចនៅក្នុងព្រះបរមរាជវាំង ។ រហូតមកដល់រជ្ជកាលព្រះរាជ សម្ភារ "ពញាតូ" ដែលជាព្រះមហាក្សត្រទ្រង់ជាកវីនិពន្ធដ៏ឆ្នើម (១៦២៩-១៦៣៤) ដែលទ្រង់គង់នៅឧត្តុង្គ ហើយមានវិបត្តិជាមួយនិងព្រះឧទ័យជាកុមារ (បិតុលា) ពីរឿងស្នេហាលើស្រីតែម្នាក់ ហើយព្រះអង្គទ្រង់ផ្លាស់មកគង់នៅវាំងកោះឃ្លោក ដោយប្រហែលជានាំមកនូវក្រុមសិល្បៈព្រះរាជទ្រព្យមួយក្រុមមកជាមួយផង ។ ព្រោះក្រោយពីការសិក្សាស្រាវជ្រាវអំពីទម្រង់ល្ខោនខ្មែរ យើងឃើញទំនងដូចជាមានគ្រូដែលសេសសល់ពីកោះឃ្លោកបានទៅបង្រៀនល្ខោនស្រីនៅម្តុំកៀនស្វាយកោះស្លាកែត ? ស្ថិតនៅខាងត្បូងឈៀងខាងកើតរាជធានីភ្នំពេញ....ហើយល្ខោនពោលស្រីនេះ នៅមានវត្តមានរហូតមកដល់សព្វថ្ងៃនេះ ។ បើយើងគិតពីបែកលង្វែករហូតមកដល់រាជព្រះឧទ័យរាជាអង្គច័ន្ទទី II (១៨០៦ - ១៨៣៤) រាជក្សត្រីអង្គម៉ី

(១៨៣៤-១៨៤០) ប្រទេសជាតិខ្មែរត្រូវចុះដុនដាបស្ទើរលោយបាត់រូប ដោយសារការឈ្លានពានប្រទាញប្រទង់ហែកហួរពីសត្រូវឈ្លានពានទាំងសងខាងផង និងដោយសារទំនាស់រាជវង្សជាទំនាស់ផ្ទៃក្នុងផង ។ ប៉ុន្តែជាកុសលល្អមហាជ័យជំនះដ៏ត្រចះត្រចង់របស់ព្រះហរិរក្សរាមាធិបតីព្រះអង្គដួង ( ១៨៤០ - ១៨៥៩ ) ក្នុងសង្គ្រាមសង្គ្រោះប្រទេសជាតិ ដោយមានប្រជារាស្ត្រទូទាំងនគរបានស្ម័គ្រចិត្តក្រោកឈរដង្ហែរព្រះអង្គផងនោះហើយ ដែលធ្វើឱ្យសៀម និងយួន ព្រមទទួលស្គាល់ព្រះអង្គជាព្រះមហាក្សត្រនៃប្រទេសកម្ពុជាព្រមគ្នា...បានបង្អាក់មហិច្ឆតាលោភលន់ នៃសត្រូវទាំងសងខាងមិនឱ្យយកទន្លេមេគង្គធ្វើជាព្រំប្រទល់នៃប្រទេសទាំងពីបាន ។ ប៉ុន្តែគឺចាប់តាំងពីពេលមុននោះមកម្ល៉េះ ដែលខ្មែរបានទទួលឥទ្ធិពលពីសៀមខាងផ្នែកវប្បធម៌ ដោយខ្មែរបានចម្លងយកមរតក កេរ្តិ៍ដូនតាខ្លួន ដែលសៀមបានឆក់ប្លន់យកទៅ ... មកវិញ ។ ហើយភាគច្រើនគឺប្រើពាក្យ ឬឈ្មោះជាសៀមដែលបានបកប្រែពីឈ្មោះដើមរបស់ខ្មែរទៅ ដូចជាឈ្មោះបទភ្លេងដ៏ច្រើនដែលយើងខ្ញុំបានរៀបរាប់ក្នុងសៀវភៅល្ខោនខោល ( បោះពុម្ពឆ្នាំ ២000 ដោយជំនួយមូលនិធិតូយូតាToyota Foundation ជប៉ុន ) ជាភស្តុតាង... រហូតដល់មានខ្មែរខ្លះយល់ច្រឡំហៅភ្លេងពិណពាទ្យរបស់ខ្លួន ថាជាភ្លេងសៀមថែមទៀតផង ។ ប៉ុន្តែក្រោយពីការកាត់បន្ថយបាននូវការឈ្លានពានរបស់សត្រូវទាំងសងខាង...ឥទ្ធិពលនេះ ក៏ត្រូវសាបរលាបទៅៗជារៀងរាល់ថ្ងៃ ដោយប្រជាជនខ្មែរមានឱកាសស្វែងយល់ កាន់តែច្បាស់អំពីវប្បធម៌ជាតិរបស់ខ្លួនឡើងវិញ ហើយខំកសាងវប្បធម៌សិល្បៈជាតិរបស់ខ្លួន បន្តពីដូនតាឱ្យបានរីកចម្រើនយ៉ាងខ្លាំងក្លា ។ ពិសេសគឺការរីកចម្រើននៅក្នុងរជ្ជកាលព្រះបាទនរោត្តមសីហនុវរ្ម័ន ( ១៩៤១-១៩៥៥) និងសម័យសង្គមរាស្ត្រនិយម ( ១៩៥៦-១៩៧០) ដែលធ្វើឱ្យពិភពលោកចាប់អារម្មណ៍ និងស្ងើចសរសើរវប្បធម៌សិល្បៈជាតិកម្ពុជា

យ៉ាងខ្លាំង ។ ក្នុងរយៈកាលនេះ ក្រោមរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រីយានី កុសមៈ នារីរត្នន៍ ជាព្រះមាតាព្រះបាទ នរោត្តម សីហនុវរ្ម័ន មិនថាឡើយតែសិល្បៈ របាំ ឬល្ខោនព្រះរាជទ្រព្យ ដែលជាប្រភេទសិល្បៈសក្ការៈសិល្បៈ នៃប្រាសាទទេវស្ថាន ដែលមានប្រភពចេញពីអ្នកប្រាជ្ញរាជបណ្ឌិតដែលបានរីកចម្រើនយ៉ាងខ្លាំង ទាំងបច្ចេកទេសសិល្បៈ ទាំងប្រណីតភាព និងសោភ័ណភាព ទាំងអលង្ការតុបតែងលំអ ដូចជា មកុដធ្វើពីមាសសុទ្ធដាំត្បូងពេជ្រដ៏មានតម្លៃ (ពិសេសគឺមកុដឯក ទាំងសម្រាប់តួនាង ទាំងតួនាយរោង ) ។ល។ នោះឡើយ...ទម្រង់សិល្បៈដ៏ទៃទៀតទាំងអស់ដែលជាសិល្បៈប្រពៃណី សិល្បៈប្រជាប្រិយ សិល្បៈជនជាតិ ដែលមានប្រភពចេញពីប្រជាជនមហាជន ក៏ត្រូវបានព្រះអង្គជំរុញលើកស្ទួយធ្វើការសិក្សាស្រាវជ្រាវចងក្រងតម្លើងឱ្យបានរីកចម្រើនខ្លាំងក្លាដូចគ្នាផងដែរ នៅទូទាំងប្រទេសកម្ពុជាគួរជាទីមោទនៈយ៉ាងក្រៃលែង ។

ប៉ុន្តែជាអកុសលមោទនភាពនេះ បានក្លាយទៅជាសុបិន្តរបស់ខ្មែរគ្រប់ៗរូបយ៉ាងឆាប់រហ័សទៅវិញ ដោយសារសង្គ្រាមបំផ្លាញជាតិដ៏សាហាវ បានចាប់ផ្ដើមនៅឆ្នាំ ១៩៧០ ។

គ្រាន់តែរយៈពេលខ្លីល្មមប៉ុណ្ណោះ ការបែកបាក់ផ្ទៃក្នុងរបស់ខ្មែរនេះ បានជំរុញប្រទេសជាតិកម្ពុជាឱ្យប្តូររបបនយោបាយច្រើនលើកច្រើនសាររហូតដល់ខ្មែរម្នាក់ៗ ស្ទើរតែចាំពុំបាននូវរូបភាពទង់ជាតិនិងភ្លេងជាតិក្នុងរបបនិមួយៗដែលខ្លួនធ្លាប់ឆ្លងកាត់នោះផង ។ ឯវប្បធម៌សិល្បៈ ដែលជាអត្តសញ្ញាណជាតិវិញ បានត្រូវទ្រុឌទ្រោមរលាយរលត់បត់បែន ទៅតាមដំណាក់កាលនិមួយៗនោះដែរ ។ យ៉ាងណាមិញនៅចន្លោះឆ្នាំ (១៩៧០-១៩៧៥) ក្នុងរបបសាធារណៈរដ្ឋខ្មែរ របស់ លន់ ណុល ដែលបានផ្ដួលរលំរបបរាជានិយមទៅ របាំព្រះរាជទ្រព្យដែលធ្លាប់ហៅពីមុនមកហើយ ដែលស្ថិតជាប់ នឹងព្រះរាជាត្រូវគេប្ដូរមកហៅថា : របាំ ឬល្ខោនក្បាច់បុរាណ

វិញ ហើយបង្វែរការទទួលខុសត្រូវ ឱ្យមកនៅក្រោមសកលវិទ្យាល័យវិចិត្រសិល្បៈ ប៉ុន្តែទីតាំងហាត់រៀនផ្នែកបច្ចេកទេសរក្សាទុកនៅដដែលគឺហាត់នៅប្រាសាទច័ន្ទឆាយា ក្នុងព្រះបរមរាជវាំង ។

ក្នុងឆ្នាំ ១៩៧៥-១៩៧៩ ពេលដែលរបបសាធារណៈខ្មែរដួលរលំទៅ របបប្រល័យពូជសាសន៍ "កម្ពុជាប្រជាធិបតេយ្យ" ក៏ឡើងមកកាន់អំណាច ។ ពេលនោះរបាំក្បាច់បុរាណក៏ដូចជាទម្រង់សិល្បៈដទៃទៀត ត្រូវគេលុបបំបាត់ចោលទាំងស្រុងដោយយកលេសថា : ជាមរតកសិល្បៈសក្តិភូមិ ។ សិល្បករ សិល្បការិនីភាគច្រើនត្រូវកាប់សម្លាប់ អ្នកខ្លះត្រូវគេធ្វើទោសទារុណកម្មសម្លាប់នៅគុកទួលស្លែងមានឯកសារនៅភស្តុតាងផង ។ ឆ្នាំ ១៩៧៩-១៩៩៣ ក្រោយពីរបបប្រល័យពូជសាសន៍ដួលរលំទៅ..... ប្រទេសជាតិ និងប្រជាជនកម្ពុជាត្រូវបានសង្គ្រោះដោយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា របបសាធារណរដ្ឋប្រជាមានិតកម្ពុជា រួចប្តូរមករដ្ឋកម្ពុជា បានកាន់កាប់អំណាច ។ ក្នុងរយៈកាលនេះ សិល្បករ និងគ្រូចាស់ៗបន្តិចបន្តួចលើគ្រប់មុខជំនាញដែលសេសសល់ពីស្លាប់បានខិតខំពីបាតដៃទទេ ដោយក្តីលំបាកលំបិនជាទីបំផុត..... ប្រឹងធ្វើឱ្យរស់ឡើងវិញនូវសិល្បៈគ្រប់ប្រភេទ ក្នុងនោះក៏មានរបាំក្បាច់បុរាណខ្មែរ ឬរបាំព្រះរាជទ្រព្យផងដែរ ដែលគេនិយមហៅឈ្មោះថា របាំ ឬល្ខោនក្បាច់បុរាណខ្មែរ ។

ក្រោយឆ្នាំ ១៩៩៣ ពោលគឺពេលដែលសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ដោយមានការបោះឆ្នោតគាំទ្រដោយអង្គការសហប្រជាជាតិ ហើយប្រទេសជាតិត្រូវសម្រេចឱ្យស្ថិតនៅក្នុងរបបរាជានិយម "ព្រះរាជាណាចក្រកម្ពុជា" ជាលើកទី ២ ឡើងវិញនោះ របាំក្បាច់បុរាណនេះ ក៏ត្រូវបានគេនិយមហៅឈ្មោះទាំងពីរគឺល្ខោន ឬរបាំក្បាច់បុរាណខ្មែរ និងល្ខោន ឬរបាំព្រះរាជទ្រព្យរហូតមកដល់សព្វថ្ងៃនេះ ។

# ប្រវត្តិប្រាសាទជាហោ

ដោយ : **សុខ ចេង**

*ទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំទី ៥៦ លេខ ៣ គ.ស ឆ្នាំ ២០០២ បានបោះពុម្ពផ្សាយ គ្របខាងក្រៅនូវរូបប្រាសាទមួយ ដែលមានទីតាំងនៅជាប់ព្រំដែនកម្ពុជាវៀតណាម ក្នុងស្រុក រមាសហែក ខេត្តស្វាយរៀង ។ ក្នុងនោះបានបញ្ជាក់ថា អ្នកឯកទេសខាងប្រាសាទបុរាណ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មិនទាន់ចុះទៅស្រាវជ្រាវ និងមិនទាន់បានចុះក្នុងបញ្ជី សារពើភ័ណ្ឌជាតិនៅឡើយ ។*

*នៅក្នុងលេខនេះ យើងបានសហការជាមួយលោក **សុខ ចេង** ប្រធានការិយាល័យបេតិកភ័ណ្ឌ ខេត្ត ស្វាយរៀង ដើម្បីស្រាវជ្រាវជាជំហានទីមួយ ក្នុងគោលបំណងផ្សព្វផ្សាយ និងថែរក្សាបេតិកភ័ណ្ឌជាតិ ។*



*ប្រាសាទជាហោ*

ប្រាសាទ **ជាហោ** គឺជាប្រាសាទមួយ ដែលមានវ័យចំណាស់ជាងគេក្នុងខេត្តស្វាយរៀង ស្ថិតនៅប៉ែកឥសាន្តនៃទីរួមខេត្ត នៅភូមិព្រៃគ្គី ឃុំគគីរ ស្រុករមាសហែក ចម្ងាយប្រមាណ ៥៨ គីឡូម៉ែត្រ ពីទីរួមខេត្ត។

ប្រាសាទនេះកសាងឡើងក្នុងអំឡុងសតវត្សទី ៦ (លំនាំរចនាបទ សម្បូរព្រៃគុហ៍) សង់លើដីទួលមួយកន្លែងមានកំពស់ ៣ ម៉ែត្រ មានទំហំ ៥០ម៉ែត្រ បួនជ្រុងប្របតាមមាត់ទន្លេជាប់ព្រំប្រទល់ដែនកម្ពុជា វៀតណាម ។វីឯតួប្រាសាទធ្វើអំពី ឥដ្ឋនិងថ្មបាយក្រៀមទំហំ ៤ ម៉ែត្របួនជ្រុង កំពស់ ១០ ម៉ែត្រ ហើយមានទ្វារចេញ-ចូលតែមួយគត់ ពីទិសខាងកើត ក្រៅពីនេះមានសុទ្ធតែទ្វារបង្ហួចបញ្ឆោតបិទជាប់ជញ្ជាំង។ ចំពោះមេទ្វារ មេបង្អួច ក្បាច់ផ្តែរនិងក្បាច់ផ្សេងៗទៀត ធ្វើអំពីដីដុតទាំងអស់ ។

តាមការសាកសួរពីព្រះតេជគុណ **ឯម ហែម** ព្រះជន្ម ៨៥ ព្រះវស្សា ព្រះអង្គជាព្រះចៅអធិការ វត្តគគីរសព្វថ្ងៃ ព្រះអង្គទ្រង់មានពុទ្ធដីកាថា : ព្រះអង្គធ្លាប់ឮចាស់ៗ មានឪពុកម្តាយព្រះអង្គ និងចាស់ព្រឹទ្ធាចារ្យ នៅក្នុងភូមិបានដំណាលដែរថា: ប្រាសាទ **ជាហោ** នេះ គេកសាងសម្រាប់ធ្វើសក្ការៈបូជា (ទេវរាជ ) នៅពេលដែលខ្មែរជំនាន់នោះ កាន់លទ្ធិព្រាហ្មណ៍សាសនា ហើយជាប្រាសាទដែលមានមហិទ្ធិឫទ្ធិខ្លាំងពូកែណាស់ ។ កងទ័ពមុន នឹងចេញទៅធ្វើសឹកសង្គ្រាមម្តងៗ គេនាំគ្នាទៅធ្វើពិធីបួងសួងមុខប្រាសាទ ដើម្បីឱ្យបានទទួលជ័យជំនះ លើពួកខ្មាំងសត្រូវ ។

ព្រះតេជគុណ **ឯម ហែម** មានពុទ្ធដីកាបន្តទៀតថា នៅភូមិព្រៃគ្គី មានលោកតាម្នាក់ឈ្មោះ **ម៉ី** គាត់និយាយថា កាលពីដើមនៅខាងលិចវត្ត*គគីរ* នេះមានវត្តមួយឈ្មោះ វត្ត *ជាហោ* ដែរ ត្រង់វត្ត*ជាហោ* កាលនោះ មានបងប្អូនប្រជាជនខ្មែរនាំគ្នាមកប្រមូលផ្តុំគ្នាជាច្រើនរកស៊ី គ្រានោះ*តាហោ*ក៏បបួលបងប្អូនទាំងនោះ កសាង

បានវត្តមួយ ហើយដាំដើមឫស្សីព័ទ្ធជុំវិញរាប់ពាន់គុម្ពជារបង សព្វថ្ងៃទីវត្តនោះ ក៏រលាយបាត់បង់រូបរាង សល់តែកូនឈើតូចៗ និងដើមឫស្សីខ្លះៗប៉ុណ្ណោះ ។

ចំណេរក្រោយមក ប្រជារាស្ត្រនាំគ្នារុករានត្រង់ទីវត្តនោះ ធ្វើស្រែចម្ការ ភ្ជួរ គាស់កកាយរុករានទៅឃើញវត្ថុបូរាណមួយចំនួនមានគងស្ពាន់ ១ ផ្ទៃទំហំ ២តឹក ចានកណ្ដឹងរូបនាគ និងចានដីដុតមួយចំនួនទៀត បច្ចុប្បន្ន ឧបាសក ឧបាសិកានៅ ទីនោះ នាំគ្នាយកទៅប្រគេនលោកវត្ត*គគីរ*ហើយ ។

ចំពោះប្រវត្តិប្រាសាទឈ្មោះ **ជាហោ** មានរឿងមួយនិយាយតៗគ្នាថា ៖ *តាជាហោ* គាត់ជាមេទ័ពស្ដេចត្រាញ់ម្នាក់ គាត់មានអនុភាពខ្លាំងពូកែណាស់ ចេះ សិល្បវិជ្ជា ហើយនាំរេហ៍ពលទៅធ្វើសឹកសង្គ្រាមម្ដងៗ បានទទួលជ័យជំនះលើពួក ខ្មាំងសត្រូវជានិច្ច ក្រោយមកស្ដេចក៏បញ្ជាឱ្យគេកសាងប្រាសាទមួយឡើង ដែលនៅ ប្របនឹងមាត់ទន្លេ ហើយយកឈ្មោះមេទ័ព*ជាហោ* ដាក់ជា**ប្រាសាទជាហោ** រហូត ដល់សព្វថ្ងៃនេះទៅ ។

បើយើងនិយាយពីប្រវត្តិស្រុកភូមិនៅទីនោះ វាមានឈ្មោះពាក់ព័ន្ធ នឹង រឿងប្រាសាទ រឿងមេទ័ពដូចជា នៅខាងត្បូងឆៀងខាងលិចប្រាសាទចម្ងាយ ៣០០ម៉ែត្រ មានទួលមួយយ៉ាងធំ អ្នកស្រុកហៅថា **ទួលត្រពាំងបន្ទាយ** រហូត មកដល់សព្វថ្ងៃ ។

មួយកន្លែងទៀតនៅខាងលិចប្រាសាទចម្ងាយ១០០ម៉ែត្រ តាមមាត់ច្រាំង ទន្លេទាំងសងខាង គឺត្រើយខាងលិច និងត្រើយខាងកើត ទីនោះអ្នកស្រុកហៅ ឈ្មោះថា **កំពង់ប្រាសាទ** សព្វថ្ងៃព្រៃដុះទ្រប់ទ្រុលគ្មានមនុស្សរស់នៅទេ ។

នៅខាងលិចប្រាសាទចម្ងាយប្រមាណ ៣ គ.ម មានភូមិមួយឈ្មោះថា **ភូមិតាវាំង** កាលពីដើមប្រហែលជាព្រះពន្លារបស់ស្ដេច ដែលមកគង់នៅប្រាសាទ

នោះក៏មិនដឹង ។

ប្រាសាទ**ខាវចោរ**នេះ គាត់ដំណាលថា នៅពេលមុនបារាំងចូលស្រុក ឆ្នាំ ១៨៦៣ តួប្រាសាទនៅមានទ្រង់ទ្រាយដើមស្ទើរតែទាំងស្រុង តែដល់ពេលបារាំងចូលមក ពួកវាបានបាញ់បំបាក់កំពូល និងជីកគាស់រុករើយកវត្ថុមានតម្លៃអស់ជាច្រើន ។ មកដល់សង្គ្រាមសម័យ លន់ ណុល យន្តហោះអាមេរិកទម្លាក់គ្រាប់បែក.គ្រាប់រ៉ុកកែត និងគ្រាប់បេ ៥២ តាមព្រំដែន ដើម្បីបោសសំអាតទ័ពយៀកកុង ពួកវាទម្លាក់មកជិតៗប្រាសាទ ធ្វើឱ្យតួប្រាសាទកក្រើក រញ្ជួយបាក់បែកអស់មួយចំនួនធំ សព្វថ្ងៃតួប្រាសាទនៅសល់តែមួយចំហៀងតែប៉ុណ្ណោះ ។

ចុងក្រោយគឺសម័យបនប្រល័យពូជសាសន៍ ប៉ុល ពត ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ ពួកវាបំផ្លិចបំផ្លាញបន្ថែមទៀត ។

សព្វថ្ងៃនេះ ដោយការយកចិត្តទុកដាក់ពីលោកអភិបាលស្រុករមាសហែក ការិយាល័យវប្បធម៌ស្រុក អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ក្នុងឃុំគគីរទាំងមូល បានទៅបំផុសប្រជារាស្ត្រទៅជួយធ្វើពលកម្ម កាប់ឆ្កាព្រៃក្នុងបរិវេណប្រាសាទ ព្រមទាំងដាំកូនឈើបន្ថែមទៀត ហើយមានឧបត្ថម្ភស្បៀងពីអង្គការ កម្មវិធីស្បៀងអាហារពិភពលោកជូនក្រុមគាត់ ។

សព្វថ្ងៃនេះទៀត មានគណៈកម្មការអភិវឌ្ឍន៍ជនបទ របស់ខេត្តស្វាយរៀង បានជួយធ្វើថ្នល់លំមួយខ្សែ(ចម្ងាយប្រាំគីឡូម៉ែត្រ)ចូលដល់ប្រាសាទទៀតផង មិនតែប៉ុណ្ណោះ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត បានរៀបចំឱ្យមានឆ្មាំចំនួន ៣ នាក់ នៅជួយមើលថែរក្សាការពារ រហូតមកដល់សព្វថ្ងៃនេះ ។

**សេចក្តីសន្និដ្ឋាន :**

ចំពោះប្រវត្តិប្រាសាទជាហោ នៅស្រុករមាសហែក ខេត្តស្វាយរៀង ដែលក្រុមយើងខ្ញុំខំប្រមែប្រមូលរឿងរ៉ាវមកចងក្រងជាប្រវត្តិ ជារឿងពិត ដោយសំអាងថា សព្វថ្ងៃនេះតួប្រាសាទ នៅមានសេសសល់ភាគខ្លះនៅឡើយ យើងគ្រាន់តែពុំដឹងថា តើព្រះនាមស្តេចអង្គណាមួយជាអ្នកកសាងតែប៉ុណ្ណោះ ។

សំណូមពរ : សូមអស់លោកធ្លាប់ដឹងឮ និងចេះចាំរឿងប្រវត្តិប្រាសាទ ជាហោនេះ ឬអស់លោកផ្នែកខាងបុរាណវិទ្យា អញ្ជើញមកស្រាវជ្រាវបន្ថែមទៀត ពីប្រវត្តិប្រាសាទជាហោ នៅខេត្តស្វាយរៀងនេះបន្តទៅទៀតផង ។

យើងខ្ញុំរង់ចាំជានិច្ច ដើម្បីទទួលពតិមានប្លែកៗពីអស់លោកអ្នក ដើម្បីបន្ថែមរឿងប្រវត្តិនេះ ឱ្យកាន់តែសុក្រិតថែមទៀត ។

## ស្រាវជ្រាវដោយ

- *លោក* **អ៊ុច សឿន** *ប្រធាន ការិយាល័យ វប្បធម៌ស្រុករមាសហែក*
- *លោក* **ជួន សាន់** *មន្ត្រី ការិយាល័យ បេតិកភ័ណ្ឌ*

## អ្នកផ្តល់ពត៌មាន

-*ព្រះតេជគុណ* **ឯម ហែម** *(ចៅអធិការវត្តគគីរ)*

-*លោកតា* **នាម ម៉ី** *ប្រជាជន ភូមិព្រៃក្តី ឃុំគគីរ*

# ហេតុអ្វីបានជាអ្នកស្រុកបាកានមិនដាំថ្នាំជក់ ?

ដោយ : មៅ សោភ័ណ្ឌ
រស់ សំណាង

ប្រវត្តិសាស្ត្រនៃទឹកដីខ្មែរ ជាហូរហែរៀងមកបានផ្សារភ្ជាប់យ៉ាងជិតស្និត ទៅនឹងជំនឿជឿលើភាពជាអរូបី ចាប់តាំងអំពីការកកើតទឹកដីមកម្ល៉េះ ។ ប្រពៃណី ជំនឿ.ទំនៀមទម្លាប់ជាប់មកជាច្រើន ត្រូវបានបង្កើតស្មារតីរក្សាយ៉ាងខ្ជាប់ខ្ជួន.សុខ. ស្ងប់.បង្កប់ក្នុងស្រទាប់ប្រជាពលករបន្តហូរហែ តួយ៉ាងដូចជាប្រវត្តិមិនដាំថ្នាំជក់របស់ អ្នកស្រុកបាកានជាដើម ។ តាមការចុះសិក្សាស្រាវជ្រាវតាមរយៈបទសម្ភាសន៍ ជាមួយលោកពូ **ជុំ ឆុន** អតីតចៅអធិការវត្តពោធិ៍មានបុណ្យ លោកតាអាចារ្យ **នេត ឌង់** និងលោកតា **សាំង សៀន** បានធ្វើការបកស្រាយតាមដំណើរនៃការ ចងចាំរបស់គាត់ថា :

កាលពីព្រេងនាយ ប្រហែលជាស្ថិតនៅក្នុងអំឡុង នៃរជ្ជកាលក្សត្រខ្មែរ មួយព្រះអង្គព្រះនាមព្រះបាទសុរិយាវង្ស សោយរាជនៅលើដែនដីនគរកម្ពុជាធិបតីមាន មហេសីជាស្រីគ្រប់លក្ខណ៍ មានកុមារមួយព្រះអង្គជាព្រះរាជបុត្រច្បុតសន្តតិវង្ស ត្រកូល ។ មានដំណាលថា ក្នុងរជ្ជកាលនោះ ស្រុកខ្មែរជួបតែភាពរកាំរកូស មិនស្រុះ រៀបទៀបស្ថិតនៅក្នុងរបៀបរបាំងរបើសគ្រប់អាណាខេត្តនគរ ដូចនេះហើយ ទើប បណ្ដាលឱ្យព្រះមហាក្សត្រចាត់ការ ដោយផ្ទាល់ព្រះអង្គ ចុះតម្រង់ ពង្រាបប្រាប់ ប្រាមតាមបណ្ដាខេត្តខ័ណ្ឌរៀងពេញព្រះនគរ យកតាំងមហេសីនិងរាជបុត្រាយា ត្រាតាមជាប់មិនមានដែលដាច់ ។ លុះសម្រេចស្ដេចយាងមកដល់នាទឹកដី ព្រៃខេត្ត

ពោធិ៍សាត់ ត្រង់សង្កាត់មួយនាស្រុកបាកានក្សត្រក្សាន្ត ទ្រង់សប់ព្រះរាជហឫទ័យ បោះព្រះពន្លាជ័យ នៅប្រ៉បនឹងទួលប្រាសាទពន្ធនៈចេតិយ ដែលទ្រង់សព្វព្រះទ័យសាងដោយក្ដីជ្រះថ្លាគ្រាកន្លងមកយ៉ាងងាយស្រួលនៅក្បែរទឹកស្ទឹង ដែលលាតសន្ធឹងដោយធម្មជាតិដ៏ប្រណីតគួរជាទីចាប់ចិត្ត ម្យ៉ាងជាតំបន់មួយជួយឱ្យងាយស្រួលក្នុងការប្រាស្រ័យការងារនគរជាមួយ និងអាណាប្រជានុរាស្ត្រ និងក្រុមទាហ៊ានរក្សាព្រំដែនខេត្តខ័ណ្ឌនគរ ដែលស្ថិតនៅក្បែរទីនោះផង ។ នឹងចាប់សន្ទនាគ្រាសម័យថ្ងៃមួយដោយព្រះមហាក្សត្រមួយថ្ងៃៗ ជាប់រវល់តែនឹងព្រះរាជកិច្ច ព្រះរាជកុមារព្រះរាជបុត្រា ដោយក្ដីអផ្សុកមិនស្រណុកក្នុងព្រះកាយា ទ្រង់សព្វព្រះទ័យចង់ចេញចរយាត្រា យាងប្រពាតព្រៃកំសាន្តហឫទ័យតាមតំបន់ភូមិស្រុក ទើបទូលរំអុកព្រះមាតា ព្រះបិតា នាំបរិវារចេញចរយាត្រាតាមព្រះហឫទ័យ គន់សព្វព្រឹក្សព្រៃ ភោគផលដំណាំ លូតលាស់ខៀវខ្ចី មានគ្រប់សព្វសារ គ្រប់ ស្លែ សាឡាត់ ខាត់ណា មានផ្លែមានផ្កាគួរជាទីត្រេកត្រអាល រហូតដល់ភ្លេចនឹកសោយព្រះក្រយា ។ លុះថ្ងៃរសៀលព្រះសុរិយា ព្រះកុមារ បានយាងមកដល់ទីចំការមួយ ដែលមានដើមថ្នាំកំពង់លូតលាស់បែកត្រួយ ចោលសន្លឹកធំៗ ខ្លះទុំចាស់ខ្ចី ច្រើនគគោកធ្វើឱ្យព្រះកុមារនឹកភ្ញាក់ព្រះទ័យចង់សោយបារី ដែលបេះសន្លឹកចេញអំពីដើមថ្មីៗ ទ្រង់ក៏យាងចូលទៅក្នុងចំការ ហើយបេះយកសន្លឹកថ្នាំណាទុំល្អល្មមមូរជាបារីសោយយ៉ាងឆ្ងាញ់ ភីលៀងអាមាត្យ ដែលអមហែហមព្រះកុមារគ្មាននរណាម្នាក់ហ៊ានឃាត់ព្រះកុមារបានឡើយ ទើបបណ្ដោយតាមព្រះទ័យរបស់ព្រះកុមារគ្រប់ៗរឿង ។ យាត្រាបណ្ដើរសោយថ្នាំបណ្ដើរយាងមកដល់ពាក់ទីម នឹងស្រះកែវ ( ស្រះព្រះកែវ ) សោយថ្នាំមិនទាន់ទាំងបានអស់មួយបារីផង ស្រាប់តែព្រះសុខភាពព្រះកុមារប្រែជាមានអាការៈ ធីងធោងហេវហត់ ព្រះកុមារក៏យាងចុះទៅក្នុងស្រះក្នុងបំណងក្បង់ទឹកសោយ តែដោយ

អាការៈធីងធោងក៏រអិលជើងនឹងថ្មមួយដុំ ធ្លាក់ទៅក្នុងទឹកផ្អើលអស់ភីលៀងអាមាត្យ សង្វាតស្ទុះទៅចាប់ព្រះកាយដ៏ល្វតល្វន់លើកឡើង ដោយក្តីភិតភ័យគ្រប់ៗគ្នា ។ ដោយក្តីបារម្ភណ៍ភ័យព្រួយអាមាត្យក៏នាំគ្នាលើកស្នួយដាក់លើព្រះស្នែង ហើយសែង បណ្តើររឹតព្រះកាយរបស់ព្រះកុមារបណ្តើរ ធ្វើដំណើរដោយក្តីត្រហេបត្រហបរត់ផង ដើរផងទំរាំឆ្លងបានមកដល់មណ្ឌលទីព្រះពន្លាជ័យនៃព្រះមាតា-បិតា ព្រះអង្គ គ្រានោះ ផ្អើលអស់រាជការសព្វមុខមន្ត្រី ឃ្មាតខ្មីញាប់ដៃជើងរៀបចំតែសព្វៗខ្លួន រីឯព្រះ មហាក្សត្រថ្លៃនិងព្រះនាងជាមហេសីស្លេកស្លាំងស្លុតស្មារតី ស្រែកបញ្ជារខ្ញុំប្រុសស្រី ទៅតាមគ្រូហ្មស្លរដាំ ខ្លះអុជទៀនធូបបែបន់ ខ្លះចិញ្ច្រាំថ្នាំ បញ្ច្រូកជួយដកអាការៈ រោគព្រះកុមារឱ្យបានធូរស្បើយ ។ គួរអនិច្ចាជាការឥតអំពើ ហេតុនៃទង្វើទាំងឡាយ ឆ្ងាយហួស នឹងបរិយាយ ព្រោះវាមិនអាចធ្វើឱ្យព្រះកាយ នៃព្រះកុមារកម្រើកទៀត បានឡើយសម្លេងដង្ហោយ ដោយក្តីសោកសង្រេងបានបញ្ចេញ សម្លេងពេញព្រះពន្លា ជាសញ្ញាបញ្ជាក់ថា វិញ្ញាណក្ខន្ធព្រះកុមារបានយាងចាកចេញទៅហើយ បន្សល់ទុក នៅឡើយតែព្រះកាយទ្រង់តែប៉ុណ្ណោះ ។ ឱ! គួរអនិច្ចាដូចគេចាប់អង្រួនព្រះហត្ថា អង្គក្សត្រាស្តេចផែនដីក្នុងព្រះចិន្តា រំែងក្តុកក្តួលរំជួលហឫទ័យ ដោយក្តីក្រហល់ ក្រហាយស្តាយស្រណោះមិនអស់ព្រះចិន្តា ទ្រង់ព្រះតម្រិះនឹកឡើងវិញទាំងអស់ ព្រោះហាក់នៅស្រស់ៗថ្មីៗ ពាក្យសំដីស្តីតបទៅមកបីដូចជារលកទឹកបន្តឥតបាត់ ឥឡូវស្ងាត់ព្រាត់ ដោយគ្មានត្រឡប់វិញឡើយ ។ ភាពអាឡោះអាល័យលាយឡំ នឹងក្តីសង្ស័យអំពីអាការៈរោគនៃព្រះកុមារមិនស្ងប់ក្នុងព្រះចិន្តា ក្រោយពីប្រារព្ធពិធី ថ្វាយព្រះភ្លើងដល់ព្រះសព្វរួចមក ព្រះមាតា បិតា ទ្រង់បានកសាងព្រះចេតិយ មួយឡើងថ្មីនៅប្រែបនឹងទីប្រាសាទ ដើម្បីតម្កល់ព្រះធាតុតាអេប្រពៃណី ។ ព្រះបាទ សុរិយាវង្ស ទ្រង់បានប្រមូលស្រីស្នំក្រមការជាបរិវារ ដែលបានហែហមព្រះកុមារ

ទាំងអស់មកសួរឡើងវិញសព្វសេចក្តី ទើបទ្រង់វិនិច្ឆ័យគិតថាព្រះកុមារពិតជាត្រូវក្ស័យព្រះសង្ខារ ដោយសារសោយថ្នាំជក់ ក្នុងចំការអ្នកស្រុកយ៉ាងពិតប្រាកដ ។ ដោយក្តីក្រេវក្រោធមោហ៍បាំង ព្រោះខ្ញាល់ដោយបានដឹងពីហេតុការដូច្នេះហើយ ទ្រង់មិនបានបណ្តោយឱ្យយូរការ ក៏ចេញព្រះបញ្ញត្តិ ចាត់ប្រមូលប្រជារាស្ត្រគ្រប់ផ្លា ដែលមានដីចំការមកជួបជុំត្រៀបត្រា ហើយដាក់ពាក្យបណ្តាសា ដោយសន្យាជាមួយសម្លេងស្គរជ័យថា : បើសម្លេងស្គរនេះ ឮទៅដល់ត្រឹមទីជនបទណា ទីនោះនឹងមិនអាចដាំថ្នាំជក់តទៅទៀតឡើយ ហើយបើហ៊ានតែល្មើសនឹងពាក្យបណ្តាសានេះ សូមឱ្យមានសត្វខ្លាចេញមកខាំប្រហារម្ចាស់ចំការ ឬកើតរោគបំផ្លាញដំណាំ មនុស្សកើតជម្ងឺអាសន្នរោគ រាគរូសក្នុងភូមិស្រុកទាំងអស់កុំឱ្យខានឡើយ ។ បន្ទាប់អំពីពាក្យបណ្តាសារបស់ព្រះបាទសុរិយាវង្សមកសម្លេងស្គរជ័យ បានបន្លឺឡើងខ្ទរពេញភូមិបាកាន បានទៅដល់ភូមិ *ត្រពាំងជង* រំលងទៅដល់ភូមិ *បឹងប្រីយ៍ ផ្លូវមាន់* លាន់របួតដល់ភូមិ *អូររំចង* ថ្លង់ដល់ភូមិ *ខ្នាទទឹង បឹងខ្លា ចំការតាញ៉ាំង* ហើយឮសម្លេងខ្លាំងដល់ *បាក់អន្លង់ ដងហាក* ហើយបកមកភូមិ *ក្រឡឹងមាស* និងភូមិ *អារ៉ែនជើងភ្លើង*ទៀត ។ ជាការពិតណាស់តាំងពីដាក់បណ្តាសា ហើយព្រះបាទ សុរិយាវង្សយាងវិលត្រឡប់ទៅកាន់រាជធានីវិញទៅអ្នកស្រុកភូមិខ្លះ ដែលមិនទាន់មានជំនឿនៅល្មើសលួចដាំថ្នាំជក់នៅក្នុងចំការនៅឡើយ ដោយចង់សាកល្បងមើលការពិត ។ ដូចពាក្យបណ្តាសាចារមក សម័យនោះ អ្នកភូមិផ្អើលឆោឡោគ្រប់កន្លែង ព្រោះឃើញសត្វខ្លាចូលមកចាប់កាច់ កគោអូសចូលព្រៃទាំងថ្ងៃ រីឯឃប់ខ្លាវាចូលមកដើររាតត្បាតពេញក្នុងភូមិអុកឡុកគោក្របី ផ្អើលគ្មានស្រាកស្រាន ទើបទាំងអស់គ្នាភ្ញាក់ប្រាណក៏បាននាំគ្នាជាក្រុមកាប់ ដុតបំផ្លាញថ្នាំជក់ចោលអស់លែងស្រណោះ ទើបអស់មានសត្វខ្លាចូលមកបៀតបៀនតទៅទៀត ។ មានរឿងពិតជាក់

ស្តែងមួយតាមការរៀបរាប់ ឱ្យដឹងទាក់ទងនឹងពាក្យបណ្តាសានេះថា : មាន គ្រួសារថ្មីថ្មោងមួយគូរ ទើបនឹងរៀបអាពាហ៍ពិពាហ៍ថ្មីៗ ឪពុកម្តាយខាងស្រីបាន ប្រគល់ផ្ទះមួយខ្នង នឹងដីចំការមួយហិកតាជាចំណងដៃ មិនដឹងជាហេតុភេទអ្វី ស្រាប់ តែបុរសជាប្តីត្រូវជួបនឹងគ្រោះចង្រៃ ដោយត្រូវសត្វខ្លាចាប់ប្រហារហែកឆី ហើយ ចាប់លីយកទាំងសត្វគោកំពុងទឹមភ្ជួរមួយក្បាល អូសចូលព្រៃទាំងថ្ងៃ ធ្វើឱ្យប្រពន្ធ ស្ងួនស្នេហ៍សោកសង្រេងរីងរៃ ស្រែកទ្រហោផ្អើលអស់អ្នកស្រុកភូមិចោមរោម សួររកហេតុការ ព្រោះសង្ស័យដោយឃើញខ្លាចូលមកក្នុងភូមិទាំងថ្ងៃ ក៏រលឹកនឹក ភ្នកដល់ពាក្យបណ្តាសា ក៏នាំគ្នាយាត្រាត្រាច់ដើររកក្រែងមាននរណាហ៊ានលបដាំថ្នាំ ជក់តែរកពុំឃើញសោះ ទាំងអស់ស្ទើគ្រស្បថស្បែតែរៀងៗខ្លួនថាមិនបានដាំទេ ។ រីឯ គ្រួសារជនរងគ្រោះទៀតសោតក៏ត្រូវគេសង្ស័យថា បានលួចដាំថ្នាំជក់តែនាងប្រកែក លុះដល់អង្គុយគិតពិចារណាម្នាក់យូរៗទៅ ក៏ស្រាប់តែនាងនឹកភ្នកឃើញដល់កញ្ចប់ ខ្មៅមួយនៅលើផ្ទះ ដែលនាងបានយកទៅចោល នៅក្នុងដង្កតដើមត្នោតមួយក្នុង ចំការ ក៏នាំអ្នកស្រុកទៅពិនិត្យ ។ មែន... គឺជាកញ្ចប់គ្រាប់ថ្នាំជក់ ដែលឪពុកម្តាយ បានរក្សាទុកមកយូរហើយៗ ភ្លេចដៃទៅឥឡូវត្រូវនាងយកមកចោលត្រូវទឹកភ្លៀង ទឹកសន្សើម ក៏ដុះលូតលាស់បែកសន្លឹកឡើង ខៀវខ្ចីត្រឹមៗចង្កេះ គឺជារឿងនេះ ហើយ ដែលបណ្តាលឱ្យបុរសរងគ្រោះស្លាប់ យ៉ាងអាណោចអាធម៌ ទើបគេនាំគ្នា បំផ្លាញចោលអស់ទៅ ។ តាំងពីអស់ដើមថ្នាំមកខ្លាក៏លែងមកបៀតបៀនទៀត ជាហេតុធ្វើឱ្យអ្នកស្រុកបាកានទាំងមូល កាន់តែជឿនិងខ្លាចរអាកាន់តែខ្លាំងឡើងៗ មិនហ៊ានល្មើសរហូតដល់បច្ចុប្បន្ននេះ ។ ជាក់ស្តែងមានរឿងថ្មីៗមួយទៀតទើប នឹង កើតមានឡើងក្នុងអំឡុងចុង ខែវិច្ឆិកា និងដើមខែធ្នូ ឆ្នាំ ២០០២ នេះឯង តាមការ រៀបរាប់របស់អ្នកគ្រូ **ម៉ុ សំអុល** ជាគ្រូបង្រៀនសាលាបឋមសិក្សាបាកានបានឱ្យដឹង

ថា : មានគេដឹងថា មានជនមកពីចម្ងាយម្នាក់ ក្រោយពីដឹងអាថិកំបាំង អំពីការមិនដាំថ្នាំជក់របស់អ្នកស្រុកបាកានមកគេបានពោលថា: ចង់ដឹងណាស់បើដាំថ្នាំជក់ទៀត (សម្រាប់ពេលបច្ចុប្បន្ន) តើមានខ្លាមកឬអត់ ? ប៉ុន្មានថ្ងៃក្រោយមកក្នុងពេលដែលចាស់ៗមួយក្រុមអង្គុយសំណេះសំណាលពីធមិអាថិស្រាប់តែមានលោកតាចាស់ម្នាក់ដួលបាត់មាត់បាត់កស្លាប់ភ្លាមមួយរំពេច បន្ទាប់មកស្រាប់តែមានលោកតាម្នាក់ទៀតបែរជារាគក្អួត និងមានអ្នកដេកស្លាប់គ្មានមូលហេតុ ទាំងអស់គ្នាមិនទាន់ចាប់អារម្មណ៏ប៉ុន្មានទេ ស្មានតែជារោគរាតត្បាតអ្វីម្យ៉ាងគិតតែអំពីសង្គ្រោះ ដោយរកពេទ្យហ្ម តែលុះដល់ផ្ញើលឃើញមានដានជើងខ្លា ដើរកាត់ផ្លូវរទេះក្បែរភូមិ ទើបគេនឹកសង្ស័យដល់រឿងចាស់ ក៏តាំងនាំគ្នារុករកត្រួតពិនិត្យគ្រប់ចំការ ។ គេបានប្រទះឃើញកូនដើមថ្នាំជក់ពីរ - បីដើមដុះលាយនឹងកូនស្ពៃក្នុងថ្នាលមួយ ។ តើវាច្រឡំពីផ្សារពោធិ៍សាត់ ឬមានគេចង់សាកល្បង ? អ្នកម្ចាស់ចំការក៏មិនបានចាប់អារម្មណ៏ដែរ ។ ក្រោយដែលបោចបំផ្លាញចោលអស់ ទើបស្ងាត់លែងឃើញខ្លា និងមានមនុស្សស្លាប់បន្តទៅទៀត ។

បច្ចុប្បន្ន ថ្វីបើមានអ្នកចំណូលថ្មី មករស់នៅក្នុងភូមិស្រុកបាកានជាច្រើនយ៉ាងណាក្តី( និយាយតែក្នុងចំនួនភូមិដូចបានរៀបរាប់ខាងលើ ) ក៏មិនមានអ្នកណាម្នាក់ប្រកបរបរដាំថ្នាំជក់ទេ ។ ព្រោះគេតែងជួបហេតុចម្លែកៗ ដូចជាមានមនុស្សស្លាប់-ឈឺ ឬ មានសត្វល្អិតបំផ្លាញដំណាំ ។ ហេតុដូច្នេះហើយទើបអ្នកស្រុកបាកានខ្លាចរអាមិនហ៊ានដាំថ្នាំជក់រហូតមកដល់បច្ចុប្បន្ន ។

*ទោះបីជាមានរឿងដំណាលតៗគ្នាពីប្រវត្តិ ដែលប្រជាជនស្រុកបាកានមិនដាំថ្នាំជក់ ឬហេតុដែលបានរៀបរាប់ខាងលើ( ជារឿងសន្និដ្ឋាន) ទើបតែកើតមាន*

*ក្នុងឆ្នាំ ២០០២ យ៉ាងណាក្តី ក៏នេះគ្រាន់តែជារឿងរ៉ាវមួយដែលកូនខ្មែរត្រូវតែយល់ដឹងនិងស្រាវជ្រាវបន្តទៀត ដើម្បីទុកជាឯកសារ សម្រាប់កូនខ្មែរជំនាន់ក្រោយៗទៀត ។*

*អ្នកដែលមិនធ្វេសស្មារតី*

*មិនស្លាប់គំនិត*

*ទោះបីស្លាប់បាត់ទៅហើយ*

*ក៏ទុកដូចជានៅរស់ ។*

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយ ជោតញ្ញាណោ **ជួន ណាត**

# របាំត្រុដិ

ដោយ : **ហ៊ុឹង ទឹម**

របាំត្រុដិនេះ មានគេសម្ដែងជាច្រើនបែប តាមអ្នកភូមិដែលនិយមថាៈ ជារបាំ ដែលស័ក្ដិសិទ្ធិក្នុងការបន់ស្រន់ ទៅទេវតា អារក្ស អ្នកតា ម្ចាស់ស្រុក មានតែនៅក្នុងខេត្តសៀមរាបប៉ុណ្ណោះដែលគេរក្សាទុករហូតមកដល់សព្វថ្ងៃនេះ ។ មានវង់ខ្លះគេសម្ដែងមានគ្នាច្រើនមិនកំណត់ថា ជាតួតំណាងសត្វអ្វី១ឡើយ គេចេះតែចូលរាំទៅ ដោយអ្នកខ្លះ ចេះរាំធ្វើត្រាប់តាមសត្វនេះ ឬសត្វនោះមាន ក្របី ទន្សោង គោ ខ្លា ឈ្លូស ។ល។ គឺសត្វដែលរស់នៅក្នុងព្រៃ ហើយព្រានព្រៃចេះតែរត់ឆ្លេឆ្លាពេញតែវង់ ដោយយកស្នាទៅជន្លួសត្វនេះបន្តិច សត្វនោះបន្តិចតាមចង្វាក់។ ភ្លេងរបាំត្រុដិ ដែលបានយកមកកែច្នៃ ឱ្យទៅជាសិល្បៈមួយមានលក្ខណៈប្រាកដនៅលើឆាកនេះ ដើមកំណើតចេញមកពីឃុំ *បាដាក* ខេត្តសៀមរាប ដែលគេសម្ដែងដើរហែរពីផ្ទះមួយទៅផ្ទះមួយតាមផ្លូវមុនពេលបុណ្យចូលឆ្នាំថ្មីរបស់ខ្មែរយើង ។

ក្នុងឆ្នាំ ១៩៥៩ ខែមេសា ខ្ញុំនិងលោកគ្រូពៅ **យូឡេង** ក្នុងក្រុមល្ខោនជាតិនៃប្រទេសកម្ពុជា បានសម្ដែងរឿង " **រិទ្ធិសែននាងកង្រី** " នៅខេត្តសៀមរាបក៏បានទៅ ស្រាវជ្រាវរបាំត្រុដិនេះនៅឃុំ *បាដាក* ក៏បានយករបាំត្រុដិនេះ ទៅសម្ដែងថ្វាយ **សម្ដេចឪ** នៅប្រាសាទភោជនីយក្នុងព្រះបរមរាជវាំង ។

ព្រះអង្គ (សម្ដេចឪ) ទ្រង់ត្រាស់បង្គាប់ឱ្យធ្វើរបាំត្រុដិនេះឡើងវិញ តែកុំឱ្យបាត់រូបភាព និងខ្លឹមសារដើមរបស់គេ ដោយធ្វើឱ្យមានក្រឡារាំ មានក្បាច់ មានច្រៀង នារីចូលរួមផង ព្រោះរបាំនេះតួសុទ្ធតែបុរស ហើយអ្នកសម្ដែងទាំង ១៨ នាក់ច្រៀងទាំងអស់គ្នា គ្មានឧបករណ៍តន្ត្រីទេ ។

ឯបទចម្រៀងវិញ ក៏បានកែច្នៃថែមថយកាត់កងបញ្ចូលគ្នា ឱ្យមានឃ្លាល្បះ មានវគ្គដើម វគ្គកណ្ដាល និងវគ្គបញ្ចប់ ដូចយើងទាំងអស់គ្នាបានទស្សនារួចមកហើយ ។ សព្វថ្ងៃនេះ របាំត្រុដិក្លាយទៅជារបាំប្រជាប្រិយទៅហើយ ។

**ប្រវត្តិរបាំត្រុដិ**

ពាក្យថា " **ត្រុដិ** " ដែលជាពាក្យផ្ដើមមកពីភាសាសំស្ក្រឹតប្រែថា: ផ្ដាច់ ឬកាត់ផ្ដាច់ គឺសំដៅដល់ការផ្ដាច់ឆ្នាំ ឬការកាត់ផ្ដាច់ឆ្នាំចាស់ ចូលទៅក្នុងឆ្នាំថ្មី ។

**ប្រភពបែបរឿងនិទាន**

អ្នកនេសាទម្នាក់ឈ្មោះ *ប៊ុន* ប្រពន្ធឈ្មោះ *ឧមា* ។ ភូមិលំនៅនៅជិតស្រុកសាវត្ថីជាមនុស្សទាល់ក្រ ដើរបរបាញ់សត្វ និងនេសាទត្រី ។ ថ្ងៃមួយព្រានរៀបចំប្រដាប់ប្រដា ធ្នូ ស្នា ព្រួញ ជ័រឆក់ កាំបិតស្នៀត និងវត្ថុអ្វីៗទៀត តាមទម្លាប់ព្រាន ។ ភរិយាក៏រៀបចំចាត់ចែងម្ហូបចំណី បារី ស្លា ប្រគល់ឱ្យប្ដី ។ ប្ដីចេញដំណើរទៅត្រាច់រង្គាត់កាត់ព្រៃរំលងដងស្ទឹងឆ្ងាយទៅៗ ពុំមានជួបប្រទះម្រឹគណាសោះ ព្រាននេះនឹកថាប្រហែលអស់លោកទេវតារក្សាបំបិទបំបាំង បង្វែងដានមិនឱ្យឃើញហើយ ទើបព្រានរៀបចំប្រដាប់ប្រដា ពលីការ សុំលាភ សុំជ័យឱ្យបានជួបម្រឹគ ។ បួងសួងរួចព្រានដើរទៅមុខក៏ជួបប្រើសមួយភ្លឺឆ្អិនឆ្អៅ រោមសុទ្ធតែសរសៃមាស ស្នែងជាកែវភ្លឺច្រាលរន្ទាល ព្រានត្រេកអរ ហើយលាក់ខ្លួនលបបាញ់បានប្រើសនោះ ។ មកដល់ផ្ទះឃើញប្រើសនោះល្អ ក៏យកទៅថ្វាយស្ដេច ហើយស្ដេចក៏ប្រទានយសដល់នាយព្រានជាចៅហ្វាយខេត្ត ប្រពន្ធជាជំទាវ ។ រឿងនេះហើយបានជាបង្កឱ្យមានក្រុមរបាំ ត្រុដិ បែបរឿងនិទាននេះ រហូតមកដល់សព្វថ្ងៃ ។

**ប្រភពបែបជំនឿអ្នកស្រុក**

គេសម្ដែងរបាំនេះ ដោយមានជំនឿថា ÷

នៅតាមស្រុកជិតឆ្ងាយយូរៗម្ដង រមែងមានសត្វព្រៃចូលមកក្នុងភូមិ

អ្នកស្រុក ប្រសិនបើមានសត្វព្រៃចូលក្នុងស្រុកហើយ នឹងកើតឧបទ្រពចង្រៃបែបណាមួយមិនខាន ។ ហេតុនេះបានជាមានទម្លាប់ថា បើឃើញសត្វព្រៃចូលស្រុកកាលណា គេនាំគ្នាប្រោះព្រំ ប្រេង ម្សៅ ឱ្យសត្វនោះ ហើយសុំពរ សុំជ័យពីសត្វទាំងនោះវិញ ។ ដើម្បីរកឱកាសបង្កក់ប្រសិទ្ធិ ចំពោះសត្វព្រៃ ឱ្យហើយស្រេចក្នុងមួយឆ្នាំៗ យ៉ាងនេះហើយ បានជាអ្នកស្រុកដែលមានជំនឿ ដូច្នេះ ក៏បង្កើតល្បែងត្រុដិនេះឡើង ។ ហេតុនេះ វង់ត្រុដិត្រូវមាន ប្រើស ទន្សោង ក្ងោក សុទ្ធសឹងជាសត្វព្រៃមកបង្ហាញខ្លួន ឱ្យអ្នកស្រុកអ្នកភូមិប្រោះព្រំ ប្រេងម្សៅ ចងដៃអំបោះកម្រងឱ្យទានជាលុយកាក់ទៅធ្វើបុណ្យ រំដោះគ្រោះឱ្យហើយស្រេចតែម្តង ដោយមានជំនឿថាប្រសិនជាមានសត្វព្រៃចូលមកក្នុងស្រុកទៅថ្ងៃមុខ ក៏គេបានប្រកបពិធីនេះរួចស្រេចទៅហើយដែរ ដូច្នេះ គេជឿថា គ្មានចង្រៃឧបទ្រពអ្វី កើតឡើងទៀតទេ ។

របាំត្រុដិមានតួសម្តែង ១៨ នាក់

| | | |
|---|---|---|
| ១- អ្នកចម្រៀងនាំមុខ | ១ នាក់ | |
| ២- អ្នកកាន់ដងដោយ | ១ នាក់ | (ខ្លះហៅថា ដងសន្ទូច) |
| ៣- អ្នកកាន់កញ្ចែឈ្មោល | ២ នាក់ | (ខ្លះហៅថា ដងកញ្ចែ) |
| ៤- អ្នកកាន់កញ្ចែញី | ២ នាក់ | |
| ៥- អ្នកវាយស្គរអារក្ស | ២ នាក់ | |
| ៦- ព្រានព្រៃ | ១ នាក់ | |
| ៧- ទន្សោង | ២ នាក់ | |
| ៨- ប្រើស | ១ នាក់ | |
| ៩- ព្រាយក្រចកវែង | ២ នាក់ | |
| ១០- ក្ងោក | ២ នាក់ | |
| ១១- យក្ខ | ២ នាក់ | |

ក្បួនចេញដំណើរ ហែរបាំត្រុដិ ជារូបភាពរទេះសាឡី



## បទចម្រៀងរបាំត្រុដិ

*បន្ទរ* : អើយ... កំបូង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធជារបាំខ្មែរ
ឆា ឆា វ៉ា សារ៉ាមុំបង វើយ វើយក្រមុំបង ......

*ច្រៀងច្រើនចប់តាមឆាកធំ ឆាកតូច អ្នកចម្រៀងចេញម្នាក់ឯង*

*អ្នកច្រៀង* : អើយ ... ត្រុដិខ្ញុំមកដល់ហើយ ដល់ក្រៅរបង រទេះគោផង ម្ចាស់
សោយចង្រ្កង់ខ្សែទាម .....

*បន្ទរ* : ណា នាង ណា ចង្រ្កង់ខ្សែទាម ...

*អ្នកច្រៀង* : អើយ... ឈរឈប់នៅក្រៅ ស្រែកហៅទៅថ្កាន ជម្រាបសុំទាន ម្ចាស់
សោយព្រលានឈរលេង

*បន្ទរ* : ណា នាង ណា ព្រលានឈរលេង ...

*អ្នកច្រៀង* : អើយ...គ្នាខ្ញុំច្រើនណាស់ គគ្រឹក គគ្រេង សុំព្រលានឈរលេង ម្ចាស់
សោយលេងបានដែរឬទេ ?

*បន្ទរ* : ណា នាង ណា លេងបានឬទេ ?...លេងបាន!! *( ស្រែកពីរដង)*
អើយ... កំបូង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធជារបាំខ្មែរ
ឆា ឆា វ៉ា សារ៉ាមុំបង វើយ វើយក្រមុំបង ......

*រៀបវង់សម្តែងជាស្នែងក្របី (សម្លេងដេញប្រើស ប្រើសរត់ចូលមក កណ្តាលវង់ ព្រានដេញពីក្រោយ)*

*អ្នកច្រៀងពោល* : ប្រើសមួយប្រឹងរត់ ព្រានព្រៃដេញស្ទាត់ ប្រើសភ័យរត់បាត់
ម្ចាស់អើយ ព្រានបាញ់ខុសម្តង .....

*បន្ទរ* : ណា នាង ណា ព្រានបាញ់ខុសម្តង .....

*អ្នកច្រៀង* : អើយ..... ប្រើសឡូកដាក់ព្រាន ព្រានខឹងពេកហោង លើកធ្នូផ្គង

ម្ចាស់សោយប្រើសគេចរត់បាត់ .....*( ប្រើសចូលក្នុង )*

*បន្ទរ* : ណា នាង ណា ប្រើសគេចរត់បាត់ .....

អើយ... កំបូង់ៗអើយនាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធជារបាំខ្មែរ

ឆា ឆា វ៉ា សាវ៉ាមុំបង វើយ វើយក្រមុំបង ......*( ប្រើសចេញ )*

*អ្នកច្រៀង* : អើយ.....ផ្ទើលអស់ពូកយក្ខ ដេញស្ទាក់ចាប់ប្រើស ទៅមុខក្រោយ

ទើសម្ចាស់ អើយ គគ្រឹកពេញព្រៃ

*បន្ទរ* : ណា នាង ណា គគ្រឹកពេញព្រៃ

*អ្នកច្រៀង* : អើយ..... យក្ខយារដាវកាប់ ទង្គិចដាវដាប់ ប្រើសគេចរត់បាត់ម្ចាស់

សោយ ឡកឡឺយដាក់យក្ខ......

*បន្ទរ* : ណា នាង ណា ឡកឡឺយដាក់យក្ខ .....

អើយ... កំបូង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធ ជារបាំខ្មែរ

ឆា ឆា វ៉ា សាវ៉ាមុំបង វើយ វើយ ក្រមុំបង ......*( ព្រានចេញ )*

*អ្នកច្រៀង* : អើយ ..... ព្រាយស្រីក្រចកវែង ចេញរាំទន្ទែង ដេញស្ទាក់ចាប់ម្រឹគ

ម្ចាស់សោយ សន្ធឹកពេញព្រៃ

*បន្ទរ* : ណា នាង ណា សន្ធឹកពេញព្រៃ .......

អើយ... កំបូង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធជារបាំខ្មែរ

ឆា ឆា វ៉ា សាវ៉ាមុំបង វើយ វើយ ក្រមុំបង ......

*អ្នកច្រៀង* : អើយ ..... ក្មោកចេញជួយព័ទ្ធ ប្រើសផុតវាសនា ទន្សោងចេញរ៉ា

ម្ចាស់សោយ ព្រានបាញ់ប្រើសស្លាប់

*បន្ទរ* : ណា នាង ណា ព្រានបាញ់ប្រើសស្លាប់.....

អើយ... កំបូង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធជារបាំខ្មែរ

ឆា ឆា វ៉ា សាវ៉ាមុំបង វើយ វើយ ក្រមុំបង ......

*អ្នកច្រៀង* : អើយ.....ត្រុដិខ្ញុំសូមលាហើយ ចប់ប៉ុណ្ណេះហោង រទេះគោផង ម្ចាស់សោយ រៀបដំណើរទៅ

*បន្ទរ* : ណា នាង ណា រៀបដំណើរទៅ .....

អើយ... កំប្លង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធជារបាំខ្មែរ

ឆា ឆា វ៉ា សាវ៉ាមុំបង វើយ វើយ ក្រមុំបង ......*( បិទបប់)*

*(ច្រៀងចូលក្នុង)*

## អំពីសម្ភារៈរបាំត្រុដិ

១- ដងដោយធ្វើអំពីផ្តៅដំបង ឬឫស្សីពីងពង់ ពត់ឱ្យងប្រវែង ២ម៉ែត្រ ។

២- កញ្ចោធ្វើអំពីផ្តៅដំបង ឬអំពីឫស្សីពីងពង់ ចំនួន ៤ដើម គឺកញ្ចោញី ចំនួន ២ កញ្ចោឈ្មោលចំនួន ២ ដែលមានកំពស់ ២ ម៉ែត្រ ត្រឹមដៃស្នាមកក្រោម ។

ឯកញ្ចោឈ្មោលមានកំពស់ខ្ពស់ជាងកញ្ចោញីចំនួន ០,៨០ម ដៃស្នាដែលពត់ឱ្យកោងរាងដងធ្នូ ដោយចងខ្សែពីចុងម្ខាងទៅចុងម្ខាង រំលេចដោយក្រណាត់ពណ៌ចម្រុះកាត់ជាត្រីកោណ ហើយមានចងចង្រ្កង់តូចធំ (ចង្រ្កង់ដំបែ) និងត្រដោកតូចធំសម្រាប់បញ្ចេញសម្លេងជារទេះគោ ។

- ដងដោយតំណាងឱ្យទូករទេះ និងចន្ទោលរទេះ

- កញ្ចោទាំង ៤ តំណាងឱ្យតួ និងក្រង់ (ទ្រុង) រទេះទាំងមូល

- អ្នកកាន់ស្គរ ២ នាក់ តំណាងឱ្យដុំ នៃកង់រទេះទាំងពីរ

៣- ក្បាលប្រើស សម្ភារៈនេះពិបាកធ្វើពេក គេច្រើនតែយកក្បាលប្រើសដែលមានស្នែងស្រាប់យកមកចងស្ពាយជិះពីលើ ដៃកាន់ស្នែងទាំងពីរ រាំលោតៗ ជាដំណើរក្បាច់ប្រើស ។

- ជាការងាយបំផុត យើងត្រូវយកដីឥដ្ឋមកវាយមកបោកឱ្យទន់ស្អិត សូន្យជារូបរាងក្បាលប្រើស ហាលថ្ងៃឱ្យស្ងួត ទើបយកក្រដាសធម្មតា ជ្រលក់ជ័រការ ឬបាយម៉ានបិតលើរូបនោះ ជាច្រើនជាន់ ហាលថ្ងៃឱ្យស្ងួត ទើបយកកាំបិតមកពុះហែកយកតែក្រដាសដែលមានរូបក្បាលប្រើស ទើបបិទក្រដាសផ្សៃផ្សំថែមលាបថ្នាំហាលថ្ងៃគូរភ្នែកច្រមុះឱ្យស្អាតជាការស្រេច ។

៤- ស្នែងទន្សោង ក៏ធ្វើពុម្ពដីឥដ្ឋ ដូចក្បាលប្រើសដែរ ។

៥- សត្វក្ងោកទាំងពីររូបភាពដើម គេយកកន្ទុយក្ងោកពិត១ មកកាន់រាំតែសព្វថ្ងៃដោយគ្មានកន្ទុយក្ងោក យើងគ្រាន់តែស្លៀកពាក់ ពណ៌បៃតង ហើយនារីរេរាំពត់ពេន ជាកាយវិការក្ងោក អាចសន្មតថាជាក្ងោក ។

៦- ព្រាយស្លៀកពាក់អាវបំពង់វែង យកក្រដាសរឹងពត់ជាក្រចកវែងប្រវែង ០.១៥ ម ពាក់ចងជាប់ នឹងម្រាមដៃសម្រាប់រាំ ។



របាំត្រុដិរៀបទានទង់សង្កែខជារាងស្នែងក្របី

# ល្បែងចោលឈូង ឬ បោះឈូង

ដោយ : **ជួប យាន**

## ១_ លក្ខណៈល្បែង

ល្បែងចោលឈូង ឬបោះឈូង មានលក្ខណៈជាល្បែងប្រជាប្រិយ ។ល្បែងនេះ គេនិយមលេងនៅរដូវចូលឆ្នាំ ឬបុណ្យធំៗផ្សេងៗ ដែលប្រកបដោយក្ដីសប្បាយរីករាយ ។ ប្រជាជនស្រី-ប្រុសទូទាំងប្រទេស ទាំងចាស់ទាំងក្មេង ក្រមុំ កម្លោះ ចូលចិត្តល្បែងនេះណាស់ ។

ល្បែងនេះលាក់បង្កប់ដោយអាថិកំបាំងស្នេហា យ៉ាងជ្រាលជ្រៅបំផុតចំពោះក្រមុំ កម្លោះ *ឧទាហរណ៍*: បទចម្រៀងមានពាក្យថា " កែវព្រលឹង - ប្រុសពន្លកជាដើម..." ដែលជាគន្លឹះទាក់ទាញអារម្មណ៍ទឹកចិត្ត ក្រមុំ កម្លោះ ឱ្យស្ថិតនៅក្នុងភាពត្រជាក់រហ៊ឹម និងផ្អែមល្ហែមជានិច្ច ។

## ២_សម្ភារៈលេង (ឈូង)

សម្ភារៈលេងក្នុងល្បែងចោលឈូងនោះ ងាយបំផុត គឺគេគ្រាន់តែយកក្រមា ឬកំណាត់សំពត់មកមូរឆ្មូលឱ្យមូល ចងក្របួចឱ្យតឹងណែន ទុកចុងបន្តិចជាកន្ទុយសម្រាប់កាន់បោះរកគ្នាទៅវិញទៅមក ។

## ៣_វិធីលេង

ជាដំបូងយុវជន-យុវនារីក្នុងភូមិ ដើរបបួលគ្នីគ្នា ឱ្យបានយ៉ាងតិចបំផុតចំនួន ១០ នាក់ ហើយចែកជាពីរក្រុមស្មើគ្នា គឺខាងស្រីមួយក្រុម ខាងប្រុសមួយក្រុម ។ ក្រុមទាំងពីរនេះ ឈរទល់មុខគ្នា ដោយចម្ងាយពី ៨ ម៉ែត្រ ទៅ ១០ ម៉ែត្រ

ពីគ្នាដើម្បីងាយស្រួលចោលឈូងទៅវិញទៅមក ។

ពេលឈរតម្រៀបគ្នាជាជួរស្រួលបួលហើយ ក្រុមខាងប្រុសចាប់ឈូងបោះទៅឱ្យខាងក្រុមនារី ។ ក្រុមខាងនារីចាំចាប់កុំឱ្យឈូងធ្លាក់ដល់ដី ។ កាលបើធ្លាក់ដល់ដី គេថា "ស្អុយ" ខាងនារីត្រូវរើសបោះទៅខាងប្រុសវិញ ។ ពួកខាងប្រុសក៏ត្រូវប្រុងចាប់កុំឱ្យធ្លាក់ដល់ដីដែរ ។

កាលណាឈូងត្រូវបានបុរស ឬនារីចាប់បាន ពេលនោះ គេមានសិទ្ធិគប់សំដៅទៅរកបុរស ឬនារីណាម្នាក់ដែលខ្លួនពេញចិត្ត ។ តាមទំនៀមកាលបើគប់ត្រូវនរណាម្នាក់ហើយអ្នកនោះ ត្រូវច្រៀង-រាំ នាំយកឈូងទៅជូនអ្នក ដែលគប់ត្រូវខ្លួនដោយមិនប្រកាន់គ្នាឡើយ ។

ចំពោះការច្រៀងរាំ ក្នុងក្រុមនារីក៏ដូចជាបុរសអាចចាត់តាំងអ្នកណាម្នាក់ក្នុងក្រុម ដែលមានវោហារនិងសម្លេងល្អ ឱ្យច្រៀង-រាំ ជំនួសក្រុម ឯអ្នកឯទៀតចាំបន្ទរចុងបទ ។

## ៤_ទំនុកច្រៀង

ទំនុកច្រៀង ដែលធ្លាប់ច្រៀងលេងក្នុងពិធីចូលឆ្នាំគន្លងមកមាន ៤ បទ តាមលំនាំដែលក្រសួងវប្បធម៌ ធ្លាប់ផ្សព្វផ្សាយតាមវិទ្យុជាតិ ។

*បទទីមួយ : ឈ្មោះបទ* ***ចោលឈូង ឬបោះឈូង***

*ស្រី* : អូនបោះឈូងទៅ ថ្លៃអើយឈូងបែកជាប្រាំ

ខែចេត្រចូលឆ្នាំ ថ្លៃអើយចាំចាប់ឈូងស្រី ។

*បន្ទរ* : ថ្លៃអើយចាំចាប់ឈូងស្រី ...

*ប្រុស* : បងបោះឈូងទៅ ថ្លៃអើយឈូងបែកជាបួន

ស្រីណាមានខ្លួន ថ្លៃអើយចាំចាប់ឈ្លូងបង ។

*បន្ទរ* : ថ្លៃអើយចាំចាប់ឈ្លូងបង...

*បទទីពីរ : ឈ្មោះបទ* ***ប្រុបកែ***

*ស្រី* : អូនបោះឈ្លូងទៅ ថ្លៃអើយឈ្លូងទើលើចុងដូង

កម្លោះឈរច្រូង ហាអើយៗអឹងអើយ ចាំទទួលឈ្លូងអូន ។

*បន្ទរ* : ចាំទទួលឈ្លូងអូន ...

*ប្រុស* : បងបោះឈ្លូងទៅ ថ្លៃអើយឈ្លូងទើលើចុងឫស្សី

ស្រីណាមិនចេញស្តី ហាអើយៗអឹងអើយ ចាំទទួលឈ្លូងបង ។

*បន្ទរ* : ចាំទទួលឈ្លូងបង ...

*ស្រី* : អូនបោះឈ្លូងទៅ ថ្លៃអើយឈ្លូងខ្ពស់ចុងស្វាយ

ប្រុសណាពោះម៉ាយ ហាអើយៗអឹងអើយ ចាំទទួលឈ្លូងស្រី ។

*បន្ទរ* : ចាំទទួលឈ្លូងស្រី ...

*ប្រុស* : បងបោះឈ្លូងទៅ ថ្លៃអើយឈ្លូងខ្ពស់ចុងសង្កែ

តាំងពីកើតពោះម៉ែ ហាអើយៗអឹងអើយ មិនដែលឃើញឆ្កែ

ស្លៀកខោ។

*បន្ទរ* : មិនដែលឃើញឆ្កែស្លៀកខោ ...

*បទទីបី : ឈ្មោះបទ* ***កំដរឈ្លូង***

បទទីបី គឺជាបទដែលខាងចាញ់ ត្រូវច្រៀងជូនឈ្លូងទៅឱ្យខាងឈ្នះ ។

*ប្រុស* : ហាអើយអឹងអើយ ឆ្នាំចាស់ផ្លាស់ទៅ ថ្លៃអើយឆ្នាំថ្មីចូលដល់

*បន្ទរ* : ឱណាកែវៗអើយ ! ឆ្នាំថ្មីចូលដល់ ...

- ហាអើយអឹងអើយ ប្រជាប្រុសស្រី ថ្ងៃអើយស្បៀកពាក់តាមប្រពៃណី .

*បន្ទរ* : ឱណាកែវ១អើយ ! ស្បៀកពាក់តាមប្រពៃណី ...

*ស្រី* : ហាអើយអឹងអើយ ញាតិមិត្តមូលមីរ ថ្ងៃអើយនាំគ្នាសប្បាយ ។

*បន្ទរ* : ឱណាកែវ១អើយ ! នាំគ្នាសប្បាយ ...

ហាអើយអឹងអើយ ជួបជុំជិតឆ្ងាយ ថ្ងៃអើយដើរលេងកំសាន្ត ។

*បន្ទរ* : ឱណាកែវ១អើយ ! ដើរលេងកំសាន្ត ...

*បទទីបួន : ឈ្មោះបទ* ***ភីសាវង់***

*ប្រុស* : ភីសាវង់១ ណាអូនអើយ ឆ្នាំថ្មីបវរ ( ស្ទួន)

យើងខ្ញុំប្រជា សូមអបអរ ភីសាវង់១ ណាអូនអើយ ទទួលអំណរ ថ្ងៃចូលឆ្នាំថ្មី ... ។

*បន្ទរ* : ទទួលអំណរ ថ្ងៃចូលឆ្នាំថ្មី ...

*ស្រី* : ខ្ញុំសូមលើកដៃឡើងជូនពរ ភីសាវង់១ ណាបងអើយ

សូមបានប្រទះ តែក្តីសុខសាន្ត ... ។

*បន្ទរ* : សូមបានប្រទះ តែក្តីសុខសាន្ត ...

*ប្រុសស្រី* : ជយោ! ជយោ! ចូលឆ្នាំថ្មី ភីសាវង់១ ណាមិត្តអើយ នាំសុខសួស្តី ឆ្នាំជ័យជំនះ ឱណាឆ្នាំសន្តិភាព

**សេចក្តីសន្និដ្ឋាន :**

ល្បែងចោលឈូងនេះ តាមខ្ញុំពិនិត្យសង្កេតពីវិធីលេងនៅភូមិខ្ញុំឃើញមានពីរប្រភេទ ។

*ប្រភេទទីមួយ : **គេលេងឈូងបោះ ឬឈូងចោល***

អ្នកត្រូវលេង សុទ្ធតែឈរទាំងអស់គ្នា គឺប្រុសម្ខាង ស្រីម្ខាង ។ ពួកខាងប្រុស បោះឈូងទៅឱ្យខាងស្រី បើខាងស្រីចាប់បាន ត្រូវចោលឈូងតម្រង់ទៅខាងប្រុសណាម្នាក់ដែលខ្លួនពេញចិត្ត ។ បើត្រូវត្រង់ខ្លួនប្រុសណាម្នាក់ហើយ ពួកខាងស្រីៗនាំគ្នាទៅចាប់ទាញអូសយកប្រុសនោះ មកទុកក្នុងវង់របស់ខ្លួនធ្វើជាខ្ញុំបម្រើ ។ បន្តមកទើបបោះឈូងទៅឱ្យខាងប្រុសវិញ បើខាងប្រុសចាប់បានត្រូវលោះយកគូកនខ្លួនពីខាងស្រីមកវិញ ហើយបោះឈូងទៅឱ្យខាងស្រីវិញ ។

គេលេងរបៀបនេះ ទៅវិញទៅមករហូតដល់ម៉ោងសម្រាក ។ ល្បែងនេះឈ្នះ ឬចាញ់នៅលើក្រុមណា ដែលចោលឈូងទៅត្រូវច្រើនជាងគេ។ គឺបើខាងប្រុសមកនៅខាងស្រីច្រើន ហើយលោះគូកនខ្លួនទៅវិញពុំបាន ខាងស្រីត្រូវឈ្នះ ។

អ្នកលេងល្បែងនេះ មានចិត្តរីករាយសប្បាយណាស់ ដោយក្រមុំ កម្លោះបានកៀកជិតស្និទ្ធិ និយាយស្ដីជាមួយគ្នាយ៉ាងរួសរាយ និងរាក់ទាក់បំផុត ។

*បទទីពីរ: **លេងឈូងច្រៀង***

លក្ខណៈលេងចែកជាពីរពួក ដូចឈូងចោលដែរ ប្លែកតែត្រង់មិនគប់ ឬចោលគ្នាទៅវិញទៅមកប៉ុណ្ណោះ ។ ប្រសិនបើខាងប្រុសចាប់បាន ក្រុមខាងស្រីត្រូវរាយទំនុកច្រៀងផ្សេងៗ ។ បើខាងស្រីចាប់បានវិញ ត្រូវខាងប្រុសច្រៀងម្ដង ។ ឯទំនុកច្រៀង មានលំនាំដូចបរិយាយរួចមកហើយ ។

លក្ខណៈឈ្នះ ចាញ់ នៅត្រង់ខាងណាចាប់ឈូងបានច្រើនជាងគេ ហើយមានសិទ្ធិប្រើខាងចាញ់ឱ្យច្រៀងច្រើនជាងគេដែរ ។

# កំណាព្យ ខ្មែរ

ដោយៈ **យ៉ាន់ ប៊ុរិន**

កំណាព្យមានសម្ផស្សដោយឡែក តាមលក្ខណៈនៃជាតិសាសន៍នីមួយៗ ។ ដូចនេះគេមិនអាចកំណត់ថា កំណាព្យជនជាតិនេះល្អជាងជនជាតិនោះទេ គឺវាសម្រប តាមលក្ខណៈវប្បធម៌ នៃជាតិសាសន៍នោះ ។

*ឧទាហរណ៍:* ខ្មែរនិយមកំណាព្យរបស់ខ្លួន ព្រោះវាបម្រើដល់ការអប់រំ សីលធម៌ ចរិយាធម៌ ព្រហ្មវិហារធម៌ នៃសង្គមខ្មែរ ។ រីឯជាតិសាសន៍ដទៃក៏ដូច្នោះ ដែរ ។

**ប្រភពនៃកំណាព្យ:**

កំណាព្យមានប្រភពមកពីភាសា នៃពាក្យជួនរណ្ដំ ពាក្យជួនរណ្ដំធ្វើឱ្យទឹក ចិត្តរំភើបជាងពាក្យធម្មតា ។

*ឧទាហរណ៍ :* ម៉ែមកពីស្រែរួតរះទៅផ្សារ ព្រោះតាចង់ពិសារត្រីឆ្អើស្ងោរជ្រក់ ម៉ែ-ស្រែ ផ្សារ-ពិសារ ឆ្អើស្ងោរ នេះហៅថា ពាក្យជួនរណ្ដំ អាស្រ័យដោយពាក្យជួន រណ្ដំនៅក្នុងភាសានេះហើយ ទើបអ្នកប្រាជ្ញទាំងឡាយជ្រើសរើសរកពាក្យល្អមក តាក់តែងកែខៃ ច្នៃជាពាក្យកាព្យ ឬកំណាព្យនេះឡើង ដោយកំណត់ឃ្លាប្រយោគ ព្យាង្គ សូរជួនរណ្ដំ មានកម្រិតនិងលក្ខណៈតភ្ជាប់ពីរបះមួយទៅរបះមួយ បង្កើត ឡើងដោយទឹកចិត្តរំភើប និងធ្វើឱ្យអ្នកអាន អ្នកស្ដាប់រំភើបផងដែរ ។

*ឧទាហរណ៍:*

មេឃភ្លឺងឹត ផ្ការលាន់ក្នុងចិត្ត រងំឥតសូរ

ស៊ីងជន់ស្ងួតចែស ភ្នំប្រេះជាអូរ ទឹកភ្នែកជន់ជោរ
ហូរលិចភូមិស្ថាន ។
បក្សីប្រែដើរ ម្រឹគប្រែហោះហើរ ត្រីលង់ស្លាប់ប្រាណ
ផ្ទះក្លាយជាខ្ទម ទ្រុឌទ្រោមវិមាន យំសោកស្រែកឃ្លាន
ទូញថ្ងូរក្នុងចិត្ត ។

ដូច្នេះកំណាព្យ គឺជាសិល្បៈនៃការសរសេរ ដែលបានកំណត់នូវពាក្យ ឃ្លា របះ របះខ័ណ្ឌ និងសួរចាប់ ចុងជូនតភ្ជាប់រណ្តំណែងណង ពីឃ្លាមួយទៅឃ្លាមួយ ពីរបះខ័ណ្ឌមួយទៅរបះខ័ណ្ឌមួយ យ៉ាងជក់ចិត្តបំផុត ។

តាមការស្រាវជ្រាវ គេបានបែងចែកកំណាព្យខ្មែរជាបួនសម័យកាលធំៗ:

**ទី១ សម័យកាលនគរភ្នំ:** (សម័យកកើតទឹកដីដំបូងសតវត្សទីមួយ) មានមួយបទ គឺបទមេបួន ។

**ទី២ សម័យចេនឡា :** (សតវត្សទី ៦ ) មានមួយបទ គឺបទបវ្បាវត្ត

**ទី៣ សម័យមហានគរ :** (សតវត្សទី៩ ដល់ ១២) មានចំនួន៥បទគឺ កាកគិត ព្រហ្មគិត ពំនោល បន្ទោលកាក និងភុជង្គលីលា ។

**ទី៤ សម័យក្រោយអង្គរ លង្វែក ឧត្តុង ចតុមុខ:** មានបទដូចជា បទពាក្យ ៦. ពាក្យ ៧. ពាក្យ ៨. ពាក្យ ៩. ពាក្យ ១០. ពាក្យ ១១.គោព័ទ្ធស៊ឹង សិង្ហតោលេងកន្ទុយ កង្កែបលោតកណ្តាលស្រះ កង្កែបលោតស្លាក់ពេជ្រ ម្កុរខ្ទាក់កែវ រមាំងដើរព្រៃ រលកយោលយាវ រលកផ្ទប់ច្រាំង នាគកៀវក្រវាត់ សុក្រទិនវិលាស ថយក្រោយចូលព្រែក ព្រះច័ន្ទបាំងឆត្រ និងសារថីទាញរថ ។ល។ ដែលសរុបរបៀបសរសេរមាន ៥៣ របៀបសូត្រមាន ៦០ ។

**តួនាទីកំណាព្យក្នុងសង្គមខ្មែរ :**

យើងសង្កេតឃើញថា កំណាព្យមានតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមខ្មែរ បម្រើឱ្យការអប់រំ និងការសប្បាយរីករាយ ទំនាក់ទំនងផ្សេងៗ ដែលជម្រៅភាសា ដួងចិត្ត អណ្ដែតអណ្ដូង ថ្នាក់ថ្នម លួងលោម អាណិតអាសូរ ស្រណោះស្រណោក បង្កើតឡើងនូវទឹកចិត្តមេត្តា ករុណា អនុគ្រោះ យោគយល់ និងសាមគ្គីភាពយ៉ាងខ្ពង់ខ្ពស់ ។ ពាក្យពេចន៍នៅក្នុងចម្រៀង ក៏សុទ្ធជាពាក្យឃ្លោងចេញមកពីកំណាព្យទាំងអស់ ។

**ភាពអន់ថយនូវឥទ្ធិពលរបស់កំណាព្យនាពេលបច្ចុប្បន្ន :**

កត្តាចម្បងគឺសង្គ្រាមរ៉ាំរ៉ៃរយៈពេល ៣០ ឆ្នាំនៃសម័យយើងនេះ ។ សូរស័ព្ទសូត្រកំណាព្យតាមវត្តអារាម តាមសាលារៀន ដែលបង្កប់នូវខ្លឹមសារអប់រំ យ៉ាងខ្ពស់ ។

*ឧទាហរណ៍* : បទព្រហ្មគីតិ (ខ្លឹមសារអប់រំ)

កូនអើយខំរកស៊ី គិតការកេរ្តិ៍ឱ្យថៃថ្នូន
កុំខំតែតែងខ្លួន ដើរតែលេងឥតអំពើ ។
ទំនេរកាប់ឫស្សី ត្បាញជាល្អីតៅកញ្ជើ
កុំឱ្យស្រីស្ដីលើ ឥតអំពើធ្វើលេងទៅ ។

បទកាគតិ (ខ្លឹមសារពិពណ៌នាសម្រស់)

កាយកើតអស្ចារ្យ អំពីផ្កាកា ជិការសោភី
ភក្ត្រាសោភ័ណ ដូចច័ន្ទបូណ៌មី សក់ដូចភ្មមរី
រលើបខ្មាញ់ខ្មៅ ។
នលាតពណិស ដូចពពិលមាស ទំទែងផ្ទិនឆ្អៅ
មើលមាត់ញញឹម បប្រិមឥតសៅ ខឹមខិនកាន់នៅ
សំដីសមសួរ ។

សព្វថ្ងៃរបៀបសូត្រ និងពាក្យពេចន៍ទាំងអស់នេះ មិនមាននៅក្នុងដួងចិត្ត នៃកុលបុត្រខ្មែរយើងទៀតទេ សូម្បីតែគ្រូបង្រៀនតាមសាលានានា ទូទាំងប្រទេស ក៏មានយ៉ាងតិចតួចបំផុត អ្នកដែលចេះ បង្ហាត់សិស្សឱ្យសូត្រកំណាព្យបទ តូចៗដូច ជាបែបក្មេង បែបរាស់ជាដើម ។

កំណាព្យពិតជាកេរមរតកវប្បធម៌ជាតិមួយ ដែលបុព្វបុរសយើងបានថែរក្សា និងខិតខំរិះរកទាំងរបៀបសរសេរ និងរបៀបសូត្រយ៉ាងសម្បូរបែប ផ្តល់ទុកឱ្យយើង ដល់សព្វថ្ងៃ ។ បើសិនជាបាត់បង់ ពិតជាគួរឱ្យសោកស្តាយ និងអាម៉ាស់បំផុត សម្រាប់ជំនាន់យើងនេះ ។

**សំណូមពរ** : រាជរដ្ឋាភិបាល ក្រសួងអប់រំ ស្ថានីយវិទ្យុ ទូរទស្សន៍ និងបណ្តាញ ផ្សព្វផ្សាយជួយទ្រទ្រង់នូវការផ្សព្វផ្សាយ ឱ្យបានទូលំទូលាយអំពីកំណាព្យខ្មែរ ទាំង របៀបសរសេរ និងរបៀបសូត្រ ទើបកេរមរតកជាតិដ៏កម្រនេះ ស្ថិតស្ថេរគង់វង្សបាន ។

*ការសិក្សា ជាអង្គការរបស់ជាតិ ។*

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយ ជោតញ្ញាណោ **ជួន ណាត**

<u>កំណាព្យ</u>

# កើតមកជាមនុស្ស

(បទកាកគតិ)

ដោយៈ **សៅ ជារឿន**

- កើតមកជាមនុស្ស កុំរឹងកុំរូស
កុំធ្វើជនពាល កុំបោកកុំប្រាស
កុំឆ្កុះកុំឆ្មៀល កុំដើរតិះដៀល
មិនធ្វើការងារ ។
- កើតមកជាមនុស្ស កុំលង់កុំលុះ
អំពើពាលា កុំដើរលួចប្លន់
នោះអន់គ្រប់គ្រា ចាប់បានវេទនា
ជាប់គុកច្រវាក់ ។
- កើតមកជាមនុស្ស កុំមានចិត្តទ្រុស្ត
កុំដើរកាប់ចាក់ កុំធ្វើជាចោរ
សាមាន្យអបលក្ខណ៍ គេបាត់លុយកាក់
គេជេរផ្ដាសា ។
- កើតមកជាមនុស្ស កុំគិតតែគួស
ផ្លូវខុសនោះណា លួចគោក្របី

ម្ចាស់គេឈឺផ្សា កុំចិត្តឫស្យា

ប្រហារគេឯង ។

- កើតមកជាមនុស្ស កុំឱ្យពន្យុះ

កុំដើរលេងល្បែង កុំផឹកប៉ៅឡៃ

ដេកដួលគេសែង គ្រួសារចំបែង

ព្រោះក្រែងខ្លួនស្លាប់ ។

- កើតមកជាមនុស្ស កុំដើរជជុះ

ឱ្យគេឈឺចាប់ កុំធ្វើអាក្រក់

ថ្ងៃក្រោយគង់យ៉ាប់ កុំអុជអាលប្រាប់

កើតរឿងឈ្លោះគ្នា ។

- កើតមកជាមនុស្ស ចេះបែងចែកពុះ

គ្រប់ពេលវេលា ប្រព្រឹត្តតែល្អ

រួបរួមសាមគ្គា នោះទើបយូរយា

ស្គាល់ត្រើយសុខសាន្ត ។

- កើតមកជាមនុស្ស ដើរតាមគំនូស

ចាស់ពីបុរាណ កាន់យកសីលទាន

ធម៌អាថិជាប់ប្រាណ ដើរតាមលំអាន

ព្រះពុទ្ធប្រដៅ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធសាសនបណ្ឌិត្យ
ចូល
លេខ ...[illegible]... ម៉ោង ...[illegible]...
ថ្ងៃទី ...[illegible]... ខែ ...[illegible]... ឆ្នាំ ...[illegible]...
បញ្ជូន..................

ក្រសួងធម្មការ និង សាសនា

លេខ ...[illegible]... ធ.ក.ស

## សេចក្ដីប្រគេន និងជូនដំណឹង
## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សូមប្រគេន ទូលថ្វាយ និងជំរាបជូន ព្រះតេជគុណ សម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ព្រមទាំងពុទ្ធបរិស័ទក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា :

ព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្ដេចព្រះសង្ឃរាជគណមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា មានមហាកិត្តិយសទទួលនូវគ្រឿងឥស្សរិយស "**អគ្គមហាសទ្ធម្មជោតិកធជ**" ពីរាជរដ្ឋាភិបាលនៃសហភាពភូមា តាមប្រកាសលេខ ១/២០០៣ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៣ ។

ពិធីនិមន្តថ្វាយ និងប្រគល់គ្រឿងឥស្សរិយស ត្រូវបានកំណត់ប្រារព្ធពិធីនៅក្រុងយ៉ាងហ្គូន មហាមណ្ឌលវិបស្សនានៃតំបន់ Kaba-Aye Estate ប្រទេសភូមា នាថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ២០០៣ ។

អាស្រ័យហេតុដូចបានប្រគេន ទូល-ថ្វាយ និងជំរាបជូនខាងលើ សូមព្រះតេជគុណ សម្ដេច ទ្រង់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ព្រមទាំងពុទ្ធបរិស័ទទាំងអស់ មេត្តាជ្រាបជាពតិមាន។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

ជា សាវឿន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៣/០២៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់ ចុតហ្មាយរបស់ព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៣ )

តែងតាំង

ព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ

ព្រះរាជាគណៈថ្នាក់ទោ នៃគណមហានិកាយ

ជា

សម្តេចព្រះឧត្តមមុនី

នរោត្តម សីហនុ

ពរល.០៣.០១.០២៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣

# វឌ្ឍនភាពថ្មីៗ នៃវិទ្យាសាស្ត្រទំនើប លើកកំពស់វិសេសភាពនៃពុទ្ធសាសនា

ដោយ : ព្រះតេជព្រះគុណ

**ធេរគោន សារនរ មហាថេរ**

ស្ថាបនិក/សង្ឃនាយក/ប្រធានរដ្ឋបាល នៃពុទ្ធមណ្ឌល

វិបស្សនា ប្រទេសសិង្ហបុរី

អ្នកវិទ្យាសាស្ត្រដ៏ឆ្នើម ដែលមានចក្ខុវិស័យរឹងមាំ មិនញញើតចំពោះ តថភាពនៃជីវិត និងសកលលោកធាតុ គឺព្រះភគវន្តសម្មាសម្ពុទ្ធបរមគ្រូ ។ ព្រះអង្គ ពុំមានឧបករណ៍ និងបរិក្ខារជឿនលឿនដូចអ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវសម័យ ទំនើបប្រើប្រាស់ប្រចាំថ្ងៃទេ ។ ហើយព្រះអង្គក៏ពុំបានប្រើសម្ភារៈមន្ទីរពិសោធន៍ ទំនើប ដែលអ្នកវិទ្យាសាស្ត្រសព្វថ្ងៃប្រើប្រាស់ដែរ ។ ប៉ុន្តែព្រះអង្គមានមធ្យោបាយ ស្រាវជ្រាវពិសេស ដែលគ្មាននរណាម្នាក់ក្នុងសកលលោកធាតុទាំងមូល អាចធ្វើបាន នោះ គឺបដិវេធញាណដ៏អស្ចារ្យរបស់ព្រះអង្គ ។

ព្រះពុទ្ធទ្រង់ជាសាស្តាតែមួយអង្គគត់ ដែលបានប្រកាសនូវប្រព័ន្ធគំនិត ដែលមិនញញើតរួញរា សូម្បីតែបន្តិចបន្តួច នៅចំពោះមុខការស្រាវជ្រាវវិទ្យាសាស្ត្រ សម័យសព្វថ្ងៃនេះ ។

បច្ចុប្បន្នវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា-ភ្លោះរបស់វា រីកដុះដាលយ៉ាង លឿនក្រៃលែង ។ ផលិតផលទំនើប មួយចំនួនរបស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

កើតឡើងជាបន្តបន្ទាប់យ៉ាងលឿនគួរឱ្យឆ្ងល់ និងភ្ញាក់ផ្អើលក្នុងចិត្ត ដែលធ្វើឱ្យមនុស្សពិបាកសម្រួលទៅតាមការផ្លាស់ប្តូរទាំងនោះជាខ្លាំង ។ លទ្ធផលមួយចំនួននៃការរកឃើញវិទ្យាសាស្ត្រទាំងនោះ ទាមទារនូវការផ្លាស់ប្តូរគំនិត និងអាកប្ប-កិរិយាជាប្រពៃណី ។

នៅក្នុងដំណើរការនេះ គំនិតអស្មិមានះនៃជំនឿសាសនាមួយចំនួន ដែលបង្កើតឡើងលើទស្សនៈនៃអាត្មន ដែលអាចបំបែកពីគ្នាបាន និងជំនឿលើការបង្កើតរបស់អាទិទេព ក៏បានចាប់ផ្តើមទន់ខ្សោយ និងរង្គោះរង្គើ ។ អរុណោទ័យដ៏ត្រចះត្រចង់នៃវិទ្យាសាស្ត្រថ្មី បានចាប់ផ្តើមបង្ហាញឱ្យឃើញនូវយុគសម័យមួយ នៃអន្តរភាពកាន់តែរីកដាលជានិច្ចសម្រាប់ទស្សនៈសាសនាមួយចំនួន ដែលបានបង្កើតឡើង ដោយផ្អែកលើគំនិតបំភាន់មិនសមហេតុផល ។

ផលិតផលថ្មីៗមួយចំនួនរបស់វិទ្យាសាស្ត្រទំនើប បានបង្កឱ្យមានឧបសគ្គដ៏ធ្ងន់ធ្ងររួចមកហើយ ដល់ប្រព័ន្ធទាំងឡាយ ដែលមិនអាចទ្រាំទ្រចំពោះការសាកល្បងរកហេតុផល ។ អាជ្ញានៃកម្លាំង ឃើញសព្វ ដឹងសព្វ ដែលមហាជនមានជំនឿបានចាប់ផ្តើមរលើងគ្រឹះ ដោយសារការបង្ហើបឱ្យដឹងនៃវិទ្យាសាស្ត្រទំនើប ។ វិទ្យាសាស្ត្របានទម្លាក់ទេវតា (អាទិទេព) ពីបល្ល័ង្កហើយ ។ ទស្សនៈដែលគេប្រកាន់មកជាយូរថាជាការសន្មតិដែលមិនចេះខុស និងដែលមិនប្រែប្រួលនោះ ត្រូវបានហួសសម័យ និងពុំអាចរក្សាការពារបាន ។ នៅចំពោះមុខការបកស្រាយ របស់វិទ្យាសាស្ត្រទំនើប ការការពារនូវឋានៈជាមហាអំណាចរបស់ពួកគេ ពុំអាចធ្វើទៅបានទាល់តែសោះ សូម្បីតែចំពោះព្រះដ៏មានអនុភាពខ្លាំងពូកែ ដែលមានឥទ្ធិពលមកលើមនុស្សជាតិអស់រយៈពេលជាច្រើនសតវត្សមកហើយផង ។

ការលុកលុយដ៏ធ្ងន់ធ្ងរជាលើកដំបូង ចូលទៅក្នុងអំណាច ដែលមិនអាចចោទសួរបាននៃទ្រឹស្ដីដ៏រឹងត្អឹង ដែលប្រកាន់ជំនឿលើអាទិទេព ដែលទទួលខុសត្រូវចំពោះការបង្កើតបានចាប់ផ្ដើមលេចឡើងកាលពី ៣៥ ឆ្នាំកន្លងទៅនេះ ។ នៅក្នុងឆ្នាំ ១៩៦៧ គ្រូពេទ្យវះកាត់ (សល្យពេទ្យ) ឈ្មោះ **គ្រិស្ទាន បេរ្នហាត** (Christian Bernhard) បានអនុវត្តការផ្សាំបេះដូងជាលើកដំបូង របស់ពិភពលោកនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ក្នុងការផ្ដួចផ្ដើមគំនិតបង្កើតយុគសម័យមួយ នៅក្នុងប្រវត្តិសាស្ត្រ នៃវិទ្យាសាស្ត្រពេទ្យ ។ ការចិញ្ចឹមបេះដូងនេះ បានបង្កឱ្យមានការភ្ញាក់ផ្អើលរញ្ជួយទូទាំងពិភពលោក។ រឿងនេះបានចោទឡើងនូវបញ្ហា អភិសមាចារ (ក្រមសីលធម៌) ដ៏សែនភ្ញាក់ផ្អើលយ៉ាងច្រើនក្រៃលែង ។ ជាវិបាក នៃការវះកាត់ឈានមុខមុនគេបង្អស់នេះ ទ្រឹស្ដីសាសនាមួយចំនួន ដែលត្រូវគេប្រកាន់ជាយូរមកហើយ បានទទួលរងនូវការចុះថយ ។

គឺចាប់មានព្រឹត្តិការណ៍នេះរៀងមក ដែលទស្សនៈនៃអាត្ម័នដ៏ឋិតថេរដែលអាចបំបែកពីគ្នាបាន និងជំនឿលើព្រះអាទិទេពដ៏មានអានុភាព បានចាប់ផ្ដើមចុះខ្សោយ ដោយត្រូវបានវាយលុកពីគ្រប់ទិសទី ដោយសាររបកគំហើញនៃការស្រាវជ្រាវវិទ្យាសាស្ត្រជាច្រើន ។ សាសនាខ្លះពុំបានយល់ស៊ីជម្រៅនូវខ្លឹមសារនៃការអភិវឌ្ឍន៍នេះទេ ។ ជនទាំងឡាយដែលមានជំនឿលើអាត្ម័ន ដែលអាចបំបែកពីគ្នាបាន ដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ដែលឋិតថេរជានិរន្តរ៍នោះមានការស្រងាកចិត្តយ៉ាងខ្លាំង ដោយទស្សនៈជំនឿដែលខ្លួនប្រកាន់តាមនោះមិនអាចទប់ទល់នឹងសមិទ្ធផល នៃរបកគំហើញវេជ្ជសាស្ត្រថ្មីនេះបាន ។

កាលបើបេះដូងរបស់មនុស្សដោយឡែក ត្រូវបានផ្សាំទៅជាបេះដូងរបស់

មនុស្សម្នាក់ទៀត វាបង្កឱ្យមានបញ្ហាសាសនា ដ៏វង្វេងវង្វាន់ដល់សាសនាមួយចំនួន ។ ស្ថិតក្នុងស្ថានភាពបែបនេះ តើនរណាដែលត្រូវទៅស្ថានសួគ៌ អ្នកបរិច្ចាគបេះដូង ឬក៏អ្នកទទួលបេះដូង ? នេះគឺជាបញ្ហាទ្វេមុខ ដែលសាសនាទាំងនោះមិនអាចដោះស្រាយបាន ។

នៅក្នុងសាសនាមួយចំនួន ដែលសង្កត់ធ្ងន់លើអាត្មនអាចបំបែកពី ជំនឿទូទៅ គឺថាបេះដូងគឺជាទីអាសនៈរបស់ "អាត្មនដោយឡែក១" នេះ ។ បេះដូងនីមួយ១ គឺជាទីអាសនៈរបស់អាត្មនមួយ ហើយបើតាមសាសនាទាំងនោះ បេះដូងនីមួយ១ គឺសម្រាប់តែបុគ្គលម្នាក់១ប៉ុណ្ណោះ ។ នៅពេលដែលបេះដូងនោះ ត្រូវបានផ្សាំទៅជាបេះដូងមនុស្សម្នាក់ទៀត តើមានអ្វីកើតឡើងចំពោះអាត្មនជាអចិន្ត្រៃយ៍ ដែលស្ថិតក្នុងបេះដូងបរិច្ចាគឱ្យទៅគេនោះ ?

"**បដិគ្គាហកៈ**" ទទួលបាននូវបេះដូង "**របស់អ្នកបរិច្ចាគ**" ។ បែបនេះមនុស្សម្នាក់បាត់បង់បេះដូងមួយ ។ តើមានអ្វីកើតឡើងចំពោះអាត្មនដ៏ទៀងរបស់គេ ? ក្នុងដំណើរការនេះ អ្នកបរិច្ចាគបេះដូងបាត់បង់លិខិតឆ្លងដែនទៅកាន់ឋានទេវតា ឬឋានព្រហ្ម ។

សាសនាទាំងឡាយដែលប្រកាន់ជំនឿថា មនុស្សគឺជាព្រះអាទិទេពបង្កើតឡើងសន្និដ្ឋានថា នៅពេលដែលព្រះជាម្ចាស់បង្កើតមនុស្ស ព្រះអង្គបានប្រគល់បេះដូងមួយទៅឱ្យមនុស្សម្នាក់ ។ នៅក្នុងបរិបទនេះសាសនាទាំងនេះ ប្រឈមនឹងបញ្ហាទ្វេមុខធំ១ពីរ ។ មនុស្សម្នាក់ (អ្នកបរិច្ចាគ) មិនមានបេះដូង ។ អ្នកទទួល (បដិគ្គាហកៈ) បានបេះដូងមួយ ។ ដោយហេតុថាបេះដូងនេះ ជាវត្ថុជំនួសបេះដូងដែលគាត់មានរួចហើយ នោះផលដែលគាត់ទទួលបាន គឺគាត់មាន បេះដូងពីរ ។

រឿងនេះក្លាយជាបញ្ហា ដែលមិនអាចដោះស្រាយបាន សម្រាប់អាទិទេព

ជាអ្នកបង្កើតលោកទាំងឡាយ ។ ប៉ុន្តែ ការផ្សាំបេះដូងមិនបានជះឥទ្ធិពល មកលើប្រព័ន្ធព្រះពុទ្ធសាសនា សូម្បីបន្តិចបន្តួចឡើយ ។ ព្រះពុទ្ធបានប្រៀនប្រដៅយើងនូវសាសនាមួយដែលគ្មាន អាត្មន (អនត្តា) ។ នៅក្នុងប្រព័ន្ធនោះ ពុំមានទីកន្លែងសម្រាប់អាត្មនដែលបំបែកពីគ្នា បានអាត្មនដ៏ទៀង ឬអាត្មនដែលត្រាច់ចរ ពីកន្លែងមួយទៅកន្លែងមួយឡើយ ។ អាស្រ័យហេតុនេះ ប្រព័ន្ធប្រាជ្ញាលោកុត្តរៈរបស់ព្រះសម្មាសម្ពុទ្ធនឹងមិនទទួលរងការប៉ះពាល់ពីទម្រង់ នៃការផ្សាំអង្គអវៈយវៈ ណាមួយឡើយ កុំថាឡើយការផ្សាំបេះដូងនោះ ។ ជាច្រើនឆ្នាំក្រោយមកបញ្ហា **"ទារកបំពង់ពិសោធន៍"** បានវាយប្រហារមួយដំបងទៀត ចំសរសៃករបស់ទ្រឹស្តីអាទិទេពបង្កើតលោក ។

បើសិនជាពន្លកពូជរបស់បុរស ឬស្ត្រីដែលគេដាក់បញ្ចូលទៅក្នុងបំពង់ពិសោធន៍ ត្រូវបានគេដាក់នៅក្នុងស្បូនរបស់ម្តាយជំនួស ម្តាយជំនួសនោះនឹងផ្តល់កំណើតដល់ទារកមួយតាមការកំណត់ ។ ម្តាយដែលផ្តល់កំណើតឱ្យទារកនោះ មិនមែនជាម្តាយបង្កើតរបស់ទារកនោះឡើយ ។ ដំណើរការនៃវិទ្យាសាស្ត្រប្រភេទ នេះប្រឆាំងទៅនឹងទ្រឹស្តីនៃការបង្កើតរបស់អាទិទេព ។ នៅក្នុងខណៈបែបនោះ ទារកម្នាក់ត្រូវបានបង្កើតឡើង ដោយវិទ្យាសាស្ត្រក្រៅស្បូនម្តាយបង្កើត ហើយវាផ្ទុយនឹងនិយាមអាទិទេព ។

ទារកក្នុងបំពង់ពិសោធន៍ មិនបង្កបញ្ហាណាមួយចំពោះទស្សនៈព្រះពុទ្ធសាសនាឡើយ ព្រោះព្រះពុទ្ធទ្រង់ត្រាស់បង្ហាញថា កំណើតអាចមានតាមវិធីផ្សេងៗដ៏ទូលំទូលាយ ។ គោលគំនិតដែលថាមនុស្សត្រូវបានបង្កើតឡើងដោយអាទិទេពបានចាប់ផ្តើមស្ថិតស្រពោនទៅស្របពេល នឹងវឌ្ឍនភាពដ៏លឿនលឿននៃការស្រាវជ្រាវ

វិទ្យាសាស្ត្រទំនើប និងការរកឃើញរបស់វិទ្យាសាស្ត្រ ។

"**ឧស្សាហ៍ៈអាទិទេពបង្កើតលោក**" បានទទួលរងការវាយប្រហារមួយព្រនង់ទៀត នៅពេលដែលលោក **អ៊ាន វិលម៉ុត** (Ian Wilmot) ជាអ្នកវិទ្យាសាស្ត្រ ជនជាតិអេកូស និងក្រុមការងាររបស់លោក បានធ្វើឱ្យ "**កូនគុក្ការ Dolly**" ជាមេចៀម ក្លាយទៅជាសត្វមានជីវិតបាន ។ Dolly គឺសរីរាង្គមួយក្រុម (aclone) ដែលកើតចេញពីកោសិកា របស់មេចៀមអ្នកបរិច្ចាគ ។

នៅក្នុងឧទាហរណ៍នេះ Dolly គឺជាសរីរាង្គមួយក្រុមរបស់មេចៀមមួយទៀតទាំងស្រុង ពោលគឺវាជាពុម្ពមានជីវិតសុទ្ធសាធ នៃចៀមដ៏ទៃទៀត ។ Dolly គឺជាភាគស្មើគ្នាទាំងស្រុង នៃមេចៀមដើម-រហូតដល់កោសិកាចុងក្រោយ ។ ដោយ Dolly គឺជាថនិកសត្វ វិទ្យាសាស្ត្រសព្វថ្ងៃ បានចាប់ផ្តើមធ្វើដំណើរលើមាគ៌ាដ៏ជោគជ័យចម្បងមួយទៀត ។ បច្ចុប្បន្នអ្នកវិទ្យាសាស្ត្រ អាចបង្កើតមនុស្សបានស្ទើរតែគ្រប់ពេលវេលា ដែលពួកគេត្រូវការ ។ ដូច្នេះអ្វីៗ ត្រូវត្រៀមខ្លួនជាស្រេចសម្រាប់ដំណាក់ការ ដ៏គំហុកនៃវិទ្យាសាស្ត្រជីវិតនេះ ។

អ្នកវិទ្យាសាស្ត្រអាចបង្កើតនូវសរីរៈចម្លងរបស់មនុស្ស និងសត្វគ្មានទីបំផុតនៅក្នុងដំណើរការថតចម្លងទាំងមានជីវិត ។ ជាមួយនឹង Dolly ដែលជាសរីរាង្គក្លូន មនុស្សបានបោះជំហានទៅមុខមួយជំហានមុនអាទិទេព ។ បច្ចុប្បន្នអ្នកវិទ្យាសាស្ត្រមិនត្រឹមតែអាចផលិតមនុស្ស-សត្វមានជីវិតប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងសរីរៈចម្លងរបស់គេជាច្រើនទៀតផង ។ មុខងាររបស់អាទិទេព ដែលបង្កើតមនុស្ស កំពុងតែត្រូវបានមនុស្សធ្វើឱ្យប្រសើរជាង ជាពិសេសតាមរយៈជំនាញខាងវិទ្យាសាស្ត្ររបស់គេ ។ វាបានជះឥទ្ធិពលទៅលើពិភពលោកដ៏ឈ្លាសវៃ ដែលថា

មនុស្សបានដណ្ដើមយកការងារ របស់ព្រះអាទិទេព ហើយមិនតែប៉ុណ្ណោះ មនុស្សកំពុងតែធ្វើកិច្ចការនេះ បានប្រសើរជាងអាទិទេពទៅទៀត ។ Dolly ដែលជាមេចៀមក្លូន បានធ្វើឱ្យអាទិទេពបង្កើតលោក អស់សង្ឃឹមទាំងស្រុង ។

តាមវិធីនេះតើ Dolly បានធ្វើអ្វីខ្លះដល់អ្នកមានជំនឿលើអាត្ម័នអចិន្ត្រៃយ៍នោះ ? សំណួរចោទឡើងថា តើសរីរាង្គមេចៀមនីមួយៗរបស់មេចៀម ដែលកើតពីសរីរាង្គក្លូននោះ នឹងមានអាត្ម័នដែលអាចឃ្លាតពីគ្នាបានឬទេ ? ឬតើអាត្ម័នរបស់មេចៀមដើម បែកខ្ញែកទៅក្នុងមេចៀម ដែលគេបង្កើតឡើងពីសរីរាង្គក្លូនដែរឬទេ ? ទោះបីជាគេជ្រើសរើសដោះស្រាយយ៉ាងណាក៏ដោយ ក៏ការបង្កើតមនុស្សពីសរីរាង្គក្លូន បានបំបែកទស្សនៈដែលថាបុគ្គលម្នាក់ៗ មានអាត្ម័នដ៏អចិន្ត្រៃយ៍នៅក្នុងខ្លួន ដែលមិនចេះស្លាប់ ហើយអន្ទោលពីកំណើតមួយ ទៅកំណើតមួយទៀត ។ តើគុណជាតិអ្វីដែលមិនប្រែប្រួលនិងដែលទៀង ត្រូវបានគេបង្កើតជាសរីរាង្គក្លូនដូចម្ដេច ? អ្នកដែលមានជំនឿលើអាត្ម័ន ត្រូវបានធ្លាក់ចូលក្នុងស្ថានភាពលំបាកដ៏ធ្ងន់ធ្ងរ ដោយសារ Dolly ដែលជាមេចៀមក្លូននេះ ។

ក៏ប៉ុន្តែ ការបង្កើតមនុស្ស ឬសត្វ ពីសរីរាង្គក្លូននេះ មិនបានជះឥទ្ធិពលអាក្រក់មកលើព្រះពុទ្ធសាសនា សូម្បីដ៏តិចតួចឡើយ ។ ធាតុមួយនៃសាមញ្ញ លក្ខណៈទាំងបី នៅក្នុងព្រះពុទ្ធសាសនា គឺអនត្តា (Soul-lessnes) ។ ដោយពិចារណាទៅលើមូលដ្ឋាននៃទ្រឹស្ដីនេះ អាត្ម័ននៃផលិតផលដែលបានមកពី ការបង្កើតមនុស្ស ឬសត្វនោះ មិនបានធ្វើឱ្យមានបញ្ហាដល់ព្រះពុទ្ធសាសនាឡើយ ។

ប្រវត្តិសាស្ត្រព្រះពុទ្ធសាសនា ផ្ដល់នូវការកត់សម្គាល់ដ៏ចាប់អារម្មណ៍ចំពោះប្រវត្តិនៃការបង្កើតមនុស្ស-សត្វពីសរីរាង្គមួយ (cloning) ។ រឿងនេះកើត

ឡើងនៅឧបកថានៃរឿងចុល្លបន្ថកត្ថេរ ។ អ្នកនាំសារមកពីផ្ទះគ្រូពេទ្យឈ្មោះ ជីវកៈ ដើម្បីនិមន្តព្រះចុល្លបន្ថកត្ថេរទៅទទួលចង្ហាន់ និងទេយ្យទានផ្សេងៗ ។ គ្រូពេទ្យ ជីវកៈ បានប្រាប់អ្នកនាំសារថា នៅក្នុងវត្តនោះមានតែភិក្ខុមួយអង្គប៉ុណ្ណោះ ។ ពេលដែលអ្នកនាំសារនោះបានទៅដល់វត្ត គាត់បានឃើញព្រះសង្ឃមួយពាន់អង្គ ។ ដោយមហិទ្ធិឫទ្ធិរបស់លោក ព្រះមហាចុល្លបន្ថកត្ថេរ បាននិម្មិតរូបព្រះអង្គចំនួនមួយពាន់ ។ រូបនិម្មិតទាំងមួយពាន់នោះ មើលទៅដូចៗគ្នាទាំងអស់ ។ នៅពេលដែលអ្នកនាំសារនោះសួរថា តើអង្គណាជាចុល្លបន្ថកៈ ? រូបនិម្មិតទាំងមួយពាន់នោះ ឆ្លើយក្នុងសម្លេងតែមួយថា "**អាត្មាជាចុល្លបន្ថកៈ**" ។

កាលបើយើងពិចារណាលើបញ្ហានេះ យើងអាចនិយាយបានយ៉ាង ត្រឹមត្រូវថា "**ឫសគល់នៃការបង្កើតរូបច្រើន ពីរូបដើមមួយ**" (roots of cloning) ឃើញ មាននៅក្នុងប្រវត្តិសាស្ត្រព្រះពុទ្ធសាសនា ។

ប្រព័ន្ធព្រះពុទ្ធសាសនា ពុំមានការយល់ទាស់ណាមួយ ចំពោះបច្ចេកវិទ្យានៃការបង្កើតមនុស្សសត្វ ពីសរីរាង្គណាមួយឡើយ ។ ប្រព័ន្ធពុទ្ធសាសនាទទួលស្គាល់នូវកំណើតគ្រប់សណ្ឋានទាំងអស់ ។ នៅក្នុងបរិបទនេះ ឧប្បត្តិកកំណើត តាមរយៈការនិម្មិតនោះ មិនបង្ហាញនូវបញ្ហាណាមួយចំពោះអ្នកកាន់ព្រះពុទ្ធសាសនាទេ ។

ព្រនង់ដ៏ខ្លាំងក្លាបំផុតទៅលើប្រព័ន្ធជំនឿទាំងឡាយ ដែលសង្កត់ធ្ងន់ លើអាត្ម័ន ដែលអាចបំបែកគ្នាបានអាត្ម័នដ៏ទៀង និងការបង្កើតមនុស្សដោយ អាទិទេពនោះ បានកើតឡើងនៅក្នុងខែមិថុនា ឆ្នាំ ២០០០ ។

ចំណុចប្រសព្វនៃព្រឹត្តិការណ៍នេះ គឺសេតវិមាន-កាលបរិច្ឆេទ គឺថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០០ ។ នៅទីនោះ អ្នកវិទ្យាសាស្ត្រមួយក្រុមបានប្រមូលផ្តុំគ្នា

ដើម្បីប្រកាសនូវលទ្ធផលនៃការស្រាវជ្រាវមិនធ្លាប់មានពីមុន ដែលពួកគេបានធ្វើឡើង ។ អ្នកវិទ្យាសាស្ត្រជាងមួយពាន់នាក់ មកពីប្រទេសនានាលើសកលលោក បានចូលរួមក្នុងការស្រាវជ្រាវនេះ ។ កិច្ចការដែលដាក់ឱ្យពួកគេធ្វើនៅពេលនោះ គឺដើម្បីបកស្រាយការសម្ងាត់ ដែលធម្មជាតិបានចារឹកទុកក្នុងស្នូលនៃកោសិកា ។ **"លេខសម្ងាត់ជីវិត"** មានឈ្មោះថា "genome" (ពន្ធុសាស្ត្រ ?) ។ វាគឺជា ពន្ធុដែលកំណត់ពណ៌សម្បុរ ទំហំ សមត្ថភាពផ្លូវកាយ ឬផ្លូវចិត្ត និងសេចក្ដីលំអិតរបស់មនុស្សគ្រប់រូប ។ ជម្ងឺ-ឃាតករទាំងអស់ ដែលមនុស្សម្នាក់នឹងក្លាយជាជនរងគ្រោះ មានបញ្ជាក់ក្នុងពន្ធុសាស្ត្រ ។

ប្រសិនបើគេបាន **"អាន"** ពន្ធុសាស្ត្រ ហើយយល់អំពីពាក្យពេចន៍ផ្នែកពន្ធុសាស្ត្រ ដែលគេបានសរសេរនៅក្នុងនោះ គេនឹងអាចកែប្រែលេខសម្ងាត់នោះចំពោះអ្វីដែលគេចង់បាន ។

ចំណុចនេះបញ្ជាក់ន័យថា មនុស្សនឹងមានកូនសោដើម្បីបង្កើតជីវិតអនុលោមទៅតាមការធ្វើកម្មវិធី ។ នៅពេលដែលលោកប្រកាសអំពីជ័យជំនះ នៃវិទ្យាសាស្ត្រមនុស្សជាតិប្រធានាធិបតី **ប៊ីល ឃ្លិនតុន** ពេលនោះបានប្រកាស ចំពោះពិភពលោកថា ឥឡូវនេះពួកអ្នកវិទ្យាសាស្ត្របានលួចយកមួយទំព័រចេញពីសៀវភៅរបស់អាទិទេពហើយ ។

នៅពេលដែលមនុស្សបង្កើតជីវិតខ្លួនគេផ្ទាល់ហើយនោះ ទស្សនៈអាទិទេពបង្កើតជីវិតមនុស្សលែងប្រើការបានទៀតហើយ ។ ដូច្នេះ វិទ្យាសាស្ត្រទំនើបបានទម្លាក់ព្រះអាទិទេពចេញពីតំណែង ជាអ្នកបង្កើតជីវិត ។ ប៉ុន្តែថាជំនឿ ដែលជឿថាព្រះអាទិទេពជាអ្នកបង្កើតលោក អាចនៅតែបន្តទៀត ទោះបីជាមានហេតុពិតថាជំនឿទាំងនេះ បានបាត់បង់គ្រឹះ ដែលពួកគេឈរលើក៏ដោយ ។

ក៏ប៉ុន្តែ ការបកស្រាយលេខសម្ងាត់នៃអក្សរក្នុងពន្ធុសាស្ត្រ គឺជាការ

ប្រទានពរជ័យដ៏អស្ចារ្យមួយ ដល់មនុស្សជាតិ ។ ប្រការនេះ នឹងត្រួសត្រាយផ្លូវសម្រាប់ការបំបាត់នូវជម្ងឺ - ឃាតករទាំងឡាយ មានមហារីកជាដើម ។ ដោយប្រកាសនៃការរកឃើញនេះ ប្រធានាធិបតី **ប៊ីល ឃ្លិនតុន** បានមានប្រសាសន៍ថា "ឡេអូ (កូនប្រុសរបស់លោក តូនី ប៊្លែរ នាយករដ្ឋមន្ត្រីនៃប្រទេសអង់គ្លេស) នឹងមិនដឹងថា "មហារីក" (cancer) គឺជាឈ្មោះនៃជម្ងឺ-ឃាតករពីមុននោះទេ ។ គេនឹងស្គាល់វាថាជាឈ្មោះនៃហ្វូងតារាទាំងឡាយ នៅលើមេឃប៉ុណ្ណោះ " ។

ការរកឃើញដ៏អស្ចារ្យនេះ មិនមានការប៉ះពាល់ដល់ព្រះពុទ្ធសាសនាសូម្បីដ៏តិចតួចឡើយ ។ ក្នុងពាក្យពេចន៍នៃបដិច្ចសមុប្បាទ ដែលព្រះសម្មាសម្ពុទ្ធបានសម្ដែងមក ជីវិតកើតឡើងដោយសារកម្ម និងផលបន្តបន្ទាប់គ្នា ។ ជីវិតមិនមានជនណាម្នាក់ជា "អ្នកបង្កើត" ទេ ។ អាស្រ័យហេតុនេះ នៅក្នុងប្រព័ន្ធព្រះពុទ្ធសាសនាពុំមានអាទិទេពបង្កើតឡើយ ពោលគឺវាជាកម្ម និងផលបន្តបន្ទាប់គ្នាតែប៉ុណ្ណោះ ។

ការរកឃើញ "ពន្ធុសាស្ត្រ" ពង្រឹងនូវទ្រឹស្តីកម្មផលរបស់ព្រះពុទ្ធសាសនា ។ ព្រះពុទ្ធបានត្រាស់ថា ប្រសិនបើគេយល់ដឹងដ៏ទូលំទូលាយ និងច្បាស់លាស់ចំពោះដំណើរការកម្មផលនោះ មនុស្សនឹងមានសក្តានុភាព រហូតដល់អាចរំដោះខ្លួនឱ្យផុតពីចំណងកើតស្លាប់ទៀតផង ។

បច្ចុប្បន្ន វាទប្បដិវាទកំពុងកើតមានជាបន្ត ដែលប្រឈមមុខជំនឿទាំងឡាយ ដែលជឿលើអាត្មនដ៏ទៀង និងអាទិទេពបង្កើតលោក ។

ការពិភាក្សាដ៏ផុលផុស ជុំវិញកោសិកាមេ (the sem-cell) ។ កោសិកាមេមួយ គឺជាចំណែកដ៏តូចបំផុត ដែលគេអាចចាប់បានដោយចុងម្ជុលដែរ ។ កោសិកាមេគឺជាកោសិកាមួយក្នុងចំណោមកោសិកាទាំងឡាយ នៅក្នុងខ្លួនមនុស្សដែលមិនទាន់

ប្រែប្រួលទៅតាមសរីរាង្គ ឬជាលិកាណាមួយនៃខ្លួនមនុស្ស ។ កោសិកាមេ "**ទទេ**" (blank) បែបនេះគេអាចយកទៅច្នៃតម្រូវ ដើម្បីបង្កើតកោសិកាណាមួយ នៅក្នុងផ្នែកណាមួយនៃរាងកាយរបស់យើង ។ កោសិកាមេបែបហ្នឹង កើតឡើងនៅក្នុងអំប្រីយ៉ូ មុនពេលវាក្លាយទៅជាគភ៌មួយ ។ នៅក្នុងខ្លួនមនុស្សយើងមានកោសិកា ២០៤ ប្រភេទ ។ កោសិកាមេមិនទាន់បានទទួលយកទម្រង់ នៃកោសិកាណាមួយក្នុងចំណោមកោសិកាទាំង ២០៤ ប្រភេទនោះទេ ។

អ្នកវិទ្យាសាស្ត្របច្ចុប្បន្ន ស្នើសុំដើម្បីដកចេញកោសិកាទាំងនោះ ហើយច្នៃតម្រូវដើម្បីព្យាបាលជម្ងឺជាច្រើនអនេក មានជាអាទិ៍ ជម្ងឺខូចប្រព័ន្ធសរសៃប្រសាទដោយភ័យព្រួរ ជម្ងឺបេះដូង ជម្ងឺសរសៃប្រសាទ ជម្ងឺទឹកនោមផ្អែម ជម្ងឺកាយវិកល ។ល។ ការព្យាបាលដោយកោសិកាមេ អាចកែច្នៃឆ្អឹងខ្នង និងសរសៃប្រសាទដែលខុសប្រក្រតីបាន ។

ប្រព័ន្ធព្យាបាលនេះ នឹងបង្ហាញនូវការប្រសិទ្ធិពរជ័យដ៏ធំធេងមួយ ដល់ជនល្បីល្បាញមួយចំនួន នៅក្នុងពិភពលោក ។ តារាហូលីវូត មីកាអែល ហ្វុក (Michael Fox) មានជម្ងឺខូចប្រព័ន្ធសរសៃប្រសាទ ។ តួឯក គ្រីស្តូហ្វឺ រីវ (Christopher Reeves) ដែលធ្លាប់តែដើរជាតួមនុស្សអស្ចារ្យ (Superman) នោះ ឥឡូវនេះស្ថិតដៃជើងទាំងស្រុង ។ ជនទាំងនេះស្ថិតក្នុងចំណោមអ្នកជម្ងឺ មានឈ្មោះល្បីៗ ដែលបានទទួលផលពីការព្យាបាលដោយកោសិកាមេ ។

មនុស្សជាច្រើនលាននាក់នៅទូទាំងពិភពលោក តស៊ូដើម្បីទទួលផលប្រយោជន៍ពីការព្យាបាល ដោយកោសិកាមេនេះ ។

ក៏ប៉ុន្តែ ប្រសិនបើយើងដកកោសិកាមេចេញពីអំប្រីយ៉ូនោះ វានឹងស្លាប់ ។

អាស្រ័យហេតុនេះ អ្នកវិទ្យាសាស្ត្រកំពុងតែសម្លឹងរកមើលប្រភពជំនួស សម្រាប់ការផ្គត់ផ្គង់កោសិកាមេ ។

ការស្រាវជ្រាវវិទ្យាសាស្ត្រប្រភេទនេះ ត្រូវតែទទួលបានការលើកទឹកចិត្ត ពីព្រោះវាជួយឱ្យមនុស្សបានធូរស្បើយពីជម្ងឺផ្សេងៗ ដំណើរមានទោសៈ និងជម្ងឺតូចតាច ដែលមនុស្សបានជួបប្រទះជាយូរមកហើយ ។ ការកែតម្រូវបញ្ហានៃការស្រាវជ្រាវបែបនេះទាំងអស់ យើងត្រូវតែប្រើប្រាស់ពួកវា ដើម្បីកែលំអរស្ថានភាពរបស់មនុស្សឱ្យបានប្រសើរឡើង ។ វាជាភារកិច្ចរបស់មនុស្សយើង ដើម្បីធ្វើឱ្យវិទ្យាសាស្ត្រជីវិតលឿនទៅមុខ ដោយការជំរុញឱ្យមានការស្រាវជ្រាវថ្មីៗ និងការអនុវត្តន៍ព្យាបាលរបស់ពួកគេ។ ពិភពលោកនេះពោរពេញទៅដោយអាថ៌កំបាំង ។ /បុរស និងស្ត្រី រងទុក្ខយ៉ាងច្រើន ទោះបីជាមានជំនឿមួយចំនួន ថាពួកគេត្រូវបានអាទិទេពបង្កើតឡើងក៏ដោយ ។

ប្រសិនបើយើងពិនិត្យមើលលើការព្យាបាលដោយកោសិកា ជាថ្មីម្តងទៀត វាបាននាំមកនូវក្តីសង្ឃឹមដល់កុមារនៅក្នុងពិភពលោករួចទៅហើយ ។ លោកសាស្ត្រាចារ្យ **លី អេខ ហ៊ិន** នៃសាកលវិទ្យាល័យសឹង្ហបុរី បានច្នៃតម្រូវការព្យាបាលដោយកោសិកាមេ ដើម្បីជួយសង្គ្រោះកុមារសិង្ហបុរីមួយចំនួន ដែលកើតជម្ងឺកាយវិកល ។

លោកសាស្ត្រាចារ្យ **លី អេខ ហ៊ិន** បានមានប្រសាសន៍ថា "យើងបានទទួលលទ្ធផលដ៏គួរឱ្យចាប់អារម្មណ៍ តាមរយៈការប្រើវិធីព្យាបាលដោយកោសិកាមេ ដើម្បីព្យាបាលកុមារមួយចំនួន ដែលមានកាយវិកល នៅក្នុងប្រទេសសិង្ហបុរី" ។

កាលបើវិទ្យាសាស្ត្រផ្នែកជីវិតមានវឌ្ឍនភាព ដោយផ្តល់នូវក្តីសង្ឃឹម

ដល់មនុស្សជាតិនោះ ជំនឿមួយចំនួនភ័យខ្លាចថា ពួកគេនឹងបាត់បង់គំនិតផ្ដួចផ្ដើមរបស់ខ្លួន ពីព្រោះគោលគំនិតអាទិទេពបង្កើតលោកសាបសូន្យ ទៅជាមួយនឹងវឌ្ឍនភាពទាំងនេះ ។ ដើម្បីការពារទស្សនៈបង្កើតលោក ដែលមិនអាចការពារបានរបស់ពួកគេ ពួកគេនឹងប៉ុនប៉ងបង្អាក់ការជឿនលឿនរបស់មនុស្សជាតិ ។ ជនមួយចំនួនព្យាយាមរារាំងការស្រាវជ្រាវដែលជាប្រយោជន៍ ដោយព្រមានថា "កុំប្រឆាំងនឹងព្រះជាម្ចាស់ (អាទិទេព)" ។

វិធានការដែលក្រុមមនុស្សមានចិត្តចង្អៀតចង្អល់មួយចំនួនបានចាត់ឡើង ដោយសហការជាមួយអ្នកនយោបាយវង្វេងផ្លូវមួយចំនួននោះ គឺជាឧបសគ្គមួយចំពោះវឌ្ឍនភាពដ៏ល្អនៃមនុស្សជាតិទូទៅ ។ ប្រសិនបើព្រះអាទិទេពបានបង្កើតមនុស្សមែននោះ ទ្រង់មុខជានឹងឈ្វេងយល់ថា ថ្ងៃណាមួយមនុស្សនឹងអភិវឌ្ឍន៍ពុទ្ធិរបស់គេ ឈានដល់កម្រិតពិនិត្យមើលសច្ចភាពនៃជំនឿក្នុងព្រះអាទិទេព ដែលមានពលានុភាពបង្កើតមនុស្ស ។ ប្រសិនបើព្រះអាទិទេពទ្រង់ឈ្វេងយល់ដូច្នេះមែន ទ្រង់អាចរារាំងការវិវឌ្ឍន៍របស់មនុស្សបែបហ្នឹងបានទៅហើយ ។

តើវាសមរម្យមានសីលធម៌ ឬសមជាមនុស្សដែរទេ ដើម្បីបង្អាក់វឌ្ឍនភាពរបស់មនុស្សនាពេលបច្ចុប្បន្ន និងអនាគត ដោយគ្រាន់តែដើម្បីការពារគំនិត ប្រហោងក្នុងចង្អៀតចង្អល់មួយ ដូចជាថាមនុស្សត្រូវបានអាទិទេពបង្កើតជាដើមនោះ? វាគួរឱ្យអស់សំណើចណាស់ ដែលក្រុមមនុស្សទាំងនេះ ត្រូវជំទាស់នឹងការស្រាវជ្រាវឯករាជ្យ និងសេរីនៃអ្នកវិទ្យាសាស្ត្រទាំងឡាយ ដើម្បីការពារទស្សនៈ ដែលមិនអាចការពារបាន ដែលមិនពិតប្រាកដ និងដែលមិនសមហេតុផលរបស់ពួកគេ ។

ប្រទេសខ្លះបាត់បង់អ្នកវិទ្យាសាស្ត្រដ៏ជំនាញរបស់ខ្លួន នៅពេលដែលគេ

បានបង្កើតឧបស័គ្គទាំងនេះឡើង ។ លោកសាស្ត្រាចារ្យ **រ៉ូចឺ ផិតដឺសុន** (Roger Pedeson) នៃសាកលវិទ្យាល័យកាលីហ្វូនីញា នៅក្រុងសាន់ហ្វ្រាន់ស៊ីស្កូ បានចាកចោលសហរដ្ឋអាមេរិក ដោយសារមានការដាក់ហាមឃាត់មកលើអ្នកវិទ្យាសាស្ត្រ ។ លោកសាស្ត្រាចារ្យ **រ៉ូចឺ ផិតដឺសុន** (Roger Pedeson) នឹងត្រូវចូលរួមធ្វើការនៅមហាវិទ្យាល័យ នៃសាកលវិទ្យាល័យ ខេមប្រ៊ីជ ប្រទេសអង់គ្លេស ។

ទោះបីជាការរកឃើញវិទ្យាសាស្ត្រចេញមកជាអ្វីក៏ដោយ ក៏ព្រះពុទ្ធសាសនានៅតែរុងរឿងរហូត ដោយមិនទទួលរងផលប៉ះពាល់ពីកត្តាទាំងនោះឡើយ ។ ជាងនេះទៀត សច្ចធម៌ជាអមតៈរបស់ព្រះពុទ្ធសាសនា នឹងកាន់តែត្រូវបានលើកតម្លៃបន្ថែមទៀត ហើយកាន់តែរឹងមាំដោយការរកឃើញថ្មីៗ នៃវិទ្យាសាស្ត្រទំនើបទាំងនេះ ។

*ព្រះពុទ្ធសាសនា*
*ជាសាសនារបស់រដ្ឋ*
*ប្រព្រឹត្តកាន់ទៀងទាត់*
*ប្រាកដជាបានសន្តិភាព ។*

ព្រះមុនីកោសល **សោម ឈុន**

ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា



លោកនិពន្ធនាយកទស្សនាវដ្តីកម្ពុជសុរិយា!

ក្នុងនាមខ្ញុំបាទជាភ្នាក់ងារឆ្លើយឆ្លងទស្សនាវដ្តីកម្ពុជសុរិយា ប្រចាំខេត្តពោធិ៍សាត់ ខ្ញុំបាទបានអានហើយនៅចម្ងល់មួយចំនួនរបស់លោក **ខៀវ យ៉ុន** ចុះក្នុងកម្ពុជសុរិយាលេខ ៤ -២០០២ ។ ចម្ងល់ឈ្មោះរុក្ខជាតិមួយចំនួនទាក់ទងក្នុងអត្ថបទរបស់ខ្ញុំបាទស្តីអំពី មុខរបរកាប់ខ្លឹមចន្ទន៍ក្រស្នារបស់អ្នកស្រុកជនជាតិព័រ និងជង ខេត្តពោធិ៍សាត់ ។ ខ្ញុំបាទមានសេចក្តីត្រេកអរជាពន្លឹក ប្រកបដោយភាពជាមោទនៈ ចំពោះការចាប់អារម្មណ៍ ផ្តល់ជាចម្ងល់ប្រកបដោយភាពចាំបាច់ និងមានសារៈសំខាន់ ទាក់ទងទៅនឹងអត្ថបទរបស់ខ្ញុំបាទ តទៅនេះខ្ញុំបាទសូមឆ្លើយមួយចំណុចម្តងៗ ជូនជ្រាបដូចខាងក្រោម :

**អំពីដើមក្រវាញ.ជន្លោ :**

ពាក្យសាមញ្ញខ្មែរយើង ច្រើនប្រើការហៅភ្ជាប់ន័យ ចំពោះឈ្មោះអ្វីមួយ

ដែលមានលំនាំពាក្យស្រដៀងឱ្យជាប់គ្នា ដូចជាពាក្យក្រវាញដង្កោនេះឯង ។ តាមការពិត ក្រវាញ ដង្កោ រុក្ខជាតិទាំងពីរនេះ គឺមានអំបូរដូចគ្នាច្រើនដុះជាហ្វូងដូចគ្នាក៏ប៉ុន្តែមានលក្ខណៈខុសគ្នាមួយចំនួនដូចជា :

**ក.ក្រវាញ:**

ក្រវាញមានដើមដូចដើមរំដេង ស្លឹករលីងដូចគ្នា តែក្រវាញមានដើមខ្ពស់ជាងរំដេងគឺមានកំពស់ប្រហែលពីមួយម៉ែត្រទៅមួយម៉ែត្រកន្លះ មានផ្កា ផ្លែដុះចេញពីដី (ពីគល់) ជាចង្កោមដូចទងផ្ការំដេង ។ ផ្លែក្រវាញមានរាងមូលប៉ុនៗម្រាមដៃមានស្រោមស្តើងគ្របពីលើ ផ្លែមានសំបកស គ្រាប់ខាងក្នុងខ្មៅ មានពី ២-៣ គ្រាប់ក្នុងមួយផ្លែ មានរសជាតិ ហិរខ្លាំង ដូចប្រេងខ្យល់ តម្លៃខ្ពស់ ។

**ខ.ដង្កោ :**

ដង្កោមានដើមដូចក្រវាញដែរ តែមានកំពស់ខ្ពស់ជាងដើមក្រវាញប្រមាណមួយម៉ែត្រ ឯស្លឹកខាងខ្នងមានរោមៗ របៀបដូចស្លឹកអំពៅ ផ្លែដុះចេញពីដីដូចគ្នាតែផ្លែដង្កោគ្មានស្រោមទេ ហើយផ្លែក៏ធំជាង សំបកក្រាស់ពណ៌ក្រម៉ៅបើគេបំបែកសំបកនោះ គេនឹងឃើញមានគ្រាប់ល្អិតៗ ជាប់គ្នាបានជាពីរគ្រាប់ធំរាងទ្រវែង មានរសជាតិហិរតិចៗ តម្លៃទៀតសោតកថោកជាងក្រវាញ សរុបសេចក្តីមកដើមទាំងពីរនោះ គឺមានឈ្មោះខុសគ្នាមិនដូចគ្នាទេ ។

**អំពីដើមចន្ទន៍ :**

ជាការពិតណាស់ ចំពោះដើមចន្ទន៍ក៏ដូចគ្នាដែរ គឺមានពីរប្រភេទខុសគ្នាដូចជា ចន្ទន៍ស និងចន្ទន៍ក្រហម :

**ក. ចន្ទន៍ស** : ដើមចន្ទន៍សធំបំផុត មានទំហំប៉ុនភ្លៅ ឯសំបកវាក្រាស់តែរាងផុយៗ មានសន្លឹកធំប៉ុនបាតដៃ ផ្នែកខាងលើរាងរលោង ឯផ្នែកខាងក្រោម

មានរោមល្អិត១ រីឯខ្លឹមរបស់វាដូចខ្លឹមឈើធម្មតា តែមានពណ៌លឿងលាយស និងមានក្លិនក្រអូប ដូចក្លិនធូបក្រអូប ។ ខ្លឹមឈើប្រភេទនេះ ក្រអូបលើសឈើទាំងពួងតែប្រយោជន៍ គឺប្រើបានតែជាគ្រឿងផ្សំ ជាឱសថមួយមុខតែប៉ុណ្ណោះ ។

**ខ្លឹមចន្ទន៍ក្រហម :**

ដើមចន្ទន៍ក្រហម ទាំងដើម ទាំងសន្លឹកមានសណ្ឋានដូចដើមរំចេក តែខុសគ្នាត្រង់សន្លឹកមិនមានបន្លាទេ ហើយដើមទៀតសោតមានទំហំធំជាងដើមរំចេក រីឯខ្លឹមមានពណ៌ក្រហមព្រឿង១ តែមានក្លិនក្រអូបបន្តិច១ ។ គេប្រើជាប្រយោជន៍បាន តែជាឱសថមួយមុខ ដូចជាចន្ទន៍សដែរ ។ សរុបសេចក្ដីមកមានន័យថា ចន្ទន៍ស និងចន្ទន៍ក្រហម គឺជាប្រភេទឈើមួយខុសគ្នា និងដោយឡែកពីឈើប្រភេទខ្លឹមក្រស្នា ។

**អំពីដើមក្រស្នា :**

ដើមក្រស្នា គឺជាប្រភេទឈើ ដែលមានតម្លៃ គឺប្រភេទឈើនេះ ហើយដែលអ្នកនិយមចូលចិត្តតែងប្រើពាក្យ ឱ្យមានកាភ័ន្តច្រឡំនោះ សរុបសេចក្ដីមកដើមក្រស្នា ឬដើមចន្ទន៍ក្រស្នា គឺជារុក្ខជាតិតែមួយ ដែលមានឈ្មោះតាមការនិយមហៅខុស១គ្នាដូចដែលអត្ថបទរបស់ខ្ញុំបាទ បានរៀបរាប់ជូនជ្រាប អំពីមុខរបរកាប់ខ្លឹមចន្ទន៍ក្រស្នា ឬខ្លឹមក្រស្នា របស់ជនជាតិព័រនិងជង ខេត្តពោធិ៍សាត់រួចមកហើយ ។

**អំពីដើមក្លាំពាក់ :**

ដើមក្លាំពាក់គឺជាប្រភេទឈើជាឱសថមួយបែបមិនមានជាប់ទាក់ទាមនឹងរុក្ខជាតិណាមួយឡើយ ហើយឈើប្រភេទនេះ មានឈ្មោះហៅជាប់គ្នា និងរុក្ខជាតិមួយមុខទៀត ដូចជាពាក្យអ្នកស្រុកហៅថា ដើមក្លាំពាក់ ក្លាំពូល (ក្លាំពាក់ដោយឡែក ក្លាំពូលដោយឡែក ) ហើយប្រភេទឈើទាំងពីរមុខនេះ គឺគេប្រើជា

ឱសថដូចគ្នា ។ សរុបមកបានន័យថា រុក្ខជាតិទាំងប៉ុន្មានប្រភេទដូចបានរៀបរាប់ជូនជ្រាបខាងលើ គឺមានឈ្មោះនិងរូបរាង ដោយឡែកពីគ្នា ដូចជា :

*១- ដើមក្រវាញ*

*២- ដើមដង្កោ*

*៣- ដើមក្លាំពាក់*

*៤- ចន្ទន៍ក្រស្នា ( ចន្ទន៍ស និងចន្ទន៍ក្រហម )*

*៥- ដើមក្រស្នា ( ដើមក្រស្នា ឬចន្ទន៍ក្រស្នា )*

សេចក្តីដូចបានអធិប្បាយជូនជ្រាបខាងលើនេះ គឺជាការស្រាវជ្រាវបន្ថែម និងស្រាយបំភ្លឺត្រួសៗ ក្រែងបើមានការខុសទាស់ត្រង់អន្លើណាមួយនោះ ខ្ញុំបាទនិងរង់ចាំការជួយស្រាយបំភ្លឺបន្ថែម ដើម្បីឱ្យអត្ថបទស្រាវជ្រាវនោះកាន់តែមានន័យច្បាស់លះទូលំទូលាយជាងនេះទៅទៀត ។ សូមអរគុណ សូមជូនពរសុខភាពល្អ និងបវរជោគជ័យសិរីសួស្តី អាយុយឺនយូរ ។

ពោធិ៍សាត់ថ្ងៃទី.២០ ខែ មករា ឆ្នាំ ២០០៣

**ម៉ៅ សោភ័ណ**

**រស់ សំណាង**



ផ្លែក្រវាញ



ផ្លែដង្កោ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



លោក ហ៊ែល ស៊ុំផា ( ១៩២២-១៩៧១ )


ឆ្នាំទី ៥៨ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស. ២៥៤៧ គ.ស. ២០០៣

ភ្នំពេញ

រូបក្របខាងក្រៅ : **ជីវប្រវត្តិសង្ខេប**

- លោក **ហ៊ែល សុំផា** កើតនៅថ្ងៃទី ២៣ មេសា ១៩២២ នៅឃុំផ្សារក្រោម ស្រុកបាកាន ខេត្តពោធិសាត់ ។
- មាតានាម **សេង លិញ** បិតានាម **ម៉ៅ ហ៊ែល** ជាមន្ត្រីក្នុងរាជការអាណាព្យាបាល " សឺក្រេទែរ រ៉េស៊ីដង្គ "
- អាយុ ៧ ឆ្នាំ ចូលរៀននៅកំពង់ស្ពឺ, រួចនៅកំពង់ចាម
- អាយុ ១២ ឆ្នាំ បិតាទទួលអនិច្ចកម្មទៅ មករៀននៅភ្នំពេញ
- ១៩៤០ ចូលរៀននៅសាលាច្បាប់ ចេញទៅធ្វើជាមន្ត្រីក្នុងតុលាការ
- ១៩៤៣ ធ្វើក្រឡាបញ្ជី នៅសាលាដំបូង កំពង់ធំ
- ១៩៤៥ ធ្វើសភាចារបុរស នៅសាលាដំបូង សៀមរាប ក៏បានរៀបអាពាហ៍ពិពាហ៍ នៅសៀមរាប
- ១៩៤៧ ជាចៅក្រម នៅសាលាឧទ្ធរណ៍ រួចផ្លាស់ទៅកំពង់ចាម-មកភ្នំពេញវិញ និងទៅសិក្សានៅប្រទេសបារាំងមួយឆ្នាំ ។
- ១៩៦២ ជាប់ឆ្នោតជាតំណាងរាស្ត្រ មណ្ឌលជីក្រែង ខេត្តសៀមរាប
- បានធ្វើជាប្រធានសមាគមអ្នកនិពន្ធខ្មែរ ពីឆ្នាំ ១៩៥៧ ដល់ ១៩៦៤
- ជាសាស្ត្រាចារ្យមហាវិទ្យាល័យច្បាប់ អស់ពេលច្រើនឆ្នាំ
- ទទួលអនិច្ចកម្ម នៅថ្ងៃទី ០៤ កញ្ញា ១៩៧១ ។



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : **ខួន វ៉ាន់ចន្ទី**

និពន្ធនាយក : **ខៀវ បញ្ញាវុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** លោក **ម៉ែន ប្រាង**

លោក **វង់ សុធារ៉ា** លោក **ឆន់ ហ៊ិន**.

លោក **មៀច ប៉ុណ្ណ** លោក **ពិ ប៊ុន្នីន**

## គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **នេខ ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អឿម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ ឃីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **នេត ឆារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ជីវិតមនុស្ស និងបញ្ហា (ត) ............... (ឈន អៀម) ១


## II. អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ :


- សីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន (ត) ...... (ឆយ យីហ៊ាង) ១២
- ការរីកចម្រើននៃព្រះពុទ្ធសាសនា (ត) .......... (ខ្លូត ធីតា) ២២
- សិលាចារឹកស្រះឈូកជាភាសាខ្មែរ (Ka110 .. (មីសែល ត្រាណេ) ៣២
- ពិធីបំបួសនាគ ........................... (ពេជ្រ សល់) ៣៧
- ពិធីចូលម្លប់ ចេញពីម្លប់ .................... (មៀច ប៊ុណ្ណ) ៤៤
- ប្រវត្តិវត្តបាកាន ....................... (ម៉ៅ សោភ័ណ) ៥២
- កំណាព្យ ចិត្តមេត្តា .......... (ឧកញ៉ាឧបាសិកា ញ៉ឹក ប៊ុនថា) ៦៤


## III. កំណត់ និងប្រវត្តិការណ៍ :


- សុន្ទរកថាព្រះតេជព្រះគុណបណ្ឌិតអាស៊ីន ញាណិស្សរៈ ....... ៦៦
- សង្ឃប្រកាស ....................................... ៧៧
- ព្រះរាជក្រឹត្យតែងតាំង .............................. ៨៥
- វិយោគកថា និងជីវប្រវត្តិរបស់សពលោក ឱម ខែម (ជា គាន) ៨៧


## IV. ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា


- មិត្តអ្នកអានជាទីមេត្រី .............................. ៩៧

# ជីវិតមនុស្ស និង បញ្ហា (ត)

បណ្ឌិត ក. ស្រី ធម្មានន្ទ
បកប្រែ : ឈេន អៀម

## ការរស់នៅជាមួយគ្នា ក្រៅចំណងអាពាហ៍ពិពាហ៍

ការរស់នៅជាមួយគ្នា មុនរៀបអាពាហ៍ពិពាហ៍ ឬការរួមសង្វាស ដូចដែលគេធ្លាប់ស្គាល់ទូទៅច្រើន គឺជាជម្រើសដ៏សុខស្រួលមួយក្នុងចំណោមយុវជននៅលោកខាងលិច ហើយកំពុងតែឆ្លងរាលដាលយ៉ាងឆាប់មកដល់ប្រទេសទាំងឡាយជាច្រើននៅអាស៊ី។ គេនិយាយថា មានប្ដី-ប្រពន្ធជាគូស្រករប្រហែលពាក់កណ្ដាលនៅសហរដ្ឋ និងប្រទេសអង់គ្លេស ធ្លាប់បានរួមរស់នៅជាមួយគ្នា មុនពេលរៀបអាពាហ៍ពិពាហ៍។ គេអាចដឹងរឿងនេះ នៅក្នុងរឿងភាពយន្ត និងក្នុងសារពត៌មាន។ ចំណែកឯលោកខាងកើត ដែលប្រកាន់អភិរក្សនិយម, ការរួមរស់នៅជាមួយគ្នាមុនពេលរៀបការ គឺជាតំណមដ៏តឹងរ៉ឹងនៅឡើយ។ ការគ្រាន់តែនិយាយអំពីប្រធានបទនេះ គឺវាគ្រប់គ្រាន់ណាស់ទៅហើយ ធ្វើឱ្យគេជ្រួញចិញ្ចើម ជាពិសេសពួកមនុស្សវ័យចំណាស់។ ប៉ុន្តែយើងត្រូវបន្ថែមថា ដោយហេតុតែពិភពលោកកំពុងតែរួញតូចទៅដ៏ឆាប់ពេកណាស់. តម្លៃជាច្រើនក្នុងបណ្ដាតម្លៃទាំងនេះ កំពុងត្រូវបានគេប្រកាន់យកនៅក្នុងលោកខាងកើតផងដែរ, ជាពិសេសនៅក្នុងតំបន់ជាយក្រុង។

នៅក្នុងសហរដ្ឋ ដែលការរួមរស់នៅជាមួយគ្នាក្រៅចំណងអាពាហ៍ពិពាហ៍ កំពុងត្រូវបានគេទទួលស្គាល់កាន់តែកើនឡើង. អាពាហ៍ពិពាហ៍មួយ ក្នុងចំណោមអាពាហ៍ពិពាហ៍បី ផ្ដល់ចេញជាផលវិបាក គឺការលែងលះគ្នា។

ករណីដ៏សោកសៅជាច្រើន តែងកើតឡើងនៅក្នុងស្ថានភាពទាំងឡាយ ដែលគូស្រករទាំងឡាយរួមរស់នៅជាមួយគ្នា ក្រៅចំណងអាពាហ៍ពិពាហ៍. យកជាឧទាហរណ៍ កាលណាភាគីខាងស្ត្រីមានផ្ទៃពោះហើយ ហើយភាគីខាងបុរស ក្រោយមកប្រកាសមិនទទួលខុសត្រូវ។ រឿងនេះជាញឹកញយ នាំដល់បញ្ហាម្តាយឥតខាន់ស្លា (Unwed mothers)។

## បញ្ហាម្តាយឥតខាន់ស្លា

ប្រព័ន្ធពត៌មាន តែងរាយការណ៍អំពីម្តាយឥតខាន់ស្លាបានបោះបង់ ឬទុកចោលទារករបស់ខ្លួន នៅលើគំនរសម្រាម, គុម្ពកម្ពោតព្រៃ ឬក្នុងបន្ទប់ទឹក, ប្រឡាយទឹក និងចរន្តទឹក។ គឺជារឿងហេតុដ៏តក់ស្លុតណាស់ សម្រាប់សមាជិកក្រុមគ្រួសារណាមួយ ដែលមានទស្សនៈត្រឹមត្រូវ ដើម្បីធ្មេចភ្នែកលើកលែងទោស។ ដោយមាន របាយការណ៍បែបនេះ កើតមានឡើងស្ទើរតែរាល់ថ្ងៃ, សាធារណជនមានសេចក្តីភ័យព្រួយ ហើយបានអំពាវនាវឱ្យចាត់វិធានការកែលំអឡើងវិញ ដើម្បីទប់ស្កាត់ បញ្ហាកាន់តែធំធេង ដែលបានមកដល់សមាមាត្រដ៏គួរភ្ញាក់ផ្អើល។

ទារកដែលគេបោះចោលខ្លះ បានរស់រាន ដោយសារតែទារកទាំងនោះត្រូវបានអ្នកប្រមូលសម្រាម, អ្នកស្រុក ឬអ្នកថ្មើរជើងឃើញទាន់ពេល, ទោះបីទារកទាំងនោះ ត្រូវបានគេទុកចោលនៅចំពោះមុខគ្រោះថ្នាក់បែបនេះ ដូចហ្វូងឆ្កែអាវ៉ាសែ, កណ្តុរប្រែង, ស្រមោច និងអាកាសធាតុត្រជាក់ ឬក្តៅ។ គេឆ្ងល់ថាហេតុយ៉ាងម៉េច ម្តាយទាំងនេះដាច់ចិត្តបោះបង់ទារកខ្លួនចោល, សូម្បីតែពពួកសត្វក៏គេបានដឹងថាវាហ៊ានប្តូរផ្តាច់ការពារកូនរបស់វាដែរ។ គេត្រូវរំលឹកថា មិនមែនទារកទាំងអស់កើតក្រៅចំណងអាពាហ៍ពិពាហ៍ ចេញមកតែពីពួកយុវតីទេ។ ស្ត្រី

ចំណាស់ៗ ក៏ជាជនជាប់ទោស ចំពោះប្រតិកម្មដ៏គួរឱ្យខ្លាចនេះដែរ ។

ឪពុក-ម្តាយ គប្បីខិតខំស្វែងយល់កូនៗរបស់ខ្លួន ។ ឪពុក-ម្តាយគប្បីធានាអះអាងថា កូនៗរបស់គេ នឹងត្រឡប់មករកគេវិញ កាលណាពួកគេមានបញ្ហា ។

មនុស្សដែលបោះបង់ចោលទារករបស់ខ្លួន ត្រូវការជំនួយ ។ ពួកគេត្រូវការដំបូន្មាន ។ យើងមិនគប្បីស្តីបន្ទោសពួកលោកខាងលិចយ៉ាងសាមញ្ញ រាល់ពេលដែលមានបញ្ហាខ្លះផុសឡើងនៅទីនេះទេ ។ គេឥតសង្ស័យទេថា យុវជនរបស់យើងកំពុងតែប្រកាន់យករបៀបលោកខាងលិចច្រើនឡើងៗ នៅក្នុងការគិតគូរ, ក្នុងទស្សនៈ, ក្នុងបែបបទរស់នៅ និងក្នុងសកម្មភាពរបស់ពួកគេ ។ ក្នុងករណីនេះហើយ ដែលតួនាទីរបស់ឪពុកម្តាយ ត្រូវធ្វើអន្តរាគមន៍ ។

ឪពុកម្តាយខ្លះ រវល់ធ្វើការខ្លាំងពេក ទាល់តែគេភ្លេចភ្លាំងដោយអចេតនានូវកូនៗរបស់គេ ។ ហេតុនេះ ឪពុកម្តាយគប្បីចំណាយពេលឱ្យច្រើនពង្រឹងវិន័យ និងអប់រំកូនៗរបស់ខ្លួន ស្តីអំពីអ្វីខុស អ្វីត្រូវ ។

យើងត្រូវការ *វិធីដោះស្រាយទន់ភ្លន់* (a humane approach) ក្នុងការអនុវត្តដោះស្រាយបញ្ហារបស់ម្តាយឥតខាន់ស្លា ដែលអាចចាប់ចេញដំណើរជាមួយគ្រួសារ ដែលឪពុកម្តាយ និងកូនៗមិននិយាយឆ្លើយឆ្លងគ្នាបានល្អ ។ កាលណាហេតុការណ៍នេះ កើតមានដល់កូនស្រីម្នាក់, នាងតែងខ្លាចគេដាក់ពិន័យ, ខ្លាចគ្រួសារ និងសង្គមមិនទទួលយក ក៏ដូចជាខ្លាចសង្គមបិទផ្លាកអសោចិ៍ឱ្យនាង: ហើយនាងគ្មាននរណារាប់រក ជួយផ្តល់ដំបូន្មាន ឬផ្តល់ជំនួយ ។ នាងត្រៀមខ្លួនទទួលកំហុសរបស់នាងដោយសុខចិត្តរែកពុនបន្ទុកតែម្នាក់ឯង ។ ឪពុកម្តាយរបស់នាងផងដែរមិនទទួលនាង ហើយសង្គមផ្តន្ទាទោសនាង ហើយជាលទ្ធផល នាងក្លាយជាមនុស្សអស់សង្ឃឹម ។

ដើម្បីជំនះបញ្ហានេះបាន, ការខិតខំអភិវឌ្ឍគ្រួសារ ត្រូវតែបានឈានឡើងជាជំហាន១ នៅកន្លែងណាដែលគូស្រករទាំងឡាយនឹងត្រូវទទួលការហ្វឹកហ្វឺន ដើម្បីក្លាយខ្លួនជាឪពុកម្ដាយដ៏ប្រសើរ. ហើយយុវជននឹងត្រូវទទួលខុសត្រូវចំពោះខ្លួនគេតាមរយៈកម្មវិធីស្ដីពីការអប់រំផ្លូវភេទ។ អង្គការសាសនា និងទីប្រឹក្សាសាសនា អាចជួយរដ្ឋាភិបាលយ៉ាងមានប្រសិទ្ធភាព ដើម្បីប្រយុទ្ធនឹងជំងឺសង្គមដ៏គួរឱ្យខ្លាចនេះ។

## ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងពលកម្មកុមារ

ពេស្យាចារកុមារ គឺជាជំនួញមួយធំធាត់យ៉ាងឆាប់បំផុត នៅក្នុងប្រទេសជាច្រើន។ ភ្នាក់ងារទេសចរណ៍ និងអ្នកដំណើរមានទ្រព្យច្រើនបាននាំយកមកសាបព្រោះនូវកិច្ចការនេះ យ៉ាងទូលំទូលាយ។

" ផ្លូវភេទ ក្លាយទៅជាឧស្សាហកម្មរកប្រាក់បានរាប់ពាន់លានដុល្លារ ហើយក្មេង១សព្វថ្ងៃ ត្រូវបានគេទិញ គេលក់ និងជួញដូរ ដូចជា ផលិតផលឧស្សាហកម្មដទៃទៀតដែរ ", នេះជាពាក្យត្អូញត្អែររបស់លោក Aaron Sachs, ជាបុគ្គលិកស្រាវជ្រាវម្នាក់ នៅវិទ្យាស្ថានពិភពលោក មានទីតាំងនៅវ៉ាស៊ីនតោន។

" នៅអាយុដប់ឆ្នាំ, អ្នកឯងជាស្ត្រីម្នាក់, នៅអាយុម្ភៃឆ្នាំអ្នកឯងជាស្ត្រីចំណាស់ម្នាក់។ ហើយនៅអាយុសាមសិបអ្នកឯងស្លាប់ " ។ នេះជាពាក្យប្រជាប្រិយពោលយ៉ាងដូចនេះ នៅក្នុងប្រទេសខ្លះ។

ពេស្យាចារកុមារ គឺជាទំនិញក្នុងចំណោមទំនិញដ៏ក្ដៅគគុកបំផុត រឿងនេះមានពិតប្រាកដយ៉ាងពិសេសនៅទ្វីបអាស៊ី, ជាមជ្ឈមណ្ឌលនៃឧស្សាហកម្មផ្លូវភេទកុមារ។ របាយការណ៍ឆ្នាំ ១៩៩៥ ស្ដីពីវឌ្ឍនភាពនៃប្រជាជាតិទាំងឡាយ របស់មូលនិធិសម្រាប់កុមារសហប្រជាជាតិ (UNICEF) ចុះបញ្ជីប្រទេសថៃ ជាប្រទេស

ទីបី ដែលមានពេស្យាចារកុមារច្រើនបំផុត។ កុមារប្រមាណ ១០០.០០០ នាក់ កំពុងលក់ភេទនៅក្នុងប្រទេសនេះ។ ប្រទេសជាប់លេខផ្តាច់គេ គឺប្រទេសឥណ្ឌា ដោយមានកុមារពី ៤០០.០០០ នាក់ ទៅ ៥០០.០០០ នាក់។ សហរដ្ឋគឺជាប្រទេសទីពីរ ដោយមានកុមាររកស៊ីលក់ភេទចំនួន ៣០០.០០០ នាក់។ ប្រទេសហ្វីលីពីនមានចំណាត់ថ្នាក់ទីបួន ដោយមានកុមារលក់ភេទចំនួន ៦០.០០០ នាក់។

របាយការណ៍និយាយថា ចំនួនមនុស្សក្រោមអាយុ ១៨ ឆ្នាំ ធ្វើពេស្យាចារប្រហែលលើសពីរលាននាក់។ អ្នកប៉ាន់ស្មានល្បីៗ និយាយថា "តួលេខមួយលានសម្រាប់ទ្វីបអាស៊ីម្នាក់ឯង, ហើយ ៣០០.០០០ សម្រាប់សហរដ្ឋ"។

ទោះបីមានពេស្យាចារភាគច្រើនជាក្មេងស្រី, នៅក្នុងផ្នែកនៃពិភពលោកជាច្រើន សូម្បីក្មេងប្រុសក៏ត្រូវបានគេប្រើសម្រាប់រកស៊ីផ្លូវភេទដែរ។

យោងតាមមន្ត្រីរបស់ក្រុមឃ្លាំមើលក្រៅរដ្ឋាភិបាលឈ្មោះ ECPAT (End Child Prostitation in Asia Tourism) ពួកទេសចរសម្បូរប្រាក់បានឱ្យដឹងថា ជីវិតមនុស្សមានតម្លៃថោក នៅក្នុងប្រទេសតតិយលោក។

ព្រោះហេតុអ្វី ពេស្យាចារកុមារបានក្លាយទៅជាមាន ប្រជាប្រិយ៍ នៅក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ? ហេតុផលដ៏គួរឱ្យជឿមួយនោះគឺ គេខ្លាចឆ្លងវីរុស (HIV), ជាមេរោគ ដែលបង្កឱ្យកើតជម្ងឺអេដស៍ (AIDS) (The Acquired Immuno-deficiency Syndrom) ដ៏សែនតក់ស្លុត។

ទេសចរផ្លូវភេទ ( Sex tourists) គិតថា ក្មេងៗគ្មានជំងឺអេដស៍ទេ។ លោករ៉ាម៉េស ស្រេស្ថា (Ramesh Shrestha), ជាមន្ត្រីអ៊ុយនីសេហ្វ (UNICEF) ម្នាក់ បំរើការនៅក្រុងហាណូយ ប្រទេសវៀតណាម បានសង្កេតឃើញថា " ដោយមានសេចក្តីភ័យខ្លាចជំងឺ HIV កាន់តែខ្លាំងឡើង, មនុស្សជាច្រើន តែងស្វះស្វែង

រកជនរងគ្រោះក្មេងៗ ហើយដោយហេតុអកុសល សំណូមពរនេះ ត្រូវបានស្វាគមន៍ដោយពពួកមនុស្សល្មោភកាមមានវ័យកណ្ដាល"។

ពួកអ្នកជំនាញការ លើកយកភាពក្រីក្រ ថាជាហេតុផលដែលកុមារៗត្រូវគេចាប់បង្ខំឱ្យចូលទៅក្នុងជំនួញផ្លូវភេទ។ លោក Ernesto F. Herrera សមាជិកព្រឹទ្ធសភា ហ្វីលីពីន បាននិយាយនៅក្នុងសុន្ទរកថាដ៏សំខាន់របស់គាត់ថ្មីៗនេះថា "កុមារៗត្រូវបានអូសទាញទៅធ្វើពេស្យាចារ ពិព្រោះរបរនេះរកប្រាក់បានច្រើនជាងការងារធម្មតា"។ ក្មេងៗ នៅតាមផ្លូវនៃទីក្រុង រីយ៉ូ, ណៃរ៉ូប៊ី, ម៉ានីល និងប៊ុមបៃ ច្រើនតែប្រកបការងារក្នុងពេស្យាកម្ម ដើម្បីមានជីវិតរស់រានហើយនេះក៏មិនមែនជាជម្រើសដែរ។ នេះគឺជាការងារសង្កេតរបស់សមាជពិភពលោកប្រឆាំងអាជីវកម្មផ្លូវភេទលើកុមារ។ សមាជបានលើកយកមកនិយាយពីស្ថានភាពកុមារក្រីក្រជុំវិញពិភពលោក កំពុងត្រូវបង្ខំចិត្តឱ្យចូលក្នុងឆាកជីវិត ដើម្បីស្វែងរកការងារដោយមិនបានរៀនសូត្រ។

នៅក្នុងប្រទេសខ្លះទៀត ក្មេងៗនៅតាមផ្លូវ គឺជាក្មេងដែលត្រូវបានគេជ្រើសរើសមុនគេឱ្យចូលទៅក្នុងពេស្យាកម្ម ហើយច្រើនតែរក្សាទុកឱ្យនៅផ្ទះបន។ ក្មេងៗ ផ្សេងទៀតរសាត់អណ្ដែតនៅក្នុងពេស្យាកម្ម លើមូលដ្ឋានធម្មតា ហើយមិនមែនជាផ្នែកនៃបណ្ដាញណាមួយទេ។ ដោយគ្មានគ្រួសារ ពួកគេត្រូវតែស្វែងរកមធ្យោបាយណាមួយដើម្បីរស់។ ការផ្លាស់ប្ដូរទីលំនៅក្នុងសង្គម រុញច្រានក្មេងៗទាំងនោះទៅក្នុងការស្វែងរកមធ្យោបាយចិញ្ចឹមជីវិត ដែលពួកគេដឹងថា ជាមធ្យោបាយថោកទាប ប៉ុន្តែផ្ដល់ឱ្យនូវការប៉ះប៉ូវមួយដ៏ជាទីកក់ក្ដៅជាង។

នៅអាមេរិកឡាទីន, ក្មេងៗនៅតាមផ្លូវ ចេញមកពីគ្រួសារក្រីក្របំផុត, ច្រើនតែមកពីតំបន់មានអំពើហិង្សា, ជាញឹកញយពួកគេត្រូវគ្រួសារបណ្ដេញចេញ,

នេះបើយោងតាមលោក ពែរ-អេរិក អាស្ត្រូម (Per-Erik Astrom) នៃសមាគមសាខាស៊ុយអែតរបស់អង្គការ "មូលនិធិសង្គ្រោះកុមារ" ។ លោកបាននិយាយទៀតថា "កុមារអាយុ ១៥ ឆ្នាំម្នាក់ ក្នុងទីក្រុង រីយ៉ូ, ប្រសិនបើវាបានរស់រានរហូតមក, គឺវាបានស្គាល់អ្វីៗទាំងអស់ អំពីការរស់រានមានជីវិត, វាមានប្អូនស្រីពីរនាក់ ហើយបានក្លាយខ្លួនជាមេអណ្ដើកបនខ្លួនឯង"។

អង្គការឈីលីមួយ សរសេរកាត់ CERSO រាយការណ៍ថា : "ម្ដាយទាំងឡាយបានបញ្ជូនកូនៗរបស់ពួកគេ ទៅឱ្យដើរតាមផ្លូវដើម្បីសុំទាន ទោះបីពួកគេដឹងនូវគ្រោះថ្នាក់ ដែលក្មេងស្រីអាចក្លាយខ្លួនជាអ្នកសេពថ្នាំញៀនស្រវឹង និងជាស្រីពេស្យាចារក៏ដោយ"។ អស់ពេលជាង ១០ ឆ្នាំហើយមកដល់ពេលនេះ, លោកស្រី ឡាដាវ៉ាន់ វង្សស្រ៊ីវង្ស បានជាប់ជាសមាជិកសភាពីរលើក មកពីខេត្ត បាយ៉ាវ ភាគខាងជើង ប្រទេសថៃ បានតស៊ូប្រឆាំងពេស្យាកម្មកុមារ, ជាឧស្សាហកម្មមួយដែលគេប៉ាន់ស្មានថា រកប្រាក់បាន ១.៥០០ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។

បូជនីយកិច្ចរបស់លោកស្រី ប្រឆាំងនឹងជំងឺសង្គមនេះ ប្រើប្រាស់យុទ្ធសាស្ត្របួនយ៉ាង ដែលរួមមានទាំង ការឃោសនាធ្វើឱ្យប្រជាជនយល់ដឹងនូវហេតុ, ផល និងមធ្យោបាយដើម្បីទប់ស្កាត់បញ្ហា។

លោកស្រី ឡាដាវ៉ាន អាយុ ៤០ ឆ្នាំ ដែលមកពីគណបក្សប្រជាធិបតេយ្យ ជាបក្សប្រឆាំងរបស់ប្រទេសថៃ, និងជាប្រធានមូលនិធិអភិវឌ្ឍន៍ស្ត្រីវ័យក្មេងភាគខាងជើង មានប្រសាសន៍ថា : ទោះបីមនុស្សទូទៅមានការយល់ដឹងច្រើនអំពីបញ្ហា, ក៏គង់នៅមានឪពុកម្ដាយ ដែលនៅតែអោបក្រសោបគំនិតចាស់គំរិលថា ពេស្យាកម្ម គឺជាមុខរបរមួយល្អដោយពិត រកបានចំណូលខ្ពស់សម្រាប់កូនស្រីៗរបស់ពួកគេ។ យើងកំពុងខិតខំប្ដូរគំនិតទាំងអស់នោះ ដោយកំពុងហ្វឹកហ្វឺនវគ្គ

សិប្បសាលា (Workshops), ការប្រជុំ, និងសិក្ខាសាលា (Seminars) ជាមួយឪពុកម្តាយ ក៏ដូចជាធ្វើការផ្សព្វផ្សាយពត៌មានតាមរយៈប្រព័ន្ធផ្សាយពត៌មាន។

លោកស្រី ឡាដាវ៉ាន និយាយថា ដើម្បីឱ្យច្បាប់អនុវត្តទៅប្រកបដោយប្រសិទ្ធភាព, វាជាការតម្រូវមួយឱ្យប្រទេសទាំងអស់ចុះកិច្ចព្រមព្រៀង និងកិច្ចសហប្រតិបត្តិការ ដើម្បីចាត់ទុកការរំលោភបំពានលើស្ត្រី និងកុមារ ថាជាទោសឧក្រិដ្ឋមួយ ពីព្រោះបញ្ហាពេស្យាកម្មកុមារ គឺមិនមែនជាអំពើដែលប្រជាជនធ្វើឡើងតែម្នាក់ឯងទេ គឺជនបរទេសទាំងឡាយ មានចំណែកក្នុងរឿងនេះដែរ។

សេចក្តីត្រូវការមកពីពួកទេសចរអឺរ៉ុប និងសេចក្តីត្រូវការមកពីបណ្តាប្រទេសអភិវឌ្ឍន៍ដទៃទៀត ដើម្បីបាននារីក្មេងៗ ហាក់ដូចជាគ្មានកំហិតព្រំដែនទេ។ យោងតាមក្រុមគាំទ្ររបស់កុមារអន្តរជាតិឈ្មោះដែនដីរបស់មនុស្ស (Terre des Hommes), ជារៀងរាល់ឆ្នាំ មានទេសចរផ្លូវភេទ ចំនួនរាប់សិបពាន់នាក់ មកពីប្រទេសអាល្លឺម៉ង់ម្នាក់ឯង ធ្វើទស្សនកិច្ចប្រទេសថៃដោយមានចំនួនប្រមាណ ១០% នៃពួកទេសចរទាំងនោះ ជាប់ពាក់ព័ន្ធក្នុងរឿងភេទជាមួយអនីតិជន។ នេះគឺជាហេតុពិតដែលនារីក្មេងៗ មកពីគ្រួសារក្រីក្រ ដែលគ្មានមធ្យោបាយបន្តការអប់រំរបស់គេទៅកំរិតមធ្យម សិក្សា កំពុងត្រូវបានគេទាក់ទាញ ទៅក្នុងពេស្យាកម្ម។

គេបានរាយការណ៍ថា មានអ្នកជំនួញសញ្ជាតិស្វីសម្នាក់ បានរំលោភសេពសន្ថវៈជាមួយកុមារ ១.៥០០ នាក់ នៅក្នុងប្រទេសស្រីលង្កា ក្នុងចន្លោះពេលប្រាំបីឆ្នាំ។

មានការដុះដាលឧស្សាហកម្មខាងអាជីវកម្ម ជួញដូរភេទរបស់កុមារសម្រាប់គោលបំណងបង្ហាញរូបភាពអាសអាភាស។ ប្រទេសថៃមានអត្រាខ្ពស់បំផុតខាងការរត់ពន្ធក្មេង និងរូបភាពអាសអាភាសយុវជន។ នេះបង្ហាញឱ្យឃើញប្រភេទ

ថៅកែទាបបំផុត នៃសម្ភារៈរូបភាពសេពកាមកូនក្មេង ដែលមាននៅក្នុងខ្សែថតវីដេអូលួចលាក់ ផ្ទុកនូវឆាកទុរាចារ ចូលចិត្តសេពកាមភេទដូចគ្នា ជាមួយកុមារ។

ការរកឃើញ ក្រុមចាប់ជំរិត និងសេពកាមជាមួយកុមារដ៏សែនគគ្រោតគគ្រាតមួយនៅក្នុងប្រទេសបែលហ្សិក បានពញាក់មតិសាធារណៈ ហើយបង្ហាញនូវហេតុ-ការណ៍ពិតយ៉ាងសែនឈឺចាប់ថា អាជីវកម្មផ្លូវភេទលើកុមារមិនមែនជាបញ្ហាមួយមាននៅក្នុងប្រទេសថៃ, ព្រេស៊ីល, បង់ក្លាដេស, ឥណ្ឌា និងស្រីលង្កា តែប៉ុណ្ណោះទេ, វាមានយ៉ាងជាក់ស្ដែងនៅក្នុងគ្រប់ប្រទេស រួមទាំងទ្វីបអឺរ៉ុបផង។ សមាជិកពិភពលោកប្រឆាំងអាជីវកម្មជួញដូរផ្លូវភេទលើកុមារ បានផ្ដើមគំនិតធ្វើសហប្រតិ-បត្តិការនៅថ្នាក់មូលដ្ឋាន, ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ដើម្បីបង្ក្រាបបញ្ហាជួញដូរផ្លូវភេទលើកុមារ។ ដោយផ្អែកលើការប្ដេជ្ញាចិត្តមានកំរិតអន្តរជាតិ, សមាជពិភពលោកបានដាក់ចេញនូវអាទិភាពទាំងឡាយសម្រាប់ការពារ ថែរក្សា ធ្វើនីតិសម្បទា និងធ្វើសមាហរណកម្មកុមាររងគ្រោះ ដោយអាជីវកម្មផ្លូវភេទ។

ពាក្យថា "ពលកម្មកុមារ" ក៏ត្រូវបានគេឱ្យនិយមន័យថា ជាការប្រើក្មេងប្រុស-ក្មេងស្រី នៅពេលពួកគេមានវ័យខ្ចីពេកឱ្យធ្វើការ ដោយឱ្យឈ្នួល ឬនៅពេលពួកគេត្រូវបានប្រើឱ្យធ្វើការមិនសមស្រប ឬមិនមានសុវត្ថិភាពសម្រាប់វ័យជាកុមាររបស់គេ ក្រោមស្ថានភាពបង្ករបួសស្នាមដល់សុខមាលភាពរបស់ពួកគេ។ ពាក្យនេះ មានន័យផ្សេងៗពីគ្នា នៅពេលវេលាខុសៗពីគ្នា និងនៅក្នុងសហគមន៍ខុសៗគ្នា, អាស្រ័យលើទស្សនៈរបស់សង្គម ចំពោះការទទួលខុសត្រូវរបស់សង្គមនេះសម្រាប់យុវជនរបស់ខ្លួនផង។

នៅប្រទេសម៉ាឡេស៊ី ការប្រើកុមារឱ្យធ្វើការ ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិនៃច្បាប់ឆ្នាំ ១៩៦៦ ស្ដីពីការប្រើកុមារ និងមនុស្សវ័យក្មេង ដែលចែងថា

កុមារម្នាក់ ឬមនុស្សណាមួយមានអាយុក្រោម ១៤ ឆ្នាំ មិនអាចប្រើឱ្យធ្វើការបាន ទេ វៀរលែងតែឋិតនៅក្រោមល័ក្ខខ័ណ្ឌដ៏ច្បាស់លាស់ណាមួយ ដូចជាការងារស្រាលៗ សមស្របទៅនឹងសមត្ថភាពរបស់ក្មេងប្រុស-ស្រី នៅក្នុងកិច្ចការណាមួយធ្វើឡើងដោយគ្រួសារ។ ឋិតក្រោមស្ថានភាពដោយឡែក ដូចជាការប្រើឱ្យធ្វើការក្នុងហាង, កុមារមិនត្រូវមានអាយុតិចជាង ១៦ ឆ្នាំឡើយ។

នាកយដ្ឋានពលកម្មម៉ាឡេស៊ី បានរឹតបន្តឹងសកម្មភាពអនុវត្តច្បាប់របស់ខ្លួន ក្រោមពន្លឺនៃការកើនឡើងនូវពាក្យបណ្ដឹងទាក់ទងនឹងពលកម្មកូនក្មេងខុសច្បាប់, ជាពិសេស ក្នុងអំឡុងពេលថ្ងៃឈប់រៀននៅសាលា។ ការប្រើកុមារដោយខុសច្បាប់ ផ្ដើមចេញជាដំបូង អំពីការខ្វះកម្លាំងពលកម្មយ៉ាងស្រួចស្រាល់នៅក្នុងប្រទេស។ សកម្មភាពអនុវត្តច្បាប់របស់នាយកដ្ឋាន ត្រូវបានរឹតបន្តឹងក្នុងទូទាំងប្រទេស តាមរយៈអធិការកិច្ចតាមកាលកំណត់ ក៏ដូចជា តាមរយៈការចុះត្រួតពិនិត្យដោយឥតប្រាប់ឱ្យដឹង ទាំងនៅពេលថ្ងៃ ទាំងនៅពេលយប់។

ពួកអ្នកជំនាញការខាងកុមារ នៅក្នុងការប្រជុំថ្នាក់តំបន់ ក្នុងក្រុងម៉ានីល បាននិយាយថា ពួកគេបានត្រូវការមិនមែនគ្រាន់តែធនធានយ៉ាងច្រើនសម្រាប់សុខមាលភាពរបស់កុមារប៉ុណ្ណោះទេ. ប៉ុន្តែ ត្រូវការឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា អំពីប្រព័ន្ធផ្សាយពតិមាន ដើម្បីជួយបញ្ជូនដំណឹងស្ដីពីគ្រោះថ្នាក់មកលើកុមារអាស៊ី ដ៏ងាយរងគ្រោះ ទៅដល់អ្នកដឹកនាំនយោបាយថែមទៀតផង។

លោកស្រី ប្រាតិម៉ា កាលេ (Pratima Kale), នាយកតំបន់នៃមូលនិធិនៃសហប្រជាជាតិសម្រាប់កុមារ (Unicef) - ប្រចាំអាស៊ីខាងកើត និងសមុទ្រប៉ាស៊ីហ្វិក បាននិយាយថា : "ពួកកុមារក្រីក្រ, ដែលត្រូវគេធ្វើអាជីវកម្ម ឬបង្ខំឱ្យធ្វើការ, រំលឹកប្រាប់ពិភពលោកថា ការដុះដាលសេដ្ឋកិច្ច មិនបានផ្ដល់ឱ្យពួកគេនូវអត្ថ

ប្រយោជន៍នៃសេចក្តីចម្រុងចម្រើនទេ។ ស្ថានភាពនៃវិសមធម៌អាចនាំ, ហើយជាញឹកញយនាំទៅដល់ការគ្រោធខឹង, ការខកចិត្ត និងអំពើហិង្សា ប្រសិនបើសេចក្តីត្រូវការជាមូលដ្ឋានរបស់ពួកគេមិនបានសម្រេចទេ, និងប្រសិនបើ ពួកគេមិនឃើញសេចក្តីសង្ឃឹមណាមួយសម្រាប់អនាគតទេ ", លោកស្រីនិយាយដូច្នេះ នៅពេលចាប់ផ្តើមការប្រជុំកំពូលអាស៊ី ស្តីពីសិទ្ធិកុមារ និងប្រព័ន្ធផ្សាយពត៌មាន។

( នៅមានត)

<u>*អ្នកដែលស្រឡាញ់ខ្លួនឯង មិនត្រូវធ្វើឱ្យអ្នកដទៃឈឺចាប់ទេ:*</u>

*"គ្រប់ទិសទី ដែលគេសញ្ចរទៅដោយមនោសញ្ចេតនា, គេមិន ឃើញមានមនុស្សណា ជាទីស្រឡាញ់ជាងខ្លួនឯងទេ, បើដឹងថាអាត្មាខ្លួនជាទីស្រឡាញ់ដូច្នេះ, ចូរកុំធ្វើឱ្យអ្នកឯទៀតរងការឈឺចាប់!"*

សំយុត្តនិកាយ

# សីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស

(តចប់)

ឆយ យីហ៊ាង
(បណ្ឌិត ឧស្សៀនវិជ្ជា)

## III. ហេតុអ្វីបានជាសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនស្រុតចុះ ?

សព្វថ្ងៃ សង្គមទាំងមូលកំពុងស្តីបន្ទោសថា សីលធម៌វិជ្ជាជីវៈរបស់គ្រូស្រុតចុះ ឬថាគ្រូខ្វះសីលធម៌វិជ្ជាជីវៈតែម្តង។ ការស្តីបន្ទោសនេះធ្វើឱ្យពិភពគ្រូបង្រៀនអាប់ឱន មានការខ្មាស់អៀន និងមិនអាចឆ្លើយតបចំពោះពាក្យ ចាក់ដោតទាំងឡាយដែលមានទាំងនៅទីក្រុង ទាំងនៅជនបទ ទាំងនៅក្នុងភោជនីយដ្ឋាន ទាំងនៅក្នុងសាលប្រជុំ។ អ្នកបន្ទោសត្មះតិះដៀលមើលឥតឃើញសោះនូវចំណុចល្អរបស់គ្រូបង្រៀន។ គេយល់ថា សូម្បីតែបន្តិចក៏គ្មានចំណុចល្អនោះផង។ អង្គការក្រៅរដ្ឋាភិបាលខ្លះបានលើកបញ្ហាគុណភាពអប់រំមកពិភាក្សាក្នុងសន្និសីទសិក្ខាសាលា ឬវេទិកាសាធារណៈ។ ការពិភាក្សាបានប្រមូលផ្តុំទៅលើសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន ហើយដែលសម្តីខ្លះរបស់ វាគ្មិនធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ឧត្តមគតិ និងសេចក្តីថ្លៃថ្នូររបស់គ្រូបង្រៀន។

ការនិយាយពីមាត់មួយទៅមាត់មួយថា គ្រូបង្រៀនបាត់បង់សីលធម៌វិជ្ជាជីវៈបែបនេះ បាក់ធ្វើឱ្យគ្រូបាត់បង់តួនាទីជាច្រើនរបស់ខ្លួន ដូចបានពោលរួចមកហើយ និងបាក់ធ្វើឱ្យគ្រូឃ្លាតឆ្ងាយពីមហាជន។ យើងមិនអាចអះអាងថា ការស្តី

បន្ទោសនោះជាការខុសទាំងស្រុងទេ តែយើងក៏មិនអាចទទួលស្គាល់ថា ការស្តីបន្ទោសនោះជាការត្រូវទាំងស្រុងដែរ ។ ព្រោះអ្វី ?

បើយើងយករបបសង្គមរាស្ត្រនិយមមកប្រៀបធៀប យើងឃើញសីលធម៌វិជ្ជាជីវៈសព្វថ្ងៃមិនទាន់ស្មើបាន ឬនៅពេលខ្លះមានការស្រុតចុះមែន។ ក្នុងរបបសង្គមរាស្ត្រនិយម គ្រូបង្រៀនមានបៀវត្សខ្ពស់ ប្រកបមុខរបរនេះដោយសេចក្តីពេញចិត្តធ្វើឱ្យគុណភាពអប់រំមានកម្រិតខ្ពស់ ស្មើមុខស្មើមាត់ជាមួយប្រទេសនានាដែលមានវិស័យអប់រំជឿនលឿន ។

បើយើងយករបបសាធារណរដ្ឋខ្មែរ និងរបបកម្ពុជាប្រជាធិបតេយ្យមកប្រៀបធៀបយើងឃើញថា វិស័យអប់រំសព្វថ្ងៃមានកម្រិតខ្ពស់ ឯសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនក៏មានលក្ខណៈគួរឱ្យសរសើរនៅលើចំណុចជាច្រើន ព្រោះបុគ្គលិកសិក្សាភាគច្រើនបានខិតខំយ៉ាងសស្រាក់សស្រាំបង្ហាត់ បង្រៀន អប់រំសិស្ស និស្សិត ទោះបីខ្លួនមានបៀវត្សតិច ស្ថិតនៅក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ ។ បញ្ហានេះ គ្រូបង្រៀននិយាយដោយឡែក មន្ត្រីបុគ្គលិកគ្រប់វិស័យនិយាយរួម បានរួមចំណែកស្តារប្រទេសជាតិឡើងវិញពីចំណុចសូន្យ ពីចំណុចដែលគ្រួសារនីមួយៗ គ្មានសម្ភារៈ គ្មានអង្ករ គ្មានប្រាក់ គ្មានទីផ្សារ គ្មានក្រសួង គ្មានមន្ទីរណាមួយឡើយ ព្រោះរបបប្រល័យពូជសាសន៍ បានបំផ្លិចបំផ្លាញខ្ទេចខ្ទីគ្រប់វិស័យ ។

អ្វីដែលយើងទទួលស្គាល់ថាត្រឹមត្រូវ គឺគួរបែងចែកឱ្យច្បាស់លាស់រវាងគ្រូដែលមានសីលធម៌វិជ្ជាជីវៈ និង គ្រូដែលខ្វះសីលធម៌វិជ្ជាជីវៈ ។ យើងសង្កេតឃើញថាបុគ្គលិកសិក្សាមួយចំនួនមិនបង្កឱ្យមានអំពើពុករលួយ ទោះខ្លួនមានជីវភាពលំបាកយ៉ាងណាក៏ដោយ ។ ម្យ៉ាងគេធ្វើជាគ្រូបង្រៀន ។ ម្យ៉ាងទៀតគេប្រកបមុខរបរ

ផ្សេង។ ការណ៍នេះ ក៏ធ្វើឱ្យខូចពេលវេលាស្រាវជ្រាវរបស់គេដែរ តែអ្វីដែលល្អនោះគឺគេនៅតែខិតខំផ្តល់ចំណេះដល់សិស្ស និស្សិត រៀងរហូតមក។ យើងក៏សង្កេតផងដែរថា បុគ្គលិកសិក្សាមួយចំនួនទៀតរួមចំណែកបង្កឱ្យមានកអំពើពុករលួយ ខ្វះស្មារតីយកចិត្តទុកដាក់ចំពោះការបង្រៀន ការអប់រំ និងការស្រាវជ្រាវ ធ្វើឱ្យបាត់បង់ទំនុកចិត្តពីសំណាក់សិស្សានុសិស្ស ដែលពីមួយថ្ងៃទៅមួយថ្ងៃ សិស្សហាក់បីក្លាយជាអ្នកត្រូវគេចាប់ជីវិតប្រកបដោយគ្រោះថ្នាក់បំផុត ព្រោះស្មារតីរបស់សិស្សនោះពោរពេញដោយសភាពខ្មៅងងឹត ដោយគេបង្ខំចិត្តធ្វើតាមគ្រូទាំងទើសទ័លបំផុត។ គេស្រែកថា *"លុយ ! លុយ ! លុយ ! គ្រប់មុខវិជ្ជា"* ។ បើគ្រូប្រើរំពាត់ទៀតនោះសតិអារម្មណ៍របស់សិស្សរឹតតែខ្មៅងងឹតថែមទៀត។

ដោយសារបៀវត្សតិច ដោយសារគ្មានមុខរបរទី២ ដោយសារប្រៀបធៀបជាមួយជីវភាពខាងក្រៅ គ្រូបើកបង្រៀនក្រៅម៉ោង ដែលគេឱ្យឈ្មោះថា *"រៀនគួ"* នៅក្បែរម៉ោងបង្រៀនធម្មតា លក់មេរៀនផង និងបង្ខំឱ្យចម្លងមេរៀនផង ចាប់ឆ្នោតដាក់ពិន្ទុ រៃអង្គាសជាញឹកញាប់ ...។ សិស្សណាបង់ប្រាក់ សិស្សនោះច្រើនបានពិន្ទុល្អ។ ជួនកាលការណ៍នេះមិនមែនមានតែក្នុងបឋមសិក្សា និងមធ្យមសិក្សាទេ តែអាចមាននៅក្នុងឧត្តមសិក្សាទៀតផង។ នៅពេលប្រឡងជ្រើសរើសម្តងៗ អាចមានអំពើពុករលួយជាច្រើន។ ការណ៍នេះគួសបញ្ជាក់ថា គ្រូលែងមានតួនាទីជាមាតាបិតា ជាមិត្តភក្តិ ជាទីប្រឹក្សា ... ទៀតហើយ។ គ្រូគ្រាន់តែជាមនុស្សសាមញ្ញម្នាក់ដែលបំពេញករណីយកិច្ចជា *"គ្រូដើម្បីប្រាក់"* ។ គ្រូកំពុងតែធ្វើឱ្យគ្រូឃ្លាតឆ្ងាយពីធម្មជាតិជាគ្រូ។ គ្រូគ្រាន់តែជាអ្នកចេះម្នាក់ដែលខ្វះ សីលមនសិការ។ ហេតុនេះ គ្រូលែងទទួលការគោរពពីមាតាបិតាសិស្ស លែងទទួលការគោរពដោយ

ស្មោះពីសំណាក់មហាជន ហើយត្រូវសង្គមធ្វើឱភាសកម្មថា *"គ្រូទាំងអស់សុទ្ធតែពុករលួយ"* ។ នោះហើយជាកត្តាសំខាន់ ដែលធ្វើឱ្យសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនស្រុតចុះ។ សីលធម៌វិជ្ជាជីវៈស្រុតចុះ មានន័យថា គ្រូបាត់បង់ឧត្តមគតិ ផ្ទុយពីគំនិតដែលចែងថា *"គ្រូត្រូវរីកចម្រើនទៅដល់ភាពល្អប្រសើរនៅក្នុងទិដ្ឋភាពនីមួយៗ នៃជីវិតរបស់ខ្លួន ដែលទាក់ទងនឹងការបង្រៀន"* ។

អាចមានបាតុភូតជូរចត់មួយចំនួនដែលជួនកាលមានលក្ខណៈលាក់កំបាំងជួនកាលមានលក្ខណៈចំហរវាងគ្រូ និងសិស្ស : គ្រូមើលសិស្សដែលមិនបង់ *"លុយរៀនគួ"* ក្នុងផ្លូវអាក្រក់ សិស្សមិនឃើញគ្រូបង្ខំឱ្យបង់ *"លុយរៀនគួ"* ពោរពេញដោយសេចក្ដីប្រមាថ។ ការណ៍នេះកើតឡើងរាល់ថ្ងៃ ជាសកម្មភាពដដែលៗ ហើយក្លាយជាការនិយាយថា ឬស្សីទ្រេត និងដូល ឯទំពាំងក៏លំបាកនឹងឈរត្រង់ដែរ។ ឯណាទៅដែលហៅថាអនាគតពលរដ្ឋ ?

ករណីដូចបានពោលខាងលើមានន័យថា យើងកំពុងបំបាត់នូវអ្វីដែលហៅថាសេចក្ដីរីករាយដែលកើតមានរវាងគ្រូ និងសិស្ស នៅក្នុងកណ្ដាលមជ្ឈមណ្ឌលអប់រំ។ ធ្វើបែបនេះក៏មានន័យថា អប់រំដែរ តែអប់រំទៅរកផ្លូវអាក្រក់ ទៅរកការមិនពេញចិត្ត ទៅរកគ្រោះថ្នាក់ដល់ប្រទេសជាតិ។ **អាយ ឈិញ** (I Ching) បានពោលថា *"នៅពេលប្រជាជនពេញចិត្ត ប្រជាជនភ្លេចអស់ការលំបាករបស់ខ្លួន។ នៅពេលដែលមានឧបសគ្គមកកាត់ផ្ដាច់ការពេញចិត្ត ប្រជាជនធ្វើការដោយឥតគិតពិចារណា។ សារៈសំខាន់នៃការពេញចិត្ត គឺត្រូវធ្វើដូចម្ដេចដើម្បីជំរុញឱ្យប្រជាជនមានសេចក្ដីក្លាហាន"* *(... when the people are led in pleasing way, the people forget their toil; when difficulties are faced in a pleasing*

*way, the people are mindless of dying. The importance of pleasing is how the people are encouraged.)*[១] ។

## IV. តើគួរធ្វើយ៉ាងដូចម្ដេច ដើម្បីស្ដារសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនឡើងវិញ ?

យើងធ្លាប់និយាយថា គ្រប់វិស័យទាំងអស់ត្រូវលិចលង់ទាំងស្រុង នៅក្នុងរបបប្រល័យពូជសាសន៍ ហើយវិស័យទាំងនោះត្រូវបានស្ដារឡើងវិញជាបណ្ដើរៗ ពីឆ្នាំ ១៩៧៩។ យើងឃើញថា : ដោយសារការខិតខំនោះ កម្លាំងផលិតកម្ម មធ្យោបាយផលិតកម្មរចនាសម្ព័ន្ធក្រោម និងរចនាសម្ព័ន្ធលើ ដែលជាផ្នែកសំខាន់ៗនៃនិមិត្តកម្ម សេដ្ឋកិច្ច-សង្គមរបស់យើងបានកកើតឡើងពេញរូបរាងដូចសព្វថ្ងៃនេះ។ នៅក្នុងរចនាសម្ព័ន្ធលើ មានសង្គមញ្ញាណ និងអង្គការ ឬស្ថាប័នគាំទ្រសង្គមញ្ញាណនោះ ដែលធ្វើឱ្យកម្ពុជាមានលក្ខណៈពេញលេញជារដ្ឋមួយប្រកប ដោយអធិបតេយ្យភាព។

### គំនូសបំព្រួញទី ៦




---

១ I Ching, Op-cit, page 130.

កត្តាសំខាន់ទាំង ៤ នេះ មានលក្ខណៈជាសម្ភារៈ។ វាបានកើតឡើងដោយកម្លាំងកាយរបស់មនុស្ស ដែលត្រូវបញ្ជាដោយកម្លាំងស្មារតី ដែលជាកម្មសិទ្ធិរបស់មនុស្សដែរ។ នៅក្នុងនិមិត្តកម្មសេដ្ឋកិច្ច-សង្គមនោះ ក្រសួងអប់រំបាននឹងកំពុងប្រើប្រាស់កាយពលកម្ម និងបញ្ញាពលកម្ម ធ្វើឱ្យវិស័យអប់រំលេចត្រដែតឡើង។ ការណ៍នេះគួសបញ្ជាក់ថា ក្រសួងអប់រំបានបណ្តុះសីលធម៌វិជ្ជាជីវៈជារឿយៗ ដល់បុគ្គលិកសិក្សា។ ប៉ុន្តែជោគជ័យនេះ អាចមិនទាន់សមល្មមនឹងតម្រូវការនៃប្រទេសជាតិ ដែលចេះតែវិវត្តទៅមុខរៀងរាល់ថ្ងៃ។

យើងក៏មិនគួរបំភ្លេចផងដែរ នូវសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនមួយចំនួនដែលកំពុងធ្លាក់ចុះ ដោយបុព្វហេតុផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់គ្រូបង្រៀន។ បើមានការធ្លាក់ចុះពិតមែន ទោះចង់ក្តី ឬ មិនចង់ក្តី យើងត្រូវតែកែលំអឡើងវិញឱ្យសមស្រប តាមគោលការណ៍វិនិយោគជាអាទិភាព ៦ យ៉ាងនៃរាជរដ្ឋាភិបាល ដែលក្នុងនោះមានការបណ្តុះបណ្តាលធនធានមនុស្សផងដែរ[២]។ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា មានប្រសាសន៍ថា " *...ការបណ្តុះបណ្តាលធនធានមនុស្ស គឺជាប្រការដែលមិនអាច*

---

២- ការវិនិយោគជាអាទិភាពរបស់រាជរដ្ឋាភិបាលគឺ ÷

- វិស័យកសិកម្ម.
- វិស័យអគ្គិសនី.
- វិស័យឧស្សាហកម្ម.
- វិស័យគមនាគមន៍ ដឹកជញ្ជូន និងទូរគមនាគមន៍.
- ការបណ្តុះបណ្តាលធនធានមនុស្ស.
- វិស័យទេសចរណ៍។

*ត្រូវរង់ចាំបានឡើយ ។ វាសនា និងអនាគតនៃប្រទេសជាតិរបស់យើង ក៏ចំណុះមួយផ្នែកយ៉ាងសំខាន់ទៅលើការ បណ្តុះបណ្តាលធនធានមនុស្សនាពេលបច្ចុប្បន្ននេះរបស់យើងដែរ"*[៣] ។ ក្នុងសន្ទរកថាដដែលនោះ សម្តេចបានបញ្ជាក់ថា *"...គ្រូបង្រៀនគឺជាអ្នកសួពល ហើយបើគ្រូបង្រៀនប្រកបដោយសីលធម៌វិជ្ជាជីវៈជាប្រចាំ យើងនឹងបានពលរបស់ប្រទេសជាតិល្អទៅតាមនោះដែរ"*[៤] ។ ឆ្លងតាមទស្សនៈខាងលើនេះ យើងមើលឃើញកាន់តែច្បាស់ អំពីសីលធម៌វិជ្ជាជីវៈ និងតម្លៃរបស់វា។ សម្តេចបានសង្កត់ធ្ងន់ថា *"គ្មានសីលធម៌វិជ្ជាជីវៈ ... សង្គមក៏នឹងបាត់បង់នូវសីលធម៌របស់ខ្លួន ហើយវប្បធម៌-អរិយធម៌ក៏ត្រូវរលំរលាយទៅតាមនោះដែរ ទីបំផុតមុខវិជ្ជាឯកទេសក៏គ្មាន ផលប្រយោជន៍ដល់សង្គមទៀតឡើយ"*[៥] ។

បើយើងមើលឃើញទោស ដែលបណ្តាលមកពីការបាត់បង់សីលធម៌វិជ្ជាជីវៈបែបនេះហើយ គួរយើងរួមចំណែកដោះស្រាយទាំងអស់គ្នា។ ជាសំណូមពរខ្ញុំសូមស្នើឱ្យមានវិធីដោះស្រាយមួយចំនួនដូចតទៅ ÷

---

៣- សុន្ទរកថារបស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងពិធីសម្ពោធអាគារសាលបុណ្យ និងពិធីប្រគល់សញ្ញាប័ត្របញ្ចប់ការសិក្សាគរុនិស្សិត មធ្យមសិក្សាទុតិយភូមិជំនាន់ទី៥ គរុសិស្សមធ្យមសិក្សាបឋមភូមិឯកទេសបារាំងខ្មែរជំនាន់ទី២ នៅមហាវិទ្យាល័យគរុកោសល្យភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០០។

៤និង៥- សុន្ទរកថារបស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងពិធីសម្ពោធអាគារសាលបុណ្យ និងពិធីប្រគល់ សញ្ញាប័ត្របញ្ចប់ការសិក្សាគរុនិស្សិត មធ្យមសិក្សាទុតិយភូមិជំនាន់ទី៥ គរុសិស្សមធ្យមសិក្សាបឋមភូមិឯកទេសបារាំងខ្មែរជំនាន់ទី២ នៅមហាវិទ្យាល័យគរុកោសល្យភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០០។

៥- សូមមើលជាមួយលេខយោងទី ៤

១- គប្បីគ្រប់គ្រឹះស្ថានសិក្សា គ្រប់ភូមិសិក្សាឆ្លុះបញ្ចាំងឡើងវិញ មើលឱ្យឃើញកត្តាវិជ្ជមាន និងកត្តាអវិជ្ជមានក្នុងក្របខ័ណ្ឌនៃសីលធម៌វិជ្ជាជីវៈ ក្នុងរយៈពេលមួយឆមាសម្តង ដោយក្នុងគ្រឹះស្ថានសិក្សានីមួយៗ ត្រូវមានគណៈកម្មការត្រួតពិនិត្យមួយ ដែលមានលក្ខណៈអព្យាក្រឹត។

២- គប្បីបន្ថយម៉ោង *"រៀនគួ"* មុនម៉ោងសិក្សាធម្មតា ហើយបង្កើតឱ្យមាន *"ក្លឹបសិក្សា"* វិញ។ *"ក្លឹបសិក្សា"* នេះអាចធ្វើឱ្យសិស្ស និស្សិតរៀនពូកែ និងអាចជាប្រភពនៃការស្រាវជ្រាវ។

៣- គ្រូបង្រៀនត្រូវធ្វើការស្រាវជ្រាវ បកប្រែឯកសារ ចងក្រង និងនិពន្ធសៀវភៅផ្សេងៗ ហើយគួរក្រសួងអប់រំមានគោលការណ៍លើកទឹកចិត្តទាំងខាងសម្ភារៈ ទាំងខាងស្មារតី។ ការស្រាវជ្រាវ... ជាប្រការមិនអាចខ្វះបាន។

៤- គួរអប់រំសិស្សតាមសម្ព័ន្ធកាយរិទ្ធ ឬកុមារ និងយុវជនឈានមុខ ដែលប្រកបដោយសេចក្តីក្លាហាន មិនកំសាក មិនព្រហើន ដើម្បីត្រៀមខ្លួនធ្វើជាពលរដ្ឋមាំមួន។ ការណ៍នេះក៏បង្កលក្ខណៈឱ្យគ្រូបង្កើនសីលធម៌វិជ្ជាជីវៈរបស់ខ្លួនដែរ ព្រោះសម្ព័ន្ធកាយរិទ្ធនោះ ឬកុមារ និងយុវជនឈានមុខនោះ ត្រូវដឹកនាំដោយគ្រូ។

៥- សាលាត្រូវបង្កើនឱ្យអស់លទ្ធភាពនូវទំនាក់ទំនងរវាងគ្រូ និងឪពុកម្តាយសិស្ស ផ្តល់ពត៌មានដល់ ឪពុកម្តាយសិស្សឱ្យទាន់ពេលវេលាអំពីអក្បកិរិយាខុសឆ្គងរបស់សិស្ស។ ការឃ្លាតឆ្ងាយពីគ្នារវាងគ្រូ និងឪពុកម្តាយសិស្ស អាចធ្វើឱ្យឪពុកម្តាយសិស្សជឿតាមពាក្យមូលបង្កាច់ខ្លះ

ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់គ្រូ។ ឯការខិតជិតគ្នារវាងអ្នកទាំងពីរ គឺជាការរួមចំណែកបណ្តុះបណ្តាលសិស្សឱ្យកាន់តែល្អប្រសើរ។

៦- គួរធ្វើសិក្ខាសាលាស្តីពីសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន ដោយគ្រូបង្រៀនខ្លួនឯង ហើយអញ្ជើញអាជ្ញាធរផ្នែកឯកជន និងសង្គមស៊ីវិលមកស្តាប់ និងផ្តល់យោបល់វិញ។ គួរហ៊ានអារកាត់ចំពោះបញ្ហានេះដោយសេចក្តីក្លាហាន តែមិនគួរឱ្យសង្គមស៊ីវិលលើកបញ្ហានេះឡើង ដោយមានអ្នកយកវេទិកានេះ មកបកអាក្រាត ហើយគ្រូបែរជាធ្វើមិនដឹងមិនឮនោះទេ។ យើងត្រូវហ៊ានបង្ហាញពីចំណុចល្អ និងចំណុចខ្វះខាតដែលត្រូវកែលំអ។

ជាសេចក្តីសន្និដ្ឋានទូទៅ យើងយល់ថាពីឆ្នាំ ១៩៧៩ មកទល់សព្វថ្ងៃ វិស័យអប់រំកើនឡើងគួរឱ្យកត់សម្គាល់។ វិស័យអប់រំ បានបណ្តុះបណ្តាលធនធានមនុស្សច្រើនជាបង្គួរ ដើម្បីផ្តល់ជូនគ្រប់ស្ថាប័ននានា។ ការណ៍នោះ ពិតជាបានកើតចេញពីស្នាដៃរបស់គ្រូបង្រៀន ដែលទោះបីស្ថិតនៅក្នុងស្ថានភាពលំបាកស្មុគស្មាញក្នុងជីវភាពប្រចាំថ្ងៃក៏ដោយ។ នេះជាជ័យជំនះដែលរដ្ឋាភិបាលដណ្តើមបានជាបន្តបន្ទាប់។ ប៉ុន្តែ ទោះយ៉ាងណាក៏ដោយ គឺវិស័យអប់រំជួបនឹងឧបសគ្គមួយចំនួនដែលជាកត្តាអវិជ្ជមាន ហើយដែលត្រូវប្រញាប់ប្រញាល់ដោះស្រាយមិនអាចខានបាន។ នោះគឺការពង្រឹង និងការបង្កើនសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀន។ គួរកត់សម្គាល់ថា មិនមែនតែវិស័យអប់រំទេដែលត្រូវបំពេញការងារនេះ។ គ្រប់មុខវិជ្ជា គ្រប់ស្ថាប័ន គ្រប់មុខរបរ សុទ្ធតែត្រូវមានក្រម សីលធម៌របស់ខ្លួន។ បុគ្គលដែលបំពេញការងារក្នុងព្រឹទ្ធសភា រដ្ឋសភា រដ្ឋាភិបាល តុលាការ អង្គការសាពតិមាន កងកម្លាំង

ប្រដាប់អាវុធ ... មិនអាចជៀសវាងពីក្រមសីលធម៌បានទេ ព្រោះក្រមសីលធម៌នេះជាចំណុចមួយដ៏សំខាន់នៃការចុះកិច្ចសន្យាសង្គម ដើម្បីរស់នៅជាសន្តិសហវិជ្ជមានជាមួយគ្នា ។

ការមើលស្រាលចំពោះការពង្រឹង និងការពង្រីកក្រមសីលធម៌ និងសីលធម៌វិជ្ជាជីវៈរបស់គ្រប់មុខរបរចិញ្ចឹមជីវិតទាំងអស់ ជាកត្តាតម្រង់សង្គមទៅរកវិនាសកម្ម។ ចូរយើងចងចាំថា ការកើនឡើងនៃវិស័យអប់រំ និងការធ្លាក់ចុះនៃវិស័យអប់រំ សុទ្ធសឹងពាក់ព័ន្ធជាមួយវិស័យដទៃទៀត ហើយបើសង្គមធ្លាក់ចុះ ក៏មិនមែនបណ្តាលមកតែពីវិស័យអប់រំមួយទេ។ បើចង់ឱ្យសង្គមរុងរឿង ក៏មិនត្រូវពង្រឹងតែសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនម្នាក់ឯងដែរ ។ នាឡិកាដែលដើរត្រូវម៉ោង ក៏ព្រោះតែខ្នៅតូច ធំរបស់វាមានផាសុខភាពដូចគ្នា។ ទូកងដែលលឿន ក៏ព្រោះតែកីឡាករមានកម្លាំងកាយ និងអុំស្រុះគ្នា។ ការប្រើពាក្យតិះដៀល ដូចបាចទឹកដាក់គ្នា ជាការឥតប្រយោជន៍ ឬជា ការជំរុញឱ្យទំនាស់ស្មារតីកាន់តែរីករាលដាល ។

សូមបុគ្គលិកសិក្សាទាំងអស់ ក្រោកឈរឡើងដោយភ្ញាក់រឭកក្នុងមុខរបររបស់យើង រក្សាកិត្តិយស និងឧត្តមគតិរបស់យើង ហើយគួរពិចារណាថា *"អំពើអកុសលរបស់យើង ដូចជាអំពើពុករលួយជាដើម គ្រាន់តែជាផ្នែក ដ៏តូចមួយនៃអំពើអកុសលនៅក្នុងសង្គមប៉ុណ្ណោះ តែមានឥទ្ធិពលធំណាស់សម្រាប់ធ្វើឱ្យសង្គមទទួលរងនូវគ្រោះ មហន្តរាយ"*។

# ការរីកចម្រើននៃព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ

(ត)

ដោយ : **បណ្ឌិត ខ្លូត ធីតា**

## ៦. បញ្ហាយុវជនក្មេងវត្ត ចំពោះព្រះពុទ្ធសាសនា[១]

យ៉ាងដូចម្ដេចដែលហៅថាយុវជន ? យុវជននៅទីនេះគឺជាក្មេង ដែលយកទៅផ្ញើតាមវត្តអារាម ឱ្យរៀនសូត្រខាងព្រះពុទ្ធសាសនា ឬឱ្យរៀនសូត្រតាមសាលាជាច្រើនកម្រិតមាន បឋមសិក្សា ឬអនុវិទ្យាល័យ វិទ្យាល័យ មហាវិទ្យាល័យជាដើម ។ល។ ក្មេង ដែលស្ថិតនៅក្នុងគ្រួសារ ទៅសិក្សារៀនសូត្រនៅសាលាទាំងនេះភាគច្រើនជាក្មេងអ្នកក្រីក្រ ។

ក្មេងៗដែលយកទៅផ្ញើ នឹងលោកចៅអធិការវត្ត លោកគ្រូសូត្រ ឬព្រះថេរៈអង្គណាមួយ ។ គ្រូបាអាចារ្យអប់រំខាងព្រះពុទ្ធសាសនាបានបំបួសជាសាមណេរបំពេញភិក្ខុនៅទីនេះ យើងនឹងលើកយកបញ្ហាពួកយុវជន ដែលមាតាបិតាបានយកទៅផ្ញើតាមវត្តអារាមហើយ ដែលនៅសិក្សារៀនសូត្រខាងសាលាដូចបានរៀបរាប់ ។ ពេលយប់លោកចៅអធិការ លោកគ្រូសូត្រ ឬព្រះថេរៈបង្ហាត់ឱ្យថ្វាយ បង្គំព្រះរតនត្រ័យរៀនសូត្រព្រះបរិត្តខ្លះៗព្រមទាំង ពន្យល់បំភ្លឺខាងវិធីប្រតិបត្តិព្រះពុទ្ធសាសនាថែម ទៀតផង ។

មធ្យោបាយនេះសម្ដេចព្រះសុមេធាធិបតី ជួន ណាត លោកបានប្រើរួច

---

១- ខ្លូតធីតា តួនាទីព្រះពុទ្ធសាសនានៅកម្ពុជា (និក្ខេបបទថ្នាក់បណ្ឌិត) សាកលវិទ្យាល័យហាណូយ១៩៩៥

មកហើយ ព្រមទាំងសម្តេចព្រះសង្ឃនាយកវត្តបទុមវតី និងព្រះថេរៈទាំងឡាយ ដែលយើងបានឃើញពួកយុវជនទាំងនេះស្ថិតនៅតាមកុដិ ។ មាតាបិតាបានផ្តល់ជួយគ្រឿងបរិភោគនិងឧបភោគខ្លះ តែព្រះសង្ឃនៅមានការទទួលខុសត្រូវជាច្រើនដែរចំពោះការ ចិញ្ចឹមបីបាច់ ថែរក្សាពួកកូនក្មេងទាំងនេះ ។ សង្ឃកិច្ចនេះទុកជាសប្បុរសកិច្ចដ៏ប្រសើរជា សង្គហកិច្ចដ៏ឧត្តម ឈ្មោះថាជាធម្មបូជា ជាបូជាដ៏ឧត្តម ។ម្យ៉ាងវិញទៀតពួកយុវជននេះអាចធ្វើវេយ្យាវច្ចៈទទួលប្រាក់កាស ដែលគេបូជាចំពោះព្រះសង្ឃក្នុងពេលនិមន្តទៅចម្រើនព្រះបរិត្ត ឬសម្តែងធម៌ទេសនាក្នុងពិធីបុណ្យណាមួយ ។

ពួកយុវជនដែលស្ថិតនៅក្នុងគ្រួសារ ក៏ត្រូវបានមាតាបិតាអប់រំឱ្យរៀនទន្ទេញធម៌ នមស្ការព្រះរតនត្រ័យ វិធីប្រតិបត្តិព្រះពុទ្ធសាសនាផងដែរ រួចទើបត្រូវគ្រូបាអាចារ្យអប់រំតទៅទៀត ។ ធ្វើយ៉ាងនេះឈ្មោះថា រចនាពួកយុវជន ឱ្យមានចិត្តខ្ជាប់ខ្ជួននិងព្រះពុទ្ធសាសនា ព្រោះថាបើកាយវាចាចិត្តយកព្រះពុទ្ធជាមូលដ្ឋាន គឺកាយថ្វាយបង្គំព្រះរតនត្រ័យ វាចាធ្លាប់សូត្រទន្ទេញធម៌នមស្ការ ចិត្តនឹងផ្តងទៅកាន់ព្រះពុទ្ធសាសនាជាមិនខាន ។ ព្រោះហេតុដូច្នេះ ការអប់រំកាយ វាចា ចិត្ត ជាការអប់រំសំខាន់ ចំពោះពួកយុវ៉ន ហើយបើកាយ វាចា ដូលទៅខាងណា ចិត្តក៏ដូលទៅខាងនោះ គឺកាយ វាចា ជាហេតុ ចិត្ត ជាផល ។ អ្នកប្រាជ្ញប្រពៃណីនិយមនិយាយថា "មានតែចិត្តទេដែលអាចសម្រេចអ្វី១បាន" ។

ពួកយុវជនជាកូនអ្នកក្រីក្រ ត្រូវបានគេរើសប្រមូលយកមកថែរក្សានៅទុតិកដ្ឋាន ហើយអប់រំខាងព្រះពុទ្ធសាសនា គឺឱ្យមានគ្រូទៅបង្ហាត់បង្រៀនវិជ្ជាខាងព្រះពុទ្ធសាសនា។ ភារៈនេះធ្លាក់ទៅលើសមាគមយុវជនខ្មែរ ដែលត្រូវតែប្រមូលក្មេងយកទៅអប់រំឱ្យរៀនសូត្រទាំងផ្លូវលោកធម៌ ឱ្យហាត់កីឡាដើម្បីសុខភាព អនាម័យ

ដែលធ្វើរូបកាយឱ្យមាំមួន ។ ព្រោះថាបើរូបមានសុខភាពហើយនាមក៏មានសុខភាពដូចគ្នា ព្រោះថាអនាគតប្រទេសត្រូវការមនុស្ស មានរូបកាយរឹងប៉ឹង ដែលអាចអត់ធន់នូវកិច្ចការលំបាកគ្រប់យ៉ាង ។

ម្យ៉ាងវិញទៀត ព្រះពោធិវង្សហួត តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតកាលពីពេលដែលលោកនិមន្តត្រឡប់ពីប្រទេសជប៉ុន ក្នុងសមាជពុទ្ធសាសនាសាកលលោក លោកមានព្រះទ័យភ័យជាអនេកប្បការ ចំពោះអនាគតពុទ្ធសាសនានៅប្រទេសកម្ពុជា ។ លោកបានផ្តើមធ្វើសមាគមមួយនាមថា "សមាគមយុវជនពុទ្ធសាសនា" ព្រមទាំងបោះពុម្ពសៀវភៅ តូចមួយនាមថា "វិធីប្រតិបត្តិពុទ្ធសាសនាដោយសង្ខេប" ដើម្បីអប់រំពួកយុវជនទាំងឡាយឱ្យចេះនមស្ការព្រះរតនត្រ័យ ឱ្យដឹងវិធីប្រតិបត្តិព្រះពុទ្ធសាសនាខ្លះ ដើម្បីនឹងឱ្យចិត្តយុវជនទាំងនោះ ជ្រួតជ្រាបនូវឱជារសព្រះពុទ្ធសាសនា ហើយដល់ធំឡើងពេញជាមនុស្សទៅជាពុទ្ធសាសនិកជនមួយរូបពេញលក្ខណៈ បរិបូណ៌ដោយសតិប្រាជ្ញា អាចយល់បានហើយចូលចិត្តព្រះពុទ្ធសាសនា ប្រព្រឹត្តប្រតិបត្តិតាមព្រះពុទ្ធសាសនា យកព្រះពុទ្ធសាសនាជាមាគ៌ាដ៏ប្រសើរសម្រាប់ត្រាប់ទៅរកសេចក្តីសុខចម្រើនទៅអនាគត ។

ចំណែកពួកយុវជនអនាថាក៏ដូចគ្នា ត្រូវតែអប់រំខាងព្រះពុទ្ធសាសនា តាមការគួរ ។

តាមយោបល់ខាងលើនេះ យើងនឹងអាចពិចារណាដូចខាងក្រោម ÷

យុវជនម្នាក់ៗ ជាពូជសម្រាប់ផ្សាំ ឱ្យបានទៅជាមនុស្សពេញលក្ខណៈ ខាងព្រះពុទ្ធសាសនា ប្រៀបដូចជាកូនឈើតូចមួយ ត្រូវតែស្រោចទឹក ពូនដីដាក់គល់ដាក់ជីរជាតិ ជានិរន្តរ៍ ទើបកូនឈើនោះ ចម្រើនដុះដាលឡើងទៅជារុក្ខជាតិមួយដើមមានផ្លែផ្កាដ៏បរិបូរណ៌ យ៉ាងណាមិញ យុវជនម្នាក់ៗ ត្រូវតែអប់រំខាងវិធីប្រតិបត្តិ

ព្រះពុទ្ធសាសនា ឱ្យបានពេញលេញ ដើម្បីនឹងរចនាយុវជននោះ កែប្រែបន្តិចម្តងៗ ឱ្យបានជ្រួតជ្រាបនូវវិជ្ជាព្រះពុទ្ធសាសនា ឱ្យទៅជាពុទ្ធសាសនិកជនម្នាក់ ចេះដឹងជ្រៅជ្រះខាងព្រះពុទ្ធសាសនា គឺថាយុវជនម្នាក់ៗជាហេតុ ពុទ្ធសាសនិកជនម្នាក់ៗ ជាផលដោយយកព្រះពុទ្ធសាសនាជាគោល នៃការប្រតិបត្តិតាំងពីបច្ចុប្បន្នដល់អនាគត ។

ក្រៅពីនេះត្រូវការអប់រំពួកយុវនារី ឱ្យបានតាំងចិត្តខ្ជាប់ខ្ជួននឹងព្រះពុទ្ធសាសនា គឺត្រូវរចនាយុវនារីនេះ ឱ្យទៅជាឧបាសិកាមួយរូបមានសេចក្តីជ្រះថ្លា និងព្រះពុទ្ធសាសនា បើមានយុវនារីពេញចិត្តខាងព្រះពុទ្ធសាសនា នោះនឹងជាកម្លាំងមួយដើម្បីជួយឧបត្ថម្ភព្រះពុទ្ធសាសនាតទៅអនាគត ។ ព្រោះថាពួកយុវនារីជាជំនួយដល់ពួកយុវជន ធ្វើកម្លាំងសទ្ធាទ្វេមួយជាពីរ ចំពោះព្រះពុទ្ធសាសនា ហើយព្រះពុទ្ធសាសនា នឹងសាយភាយក្នុងព្រះរាជាណាចក្រទាំងមូល ដោយពោលបានថា :

យុវជន យុវនារី ជាអនាគត នៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ជាទំពាំងស្នងឫស្សី ។

**គ. បញ្ញាវរជនចំពោះព្រះពុទ្ធសាសនា**

អ្វីដែលហៅថាវរជនពុទ្ធសាសនា ? ជាជនដែលមានវិជ្ជាខាងផ្លូវលោក ផ្លូវធម៌ ច្រើន ជាងជនសាមញ្ញ ។

វរជនមានពីរផ្នែកគឺ :

១- វរជនខាងវិជ្ជាផ្លូវលោក

២- វរជនខាងវិជ្ជាផ្លូវធម៌

វរជនខាងវិជ្ជាផ្លូវលោកសំដៅយកពួកនិស្សិត ដែលបានសិក្សានៅឧត្តមវិជ្ជាខាងបរទេស នឹងពួកមន្ត្រីធំៗនៅក្នុងប្រទេស ។ ពួកនេះដោយភាគច្រើនមិនងាយនឹងញុំាងចិត្តគេឱ្យចូលមកជឿស៊ប់ ចំពោះព្រះពុទ្ធសាសនាទេ ព្រោះថាវរជនទាំងនេះ

លោកបានតាំងខ្លួនលោកថាជាបណ្ឌិត អ្នកចេះអ្នកមានប្រាជ្ញាទៅហើយ ម្ដេចឡើយឱ្យគេមកស្ដាប់មកជឿលោកសង្ឃ ឬអាចារ្យព្រះត្រៃបិដកបាន ។ បើលោកទាំងនោះ រៀនសូត្រនូវឧត្ដមវិជ្ជា គឺលេខគណិត រេខាគណិត ពិជគណិត ទស្សនវិជ្ជា តក្កវិជ្ជា វិជ្ជាតិកនិច វិជ្ជាសេដ្ឋកិច្ច នយោបាយ វិទ្យាសាស្ត្រ អនាម័យ វេជ្ជសាស្ត្រ តារាសាស្ត្រ អក្សរសាស្ត្រជាដើម គឺចិត្តលោកបាក់ទៅខាងលោកវិជ្ជាពេញលក្ខណៈទៅហើយម្ដេចឡើយឱ្យលោកមកជឿសាសនាវិជ្ជានេះបាន ។ បើលោកទាំងនោះយល់ខ្លួនឯងថា អញវិសេសវិសាលជាងអ្នកទាំងឡាយ ម្ដេចឡើយនឹងទៅទូន្មានប្រដៅបាន ។ បញ្ហានេះពិបាកនឹងដោះស្រាយពន់ពេក ព្រោះថាលោកទាំងនេះលោកមានចិត្តងងល់ងប់ទៅក្នុងឧត្ដរមនុស្សធម៌ទៅហើយ តែគង់មានថ្ងៃណាមួយលោកនឹងទទួលទុក្ខជាទំងន់ម្ដង ឬច្រើនដង ។ ទុក្ខលំបាកនោះ នឹងទៅដាស់សតិសម្បជញ្ញៈលោកឱ្យនឹករលឹកដល់ ឬមធ្យោបាយផ្សេងៗដែលនឹងធ្វើទុក្ខនោះឱ្យស្រាលចុះ ។ ក្នុងពេលនោះជាថ្ងៃនក្ខត្តឫក្សជាថ្ងៃជោគជ័យមង្គលដែលលោកបានរិះរកអានសៀវភៅគ្រប់បែបយ៉ាង ហើយមានមួយថ្ងៃប៉ះត្រូវអានសៀវភៅព្រះពុទ្ធសាសនា ហើយបានជួបប្រទះ នឹងពុទ្ធភាសិតណាមួយ ហើយយកពុទ្ធភាសិតនោះមកអនុវត្តតាម ហើយបានផលល្អ បានសុខកាយ សប្បាយចិត្តពេលនោះឯងលោកនឹងបានពួសពួសូរពិរោះសុខដុមរមនាថា "នេះនាំឱ្យសុខនោះនាំឱ្យសុខ " ។ កាលណាចិត្តលោកបានប្រព្រឹត្តប្រតិបត្តិទៅហើយបានសេចក្ដីសុខ ហើយដឹងច្បាស់ដោយខ្លួនឯងថាសុខពិត កាលនោះលោកនឹងមានចិត្តជ្រះថ្លា នឹងព្រះពុទ្ធសាសនាយ៉ាងក្រៃពេក ។ ប៉ុន្ដែ មិនងាយនឹងបានជួបប្រទះនូវសណ្ឋានចិត្តបែបនេះឡើយ ។

នេះជាទស្សនៈមួយល្អប្រសើរដែរ ប៉ុន្ដែបច្ចុប្បន្ន អាចផ្សេងពីទស្សនៈខាងលើនេះខ្លះ ដោយសារបច្ចេកវិទ្យាទំនើបផង និងដោយសារមនុស្សទាំងនោះ មិនមែន

ចេះតែអាណាចក្រទេ គេខ្លះក៏ចេះលាយឡំដែរអាចវិភាគបានដែរ ។

បើដូច្នេះ តើបញ្ហានេះនឹងដោះស្រាយយ៉ាងណាទៅ ?

បើតាមពិនិត្យឱ្យម៉ត់ចត់ទៅ បញ្ហានេះ អាចនឹងដោះស្រាយបានដោយប្រើមធ្យោបាយដូចខាងក្រោម :

១- ការសេពគប់នឹងការប្រាស្រ័យគ្នាទៅវិញទៅមក

២- ចាត់ការឱ្យពួកក្រុមសាលាបាលី ដែលស្ថិតនៅតាមក្រសួងក្រុម ឱ្យជួយឃោសនាផ្សាយចំពោះមន្ត្រីធំៗទាំងនោះ ។

៣- ធ្វើសន្និសីទពុទ្ធសាសនា ហើយអញ្ជើញមន្ត្រីធំៗ នឹងពួកនិស្សិតឧត្តមវិជ្ជាទៅសវនា ។

៤- ត្រូវពិនិត្យមើលចំណុចខ្សោយលោកអ្នកទាំងនោះ ហើយមកលៃលកដោយឧបាយប្រាជ្ញា ដ៏ប្រពៃហើយញ៉ាំងសទ្ធា ឱ្យកើតមានឡើងចំពោះព្រះពុទ្ធសាសនា ។

មធ្យោបាយទាំងបួននេះ បើយកមកអនុវត្តតាមការគួរទៅតាមចរិតនិស្ស័យ ចំនុចខ្សោយ នឹងអាចញ៉ាំងជំនឿ ឱ្យកើតមានឡើងចំពោះព្រះពុទ្ធសាសនាក្នុងពេលថ្ងៃណាមួយបាន ។

រឿងនេះ ត្រូវព្យាយាមឱ្យយ៉ាងម៉ឺងម៉ាត់ ហើយត្រូវយកសតិប្រាជ្ញាមកត្រិះរិះឱ្យមាំមួន ទើបសម្រេចទៅបានខ្លះព្រោះថា "ប្រដៅក្រពើឱ្យហែលទឹក " ជាការឥតប្រយោជន៍មែនពិត តែត្រង់នេះគឺប្រដៅក្រពើឱ្យហែលគោគ តែស្រេចនឹងអនាគតដោះស្រាយនូវបញ្ហាដ៏លំបាកនេះចុះ នេះជាទស្សនៈនៅសម័យកាលដែលមនុស្សមិនមានការពិចារណាច្រើន ការអប់រំពិតជាលំបាកដូច្នេះ ។

## ឃ. បញ្ហាព្រះសង្ឃចំពោះព្រះពុទ្ធសាសនា

ព្រះសង្ឃគឺសំដៅយកព្រះសង្ឃទាំងពីរគណៈ សូមព្រះសង្ឃទាំងពីរគណៈរួបរួមគ្នា ដោយសាមគ្គីភាពដើម្បីនឹងផ្សាយព្រះពុទ្ធសាសនា ឱ្យរីកពេញព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

ព្រះសង្ឃគឺព្រះភិក្ខុសាមណេរ ត្រូវប្រព្រឹត្តឱ្យត្រឹមត្រូវតាមវិន័យបញ្ញត្តិ រក្សាអប្បមាទធម៌ឱ្យបានពេញលេញសំដែងធម៌ទេសនា ពន្យល់ពពួកពុទ្ធបរិស័ទឱ្យបានយល់ជាក់ច្បាស់ នូវវិធីប្រតិបត្តិព្រះពុទ្ធសាសនា ព្យាយាមរៀនសូត្រធម៌ និងវិន័យឱ្យបានមុតមាំ កាន់ចរិយា ឱ្យសមរម្យទៅតាមពុទ្ធានុញ្ញាត្តិ ទើបព្រះពុទ្ធសាសនាបានរីកចម្រើនរុងរឿងតទៅអនាគត ។ ព្រះសង្ឃត្រូវប្រព្រឹត្តសីល សមាធិ បញ្ញាឱ្យបរិបូរណ៍ បំពេញគន្ថធុរៈ នឹងវិបស្សនាធុរៈឱ្យបានពេញលក្ខណៈ ធ្វើតាមឱវាទរបស់ព្រះពុទ្ធមានសព្វហាមមិនឱ្យធ្វើបាបទាំងពួង ១ កុសលស្សូប សម្បទា ញ៉ាំងកុសលឱ្យដល់ព្រម ១ សចិត្តបរិយោទបនំ ជំរះចិត្តរបស់ខ្លួនឱ្យផូរផង់ ១ ធ្វើធម៌អរិយសច្ចឱ្យជាក់ច្បាស់ក្នុងសន្តានចិត្តឡើង ញ៉ាំងលោកធម៌ទាំងប្រាំបី ឱ្យអស់ទៅ តម្កល់ចិត្តឱ្យឡើងទៅកាន់លោកុត្តរធម៌ ៩ តាមលំដាប់ពិចារណានូវវុឌ្ឍធម៌ និង អន្តរាយិកធម៌ ដើម្បីនឹងការពារកុំឱ្យព្រះពុទ្ធសាសនា វិនាសទៅអនាគត ។

ខ្មែរយើងបានចាត់ទុកព្រះសង្ឃជាស្រែបុណ្យសម្រាប់ឱ្យពួកឧបាសកឧបាសិកា សាបព្រោះនូវពូជ បើស្រែនោះមានជីវជាតិល្អ ពូជដែលសាបព្រោះក៏បានផលល្អ ។ ព្រោះហេតុដូច្នេះត្រូវប្រព្រឹត្តប្រតិបត្តិឱ្យបានជាទីជ្រះថ្លា នៃពួកឧបាសកឧបាសិកា ទើបគេឧស្សាហ៍ ព្រោះសាបនូវពូជបុណ្យកុសល ។

ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមសីល សមាធិ បញ្ញា ព្រះសង្ឃអង្គណាដែលគ្មានសីល សមាធិ បញ្ញា នៅក្នុងខ្លួនមិនប្រព្រឹត្តតាមសិក្ខាបទ ២២៧ ព្រះសង្ឃអង្គនោះ គេមិនហៅថាព្រះសង្ឃទេ ។ ព្រោះហេតុដូច្នេះ ត្រូវព្យាយាមធ្វើកាយវាចាចិត្ត ឱ្យមានរបៀបរាបសារ ញុំាងចិត្តឱ្យស្អាតបរិសុទ្ធ រចនាប្រាជ្ញាឱ្យមានឡើងតាមលំដាប់ ទើបព្រះសង្ឃនោះជាទីគោរពនៃពួកពុទ្ធសាសនិកជនទាំងឡាយ ។ *ប៉ុន្តែបច្ចុប្បន្ន ចំពោះបញ្ហានេះ លំបាកណាស់ ។*

ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយត្រឹមត្រូវ គឺប្រតិបត្តិតាមមជ្ឈិមាបដិបទា ។

មជ្ឈិមាបដិបទា គឺផ្លូវកណ្តាលគឺផ្លូវអដ្ឋង្គិកមគ្គមានអង្គ ៨

| | |
|---|---|
| ១- សម្មាទិដ្ឋិ | បញ្ញាឃើញប្រពៃ |
| ២- សម្មាសង្កប្បៈ | ត្រិះរិះប្រពៃ |
| ៣- សម្មាវាចា | វាចាប្រពៃ |
| ៤- សម្មាកម្មន្តៈ | ការងារប្រពៃ |
| ៥- សម្មាអាជីវៈ | ចិញ្ចឹមជីវិតប្រពៃ |
| ៦- សម្មាវាយាមៈ | ព្យាយាមប្រពៃ |
| ៧- សម្មាសតិ | រំលឹកប្រពៃ |
| ៨- សម្មាសមាធិ | តាំងចិត្តខ្ជាប់ប្រពៃ |

សម្មាទិដ្ឋិ សម្មាសង្កប្បៈ សង្គ្រោះចូលក្នុងបញ្ញាសិក្ខា សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សង្គ្រោះចូលក្នុងសីលសិក្ខា សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សង្គ្រោះចូលក្នុងចិត្តសិក្ខា ។

ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិតាមព្រះនព្វលោកុត្តរធម៌ គឺមគ្គ ៤ ផល ៤ និព្វាន ១ ។

បើព្រះសង្ឃប្រតិបត្តិតាមធម៌ និងវិន័យបញ្ញត្តិហើយព្រះសង្ឃនោះ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលឱ្យដល់អ្នកទើបនឹងមកដល់ថ្មី ទានដែលបុគ្គលនាំមកអំពីចម្ងាយ បង្អោនចូលមកបូជា ទានដែលបុគ្គលទាក់តែងដើម្បីភ្ញៀវជាដើម ។

ព្រះសង្ឃនេះជាកម្លាំងមួយសម្រាប់រក្សាកេរ្តិ៍តំណែល ព្រះពុទ្ធសាសនាឱ្យគ្រប់ ៥០០០ ព្រះវស្សា ប្រមូលរួបរួមពួកប្រជារាស្ត្រខ្មែរឱ្យខំព្យាយាមការពារព្រះពុទ្ធសាសនា ឱ្យបានស្ថិតស្ថេរចិរកាលតទៅអនាគត ធ្វើសាមគ្គីភាពឱ្យចម្រើនដុះដាលឡើង ក្នុងសន្តានចិត្តពួកពុទ្ធសាសនិកជនគ្រប់រូប ដើម្បីវាតសកម្មភាព ព្រះពុទ្ធសាសនា ឱ្យមានវឌ្ឍនភាពតាមការគួរ និងញ៉ាំងចិត្តប្រជាជនឱ្យមានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ដោយពន្យល់បំភ្លឺ ខាងវិធីប្រតិបត្តិព្រះពុទ្ធសាសនា ឱ្យបានរុងរឿងជាភិយ្យោភាព ។

ព្រះសង្ឃនេះជាមគ្គុទេសក៏ដ៏ឆ្នើមសម្រាប់ដឹកនាំប្រជាជន ឱ្យចូលទៅក្រេបទឹកអម្រឹតគឺអមតមហានិព្វាន ។

ព្រះសង្ឃនេះ ជាសុវណ្ណភត្រាសម្រាប់ដឹកនាំសត្វពីអាកាសធាតុទៅដល់និព្វានធាតុ ។

ព្រះសង្ឃនេះ ជាប្រទីបសម្រាប់បំភ្លឺសព្វសត្វ ឱ្យយល់ផ្លូវខុស និងបានត្រាប់ផ្លូវ មជ្ឈិមាបដិបទា គឺផ្លូវអដ្ឋង្គិកមគ្គនោះឯង ។

*ចំពោះទស្សនៈខ្ញុំយល់ថា ការដែលនិយមបកស្រាយថាធ្វើយ៉ាងណាឱ្យព្រះធម៌ ព្រះពុទ្ធគម្រប់ ៥០០០ ព្រះវស្សានោះ ហាក់ដូចមិនទាន់សមស្របទាល់*

*តែសោះ ។ ព្រោះព្រះធម៌នេះដរាបណាមនុស្សនៅតែមានជីវិតនៅលើទឹកដីលើចក្រវាឡ មនុស្សនៅតែត្រូវការដដែល ។ ត្រង់ការគោរពមិនជិតដល់ ឬយ៉ាងណានោះ ជារឿងបុគ្គល ។ ឯតម្រូវការរបស់មនុស្សគឺគ្មានថ្ងៃបញ្ចប់ ។ ខ្ញុំគិតថាការគិតថា ៥០០០ ព្រះវស្សានេះ ប្រហែលទស្សនៈអ្នកនិពន្ធ ក្រោយព្រះពុទ្ធឬយ៉ាងណា ? បើព្រះពុទ្ធបរិនិព្វានទៅបាន ៥០០ ឆ្នាំហើយទើបអាចកត់ត្រាជាអក្សរបាន ។ ឬម្យ៉ាងទៀតមានសង្ឃាយនាផ្សេងផ្ទាត់ណាស់ដែរ ប៉ុន្តែមិនដឹងជាបញ្ហាចេញគំនិតថាខិតខំថែរក្សាព្រះធម៌ព្រះពុទ្ធឱ្យគ្រប់ ៥០០០ ព្រះវស្សា ? ។*

> *បំបាត់ជីវិតមនុស្សបាន*
> *តែថាពុំអាចអ្នកឯណា*
> *សម្លាប់គំនិតបាន ។*
>
> សម្ដេច ចៅហ្វាវាំង **ប៉ែន នុត**

# សិលាចារឹកស្រះឈូក ជាភាសាខ្មែរ (Ka 110)

## (ភាគ ២)

ដោយ : **មីសែល ត្រាណេ**

## ១ _ សេចក្តីផ្តើម :

នៅក្នុងការសិក្សាស្រាវជ្រាវមុន ដែលមានចំណងជើងថា "អត្ថបទសិលាចារឹកបាលីចាស់ជាងគេបំផុត នៃអតីតព្រះរាជាណាចក្រកម្ពុជា" ខ្ញុំគ្រាន់តែបានសង្កត់ទម្ងន់ទៅលើអត្ថន័យ និងអត្ថរសទៅលើព្រះគាថាបាលី តែប៉ុណ្ណោះ ។ ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់មួយទៀត នឹងបង្ហាញជូនដល់អ្នកស្រាវជ្រាវផ្នែកខេមរវិជ្ជានូវភាគជាភាសាខ្មែរនៃសិលាចារឹក ដ៏សំខាន់ខាងលើនេះ ដែលមានលេខចំរឿនគឺ Ka 110 ។

ផ្ទាំងសិលាចារឹកនេះ សព្វថ្ងៃត្រូវបានគេតម្កល់ទុកក្នុងកុនសារមន្ទីរតូចមួយ ស្ថិតក្នុងបរិវេណនៃវត្តស្រះមរកត ស្រុកគោកប៉ិប ខេត្តបច្ចិមបុរី ។ ដោយកាលថ្ងៃទី ២០ ខែ ៩ ឆ្នាំ ២០០០ កន្លងមកនេះ ខ្ញុំបានពិនិត្យសិលាចារឹកនេះឡើងវិញម្តងទៀត យ៉ាងហ្មត់ចត់ ឥឡូវនេះខ្ញុំមានលទ្ធភាពនឹងបង្ហាញជូនអស់លោកអ្នកនូវលទ្ធផលនៃការស្រាវជ្រាវរបស់ខ្ញុំបន្ថែមទៀត ថ្វីត្បិតតែពុំទាន់មានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយក៏ដោយ ។

សូមរំលឹកថា ផ្ទាំងសិលាចារឹកនេះ មានកំពស់ប្រមាណជាជាង ២ ម៉ែត្រ ក៏ប៉ុន្តែផ្នែកដែលមានចារអក្សរមានប្រវែងត្រឹមតែ ១ ម៉ែត្រទេ ។ ជាការសោកស្តាយណាស់ដែរ ដែលអក្សរចារមួយចំនួន ពីបន្ទាត់ទី ១ ដល់ទី ៣ ហើយពីបន្ទាត់ទី ១៧ ដល់ទី ២៧ ដែលជាភាសាខ្មែរត្រូវរលប់ច្រើនអន្លើ ។

ម្យ៉ាងទៀត សូមរំលឹកឡើងវិញដែរថា ផ្ទាំងសិលាចារឹកនេះត្រូវបានចារឡើងនៅឆ្នាំ ៦៨៣ ស.ក ដែលត្រូវនឹងឆ្នាំ ៧៦១ នៃ គ.ស ។ ហើយអ្នកនិពន្ធគឺព្រះភិក្ខុខ្មែរមួយព្រះអង្គ ដែលមានព្រះនាមថា កម្រាតេងពុទ្ធិសិរី ។ ឥឡូវនេះយើងសូមចម្លង នូវឃ្លាប្រយោគជាភាសាខ្មែរ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

**អត្ថបទខ្មែរ នៃសិលាចារឹក :**

១- ( ៦៨៣ ស.ក ឆ្ល នក្សត្រ មារោច ជ្យេម្ហ

២- វុទ្ធ វារ នុ ( រាតេង ) វុទ្ធ សិរីប្រតិម្ព

៣- ព្រះ គាប្ត នោះ

៤- ( អត្ថបទជាបាលី )

---

១៧- ព្រះ គោនេះ ផោង តិ អញ ជាន ត កម្រតេង ( ... )

១៨- ... ត ព្រះ បាទ នេរុអ្នាក្ត បញោ ( ... )

១៩- ... អ្នាក្ត សិលា បញ្ចុ បរិខា ( ... )

២០- ... វុំអាច្ចិ ប្រស ( ណោយ្ត ) លេង ខ្សាយនេះ ( ... )

២១- ... អ្នាក្ត នោះ វុំ អាច តិ យោក បឳយ ( ... )

២២- ... ( វុំ អាចតិ ) យោក ឧបយ ត កូន ... វុំ អាច តិ

២៣- ... យ ថៃយ

២៤- ... ក្សះ បុន្យ: នេះ ( កិរិយា បុណ្យបារមី )

២៥- ... គោត្រ កូល បាទ វំ ...

២៦- ... ព្រះ បាទ បតិម្ព ( កម្រតេង )

២៧- ... ចរចា លេក គោត្រ កូល បាទ វំ ...

## ៣-ខ្លឹមសាររួមនៃសិលាចារឹក

" នៅឆ្នាំ ៦៨៣ ស.ក ត្រូវជាឆ្នាំ ៧៦១ នៃ គ.សឆ្នាំ ឆ្លូវ ឆក្សត្រ ថ្ងៃមួយរោច ខែ ជេស ថ្ងៃ ពុធ ព្រះកម្រាតេង ( ព្រះភិក្ខុសង្ឃនាមព្រះពុទ្ធសិរី បានប្រតិស្ឋាននូវរាជបុញ្ញាតិនេះ .... កសាងព្រះគោ និងព្រះពុទ្ធបាទ... ។

## ៤-បរិបទភូមិសាស្ត្រ និងវប្បធម៌បាលី :

គេពុំអាចផ្តាច់ភូមិសាស្ត្រ និងវប្បធម៌បាលីចេញពីប្រវត្តិទឹកដី នៃអតីតព្រះរាជាណាចក្រកម្ពុជាបានឡើយ ។ វត្តមាននៃជនជាតិសៀម ឬថៃជាព្រឹត្តិការណ៍មួយដ៏ថ្មីថ្មោងបំផុត ក្នុងភូមិភាគនេះ ដែលពីដើមជាអាណាខេត្តរបស់ខ្មែរយើង ។ម្យ៉ាងទៀតនៅពេលដែលសិលាចារឹកនេះ ត្រូវបានចារឡើងជនជាតិថៃពុំទាន់មករស់នៅក្នុងតំបន់នេះនៅឡើយ ។ មួយវិញទៀតគេសង្កេតឃើញរហូតមកដល់សព្វថ្ងៃនេះនៅមានភូមិខ្លះដែលនៅរក្សាទាំងប្រពៃណី និងភាសាខ្មែរនៅឡើយ ដូចជាភូមិស្វាយជាដើម ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីវត្តមរកតនេះ ។ ដូចនេះការដែលផ្ទាំងសិលាចារឹកនេះ ត្រូវបានចារឡើងជាភាសាខ្មែរពុំមែនជាការចៃដន្យដែរ ។ ក៏ប៉ុន្តែ អ្វីដែលសំខាន់ គឺទន្ទឹមនឹងនេះមានវត្តមានរបស់ភាសាបាលីផងដែរ ដែលជាភាសាយាន។ យ៉ាងណាមិញវត្តមានរបស់ព្រះពុទ្ធសាសនាក៏មិនត្រូវធ្វើឱ្យយើងភ្ញាក់ផ្អើលដែរ ពីព្រោះគេបានរកឃើញក្នុងភូមិភាគនេះ នូវបដិមាសាស្ត្រខ្មែរបុរាណតំណាងព្រះពុទ្ធអង្គព្រះពោធិ-សត្វ អវលោកេស្វរៈ ព្រះសេអារមេត្រីរាប់រយអង្គ ព្រមទាំងសីមាវត្តជាច្រើន ដែលស្ថិតក្នុងសម័យវប្បធម៌ចេនឡា ។ ប៉ុន្តែអ្វីដែលសំខាន់នៅទីនេះ ដែលយើងកត់សម្គាល់ គឺព្រះពុទ្ធសាសនា ក្នុងភូមិភាគនេះ ជាពិសេសក្នុងបរិវេណនៃវត្តស្រះឈូកនាសម័យបុរាណត្រូវបានប្រារព្ធជាមួយគ្នា នឹងព្រហ្មញ្ញសាសនាដូចដែលខ្លឹមសារនៃសិលាចារឹកជាភស្តុតាងស្រាប់ ។ សូមបញ្ជាក់ថា ទន្ទឹមនិងការស្ថាបនាព្រះពុទ្ធបាទ គេក៏បាន

ស្ថាបនាព្រះគោថ្មដែរ ឬក៏ព្រះសីវលិង្គដែរ ដើម្បីជាទីគោរពសក្ការបូជា ក្នុងសាសស្ថានខាងលើនេះ ។ សេចក្តីសន្និដ្ឋានខាងលើនេះ ក៏អាចបញ្ជាក់តាមរយៈសំណល់នៃទេវស្ថាន ដូចជាព្រះសីវលិង្គ ស្នានា ទ្រោនី ក្បាច់ក្បូរប្រាសាទជាដើម ។

ដោយឡែកយើងក៏បានជួបនូវចម្លាក់នៃសត្វអច្ឆរិយៈ ដូចជានាគ គោ ម្ករ និងដីរ៍ដែរ ។ ក៏ប៉ុន្តែសត្វទាំងនោះអាចជាសញ្ញានិមិត្តនៃព្រះពុទ្ធសាសនា ក៏ដូចជាព្រហ្មញ្ញសាសនាដែរ ។

## ៥.អត្ថប្រយោជន៍នៃសិលាចារឹក

វិភាគទានដ៏មហាធំធេង ដែលកាត់ថ្លៃពុំបាន គឺការកែទស្សនៈអ្នកស្រាវជ្រាវមួយចំនួន ដូចជា លោក ហ្សកសេដេស ប៉រស៊ីសីយេ ប៊ុហ្សូ សាវរសពៅ ដែលបានសន្និដ្ឋានថា ជនជាតិខ្មែរបានខ្ចីភាសាបាលីតាមរយៈពួកមន ដែលរួមឈាមជ័រជាមួយខ្មែរនាដើមសតវត្សទី ១៣ នៃ គ.ស ។

រួមសេចក្តីមក វត្តមានរបស់សិលាចារឹកខាងលើនេះ អាចបញ្ជាក់នូវចំណាស់របស់វប្បធម៌បាលីនៅក្នុងអតីតទឹកដីអតីតកម្ពុជា ។ សូមរំលឹកថាថ្មី១នេះ យើងក៏បានជួបប្រទះនូវសិលាចារឹកមួយផ្ទាំងទៀត ដែលសរសេរជាភាសាបាលីដូចគ្នា នៅក្នុងទីក្រុងអង្គរបុរី ដែលជាអតីតរាជធានីខ្មែរមួយ ក្នុងចំណោមព្រះរាជធានីជាច្រើនក្នុងសម័យបុរេអង្គរ ។

សូមរំលឹកថា គេពុំទាន់ដឹងចំណាស់យ៉ាងប្រាកដ នៃផ្ទាំងសិលាចារឹកអង្គរបុរីនៅឡើយទេ ។ ដោយហេតុថា សិលាចារឹកនោះ គ្មានកាលបរិច្ឆេទ ក៏ប៉ុន្តែ បើយើងវិភាគលក្ខណៈនៃតួអក្សរ យើងអាចកត់សម្គាល់ថា ឯកសារនេះស្ថិតនៅក្នុងសតវត្ស ទី ៧ នៃ គ.ស ។

ចំណុចដ៏សំខាន់មួយទៀតរបស់សិលាចារឹកស្រះឈូក គឺផ្នែកភាសាសាស្ត្រ។ ក្នុងសិលាចារឹកនេះ យើងឃើញការប្រើពាក្យ កម្រតែង សម្រាប់ហៅព្រះភិក្ខុសង្ឃ ។ សូមបញ្ជាក់ថា ការហៅបែបនេះ ជាទម្លាប់មួយដែលមានជីវិតរហូតដល់ចុងសតវត្ស ទី ១៩ ដើមសតវត្សទី ២០ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង និងនៅខេត្តសុរិន្ទ្រ បុរីរម្យ ។ល។ ជាដើម ។



ផ្ទាំងសិលាចារឹកស្រះឈូក (សាះប៊ូ) Ka 110 ក្នុងបរិវេណវត្តមរតក ពាក់កណ្ដាល ស.វ ទី ៨ នៃ គ.ស ស្រុកគោក ប៊ុប. ខេត្តបច្ចិមបុរី (២០/០៩/២០០០)

# ពិធីបំបួសនាគ

ដោយ : **អ្នកស្រី ពេជ្រ សល់**

(គ.ស ១៩៦៦)

ពិធីបំបួសនាគអាចធ្វើនៅខែណាក៏បាន លើកលែងតែខែ ៣ ដែលព្រះសង្ឃចូលព្រះវស្សា គឺចាប់តាំងពីថ្ងៃ ១ រោច ខែ អាសាឍទៅ ។ ប៉ុន្តែជាទំនៀមរៀងមក ពិធីបំបួសនាគហ្លួងតែងធ្វើនៅថ្ងៃ១៥ កើត ខែអាសាឍជានិច្ច គឺថាមុនថ្ងៃកំណត់ចូលព្រះវស្សា ។

ក្នុងមួយឆ្នាំៗ បុត្រនៃក្រុមព្រះរាជវង្សានុវង្ស និងបុត្រនៃមន្ត្រីជាន់ខ្ពស់ ដែលបានចូលទៅសុំឱ្យព្រះករុណាបំបួស សុទ្ធតែមានកំណត់គឺថា យកត្រឹមតែ ១២ នាក់ យ៉ាងច្រើន លើសចំនួនកំណត់នេះ អ្នកចូលទៅសុំត្រូវចាំទៅឆ្នាំមុខទៀត ។

មានដំណាលកាលពីព្រេងនាយថា មានសត្វនាគមួយដំណែងខ្លួនជាមនុស្ស ហើយចូលទៅសុំបួសយកនិស្ស័យក្នុងសំណាក់ព្រះពុទ្ធសាសនា ។ ថ្ងៃមួយលោកគ្រូប្រើលោកនេនឱ្យទៅហៅ ជួនជាពេលនោះលោកដែលជាសត្វនាគនោះ កំពុងដេកលក់ពុំដឹងខ្លួន ហើយក្លាយខ្លួនជាសត្វនាគពេនទ្រេលពេញក្នុងបន្ទប់ ។ ដំណើងនោះ ក៏ជ្រាបទៅដល់ព្រះបរមសាស្តា ព្រះអង្គទ្រង់បង្គាប់ឱ្យលោកនាគនោះ ចាកសិក្ខាបទទៅវិញ ដោយហេតុថា ច្បាប់ព្រះពុទ្ធសាសនាហាមមិនឱ្យសត្វចូលបួសបានទេ ប៉ុន្តែដោយទ្រង់មេត្តាករុណាដល់នាគដែលមានសេចក្តីជ្រះថ្លា នឹងសាសនាព្រះអង្គ ទ្រង់ក៏សន្យានឹងនាគថា ចាប់អំពីថ្ងៃនេះទៅ តថាគតសន្មតឱ្យនាមអ្នកសុំផ្នួសថា "នាគ" ជាទីរំលឹកដល់នាគអ្នក ។ ហេតុនេះបានជាមានឈ្មោះថា "បំបួសនាគ" ដរាប

រៀងមកដល់សព្វថ្ងៃ [១] ។

ឯទំនៀមបំបួសនាគ ក៏មានលំនាំផ្សេងៗ ខុសគ្នាបន្តិចៗ ដូចជាទំនៀមធំៗដទៃទៀតដែរ មានទំនៀមខ្លះ ដែលគេយល់ឃើញថា មិនត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធសាសនា គេក៏កាត់ចោលទៅ ទំនៀមខ្លះដែលកើតឡើងតាមកាលៈទេសៈ ក៏ត្រូវបញ្ចូលមកវិញ។ ហេតុនេះយើងសូមជម្រាបថា សេចក្ដីអធិប្បាយអំពីពិធីបំបួសនាគ ដែលយើងនឹងអធិប្បាយជូនក្នុងទីនេះ ពុំមែនជារបៀបតួយ៉ាង ដែលគេត្រូវតែធ្វើតាមនោះទេ គឺជារបៀបទំនៀមយ៉ាងសង្ខេបមួយ ដែលគេធ្លាប់បានឃើញធ្វើមកហើយ ។

មុនថ្ងៃបំបួសចំនួន ៤-៥ ថ្ងៃ អ្នកដែលត្រូវចេញទៅបួស ត្រូវកាន់ទៀនធូបទៅជម្រាបលាបងប្អូន និងញាតិមិត្តរបស់ខ្លួន ដើម្បីឱ្យគេបានដឹងផងថា : ខ្លួននឹងចូលទៅបម្រើព្រះពុទ្ធសាសនាហើយ ។

ទំនៀមដែលយើងអធិប្បាយដូចតទៅនេះ ជាទំនៀមដែលគេធ្វើនៅគេហដ្ឋានសាមីខ្លួនក៏បាន ឬធ្វើនៅទីអារាមក៏បាន ប៉ុន្តែពិធីខ្លះគេលះបង់អស់ទៅហើយ ។

បើបំបួសសាមណេរ ត្រូវមានរៀបចំត្រៃចីវរ បាត្រ កន្ទេល ខ្នើយ ។ បើបំបួសជាភិក្ខុវិញ ត្រូវមានកាំបិទកោ ថ្មសំលៀង បំពង់ម្ជុលថែមលើបរិក្ខារខាងលើនេះទៀតទើបគ្រប់ ។ ក្រៅអំពីបរិក្ខារទាំងនេះ មានដបទឹកអប់ បាយសីធំមួយ ធ្វើដោយដើមចេកមួយដើម ដែលមានកំពស់ត្រឹមចិញ្ចើមមនុស្សឈរ ។ បាយសីនោះ

---

១- តាមពិតពាក្យថា នាគ ក្នុងទីនេះគឺជា "តំខណិកនាម" ដែលឧបសម្បទាចារ្យសន្មតដាក់ឱ្យកុលបុត្រជាឧបសម្បទាបេក្ខៈ (ចូរមើលសៀវភៅបព្វជ្ជាខន្ធសង្ខេបរបស់សម្ដេចព្រះធម្មលិខិត ល្វី ឯម ដែលបោះពុម្ពផ្សាយនៅពុទ្ធសាសនបណ្ឌិត្យ) ។

មាន ១៩ ថ្នាក់ ដែលជាតំណាងព្រលឹងមនុស្សទាំង ១៩ ប៉ុន្តែមានអ្នកខ្លះ ធ្វើសង្ខេបត្រឹមតែ ៩ ថ្នាក់ ។ នៅលើកំពូលបាយសីមានកន្ទោងស្លឹកចេកមួយ ដាក់បាយព្រលឹង ១៩ ( ឬ ៩ ) ពំនូត មានសាជីធ្វើដោយស្លឹកចេកគ្របពីលើ ហើយនៅកំពូលសាជីមានដោតទៀនរាយមួយផង ។ គេយកស្លឹកចេក ៣ ផាងមករុំព័ទ្ធបាយសីនោះ ១ ជាន់ រួចទើបយកសំពត់ហូលរុំ ១ ជាន់ពីក្រៅទៀត ។

លុះរៀបគ្រឿងបរិក្ខារដូចបានពោលមកនេះ ជាជួរតាមលំដាប់ស្រេចហើយ នាគត្រូវចូលទៅអង្គុយជិតបាយសីធំ ដើម្បីស្តាប់ព្រះសង្ឃចម្រើនព្រះបរិត្តដោយមានឪពុកម្តាយបងប្អូននឹងក្រុមញាតិមិត្រអង្គុយអមផង ។ បន្ទាប់មកគេរៀបធ្វើពិធី "ហៅព្រលឹងនាគ " គ្រានោះអាចារ្យកាន់អំពៅខ្មៅ ១ ដើមដែលគេទុកឱ្យមានសន្លឹកពីរឬបីនៅចុង ហើយចងឱ្យមានទំនងដូចចំពុះបក្សី ។ អាចារ្យកាន់ដើមអំពៅបង្វែរចំពុះនោះទៅគ្រប់ទិស បោយហៅព្រលឹងឱ្យនាគ[១] បន្ទាប់មកគេរៀប "ធ្វើធ្មេញ " ឱ្យនាគទៀត ។

កាលជិនាន់ដើម នៅពេលបំបួសនាគក្តី នៅពេលរៀបអាពាហ៍ពិពាហ៍ក្តី គេនិយមយកម្រ័ក្សបុកលាយជាមួយរុក្ខជាតិខ្លះទៀត ដើម្បីយកទៅលាបធ្មេញសាមីខ្លួនឱ្យមានសម្បុរខ្មៅស្រិលមែនៗ ។ សព្វថ្ងៃនេះ អាចារ្យគ្រាន់តែរៀប "ធ្វើធ្មេញ" "បំពេញកិច្ចទេ តមកទៀតអាចារ្យរៀបចំបញ្ចុកបាយនាគ" គឺគេយកបាយព្រលឹងទៅដាក់ក្នុងទឹកដូងហើយបញ្ចុកមាត់នាគទៅ រួចហើយទើបយកអំបោះជ្រលក់ទឹកមន្ត ចងដៃនាគ ។ បន្ទាប់មកទៀត ពួកក្រុមញាតិសាច់សាលោហិតនាំគ្នាអង្គុយជារង់ជុំវិញនាគ ហើយរៀបបង្វិលពពិល ដើម្បីចំរើនសិរីសួស្តីជ័យមង្គលដល់នាគនោះ។

---

១- ពិធីហៅព្រលឹងមនុស្សឈឺ ក៏មានសភាពដូច្នេះដែរ ។

ជាធម្មតា គេត្រូវបង្វិលពពិល ១៩ ជុំ ហើយបក់ផ្សែងសំដៅទៅរកនាគផង ។ លុះគ្រប់កំណត់ជុំហើយ អាចារ្យពន្លត់ទៀន រួចយកកំញូម លាយជាមួយនឹងទឹកអប់បន្តិច យកទៅលាបចិញ្ចើមនិងថ្ពាសនាគ ។

ថ្ងៃបន្ទាប់មក គេរៀបក្បួនហែនាគទៅកាន់វត្តព្រះកែវមកិត បើប្រសិនជានាគនោះជាវង្សក្សត្រ ឬជាកូននាម៉ឺនជាន់ខ្ពស់ ការហែនាគមានសភាពគគ្រឹកគគ្រេងណាស់ ស្មើរតែប្រហាក់ប្រហែលនឹងការរៀបចំហែស្តេច១ ព្រះអង្គដែរ ព្រោះកាលដែលព្រះបរមសាស្តាយើង ទ្រង់ចេញទៅសាងព្រះផ្នួស ព្រះអង្គជាព្រះរាជបុត្រាក្សត្រគ្រងរាជ្យដែរ ។ គេឃើញមានភ្លេងឆៃយ៉ាំ ១ ក្រុមចេញដើរមុខក្បួន មានមនុស្ស ទ្រពានប្រាក់តំកល់ត្រៃចីវរ ទ្របាត្រនិងគ្រឿងសក្ការៈបូជា ដើរមុខនាគ ។ បន្ទាប់មកទៀត នាគដែលមានសំលៀកបំពាក់ដូចស្តេចសម័យបុរាណជិះសេះមាន មនុស្សបាំងក្លស់ឱ្យផង ។

នៅមុខវត្ត មានមនុស្សកំប្លែងម្នាក់ធ្វើជាមារាធិរាជ ដែលចាំរាំងព្រះពោធិសត្វ មិនឱ្យចេញទៅបួស ស្ទុះទៅចាប់មុខសេះដែលនាគជិះ ហើយធ្វើបាក់ដូចជាឃាត់មិនឱ្យនាគចូលទៅបួស ។ ប៉ុន្តែនាគមិនព្រមលោតចុះពីលើខ្នងសេះ ហើយដើរចូលទៅក្នុងទីវត្ត ដោយមានក្រុមញាតិសាលោហិតហែតាមពីក្រោយផង។ ដល់ហើយក្បួនហែនាគដើរប្រទក្សិណព្រះវិហារ ៣ ជុំ អាចារ្យស្រែកអនុមោទនា ដើម្បីសម្តែងសេចក្តីត្រេកអរនឹងកិច្ចរបស់កុលបុត្រ ដែលស្ម័គ្រចិត្តលះបង់ភេទគ្រហស្ថ ហើយទទួលយកភេទជាបុព្វជិត ។ នៅពេលដែលអាចារ្យស្រែកថា: " អនុមោទនាលោកអើយ! " អ្នកដើរហែទាំងប៉ុន្មានក៏ទទួលព្រមគ្នាថា សាធុ! ប្រែថា ប្រពៃហើយ ប្រសើរហើយ ។

លុះហែប្រទក្សិណគ្រប់ ៣ ជុំហើយ នាគចូលទៅក្នុងព្រះវិហារ អុជធូប ទៀនដោតនៅមុខពុទ្ធាសនៈ រួចថ្វាយបង្គំព្រះពុទ្ធរូប ៣ ដង ទើបថយទៅអង្គុយពីមុខត្រៃចីវរ និងបាត្រ ។ បើមាននាគច្រើនរូប នាគត្រូវអង្គុយជាជួរ តាមលំដាប់អាយុចាស់ក្មេង ។ បើបួសជាសាមណេរមានតែលោកជាឧបជ្ឈាយ ១ អង្គជាការស្រេច តែបើបួសជាភិក្ខុវិញ ច្បាប់វិន័យពុទ្ធសាសនាថា ត្រូវមានព្រះសង្ឃយ៉ាងតិចត្រឹម ៥ អង្គ ។

តពីនេះ នាគកាន់ទ្រសំពត់កាសាវៈគឺ ស្បង់ចីពរចូលទៅដាក់ចំពោះមុខព្រះឧបជ្ឈាយ៍ហើយថ្វាយបង្គំ ៣ ដង សូត្រធម៌វន្ទាសូមខមាទោសរួចហើយសូត្រពាក្យសុំផ្នួសជាតម្រប់ ៣ ដង ព្រមទាំងប្រគេនសំពត់កាសាវៈទៅព្រះឧបជ្ឈាយ៍ ១ ទទួលហើយ នាគសូត្រសុំសំពត់កាសាវៈនោះមកវិញ ។ ព្រះឧបជ្ឈាយ៍ក៏ប្រគល់ឱ្យតាមសុំ "នាគអង្គុយច្រហោងប្រណម្យអញ្ជលី កាន់ទ្រសំពត់កាសាវៈនៅមុខព្រះឧបជ្ឈាយ៍។ ចាប់ចុងម្រាមដៃហើយប្រាប់ធម៌កម្មដ្ឋាន ៥ យ៉ាងហៅថា តចបញ្ចកកម្មដ្ឋាន ដែលហៅតាមទម្លាប់ថាឱ្យធម៌ "កេសា" ឱ្យនាគថាតាមដោយមានបាលីថា កេសា, លោមា, នខា, ទន្តា, តចោ... ប្រែថា "សក់,រោម,ក្រចក, ធ្មេញ, ស្បែក ។ "ហើយប្រាប់ច្រាសមកវិញទៀតថា តចោ.ទន្តា.នខា.លោមា.កេសា. ប្រាប់ពន្យល់នាគឱ្យយល់ច្បាស់ថា របស់ទាំង ៥ យ៉ាងនេះ ជាវត្ថុបដិកូលស្មោកគ្រោត គួរខ្ពើមរអើម ។ រួចកិច្ចនេះ ហើយព្រះឧបជ្ឈាយ៍យកអង្ស៊ក់ពាក់កនាគជាសញ្ញាថា នឹងជិតបានទៅជាសាមណេរហើយ ។ នាគថយខ្លួនទៅផ្លាស់សំលៀកបំពាក់គ្រហស្ថចេញក្នុងទីដ៏សមគួរ ហើយទើបស្លៀកស្បង់គ្រងចីពរ ត្រឹមត្រូវតាមច្បាប់វិន័យ ។ បន្ទាប់ពីនេះនាគកាន់គ្រឿងសក្ការៈបូជា មានទៀនធូបជាដើមចូលទៅថ្វាយបង្គំព្រះឧបជ្ឈាយ៍ សូត្រពាក្យសុំត្រៃសរណគមន៍និងសីលព្រះឧបជ្ឈាយ៍ឱ្យត្រៃសរណគមន៍និងសីល ១០

តាមសុំ រួចហើយទើបសាមណេរសូត្រសុំនិស្ស័យ (ទីនៅអាស្រ័យ )ចំពោះព្រះឧបជ្ឈាយ៍ បើបួសជាសាមណេរ ពិធីបំបួសត្រូវចប់អស់តែត្រឹមប៉ុណ្ណេះឯង ។

បើត្រូវការបំពេញឧបសម្បទាជាភិក្ខុ ត្រូវមានកិច្ចបន្តទៅទៀតគឺសាមណេរនោះ ត្រូវស្ពាយបាត្រក្រោកឈរឡើង ចូលទៅឈរកណ្ដាលជំនុំសង្ឃ ចំពោះមុខព្រះឧបជ្ឈាយ៍ ទើបឧបសម្បទាចារ្យ (គ្រូសូត្រ) សូត្រតាំងនាមឧបសម្បទាបេក្ខៈ និងព្រះឧបជ្ឈាយ៍ប្រាប់បង្ហាញដល់នាគនូវបាត្រ. សង្ឃាដី. ចីពរនិងស្បង់ ឱ្យនាគទទួលស្គាល់យល់ដឹងថា " នេះបាត្ររបស់អ្នក" ជាដើម ហើយឱ្យនាគថយទៅឈរឆ្ងាយបន្តិច ផុតពីទីប្រជុំសង្ឃ ទើបសូត្រប្រកាសប្រាប់សង្ឃសុំឱកាសប្រៀនប្រដៅនាគព្រមទាំងសាកសួរនូវកិច្ចផ្សេងៗ មានរោគាពាធក្នុងខ្លួនជាដើម ដើម្បីឱ្យដឹងថាសាមីខ្លួននោះបរិសុទ្ធស្អាត អាចនឹងទទួលឧបសម្បទាពេញលក្ខណៈជាភិក្ខុបានឬទេ។ លុះប្រៀនប្រដៅសាកសួររួចហើយ ទើបលោកគ្រូសូត្រនោះ ត្រឡប់ចូលមកក្នុងកណ្ដាលជំនុំសង្ឃវិញសូត្រប្រកាសប្រាប់សង្ឃ និងហៅនាគឱ្យចូលមកអង្គុយកណ្ដាលជំនុំសង្ឃថ្វាយបង្គំព្រះឧបជ្ឈាយ៍ និងព្រះសង្ឃរួចហើយ ឱ្យអង្គុយច្រហោងប្រណម្យអញ្ជលីសូត្រសូមឧបសម្បទា ចំពោះសង្ឃ ៣ ដង គឺសូមឱ្យសង្ឃអនុគ្រោះ លើកខ្លួនឱ្យផុតពីភេទជាសាមណេរ ហើយតំកល់តំកើងឱ្យឡើងពេញលក្ខណៈជាភិក្ខុ ។ ពេលនោះជំនុំសង្ឃត្រូវអង្គុយព័ទ្ធចូលឱ្យជាប់ហត្ថបាសគ្នា ទើបលោកគ្រូសូត្រសួរបញ្ជាក់នាគ នូវអន្តរាយិកធម៌ គឺរោគាពាធផ្សេងៗ ជាដើម ដែលបានសួរខាងក្រៅជំនុំសង្ឃហើយនោះថែមមួយលើកទៀត ។ លុះបានសាកសួរកិច្ចនេះចប់សព្វគ្រប់ហើយ ឧបសម្បទាចារ្យ ( លោកគ្រូសូត្រ ) សូត្រញត្តិចតុត្ថកម្មវាចា[១] ។ ចប់ញត្តិចតុត្ថ

១- តាមទម្លាប់ គេតែងហៅថា ... ញត្តិនាគ ឬសូត្រញត្តិនាគ ( អាសាញត្តិនាគ ) ។

កម្មវាចាខណៈណា. ឧបសម្បទាបេក្ខៈ គឺសាមណេរនោះ ក៏បានឋិតនៅក្នុងភាពជាភិក្ខុពេញបរិបូណ៌ក្នុងខណៈនោះ ។ បន្ទាប់ពីនេះព្រះឧបជ្ឈាយ៍ ឬលោកគ្រូសូត្រប្រៀនប្រដៅប្រាប់នូវវិន័យសង្ឃករណីកិច្ចចំពោះភិក្ខុថ្មីនោះ (ហៅតាមទម្លាប់ថា "ផ្តាំនាគ" តាមប្រពៃណីពីបុរាណ ផ្តាំនាគនេះលោកសូត្រជាបទយ៉ាងគ្រលួច គួរជាទីចាប់អារម្មណ៍ពីរោះណាស់ នាំឱ្យមាតាបិតា និងបងប្អូនរបស់ភិក្ខុថ្មី យំស្រក់ទឹកភ្នែកស្រណោះអាឡោះអាល័យយ៉ាងក្រៃលែង ។

ចាប់តាំងពីថ្ងៃនោះមក ភិក្ខុថ្មីក៏អាស្រ័យនៅជាមួយនឹងព្រះសង្ឃឯទៀតក្នុងទីវត្ត ។

*គ្មានសុខដទៃក្រៃលែងជាងសន្តិភាព ។*

*ចេសក្តីលោភនាំឱ្យអន្តរាយ សន្តិភាព ។*

ព្រះមុនីកោសល **សោម ឈុន**

# ពិធីចូលម្លប់ ចេញពីម្លប់របស់ប្រជាជន នៅក្នុងភូមិនានា នៃឃុំត្រប់ ឃុំសំពៅក ស្រុកបាធាយ

ដោយ : មៀច ប៊ុណ្ណ

តាមប្រពៃណីទំនៀមទម្លាប់របស់ប្រជាជននៅតំបន់នេះ បើកាលណាកូនស្រី (ទោះច្បង កណ្ដាល ឬពៅក្ដី ) ចូលដល់វ័យគ្រប់ការ (អ្នកស្រុកនៅតំបន់ខ្លះគេថា កូនស្រីវាន់កន្ទប) ហើយនោះ គេបានគិតគូរជាមួយប្ដីប្រពន្ធ ព្រមទាំងជម្រាបឪពុកម្ដាយទាំងសងខាង ដើម្បីរៀបចំពិធីបញ្ចូលម្លប់ឱ្យកូន ។ ពិធីចូលម្លប់ប្រព្រឹត្តទៅយ៉ាងសាមញ្ញ ដោយគ្រាន់តែធ្វើស្លាធមិមួយគូដោតស្លាម្លូ រួចអុជធូបសែនព្រេនជម្រាបខ្មោចជួរ ជីបូរ មេបា ចាស់ទុំឱ្យបានជ្រាបថា កូនស្រីឈ្មោះ ...........ត្រូវបានធ្វើពិធីបញ្ចូលម្លប់នៅថ្ងៃ .......... នេះហើយ សូមព្រលឹងដូនតា មេបាចាស់ទុំជួយដឹងឮ និងជួយឱ្យពរស័ព្ទសាធុការដល់កូនស្រី ....ផង ។

**I-ភារកិច្ចរបស់ក្រមុំចូលម្លប់**

**១-ត្រណមផ្សេងៗ :**

កូនក្រមុំដែលត្រូវគេបញ្ចូលម្លប់ត្រូវតម មិននិយាយស្ដីជាមួយប្រុសៗលើកលែងតែឪពុកបង្កើតរបស់ខ្លួន

- មិនឱ្យបរិភោគម្ហូបអាហារ ដែលមានជាតិសាច់ ស៊ុត ត្រី អនុញ្ញាតឱ្យបរិភោគតែអាហារបួស មួយថ្ងៃតែពីរដងប៉ុណ្ណោះ
- មិនឱ្យចេញក្រៅបន្ទប់ ចុះមកដី ឬចេញក្រៅរបងផ្ទះ
- មិនបញ្ចេញរូបកាយ ឱ្យប្រុសៗឃើញ

## ២.កិច្ចការមួយចំនួនដែលត្រូវធ្វើ

-ហាត់រៀនដេរប៉ាក់ ជុល ត្បាញរវៃ ដាំស្លឱ្យស្ទាត់ជំនាញ

-ហាត់ពត់លត់ដំខ្លួនឱ្យទៅជាស្ត្រីមេផ្ទះ ដែលមានសមត្ថភាព

-គុបតែងលម្អខ្លួនប្រាណ ដោយលាបម្សៅ រមៀត ទឹកអប់រាល់ថ្ងៃ

-ទទួលការអប់រំណែនាំពីម្ដាយ អំពីក្រិត្យវិន័យរបស់ស្ត្រីខ្មែរ

-ធ្វើកិច្ចវត្តថ្វាយបង្គំព្រះ ព្រឹកម្ដងល្ងាចម្ដង ។

## II- រយៈពេលចូលម្លប់

តាមទំនៀមទម្លាប់ប្រជាជននៅតំបន់នេះ គេកំណត់រយៈពេលចូលម្លប់ ពី ១ ខែ ទៅ ៣ ខែ ខុសប្លែកពីតំបន់ឯទៀតៗ នៃប្រទេសកម្ពុជា ដែលជួនកាលគេអូសបន្លាយពេលចូលម្លប់រហូតដល់ ៦ ខែ ៩ ខែ ឬ ១ ឆ្នាំ

នៅថ្ងៃដែលត្រូវកំណត់ចូលម្លប់នោះ គេបានដាំចេកណាំវ៉ា ( ស្រុកខ្លះហៅថាចេកទឹក ) ។ កាលណាចេកនោះ មានផ្លែពេញចំណាស់ល្មមកាប់បន្ទុំនោះ គេក៏ប្រកាសធ្វើពិធីចេញពីម្លប់ ។

គ្រួសារអ្នកខ្លះខាតធនធាន ទាល់ដៃទាល់ជើង មិនសូវសម្បូរកម្លាំងពលកម្មនោះ គេក៏សង្ខេបរយៈពេលចូលម្លប់នេះ មកនៅត្រឹមតែ ២០ ថ្ងៃ ឬ ១ ខែប៉ុណ្ណោះ។

## III- ពិធីបញ្ចេញកូនស្រីពីម្លប់

កាលណាពិធីចូលម្លប់បានគ្រប់ទៅតាមកាលកំណត់ហើយនោះ គ្រួសារនេះត្រូវប្រារព្ធពិធីបញ្ចេញកូនពីម្លប់ ។ មាតាបិតាបានដើរជម្រាបភ្ញៀវជាញាតិមិត្តជិតឆ្ងាយពីកាលបរិច្ឆេទ នៃការបញ្ចេញកូនស្រីពីម្លប់ ។ គេត្រូវត្រៀមលុយកាក់មួយចំនួនសម្រាប់ទិញសម្ភារៈ រណ្ដាប់ រណ្ដា ស្បៀង ម្ហូបអាហារ ដែលត្រូវការ

ជាចាំបាច់ក្នុងពិធីបញ្ចេញពីម្លប់ មានជាអាទិ៍ ត្រី សាច់ បន្លែ ផ្លែឈើ ស្លាម្លូ កំបោរ ថ្នាំ ...នំគ្រប់ប្រភេទ ដែលជាតម្រូវការចាំបាច់នៃពិធី ។ គេត្រូវការពេលវេលាចំនួនមួយថ្ងៃមួយយប់ ដើម្បីប្រារព្ធពិធីបញ្ចេញពីម្លប់ ។ នៅថ្ងៃចូលរោង ញាតិមិត្តមកជួយសង់រោង សង់បុស្សបុក រាជវ័តិ រានទេព្ដា បាយសី ជម ពែ ស្លាធមិ ។ល។ នៅពេលល្ងាច វង់ភ្លេងប្រពៃណីមានភារកិច្ចមកលេងកំដរោង និងផ្ទះម្ចាស់ពិធី ។ ព្រះសង្ឃចម្រើនព្រះបរិត្តនៅពេលព្រលប់នាថ្ងៃចូលរោង ជាកិច្ចបើកពិធី ។ បន្ទាប់ពីនេះ វង់ភ្លេងបានធ្វើពិធីអុំទូក បេះល័ខ កាត់ស្លឹក ពិធីក្រាញ់ ននៀល ចាក់ក្រពើ ចាក់អន្ទង់... ។

នៅព្រឹកថ្ងៃទីពីរ អាចារ្យបានឱ្យកូនស្រីចេញមកធ្វើពិធីថ្វាយបង្គំព្រះអាទិត្យ ។ ទោះបីមកដល់ថ្ងៃនេះហើយក្ដី ក៏កូនក្រមុំមិនទាន់បញ្ចេញខ្លួនឱ្យអ្នកផងបានឃើញឡើយ ។ នៅពេលចេញមកសំពះព្រះអាទិត្យ នោះគេនាំគ្នាដើរជុំវិញអាសនៈទេវតាដែលហ៊ុំព័ទ្ធដោយរាជវ័តិ និងមានវាំងននបាំងបិទពីក្រៅយ៉ាងជិត មិនអាចឱ្យអ្នកណាមើលឃើញនាងឡើយ ។ នៅក្នុងពេលព្រះសង្ឃចម្រើនព្រះបរិត្ត ក៏នាងមិនអាចបញ្ចេញខ្លួនមកក្រៅដែរ ។ ការប្រគេនចង្ហាន់ព្រះសង្ឃចំនួន ៥ អង្គត្រូវបានប្រព្រឹត្តទៅនៅម៉ោងប្រមាណជា ១០ កន្លះព្រឹក ។ ជាមួយនោះដែរមានការប្រគេនសាដកឬចីវរមួយត្រៃទៅតាមលទ្ធភាព ។ ព្រះសង្ឃសូត្រជ្រាយពុទ្ធជ័យមង្គល បាចផ្កាស្លាប្រសិទ្ធិពរសិរីសួស្ដីចំពោះកូនស្រី ។

## IV- ពិធីដាំថ្លាំស្មោរល័ខ

តាមទំនៀមពីបុរាណ គេយកក្អមឬកូនថ្លាងមកដាំទឹកស្មោរវល្លិ ៣ សន្លឹក កញ្ចើបាយដាច រាក់ស រាក់ក្រហម ឱ្យពុះ ទើបយកផ្លែចបជីកស្អាតទៅដាក់គងពីលើ

ទឹកពុះត្រងយកចំហាយញើសមកផ្តិតនិងសំឡីទុកសម្រាប់ជូតមាត់កូនស្រី ។ នៅពេលមុននឹងបង្ហាត់ភ្លើង គេសូត្របាលីយ៉ាងនេះថា **"ឥន្ទ្រីកិញ្ចំ សិទ្ធិកម្មំ សិទ្ធិរោគា សិទ្ធិសូស្តី គចន្តុមេ ..."**

## V-ពិធីធ្វើធ្មេញ

ដំបូងគេយកល័ខ[១] មកបុកលាយនឹងស្លឹកសំបូរពាសន្ទឹក បុកឱ្យម៉ដ្ឋរួចខ្ចប់នឹងក្រណាត់យកមកឱ្យកូនស្រីបៀម មុននឹងយកចំហាយញើស ដែលជាប់នៅផ្ទៃចបជីកយកមកជូតមាត់ ។

## VI-ពិធីអង្គុយអង្កររាប ឬ រាវអង្ករ

គេត្រូវយកអង្ករទម្ងន់ ១ហាប (៦០ គ.ក )មករាវចឱ្យរាបស្មើនៅលើកន្ទេលមួយ ។ បន្ទាប់មកគេយកវត្ថុផ្សេងៗ មានជាអាទិ៍ស្បូវភ្លាំង កាត់ឱ្យខ្លី ចងឱ្យណែន ស្រូវនាងគង់ ត្រល់ ចិញ្ចៀនមាស ទេពពិរូ កញ្ជើបាយដាច បន្ទាស្អិត ភ្លាំង.... មកកប់ក្នុងអង្ករនោះ ។ គេចែកអង្កររាបជា ៣ ល្វែង ឱ្យកូនស្រីអង្គុយបែរមុខទៅទិសខាងកើត រួចយកដៃមករាវកកាយអង្ករពីខាងក្រោយខ្នងខ្លួន ។

បើបានប្រទះឃើញរបស់អ្វីនោះ គេទស្សន៍ទាយជោគវាសនាកូនស្រីតាមតម្លៃវត្ថុដែលនាងរាវបានមកនោះ ។

## VII- ពិធីសែនជើងសេះ

គេយកសេះល្អមួយមកធ្វើកិច្ចជារៀនជិះ ។ នៅលើកទីមួយ សេះរត់បានឆ្ងាយបន្តិច អ្នកជិះធ្វើជាធ្លាក់ពីលើខ្នងសេះ ។ នៅលើកទីពីរ សេះបោលបានឆ្ងាយជាងមុន ទើបអ្នកជិះធ្លាក់ពីខ្នងសេះ ។ គេពោលថា សេះមិនទាន់រាប ទើបមានការ

---

១- ល័ខជុំកន្ទង់

ភ្លាំងភ្លាត់ដូច្នេះ ។ នៅលើកទី ៣ សេះក៏រត់បានល្អ អ្នកជិះក៏មិនធ្លាក់ បែបនេះ គេពោលថា "សេះរាបហើយ....." ។

## VIII- ពិធីកប់សក់

លោកអាចារ្យបានកាត់សក់កូនស្រីបន្តិចខ្ចប់នឹងស្លឹកចេក រួចទើបនាំកូនស្រីព្រមទាំងឪពុកម្ដាយញាតិមិត្ត ដង្ហែប្រទក្សិណជុំវិញរោងពិធីចំនួន ៣ ជុំ រួចហើយលោកអាចារ្យនាំមុខក្បួនហែ ធ្វើដំណើរទៅកាន់ស្រែណា ដែលបម្រុងនឹងចែកឱ្យកូនស្រីនេះ។ ទៅដល់ហើយ លោកអាចារ្យយកកញ្ចប់សក់នេះ ទៅកប់នៅកណ្ដាលស្រែ ដោយឧបកិច្ចថា ឱ្យកូនស្រីនេះបានចម្រុងចម្រើន មានសិរីសួស្ដីជ័យមង្គល អាយុយឺនយូរតរៀងទៅ ។ លុះធ្វើកិច្ចនេះចប់ហើយ អ្នកទាំងនោះក៏នាំគ្នាវិលមកកាន់ផ្ទះវិញដោយដើរដង្ហែរជាក្បួន ៣ ជុំរោងរួចទើបបែកគ្នា ។

## IX- ពិធីជិះសេះរោងចេញសុំស្បៀង[១]

អ្នកភ្លេងម្នាក់ត្រូវចាត់ឱ្យដើរតួរជាអ្នកជិះសេះរោង ដើម្បីដើរអង្គាសសុំស្បៀង ពីបណ្ដាជននៅក្នុងភូមិផងរបងជាមួយ ។ កាលណាមានអ្នកស្រុកណា ហៅអ្នកជិះសេះរោងក៏ចូលទៅកាន់ផ្ទះនោះ ។ អ្នកហៅរមែងឱ្យ មាន់ ត្រី អង្ករ អំបិល...ឬវត្ថុផ្សេងៗទៀតដែលគេមាន ។ អ្នកជិះសេះរោងប្រកាន់ជំហារច្បាស់លាស់មួយ គឺបើគេមិនហៅទេ នោះនឹងមិនជិះសេះចូលទៅសុំគេដល់ផ្ទះឡើយ ។ លុះត្រឡប់មកដល់ផ្ទះពិធីវិញ អ្នកជិះសេះរោងទទួលបាននូវភស្ដុភារមួយចំនួនយកទៅជូនម្ចាស់ដើមការ ដើម្បីយកទៅចាត់ចែងធ្វើម្ហូបអាហារសម្រាប់ពិធីលៀងភ្ញៀវ ។

---

១-នេះជាពិធីមួយបកស្រាយនូវចំណងសាមគ្គីដ៏ល្អិតរមួត រវាងជនជាតិខ្មែរយើង ដែលតែងតែជួយឈឺឆ្អាលសង្គ្រោះគ្នាទៅវិញទៅមកគ្រប់គ្រាមានអាសន្នធុរៈ ។

## X- ពិធីលៀងភ្ញៀវ :

ពិធីនេះ ច្រើនធ្វើនៅពេលរសៀលម៉ោង ៣ ទៅ ម៉ោង ៥ ។ កាលពីដើម គេក្រាលកន្ទេលផ្ទាល់នឹងដី សម្រាប់ដាក់ស្លក បាយ សម្ល និងឱ្យភ្ញៀវអង្គុយបញ្ឈរ ជង្គង់បរិភោគអាហារ ។ ប៉ុន្តែឥឡូវ គេបានវិវត្តមកដល់សម័យថ្មីមួយ ដែលអ្នកចូលរួមក្នុងពិធីជប់លៀង មានវាសនាបានអង្គុយលើកៅអី និងមានតុល្អៗ សម្រាប់ដាក់អាហារចំណីបានសមរម្យ ។ ម្ហូបដ៏ឆ្ងាញ់ពិសារ រួមជាមួយនិងស្រា បង្កើតបានជាបរិយាកាសរីករាយ អ៊ូរអរចំពោះភ្ញៀវទាំងឡាយ ។ ពេលបរិភោគរួចហើយ ភ្ញៀវម្នាក់ៗចងដៃភ្ជាប់ព្រលឹងកូនស្រី ជាលុយកាក់ ប្រាក់កាស ជាសំពត់អាវ ជាគ្រឿងអលង្ការ ទៅតាមលទ្ធភាពរបស់ម្នាក់ៗ និងទៅតាមមនោសញ្ចេតនា ជាសាច់ញាតិជិតស្និទ្ធឬជាមិត្តភក្តិក្លែម្រាក់...។ ជាមួយនឹងចំណងដៃ ជាវត្ថុផ្សេងៗដូចជម្រាបខាងលើ ភ្ញៀវប្រុសស្រីនៅថែមទាំងបានជូនពរស័ព្ទសាធុការដល់កូនស្រី ឱ្យមានសិរីសួស្តី មានជោគវាសនាល្អ មានអាយុយឺនយូរ និងមានទ្រព្យធនសម្បូរធូរធារតរៀងទៅ ។

## XI- ឧត្តមគតិរបស់ខ្មែរចំពោះការចូលម្លប់

គ្រប់តែខ្មែរទាំងអស់ដែលមានកូនស្រី តែងរំពឹងគិតទុក និងមានបំណងប្រាថ្នាថា ពិធីចូលម្លប់ពិតជាផ្តល់នូវអត្ថប្រយោជន៍ផ្សេងៗ ដូចពោលតទៅនេះ ÷

**១-សងគុណឪពុកម្តាយ :**

កូនប្រុសបួសនេនសងគុណម្តាយ បួសភិក្ខុសងគុណឪពុក ។ ឯកូនស្រីយកពិធីចូលម្លប់នេះ ធ្វើជាកិច្ចដើម្បីតបស្នងសងគុណម៉ែឪ ឱ្យសក្តិសមខ្លួនជាកូនកតញ្ញូ

**២-បំពេញលក្ខណៈឱ្យកូនស្រី:** មានគុណសម្បត្តិ លក្ខណៈសម្បត្តិ សក្តិសម

ជាស្រីខ្មែរគបលក្ខិណា ឬគ្រប់លក្ខណ៍ ។ ខ្មែរទាំងអស់តែងតែឱ្យតម្លៃខ្ពស់ទៅលើលក្ខណ៍

**៣- បណ្តុះបណ្តាលវិជ្ជាជីវៈឱ្យកូនស្រី**

ពេលឋិតនៅក្នុងម្លប់ កូនស្រីបានរៀនដេរប៉ាក់ ចាក់ជុល ត្បាញ រវៃ ដាំស្ល និងហាត់រៀនធ្វើវិជ្ជាមេផ្ទះដទៃៗទៀតឱ្យបានស្ទាត់ជំនាញ ដើម្បីក្លាយខ្លួនទៅជាប្រពន្ធល្អ មាតាល្អ មេផ្ទះល្អ ... ។

**៤- បង្ហូរបកាយឱ្យល្អស្រស់ :**

ក្នុងរយៈពេលឋិតក្នុងម្លប់ កូនស្រីដែលទើបឈានចូលក្នុងវ័យក្រមុំ ហើយដែលបានឈប់សម្រាកពីការងារធ្ងន់ស្រោលនៅស្រែចម្ការ បានបរិភោគអាហារបួស បានតុបតែងខ្លួនប្រាណដោយប្រេងម្សៅជារៀងរាល់ថ្ងៃនោះ រូបរាងនាងប្រែល្អប្លែកខុសពីពេលនៅក្រៅម្លប់ ។ **"ស្រីយករូបជាសម្បត្តិ ប្រុសមានវិជ្ជាជាទ្រព្យធន ព្រះសង្ឃយកសីលជាបើមទុន ព្រាថ្ងយកគុណាធមិជាអលង្ការ"** ។ រូបសម្ផស្សដ៏ល្អឆើតឆាយរបស់នារីចូលម្លប់ ពិតជាទាក់ទាញអារម្មណ៍អ្នកផង ឱ្យចាប់ចិត្តមេត្រី ។ ដូច្នេះមិនយូរប៉ុន្មាន ក្រោយពីការចេញពីម្លប់ នាងពិតជាមានគេចូលស្តីជាមិនខាន ។

## XII- អត្ថន័យ នៃពិធីផ្សេងៗក្នុងការចូលម្លប់ និងបញ្ចេញពីម្លប់

១- ឱ្យអ្នកផង និងសាមីខ្លួនដឹងថា ខ្លួនកំពុងឈានចូលវ័យក្រមុំ

ការមករដូវជាលើកដំបូងបានបើកទ្វារ ឱ្យកូនស្រីចាកចេញពីវ័យជំទង់ចូលទៅវ័យក្រមុំ ។ វ័យថ្មីភារកិច្ចថ្មី ។ ត្រៀមខ្លួនបំពេញតួនាទីជាប្រពន្ធគេ ជាមេផ្ទះ ជាមាតា .... ។

**២- រាវអង្ករ ឬអង្គុយអង្កររាប**

ធារអង្ករទម្ងន់មួយហាប តំណាងឱ្យភោគផលកសិកម្ម ដែលកូនស្រីត្រូវតែពុះពារដាំដុះឱ្យបានផលច្រើន ដើម្បីជីវភាពធូរធារ ។

-កប់វត្ថុពិសេសៗផ្សេងៗក្នុងអង្ករឱ្យកូនស្រីរាវ គឺជាចំណោទប្រស្នា ឱ្យកូនស្រីយល់ថា ទ្រព្យសម្បត្តិវត្ថុផ្សេងៗ ដែលកប់នៅក្នុងអង្ករនោះ ជារង្វាន់ ។ រាវគឺសកម្មភាពការងារ ដែលខ្លួនត្រូវធ្វើ ។ ឯការចាប់យកបាននូវរបស់អ្វីមួយនោះ គឺជាលទ្ធផលផ្លែផ្កានៃការងារ ។

**៣-ពិធីសែនជើងសេះ**

ជះសេះធ្លាក់លើកទី ១ និងលើកទី ២ ជាការបកស្រាយនូវការពិសោធន៍សាកល្បង នៅគ្រាដំបូង តែងតែមិនទាន់បានផលល្អនៅឡើយទេ ប៉ុន្តែបន្ទាប់ពីការតស៊ូព្យាយាមនៅលើកទី ៣ ឬលើកក្រោយៗ ជាបន្តបន្ទាប់នោះ រាល់កិច្ចការពិតជាបានសម្រេចលទ្ធផលល្អមិនខាន ។

**៤-ពិធីធ្វើធ្មេញ**

គឺជាការបង្ហាញប្រាប់ពីរសជាតិល្វីងជូរចត់ និងរសជាតិផ្អែមល្ហែមនៃជីវិត ។ ជីវិតពិតជាបានជួបនឹងភារៈទាំងពីរនេះជាចាំបាច់ ដូច្នេះ សំខាន់ កូនស្រីត្រូវតែចេះតស៊ូ ខន្តីអត់ធ្មត់ នៅពេលជួបការលំបាកក្នុងជីវិត ។ ការឧស្សាហ៍ព្យាយាមការចេះយោគយល់ចិត្តគ្នា ការចេះធ្វើម្ចាស់លើចិត្ត ចេះគ្រប់គ្រងចិត្តរបស់ខ្លួន ការចេះសម្រប សម្រួលជាមួយស្វាមី នោះហើយជាបង្អែមនៃជីវិត ។

នៅមានចំណុចដែលត្រូវវិភាគច្រើនទៀត ដែលខ្ញុំសូមទុកឱ្យអស់លោកអ្នកអានបន្តត្រិះរិះពិចារណាបន្ថែមទៀតផងចុះ ។

✱អ្នកស្រាវជ្រាវបានជួបសម្ភាសន៍ ជាមួយលោកតា **គាន់ ពែក** អាយុ ៨៥ ឆ្នាំ នៅឃុំត្រប់ស្រុកបាធាយ ដែលធ្លាប់ធ្វើជាអាចារ្យ ដឹកនាំពិធីចូលម្លប់ចេញពីម្លប់ នៅតំបន់នេះ ។

# ប្រវត្តិ វត្តបាកាន

ដោយ : ម៉ៅ សោភ័ណ
រស់ សំណាង



*( ព្រះវិហារវត្តបាកាន )*

**បាកាន** គឺជាឈ្មោះវត្តមួយក្នុងចំណោមវត្តមួយរយម្ភៃប្រាំ ដែលមាននៅក្នុងទឹកដីនៃខេត្តពោធិ៍សាត់ ។ *វត្តបាកាន* ស្ថិតនៅក្នុងភូមិ *បាកាន* ឃុំ *ត្រពាំងជង* ស្រុក *បាកាន* ចម្ងាយ ៩ គីឡូម៉ែត្រ ស្ថិតនៅខាងត្បូងឆៀងខាងលិច សាលាស្រុក *បាកាន* ។ បើនិយាយអំពីប្រវត្តិរបស់វត្តបាកាន គេក៏នឹកឃើញភ្លាមដល់ភាពជាអច្ឆរិយៈទាំងបី ដែលជំរុញឱ្យឈានដល់ការកកើតវត្តទៅតាមដំណាក់កាល ខុសៗគ្នា ដូចជា :

១/ ប្រវត្តិ នៃការកសាងប្រាសាទបុរាណ (ព្រះខ័ន ឬពន្ធនៈចេតិយ) ។

២/ ប្រវត្តិ ព្រះបដិមាបែរព្រះភ័ក្ត្រទៅទិសខាងលិច ។

៣/ ប្រវត្តិ នៃភាពអស្ចារ្យរបស់ដើមពោធិ៍ ។

យើងបានធ្វើការសិក្សាស្រាវជ្រាវ តាមរយៈការធ្វើបទសម្ភាសន៍ នៅក្នុងមូលដ្ឋាន ជាមួយនឹងព្រឹទ្ធាចារ្យមួយចំនួនដែលនៅចងចាំ តាមការដំណាលត១គ្នាមកនោះ គឺមាន លោកតាអាចារ្យ **នេត ផង់** លោកតា **សាំង សឿន** និងលោកតា **ឌៅង អាត** អាចឱ្យយើងយកមកធ្វើការផ្ទៀងផ្ទាត់ជាមួយ នឹងឯកសារមួយចំនួនទៀតគ្រាន់ជាទីអាងមានដូចជា :

១/ ឯកសារមហាបុរសខ្មែររបស់លោក **អេង សុត**

២/ ឯកសារចម្លងព្រះរាជពង្សាវតារខ្មែរដោយលោក **មី សែលត្រាណេ**

៣/ ឯកសារ Angkor et Sicles Dant Khmere របស់ទស្សនាវដ្ដីសាលាបារាំងចុងបូពា (រូបថតរក្សាទុកក្នុងសាលាស្ថាបត្យកម្មថៃអយុធ្យា) ។

៤/ ឯកសារសម្រង់បញ្ជីសារពើភ័ណ្ឌប្រាសាទបុរាណខ្មែរឆ្នាំ ១៩៧៥ ។

៥/ ឯកសារអរិយធម៌ខ្មែររបស់អ្នកស្រី **ត្រឹង ងា** អាចធ្វើការបែងចែកដាច់ដោយឡែកពីគ្នា តាមការរៀបរាប់ដូចខាងក្រោមនេះ :

**អំពីប្រវត្តិប្រាសាទបុរាណ :**

*ក/ តាមបទសម្ភាសន៍:*

-ក្នុងអំឡុងឆ្នាំ ៧០០ នៃគ្រិស្តករាជ ស្ថិតក្នុងរជ្ជកាលក្សត្រខ្មែរមួយព្រះអង្គគ្រងរាជ្យ ព្រះនាម **ព្រះបាទសុរិយធម្ម** (ព្រះនាមក្សត្រនេះគ្មាននៅក្នុងពង្សាវតារខ្មែរទេ) ដោយទ្រង់មានព្រះទ័យស្មោះភក្ដីក្នុងផ្លូវព្រះពុទ្ធសាសនា ព្រះអង្គបានឱ្យកសាងប្រាសាទចេតិយមួយឡើង ទុកសម្រាប់តម្កល់ព្រះសារីរិកធាតុ របស់

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ហើយប្រសិទ្ធនាមថា (**ប្រាសាទ ពន្លនៈចេតិយ**) សាងឡើងអំពីថ្មភក់ និងថ្មបាយក្រៀម លើកបន្ទុបតម្រៀបផ្ទាបន្តជាប្រាង្គប្រាសាទ មានក្លោងទ្វារបួនទិស និងសាងចេតិយតូចៗដាច់ទាំងបួនទិសថែមទៀត ផង ។

គ/ ឯកសារសំណេរ :

-ផ្អែកលើសម្រង់បញ្ជីប្រាសាទបុរាណបានបញ្ជាក់ច្បាស់ថា នៅក្នុងបរិវេណវត្តបាកាន ក្នុងភូមិបាកាន ឃុំត្រពាំងជង ស្រុកបាកានមានប្រាសាទបុរាណមួយកន្លែងសាងឡើងអំពីថ្មភក់និងថ្មបាយក្រៀមមានឈ្មោះថា *ប្រាសាទព្រះខ័ន* លក្ខណៈសម្គាល់ប្រាសាទរាងសាជីជ្រុងឧបសម្ព័ន្ធសិលាចារឹក ចុះក្នុងបញ្ជីក្បាលសូន្យមួយលេខពីររយកៅសិប កាមួយរយចិតសិបប្រាំបួន បេអឹ (ក្បាល 01 លេខ 290 K 179 BE 13/01/1941) ចុះស្រាវជ្រាវ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៤១ ។ ក្នុងឯកសារសៀវភៅសាលាបារាំងចុងបូព៌ាបានបញ្ជាក់ថា ប្រាសាទនេះ កសាងឡើងក្នុងសតវត្សទី ១៧ (ដប់ប្រាំពីរ) ។ បើយើងធ្វើការប្រៀបធៀបប៉ាន់ស្មានតាមរយៈឯកសារពង្សាវតារខ្មែរ គឺប្រហែលនៅក្នុងរជ្ជកាលក្សត្រខ្មែរមួយព្រះអង្គព្រះនាម **ព្រះបាទសុរិយោពណ៌** ព្រោះកាលនោះក្នុងនគរមានការរំពើតរំពើងដោយក្សត្រខ្មែរព្រះនាម **ពញា តន់** ឡើងសោយរាជហើយទ្រង់ពុំយកព្រះទ័យទុកដាក់នឹងការងារផែនដី ទ្រង់សព្វព្រះទ័យតែនឹងបណ្តើរផ្តែ គង់លើសេះដេញសត្វ ចាក់ជង់បង្កាត់ ទាក់ក្រួច ទទា មាន់ព្រៃ និងលលកជាធម្មតា ហើយថែមទាំងនាំបណ្តោជាខ្ញុំពីស្តេចបុរាណចេញប្រពាតព្រៃ ព្រមទាំងបៀតបៀនប្រពន្ធកូនអ្នកស្រុក និងមន្ត្រីជាខ្ញុំជានិច្ចកាលទើបជាហេតុបណ្តាលឱ្យនគរទាំងមូលស្ថិតក្នុងភាពអណាធិបតេយ្យ[១] បែងចែកទឹកដី

---

១- អានាធិបតេយ្យ < អ+(ន) + អាធិបតេយ្យ=គ្មានអាធិបតេយ្យ.គ្មានអាធិបតេយ្យ.គ្មានឥស្សរភាព (វចនានុ-ទំ-១៦០៦ និង ១៧៣២)

ស្ដេចត្រាញ់ តាមអាណាខេត្តនីមួយៗ ធ្វើបាបរាស្ត្រតាមតែអំពើចិត្តរបស់ខ្លួន ។ ឃើញហេតុភេទដូច្នេះហើយ ទើប **ព្រះមហាទេវីក្សត្រី** ដែលត្រូវជាព្រះអយ្យិកា មិនសពព្រះរាជហឫទ័យទើបព្រះនាងធ្វើចុតហ្មាយ អាលាក់ទូលថ្វាយព្រះចៅក្រុងសុខោទ័យ ដើម្បីសុំសេចក្ដីអភ័យយាង **ព្រះបាទសុរិយោពណ៌** ដែលស្ដេចក្រុងទេព យាងទៅជាកំណែនក្នុងគ្រាចាញ់សង្គ្រាម ឱ្យមកស្នងរាជសម្បត្តិក្នុងនាមប្រយូរវង្សពីព្រះ **ពញ្ញា តន់** ដូចនេះហើយទើប **ព្រះបាទសុរិយោពណ៌** ទ្រង់យាងមកសោយរាជ ហើយទ្រង់យាងទៅ បង្ក្រាបស្ដេចត្រាញ់ទាំងអស់តាមគ្រប់អាណាខេត្ត លុះមកដល់ខេត្តពោធិ៍សាត់ ទើបទ្រង់សពព្រះទ័យសាងប្រាសាទនេះឡើង ក្នុងគោលបំណងទុកជាទីសក្ការៈបូជាផង និងជាគោល សង្កត់ផែនដីជាទីចំណាំនិងសុំសុខក្សេមក្សាន្តតរៀងទៅផង ។



*( ទួលប្រាសាទ និងដើមពោធិ៍ ដែលបន្សល់ទុកមកដល់បច្ចុប្បន្ន)*

## សំណាកសម្គាល់វត្ថុតាង

-ក្នុងអំឡុងសង្គ្រាមឈ្លានពានពីសត្រូវជិតខាងមកលើទឹកដីខ្មែរ ជាញឹកញាប់នោះត្រូវធ្លាក់ទៅលើការកាន់កាប់ពីបរទេស ដូច្នេះតួចេតិយទាំងបួនទិស និង

តួប្រាសាទត្រូវគេគាស់បំផ្លាញរកកំណប់ រំលើងអស់តួចេតិយពីរ មួយត្រូវនាំយកទៅស្រុកថៃ នៅសល់តែប្រាង្គ និងចេតិយពីរ ព្រមទាំងសំណល់របស់រាជវត្ថុរូបសំណាកតោ ឈើ និងក្បាច់ រចនាខ្លះតែប៉ុណ្ណោះ ។

ស្ថិតក្នុងរជ្ជកាលព្រះចៅក្រុងកម្ពុជាធិបតី **ព្រះបាទមុនីវង្ស** ដោយព្រះអង្គសពព្រះរាជហឫទ័យនឹងព្រះរាជដំណាក់មួយនៅក្នុងឃុំត្រពាំងជង ស្រុកបាកាន និងដោយបានឃើញពីភាពបាក់បែករាត់រាយនៃថ្មប្រាសាទ ព្រះអង្គត្រាស់បង្គាប់ឱ្យ គេរើយករូបសំណាកនិងក្បាច់រចនាល្អៗ មួយចំនួនមករក្សាទុកនៅក្នុងរាជដំណាក់របស់ព្រះអង្គឯត្រពាំងជងទៅ ។

ក្នុងសម័យបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ តួចេតិយដ៏អភ័ព្វត្រូវបានក្លាយជាជើងទំនប់ក្នុងស្ទឹងដំណាក់ឈើក្រម ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។ មិនតែប៉ុណ្ណោះថ្មប្រាសាទនៅដំណាក់ត្រពាំងជង ក៏ត្រូវបាត់បង់ស្ទើរទាំងអស់ដែរ ។

បច្ចុប្បន្ននៅសល់តែតួប្រាសាទរាងសាជីជ្រុង ដែលមានដីពូនជាកូនភ្នំ និងដើមពោធិ៍ ដុះគ្របពីលើតែប៉ុណ្ណោះ ។

## អំពីប្រវត្តិវត្តបាកាន និង បដិមាបែរព្រះភក្ត្រទៅទិសខាងលិច :

*ក/ ពាក្យតំណាលតាមការចងចាំ :*

កាលពីព្រេងនាយស្ថិតក្នុងរជ្ជកាលព្រះបាទសុរិយាវង្ស បន្ទាប់ពីព្រះអង្គកសាងភ្នំឈ្មោះ *ពន្ទនៈ ចេតិយ* ប្រតិស្ឋានទុកសម្រាប់សាសនា រួចហើយព្រះអង្គទ្រង់ចម្រើនធម៌ នៅទីនោះមួយរយៈ ។ សម័យថ្ងៃមួយស្រាប់តែមាន ហេតុអស្ចារ្យមួយកើតមានឡើង គឺមានដើមពោធិ៍មួយដើមអណ្តែតបញ្ច្រាសទឹក មិនដឹងជាមកអំពីទីណា មតិខ្លះថាជាវត្ថុដែលទេវតានិម្មិតមកពីបឹងទន្លេសាបតាម ដងស្ទឹងពោធិ៍សាត់ឡើងមកដល់ទីកន្លែងមួយមិនប្រាកដឈ្មោះភូមិ ត្រូវបានអ្នកស្រុកប្រទះ

ឃើញអព្ភូតហេតុអស្ចារ្យនេះ ក៏តាំងនាំគ្នាចុះទៅបួងសួងអធិដ្ឋាន សុំយាងដើមពោធិ៍នោះមកដាំនៅទីនេះ ដើម្បីបានថែរក្សាទុកជាទីសក្ការៈបូជា សុំសេចក្ដីសុខដល់កូនចៅនៅភូមិស្រុក ។ ប៉ុន្តែដើមពោធិ៍មិននៅស្ងៀមមួយកន្លែងឡើយ ចេះតែបន្តអណ្ដែតឡើងទៅលើទៀតអ្នកស្រុកភូមិឃើញដូច្នេះ នឹកអស់សង្ឃឹមទាំងអស់គ្នាក៏លាន់មាត់ព្រម១គ្នាថា **ព្រះពោធិ៍លោកមិននៅទេៗ** ក្រោយមកឈ្មោះនេះបានក្លាយជាប់មកជាឈ្មោះភូមិហៅកាត់ខ្លីថា **ភូមិ ព្រះទេ្ទៗ** រឿងរហូតមក ។ និយាយអំពីដើមពោធិ៍ កាលបើបានអណ្ដែតចេញអំពីភូមិនោះមកហើយ បានត្រូវអ្នកស្រុកភូមិមួយកន្លែងទៀតឃើញហើយនាំគ្នាធ្វើដូចមុនទៀត ប៉ុន្តែម្ដងនេះគេនាំគ្នាហែលទឹកអូសខ្សែព្ញរយកទៅចងទាក់ដើមពោធិ៍ មកក្រៀកភ្ជាប់នឹងដើមចារមួយដើម តែទីបំផុតដើមចារត្រូវដើមពោធិ៍អណ្ដែតអូស រលើងឫសធ្លាក់ចោលមែក រយុលមកក្នុងទឹកដាច់ទាំងខ្សែព្ញរជាច្រើនកំណាត់ទៀតផង ក្រោយមកជាប់ឈ្មោះជា ភូមិ **ចាររយុល** ក្រោយហៅយា១មកនៅត្រឹមពាក្យថា ភូមិ **ចាយ៉ុង** វិញ ។ ដើមពោធិ៍បានអណ្ដែតឡើងបន្តមកដល់ប្រើប នឹងកំពង់ទឹកនៃទី **ប្រាសាទពន្ធនៈចេតិយ** ហើយអណ្ដែតវិលវល់ហាក់កំពុងរកទីសំចត ឃើញដូច្នេះ **ព្រះបាទសុរិយោវង្ស** និងព្រះជាយាព្រមទាំងសេនាបតីសព្វមុខមន្ត្រីនាំគ្នារៀបចំពិធីពលីការបូជាទៀនធូប ភ្ញី ផ្កានមស្សការ ចំពោះព្រះរត្នត្រ័យរួចហើយ **ព្រះបាទសុរិយោវង្ស** ទ្រង់បានបួងសួងអធិដ្ឋានផ្សងថា ‹ ប្រសិនបើដើមពោធិ៍ដ៏មហាស្ចារ្យនេះ មានបុណ្យបារមីមានមហិទ្ធិឫទ្ធិខ្លាំងពូកែ និងជាអ្នកថែរក្សាព្រះពុទ្ធសាសនា អស់កាលដ៏យូរសូមលោកឱ្យមហេសីនៃខ្ញុំព្រះករុណា ជាក្សត្រីស្រីគ្រប់លក្ខណ៍ចុះទៅចងទាក់ដើមពោធិ៍នេះ ឱ្យបានជាប់ដើម្បីអូសទាញយកមកដាំ ប្រតិស្ឋានទុកក្នុងទីពន្ធនៈចេតិយគ្រាន់ទុកជាទីគោរពបូជាតរៀងទៅ › ចប់ពិធីបួងសួងមហេសី **ព្រះបាទសុរិយោវង្ស** ទ្រង់យាងចុះចាកកំពង់

ទឹកតាមព្រះទីនាំង នាំយកអំបោះប្រាំពីរសរសៃទៅចងទាក់ដើមពោធិ៍ ហើយឱ្យមន្ត្រី សេនាបតី ខ្ញុំរាជការ អាមាត្រទាញស្រែកហ៊ោគឹកកងជាមួយនឹងសម្លេងប្រគុំដន្ត្រី ពិណពាទ្យទាញអូសដើមពោធិ៍ ពីក្នុងស្ទឹងឡើងមកលើគោក ។ ទាញឡើងមកលើគោក គឺមិនពិបាកក្នុងការទាញឡើយ ។ ដោយក្តីសប្បាយរីករាយ និងជោគជ័យនេះ ទាំងប្រជារាស្ត្រ ទាំងមន្ត្រី សេនាបតីនាំគ្នាភ្ញាត់មាត់ ស្រែកព្រមគ្នាឡើងថា "**បានការហើយៗ** " ទីនោះជាប់ឈ្មោះថាភូមិបានការ រហូតមក ។ ក្រោយមកទីនោះក៏បានរៀបចំឡើងជាទីអារាម ។ ក្រោយមកទៀតដោយបានដឹងថាសៀមប៉ងតាមរកទីទួលកំណប់ឈ្មោះបានការៗ នោះអ្នកស្រុកក៏មូលមតិគ្នាជាសម្ងាត់ប្តូរមកជាឈ្មោះវត្ត **បាគាន** វិញរៀងរហូតមក ។ អំពីព្រះបដិមាបែរព្រះភ័ក្ត្រ ឆ្ពោះទៅទិសខាងលិចវិញនោះ គឺជាកលល្បិចរបស់ពួកចារកម្មសៀម ក្នុងសង្គ្រាមចូលមកឈ្លានពានទឹកដីខ្មែរតែប៉ុណ្ណោះ គឺពួកវាបានសន្យាជាមួយទ័ពក្រោយថា បើលើកទ័ពចូលទៅដល់ទីណាដែលឃើញមានសំណាកព្រះបដិមាបែរភ័ក្ត្រ ឆ្ពោះទៅទិសខាងលិចត្រូវបញ្ឈប់ទ័ព ឬក៏ប្រញាប់ដកទ័ពថយចេញវិញភ្លាម ព្រោះទីនោះពុំធានាសុវត្ថិភាពទេ ។ ដោយខ្មែរយើងមិនដឹងស្មានតែព្រះបដិមាបែរព្រះភ័ក្ត្រទៅទិសខាងលិចដោយខ្លួនឯង ក៏នាំគ្នារក្សាភាពដើមដូច្នេះរៀងរហូតមកឥតមានហ៊ាន កែប្រែឡើយ ។

*ខ/ ការអះអាងតាមរយៈឯកសារ :*

ក្រោយពីបានសាងប្រាសាទព្រះខ័នរួចមក ការឈ្លបចូលមកឈ្លានពានបំផ្លិចបំផ្លាញជាញឹកញាប់ពីសំណាក់ក្រុងទេព បានធ្វើឱ្យប្រាសាទព្រះខ័នទទួលរងនូវការខូចខាតយ៉ាងដំណំ ។ លុះចំណេរក្រោយមកមានព្រះសង្ឃមួយអង្គនិមន្តធ្វើធុតង្គបានមកដល់ទីទួលបុរាណដ្ឋាននេះ ដែលស្ថិតជាទីព្រៃរហោស្ថានប្រកប

ដោយសំណង់បាក់បែកទ្រុឌទ្រោម គ្មានអ្នកថែរក្សាឃើញដូច្នោះព្រះសង្ឃអង្គនោះក៏សម្រេចព្រះទ័យសំណាក់ធ្វើធុតង្គនៅប្រប់នឹងទីបុរាណនោះទៅ ដើម្បីមើលថែរក្សាប្រាសាទនេះផង ។ ពេលក្រោយមកទៀតអ្នកស្រុកបានមករានដីព្រៃធ្វើចំការនិងចាំឈើហ៊ុប ព្រមទាំងរស់នៅក្បែរៗទីនោះ គេតែងយកចង្ហាន់ទៅប្រគេនព្រះសង្ឃជារៀងរាល់ថ្ងៃ ។ ដោយក្តីចាប់អារម្មណ៍ នឹងប្រាសាទផងនិងដោយមានព្រះសង្ឃផង អស់ពួកអ្នកស្រុកភូមិបានជំនុំ គ្នានិមន្តព្រះសង្ឃអង្គនោះឱ្យនៅគង់នៅទីនោះតែម្តង ព្រោះងាយក្នុងការមើលថែ ប្រាសាទផងពិសេសងាយស្រួលក្នុងការបដិបត្តិគោរពបូជាតាមផ្លូវព្រះពុទ្ធសាសនា ព្រោះទីនោះនៅឆ្ងាយពីទីវត្ត ។ គេបានមូលមតិគ្នាកសាងសាលាបុណ្យមួយឡើង នៅប្រប់ នឹងទីប្រាសាទនិងបានកសាងបដិមាមួយព្រះអង្គ ប្រតិស្ឋានទុកក្នុងសាលាបុណ្យនោះទៀតផង (រូបសំណាកព្រះបដិមាចូលបរិនិព្វាន ) ។ តាំងអំពីមាន ព្រះសង្ឃមានសាលាបុណ្យមកអ្នកស្រុកបាននាំគ្នាទៅធ្វើបុណ្យច្រើនឡើងៗ ជាហេតុនាំឱ្យជួបនូវការខ្វះខាតចានឆ្នាំងសម្រាប់ប្រើប្រាស់ សម្រាប់កម្មវិធីបុណ្យក្នុងគ្រាជាមួយនោះ ស្រាប់តែមានហេតុភេទចម្លែកកើតឡើង គឺមានលោកតាម្នាក់សម្រានលក់បានយល់សុបិនឃើញដូនជីចំណាស់ម្នាក់ដើរចុះអំពីប្រាសាទ ដើរសំដៅមករកគាត់ ហើយនិយាយប្រាប់ថាបើខ្វះសម្ភារៈប្រើប្រាស់ចាំបាច់ អញ្ជើញឱ្យទាំងអស់គ្នារៀបចំធូបផ្កាភ្ញីបួងសួងចំពោះទិប្រាសាទព្រះខ័នត្រង់ក្លោងទ្វារខាងត្បូង សុំខ្ចីគ្រឿងប្រើប្រាស់តាមតម្រូវការទៅនោះនិងបានដូចបំណងហើយ តែដាច់ខាតត្រូវតែសងម្ចាស់គេវិញ ទើបឱ្យបាន ។ ភ្ញាក់ពីដំណេកលោកតាបានរៀបរាប់ប្រាប់គេឯងគ្រប់គ្នា ពិសេសព្រះសង្ឃ ។ ដោយចង់ដឹងការពិតអ្នកស្រុកក៏នាំគ្នារៀបចំពិធីបួងសួងតាមសុបិន្តនោះ ។រឿងដែលមិនគួរជឿបានប្រាកដឡើងនៅចំពោះមុខដូចបំណង ។ តាំងពីនោះមកចានឆ្នាំងប្រើប្រាស់

រាល់បុណ្យទានតូចធំលែងជួបប្រទះនឹងការខ្វះខាតទៀតមែន ។ ចំណេរសម័យក្រោយមក ដោយមានមនុស្សមិនប្រកាន់ពាក្យសច្ចៈ ខ្ចីយកមកប្រើប្រាស់ធ្វើឱ្យបែកបាក់បាត់បង់បណ្តាលឱ្យរលស់បន្តិចម្តងៗរហូតដល់លែងសក្តិសិទ្ធិ (ខ្ចីលែងបាន) ចាប់តាំងពីពេលនោះមក ។ រីឯព្រះបដិមាក៏បែរព្រះភ័ក្ត្រឆ្ពោះទៅទិសខាងលិចដោយឯកឯង ។ ទោះជាព្រះសង្ឃនិងពុទ្ធបរិស័ទបាននាំគ្នាលើកបង្វិលបែរមកទិសខាងកើតវិញ លុះព្រឹកឡើងព្រះដិមាបានបែរត្រឡប់ទៅខាងលិចវិញដដែល ។ ទាំងអស់គ្នាធ្វើរបៀបនេះ ម្តងហើយម្តងទៀតទាំងព្រះសង្ឃទាំងពុទ្ធបរិស័ទនៅតែពុំបានសម្រេច ក៏ស្រុះចិត្តគ្នាទុកព្រះបដិមាឱ្យបែរព្រះភ័ក្ត្រទៅខាងលិច រហូតមកដល់សព្វថ្ងៃនេះទៅ ។ ភាពអស្ចារ្យនេះបានលេចឮពីមាត់មួយទៅមាត់មួយ អ្នកស្រុកក៏ផ្តើលនាំគ្នាមកធ្វើបុណ្យនៅសាលាបុណ្យនេះ ជាប់ជាប្រចាំគ្មានដាច់ ។ នៅក្នុងសម័យថ្ងៃមួយស្រាប់តែមានហេតុភេទអស្ចារ្យមួយទៀតបានកើតឡើង ។ តាមដំណាលថា: ស្រាប់តែមានដើមពោធិ៍មួយដើមបានអណ្តែតបញ្ច្រាសទឹក បើតាមការសិក្សាអំពីទីតាំងភូមិសាស្ត្រយើងអាចសន្និដ្ឋានបានថា ដើមពោធិ៍នោះ គឺជាដើមពោធិ៍មានបុណ្យដែលនៅក្នុងរជ្ជកាល **ព្រះបាទអង្គចន្ទរាជា** គ្រងរាជនៅក្រុងបន្ទាយជ័យ ហើយលើកទៅតាំងនៅក្រុងលង្វែកវិញនោះ ព្រះអង្គបានយាងដើមពោធិ៍ពីវត្តពោធិ៍មានបុណ្យទៅប្រតិស្ឋានដាំរក្សាទុកនៅឯវាំងលង្វែក ព្រោះនៅខេត្តពោធិ៍សាត់ ជិតព្រំប្រទល់ស្វាយដូនកែវ (ខ្មែរ-សៀម )សៀមតែងចូលមកវាយឆ្មក់ជាញឹកញាប់ពេក ។ មួយរយៈនៃការឃ្លាតចាកពីទឹកដីខេត្តពោធិ៍សាត់ និងដោយទីតាំងដាំដើមពោធិ៍នៅក្បែរមាត់ទឹកពេកទឹកជំនន់ធំ ក៏បានគួចរំលើងឫសអណ្តែតខ្លួនបញ្ច្រាសទឹកឡើងមកតាមទន្លេរហូតចូលតាមព្រែក ឡើងតាមស្ទឹងពោធិ៍សាត់ចាស់បញ្ច្រាសមកដល់ភូមិមួយ ។ អ្នកស្រុកបានឃើញហេតុចម្លែកនេះ ក៏តាំងនាំគ្នាបន់ស្រន់បួងសួងផង

លោតហែលទឹកអូសពួរយកទៅចងទាញផង ក្នុងគោលបំណងយាងមកដាំរក្សាទុកជាទីសក្ការៈបូជា ព្រោះជារឿងចម្លែកមិនដែលមាន ។ តែការទាក់ហើយនាំគ្នាទាញមិនបានសម្រេចឡើយ ទីបំផុតពួរទាំងប៉ុន្មានត្រូវដាច់ហើយដើមពោធិ៍បានអណ្តែតឡើងមកខាងលើស្ទឹងបន្តទៅទៀត ទីនោះអ្នកស្រុកហៅតៗគ្នាមកថា **ទីព្រះមិនឱ្យ** ក្រោយមកការហៅបានក្លាយយារៗមកនៅត្រឹមពាក្យថាទី **ព្រះម្លូ (ភូមិព្រះម្លូ)** រៀងរហូតមក ។ និយាយអំពីដើមពោធិ៍កាលបើរួចពីកន្លែងមួយមកហើយ បានអណ្តែតបញ្ច្រាសមកដល់ទីភូមិមួយទៀតនៅទីនោះ ត្រូវអ្នកស្រុកភូមិឃើញហើយនាំគ្នាអុជទៀនធូប បួងសួងអធិដ្ឋាន សុំយាងដើមពោធិ៍ឱ្យព្រមនៅគង់ទីនោះ ហើយគេក៏សម្រេចនាំគ្នាហែលទឹកយកខ្សែពួរយកទៅចងទាញដើមពោធិ៍ យកទៅចងនឹងដើមចារធំមួយដើមដែលដុះប្រប់នឹងមាត់ស្ទឹង ដោយអំណាចនៃ កម្លាំងបុណ្យបារមីដើមពោធិ៍បានអណ្តែតបញ្ច្រាសទឹកទាញដើមចារនោះ ដួលរលំបាក់ដីមាត់ច្រាំងរលើងឫសឡើងលើមួយចំហៀង ធ្លាក់មែករយុលមកក្នុងទឹកដើមពោធិ៍បានអណ្តែតឡើងមកលើបន្តទៀត ។ ទីដែលដើមពោធិ៍ទាញដើមចារឱ្យដួលរលំធ្លាក់មែកយុលនោះត្រូវបានអ្នកស្រុកហៅជាប់ ឈ្មោះរហូតមកថាភូមិមែកចារយុល ក្រោយមកក៏ក្លាយនៅត្រឹមពាក្យថា ភូមិ ចាយ៉ូវ វិញម្តងទៅ ។ ស្តីពីដើមពោធិ៍ម្តងហើយម្តងទៀត ដើមពោធិ៍ត្រូវបានអ្នកស្រុកនៅ ក្នុងភូមិប្រប់មាត់ស្ទឹងខាងមុខមួយកន្លែងទៀត នាំគ្នាធ្វើការទាក់ទាញម្តងទៀត ម្តងនេះគេផ្តើមចង និងដើមចារដូច មុនទៀតតែដើមចារម្តងនេះធំជាងដើមចារមុន ប៉ុន្តែត្រូវដើមពោធិ៍ទាញ ឱ្យដួលបាក់មែកបះទាំងឫសដូចមុនទៀត ទីនោះជាប់ឈ្មោះ មកថាភូមិ ចារយុលលើ ព្រោះដើមចារនោះនៅខាងលើទឹក តែដោយពិបាកចំណាំមានឈ្មោះជាន់គ្នាផងគេក៏នាំគ្នាហៅកំលាយមកថា ភូមិចេកយុលវិញ ហើយភូមិនេះស្ថិតក្នុងភូមិ កាប់ក្រឡាញ់

សព្វថ្ងៃ ។ ប្រហែលជាដោយសារមានគោលដៅច្បាស់ដើមពោធិ៍ក៏អណ្តែតបញ្ច្រាសទឹកមកទៀត ប៉ុន្តែដោយវត្តពោធិ៍មានបុណ្យគ្មានផ្លូវទឹកចូលទៅដល់នោះ ក៏ហូរត្រួចវិលវល់ត្រង់កំពង់ទឹកខាងមុខទីប្រាសាទព្រះខ័ន ។ លុះមកដល់ទីនេះគេក៏នាំគ្នាសាកល្បងទាក់ទាញម្តងទៀត ដោយរៀបចំគ្រឿងពលីការបូជា ទៀនធូប ផ្កាភ្ញី អធិដ្ឋានបួងសួងសុំយាងដើមពោធិ៍ ដើម្បីប្រតិស្ឋានដាំទុកនៅទីនោះ ។ ម្តងនេះព្រះសង្ឃលោកបានឱ្យគេយកខ្សែអំបោះ ៧ សសៃយកទៅចងដើមពោធិ៍នោះ ជាមួយនឹងការប្រគុំភ្លេងពិណពាទ្យថ្វាយទៀតផង ។ ដើមពោធិ៍ត្រូវបានអូសឡើងមកលើគោកបានយ៉ាងងាយធ្វើឱ្យដីមាត់ស្ទឹង ជម្រាលរាបស្មើរហូតដល់សព្វថ្ងៃ ។ អ្នកស្រុកភូមិឃើញដូច្នេះត្រេកអរណាស់ក៏បានស្រែកព្រមៗគ្នាឡើងថា បានការហើយៗ ។ ជាប់ឈ្មោះថាទីទួលបានការៗទៅ ។ ដោយប្រាសាទព្រះខ័នត្រូវបាន ទទួលដំណឹងពីព្រំដែនមកថាពួកទ័ពសៀមដោយល្បីថា ប្រាសាទព្រះខ័នមានអនុភាពអាចសុំបានកំណប់ទ្រព្យ វាមានបំណងមកកកាយរើរកវត្ថុមានតម្លៃ ដូច្នេះអ្នកស្រុកភូមិ ទាំងព្រះសង្ឃ ទាំងឧបាសកបានឯកភាពគ្នាសម្រេចលើកដីពូនជាកូនភ្នំគ្របពីលើប្រាសាទនោះឡើងក្នុងបំណងលាក់ទុកជាអាថិកំបាំង ហើយយាងដើមពោធិ៍ដាក់ដាំនៅពីចំហៀងខាងលើកូនភ្នំ ព្រមទាំងសាងបដិមាបរិនិព្វានមួយអង្គបែរព្រះភ័ក្ត្រ ឆ្ពោះទៅទិសខាងកើតវិញ ក្នុងបំណងឱ្យមានបដិមាមួយបែរព្រះភ័ក្ត្រទៅកើត និងមួយបែរព្រះភ័ក្ត្រឆ្ពោះទៅទិសខាងលិច ដើម្បី

- *ព្រះបដិមាបែរព្រះភ័ក្ត្រឆ្ពោះទៅទិសខាងកើត:*

១/ ក្នុងបំណងមើលរក្សាទឹកដីខ្មែរ ទិសខាងកើត ។

២/ ដើម្បីសិក្សាពីទីកើតនៃសង្ខារផង ។

- *ព្រះដិមាបែរព្រះភ័ក្ត្រឆ្ពោះទៅទិសខាងលិច*

១/ ក្នុងបំណងមើលរក្សាទឹកដីខ្មែរទិសខាងលិច ។

២/ដើម្បីសិក្សាពីរំលត់ទៅនៃសង្ខារផងគឺ ដើម្បីទទួលនូវធុរៈរបស់សាសនា គន្ថធុរៈ និងវិបស្សនាធុរៈផង ។

អាស្រ័យដោយអំណាចបុណ្យបារមី ដើមពោធិ៍មានបុណ្យបារមី នៃប្រាសាទព្រះខ័នបារមី និងភាពអស្ចារ្យនៃព្រះបដិមាបែរព្រះភ័ក្ត្រឆ្ពោះទៅទិសខាងលិច ធ្វើឱ្យអ្នកស្រុកភូមិជិតឆ្ងាយ ៗក់ផ្អើលមកចូលរួមធ្វើបុណ្យទានច្រើនឡើង១ មិនយូរប៉ុន្មានដោយរោងបុណ្យទីនោះតូចកាន់តែធ្វើឱ្យចង្អៀតទៅៗ អ្នកស្រុកភូមិនិងព្រះសង្ឃបានស្រុះចិត្តគ្នាកសាងព្រះវិហារមួយឡើងជារូបរាង ទីនោះក៏បានក្លាយជាវត្តពេញលក្ខណៈ ហើយប្រសិទ្ធនាមយកនូវភាពអស្ចារ្យ ដែលអាចយាងដើមពោធិ៍មកប្រតិស្ឋានដាំទីនេះ បានថា *វត្តបានការ* ... ក្រោយមកឈ្មោះវត្តនេះ ត្រូវបានប្តូរក្រឡាស់មកនូវត្រឹមឈ្មោះថា ***វត្តបាកាន*** វិញរៀងរហូតមកដល់សព្វថ្ងៃ ។

> *ការដែលឈើចាប់ស្លាប់បាត់នេះ*
> *ជាការតូចបន្ទាប់បន្សំទេ គ្រាន់តែ*
> *ផ្លាស់ប្តូរនេះចោលទៅរករូបថ្មីទៀតប៉ុណ្ណោះ*
> *ឯការដែលធំធ្ងន់មាំមួនគ្រប់ខ្លួនសត្វរាល់គ្នានោះ*
> *គឺព្រះពុទ្ធសាសនាឯនោះ ។*
>
> ព្រះមហាវិមលធម្ម **ថោង**
> ( ទស្សនាវដ្តី មិត្តសាលាបាលីឆ្នាំ ១៩៥១ )

# ចិត្តមេត្តា

ដោយ: ឧកញ៉ា ឧបាសិកា ញ៉ឹក ម៉ុនថា

ព្រះច័ន្ទអាទិត្យរះហើយលិច    មិនអាចគេចផុតពីភាវៈ
ធម្មជាតិមានពិតបានឃើញជាក់    ហើយទាក់ទងគ្នាជាធម្មតា ។
ឯជីវិតយើងក៏ដូចគ្នា    កើតចាស់គ្រាំគ្រាហើយមរណា
ឥតមានព្យាយាមដោយហេតុណា    នឹងថាកុំស្លាប់មិនបានឡើយ ។
បើតង់តែស្លាប់គ្រប់អាត្មា    ត្រូវតាំងចេតនាវៀរឱ្យហើយ
តាំងពីវ័យក្មេងកុំកន្តើយ    បណ្តែតបណ្តោយក្នុងអវិជ្ជា ។
គួរកុំប្រមាទធ្វេសប្រហែស    ក្រេបយកចំណេះគ្រប់វេលា
ទូន្មានខ្លួនល្អឈ្មោះអ្នកជា    មិនដើរពាលាស្រីស្រាល្បែង ។
កើតមកជាមនុស្សរស់ឱ្យថ្លៃ    រស់មានតម្លៃមិនចំបែង
ព្រោះសាងសុចរិតឥតមានក្លែង    បន្ទំគេឯងនាំទោសា ។
ត្រូវអប់រំខ្លួនទូន្មានចិត្ត    ដោយប្រឹងប្រព្រឹត្តក្នុងកិច្ចការ
នាំនូវប្រយោជន៍គ្រប់រូបា    ព្រោះចិត្តមេត្តាប្រោសប្រណី ។
កុំឃើញគេក្រហើយមាក់ងាយ    ពេបជ្រាយនិយាយខុសសំដី
ត្រគោះបោះបោកដោយគ្មានន័យ    ហាស្តីឱ្យរួចតែពីមាត់ ។
ឃើញអ្នកតូចទាបចាស់ជរា    ត្រូវនឹងដល់គ្រាចាស់ដូចគាត់
មានក្រទាបខ្ពស់មិនប្រាកដ    ប្រែប្រួលហើយព្រាត់ប្រាសចោលទៅ ។

ដូច្នេះត្រូវមានចិត្តមេត្តា    ករុណារកគ្នាដូចសំពៅ
ទោះជាក្តោងធំក៏គង់នៅ    ពឹងទៅពឹងមកនឹងសំប៉ាន ។
កាលបើចិត្តល្អចិត្តត្រជាក់    មិនជាប់អន្ទាក់មារសាមាន
ចិត្តមិនមួម៉ៅក្តៅក្នុងប្រាណ    រស់ដោយសុខសាន្តព្រោះធម៌ស្ងប់ ។
ស្ងប់ព្រោះរស់ក្នុងធម៌វិន័យ    ចិត្តចេះប្រណីព្រោះបានធ្លាប់
មេត្តាគេឯងតែមិនជាប់    នឹងគ្រឿងបន្ទប់កាមគុណប្រាំ ។
មច្ឆារស់បានព្រោះគង្គា    ឯយើងរាល់គ្នាព្រោះបានចាំ
រៀនសូត្រចេះដឹងតាមបណ្តាំ    ព្រះពុទ្ធបានផ្តាំឱ្យមេត្តា ។
ទើបបានជួបសុខល្អប្រពៃ    នាំមានសិរីខ្ពស់ឧត្តម
បើចង់បានសុខត្រូវរៀបចំ    ចិត្តដោយខិតខំប្រឹងសិក្សា ។
ទាំងក្នុងពុទ្ធចក្រអាណាចក្រ    ចិត្តមិនប្រឡាក់ដោយតណ្ហា
ព្រោះមានវិជ្ជាមានបញ្ញា    ដោះស្រាយកិច្ចការរួចទុក្ខភ័យ ។
បុគ្គលគ្រប់រូបចង់បានសុខ    ខ្លាចទុក្ខព្រាត់ប្រាសខ្លាចក្សិណក្ស័យ ។
បើខ្លាចដូចគ្នាប្រយោជន៍អ្វី    នឹងផ្តល់ទុក្ខភ័យឱ្យដល់គ្នា ។
ខុសឆ្គងតិចតួចអនុគ្រោះ    កុំខំសាបព្រោះពៀរវេរា
កុំមានគំនុំអភិជ្ឈា    រំពៃទោសគ្នាហើយព្យាបាទ ។
ចិត្តធម៌ចិត្តបុណ្យចិត្តមេត្តា    កុំវាយប្រហារខំសំអាត
កុំមានអវិជ្ជាហើយប្រមាទ    ទុកពេលឱ្យខាតបាបយកបុណ្យ ។
ព្រោះពេលស្លាប់ទៅគ្មានអ្វីតាម    ទ្រព្យធនប៉ុន្មានកុំឱ្យកុន
វល់ប្រឹងរកចាយមិនទាន់    ភ័យស្លន់ព្រោះស្លាប់បានមកដល់ ។
ឆ្លៀតលះធ្វើទានសីលភាវនា    កុំលោភទាមទារចង់បានផល
របូតភ្លេចខ្លួនសាងអកុសល    នាំមានកង្វល់ផលជាទុក្ខ ។

# សុន្ទរកថា

ព្រះតេជព្រះគុណ **បណ្ឌិត អាស៊ីន ញាណិស្សរៈ**
ប្រធានបណ្ឌិតសភា ពុទ្ធសាសនា អន្តរជាតិសិតាគុ (ប្រទេសមីយ៉ាន់ម៉ា)

សន្តិភាពពិភពលោកតាមរយៈសាសនាពិភពលោក គឺជាប្រធានបទបច្ចុប្បន្នសព្វថ្ងៃនេះ ដែលត្រូវបានពុទ្ធិកមគ្គុទ្ទេសក៍ ពិភពលោកស្នើឡើង ក្នុងសន្និសីទកំពូលពុទ្ធសាសនា នាពេលថ្មីៗនេះ ។ ការទូត និងសង្គ្រាម ទាំងពីរវិស័យនេះ ត្រូវបានគេប្រើប្រាស់ជាឧបករណ៍ដឹកនាំរដ្ឋ សម្រាប់ថ្លឹងថ្លែង ដើម្បីបង្កើតបរិយាកាសអន្តរជាតិនៃសន្តិភាព និងសុខដុមភាព ប៉ុន្តែបានសម្រេចជោគជ័យ ដោយមានកំរិតប៉ុណ្ណោះ ។ ប្រយោជន៍ជាសារវន្តរបស់ជាតិ អំណាចនយោបាយ សេចក្តីប្រាថ្នារបស់អ្នកខ្លាំងដើម្បីត្រួតត្រាអ្នកខ្សោយ បានក្លាយជាកម្លាំងដ៏ខ្លាំងក្រៃលែង ដែលត្រូវគេដាក់នៅក្រោមការត្រួតពិនិត្យដ៏មានប្រសិទ្ធភាព ។ សីលធម៌ក្នុងទំនាក់ទំនងអន្តរជាតិត្រូវបានមគ្គុទ្ទេសក៍ ពិភពលោកផ្សព្វផ្សាយ សុំឱ្យប្រតិបត្តិជានិច្ចកាល ប៉ុន្តែពួកគេកម្រអនុវត្តសីលធម៌ទាំងនោះណាស់ ។ ជាលទ្ធផល អត្ថិភាពនៃមនុស្សបានក្លាយជាសភាវៈកាន់តែផុយស្រួយទៅ ហើយពិភពលោក នៅតែមានគ្រោះកំណាច ដោយអំពើហិង្សា ទុរភិក្ស ជំងឺ ការបំផ្លិចបំផ្លាញបរិស្ថាន និងអំពើភេរវកម្មនៅឡើយ ។ ការខិតខំថ្មីៗត្រូវបានគេធ្វើឡើង ដើម្បីត្រឡប់ទៅរកសាសនា ជាប្រវត្តិសាស្ត្រពិភពលោក ដែលបានដាក់ចុះ ព្រះធម៌គ្មានកាលកំណត់ (អកាលិកធម៌) នឹងផ្តល់នូវការដោះស្រាយដល់បញ្ហាពិភពលោកជាទូទៅ ។

មិនបាច់សង្ស័យឡើយ សាសនា និងអ្នកដឹកនាំសាសនា មានឥទ្ធិពលយ៉ាងធំមហិមាលើប្រជាជន ហើយពួកគេថែមទាំងមានបណ្តាញការងារយ៉ាងខ្លាំង ទូទាំងពិភពលោកផង ។ បើអ្នកដឹកនាំសាសនា ( ទាំងនោះ ) អាចធ្វើឱ្យមនុស្សម្នាក់ៗមានសេចក្តីស្ងប់ និងមានសេចក្តីសប្បុរស នោះសាសនាអាចបង្កើតសង្គមមួយដែលមានសេចក្តីស្ងប់ និងមានសុខដុមភាព នៅថ្នាក់ជាតិសងវិញដែរ ។ ពេលណាសន្តិភាពត្រូវសម្រេចបាន នៅថ្នាក់ជាតិហើយ វានឹងនាំទៅដល់ការយោគយល់គ្នាទៅវិញទៅមកមិត្តភាពរវាងជាតិ និងជាតិ និងសន្តិភាពពិភពលោក ដោយពិត ។ ព្រោះហេតុនោះ ចំណុចចាប់ផ្តើមសម្រាប់សន្តិភាពពិភពលោក គឺបុគ្គលម្នាក់ៗ ដែលត្រូវប្រឹងប្រែងធ្វើឱ្យមានសន្តិភាពខាងក្នុង (សន្តិភាពផ្លូវចិត្ត) និងសេចក្តីស្ងប់ខាងក្រៅ ដោយមធ្យោបាយប្រតិបត្តិខាងផ្លូវចិត្ត ដូចគម្ពីរធម្មបទបានថែងថា "*ការទូន្មានចិត្តឱ្យបានល្អ គឺជាការលំបាកគ្រប់គ្រងក្រៃលែង ពីព្រោះចិត្តជាសភាវៈប្រែប្រួលជានិច្ច និងមានលក្ខណៈរប៉ិលរប៉ូច ។ ចិត្តដែលបុគ្គលទូន្មានបានហើយ គឺជាចិត្តប្រសើរ*។ ខ្សែបន្ទាត់នៃការត្រិះរិះពិចារណានេះ គឺដូចគ្នានឹងពាក្យស្លោករបស់អង្គការ អ៊ុយណេស្កូ (UNESCO) ដែលបានថែងថា "សង្គ្រាមផ្តើមចេញពីក្នុងចិត្តរបស់មនុស្ស ហើយកិច្ចការពារសន្តិភាព ក៏ត្រូវកសាងឡើងក្នុងចិត្តមនុស្ស ។

ក្នុងសម័យកាលក្រោយសង្គ្រាម សន្តិភាព និងស្ថិរភាពពិភពលោក ត្រូវបានរំខានយ៉ាងខ្លាំង ដោយភាពតានតឹងខាងសាសនា ។ វិបត្តិក្នុងមជ្ឈិមបូព៌ា និងអាស៊ី ខាងត្បូង អាចនឹងដោះស្រាយបានល្អប្រសើរ បើគេអាចរកឃើញមាគ៌ា និងមធ្យោបាយសម្រាប់ធ្វើឱ្យធូរស្រាយនូវភាពតានតឹងខាងសាសនា ។ កាលណាវិបត្តិបន្តអូសបន្លាយកាន់តែយូរ អរិភាពក៏កាន់តែកើនឡើងខ្លាំងដែរ ។ ប្រជាជនពាក់ព័ន្ធត្រូវយល់ថា អរិភាពចិញ្ចឹមតែអរិភាពប៉ុណ្ណោះ ហើយមានតែស្មារតីនៃខន្តីធម៌

ចំពោះអត្ថិភាព (ជីវិត) របស់មនុស្សដទៃប៉ុណ្ណោះ ទើបអាចរកឃើញដំណោះស្រាយចំពោះបញ្ហាបាន ។ ដូចព្រះសម្ពុទ្ធបានសម្តែងហើយថា "អ្នកច្រូតកាត់នូវអ្វីដែលអ្នកបានសាបព្រោះ" ។ ជាក់ស្តែង ដោយហេតុថា ប្រជាជនស្ថិតក្នុងវិបត្តិបានសាបព្រោះនូវអវិភាពជាជំនួស មេត្តា គេកំពុងទទួលផលដ៏ជូរចត់នៃសង្គ្រាម អំពើហិង្សា និងអំពើឃោរឃៅ ។ មានតែមនុស្សស្លូតត្រង់ប៉ុណ្ណោះ ដែលបានទទួលរងទុក្ខយ៉ាងច្រើនឥតគណនា ។ ដើម្បីបញ្ឈប់ការបង្ហូរឈាមនេះ ល្មមដល់ពេលវេលាហើយដែលសាសនាត្រូវបានគេហៅ រកឱ្យជួយបញ្ចុះបញ្ចូលមនុស្សអ្នកទទួលខុសត្រូវ ឱ្យភ្ញាក់រលឹក ហើយយល់ឱ្យច្បាស់នូវភាពគ្មានខ្លឹមសារ នៃពិធីចាស់គំរិលទាំងនោះ ។ម្យ៉ាងទៀត គម្ពីរធម្មបទបានអធិប្បាយថា "អ្នកឈ្នះរមែងបង្កើតសត្រូវ អ្នកចាញ់រមែងដេកកើតទុក្ខ សន្តបុគ្គល ដែលមិនគិតពីឈ្នះ ឬចាញ់ រមែងរស់នៅក្នុងសន្តិភាព" ។ អ្នកដឹកនាំសាសនា អង្គការសហប្រជាជាតិ និងពពួកមនុស្ស ដែលមានទស្សនៈដូចគ្នា ស្តីពីសន្តិភាពពិភពលោក គប្បីរួបរួមគ្នាជាធ្លុងមួយ ហើយអប់រំសាធារណមតិ ដែលអាចដាក់ការគាបសង្កត់លើអ្នកដឹកនាំពិភពលោក ឱ្យបំពេញសកម្មភាពកាន់តែប្រកបដោយវិចារណញ្ញាណច្រើនឡើង ។ សន្និសីទកំពូលខាងសាសនា ដោយមានសាសនា នា១ប្រភេទនេះ គប្បីធ្វើឱ្យបានទៀងទាត់ ដើម្បីរំលឹកពិភពលោកអំពីគ្រោះមហន្តរាយជិត កើតមានធ្លាក់មកលើមនុស្សជាតិ ។ ដើម្បីគោលបំណងនោះ យើងត្រូវការឆន្ទៈសមូហភាព ការដឹកនាំដ៏ក្លាហាន និងការគាំទ្រ ដ៏ធំទូលាយពីពិភពលោក ។ កាលណាយើងអាចបញ្ជូនសារនៃខន្តីធម៌ សន្តិភាព និងករុណាធម៌ ទៅក្នុងពិភពលោកកាន់តែច្រើន យើងអាចនឹងធ្វើឱ្យធូរស្រាយនូវភាពតានតឹងខាងសាសនា កាន់តែច្រើនដែរ ។

ប្រៀបធៀបនិងសាសនាផ្សេង១ទៀត ពុទ្ធសាសនាមានកម្លាំងខ្លាំងក្នុងការថែរក្សាលទ្ធិ ប៉ុន្តែមានភាពទន់ខ្សោយក្នុងការឃោសនាផ្សព្វផ្សាយព្រះធម៌ (សិក្ខាបទ)

របស់ព្រះសម្ពុទ្ធ ។ តាំងពីព្រះពុទ្ធជាម្ចាស់បរិនិព្វានទៅ សង្គាយនាខាងពុទ្ធសាសនា ដ៏ធំចំនួន ៦ លើក ត្រូវបានប្រារព្ធធ្វើឡើង ៣ ដង ក្នុងប្រទេស ឥណ្ឌា ១ ដង ក្នុងប្រទេសសិរីលង្កា និង ២ ដងក្នុងប្រទេសមីយ៉ាន់ម៉ា ដើម្បីថែរក្សា និងផ្ទៀងផ្ទាត់ព្រះត្រៃបិដកឱ្យបានត្រឹមត្រូវ ។ ព្រះធម៌របស់ព្រះសម្ពុទ្ធត្រូវបានចម្លង ហើយថែរក្សាតាមមធ្យោបាយជាច្រើនជាអាទិ៍ ការទន្ទេញចាំមាត់ ចារក្នុងស្លឹករឹត ឆ្លាក់លើផ្ទាំងថ្ម និងបោះពុម្ពជាសៀវភៅ ។ ការថែរក្សាព្រះរាជសារ (ព្រះធម៌) របស់ព្រះពុទ្ធតាមរយៈបន្តផ្ទាល់មាត់ មានសារសំខាន់នៅក្នុងប្រវត្តិសាស្ត្រ នៃពុទ្ធសាសនា ។ នៅឯសង្គាយនាពុទ្ធសាសនា ទាំងបីលើក ក្នុងប្រទេសឥណ្ឌា ព្រះត្រៃបិដកត្រូវបានផ្ទៀងផ្ទាត់ និងពិនិត្យឡើងវិញ ដោយការសូធ្យផ្ទាល់មាត់ ។ ព្រះភិក្ខុជាអធិបតីទាំងឡាយ គឺជាតិបិដកធរ ហើយសុទ្ធតែជាព្រះអរហន្ត ។ នៅបច្ចុប្បន្នកាលនេះ ប្រទេសមីយ៉ាន់ម៉ាមានភិក្ខុសង្ឃជាតិបិដកធរ (អ្នកចេះចាំព្រះត្រៃបិដកស្ទាត់ជំនាញ) ៩ អង្គ ដែលចេះចាំសូធ្យរត់មាត់ នូវគម្ពីរព្រះត្រៃបិដក ចំនួន ៨០២៦ ទំព័រ ។ ម្យ៉ាងវិញទៀតតាមប្រវត្តិសាស្ត្រ មានកម្លាំងសាសនទូតពុទ្ធសាសនា ដែលបានចាត់តាំងឡើង ហើយឋិតថេរជាប់លាប់ ទាំងថ្នាក់ជាតិ និងទាំងថ្នាក់អន្តរជាតិតិចតួចណាស់ នៅក្នុងប្រទេសកាន់ព្រះពុទ្ធសាសនា ។ សូម្បីនៅក្នុងរង្វង់ការខិតខំរបស់សាសនទូត នៅក្នុងតំបន់ព្រៃប្រទល់ ក៏ពុំអាចទាក់ទាញកុលសម្ព័ន្ធភ្នំ ឱ្យចូលក្នុងក្រុមពុទ្ធសាសនិកបានដែរ ។ សាសនាផ្សេងៗទៀត រត់មុខដាច់ឆ្ងាយពីពុទ្ធសាសនា ក្នុងការខិតខំផ្នែកសាសនទូត ហើយដាច់ឆ្ងាយលើសលប់ក្នុងវិស័យសម្ភារៈ ប្រាក់កាស និងប្រភពធនធានផ្សេងៗទៀត ។ ក្នុងប្រទេសមីយ៉ាន់ម៉ា ដើម្បីធ្វើឱ្យការខិតខំរបស់សាសនទូតទាំងខាងក្នុង និងទាំងខាងក្រៅប្រទេស បានល្អប្រសើរ គេបានបង្កើតនាយកដ្ឋានថ្មីមួយ ក្នុងឆ្នាំ១៩៩១ សម្រាប់ការលើកស្ទួយ និងការឃោសនាផ្សព្វផ្សាយសាសនា ។

មជ្ឈមណ្ឌលសាសនទូតជាច្រើន ត្រូវបានប្រើក្នុងតំបន់ជាយដែន ហើយចំនួនភិក្ខុសង្ឃ និងឧបាសក ជាសាសនទូត ក៏កើនឡើងកំពុងបំរើការនៅទីនោះ ។ ជាលទ្ធផលបរិមាណដ៏ធំមួយ នៃជនជាតិក្នុងតំបន់ព្រំដែន បានត្រឡប់មកគោរពរាប់អានព្រះពុទ្ធសាសនា ។

ក្នុងតំបន់ជ្រលងភ្នំ និងតំបន់វាលរាប ដែលពុទ្ធសាសនា បានរីកដុះដាលដល់ទីនោះ ជាច្រើនសតវត្សមកហើយ ក៏គេកំពុងខិតខំធ្វើឱ្យពុទ្ធសាសនាបានរឹងមាំដែរ ។ ជាមួយនឹងភិក្ខុសង្ឃជិត ៥០០.០០០ អង្គ និងសីលវតីប្រមាណ ៣៥០០០រូប ស្មោះកម្ម ការលើកស្ទួយ និងការឃោសនាផ្សព្វផ្សាយពុទ្ធសាសនា កំពុងប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ។ ការប្រឡងសូធ្យគម្ពីរសាសនា តាមកំរិតសិក្សានានា បានប្រព្រឹត្តទៅរៀងរាល់ឆ្នាំ ហើយសិស្សដែលបានប្រឡងជាប់ ត្រូវបានគេឧបត្ថម្ភជាអង្ករ និងវត្ថុចាំបាច់ផ្សេងៗ ។ ឋានន្តរសក្តិ នៃសាសនា ត្រូវបានបំពាក់ប្រគេនដល់ភិក្ខុសង្ឃដែលលេចធ្លោក្នុងការសិក្សាគម្ពីរសាសនា សមាធិកម្មដ្ឋាន និងការងារសាសនទូត ។ វត្តអារាមថ្មីកំពុងត្រូវបានសាងសង់ ហើយវត្តចាស់ៗ ក៏កំពុងជួសជុលកែលំអ ដោយការឧបត្ថម្ភពីរដ្ឋ និងឧបាសក ឧបាសិកា ( ពុទ្ធបរិស័ទ ) ។ នាយកដ្ឋានកិច្ចការសាសនាកំពុងបោះពុម្ពផ្សព្វផ្សាយ ព្រះត្រៃបិដក និងគម្ពីរធម៌ផ្សេងៗទៀត ដល់ភិក្ខុសង្ឃ ក៏ដូចជាគ្រហស្ថ ឬឃរាវាសទូទៅ ។ ដោយបានសម្រេចការឯកភាពគ្នាគ្រប់និកាយ គណៈកម្មាធិការ សង្ឃមហានាយករដ្ឋ (Srate Sangha Mahanayaka Commiltee) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨០ ។ អង្គការចាត់តាំងសង្ឃ (Sang ha Organisation) គ្រប់លំដាប់ថ្នាក់ពីតំបន់ភូមិស្រុក រហូតដល់ថ្នាក់រដ្ឋ ត្រូវបានបង្កើតឡើង ដើម្បីទទួលបន្ទុកកិច្ចការទាំងអស់ ដែលជាប់ទាក់ទង នឹងការងារខាងភិក្ខុសង្ឃ ។

ឯការឃោសនាផ្សព្វផ្សាយព្រះពុទ្ធសាសនា នៅក្រៅប្រទេសមានភិក្ខុសង្ឃមីយ៉ាន់ម៉ាជាច្រើនអង្គ បានចេញទៅសម្តែងធម៌ទេសនានៅក្រៅប្រទេស ព្រមទាំងបង្រៀនសមាធិកម្មដ្ឋាន តាមបែបពុទ្ធសាសនាផង ។ មានវត្តអារាមព្រះពុទ្ធសាសនាកាន់តែច្រើនត្រូវបានស្ថាបនា នៅជុំវិញពិភពលោក ហើយមណ្ឌលសមាធិ ក៏មានទូទាំងពិភពលោក រួមមានប្រទេស ម៉ិចស៊ិក ប្រទេសហ្សាម៉ៃអ៊ិក និងអាហ្វ្រិកខាងត្បូង ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ក្នុងប្រវត្តិការងារសាសនទូត គឺការបើកសកលវិទ្យាល័យសាសនទូត ពុទ្ធសាសនាថេរវាទអន្តរជាតិ (International Thera vada Buddhist Missionary University) នៅថ្ងៃទី ៩ ខែធ្នូឆ្នាំ ១៩៩៨ ។ លក្ខណៈពិសេសឯកនៃសាកលវិទ្យាល័យ គឺថា ជាសាកលវិទ្យាល័យសេរី គ្មានបង់ថ្លៃស្នាក់នៅ និងអាហារ ។ កម្មវត្ថុរបស់សកលវិទ្យាល័យនេះ គឺឃោសនាផ្សព្វផ្សាយពុទ្ធសាសនាថេរវាទយ៉ាងសុទ្ធសាធ ទូទាំងពិភពលោក ព្រមទាំងបង្រៀនសាសនទូតផង ។ បន្ទាប់ពីការសិក្សាពុទ្ធសាសនាថេរវាទ ទាំងទ្រឹស្តី និងទាំងការអនុវត្តន៏ ជាក់ស្តែង សិស្សបរទេសទាំងឡាយ អាចបម្រើការងារសាសនទូត ក្នុងប្រទេសរបស់ខ្លួនគេផ្ទាល់ ។ និស្សិតទាំងឡាយ ដែលត្រូវទទួលឱ្យសិក្សានៅសកលវិទ្យាល័យនេះ ពុំបានគិតសញ្ជាតិសាសនា និងភេទឡើយ ។ នៅបច្ចុប្បន្ននេះ មាននិស្សិតបរទេស ៩០ រូប មកពីប្រទេសចំនួនដប់ប្រាំពីរ កំពុងសិក្សានៅសកលវិទ្យាល័យនេះ ។ និស្សិតទាំងឡាយ ដែលបានប្រឡងចេញពីសកលវិទ្យាល័យសាសនទូត ពុទ្ធសាសនាថេរវាទអន្តរជាតិ ឥឡូវកំពុងចាប់បំពេញការងារសាសនទូត ទូទាំងពិភពលោក ។ យើងបានលើកសំណើរជាញឹកញាប់ នៅឯសន្និសីទពុទ្ធសាសនាអន្តរជាតិ (International Buddhist Conferences) ដើម្បីបង្កើតស្ថានីយវិទ្យុទូរទស្សន៍ផ្សព្វផ្សាយមួយ នៅពុទ្ធគយា ឬនៅកន្លែងផ្សេងទៀតសមស្រប ដែលអាចផ្សាយចេញព្រះធម៌របស់

ព្រះពុទ្ធ និងសកម្មភាពប្រតិបត្តិជុំវិញពិភពលោក ។ ដោយហេតុថា គំរោងត្រូវចាយវាយប្រាក់កាស់អស់យ៉ាងច្រើន វាជាការចាំបាច់ត្រូវមានការឧបត្ថម្ភជាលក្ខណៈអន្តរជាតិ ។ ការដាក់បញ្ចូលធម៌ទេសនាពុទ្ធសាសនា អត្ថបទ និងពត៌មានសំខាន់ៗ ដែលជាប់ទាក់ទងនឹងពុទ្ធសាសនា លើបណ្តាញ Internet នឹងផ្តល់នូវកម្លាំងថាមពលផ្សព្វផ្សាយពុទ្ធសាសនា នាពេលអនាគត បាននិវត្តប្រែប្រួលរីកចំរើនយ៉ាងដាច់ខាត ។

តាំងពីការឃោសនាផ្សព្វផ្សាយព្រះពុទ្ធសាសនា ត្រូវបានផ្សារភ្ជាប់ជិតស្និទ្ធនឹងពុទ្ធិកសិក្សា ខ្ញុំព្រះករុណាអាត្មាភាពសូមអនុញ្ញាត ទាញការចាប់អារម្មណ៍របស់ព្រះតេជព្រះគុណ អស់លោក ចំពោះការខិតខំរបស់យើងខ្ញុំ ព្រះករុណា អាត្មាភាព ដើម្បីបង្កើនពុទ្ធិកសិក្សាក្នុងប្រទេស ។ ដើម្បីអប់រំភិក្ខុសង្ឃក្នុងគម្ពីរព្រះត្រៃបិដក យើងខ្ញុំព្រះករុណា អាត្មាភាព បានបង្កើតសកលវិទ្យាល័យបរិយត្តិសាសនា (Pariyatti sasana ) ពីររួចជាស្រេច មួយនៅក្រុងយ៉ាងហ្គូន និងមួយទៀតនៅក្រុងមណ្ឌលេ ដោយសកលវិទ្យាល័យនីមួយៗ មាននិស្សិតជាភិក្ខុសង្ឃ ចំនួន ៥០០ អង្គ។ បន្ទាប់ពីការប្រឡងចេញ ភិក្ខុសង្ឃទាំងនេះ បានចេះចាំស្ទាត់ព្រះត្រៃបិដក និងយល់ដឹងច្បាស់នូវការងារវិស័យសាសនទូត ។ នៅមានមជ្ឈមណ្ឌលសិក្សា ពុទ្ធសាសនាមួយទៀតគឺបណ្ឌិតសភាពុទ្ធសាសនាពិភពលោកសិតាគុ (Sitagu)នៅតំបន់សាគាំង (Sagaing) មីយ៉ាន់ម៉ាខាងលើ មានទីធ្លាដ៏ល្អ ដោយអាគារ ២៨ ខ្នង សង់តាមរចនាបថស្ថាបត្យកម្ម ម្យ៉ាន់ម៉ា ។ សមណនិស្សិតជាង ១០០ អង្គ កំពុងសិក្សាពុទ្ធធម៌នៅកំរិតមហាវិទ្យាល័យ និងក្រោមមហាវិទ្យាល័យ ។ អ្នកមានប្រាជ្ញាពុទ្ធសាសនា មកពីប្រទេសឯទៀតៗ ក៏កំពុងធ្វើការស្រាវជ្រាវក្រោយមហាវិទ្យាល័យ ក្រោមការដឹកនាំរបស់សិតាគុ សាយ៉ាដាវ និងសមាជិកមហាវិទ្យាល័យ មានចំណេះដឹងខ្ពស់របស់លោក ។ ហើយក៏មានវត្ត និងមហាវិទ្យាល័យ ជាង ១០០០ កន្លែងផងដែរ កំពុង

បង្រៀនព្រះត្រៃបិដក ។ ចំពោះប្រជាជន រដ្ឋាភិបាល និងគណៈកម្មាធិការសង្ឃមហានាយករដ្ឋ បានខិតខំយ៉ាងស្វិតស្វាញ ដើម្បីបញ្ចូលតម្លៃនៃព្រះពុទ្ធសាសនា ក្នុងប្រព័ន្ធអប់រំសម័យទំនើប ។ ការសិក្សាពីថ្នាក់បឋមសិក្សា ដល់ថ្នាក់សកលវិទ្យាល័យ ព្រះធម៌របស់ព្រះពុទ្ធ (ពុទ្ធធម៌) គឺជាផ្នែកមួយនៃកម្មវិធីសិក្សា ។ ការអប់រំសម័យទំនើប ពុំមែនគ្រាន់តែអភិវឌ្ឍន៍ប្រជាជាតិមួយយ៉ាងសាមញ្ញប៉ុណ្ណោះទេ ថែមទាំងមានទំហំសីលធម៌ សម្រាប់អប់រំប្រជាជន ឱ្យបានជាពលរដ្ឋល្អ តាមគោលការណ៍សីលធម៌ចរិយាធម៌ផង ។ ការអប់រំវិទ្យាសាស្ត្រ ត្រូវតែជាការអប់រំឱ្យទៅជាមនុស្សស្រឡាញ់សាសនា និងវប្បធម៌ ។

ក្នុងប្រទេសមីយ៉ាន់ម៉ា កុមារទាំងឡាយនោះ ដែលពេញចិត្តនិងការអប់រំពុទ្ធសាសនា ខ្លាំងក្លាអាចចូលទៅសាលាវត្ត ដែលសាលាភាគច្រើនត្រូវបានភិក្ខុសង្ឃគ្រប់គ្រង ។ ក្រឡេកមើលទៅក្នុងអតីតកាលក្នុងរជ្ជកាល ប្រទេសមីយ៉ាន់ម៉ា មានមហាក្សត្រគ្រប់គ្រង សាលារៀនវត្តបានទទួលបរាជ័យបណ្ដោះអាសន្ន ក្នុងសម័យអាណានិគម ប៉ុន្តែសាលាវត្តទាំងនោះ ត្រូវបានរស់ឡើងវិញក្រោយបានឯករាជ្យ ។ ពីឆ្នាំ ១៩៨៨ សាលាវត្ត ត្រូវបានធ្វើឱ្យមានការរីកចម្រើនយ៉ាងប្រសើរ ដោយមានកុមារជិត ១៥០.០០០ នាក់ រៀនក្នុងសាលា វត្តចំនួន ២២៨ ។ សិស្សសាលាទាំងឡាយ ក៏យកចិត្តទុកដាក់រៀនមុខវិជ្ជាអក្សរសាស្ត្រពុទ្ធសាសនាដែរ រយៈពេលវិស្សមកាល រដូវក្ដៅ ក្រោមការទំនុកបំរុងរបស់គណៈកម្មាធិការសង្ឃមហានាយករដ្ឋ និងសមាគមសាមគ្គី និងសមាគមអភិវឌ្ឍន៍ ។ នៅក្រៅថ្នាក់រៀន មាតាបិតាបានបង្រៀនពីតម្លៃពុទ្ធសាសនា ដល់កូនៗរបស់គេ នៅផ្ទះ និងនៅវត្ត ។ គាថាពុទ្ធសាសនា ត្រូវបានគេសូធ្យ ហើយអក្សរសាស្ត្រពុទ្ធសាសនា ត្រូវបានសាធារណជនអានយ៉ាងទូលំទូលាយ ។ ប្រធានបទដកស្រង់ពីជាតក ពីជីវប្រវត្តិរបស់ព្រះពុទ្ធ ត្រូវ

បានគេតាក់តែងជាឆាកសម្តែងសិល្បៈ ។ ពិធីបុណ្យ និងពិធីនានាតាមពុទ្ធសាសនា បានពង្រឹងតម្លៃពុទ្ធសាសនា ដែលបានក្លាយជាមាគ៌ា ដឹកនាំជីវភាពប្រចាំថ្ងៃ ។ គ្មានអ្វីគួរឱ្យសង្ស័យទេ ទោះបីជាការអប់រំសម័យទំនើប ជាឧបករណ៍មួយ សម្រាប់ឱ្យសង្គមផ្លាស់ប្តូរទៅកាន់ការអភិវឌ្ឍន៍ ក៏តម្លៃនៃពុទ្ធសាសនា នៅតែត្រូវបានគេថែរក្សា និងស្រឡាញ់តទៅវែងឆ្ងាយទៀត ។

ជីវិតមនុស្សតាមធម្មតា គឺជាសេចក្តីទោមនស្ស ជាទុក្ខ និងមិនទៀងទាត់ ដែលបណ្តាលឱ្យឈឺចាប់ និងរងទុក្ខលំបាក ។ ចិត្ត គឺជាសភាវៈឃ្លេងឃ្លោង រសាប់រសល់ ហើយព្រួយកង្វល់ចិត្ត ។ ដើម្បីអប់រំទូន្មានចិត្តឱ្យល្អ គឺជាការលំបាកស្មុគស្មាញបំផុតក្នុងជីវិត ។ សមាធិកម្មដ្ឋានបានជួយមនុស្ស ឱ្យអប់រំចិត្តឱ្យមានវិន័យ ព្រមទាំងឱ្យបានឃើញវត្ថុអ្វី១ទាំងអស់តាមសច្ចភាពជាក់ស្តែង ។ ក្នុងពិភពលោកដែលមានសភាពតានតឹង អារម្មណ៍ធ្ងន់ធ្ងរនេះ ការប្រតិបត្តិសមាធិកម្មដ្ឋាន អាចជួយសម្រាលភាពតានតឹងទាំងឡាយ យ៉ាងហោចបាននាំមកនូវអត្ថប្រយោជន៍ នៃការសម្រាកលំហែ ។ នៅកំរិតមួយខ្ពស់ជាង ដោយការប្រតិបត្តិវិបស្សនាកម្មដ្ឋាន គេអាចរកឃើញថា តើកាយ និងចិត្ត ត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច ឱ្យទៅជាតួអង្គកាយ និងចេតសិក នៅទីបំផុត ។ កាលណាគេបានពិនិត្យពិចារណាពីហេតុ-ផល នៃការកើតឡើង ហើយរលាយរលត់ទៅវិញជានិរន្តរ៍ នៃធាតុភូតកាយ និងចេតសិក គេនឹងយល់ច្បាស់ដោយឥតសង្ស័យ នូវហេតុពិតទាំងឡាយ និងចរិតនៃធាតុភូត ។ តាមទស្សនៈរបស់ព្រះពុទ្ធសាសនា ការចាប់យកបានបញ្ញា គឺមានលក្ខណៈសារវន្តណាស់ ដើម្បីធ្វើឱ្យសន្តិភាព និងសុភមង្គលបានល្អប្រសើរ ។ មីយ៉ាន់ម៉ា គឺជាស្ថានសួគ៌សម្រាប់មនុស្សទាំងឡាយនោះ ដែលស្វែងរកសន្តិភាព និងសុភមង្គល តាមរយៈសាលាសមាធិកម្មដ្ឋានផ្សេង១ និងគ្រូអាចារ្យសមាធិរបស់សាលាទាំងនោះ ។ អ្នក

ណាក៏អាចគ្រេបបទពិសោធន៍កាត់ថ្លៃមិនបាន នៃប្រពៃណីសមាធិកម្មដ្ឋាន របស់មីយ៉ាន់ម៉ា ដើម្បីសន្តិភាព និងសុភមង្គលដែរ ។ ការបន្សាត់បង់មន្ទិលសៅហ្មងខាងផ្លូវចិត្ត ដោយប្រមូលផ្តុំចិត្ត គឺអ្នកដែលបានហ្វឹកហាត់សមាធិកម្មដ្ឋាន រមែងបានសម្រេចសន្តិភាព និងសេចក្តីស្ងប់ខាងក្នុង ធ្វើឱ្យខ្លួនគេជាមនុស្សមានការអត់ឱន ត្រាប្រណី និងក្តីមេត្តាករុណា ។ បើបច្ចេកទេសសមាធិកម្មដ្ឋាននេះ ត្រូវបានព្រះពុទ្ធជាម្ចាស់រកឃើញជាង ២០០០ ឆ្នាំមកហើយ ជាគុណធម៌មានស្រាប់ សម្រាប់ពិភពលោក គុណធម៌នេះមានប្រសិទ្ធភាពព្យាបាល និងផ្សះឱ្យជានៅក្នុងពិភពលោកដ៏ឃោរឃៅ និងគ្រោះថ្នាក់នេះ ។

ដើម្បីបញ្ចប់ គណៈប្រតិភូមីយ៉ាន់ម៉ារបស់យើងខ្ញុំព្រះករុណា-អាត្មាភាព ដែលតាំងភិក្ខុសង្ឃ ៥០០០០០ អង្គ ក្នុងប្រទេសមីយ៉ាន់ម៉ា និងគណៈកម្មាធិការសង្ឃមហានាយករដ្ឋ សូមថ្លែងអំណរគុណដ៏ស្មោះស ចំពោះការផ្តល់ដល់យើងខ្ញុំព្រះករុណា-អាត្មាភាព នូវឱកាសមួយ ដើម្បីបង្ហាញនូវការខិតខំរបស់យើងខ្ញុំព្រះករុណាអាត្មាភាព ដើម្បីបានបរិសុទ្ធភាព និរន្តរភាព និងការលើកស្ទួយដល់ពុទ្ធសាសនាថេរវាទ ក្នុងប្រទេសមីយ៉ាន់ម៉ា ។ យើងខ្ញុំព្រះករុណា-អាត្មាភាព សូមស្នើដោយទទួចឱ្យពុទ្ធសាសនិកជនជាធម្មមិត្តរបស់យើងខិតខំថែមទៀត ក្នុងវិស័យថែរក្សា និង ឃោសនាផ្សព្វផ្សាយពុទ្ធសាសនា សន្តិភាពពិភពលោក ការអប់រំពុទ្ធសាសនា និងភាវនាពុទ្ធសាសនា ។ យើងខ្ញុំព្រះករុណា-អាត្មាភាព ទទួចសុំឱ្យធម្មមិត្តពុទ្ធសាសនិកទាំងឡាយរបស់យើង មេត្តាពិចារណាសេចក្តីស្នើ របស់យើងខ្ញុំព្រះករុណា - អាត្មាភាព សម្រាប់បង្កើតស្ថានីយផ្សាយសម្លេង (រូបភាព) ពុទ្ធសាសនាពិភពលោក និងសកលវិទ្យាល័យពុទ្ធសាសនាពិភពលោកមួយ ។ យើងខ្ញុំព្រះករុណា-អាត្មាភាព សង្ឃឹមថា អាចជំនះលើឧបសគ្គទាំងឡាយទាំងពួងបាន ដើម្បីឯកភាពនិងការថែរក្សា

ពុទ្ធសាសនាក្នុងពិភពលោក ដោយសារការប្តេជ្ញាចិត្ត ភក្តីភាព និងការឧទ្ទិសរបស់យើង ។

ជាថ្មីម្តងទៀត យើងខ្ញុំព្រះករុណា-អាត្មាភាព សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះគណៈកម្មាធិការរៀបចំ និងរដ្ឋាភិបាលនៃប្រទេសកម្ពុជា ព្រមទាំងប្រជាជន ចំពោះបដិសណ្ឋារកិច្ច និងសេចក្តីប្រោសប្រណីរបស់ពួកគេ ។ យើងខ្ញុំ ព្រះករុណា-អាត្មាភាព សូមថ្វាយព្រះពរព្រះករុណាព្រះបាទ នរោត្តម សីហនុ សូមព្រះអង្គមានព្រះជន្មាយុយឺនយូរ ព្រះសុខភាពល្អ ព្រះសុភមង្គល ។

សូមព្រះធម៌ ឈ្នះនៅក្នុងបរិសុទ្ធភាព ដ៏ឥតសៅហ្មងរបស់ខ្លួនក្នុងពិភពលោក ។

*បើមានតែរូបច្រើនពុំមានភ្នែក*
*បុគ្គលពុំអាចនឹងរមិលមើល*
*ឱ្យស្គាល់រូបជាក់ច្បាស់បាន ។*

សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា
វជិរប្បញ្ញោ **ឈឹ ឯម**

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សង្ឃប្រកាស

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី ១២ បានប្រារព្ធពិធីបើកនៅសាលសន្និសីទចតុមុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចជា ស៊ីម ប្រមុខរដ្ឋស្តីទី ហើយបានដំណើរការអស់ថេរវេលា ៣ ថ្ងៃ ពីថ្ងៃប្រហស្បតិ៍ ៧ រោច ដល់ថ្ងៃសៅរ៍ ៩ រោច ខែពិសាខ ឆ្នាំ មមែបញ្ចស័ក ពុទ្ធសករាជ ២៥៤៧ ត្រូវនឹងថ្ងៃទី ២២ ដល់ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៣ នៅក្រសួងធម្មការ និងសាសនា ក្រោមព្រះរាជាធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ដោយមានមន្ត្រីសង្ឃចំនួន ៧៥ អង្គ និងមន្ត្រីធម្មការ និងសាសនា ចំនួន ៤៥ រូប ចូលរួមជាសមាជិក ។ ដោយយោងតាមប្រសាសន៍របស់សម្តេចប្រមុខរដ្ឋស្តីទី និងស្មារតីរបស់អង្គមហាសន្និបាត ដែលបានពិភាក្សាប្តូរយោបល់គ្នា អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃនេះ បានចេញសង្ឃប្រកាសដែលមានខ្លឹមសារដូចខាងក្រោម :

១- បន្តការពង្រឹងគុណភាពក្នុងការដឹកនាំ និងគ្រប់គ្រងវត្តអារាម ព្រមទាំងភិក្ខុសាមណេរ ឱ្យបានរៀបរយតាមធម៌វិន័យ និងរក្សាបាននូវតម្លៃខាងពុទ្ធសាសនា សិល្បៈ វប្បធម៌ និងស្ថាបត្យកម្មខ្មែរពិតៗ ។

២- ធ្វើឱ្យវត្តអារាមនីមួយៗ ទៅជាមជ្ឈមណ្ឌលផ្តល់ចំណេះដឹង ផ្លូវលោក ផ្លូវធម៌ អប់រំផ្លូវចិត្ត ចៀសវាងអំពើហិង្សា ជាពិសេសជាមជ្ឈមណ្ឌលរក្សានូវទំនៀមទម្លាប់ជាតិ ប្រពៃណីព្រះពុទ្ធសាសនា សៀវភៅធម៌ ក្បួនច្បាប់ វប្បធម៌យ៉ាងខ្ជាប់

ខ្លួន ដោយបង្កើត ឱ្យមានបណ្ណាល័យរក្សាទុកនូវក្បួនច្បាប់សៀវភៅគ្រប់មុខ វិជ្ជា សម្រាប់ប្រយោជន៍ក្នុងការស្រាវជ្រាវនៃមហាជនគ្រប់ស្រទាប់ មានសាលាពុទ្ធិក សង្គហកុមារ ព្រមទាំងធ្វើឱ្យទៅជាបូជនីយដ្ឋាន និងរមណីដ្ឋានទេសចរណ៍សំខាន់ៗ ប្រកបដោយរុក្ខជាតិ ធំ-តូច ដែលមានប្រយោជន៍ដល់បរិស្ថានធម្មជាតិផង និងជា សេចក្តីត្រូវការប្រចាំថ្ងៃផង ។

៣- ត្រូវរក្សារចនាបទត្រឹមត្រូវតាមលក្ខណៈខ្មែរ ហើយត្រូវមានប្លង់ និងគម្រោងត្រឹមត្រូវឆ្លងកាត់ការឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចំពោះការ កសាងសំណង់សំខាន់ៗរបស់ពុទ្ធសាសនា ក្នុងវត្តអារាម ។

៤- បង្កើនសកម្មភាពក្នុងកិច្ចការសង្គមរបស់សង្ឃ និងពុទ្ធបរិស័ទ ក្នុងការ អប់រំសីលធម៌ ចរិយាធម៌ អប់រំជីវភាពរស់នៅ រួមចំណែកបំបាត់ភាពក្រីក្រជាមួយ រាជរដ្ឋាភិបាល ។

៥- បង្កលក្ខណៈឱ្យពហុស្សុតធ្វើការស្រាវជ្រាវក្បួនខ្នាត រៀបចំចងក្រង សៀវភៅអត្ថបទខ្លីៗ និងជំរុញការបោះពុម្ពផ្សាយឱ្យទូលំទូលាយ សម្រាប់ជាទុនផ្តល់ ចំណេះដឹងអប់រំសីលធម៌ អារ្យធម៌ល្អៗ សំដៅបំបាត់អំពើហិង្សាក្នុងសង្គម ។

៦- លើកកំពស់ស្មារតីការបដិបត្តិធម៌វិន័យ ក្នុងជួរសង្ឃឱ្យកាន់តែសុក្រឹត តាមពុទ្ធោវាទ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ។ ជំរុញ ឱ្យចេះប្រើប្រាស់គម្ពីរព្រះត្រៃបិដក ដែលជាមូលដ្ឋានគ្រឹះ នៃទ្រឹស្តីព្រះពុទ្ធសាសនា ជាមាគ៌ាគន្លឹះនៃវប្បធម៌-សន្តិភាព ។

៧- ចូលរួមយ៉ាងសកម្មក្នុងការអប់រំទប់ស្កាត់ល្បែងអបាយមុខ ការសេព គ្រឿងញៀន ទប់ស្កាត់និងបង្ការការរីករាលដាលនៃជំងឺធ្ងន់ធ្ងរផ្សេងៗមានជំងឺអេដស៍

ជាដើម តាមរយៈសកម្មភាពព្រះពុទ្ធសាសនា ។ កុលបុត្រដែលសុំបព្វជ្ជា ត្រូវឆ្លងកាត់ការពិនិត្យរោគសង្គម (អេដស៍)ជាមុន ។

៨- ភិក្ខុដែលត្រូវបានជ្រើសតាំងជាចៅអធិការវត្ត ត្រូវមានសញ្ញាប័ត្រកិរិតទាបបំផុតត្រឹមបាតិមោក្ខធម្មវិន័យថ្នាក់ឯក ឬពុទ្ធិកបឋមសិក្សា ។

៩- ពង្រឹងគុណភាពពុទ្ធិកសិក្សានៅតាមខេត្ត-ក្រុង ដោយរៀបចំសាលាធម្មវិន័យ ពុទ្ធិកបឋមសិក្សាឱ្យមានប្រព័ន្ធត្រឹមត្រូវជាកម្រងវត្ត កម្រងសាលា តាមចំនួនជាក់ស្តែងតិច ឬច្រើន ដែលអាចប្រមូលផ្តុំបាន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងការផ្តល់ចំណេះដឹង ។ គោលដៅចម្បងគឺបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរព្រះសង្ឃឱ្យកាន់តែកើនឡើង សំដៅលើកស្ទួយវិស័យព្រះពុទ្ធសាសនាឱ្យសក្តិ សមជាសាសនារបស់រដ្ឋ ។

១០- ព្រះគ្រូចៅអធិការគ្រប់វត្ត ដែលបានគ្រប់គ្រងភិក្ខុ-សាមណេរផ្ទាល់ ត្រូវរៀបចំចាត់ចែងភិក្ខុ-សាមណេរ ឱ្យបានសិក្សារៀនសូត្របាលី បាតិមោក្ខ ចរិយាធម៌ និងធម្មវិន័យតាមប្រពៃណីព្រះពុទ្ធសាសនា ។

១១- សំណូមពររាជរដ្ឋាភិបាលចាត់ទុកបុណ្យមាឃបូជា ដែលជាបុណ្យប្រពៃណីព្រះពុទ្ធសាសនា ដូចជាបុណ្យពិសាខបូជា ក្នុងប្រតិទិនឈប់សម្រាករបស់មន្ត្រីរាជការ ដោយចាត់ទុកបុណ្យទាំងពីរនេះ ជាភារកិច្ចចម្បងរបស់រាជរដ្ឋាភិបាល។ អង្គមហាសន្និបាត សូមឱ្យសម្តេចព្រះសង្ឃរាជ ធ្វើលិខិតទៅរាជរដ្ឋាភិបាលបញ្ចូលព្រះសង្ឃទៅជួយអប់រំសិស្សសាលា ស្របតាមកម្មវិធីរបស់ក្រសួងអប់រំ ដើម្បីឱ្យកុលបុត្រកុលធីតាខ្មែរ បានចេះដឹងនូវវិជ្ជាព្រះពុទ្ធសាសនា សំដៅបណ្តុះបណ្តាលនិងលើកដំកើង សីលធម៌ សុជីវធម៌ ចរិយាធម៌ ព្រះពុទ្ធសាសនា ។

សង្ឃប្រកាសនេះ ជាច្បាប់សម្រាប់អនុវត្តនៅគ្រប់វត្តអារាម ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៣

**សម្តេចព្រះមហាសុមេធាធិបតី**

**សម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃកម្ពុជា**

**នន់ ងៀត**

បានឃើញ និងឯកភាព

**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

**ជា សាវឿន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សង្ឃប្រកាស

( គណៈធម្មយុត្តិនិកាយ )

សម័យប្រជុំពេញអង្គ នៃអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី ១២ នៃមន្ត្រីសង្ឃគណៈធម្មយុត្តិកនិកាយ បានប្រព្រឹត្តទៅនិងធ្វើការពិភាក្សា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចព្រះសុគន្ធាធិបតី **បួរ - គ្រី** សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ នៃកម្ពុជា ។ អង្គពិភាក្សាបានដំណើរការអស់រយៈពេលបីថ្ងៃ គឺចាប់ពីរសៀលថ្ងៃទី ២២.២៣.២៤ ខែ ឧសភា ព.ស ២៥៤៧ គ.ស ២០០៣ ដោយមានការចូលរួមពីឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឯកឧត្តម រដ្ឋលេខាធិការ ឯកឧត្តម អនុរដ្ឋលេខាធិការនៃក្រសួងធម្មការនិងសាសនា និងមន្ត្រីសង្ឃចំនួន ៤៣ អង្គ ព្រមទាំងមន្ត្រីធម្មការ និងសាសនាខេត្ត-ក្រុង ចំនួន ១៦ រូបជាអ្នកសង្កេតការណ៍ ។

អង្គសន្និបាតបានទទួលយកខ្លឹមសារ នៃសុន្ទរកថារបស់សម្តេច **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ដែលបានថ្លែងក្នុងឱកាសបើកអនុ-សំវច្ឆរមហាសន្និបាត នាសាលសន្និសីទចតុមុខ និងយោងតាមការពិភាក្សាអស់រយៈពេលពីរថ្ងៃកន្លះ អង្គអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី ១២ នៃគណៈធម្មយុត្តិកនិកាយបានដាក់ចេញនូវសង្ឃប្រកាស ដែលមានខ្លឹមសារដូចខាងក្រោម :

**១.ការពង្រឹងរចនាសម្ព័ន្ធសង្ឃ ការងារគ្រប់គ្រងនិងដឹកនាំ :**

-មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ត្រូវធ្វើជាគំរូ ក្នុងការគោរពប្រតិបត្តិធម្មវិន័យឱ្យបានត្រឹមត្រូវតាមឱវាទព្រះពុទ្ធជាអម្ចាស់ ។

- ចូលរួមក្នុងចលនាអប់រំ បណ្តុះបណ្តាលធនធានព្រះសង្ឃ ឱ្យបានរីកចម្រើនទាំងបរិមាណ និងគុណភាព ។

- ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងវត្តអារាម ព្រះសង្ឃ និងគណៈកម្មការវត្តឱ្យបានល្អតាមលំដាប់ថ្នាក់ គោរពភារកិច្ចក្នុងការដឹកនាំការងារគ្រប់កាលៈទេសៈ ។

- ជួយផ្តល់មតិយោបល់ក្នុងការជ្រើសរើសចៅអធិការវត្តថ្មី ដែលមានគុណសម្បត្តិ ចរិយាសម្បត្តិ និងចំណេះដឹង (គឺមានចំណេះវិជ្ជា ការប្រតិបត្តិល្អ មានប្រជាប្រិយ៍និងសមត្ថភាពក្នុងការកសាង និងដឹកនាំ ) និងត្រូវមានការចាត់តាំងត្រឹមត្រូវពីសម្តេចព្រះសង្ឃរាជ ដោយមានការឯកភាពពីក្រសួងធម្មការ និងសាសនា ។

- សម្តែងនូវទឹកចិត្តរីករាយ អារម្មណ៍ជ្រះថ្លា និងភាពជិតស្និទ្ធជាមួយពុទ្ធបរិស័ទជាគ្រហស្ថក្នុងសមាគមន៍ និងសាធារណជនទូទៅ ។

- ជួយសម្រួល និងសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរធម្មការ និងសាសនាខេត្ត-ក្រុង ដើម្បីញ៉ាំងព្រះសង្ឃពុទ្ធសាសនាឱ្យមានតួនាទីសំខាន់ ក្នុងការអភិវឌ្ឍន៍សង្គម ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ ។

**២ . វិស័យការងារពុទ្ធិកសិក្សា :**

- ជំរុញការបង្កើតសាលាធម្មវិន័យ ពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យមសិក្សា និងការអប់រំចរិយាធម៌ គុណធម៌ដល់កុមារ យុវជន បព្វជិត និង គ្រហស្ថ ដោយបង្កើតមជ្ឈមណ្ឌលអប់រំចិត្ត នៅគ្រប់មណ្ឌលខេត្ត-ក្រុង ។

-បង្កើតឱ្យមានប្រព័ន្ធអប់រំគ្រប់លំដាប់ថ្នាក់ តាមបែបប្រព័ន្ធអប់រំជាតិ

និងអន្តរជាតិ ។

- មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ និងព្រះគ្រូចៅអធិការ មានភារកិច្ចទទួលខុសត្រូវលើការងារនេះ ក្នុងឋានៈជាគ្រូបង្គោលតាមមូលដ្ឋាន ។

**៣. សាធារណុបត្ថម្ភ :**

- មន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ត្រូវយកព្រះទ័យទុកដាក់ ក្នុងចលនាបង្កើតសមាគម និងហិបសង្គហៈ តាមវត្តអារាមហើយគ្រប់គ្រងឱ្យបានល្អ ។

- វត្តដែលមានលទ្ធភាព ត្រូវជួយទំនុកបំរុងដល់វត្ត ដែលមានការខ្វះខាត ។

- រាល់ការងារគ្រប់គ្រង និងបែងចែកថវិកាត្រូវមានឯកសារដាក់លាក់ត្រឹមត្រូវ ។

- ព្រះសង្ឃត្រូវមានតួនាទី ក្នុងការស្វែងរកដៃគូ និងម្ចាស់ជំនួយឧបត្ថមផ្សេងៗ ដើម្បីអភិវឌ្ឍន៍រាល់កម្មវិធីបំរើពុទ្ធសាសនា និងសង្គម ។

**៤ . ការផ្សព្វផ្សាយ (ធម្មទូត)**

- មន្ត្រីសង្ឃគ្រប់ឋានានុក្រម ត្រូវពង្រឹងសមត្ថភាព និងគុណធម៌ក្នុងការចូលរួមការងារអប់រំផ្សព្វផ្សាយ នូវព្រះធម៌ ព្រះវិន័យ ទាំងការសិក្សាទាំងការប្រតិបត្តិ ។

- បង្កើតឱ្យមានធម្មកុដិ ធម្មសភា ធម្មបណ្ណាល័យ ឬសាលាហោត្រ័យសម្រាប់ការសិក្សាស្រាវជ្រាវរបស់បព្វជិត និងគ្រហស្ថតាមមូលដ្ឋាន ។

- បង្កើតកម្មវិធីបណ្តុះបណ្តាល ការសម្តែងធម្មទេសនា ការសូត្រធម៌បទការតែងនិពន្ធ និងការផ្សព្វផ្សាយតាមលទ្ធភាព ដែលអាចធ្វើទៅបាន ។

- ការបង្កើតវត្តថ្មីបាន ត្រូវមានការឯកភាពតាមឋានានុក្រម ដើម្បីធ្វើជាមជ្ឈមណ្ឌលសម្រាប់ផ្សព្វផ្សាយអប់រំ ។

**៥ _ មហាពោធិសមាគម :**

- គ្រប់វត្ត ទាំងវត្តចាស់ ទាំងវត្តថ្មី ព្រមទាំងមន្ត្រីសង្ឃដែលបានទទួលការតែងតាំងត្រូវបានទទួលសិទ្ធិជាសមាជិកពេញសិទ្ធិនៃមហាពោធិ សមាគម ។

- វត្តនិមួយៗ និងជាសមាជិក ត្រូវឧបត្ថម្ភយ៉ាងតិច ១០ ម៉ឺនរៀលក្នុង ១ឆ្នាំ ។

- វត្តនិមួយៗ និងសមាជិកត្រូវយកព្រះទ័យទុកដាក់ចូលរួមយ៉ាងសកម្មដោយមានឯកសារត្រឹមត្រូវ ហើយគោរពតាមលក្ខន្តិកៈរបស់ពុទ្ធិកសមាគម ។

- សម្តេចព្រះសង្ឃរាជ ជាព្រះប្រធានប្រទានបង្កាន់ដៃ ដើម្បីទុកជាឯកសារដល់ម្ចាស់ទានតាមមូលដ្ឋាន ។

សង្ឃប្រកាសនេះ គឺជាច្បាប់សម្រាប់អនុវត្តនៅតាមវត្តគណៈធម្មយុត្តិកនិកាយ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៣

**សម្តេចព្រះសុគន្ធាធិបតី ព្រះសង្ឃរាជគណៈ**

**ធម្មយុត្តិកនិកាយ**

**សម្តេចព្រះសង្ឃរាជ បួរ គ្រី**

បានឃើញ និងឯកភាព

**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

**ជា សាវឿន**

# ពិធីប្រកាសតែងតាំងមហាឧបាសិកា ញ៉ឹក ម៉ុនថា ជា ឧកញ៉ាឧបាសិកា ញ៉ឹក ម៉ុនថា



***ឯកឧត្តម ជា សាវឿន*** *រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាក្នុងពិធីប្រកាស តែងតាំង* ***ឧកញ៉ាឧបាសិកា ញ៉ឹក ម៉ុនថា*** *តាមព្រះរាជក្រឹត្យលេខ នស/រកត/០៤០៣/១៤០*

*ចូរកុំប្រកាន់ខ្ជាប់តែតាមទស្សនៈផ្ទាល់ខ្លួន :*

*"មនុស្សដែលមានឈ្មោះថា* ***សមណៈ ,ព្រាហ្មណ៍*** *ខ្លះមានទម្លាប់ប្រកាន់ខ្ជាប់តាមទស្សនៈខ្លួនផ្ទាល់, មនុស្សដែលមើលឃើញតែមួយជ្រុងប៉ុណ្ណោះ រមែងជាប់ផុងក្នុងជម្លោះ និងការតវ៉ា " ។*

*ព្រះពុទ្ធ*

# ព្រះរាជក្រឹត្យ

នស / រកត / ០៤០៣/១៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា)

## តែងតាំង

ឧបាសិកា ញ៉ឹក ប៊ុនជា

ជា

**ឧកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៣
ជួសព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

អគ្គមេធា និង ស្ការ
ជា ស៊ីម

លេខ: ១៤០ ធ ល
៣ាប.០៣.០៤.១៥៦ ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៣
... តាន់



*រូបថតលោក **ឱម ខែម***

# វិយោគកថា និងជីវប្រវត្តិរបស់សពលោក ឱម ខែម អតីតនាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

- សូមនមស្សការ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ជាទីគោរពសក្ការៈ.
- សូមនមស្សការ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ.
- សូមគោរព ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី សីលវន្ត សីលវតី និងញាតិមិត្តក្រុមគ្រួសារសពលោក **ឱម ខែម** ជាទីគោរព.

ថ្ងៃនេះ គឺថ្ងៃសៅរ៍ ៩ រោច ខែពិសាខ ឆ្នាំមមែ បញ្ចស័ក ព.ស ២៥៤៧ ត្រូវនឹងថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៣ ដែលយើងទាំងអស់គ្នា បានមកជួបជុំគ្នា នៅក្នុងបរិវេណនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនេះ ក្នុងអារម្មណ៍រន្ធត់ក្តុកក្តួល

អួលអាក់ ស្រពាប់ស្រពោន និងទុក្ខក្រៀមក្រំយ៉ាងក្រៃលែង ដើម្បីប្រារព្ធពិធីបូជាសពលោក **ខ្ទឹម ខែម** អតីតនាយកពុទ្ធសាសនបណ្ឌិត្យ និងជាទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា។ ក្រោយដែលបានតម្កល់សពធ្វើបុណ្យទក្ខិណានុប្បទានតាមប្រពៃណីព្រះពុទ្ធសាសនា អស់រយៈពេលបួនថ្ងៃកន្លងមក។

ការទទួលមរណភាពរបស់លោក **ខ្ទឹម ខែម** បានធ្វើឱ្យលោកស្រី **ហូ សុន្ទរី** ជាភរិយា ព្រមទាំងបុត្រធីតា ចៅប្រុស បងប្អូនសាច់សាលោហិត និងមិត្តភក្តិរួមជំនាន់មានសេចក្តីស្តាយស្រណោះអាលោះអាល័យ និងរន្ធត់តក់ស្លុតឥតឧបមា ពុំមានវាចាអ្វីមកថ្លែងឱ្យត្រឹមស្មើបានឡើយ។

ការបាត់បង់ជីវិតលោក **ខ្ទឹម ខែម** គឺជាការបាត់បង់ពុទ្ធសាសនិក និងជាអ្នកនិពន្ធខ្មែរមួយរូប ដែលក្នុងមួយជីវិតរបស់លោក បានបូជាកម្លាំងកាយចិត្ត និងបញ្ញាញាណបម្រើយ៉ាងសកម្មនៅក្នុងវិស័យព្រះពុទ្ធសាសនា. ក្នុងវិស័យស្រាវជ្រាវនិពន្ធ និងក្នុងការថែរក្សាប្រពៃណីទំនៀមទម្លាប់ដ៏ល្អរបស់ជាតិ។

សូមឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី និងបងប្អូនទាំងអស់ មេត្តាក្រោកឈរឡើង ដើម្បីគោរពវិញ្ញាណក្ខន្ធសព «គោរព»។

តទៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទសូមអនុញ្ញាតប្រគេន និងជម្រាបជូនដោយសង្ខេបនូវដំណើរជីវិតរបស់លោក **ខ្ទឹម ខែម** ដូចខាងក្រោមនេះ :

លោក **ខ្ទឹម ខែម** កើតនៅថ្ងៃទី ០១ មករា ឆ្នាំ ១៩៣៤ នៅភូមិថ្កូវ ឃុំផុង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ បិតានាម **ខ្ទឹម ឃឹម** (បានទទួលមរណភាពតាំងពីលោក **ខ្ទឹម ខែម** មិនទាន់ដឹងក្តី) និងមាតានាម **សូ តឹប** ជាកសិករនៅភូមិថ្កូវ ឃុំផុង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ លោក **ខ្ទឹម ខែម** មានបងប្អូនតែពីរនាក់គត់ គឺបងស្រីម្នាក់ និងរូបលោកជាប្អូនប្រុស។

កាលនៅពីកុមារភាព, កុមារ **ឡិម ខែម** ត្រូវបានម្ដាយនាំយកទៅឱ្យសិក្សាអក្សរសាស្ត្រលេខនពន្ធ នៅវត្តផុង ឃុំផុង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ លុះដល់បានអាយុ ១៥ ឆ្នាំ, ម្ដាយក៏បានអនុញ្ញាតឱ្យយុវជន **ឡិម ខែម** បួសជាសាមណេរ និងបានសិក្សារៀនសូត្រព្រះបរិយត្តិធម៌នៅវត្ត សុរភី ឃុំរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

ចាប់ពីឆ្នាំ ១៩៥២ ដល់ឆ្នាំ ១៩៦០ សមណសិស្ស **ឡិម ខែម** បានបន្តការសិក្សានៅពុទ្ធិកបឋមសិក្សាវត្តឧណ្ណាលោម និងបានប្រឡងជាប់ចូលរៀននៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រោមព្រះរាជូបត្ថម្ភផ្ទាល់នៃសម្ដេចព្រះមហាសុមេធាធិបតី **ជួន ណាត** ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ និងព្រះបាឡាត់សង្ឃវ័ក្ស **មួល ហ៊ិន** ។

អាស្រ័យដោយការខិតខំ តស៊ូអំណត់ព្យាយាមសិក្សារៀន, សមណសិស្ស **ឡិម ខែម** ក៏បានប្រឡងជាប់សញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា និងបានប្រឡងជាប់ចូលរៀនពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជបានមួយឆ្នាំ ក៏បានលាសិក្ខាបទមកជាគ្រហស្ថ និងបានទៅធ្វើជាគ្រូពុទ្ធិកបឋមសិក្សានៅវត្តអន្សោង ឃុំអន្សោង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង និងបន្ទាប់មកទៀត ត្រូវក្រសួងធម្មការចាត់ឱ្យទៅបង្រៀននៅសាលាពុទ្ធិកបឋមសិក្សាវត្តទក្ខិណាវ៉ន ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ពីឆ្នាំ ១៩៦១ ដល់ឆ្នាំ ១៩៦៤។

ពីឆ្នាំ ១៩៦៥ ដល់ឆ្នាំ ១៩៧៥, លោក **ឡិម ខែម** បានចូលបំរើការងារនៅពុទ្ធិកសមាគមកម្ពុជរដ្ឋ ក្នុងឋានៈជាលេខាធិការ និងជាបណ្ណាធិការទស្សនាវដ្ដីពន្លឺពុទ្ធចក្រ។ លោក **ឡិម ខែម** បានរៀបអាពាហ៍ពិពាហ៍ ជាមួយលោកស្រីហួ សុន្ទរី នៅសង្កាត់លេខ ៤ ក្រុងភ្នំពេញ នៅឆ្នាំ ១៩៦៩ និងបច្ចុប្បន្នមានកូន ៤ នាក់

ប្រុសពីរនាក់ និងស្រីពីរនាក់ និងបានជួយចិញ្ចឹមក្មួយកំព្រាម្នាក់នៅក្នុងបន្ទុក ផង។ ក្រៅពីភាសាខ្មែរ លោក **ឡឹម ខែម** ចេះភាសាបាលី អាចស្រាវជ្រាវធម៌វិន័យបាន និងចេះភាសាអង់គ្លេសគួរឱ្យសរសើរ និងធ្លាប់ធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស នាចុងទសវត្សឆ្នាំ ៦០ ផង។

ក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ. លោក **ឡឹម ខែម** និងលោកស្រី ហួ សុន្ទរី ព្រមទាំងកូនប្រុសស្រី និងក្រុមគ្រួសារ ត្រូវគេជន្លៀសឱ្យទៅរស់នៅភូមិអូរបាក់រទេះ ឃុំសំបុក ស្រុកក្រចេះ ខេត្តក្រចេះ នឹងត្រូវគេបង្ខំឱ្យធ្វើការជាទម្ងន់ និងទទួលទុក្ខទារុណកម្មយ៉ាងជូរចត់បំផុត។

ក្រោយថ្ងៃជ័យជំនះ ៧ មករា ឆ្នាំ ១៩៧៩. លោក **ឡឹម ខែម** បានចូលមកបម្រើការនៅទីស្នាក់ការធម្មការ និងសាសនា។ ក្រោយមកលោក **ឡឹម ខែម** ជាមួយនិងមិត្តភ័ក្ដរួមការងារចំនួន ៤ រូបទៀត ក្នុងនោះមានឯកឧត្ដម **ឈន អៀម** នឹងខ្ញុំព្រះករុណាខ្ញុំបាទផងដែរ ត្រូវបានចាត់តាំងឱ្យមកបម្រើការនៅទីស្ដីការក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ដើម្បីទទួលភារកិច្ចនៅក្នុងនាយកដ្ឋានឃោសនាហ្វឹកហ្វឺននិពន្ធ មានការចេញផ្សាយទស្សនាវដ្ដី រណសិរ្ស ២ច្បុ ជាដើមតរៀងមក។

សូមទូលប្រគេន និងជម្រាបជូនជ្រាបផង ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ ភ្លាម ទីស្នាក់ការធម្មការ និងសាសនា តាំងនៅក្នុងវត្តឧណ្ណាលោម ដោយសម្ដេចព្រះសង្ឃរាជជាអម្ចាស់ទ្រង់ព្រះអនុញ្ញាតផ្ដល់កុដិមួយ ស្ថិតនៅជាប់របងខាងកើត ផ្នែកខាងត្បូងដើម្បីដំណើរការងាររបស់ខ្លួន។ គឺនៅពេលនោះហើយ ដែលលោក **ឡឹម ខែម** ជាមួយនឹងមិត្តភក្ដិផ្សេងទៀត មានសពលោក អ៊ុក ម៉ៅជាដើម បានស្វះស្វែងទៅស្នើសុំសៀវភៅពីទីផ្សេងៗមានរោងចក្រនៅចាក់អង្រែ. ពីក្រសួង

ការបរទេស ដោយដាក់រទេះរុញយកមកតម្កល់ទុកធ្វើជាឯកសារ សម្រាប់សិក្សាស្រាវជ្រាវនៅទីស្នាក់ការវត្តឧណ្ណាលោម មានគម្ពីរព្រះត្រៃបិដកជាដើម ។

អាស្រ័យដោយការខិតខំ និងស្មារតីស្រឡាញ់ប្រពៃណីទំនៀមទម្លាប់ជំនឿសាសនា និងឯកសារជាប្រភពនៃការផ្តល់ចំណេះដឹង ទាំងវិស័យព្រះពុទ្ធសាសនា និងចំណេះទូទៅរបស់លោក **ឱម ខែម** និងមិត្តភ័ក្តរួមការងារ. ទើបពុទ្ធ-សាសនបណ្ឌិត្យត្រូវបានបង្កើតឡើងនៅវត្តឧណ្ណាលោម ជាជំហានដំបូង និងដំណើរការរីកចម្រើនជាបន្តបន្ទាប់ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ដោយមានលោក អ៊ុក ម៉ៅ និងលោក ឱម ខែម ជាអ្នកគ្រប់គ្រងដឹកនាំផ្ទាល់ ។

នៅពេលដែលក្រសួងធម្មការ និងសាសនា ត្រូវបានបង្កើតឡើង និងអាស្រ័យដោយមានកិច្ចសហការ និងទំនាក់ទំនងល្អរបស់លោក ឱម ខែម ជានាយកពុទ្ធសាសនបណ្ឌិត្យ. ឯកឧត្តម ឈន អៀម ជារដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា និងថ្នាក់ដឹកនាំផ្សេងៗទៀត ព្រមទាំងមានការជួយឧបត្ថម្ភ ទាំងស្មារតីនិងសម្ភារៈថវិកាពីមូលនិធិហិនរិចបូល ប្រទេសអាល្លឺម៉ង់ និងអង្គការពុទ្ធសាសនាជប៉ុនផង ទើបពុទ្ធសាសនបណ្ឌិត្យមានលទ្ធភាព និងអាចដំណើរការរីកចម្រើនជាបន្តបន្ទាប់ រហូតដល់មានអគារដ៏ល្អប្រណីតស័ក្តិសមជាទីតាំងតម្កល់ឯកសារស្រាវជ្រាវគួរជាទីជ្រះថ្លានៅទីនេះ ។ សមិទ្ធផលនេះ គឺជាការរួមចំណែកដ៏ធំធេងរបស់លោក ឱម ខែម ដែលយើងខ្ញុំព្រះករុណា-ខ្ញុំបាទ សូមចារឹក និងសូមចាត់ទុកថា លោក ឱម ខែម គឺជាស្ថាបនិកមួយរូបដ៏សកម្ម ក្នុងនាមផលប្រយោជន៍សម្រាប់ព្រះពុទ្ធសាសនា និងសម្រាប់សង្គមជាតិ ។

ក្រោយពេលដែលលោក ឱម ខែម ត្រូវបានចូលនិវត្តន៍. អាស្រ័យដោយ

បទពិសោធន៍ការងារចាស់ទុំ សមត្ថភាពជំនាញ សីលធម៌ថ្លៃថ្នូរ និងស្មារតីអំណត់ព្យាយាម, ទើបរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានតែងតាំងឱ្យធ្វើជាទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា រហូតមក ។ ជាមួយគ្នានេះ, លោក ឱម ខែម ក៏ត្រូវបានមហាសន្និបាតលើកទី ១ នៃពុទ្ធិកសមាគមកម្ពុជរដ្ឋ ផ្តល់កិត្តិយសជូនលោក ឱ្យធ្វើជាអគ្គលេខាធិការសមាគម ដើម្បីរួមចំណែកបម្រើការងារពុទ្ធិកសមាគមកម្ពុជរដ្ឋ តរៀងមក។

លោក ឱម ខែម បានទទួលគ្រឿងឥស្សរិយយសការងារ មេដាយសិរីទ្ធ និងមេដាយមាសការងារ ក្នុងការសាងសង់អគារពុទ្ធសាសនបណ្ឌិត្យនេះ។

លោក ឱម ខែម គឺជាមន្ត្រីរាជការម្នាក់ ដែលមានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងភារកិច្ច និងមានសីលធម៌រស់នៅគួរឱ្យគោរពស្រឡាញ់ ទាំងចរិតឫកពារភាសានិយាយស្តី ការរស់នៅ និងទាំងជាអ្នកមានអធ្យាស្រ័យសន្តោសយោគយល់ច្រើនស័ក្តិសមជាកល្យាណមិត្តគួររាប់អាន។

ខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់ ធ្លាប់រួមប្រាស្រ័យការងារជាមួយលោក ឱម ខែម ពីឆ្នាំ ១៩៦៨ ដល់ឆ្នាំ ១៩៧៥ និងពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ២០០៣ មានរយៈពេល ៣១ ឆ្នាំ បានសង្កេតឃើញថា លោក ឱម ខែម បានយកពេលវេលាយ៉ាងច្រើន សម្រាប់ការស្រាវជ្រាវ និងតាក់តែងនិពន្ធ។ ជាញឹកញាប់, ថ្ងៃខ្លះ យប់ខ្លះ លោក ឱម ខែម តែងអង្គុយស្រាវជ្រាវសរសេរ ចងក្រង និពន្ធ ដោយពុំសូវជាគិតពីម៉ោងពេលវេលាឡើយ។ ការសប្បាយរបស់លោក ឱម ខែម គឺការអានសៀវភៅការស្រាវជ្រាវ និងសរសេរនិពន្ធ។ លោក ឱម ខែម បានដាក់ធុរចិត្តបំពេញការងារជាប្រយោជន៍ព្រះពុទ្ធសាសនា និងផលប្រយោជន៍សង្គមជាតិហាក់ដូចជាច្រើនជាងការងារផ្ទះសម្បែង និងគ្រួសារ។ ជាក់ស្តែងក្នុងឋានៈលោកជាអ្នកទទួលខុសត្រូវ

មួយផ្នែកនៃឯកសារសម្រាប់បម្រើសន្និសីទកំពូលព្រះពុទ្ធសាសនាលើកទី ៣ កាលពីចុងឆ្នាំ ២០០២ កន្លងមកនេះ លោក ឱម ខែម បានប្រើពេលវេលាយ៉ាងច្រើនទាំងថ្ងៃ ទាំងយប់ បម្រើភារកិច្ចដែលក្រសួងបានប្រគល់ឱ្យ រហូតដល់បានសម្រេចជោគជ័យគួរឱ្យសរសើរ ។

ដោយសកម្មភាពការងារច្រើន លើសម៉ោង លើសពេល, ការប្រើប្រាស់ឥរិយាបថទាំងបួនពុំបានស្មើជាប្រក្រតី, លោក ឱម ខែម ក៏ត្រូវអាការរោគតាមយាយីជាបន្តបន្ទាប់ ។ លោកស្រី ហូ សុន្ទរី ជាភរិយា និងកូនប្រុសស្រី បានខិតខំព្យាបាលស្វាមី និងឪពុក ដោយអស់ពីចិត្តពីថ្លើម ។ ប៉ុន្តែ អាការរោគរបស់លោក ឱម ខែម ពុំបានធូរស្រាយឡើយសោះ ។

គួរឱ្យស្តាយពន់ពេកណាស់ ដោយក្រឹត្យក្រមធម្មជាតិ ពុំអាចអនុគ្រោះបានព្រោះអ្វីៗទាំងអស់ សុទ្ធតែស្ថិតនៅក្នុងអំណាចនៃសភាវធម៌ គឺអនិច្ចំ ទុក្ខំ អនត្តាមិនទៀង ជាទុក្ខ និងមិនមែនជារបស់ផងខ្លួន កើត ចាស់ ឈឺ ស្លាប់ ។ យ៉ាងណាមិញជីវិតលោក ឱម ខែម ក៏ពុំមានករណីពិសេស ដែលធម្មជាតិ ត្រូវអនុគ្រោះ និងលើកលែងបានដែរ ។

លោក ឱម ខែម បានទទួលមរណភាព នៅថ្ងៃ ពុធ ទី ២១ ខែ ឧសភា ឆ្នាំ២០០៣ វេលាម៉ោង ០០.០៥ នាទី ក្នុងជន្មាយុ ៦៩ ឆ្នាំ ក្រោមទំនួញយំសោកសង្រេក ស្តាយស្រណោះអាលោះអាល័យ របស់លោកស្រី ហូ សុន្ទរី ជាភរិយា កូនប្រុសស្រី ញាតិមិត្ត បងប្អូន គួរឱ្យសង្វេគ ។

សពលោក ឱម ខែម ត្រូវបានក្រសួងធម្មការ និងសាសនា, ពុទ្ធិកសមាគមកម្ពុជរដ្ឋ និងក្រុមគ្រួសារសព រៀបចំចាត់ចែងធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលជូនដល់បដិសន្ធិវិញ្ញាណរបស់សពតាមប្រពៃណីព្រះពុទ្ធសាសនា យ៉ាង

ស័ក្តសម ។

តទៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងវិយោគកថាទៅកាន់សពលោក ឱម ខែម មុននឹងប្រារព្ធពិធីជូនភ្លើងបូជាសពដូចតទៅនេះ

សពលោក **ឱម ខែម** ជាទីគោរព,

លោកបានលាចាកលោកយើងនេះ ចោលយើងខ្ញុំទាំងអស់គ្នា និង លោកស្រី ហូ សុន្ទរី ជាភរិយា និងកូនប្រុសស្រី ជាទីស្រឡាញ់ស្និទ្ធស្នេហ៍គួរឱ្យអាណិត ជារៀងរហូត ។ នាទីនេះ ជានាទីចុងក្រោយ ដែលយើងខ្ញុំបានត្រឹមតែជូនដំណើរលោកមកដល់ទីមេរុនេះ និងប្រារព្ធពិធីបូជាសពលោកតាមប្រពៃណី តែប៉ុណ្ណោះ ។

ភរិយារបស់លោក, កូនប្រុសស្រីរបស់លោក, ចៅប្រុសស្រីរបស់លោក, កំពុងតែសម្លឹងមើលមឈូសជាទីតម្កល់សពរបស់លោកតាំងនៅទីមេរុដោយអារម្មណ៍ក្តុកក្តួលតក់ស្លុតពោរពេញដោយសេចក្តីស្តាយស្រណោះអាលោះអាល័យ ដោយការបាត់បង់ស្វាមីដ៏មានភក្តីភាពជាទីស្រឡាញ់ប្រកបដោយសង្គហធម៌ខ្ពស់ និងបាត់បង់ឪពុក ជីតា ប្រកបដោយព្រហ្មវិហារធម៌កម្ររកបាន ។

បងប្អូន ញាតិ សាច់សាលោហិត និងមិត្តភក្តិរួមជំនាន់ កំពុងតែស្តាយស្រណោះ ដោយការបាត់បង់កល្យាណមិត្តជាយុទ្ធិកជនដ៏សកម្មលើសមរភូមិសតិអារម្មណ៍ និងព្រឹទ្ធអ្នកនិពន្ធ ដែលបរិបូរដោយព្យាយាមតស៊ូអត់ធ្មត់ និងបទពិសោធន៍ចាស់ទុំ ។

សពលោក **ឱម ខែម** ជាទីគោរព

បន្តិចទៀតនេះ ព្រះអគ្គីនឹងឆាបឆេះរាងកាយរបស់លោក រលាយសាបសូន្យ ចាករូបភាពដើម ក្លាយទៅជាផេះផង់ ។ ប៉ុន្តែ អ្វីដែលសេសសល់នៅ មិនរលត់រលាយសាបសូន្យ ដូចរាងកាយនោះ គឺអំពើជាកុសល សេចក្តីល្អ គំរូវីរភាពស្នាដៃ

កិត្តិយស សេចក្តីថ្លៃថ្នូរ និងគុណបំណាច់របស់លោកចំពោះជាតិ ចំពោះពុទ្ធសាសនា និងចំពោះប្រជាជន នៅតែរស់នៅជាអមតៈគ្មានថ្ងៃស្លាប់ និងសាបសូន្យឡើយ ។ រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ រីរូបនៃសព្វសត្វ តែងវិបត្តិចាស់ជរា ឯនាមនិងគោត្តា ពុំជរាដូចរូបឡើយ ។

សពលោក **ឱម ខែម** ជាទីគោរព.

ចាប់ពីនាទីនេះ ម៉ោងនេះ ពេលនេះ ថ្ងៃនេះតទៅ យើងទាំងអស់គ្នាក៏ដូចជាលោកស្រី ហូ សុន្ទរី ជាភរិយា និងកូនប្រុសស្រី ព្រមទាំងក្រុមគ្រួសារញាតិមិត្ត បងប្អូនទាំងអស់ លែងបានឃើញមុខ ជួបមុខលោកទៀតហើយ នៅសល់ឡើយតែអនុស្សាវរីយ៍កម្សត់កម្រល្អៗ ដែលយើងខ្ញុំទាំងអស់គ្នាត្រូវចងចាំ និងបន្តថែរក្សានូវគំនិត និងគំរូវីរភាពដ៏ប្រពៃរបស់លោក ដើម្បីជាគុណប្រយោជន៍ សម្រាប់ព្រះពុទ្ធសាសនា និងសម្រាប់សង្គមជាតិ ។

សូមបដិសន្ធិវិញ្ញាណរបស់លោក បានទៅសោយសុខក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះគុណ. សូមអរគុណ.

*ពិធីបូជាសពលោក **ទិម ខែម** បានទទួលកិត្តិយសយ៉ាងក្រៃលែង ដោយបានសម្តេចព្រះសង្ឃរាជទាំងពីរគណៈយាងចូលរួម និងប្រទានភ្លើង។ ក្នុងនោះដែរយើងសង្កេតឃើញមានវត្តមានព្រះមេគណទូទាំងខេត្ត-ក្រុង ឯកឧត្តម រដ្ឋមន្ត្រី, រដ្ឋលេខាធិការ និងមន្ត្រីរាជការ, ប្រធានមន្ទីរទាំងអស់នៃក្រសួងធម្មការ និងសាសនា និមន្ត និងអញ្ជើញចូលរួមផងដែរ។*

*វិយោគកថា ត្រូវបានរៀបចំ និងអានដោយឯកឧត្តម **ជា គាន** អគ្គលេខាធិការរងនៃគណៈកម្មការបុណ្យជាតិ-អន្តរជាតិ និងជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា។*



សម្តេចព្រះសង្ឃរាជទាំងពីរគណៈប្រទានភ្លើងបូជាសពលោក **ទិម ខែម**

ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា



**មិត្តអ្នកអានជាទីមេត្រី !**

កម្ពុជសុរិយា បានទទួលអត្ថបទពីបណ្ដាខេត្តមួយចំនួនក្នុងប្រទេស និងមួយចំនួនទៀតមកពីក្រៅប្រទេស ជាអត្ថបទបែបស្រាវជ្រាវ ជាអត្ថបទកំណាព្យ និងជាសំណួរ ។ កម្ពុជសុរិយាសូមជម្រាបបញ្ជាក់ថា រាល់អត្ថបទទាំងអស់យើងនឹងធ្វើការពិនិត្យ និងសម្រេចបោះពុម្ពផ្សាយទៅបានដោយ ៖

- មានខ្លឹមសារអត្ថាក្រឹត ទាក់ទងនឹងអក្សរសិល្ប៍ពុទ្ធសាសនា, អក្សរសាស្ត្រទូទៅ និងអក្សរសិល្ប៍ខ្មែរ,
- មិនចម្លងពីច្បាប់ដើមណាមួយ និងមិនវែងពេក

អាស្រ័យហេតុនេះ រាល់អត្ថបទដែលអស់លោកអ្នកបានផ្ញើមកហើយ ហើយមិនទាន់ឃើញចុះផ្សាយនោះ កម្ពុជសុរិយានឹងបន្តចុះផ្សាយតាមលំដាប់លេខរៀង ឬថែរក្សាសម្រាប់បោះពុម្ពជាសៀវភៅ ឬជាព្រឹត្តិប័ត្រ ប្រចាំខែនៅអនាគតដ៏ខ្លីខាងមុខ ។

**សូមអរគុណ**

# អត្ថបទដែលកម្ពុជសុរិយាបានទទួលក្នុងត្រីមាសទី២ ឆ្នាំ២០០៣

| ល.រ | នាម និង គោត្តនាម | មកពី | ឈ្មោះអត្ថបទ |
|---|---|---|---|
| ១ | លោក ហម ឆាយលី | បារាំង | - សិលាចារឹកស្តុកកក់ធំ<br>- កំណាព្យ<br>- ដីខ្មែរក្អមខ្មែរ<br>- ព្រះខ្ទប និងក្របីឈ្លៀច<br>- សម្លេងស្គរធំ |
| ២- | សាមណនិស្សិត សុខ ឡឿន | វត្តលង្កា | - កំណាព្យ<br>- អ្នកដឹកនាំសង្គមសុខសាន្ត |
| ៣- | ឧបាសក អ៊ឹង តឹមអ៊ី | កំពង់ធំ | - បទសន្ទនា<br>- ដំណើរទៅកាន់សុភមង្គល<br>- កំណាព្យ.<br>- អដ្ឋង្គិកមគ្គអង្គប្រាំបី.<br>- ប្រយោជន៍បីយ៉ាងគួរស្វែងរក |

## សូមថ្លែងអំណរគុណចំពោះ

*ឧកញ៉ា ឧបាសិកា **ញ៉ឹក ម៉ុនថា** ដែលបានជួយឧបត្ថម្ភថវិកា ចំនួន ៥០ ដុល្លារ សម្រាប់ការចុះស្រាវជ្រាវ និងថតរូបភាព ដើម្បីបោះពុម្ពផ្សាយទស្សនាវដ្ដីកម្ពុជសុរិយា លេខ ២ ឆ្នាំ ២០០៣ នេះ ។*

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



លោក ឌឹក គាម ហៅ ឃីម (១៩៣៦)

ឆ្នាំទី ៥៧ លេខ ៣

ខែ កក្កដា - សីហា - កញ្ញា

ព.ស. ២៥៤៧

គ.ស. ២០០៣

ភ្នំពេញ

រូបក្រុបខាងក្រៅ :		**ជីវប្រវត្តិសង្ខេប**

*លោក **ខឹក គាម** ហៅ **ឃឹម** កើតនៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៣៦ នៅសង្កាត់ឫស្សីកែវ ស្រុកឆ្លូង ខេត្តក្រចេះ ។*

**ស្នាដៃសំខាន់ៗ :**

- *វេយ្យាករណ៍ ដោយរូបភាព*
- *រឿង ព្រះនាងឥន្ទ្រទេវី*
- *រឿង ចៅពញ្ញាហុក*



# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : **ខួន វ៉ាន់ចន្ធី**

និពន្ធនាយក : **ខៀវ បញ្ញាវុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង**. លោក **ម៉ែន ព្រាង**

លោក **ទង់ សុធារ៉ា**. លោក **ឌន់ ហ៊ិន**.

លោក **មៀច ប៉ុណ្ណ**. លោក **ពិ ប៊ុន្នីន**

## គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ខាង សារឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ, ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **នេត បារ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ជីវិតមនុស្ស និងបញ្ហា (ត) ............... (ឈន អៀម) ១
- ពុទ្ធសាសនានៅក្នុងទ្វីបអាស៊ីបច្ចុប្បន្ន ........(ក.ស្រីធម្មានន្ទ) ១៤


## II. អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ :


- វិសុទ្ធមគ្គទាំង ៧ ........................(ឆេង ផុន) ២៤
- ការរីកចម្រើននៃព្រះពុទ្ធសាសនា (តចប់) .......(ខ្លួត ធីតា) ៣០
- សិលាចារឹកថ្មីពីរនៅថលាបរិវ៉ាត់.............. (វ៉ង់ សុធារ៉ា) ៤០
- ព្រះរាម ឬរាមចន្ទ្រ.........................(ធន់ ហ៊ិន ) ៥០
- ប្រវត្តិបឹងកោះគ្នោត......................... (ជួប ឃាន) ៦១
- ពិធីហៅព្រលឹងស្រូវ ...................(ជាវ ហាន ) ៦៧
- អំពីបាលីស្នេហ៍........................(ម្ទេស ប៊ុណ្ណ) ៧០
- អំពីពាង..............................(ញ៉ាង ប៊ុនថន) ៧៤
- ម្ហូបស៊ុក..............................(សម សាឯម) ៧៥
- រឿង " ឆ្នាំប្រាសាទបាយ័ន " ..............(ខៀវ បញ្ញាវុឌ្ឍ) ៧៧
- កំណាព្យ, សម្លេងស្គរធំ .................. (ហាម ឆាយលី) ៨៩


## III. កំណត់ និងប្រវត្តិការណ៍ :


- សន្និសីទអំពី " ការអភិរក្សសាស្ត្រស្លឹករឹត និងក្រាំង " ........ ៩១
- សេចក្ដីជូនដំណឹងរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ....(ប្រាក់ ម៉ន) ៩២


## IV. ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា


- មិត្តអ្នកអានជាទីមេត្រី ................ (ខៀវ បញ្ញាវុឌ្ឍ) ៩៦

# ជីវិតមនុស្ស និង បញ្ហា

បណ្ឌិត **ក.ស្រីធម្មានន្ទ នាយកមហាថេរ**
បកប្រែ **ឈន_អៀម**

## វីតិក្រមផ្លូវភេទ

(Sex deviations)

វីតិក្រមផ្លូវភេទ ជួនកាលគេហៅថា ទុរាចារក្នុងការសេពកាម (Sexual aberrations)គឺការប្រព្រឹត្តិឃ្លាតចេញពីទម្លាប់រួមភេទធម្មតា មានទាក់ទងមនុស្សជាតិស្ទើរតែទាំងអស់ តាំងពីមានប្រវត្តិសាស្ត្រកត់ត្រាទុកពីព្រេងនាយម្ល៉េះ។ តាមទម្លាប់ វីតិក្រមផ្លូវភេទ (Sex deviations) គឺនិយាយយោងទៅរកមនុស្សដែលបង្ហាញឱ្យឃើញនូវអ្វីដែលយើងអាចហៅថា ការងាកចេញពីទម្លាប់រួមមគ្គសង្វាស ឬការប្រាសចាកអំពីអ្វីដែលសង្គមថ្មីទទួលថាជារឿងធម្មតា. គឺជាឥរិយាបថ វិបល្លាសផ្លូវភេទ (Sex perverts) ។ ដូច្នេះមានមនុស្សជាច្រើន. វៀរលែងតែគេបានដឹងច្បាស់នៅក្នុងសន្តានចិត្តរបស់គេផ្ទាល់. បានចែកជាប្រភេទ ហើយនិយាយអំពីមនុស្សទាំងនោះតាមធម្មតាថា *មនុស្សវិបល្លាស(Perverts =មនុស្សដែលមានឥរិយាបថមិនធម្មតា), មនុស្សមានចិត្តវិបល្លាសផ្លូវភេទ (Sexual phychopaths) មនុស្សមានសរសៃប្រសាទវិបល្លាសផ្លូវភេទ (Sex neurotics)* ។ល។ ជាញឹកញយដោយគេមិនទាំងដឹងច្បាស់ណាស់ផងទេនូវស្ថានភាពដែលគេនិយាយយោងដល់។ ប្រពៃណីសង្គមរបស់យើងហាក់ដូចជា តម្រូវឱ្យសង្គមមើលស្រាលលើមនុស្សវីតិក្រមផ្លូវភេទម្នាក់ (a sex deviant) ថាជាមនុស្សនាំមកនូវ ភាពអាម៉ាស់ដល់គ្រួសាររបស់គេ។

វិតិក្រមផ្លូវភេទដូចជាការសេពកាមជាមួយមនុស្សមានភេទដូចខ្លួន(Homosexuality) ការសេពកាមជាមួយឧភតោព្យញ្ជនកៈ (គឺអ្នកដែលមានភេទពីរ ជួនកាលជាប្រុស ជួនកាលជាស្រី = bisexuality) ការស្លៀកពាក់សម្លៀកបំពាក់របស់មនុស្សមានភេទផ្ទុយពីខ្លួន (Transvestism) ត្រូវបានគេចាត់ទុកជាកម្មវត្ថុតំណមតាំងពីយូរយារណាស់មកហើយ. គេកម្រលើកយកមកនិយាយគ្នា នៅក្នុងសង្គមមានសុជីវធម៌ និងមានសេចក្ដីគោរពគ្នាណាស់។ ប៉ុន្តែវាចម្លែកពេកណាស់ នៅក្នុងទស្សនៈរបស់គេស្ដីពីប្រធានបទនេះ។

ជាញឹកញាយណាស់ គេតែងប្រើពាក្យ " Homosexual " = (មនុស្សមានប្រតិពទ្ធ័ចំពោះអ្នកមានភេទដូចខ្លួន) សម្គាល់មនុស្សប្រុសមានចរិតស្រី ឬមនុស្សប្រុសស្លៀកសម្លៀកបំពាក់ស្រី។ នេះគឺជារូបភាពសាមញ្ញនៃការប្រតិពទ្ធ័ជាមួយមនុស្សមានភេទដូចខ្លួនដែលបាំងបិទភាពស្មុគស្មាញរបស់វាបានយ៉ាងសុខស្រួល ដូចជា រូបភាពវិតិក្រមផ្លូវភេទដទៃទៀតដែរ។

ពាក្យ " Homosexuality " (សេចក្ដីប្រតិពទ្ធ័ជាមួយមនុស្សមានភេទដូចគ្នា) សំដៅទៅដល់មនុស្សដែលមានអារម្មណ៍ស្រើបស្រាលចង់រួមមគ្គសង្វាស ជាមួយមនុស្សផ្សេងដែលមានភេទដូចខ្លួន។ ទាំងបុរស ទាំងស្ត្រី គេអាចហៅថា "Homosexual" ឬ "Gay" គឺពពួកអ្នកស្រឡាញ់ការរួមសង្វាសជាមួយមនុស្សមានភេទដូចគ្នា ប៉ុន្តែពាក្យទាំងពីរនេះគ្រាន់តែជាឆត្របាំងបិទនៅពីលើ ដែលនៅពីក្រោមមានប្រភេទផ្សេងៗជាច្រើនទៀត។ និយាយដោយទូលំទូលាយទៅ អ្នកស្រឡាញ់មនុស្សមានភេទដូចគ្នារួមមាន ពួកអ្នកស្រឡាញ់អ្នកមានភេទដូចគ្នា (gay man) ពួកអ្នកចូលចិត្តស្លៀកពាក់សម្លៀកបំពាក់ភេទផ្សេងពីខ្លួន (transvestites),

(ទាំងស្រី ទាំងប្រុស), ពួកអ្នកមានអារម្មណ៍វិបល្លាសចង់ធ្វើជាសមាជិកភេទផ្ទុយពីខ្លួន, ឬពួកអ្នកទទួលការវះកាត់ប្តូរភេទ (ប្តូរពីប្រុសទៅជាស្រី ពីស្រីទៅជាប្រុស) (trans-sexual) និងពួកស្ត្រីរួមភេទដូចគ្នា ( lesbians ) ។

ហើយដើម្បីមើលឃើញរឿងកាន់តែស្មុគស្មាញជាងនេះទៀតវាមានភាពផ្សេងគ្នាយ៉ាងសុខុមមួយរវាងពាក្យប្តូរផ្លាស់គ្នាបាន "tranvestite"(អ្នកចូលចិត្តស្លៀកពាក់របស់ភេទផ្សេង) និង"trans-sexual"(ស្រីចូលចិត្តរួមភេទដូចគ្នា) ។ វចនានុក្រមជាច្រើនពន្យល់ពាក្យ " transvestite " ថាជាមនុស្សម្នាក់ដែលស្លៀកពាក់របស់ភេទផ្ទុយគ្នា ជាញឹកញយកើតចេញពីសេចក្តីសប្បាយនឹងការប្រព្រឹត្តិនេះ។

ចំណែកឯពាក្យ " trans-sexual " (ដូចគេធ្លាប់យល់ជាទូទៅ) គឺអ្នកណាមួយ ដែលបានសម្រេចចិត្តដើម្បីរស់នៅ ជាមួយមនុស្សម្នាក់របស់ភេទផ្ទុយគ្នា ។ ពេលខ្លះការធ្វើអត្តសញ្ញាណកម្ម របស់អ្នកដែលបានសម្រេចចិត្តចង់រស់នៅជាមួយមនុស្សម្នាក់មានភេទផ្ទុយពីខ្លួនខ្លាំងពេកទៅ រហូតដល់សុខចិត្តទទួលការវះកាត់ប្តូរភេទ។

មនុស្សខ្លះដែលចូលចិត្តស្លៀកពាក់ សម្លៀកបំពាក់ភេទផ្សេងអាចមិនមែនជា "gay" ទេ, ពួកគេគ្រាន់តែសប្បាយស្លៀកពាក់សម្លៀកបំពាក់របស់ភេទផ្ទុយគ្នាដោយមិនមានបំណងរួមរស់ជាមួយមនុស្សមានភេទផ្ទុយគ្នានោះទេ។

Gay គឺជាបុរសស្រឡាញ់មនុស្សមានភេទដូចខ្លួន គឺមិនមែនជាបុរសស្រឡាញ់ភេទផ្ទុយគ្នាទេ (Straight man) ។ កាលណាចោទសួរថាហេតុអ្វីមនុស្សប្រុសមានមុខមាត់ធម្មតាម្តេចទៅស្នេហាមនុស្សប្រុសម្នាក់ទៀត គេតែងឆ្លើយថាវាគ្មានអ្វីមិនធម្មតានោះទេចំពោះខ្លួនគេ។ ប៉ុន្តែមនុស្សជាច្រើន មើលឃើញថាគេពិបាកទទួល gays ជាមនុស្សធម្មតាណាស់។

ចំណែកឯ transvestites និង trans-sexual វិញ ចាត់ទុកខ្លួនពួកគេនឹងត្រូវបានសហគមន៍ gay ចាត់ទុកជាស្ត្រី ។ ជាទូទៅពួកគេមានអារម្មណ៍ថា ពួកគេជាស្ត្រីកើតមកក្នុងរាងកាយបុរស ។ ហើយក្នុងឋានៈជាស្ត្រីពួកគេស្រឡាញ់បុរសត្រឹមត្រូវ (Straight man) ហើយមិនស្រឡាញ់បុរសក្លែងភេទ (gay man) នោះទេ ។

តាមពិតពិភពលោក គឺជាកន្លែងមួយឯកោ ត្រម៉ង់ត្រមោច និងជាសត្រូវសម្រាប់ពួក transvestites និង trans-sexuals ។ វាជារឿងពិបាកសម្រាប់ពួកគេដើម្បីបានទំនាក់ទំនងមួយមានអត្ថន័យ ពីព្រោះមានបុរសត្រឹមត្រូវតិចតួចណាស់ដែលចង់ប្រឈមមុខជាមួយរឿងអាម៉ាស់នៅក្នុងសង្គម ហើយនិងសេចក្ដីលំបាកខាងផ្លូវអារម្មណ៍ភេទ ដែលកើតមកពីមានដៃគូជាមនុស្ស transvestite គឺមនុស្សប្រុសស្លៀកពាក់ជាស្រី ។

តើអ្វីជាមូលហេតុ នាំឱ្យមនុស្សម្នាក់ទៅជា gay ? យោងតាមអ្នកស្រាវជ្រាវខ្លះថា ទំនាញផ្លូវកាម និងអារម្មណ៍រំភើបទៅរកដៃគូម្នាក់មានភេទដូចគ្នា គឺជាចរិតលក្ខណៈ ហ្សែនទិក (a genetic trait) ទោះបីកត្តាសង្គម និងការចិញ្ចឹមបីបាច់ ត្រូវបានគេគិតផងដែរថា បានដើរតួក្នុងរឿងនេះ ។ ការរួមមេត្តសង្វាសភេទដូចគ្នាមិនមែនជាវិបត្តិ (disorder) វេជ្ជសាស្ត្រ ឬចិត្តសាស្ត្រទេ ទោះបីមានមនុស្សជាច្រើនបានចាត់ទុកថាមិនប្រក្រតីក៏ដោយ ។ ការរួមគ្គសង្វាសភេទដូចគ្នា ត្រូវបានគេយកចេញពីបញ្ជីនៃវិបត្តិសរសៃប្រសាទ (mental disorders) នៅក្នុងដើមទសវត្សឆ្នាំ១៩៧០ កាលដែលគេបានដឹងច្បាស់ថា អ្នករួមមេត្តសង្វាសភេទខុសគ្នាជាមនុស្សមានសុខភាពផ្លូវចិត្តល្អ ដូចអ្នករួមមេត្តសង្វាសភេទខុសគ្នាដែរ ។ ពួកគេមានសមត្ថភាពដូចគ្នាដើម្បីបំពេញមុខងារក្នុងសង្គម ដើម្បីសម្រេចគោលដៅ ដើម្បីបំពេញតម្រូវការរបស់ខ្លួន និងដើម្បីអភិវឌ្ឍសញ្ញានៃអត្តសញ្ញាណកម្ម(a sense of

identity ) ។

ប៉ុន្តែចំណូលចិត្តសម្លៀកបំពាក់ភេទផ្ទុយគ្នា ត្រូវបានចាត់ទុកជាវិបត្តិសរសៃប្រសាទ ពីព្រោះអ្នកចូលចិត្តសម្លៀកបំពាក់ភេទផ្ទុយគ្នា មានអារម្មណ៍ថាខ្លួនជាប់អន្ទាក់ក្នុងរូបរាងកាយមនុស្សប្រុសបណ្តាលឱ្យមានភាពច្របូកច្របល់ផ្លែក្នុងជាច្រើន ចំណែកឯបុរសដែលបានក្លែងខ្លួនធ្វើស្រី គឺមានផាសុកភាព ទាំងស្រុងជាមួយនឹងភាពបុរសរបស់គេ។

ទោះបីអ្នករួមមគ្គសង្វាសភេទដូចគ្នា អាចបានទទួលការកែតម្រង់ទិសផ្លូវភេទរបស់ពួកគេក្តី ក៏សង្គមមិនអាចត្រៀមខ្លួនទទួលពួកគេទេ។ ពួកគេអាចរៀបចំខ្លួនដើម្បីចែករំលែកគំនិត និងអារម្មណ៍របស់ពួកគេជាមួយសមាជិកគ្រួសារ និងមិត្រភក្តិជិតស្និទ្ធ ប៉ុន្តែមិនធ្វើដូច្នេះជាសាធារណៈទេ។ មនុស្សសេពកាមជាមួយមនុស្សមានភេទដូចគ្នាម្នាក់ អាចធ្វើដំណើរឆ្លងកាត់ដំណាក់កាលជាច្រើន មុននឹងមកដល់ការព្រមព្រៀង ជាមួយខ្លួនឯង (ជាបុរស ឬស្ត្រី)។ ពួកគេប្រហែលជាមិនអាចធ្វើអ្វីមួយបានដើម្បីកែប្រែ " លក្ខខណ្ឌ " របស់ពួកគេទេ, ហើយយើងក៏មិនគប្បីធ្វើវិភាគទានដល់សម្ពាធសង្គមកំពុងគ្របសង្កត់ ដែលចាប់បង្ខំឱ្យពួកសេពកាមជាមួយភេទដូចគ្នាបិទបាំងលាក់បំពួនអត្តៈពិតរបស់ពួកគេកាន់តែជ្រៅទៅទេ ។តាមទស្សនៈរបស់ព្រះពុទ្ធសាសនាអំពើសេពកាមប្រភេទនេះ អាចចាត់ទុកជាកិរិយាខុសឆ្គងក្នុងការរួមភេទ ចំពោះអ្នកទាំងឡាយដែលខិតខំលះបង់កាមសុខដើម្បីដឹកនាំជីវិតជាអ្នកបួស។ ចំពោះមនុស្សផ្សេងទៀត អំពើនេះអាចត្រូវចាត់ទុកជាការបំពានក្នុងផ្លូវភេទ។

## ការបំបៅដោះកូន និងអត្ថប្រយោជន៍របស់វា

ឥរិយាបថថ្មី របស់មាតា ជាអ្នកធ្វើការងារចំពោះកូនៗ របស់គេ កំពុង

ពង្រឹងសេចក្តីមេត្តា ករុណាចំពោះកូន មានមកអស់កប្បកល្បហើយដែលកូន១ សង្ឃឹមចង់ឱ្យមាន។ ការជំនួសការបំបៅកូនដោយដោះ ដោយការបំបៅកូនដោយដប គឺជាមូលហេតុមួយផ្សេងទៀត។ ពេលដែលម្តាយបំបៅកូនដោយដោះ ហើយឱបកូនក្នុងដៃ សេចក្តីស្រឡាញ់ថ្នាក់ថ្នមរវាងកូននិងម្តាយ ប្រែក្លាយទៅជាមានទំហំធំធេងយ៉ាងច្រើន។ ម្តាយចិញ្ចឹមកូនដោយដោះ តាមរយៈសភាវគតិរបស់ខ្លួនជាម្តាយ ជាញឹកញួយរមែងទទួលនូវសេចក្តីសោមនស្សដ៏ធំសម្បើមអំពីការដឹងថា ខ្លួននាងកំពុងផ្តល់ឱ្យទារកនាង, តាមដូចដែលធម្មជាតិចង់ឱ្យធ្វើ, នូវវត្ថុអ្វីមួយជារបស់នាងផ្ទាល់ ដែលគ្មានអ្នកណាផ្សេងអាចឱ្យបាន។ ឥទ្ធិពលដែលម្តាយមានទៅលើកូនរមែងដុះដាលដោយប្រការយ៉ាងនេះហើយប្រែក្លាយទៅជាឥទ្ធិពលកាន់តែមានអានុភាពច្រើនឡើងទៀត។ ក្រោមកាលៈទេសៈបែបនេះ សេចក្តីអាណិតអាសូរកូន ភាពជិតស្និទ្ធគ្នា និងសេចក្តីគោរពស្តាប់ដំបូន្មានក្នុងគ្រួសារកាន់តែបានលើកកំពស់ឥតឈប់ឈរ។

ទឡ្ហីករណ៍ប្លែក១ត្រូវបានលើកឡើងដើម្បីបញ្ចុះបញ្ចូលម្តាយទាំងឡាយឱ្យជឿថា " ទឹកដោះគឺប្រសើរណាស់ "។ ហេតុផលទាំងឡាយរួមមានទាំងអត្ថ-ប្រយោជន៍ខាងសរីរសាស្ត្រ ទាំងអត្ថប្រយោជន៍ខាងចិត្តសាស្ត្រសម្រាប់ក្មេង និងម្តាយផងដែរ។ ជាតិប្រូតេអ៊ីន និងគ្រឿងផ្សំផ្សេងទៀតនៅក្នុងទឹកដោះមនុស្ស ខុសប្លែកខាងគុណភាពអំពីជាតិប្រូតេអ៊ីននៅក្នុងទឹកដោះគោ។ ទឹកដោះមនុស្សត្រូវបានចំរាញ់អស់មេរោគ ហើយនិងមិនទទួលរងនូវការឆ្លងរោគទេ។ កូនក្មេងចិញ្ចឹមដោយទឹកដោះមនុស្ស ធន់ទ្រាំនឹងជំងឺនិងការឆ្លងជំងឺ។ ពួកក្មេងទាំងនោះ មិនសូវរងប្រតិកម្ម អាល់លែហ្ស៊ីក (allergic reactions)ទេ។ ការចិញ្ចឹមកូនដោយទឹកដោះមនុស្ស អស់ប្រាក់តិចជាងការទិញទឹកដោះដាក់ដបចិញ្ចឹមកូន។ ការចិញ្ចឹមកូនដោយដោះនាំ

ឱ្យមានភាពជិតស្និទ្ធខាងផ្លូវចិត្តមួយយ៉ាងខ្ពស់ ដែលផ្តល់នូវអត្ថប្រយោជន៍ខាង អារម្មណ៍រំភើប និងមនោសញ្ចេតនា លើសវិធីចិញ្ចឹមកូនផ្សេងទៀត ។ការចិញ្ចឹមកូនដោយទឹកដោះជួយសម្រួលផងដែរដល់ការរីកចម្រើនទំនាក់ទំនង និងសម្ព័ន្ធភាពម្តាយកូន ។

ការចិញ្ចឹមកូនទើបកើត ដោយទឹកដោះម្តាយងាយស្រួលជាងនិងអស់ពេលតិចជាងការចិញ្ចឹមកូនដោយដបទឹកដោះ ។ គេមិនចាំបាច់រម្ងាប់មេរោគ និងលាងដបទេ ។ ការផ្តល់ទឹកដោះមានត្រៀមជាស្រេចកាលណាទារកត្រូវការទឹកដោះ ។ គេបានឃើញថាទារក ដែលគេចិញ្ចឹមដោយទឹកដោះ មិនសូវយំទេក្នុងបណ្តាខែក្រោយៗមកនៃឆ្នាំដំបូង បើប្រៀបធៀបជាមួយទារកដែលចិញ្ចឹមដោយដប ។ ចូរចងចាំថា គ្មានអ្វីប្រសើរជាងសេចក្តីស្នេហារវាងឪពុក-ម្តាយនិងកូនទេ ។ ចំណាយពេលខ្លះសម្រាប់ទារករបស់លោកអ្នក គឺប្រាកដជាមានតម្លៃដោយពិត ។

ក្នុងអំឡុងថ្ងៃដំបូងៗបន្ទាប់ពីការកើត ការចិញ្ចឹមកូនដោយដោះផ្តល់ឱ្យទារកនូវអត្ថប្រយោជន៍នៃទឹកដោះដំបូង (the benefits of colostrum) ។ ទឹកដោះដំបូង ( colostrum ) គឺជាសារធាតុមុនទឹកដោះ ( Pre-milk substance ) បញ្ចេញដោយដោះម្តាយ រហូតដល់ទឹកដោះផលិតបាន តាមធម្មតាប្រហែល ថ្ងៃទីពីរ ឬទីបីក្រោយកំណើតទារក ។ ទឹកដោះដំបូងសម្បូរជីវជាតិគ្រប់មុខ សម្រាប់សេចក្តីត្រូវការជាសារវន្តរបស់ទារក ។

ទឹកដោះម្តាយផ្តល់ឱជារស និងវីតាមីនគ្រប់យ៉ាងដល់សេចក្តីត្រូវការរបស់ទារក យ៉ាងហោចណាស់សម្រាប់ប្រាំមួយខែដំបូងក្រោយពេលកើត ។ ទឹកដោះម្តាយមានផ្ទុកកត្តាការពារ និងធន់ទ្រាំនឹងជំងឺ ដែលជួយបញ្ចៀសជំងឺ និង *អាល់ល័ែរហ្ស៊ី*ជាច្រើនមុខ( ពោលគឺរោគកើតពីប្រតិកម្មទៅនឹងសារធាតុអ្វីមួយ) ។ លើកលែងតែក្នុង

ករណីធ្ងន់ធ្ងរដូចជាម្ដាយមានមេរោគអេដស៍ (Aids) ហើយដែលម្ដាយអាចចម្លងទៅដល់ទារក នោះពុំមានអ្វីពិតប្រាកដយកមកជំនួសទឹកដោះម្ដាយបានឡើយ ។

ជាមួយគ្នានេះការប៉ះពាល់រូបកាយជាមួយម្ដាយបន្ថែមសេចក្ដីសោមនស្សរីករាយដល់ការបៅដោះយ៉ាងពិតប្រាកដ ។ អាជ្ញាធរទាំងឡាយនៅក្នុងវិស័យផ្សេងៗពាក់ពន្ធ័ការអភិវឌ្ឍន៍កុមារ បានទទួចថា ដោះម្ដាយគឺជាមាតាជាទីគាប់ចិត្តតែមួយគត់សម្រាប់ចិញ្ចឹមកូនក្មេង ។ ការចិញ្ចឹមកូនដោយដោះ ត្រូវបានតម្រូវដោយលោកវេជ្ជបណ្ឌិតជាច្រើនរូប គេជឿថាវាផ្ដល់អត្ថប្រយោជន៍ដល់ទារកខាងសរីរៈ ក៏ដូចជាខាងអារម្មណ៍ផ្លូវចិត្ត ដោយសារតែអត្ថប្រយោជន៍ដ៏សំខាន់ដែលចេញមក ពីសេចក្ដីសោមនស្សផ្ទាល់របស់មាតា ក្នុងការចិញ្ចឹមទារករបស់ខ្លួន ។ ទារកត្រូវការបបោសអង្អែល ថ្នាក់ថ្នម ត្រូវការពេលវេលាច្រើន ហើយនិងបរិយាកាសសម្រាកលំហែបីដូចជាត្រូវការទឹកដោះផ្ទាល់ដូច្នោះដែរ ។

លក្ខណៈជាប្រពៃណីនេះគឺមានសេចក្ដីសុខ និងសេចក្ដីចម្រើនដល់កុមារ ។ គឺវាអាស្រ័យលើម្ដាយឪពុក ជាពិសេសអាស្រ័យលើម្ដាយដែលត្រូវផ្ដល់ឱ្យកូនៗនូវសេចក្ដីស្នេហា ការថែទាំ និងសេចក្ដីអាណិតអាសូរ ទុកដូចជាលាភពេញសិទ្ធិរបស់ពួកគេ ។ ម្ដាយត្រូវទទួលខុសត្រូវចំពោះកូន ដែលក្លាយទៅជាកូនល្អ ឬកូនខិលខូច ។ ដូច្នេះម្ដាយអាចជួយកាត់បន្ថយបទល្មើសយុវវ័យ ។

អ្នកដែលដឹកនាំជីវិតរបស់គេប្រឆាំងនឹងធម្មជាតិ ត្រូវប្រឈមមុខនឹងផលវិបាក ឬមួយខាងផ្នែករូបកាយ ឬមួយខាងផ្នែកផ្លូវចិត្ត ។

### ការពន្យារកំណើត

( Birth Control )

ភាពជាឪពុកម្ដាយមានផែនការ ឬភាពជាឪពុកម្ដាយស្ម័គ្រចិត្តក្រោមកម្ម-

វិធីផែនការកម្មគ្រួសារ យោងទៅរកការរៀបចំឱ្យមានផ្ទៃពោះ (*ឬមានគភ៌*) តាមប្រាថ្នានៅក្នុងរង្វង់គ្រួសារ ហើយភាពជាឪពុកម្ដាយមានផែនការ ឬស្មគ្រចិត្តដូចនេះ ត្រូវបានចាត់ទុកថាជាការត្រួតត្រាកំណើត ឬការពន្យារកំណើត។ ភាពជាឪពុកម្ដាយមានផែនការទាក់ទងទៅនឹងការធ្វើនិយតកម្ម និងការទុកចន្លោះកំណើតទារក ដោយមធ្យោបាយផ្លូវច្បាប់ និងអភិសមាចារ អាស្រ័យលើសុខភាព លក្ខខណ្ឌសេដ្ឋកិច្ច និងកាលៈទេសៈរបស់ប្ដី និងប្រពន្ធ។

គេត្រូវលើកយកមកពិចារណា នូវហេតុការណ៍ ដែលថាអត្រាពន្យារកំណើត នាំទៅកាន់ជីវភាពរស់នៅមានសុវត្ថិភាព។ កំណើនប្រជាជនយ៉ាងឆាប់ គឺជានិន្នាការមួយដ៏គ្រោះថ្នាក់ដែលបង្កើតឱ្យមានបញ្ហា ក្រោយពេលប្រជាជនកំពុងដើរឆ្ពោះទៅកាន់ភាពគ្រប់គ្រាន់ និងជីវភាពមានលំនឹង។

នៅទ្វីបអាស៊ីជាទីដែលជំនាន់មនុស្សបន្តរស់នៅក្នុងស្ថានភាពឱនថយ វាជាការត្រឹមត្រូវមួយដើម្បីចាប់យកអត្ថប្រយោជន៍ផែនការកម្មគ្រួសារ រហូតមកដល់ពេលនេះវាមិនទាន់មានអ្វីជាទំនាស់ជាមួយបញ្ហាសហគមន៍ទេ។ ប្រទេសមួយដែលអាចទ្រទ្រង់ខ្លួនឯងបាន ទទួលបានសេរីភាពដ៏ធំបំផុត។

វាគ្មានហេតុផលណាមួយទេនាំឱ្យពុទ្ធសាសនិកជន ជំទាស់នឹងការពន្យារកំណើត។ ពុទ្ធសាសនិកជនមានសេរីភាព និងប្រើប្រាស់វិធីណាមួយក្នុងបណ្ដាវិធីថ្មី ឬចាស់ដើម្បីបញ្ចៀសការមានគភ៌។ អ្នកដែលជំទាស់ទៅនឹងការពន្យារកំណើតដោយនិយាយថា អំពើនេះប្រឆាំងនឹងច្បាប់របស់អាទិទេព ត្រូវតែយល់ឱ្យច្បាស់ថាទស្សនៈរបស់ពួកគេទាក់ទងទៅនឹងបញ្ហានេះ គឺមិនសមហេតុផលទាល់តែសោះ។ នៅក្នុងការពន្យារកំណើតអ្វីដែលគេធ្វើ គឺដើម្បីបញ្ចៀសការកកើតជាជីវិតមួយហើយដោយប្រការយ៉ាងនេះមិនមានការសម្លាប់ពាក់ព័ន្ធទេ។

## ការរំលូតកូន

ទោះបីមនុស្សម្នាក់មានសេរីភាពធ្វើផែនការគ្រួសារមួយ អនុលោមទៅតាមជំនឿស៊ប់របស់ខ្លួនផ្ទាល់ក៏ដោយ ប៉ុន្តែការរំលូតកូនមិនមានហេតុ-ផលកែតម្រូវបានទេ។ អំពើនេះគឺជាកំហុសពីព្រោះវាពាក់ពន្ធ័នឹងការកំចាយ ឬការបំផ្លាញជីវិតមួយ ទោះមើលឃើញក្តី ឬមើលមិនឃើញក្តី។

ពាក្យរំលូតកូនរំលឹកឱ្យឃើញរូបភាពទាំងឡាយនៃស្ត្រីក្មេងៗឥតក្តីសង្ឃឹម និងឆ្មបរំលូតកូនលួចលាក់។ ចំពោះមនុស្សជាច្រើន ពាក្យនេះមានន័យសម្គាល់អំពើខុសច្បាប់និងឧក្រិដ្ឋផងដែរ។ នៅក្នុងប្រទេសលោកខាងលិចដែលរីកចំរើន បញ្ហានេះត្រូវបានគេដាក់បញ្ចូលក្នុងនយោបាយទៀតផង។

ការរំលូតកូនត្រូវបានគេឱ្យនិយមន័យថា ការបញ្ចេញឬទម្លាក់កំណកំណើតទារកតាមទ្វារយោនី កើតឡើងដោយមធ្យោបាយចៃដន្យ ឬដោយដាក់ថ្នាំទម្លាក់ មុនពេលកំណកំណើត (foetus) អាចមានជីវិតដោយខ្លួនឯងផ្ទាល់។ តាមពាក្យវេជ្ជសាស្ត្រ ការរំលូតកូន គឺជាការបញ្ចប់ភាពមានគភ៌រហូតដល់សប្តាហ៍ទី២៨ នៃការពរពោះ។ ក្រោយសម័យកាលនេះ កំណកំណើតទារក ត្រូវបានគេចាត់ទុកតាមក្បួនវេជ្ជសាស្ត្រថាអាចមានជីវិតរស់បាន ឯការរំលូតណាមួយនៅពេលក្រោយនេះ នៃតួអង្គមនុស្សមិនទាន់កើត អាចកើតមកហើយរស់ ឬកើតមកហើយស្លាប់។

នៅក្នុងច្បាប់ កាលណាការរំលូតកូន ត្រូវបានប្រព្រឹត្តឡើងដោយបំណងព្យាបាទ ការរំលូតកូននេះក្លាយជាទោសឧក្រិដ្ឋ ហើយភាគីប្រព្រឹត្តអំពើនេះ អាចត្រូវគេប្តឹងចោទប្រកាន់ ហើយត្រូវទទួលការផ្តន្ទាទោស។ កាលណាការរំលូតកូនណាមួយ បណ្តាលឱ្យស្ត្រីស្លាប់ ទោសកំហុសត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ។

បញ្ហារំលូតកូនបានឋិតនៅ ជារឿងចម្រូងចម្រាស់ជានិច្ច ប៉ុន្តែចំពោះស្ត្រីដែលប្រឈមមុខនឹងការមានផ្ទៃពោះមិនចង់បាន, រឿងគឺមិនមែនខុសច្បាប់ ហើយក៏មិនមែននយោបាយដែរ ។ វាជារឿងផ្ទាល់ខ្លួន ហើយជារឿងដែលត្រូវតែដោះស្រាយយ៉ាងប្រញាប់ទោះត្រូវចំណាយអ្វីក៏ដោយ ។ ក្រោមកាលៈទេសៈខ្លះស្ត្រីទាំងឡាយឋិតក្នុងស្ថានភាពអស់សង្ឃឹម ដូចនេះអាចត្រូវបង្ខំចិត្តងាកទៅរកការរំលូតកូនចោល ។ ប៉ុន្តែស្ត្រីទាំងនោះមិនគប្បីកែតម្រូវអំពើរំលូតកូននោះទេ ពីព្រោះទោះជាតាមវិធីណាក៏ដោយ គេនឹងត្រូវប្រឈមមុខនឹងផលវិបាកអាក្រក់នៃការប្រព្រឹត្តអំពើកាចសាហាវមួយបែបនេះ ។

នៅក្នុងប្រទេសនេះ ( ម៉ាឡេស៊ី) ការបញ្ចប់ភាពមានផ្ទៃពោះ ត្រូវបានគេអនុញ្ញាតិ តែកាលណាគេដឹងច្បាស់ថាសុខភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ម្តាយឋិតក្នុងគ្រោះថ្នាក់ ។ នីតិវិធីត្រូវបានគេយោងទៅរកការរំលូតកូនព្យាបាលរោគ ហើយកិច្ច-ការនេះ ទាមទារឱ្យចេញវិញ្ញាបនប័ត្របញ្ជាក់អំពីវេជ្ជបណ្ឌិតពីរនាក់ ។ សំណូមពរផ្សេងណាមួយ ដើម្បីរំលូតកូនដោយប្រើថ្នាំទម្លាក់ នឹងជាអំពើប្រឆាំងច្បាប់ ។

គោលការណ៍របស់សាសនា មិនគប្បីចុះចាញ់សោះឡើយ ដើម្បីបំពេញចិត្តមនុស្សជាតិ ។ ផ្ទុយទៅវិញគោលការណ៍ទាំងនោះ ត្រូវតែឈរវឹងមាំដើម្បីសុខ-មាលភាពមនុស្សជាតិជារួម ។

## អំពើឃោរឃៅក្នុងគ្រួសារ

បញ្ហានៃអំពើឃោរឃៅនៅក្នុងគ្រួសារ កំពុងប៉ះពាល់ដល់គ្រួសារទាំងឡាយ ជាពិសេសក្នុងក្រុមគ្រួសារមានចំណូលប្រាក់ទាប ហើយនៅក្នុងបញ្ហានេះ បានឡើងដល់សមាមាត្រដ៏គួរឱ្យភ័យព្រួយ ។ វាបានក្លាយជាការងារចាំបាច់ សម្រាប់

រដ្ឋាភិបាល (ម៉ាឡេស៊ី) ដើម្បីព្រាងច្បាប់ស្តីពីអំពើហោរហៅក្នុងគ្រួសារដែលត្រូវបានសភាអនុមត័កាលពីខែមិថុនា ឆ្នាំ១៩៩៦។

ភស្តុតាងបានបង្ហាញថា ភរិយាទុរន់ទុរាម្នាក់ ក្នុងករណីជាច្រើននៅតែស្រឡាញ់ប្តីរបស់នាង ទោះបីត្រូវរងការរំលោភបំពានសព្វបែបយ៉ាង ដែលនាងដាក់កំហុសទៅលើការស្រវឹងស្រា ល្បែង ស្រី និងបញ្ហាលុយកាក់ជាប្រចាំ។ នេះជាតថភាពនៃបញ្ហាអំពើហោរហៅក្នុងគ្រួសារ ដែលស្ត្រីជាច្រើនកំពុងប្រឈមមុខសព្វថ្ងៃ។ ស្ត្រី ទុរន់ទុរាជាច្រើននាក់ សុខចិត្តអត់ធ្មត់រងអំពើហោរហៅនេះពីព្រោះនាងមានជំនឿ មុតមាំថាការសងសឹកណាមួយចេញពីភាគីនាង អាចនាំទៅដល់ការបាត់បង់នូវការថែរក្សាកូនរបស់នាង សិទ្ធិទទួលផ្ទះអាពាហ៍ពិពាហ៍ជាមរតកនិងសិទ្ធិទទួលសន្តិសុខហិរញ្ញវត្ថុក្នុងទ្រង់ទ្រាយណាមួយ។

ជាទូទៅសាធារណជនប្រកាន់ទស្សនៈថា អំពើហោរហៅក្នុងគ្រួសារ គឺជារឿងមួយដែលមិនសក្តិសមមានអន្តរាគមន៍ពីខាងក្រៅណាមួយឡើយ។ ជាឧទាហរណ៍ អ្នកជិតខាងទាំងឡាយនឹងមកជួយស្ត្រីម្នាក់ភ្លាម កាលណាគេឮនាងស្រែកព្រោះការវាយដំជាប្រចាំរបស់ប្តីនាង មនុស្សទាំងឡាយផ្សេងទៀតមិនចង់ធ្វើអន្តរាគមន៍ទេ ពីព្រោះគេចាត់ទុករឿងនោះជារឿងគ្រួសារផ្ទាល់ខ្លួន។ រហូតមកដល់ពេលថ្មីៗនេះ ទស្សនៈនេះក៏ត្រូវបានប៉ូលីសប្រកាន់យកដែរ។ ប៉ុន្តែក្រោមច្បាប់ប្រឆាំងអំពីហោរហៅក្នុងគ្រួសារ ( The Domestic Violence Act), ភារកិច្ចរបស់ប៉ូលីសឥឡូវនេះមាន រួមបញ្ចូលការជូនដំណើរភរិយាត្រូវប្តីបំពារបំពានទៅផ្ទះដើម្បីប្រមូលយកទ្រព្យ សម្បត្តិរបស់នាង ប្រសិនបើមានការចាំបាច់។ អ្វីដែលភរិយារងការបំពារបំពានសុំឱ្យជួយ គឺកិច្ចការពារនៅក្រោមច្បាប់ ហើយមិនមានច្រើនទេ ដែលសុំឱ្យប្តីរបស់ពួកគេត្រូវទទួលទោសនោះ។

ច្បាប់ផ្ដល់កិច្ចការពារដល់ភរិយារងអំពើបំពារបំពាន ដោយមិនធ្វើឱ្យ គ្រួ-សារបែកបាក់។ ឋិតនៅក្រោមច្បាប់ គេអាចប្ដឹងទៅតុលាការឱ្យហាមឃាត់សហព័ទ្ធដែលបំពារបំពានមិនឱ្យទៅផ្ទះអាពាហ៍ពិពាហ៍ (matrimonial home) ឱ្យផ្ដល់ការឧបត្ថម្ភដល់សហព័ទ្ធដែលរងគ្រោះ និងកូន ព្រមទាំងប្រគល់ឱ្យនាងថែទាំកូន។ ច្បាប់កំណត់អំពើឃោរឃៅក្នុងគ្រួសារ ជាបទល្មើសមួយត្រូវផ្ដន្ទាទោស។

*មនុស្សប្រមាទខាតគ្រប់យ៉ាង*
*ធ្វើអ្នកបួសក៏មិនកើត*
*ធ្វើគ្រហស្ថក៏មិនកើត។*

សម្ដេចព្រះធម្មលិខិតឧត្ដមប្រឹក្សា
វជិរប្បញ្ញោ **ល្វី ឯម**

# ពុទ្ធសាសនានៅក្នុងទ្វីបអាស៊ីបច្ចុប្បន្ន

ដោយៈ ព្រះតេជគុណ
បណ្ឌិត ក.**ស្រីធម្មានន្ទ នាយកមហាថេរ**
សង្ឃនាយកនៃប្រទេសម៉ាឡេស៊ី

ជាងម្ភៃប្រាំសតវត្សកន្លងទៅហើយ ដែលពុទ្ធសាសនាបានជះឥទ្ធិពលដ៏ធំសម្បើមមកលើវប្បធម៌ និងអារ្យធម៌ក្នុងតំបន់ដ៏ធំទូលាយនៃទ្វីបអាស៊ី។ ដោយការផ្សព្វផ្សាយទៅ បីដូចជាខ្យល់ជំនោរដ៏ស្រទន់មកលើទ្វីបអាស៊ី សាសនាប្រកបដោយសន្តិភាព និងករុណាធម៌នេះ បានធ្វើឱ្យជីវភាពនៃមនុស្សច្រើនលានរាប់មិនអស់ក្នុងដែនដីជាច្រើន សម្បូរសប្បាយដោយផ្តល់ដល់មនុស្សទាំងនោះ មិនគ្រាន់តែមាគ៌ានៃជីវិតដ៏ទន់ភ្លន់ និងសុខដុមប៉ុណ្ណោះទេ ប៉ុន្តែដោយលើកទឹកចិត្តដល់ពួកគេឱ្យចេះច្នៃប្រឌិតបង្កើតទម្រង់វប្បធម៌ប្លែកៗមានៈ គំនូរ ចម្លាក់ តន្ត្រី និងស្ថាបត្យកម្មថែមទៀត។ សាសនានេះ បានបង្រៀនមនុស្សឱ្យចេះរស់នៅក្នុងសន្តិភាពជាមួយគ្នាទៅវិញទៅមក ឱ្យចេះគោរពជំនឿទាំងឡាយរបស់អ្នកដទៃ ឱ្យចេះផ្តល់កិត្តិយសដល់ឪពុកម្តាយ រាមច្បង និងឱ្យចេះថែរក្សាបរិស្ថាន។

ប៉ុន្តែសព្វថ្ងៃ មាគ៌ានៃជីវិតពីបុរាណដ៏ប្រសើរនេះ កំពុងទទួលរងការគំរាមកំហែង ហើយរបៀបរបបវប្បធម៌ និងសង្គមកំពុងតែស្រុតចុះ តាមរយៈការបញ្ចូលគំនិត និងជំនឿទាំងឡាយដែលចម្លែកក្រៅពីមាគ៌ាវប្បធម៌ផ្ទាល់ខ្លួននៃជីវិតរបស់យើង។

ក្នុងពេលថ្មីៗនេះពុទ្ធសាសនិកជនអ្នកយល់ដឹងបានកត់សម្គាល់ឃើញដោយសេចក្ដីព្រួយបារម្ភថា ចំនួនពុទ្ធសាសនិកជនក្នុងទ្វីបអាស៊ីបានថយចុះក្នុងកម្រិតអាត្រាដ៏គួរឱ្យព្រួយ ជាពិសេសក្នុងចំណោមជំនាន់មនុស្សក្មេងៗ។ មានហេតុ-ផលជាច្រើនចំពោះរឿងនេះ គឺមានហេតុ-ផលទាំងខាងក្នុង និងទាំងខាងក្រៅ។

ពុទ្ធសាសនាកំពុងទទួលរងការគំរាមកំហែង ដោយការបញ្ចូលទស្សនៈសាសនាច្រើនតែធ្វើឡើងតាមរយៈមធ្យោបាយមិនសូវស្មោះត្រង់ ដែលជាទស្សនៈសាសនាកំពុងត្រូវបានបដិសេធច្រើនឡើងៗពីពួកលោកខាងលិចដែលជាមនុស្សមានចំណេះដឹង និងមានការអភិវឌ្ឍន៍ខាងសម្ភារៈ។

ប្រឈមមុខនឹងការរលោះទៅបន្តិចម្ដងៗនៅក្នុងទ្វីបអឺរ៉ុប និងអាមេរិក ទម្រង់ថ្មីៗជាច្រើននៃសាសនាទាំងនោះ កំពុងត្រូវបានបញ្ចូលខ្លួនទៅកាន់តំបន់ក្រីក្រក្នុងប្រទេសតតិយលោក ដែលនៅទីនោះ អវិជ្ជាបានរីករាលដាល។

នៅទ្វីបអាស៊ី ចំណុចដៅនៃក្រុមសាសនាថ្មីៗទាំងនោះ គឺមនុស្សក្មេងៗស្លូតត្រង់ មកពីក្រុមដែលមានចំណេះដឹង មានទ្រព្យសម្បត្តិ ក៏ដូចជាមនុស្ស ទាំងឡាយដែលមិនចេះអក្សរ ហើយក្រីក្រ។ ជាមួយនឹងការប្រើប្រាស់ទូលំទូលាយនូវបច្ចេកវិជ្ជាពតិមាន ក្រុមសាសនាទាំងនោះ កំពុងស្វែងរកការបង្កើនឥទ្ធិពលរបស់ខ្លួនតាមរយៈការផ្សព្វផ្សាយពាក្យកុហកត្រង់ៗ ដោយចេតនាអំពីពុទ្ធសាសនាតាមប្រពន្ធ័អាំងទែរណែត។ វាជាការក្ដៅក្រហាយបំផុត ក្នុងពេលដឹងថាអ្នកចូលសាសនាថ្មីៗត្រូវបានគេប្រើឱ្យធ្វើជាសាក្សី ដែលនៅក្នុងការងារនេះ ពួកគេដៀលត្មះការប្រតិបត្តិចំពោះឪពុកម្ដាយក្នុងនាមនៃពុទ្ធសាសនា ហើយធ្វើការផ្ដល់ពិន្ទុឱ្យសាសនាថ្មីៗរបស់ពួកគេ។ នៅពេលដែលពុទ្ធសាសនិកជនទាំងឡាយ មិនមានប្រាថ្នាដើម្បីជ្រៀតជ្រែក

ជាមួយនរណាម្នាក់ ហើយមានប្រាថ្នាដោយពិតប្រាកដដើម្បីចែករំលែក ជំនឿដ៏ស្មោះត្រង់របស់ខ្លួនជាមួយអ្នកដទៃ យើងមិនអាចអត់ឱនឱ្យបានទេ នៅពេលដែលគេនិយាយកុហកត្រង់ៗ និងមិនអាចកែតម្រូវបាន អំពីសាសនារបស់យើង។ យើងត្រូវប្រើប្រាស់ធនធានទាំងអស់នៅក្រោមការត្រួតត្រារបស់យើងដើម្បីប្រឈមមុខយ៉ាងក្លាហានចំពោះការគំរាមកំហែងពីខាងក្រៅទាំងនោះ។ នៅទីបំផុតយើងត្រូវរំលឹកបន្ទូលរបស់មហាអធិរាជ អសោក ដែលបានត្រាស់ថា " *អ្នកណាដែលរំលោភបំពានលើជំនឿអ្នកដទៃ ទន្ទឹមនឹងអួតសរសើរជំនឿផ្ទាល់របស់ខ្លួនគ្រាន់តែបាន ទទួលជោគជ័យ ក្នុងការផ្តន្ទាទោសសាសនាផ្ទាល់ខ្លួនប៉ុណ្ណោះ* "។

ល្បិចកលទូទៅ ដែលគេកំពុងប្រើជាទូទៅនៅពេលថ្មីៗនេះ គឺការបង្ខំមនុស្សដែលបាត់ស្មារតីពាក់កណ្តាល ឬឈឺជិតផុតដង្ហើមទៅហើយ ឱ្យទទួលយកអាទិទេពរបស់ពួកគេ ដោយគេសន្យាថាបាបទាំងអស់របស់ពួកគេនឹងត្រូវលាងជម្រះអស់ហើយ ពួកគេនឹងបានទៅកាន់ឋានសួគ៌ដោយសេរី។ បើពួកគេមិនព្រមវិញ ពេលនោះមនុស្សស្លូតត្រង់ទាំងនោះ នឹងត្រូវគំរាមដោយភ្លើងនរក នៅជាតិក្រោយ។ វាជាការពិបាកសម្រាប់មនុស្សជានា ម្នាក់ដើម្បីយល់បានថា តើជឿយ៉ាងដូចម្តេចកើត? ឧទាហរណ៍ ឧក្រិដ្ឋជនម្នាក់ដែលបានធ្វើឃាតឪពុកម្តាយបង្កើតរបស់ខ្លួនដោយមានចេតនា អាចត្រូវបានសណ្តោសទោស ដោយគ្រាន់តែប្តូរសាសនារបស់ខ្លួនយ៉ាងសាមញ្ញ។ គេអាចសន្និដ្ឋានបានយ៉ាងស្រួលថា គេអាចប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយបានប្រសិនបើគេគ្រាន់តែជឿលើអាទិទេពនៅខណៈពេលចុងក្រោយ។ ពេលនោះប្រសិនបើមាននរណាម្នាក់ចូលសាសន៍ក្រុមសាសនានោះ ចូលទៅរកគ្រួសារអ្នកនោះ ហើយស្នើរសុំឱ្យគ្រួសារនោះប្តូរជំនឿសាសនាផងដែរ "ដោយសារសេចក្តី

ស្រឡាញ់ និងការដឹងគុណ" ចំពោះជនដែលបានចែកឋានទៅ ។ ពួកគេបន្តលួងលោមវែងឆ្ងាយទៀតថា អ្នកចែកឋានទៅហើយចង់ឱ្យពួកគេទៅជួបជុំគ្នានៅឋានសួគ៌នាជាតិក្រោយ!

ទាំងនោះគឺជាល្បិចកលខ្លះៗប៉ុណ្ណោះ ដែលពួកមនុស្សទាំងនោះបានប្រើប្រាស់ ដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងឡាយឯទៀតឱ្យចូលកាន់សាសនារបស់ពួកគេ ។ មានការនិយាយតិចតួចណាស់ អំពីការធ្វើចិត្តរបស់ពួកគេឱ្យបានល្អប្រសើរក្នុងការយល់ដឹងពីធម្មជាតិនៃជីវិត និងសុភមង្គល ដោយធ្វើចិត្តឱ្យស្អាតបរិសុទ្ធ។

ប៉ុន្តែគេត្រូវនិយាយដោយភាពស្មោះត្រង់ថា នៅពេលដែលពួកគេ ប្រឈមមុខនឹងការគំរាមកំហែងពីខាងក្រៅ ពុទ្ធសាសនិកជនទាំងឡាយខ្លួនឯងត្រូវតែភ្ញាក់រឭកអំពីភាពទន់ខ្សោយផ្ទៃក្នុងរបស់ខ្លួនដែលធ្វើឱ្យខ្លួនក្លាយទៅជាចំណុចងាយស្រួលសម្រាប់ក្រុមសាសនាទាំងឡាយឯទៀត ។

នៅពេលគេចោទសួរ យុវជនជាច្រើននិយាយថា វិធីទាំងឡាយដែលអ្នកដឹកនាំពុទ្ធសាសនាបានប្រើប្រាស់ ដើម្បីទ្រទ្រង់អត្ថប្រយោជន៍ក្នុងព្រះធម៌របស់ព្រះពុទ្ធគឺហួសសម័យ ហើយលែងសមស្របសម្រាប់សេចក្តីត្រូវការក្នុងសម័យថ្មីហើយ ។ យុវជនសព្វថ្ងៃធុញទ្រាន់ក្នុងការទៅកាន់វត្តអារាម ដើម្បីស្តាប់ធម៌ដែលទេសនាតាមរបៀបសម្តែងហួសសម័យ និងការប្រើប្រាស់ឧបករណ៍ដែលគ្មានទំនាក់ទំនងសោះជាមួយសង្គមថ្មី។ ពួកគេបានឃើញផងដែរនូវអណ្តាប់អណ្តាតង្វាយ ប្រព្រឹត្តធ្វើឡើងក្នុងនាមពុទ្ធសាសនា ថាជាការខ្ជះខ្ជាយប្រាក់កាស ហើយជាការរំខានថែមទៀត ពីព្រោះពួកគេរស់នៅក្នុងយុគសម័យ និងវប្បធម៌មួយផ្សេង។ ប្រឈមមុខនឹងការប្រតិបត្តិសាសនាគ្មានន័យហើយឥតផ្លាស់ប្តូរ ពួកយុវជនគេចូលចិត្តរស់នៅដោយគ្មាន

សាសនា។ ជាពិសេសដោយសារឪពុកម្ដាយ និងរៀមច្បងឯទៀតៗរបស់ពួកគេ មិនសូវចេះដឹង មិនអាចណែនាំពួកគេឱ្យយល់ពីភាពទាក់ទងរបស់ព្រះពុទ្ធសាសនា ទៅនឹងសេចក្ដីត្រូវការរាល់ថ្ងៃរបស់ពួកគេបាន។ ជាងនេះទៅទៀត ទម្រង់សម័យថ្មីនៃសម្ភារៈនិយម និងការទាក់ទាញរបស់ប្រពន្ធ័ផ្សព្វផ្សាយពត៌មាន ធ្វើឱ្យពួកគេចាត់ទុកសាសនា ជាជំនឿខុសហើយឆោតល្ងង់។ ក្នុងករណីជាច្រើន យើងបានបញ្ចូលព្រះពុទ្ធសាសនា និងពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ទុកជាមុខវិជ្ជាសម្រាប់សិក្សា នៅសាលាយ៉ាងសាមញ្ញ ដោយគ្មានបង្កើតទំនុកចិត្ត និងការយល់ដឹងក្នុងសណ្ដានចិត្តរបស់ពួកគេសោះ។មនុស្សជាច្រើន ដែលហៅខ្លួនឯងជាពុទ្ធសាសនិក ក៏មិនអាចមានសមត្ថភាពឆ្លើយតបទៅនឹងការរិះគន់យ៉ាងសាមញ្ញ ដែលគេបានលើកឡើងប្រឆាំងនឹងសាសនាខ្លួនបានផង។ ឧទាហរណ៍ មានគេនិយាយថា "*ព្រះពុទ្ធមិនមែនជាអាទិទេពទេ លោកគ្រាន់តែជាមនុស្សម្នាក់ដែលបានស្លាប់បាត់យូរហើយ។ តើមានប្រយោជន៍អ្វីក្នុងការសំពះព្រះពុទ្ធ ពីព្រោះលោកមិនអាចឱ្យពរ ឬជួយសង្គ្រោះលោកបានទេ*"។ បន្ទាប់មក មានអ្នកខ្លះនិយាយថា "*ពុទ្ធសាសនា មិនមែនជាសាសនាមួយទេ ព្រោះហេតុនោះ ហេតុអ្វីមនុស្សចង់ដើរតាមពុទ្ធសាសនានោះ?*" បន្ទាប់មកទៀតពួកគេនិយាយថា "*ពួកពុទ្ធសាសនិកជន ជាពួកបូជារូបបដិមា ពីព្រោះពួកគេក្រាបសំពះនៅពីមុខពុទ្ធបដិមា*"។ តើមានពុទ្ធសាសនិកជនច្រើនប៉ុណ្ណា ដែលអាចយល់ថាសំណួរទាំងនោះ មិនគ្រាន់តែខុសទេ ប៉ុន្តែគួរឱ្យអស់សំណើចថែមទៀត? ពួកគេមិនយល់ពីគំនិតពុទ្ធសាសនា ដែលគោរពព្រះពុទ្ធទុកជានិមិត្តរូបនៃសេចក្ដីប្រាថ្នាដ៏ខ្ពស់បំផុតរបស់ពុទ្ធសាសនិកជនទេ។ ពុទ្ធសាសនិកជនមិនមែនបន់ស្រន់រូបភាពទេ ប៉ុន្តែថ្វាយសេចក្ដីគោរពចំពោះព្រះពុទ្ធ ដោយយករូបភាព ជាកម្មវត្ថុដើម្បីឆ្លុះបញ្ចាំងលើគុណសម្បត្តិដ៏ឧត្តមរបស់ព្រះអង្គ សំដៅធ្វើឱ្យចិត្តរបស់គេស្ងប់ ដោយអភិវឌ្ឍ

សមាធិ ។ សេចក្តីទាំងឡាយនេះ ត្រូវបានគេបង្រៀនដល់ពុទ្ធសាសនិកជន ទាំងអស់ ដើម្បីឱ្យពួកគេដឹងថា អ្វីទៅជាសាសនា ដែលគេប្រតិបត្តិតាម ដោយពិតប្រាកដ។ ពួកសាសនិកជនត្រូវដឹងនូវវិភាគទានដ៏ថ្លៃថ្លា ដែលព្រះពុទ្ធបានធ្វើ ដើម្បីផ្សព្វផ្សាយ ករុណា និងមេត្តាធម៌ ក្នុងចំណោមមនុស្សជាតិ ។

សូម្បីតែមនុស្សមិនមែនជាពុទ្ធសាសនិក ដែលមិនមានគំនិតលំអៀងក៏ចាត់ទុកព្រះពុទ្ធសាសនា ជាសាសនាទន់ភ្លន់មួយ ពីព្រោះពួកពុទ្ធសាសនិកជន មិនងាកទៅរកអំពើកេងប្រវ័ញ្ចដើម្បីអូសទាញមនុស្សឯទៀតឱ្យចូលពុទ្ធសាសនាទេ ប៉ុន្តែពួកគេប្រតិបត្តិសាសនារបស់ពួកគេដោយមិនរំខានពួកអ្នកជំនឿសាសនាដទៃឡើយ ។ ពុទ្ធសាសនិកជនគោរពជំនឿរបស់អ្នកដទៃ ។ សូម្បីវិហារកាតូលិកបានទទួលស្គាល់ថា ជនមិនមែនគ្រីស្តសាសនិក ក៏អាចទៅកាន់ឋានសួគ៌បានដែរ ដោយគេយល់ព្រមតាមរយៈនេះថា សាសនាទាំងអស់បង្រៀនមនុស្សឱ្យប្រព្រឹត្តល្អ ។ នេះមិនមែនជាបុព្វសិទ្ធិសម្រាប់តែសាសនាមួយប៉ុណ្ណោះទេ ។ នៅពេលដែលពុទ្ធសាសនិក មិនជឿទៅលើអាទិទេពដើម្បីជួយសង្គ្រោះពួកគេ ក៏ពួកគេខិតខំដើម្បីសម្រេចទេវចរិតរបស់ពួកគេដោយដើរតាមមាគ៌ាដ៏ប្រសើរ ប្រាំបីយ៉ាង (អដ្ឋង្គិកមគ្គ) ដែរ ។

ដើម្បីជំនះបញ្ហានេះបាន អ្នកដឹកនាំជាពុទ្ធសាសនិក (ព្រះសង្ឃ និងគ្រហស្ថ) ត្រូវប្រើវិធីសម័យថ្មីដែលពួកគេមាន ដើម្បីបញ្ចូលព្រះធម៌ ។ ការទេសនា ឬការនិយាយស្តីត្រូវបង្កើនការទាក់ទាញចិត្តឱ្យខ្លាំង ហើយទាក់ទងនឹងសេចក្តីត្រូវការសម័យថ្មី ។ សង្ខេបមក ព្រះធម៌គឺ អកាលិកធម៌ (ធម៌គ្មានកាលកំណត់) គ្រាន់តែបែបបទដែលយើងពន្យល់ធម៌ ត្រូវធ្វើឱ្យបានស្របស្រួលទៅនឹងល្បឿននៃការប្រែប្រួលនៅក្នុងសង្គមប៉ុណ្ណោះ ។ ព្រះពុទ្ធអង្គផ្ទាល់ទ្រង់ក៏បានសម្រួលការប្រតិបត្តិពីបុរាណជាច្រើន ឱ្យស្របទៅនឹងមនុស្ស នាសម័យកាលរបស់ព្រះអង្គ ហើយព្រះអង្គ

ក៏បាន បញ្ជាក់យ៉ាងច្បាស់ផងដែរថា សិក្ខាបទបន្ទាប់បន្សំខ្លះ អាចនឹងកែប្រែបាន ដើម្បីឱ្យសមស្របទៅនឹងការប្រែប្រួលនៃពេលវេលា។ ពីព្រោះហេតុនេះយើងត្រូវប្រើបច្ចេកវិជ្ជាសម័យថ្មី ជាពិសេសប្រពន្ធ័ផ្សព្វផ្សាយពត៌មានអេឡិចត្រូនិក ដើម្បីផ្សព្វផ្សាយព្រះធម៌ឱ្យមានប្រសិទ្ធភាពនិងកាន់តែសម្រេចផលបានល្អ។តាមគន្លងនេះយើងអាចផ្សាយទៅដល់មនុស្សជាច្រើន ហើយទប់ស្កាត់ការឃោសនា មួលបង្កាច់ដ៏ច្រើនលើសលប់ ដែលកំពុងតែផ្សព្វផ្សាយទៅ ដោយសាសនាទាំងឡាយដទៃ។ ភិក្ខុសង្ឃ ជាពិសេសត្រូវរៀនប្រើប្រពន្ធ័ផ្សព្វផ្សាយនេះ ហើយត្រូវចំណាយពេល និងពលកម្មរបស់ខ្លួន អនុវត្តភារកិច្ចដ៏ឧត្តុង្គឧត្តមក្នុងការផ្សព្វផ្សាយព្រះសារដ៏វិសេសដែលបានបន្ទុកបណ្តាក់មកលើខ្លួន ដោយព្រះបរមគ្រូក្នុងបែបបទដែលសមស្រប ទៅនឹងយុគសម័យថ្មី។ ជនជាគ្រហស្ថត្រូវធ្វើការយ៉ាងជិតស្និតជាមួយភិក្ខុសង្ឃ ដើម្បីឧបត្ថម្ភលោកក្នុងការងារនេះ។

ព្រឹត្តិការណ៍ដ៏មានសារសំខាន់បំផុតមួយ ក្នុងការដោះស្រាយបញ្ហានេះ គឺសន្និសីទផ្សព្វផ្សាយពុទ្ធសាសនាអន្តរជាតិលើកទីមួយដែលបានប្រព្រឹត្តទៅនៅទីក្រុងក្យូតូ ប្រទេសជប៉ុនក្នុងឆ្នាំ ១៩៥៨។ អ្នកដឹកនាំពុទ្ធសាសនាធំៗមកពីប្រទេសចំនួន ១៧ក្នុងទ្វីបអាស៊ីបានចូលរួមសន្និសីទនេះ។ អ្នកចូលរួម ដែលរួមមាន ទាំង ព្រះសង្ឃដាឡៃឡាម៉ា ផងបានថ្លែងហើយថ្លែងទៀតនូវមនោសញ្ចេតនាថា ពុទ្ធសាសនិកជនជឿដោយស្មោះសរក្នុងសុខដុមភាព អន្តរសាសនា ហើយគ្មាន បំណងណាមួយដើម្បី "ប្តូរជំនឿសាសនា" អ្នកដទៃ ដើម្បីបង្កើនចំនួនអ្នកជឿសាសនារបស់ខ្លួន ដោយប្រើប្រាស់មធ្យោបាយដែលខ្លួនមាន ហើយផ្សព្វផ្សាយ ពាក្យកុហក អំពីសាសនាឯទៀតយ៉ាងសាមញ្ញនោះទេ ។ ពុទ្ធសាសនិកជន មានសេចក្តីកង្វល់ដោយឡែក ពីរបៀបរបប ដែលនៅក្នុងនោះភាពក្រីក្រ និងភាពល្ងង់ខ្លៅត្រូវបានគេកេងប្រវញ្ច័ដើម្បីប្តូរ

ជំនឿពុទ្ធសាសនិកជនស្លូតត្រង់ ហើយបង្អាក់រំខាន វប្បធម៌ និងការប្រតិបត្តិ ពីបុរាណរបស់ពួកគេ។ ប្រទេសជាច្រើនដែលធ្លាប់កាន់ ព្រះពុទ្ធសាសនា កំពុងស្ថិតក្នុងការបាត់បង់ឧត្តមភាពនៃពុទ្ធសាសនារបស់ខ្លួន ដោយសារវិធីគួរឱ្យស្ងប់ខ្ញើម ទាំងនេះដែលពួកគេហៅខ្លួនថា "អេវ៉ង់ហ្សេលិក" បានប្រើ។ សេចក្ដីសម្រេចចិត្តមួយដែលអនុម័តហើយនៅសន្និសីទនោះ ជាពិសេសនៅក្នុងប្រទេសដែលហិនហោចដោយសារសង្គ្រាម និងវិនាសកម្មធម្មជាតិ។ បច្ចុប្បន្ននេះប្រទេសទាំងឡាយដែលមានប្រជាជនជាពុទ្ធសាសនិកច្រើនគឺ ភូមា (៩៥%) ស្រីលង្កា (៧០%) តៃវ៉ាន់ (៦០%) ជប៉ុន (៦៥%) និងថៃ (៩៤%)។

ចំណុចខ្សោយដ៏ធំបំផុតមួយ ក្នុងចំណោមមេដឹកនាំពុទ្ធសាសនា គឺនិន្នាការរបស់មេដឹកនាំសាសនាទាំងនោះ បានចំណាយប្រាក់កាសដ៏ធំសម្បើមទៅលើគម្រោងកសាងយកមុខមាត់ ដូចជា សាងសង់វិហារដ៏ធំស្កឹមស្កៃ និងពុទ្ធបដិមាដ៏ធំៗនៅក្នុងតំបន់ទាំងឡាយដែលវិហារ និងពុទ្ធបដិមា ទាំងនោះមិនមានតម្រូវការចាំបាច់ដោយពិតប្រាកដផង។ មែនហើយវាពុំមានអ្វីខុសដោយពិតប្រាកដ ជាមួយគម្រោងកសាងទាំងនោះទេ ប៉ុន្តែយើងគ្រាន់តែពិចារណាថា តើវាបានកុសលច្រើនប៉ុណ្ណា បើប្រាក់កាសនោះត្រូវបានយកទៅប្រើប្រាស់ដើម្បីកសាង មន្ទីរពេទ្យ សាលារៀន មជ្ឈមណ្ឌលបង្រៀនធម៌ មណ្ឌលជនកំព្រា ផ្ទះសម្រាប់មនុស្សចាស់ ជាដើម។ល។ ជាពិសេសនៅប្រទេសកាន់ព្រះពុទ្ធសាសនា។ នៅក្នុងគន្លងនេះ យើងអាចថែទាំពុទ្ធបរិសទ័របស់យើងផ្ទាល់កុំឱ្យពួកគេធ្លាក់ជាចំណីរបស់មាគ៌ានៃជីវិត និងផ្ដត់គំនិតបរទេស។ វិហារនិងរូបបដិមាទាំងឡាយគ្រាន់តែជានិមិត្តរូបយ៉ាងសាមញ្ញនៃសាសនាប៉ុណ្ណោះ។យើងត្រូវផ្ដល់ផាសុខភាពខាងសម្ភារៈ ឱ្យពលរដ្ឋជាបរិសទ័របស់យើង នៅលើផែនដីនេះ

ហើយនាំឱ្យពួកគេផងដែរ នូវឱសថដ៏ឧត្តមនៃព្រះធម៌ ដើម្បីឱ្យពួកគេក្រេបរសជាតិសន្តិផ្លូវចិត្តថែមទៀត។

ពិភពលោកបានជាប់ជំពាក់ដោយបញ្ហាជាច្រើន ហើយបញ្ហាទាំងនោះសុទ្ធតែមានហេតុ នៅក្នុងសណ្តានចិត្តមនុស្សទាំងអស់។ ព្រោះហេតុនេះ បើជំនាន់របស់យើងប្រាថ្នាផ្តល់សេវកិច្ច ចំពោះមនុស្សជាតិ នោះគេត្រូវធ្វើការកែប្រែមនុស្សជាតិដោយបំផ្លាញចោលចរិតសត្វរបស់ពួកគេ ហើយអភិវឌ្ឍ ចរិតមនុស្ស និងចរិតទេព្តាជាជំនួស។ គឺមានតែផ្លូវនេះមួយទេដែលអាចធ្វើការងារនេះបាន គឺការបញ្ចូលសារដ៏ទន់ភ្លន់របស់ព្រះពុទ្ធ។ គោលដៅគឺពុំមែនបង្កើនចំនួនពុទ្ធសាសនិកជនទេ ប៉ុន្តែដើម្បីផ្តល់ពុទ្ធិដល់មនុស្ស ដើម្បីពួកគេបានក្រេបរសជាតិសន្តិភាព សុខដុមភាព និងបីតិ សម្រាប់ជាអត្ថប្រយោជន៍ដល់សព្វសត្វ។ យកជាឧទាហរណ៍ មានពេលមួយនោះអ្នកនិពន្ធបាននិយាយទៅកាន់ ពួកអ្នកជាប់ឃុំឃាំងមួយចំនួននៃពន្ធនាគារដ៏ធំបំផុតរបស់ប្រទេសម៉ាឡេស៊ី។ លោកបានសួរមនុស្សទាំងនោះថា តើគេនឹងធ្វើអ្វីនៅពេលគេវិលត្រឡប់ទៅកាន់សង្គមវិញ ចម្លើយរបស់ពួកគេមានលក្ខណៈរួមគ្នា គឺ " គេវិលត្រឡប់ ទៅរករបៀបរស់នៅពីមុនរបស់ពួកគេ!" នេះបង្ហាញថាទណ្ឌកម្ម លើរូបរាងកាយប៉ុណ្ណោះ មិនគ្រប់គ្រាន់ដើម្បីកែចរិយារបស់គេ ឬឫកពារិយាបថរបស់គេ ចំពោះជីវិតរស់នៅបានទេ។ មានតែការអភិវឌ្ឍន៍ខាងស្មារតីប៉ុណ្ណោះ ទើបអាចមានឥទ្ធិពលឋិតថេរមកលើជីវិតរស់នៅបាន។

ប្រសិនបើយើងមានបំណងបញ្ចូលព្រះធម៌ឱ្យបានជោគជ័យ យើងត្រូវបង្ខិកវាត្តិនដ៏ពូកែ និងមានឥទ្ធិពល ជាពិសេស ក្នុងចំណោមព្រះសង្ឃ។ នៅពេលនោះតំណាងទាំងឡាយ មកពីប្រទេសកាន់ព្រះពុទ្ធសាសនានៃទ្វីបអាស៊ី កំពុងរៀបចំដំណើរការបង្កើតគណៈកម្មាធិការការងារ ដើម្បីសិក្សាចំណុចខ្សោយ ហើយកំណត់

ឱ្យបាននូវចំណុចត្រូវកែលំអក្នុងការប្រតិបត្តិព្រះពុទ្ធសាសនា។ នេះរួមបញ្ចូលទាំងប្រពន្ធ័ហ្វឹកហ្វឺន គ្រូប្រដៅសាសនាដ៏ល្អប្រសើរផង។ ភិក្ខុទាំងឡាយត្រូវជាបុគ្គលមានលក្ខណៈសម្បត្តិល្អផ្ដាច់គេក្នុងចរិយាផ្ទាល់ខ្លួនក៏ដូចជាភាពវ័យឆ្លាតក្នុងការបកស្រាយ និងការផ្សព្វផ្សាយព្រះធម៌ដល់សវនជនសម័យថ្មី។ លោកទាំងនោះត្រូវមានចំណេះដឹងអំពីសេវកិច្ចចំពោះសង្គមផងដែរ។ ព្រះសង្ឃមិនអាចពួនសម្ងំនៅក្រោយជញ្ជាំងវិហាររបស់ខ្លួន ហើយធ្វើមិនដឹងមិនឮ ចំពោះបញ្ហាប្រឈមដ៏ធំធេងកំពុងមានវត្តមាននៅក្នុងពិភពលោកខាងក្រៅឡើយ។ លោកត្រូវប្រើសេចក្ដីព្យាយាម ឋាមពលញាណសក្តិ និងបញ្ញារបស់ខ្លួនដើម្បីបម្រើមនុស្សជាតិ ក្នុងបែបបទដែលអាចធ្វើបាន។ យើងត្រូវបញ្ឈប់ការថ្កោលទោសលើភាពផ្សេងៗគ្នារបស់យើងក្នុងទ្រង់ទ្រាយនៃពុទ្ធសាសនា ដែលយើងប្រតិបត្តិ ថាតើពិធីគោរពបូជា ធ្វើបានត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ ជាការប្រសើរ យើងត្រូវរួបរួមគ្នានៅពីក្រោយព្រះធម៌ ហើយធ្វើការសម្រាប់សុខមាលភាព មនុស្សគ្រប់រូប ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត។

ពុទ្ធសាសនា គឺជាស្នូលនៃជីវភាពរស់នៅរាល់ថ្ងៃរបស់យើង។ ពុទ្ធសាសនាអាចដឹកនាំ មនុស្សជាតិ ជាគ្រហស្ថ ក៏ដូចជាបព្វជិត ឱ្យផ្ដល់វិភាគទាន ដ៏ប្រសើររបស់ខ្លួនដើម្បីបំពេញតួនាទីរៀងខ្លួននៅក្នុងសង្គមរបស់ពួកគេ។ បើមនុស្សម្នាក់ៗយល់ដឹងថា តើបុរស ឬស្ត្រីនោះអាចផ្ដល់វិភាគទាន ដ៏ប្រសើរយ៉ាងណាខ្លះ ដល់សុខមាលភាពនៃពិភពលោកនោះជីវិតរស់នៅនឹងមានអត្ថន័យពេញលេញ។ នេះមិនមែនជាការគិតគួរចង់បានដ៏សាមញ្ញទេ។ ដោយអាងហេតុផលចំពោះការសង្ស័យថាព្រះធម៌របស់ព្រះពុទ្ធអាចត្រូវបានគេសិក្សាយល់ដឹង និងប្រតិបត្តិតាម ដើម្បីធ្វើឱ្យសតវត្ស ទី ២១ ជាយុគដ៏សុក្រិត ជាយុគនៃចិន្តាមនុស្សបានឬទេ។

# វិសុទ្ធិទាំង ៧

ដោយ : **ព្រឹទ្ធាចារ្យ ឆេង ផុន**

ហេតុដូចម្តេចបានជាអង្គប្រជុំ ចាស់ទុំ ចាស់ព្រឹទ្ធាចារ្យ លោកគ្រូ អ្នកគ្រូ សិល្បករបានសម្រេចយកប្រភេទសិល្បៈទេវៈទី ៣ គឺ សំដៅយកគុណធម៌ ៧ យ៉ាង គឺវិសុទ្ធិទាំង ៧ ?

វិសុទ្ធិទាំង ៧ នេះ អាចនាំមនុស្សលោកឱ្យទៅដល់ត្រើយនាយព្រះមហាបរិនិព្វានបាន ឬក៏យ៉ាងហោចណាស់ គឺធ្វើឱ្យមនុស្សបន្ថយនូវកិលេស គ្រឿងសៅហ្មង បន្ថយភាពភាន់ច្រឡំ ភាពសង្ស័យ មើលឃើញវត្ថុ និងបាតុភូតតាមសភាវៈពិត សភាវៈមែន :

ឧទាហរណ៍ : លោកិយ បញ្ញារបស់មនុស្ស ធ្វើឱ្យពិភពលោករីកចម្រើន សំបូរបែប ដោយសម្ភារៈផ្សេងៗ ធ្វើឱ្យជីវិតរស់នៅប្រកបដោយប្រណីតភាព ធ្វើឱ្យសន្មតិសច្ចៈ ឬ ( បញ្ញត្តិសច្ចៈ ) មានកម្លាំងខ្លាំងក្លា ។ លោកុត្តរសច្ចៈ ( ធម្មបញ្ញា) គឺបញ្ញាផ្លូវធម៌ ជាបញ្ញាខ្ពស់បំផុតសម្រាប់ឆ្លុះបញ្ចាំង សភាវធម៌ពិត សភាវធម៌មែន របស់វា អាចបន្ថយបាននូវ អំណាចកិលេស លោភៈ ទោសៈ មោហៈ កម្ចាត់នូវចំណង់លោកិយជាបណ្តើរៗ ។

## ១_សីលវិសុទ្ធិ :

ការរក្សាសីលមានភាពបរិសុទ្ធប្រពៃនេះ ជាគ្រឹះ ជាមូលដ្ឋានដ៏រឹងមាំបំផុត សម្រាប់ធ្វើឱ្យសមាធិបានសម្រេច ។

សីល គឺជាការគ្រប់គ្រងកាយ និងវាចាឱ្យមានវិន័យ មានសណ្ដាប់ធ្នាប់ មានរបៀបរៀបរយ សម្រាប់អប់រំចិត្ត ប្រដៅចិត្ត ត្រួតចិត្ត បញ្ជាលើចិត្តបានគ្រប់ពេលវេលា ។

**២-ចិត្តវិសុទ្ធិ :**

ការធ្វើចិត្តឱ្យស្ងប់ ក្នុងអប្បនាសមាធិ ( បានឈាន ) ឬ ក្នុងឧបចារៈ (ជិតបានឈាន) ទាបបំផុតជាខនិកៈសមាធិ (ស្ងប់ជាខណៈៗ ) សុទ្ធតែជាគ្រឹះសម្រាប់ឈានទៅធ្វើវិបស្សនាបញ្ញា វិបស្សនាញាណ ។

**៣-ទិដ្ឋិវិសុទ្ធិ :**

សេចក្ដីបរិសុទ្ធដោយការឃើញ ។ គឺឃើញនូវ ឃើញដោយបរិសុទ្ធ ឃើញហួសពីអ្វីៗដោយសន្មត ពីអ្វីៗដោយឡែក ពីអ្វីជាខាងក្រៅ ។ តាមធម្មតាមនុស្សយើង តែងមើលឃើញអ្វីៗទៅតាមបញ្ញត្តិ ឬ តាមសន្មត ដូចជាគេសន្មតថា នេះជាមនុស្ស ជាសត្វ ឈ្មោល ញី ស ខ្មៅ ធាត់ ស្គម ស្រី ប្រុស ក្មេង ចាស់ មាន ក្រ ធំ តូច ខ្មែរ យួន ចិន ចាម ជាដើម សុទ្ធតែជាសន្មតិសច្ចៈ ។ ដូច្នេះ គេស្គាល់ពិត ដឹងពិត ត្រឹមតែការសន្មតិប៉ុណ្ណោះ ព្រោះគេជាបុថុជ្ជន គេប្រើត្រឹមតែបញ្ញាលោកិយ ។ ការពិតសុទ្ធតែជារបស់រួមផ្សំគ្នា ប្រមូលបញ្ចូលគ្នា ផ្តុំគ្នា ជាសង្ខារធម៌ទាំងឡាយតែប៉ុណ្ណោះ គឺគ្រាន់តែជារូបៗ រូបបូកនឹងរូប រូបបូកនឹងនាម នាមបូកនឹងនាម ហើយទាំងអស់ស្ថិតនៅក្រោមអំណាចក្រិត្យក្រមធម្មជាតិតែប៉ុណ្ណោះ ។ ចំណែកអ្នកចម្រើនវិបស្សនា គេស្គាល់តាមការសន្មតិនោះដែរ តែគេយកបញ្ញាពិចារណាទៅផ្ទុះវែកញែក មើលសភាវធម៌ពិត ដែលស្ថិតនៅកប់ជ្រៅក្នុងសន្មតិនោះថែមទៀត ។ ការវែកញែក ពិចារណាល្អិតល្អន់នេះ នាំឱ្យអ្នកវិបស្សនាឃើញច្បាស់ថា មិនមែនជា

មនុស្ស ជាសត្វ ឈ្មោល ញី ស ខ្មៅ ជាដើមទេ គឺបែរជាឃើញថា ជាធាតុ ៤ ជាខន្ធ ៥ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឬជារូប និងនាមប៉ុណ្ណោះ ។ មុនពុទ្ធកាល អ្នកចម្រើនវិបស្សនាយល់ច្បាស់ថារូប និងនាម ជារបស់ផ្សេងគ្នាផង រួមគ្នាផង ។ ការយល់យ៉ាងនេះ លោកហៅថា ទិដ្ឋិវិសុទ្ធិ គឺបរិសុទ្ធ ដោយការពិចារណាឃើញថា មិនមែនសត្វ បុគ្គល ឬមនុស្ស ប្រុស ស្រី ជាដើមឡើយ គឺវាគ្រាន់តែជាធាតុ ជាខន្ធ ឬជារូប និងនាម ដែលផ្សេងគ្នាផង និងរួមគ្នាផងតែប៉ុណ្ណោះ ។

## ៤-កង្ខាវិតរណវិសុទ្ធិ

សេចក្ដីបរិសុទ្ធដោយញាណ ជាគ្រឿងឆ្លងផុតសេចក្ដីសង្ស័យ ។ សង្ស័យអំពីអ្វី ? សង្ស័យអំពីខន្ធ ៥ ឬនាមរូប ដោយឆ្ងល់ថា : តើខន្ធ ៥ ឬ នាមរូបកើតមកពីណា ? មានអ្វីជាហេតុបច្ច័យ ?

មុនពុទ្ធកាល គេយល់ថា នាមរូបកើតពីអាទិទេព ដូចជាព្រះព្រហ្ម ព្រះឥសូរ ជាដើម ជាអ្នកបង្កើត ។ ក្នុងពុទ្ធកាលដោយការខិតខំពិចារណារបស់អ្នកចម្រើនវិបស្សនា បានយល់ច្បាស់ថា នាមរូបគឺកើតមកពី :

- អវិជ្ជា : ការមិនដឹងសច្ចធម៌ ។
- តណ្ហា : ការចង់ជួបស្និទ្ធស្នាល នឹងកាមគុណ ៥ គឺរូប សម្លេង ក្លិន រស សម្ផស្ស ។
- ឧបាទាន : ការប្រកាន់ខ្ជាប់នូវកាមគុណ ៥ ថាជារបស់ខ្លួន ។
- កម្ម : ការបញ្ចេញសកម្មភាព កាយ វាចាចិត្ត ប្រព្រឹត្តធ្វើអំពើកុសល និងអកុសល ។
- អាហារ : ឱជារស ដែលសម្រាប់ទ្រទ្រង់ជីវិត ។

ការយល់ដឹងអំពីដើមកំណើត ឬហេតុបច្ច័យ នៃនាមរូប ទាំងអតីត អនាគត បច្ចុប្បន្នយ៉ាងនេះ លោកហៅថា: កង្ខាវិតរណវិសុទ្ធិ គឺសេចក្ដីបរិសុទ្ធ ដោយការឆ្លងផុតនូវសេចក្ដីសង្ស័យ ។

## ៥- មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ :

សេចក្ដីបរិសុទ្ធដោយញាណ ជាគ្រឿងពិចារណាឃើញថា នេះជាផ្លូវ នេះមិនមែនជាផ្លូវ ។ ការពិចារណានាមរូប ឬបញ្ចក្ខន្ធគឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឯណានីមួយជាអតីតក្ដី អនាគតក្ដី បច្ចុប្បន្នក្ដី ឱ្យឃើញសុទ្ធតែ អនិច្ចំ ទុក្ខំ អនត្តា ចិត្តក៏ចុះស៊ប់តាំងនៅក្នុងការពិចារណា អារម្មណ៍របស់វិបស្សនា ហើយពេលនោះស្រាប់តែឧបកិលេសទាំង ១០ ណាមួយកើតឡើង ហើយរីករាយសប្បាយ ដោយសម្គាល់ថាខ្លួនបានសម្រេចធម៌វិសេសហើយ បណ្ដោយឱ្យទិដ្ឋិ មានៈ តណ្ហា កើតឡើង មិនប្រឹងបដិបត្តិ ពិចារណាតទៅទៀតក៏ឈប់ផ្អាកត្រឹមប៉ុណ្ណោះ ។ ការបណ្ដោយចិត្តឱ្យរីករាយសប្បាយ ស្និទ្ធស្នាល និងឧបកិលេសទាំង ១០ ណាមួយនេះ មិនមែនជាមគ្គទេ ។ ឯមគ្គនោះ លុះត្រាតែអ្នកចម្រើនវិបស្សនា លើកយកឧបកិលេសទាំងនោះមកពិចារណាឱ្យឃើញថា សុទ្ធតែ អនិច្ចំ ទុក្ខំ អនត្តា មួយជាន់ទៀត ទើបអាចឃើញមគ្គទៅកាន់និព្វាន ។ ការយល់ច្បាស់ ដឹងច្បាស់ ឃើញច្បាស់បែបនេះ លោកហៅថា មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ឬសេចក្ដីបរិសុទ្ធដោយញាណ ពិចារណាឃើញថា ឧបកិលេស ជាឧបសគ្គរាំងរាវិបស្សនា មិនឱ្យឆ្លងទៅដល់មគ្គ ។

## ៦- បដិបទាញាណទស្សនវិសុទ្ធិ :

សេចក្ដីបរិសុទ្ធដោយញាណ ជាគ្រឿងឃើញបដិបទា ។ វិសុទ្ធិនេះ កើតឡើងបន្ទាប់ពីឧបកិលេស រលត់បាត់អស់ទៅហើយញាណពិចារណាស្គាល់មគ្គ និងមិនមែនមគ្គកើតឡើងប្រាកដ ។ បដិបទា ក្នុងទីនេះ សំដៅយកការឃើញអរិយសច្ចៈ ៤

ហើយដំណើរចិត្តពិចារណា បានប្រព្រឹត្តទៅតាមលំដាប់វិបស្សនាញាណ ៩ ចាប់តាំងពីឧទយព្វយញ្ញាណ ជាតរៀងទៅដរាបដល់បានសម្រេច មគ្គផលជាព្រះអរិយបុគ្គល ៤ ពួកថ្នាក់ណាមួយតាមឧបនិស្ស័យ ។ អ្នកវិបស្សនាខ្លះ សម្រេចត្រឹមថ្នាក់ សោតា ខ្លះថ្នាក់ សកទាគាមី ខ្លះថ្នាក់ អនាគាមី ខ្លះបានសម្រេចដល់ថ្នាក់ អរហន្ត ។ ការខិតខំពិចារណារហូតដល់បានសម្រេចមគ្គផល និព្វានបែបនេះ លោកហៅថា បដិបទាញាណទស្សនៈវិសុទ្ធិ ។

## ៧_ ញាណទស្សនវិសុទ្ធិ :

សេចក្តីបរិសុទ្ធដោយញាណទស្សនៈ ។ វិសុទ្ធិនេះកើតបន្ទាប់អ្នកចម្រើនវិបស្សនា បានសម្រេចមគ្គផលជាព្រះអរិយបុគ្គលថ្នាក់ណាមួយហើយ ។ លោកដឹងច្បាស់ដោយខ្លួនឯង ដោយបច្ចវេក្ខណញ្ញាណថា អាត្មា អញបានសម្រេចត្រឹមថ្នាក់សោតា ថ្នាក់សកទាគាមី អនាគាមី ឬថ្នាក់អរហន្ត ។ ថ្នាក់សោតា សកទាគាមី អនាគាមី មានបច្ចវេក្ខណញ្ញាណ ៥ សម្រាប់ពិចារណាគឺ :

| | | |
|---|---|---|
| ១-បហីនកិលេស | បច្ចវេក្ខតិ | ពិចារណាកិលេសដែលលះបង់អស់ហើយ ។ |
| ២-អវសិដ្ឋកិលេសំ | បច្ចវេក្ខតិ | ពិចារណាកិលេសដែលសេសសល់ ។ |
| ៣-មគ្គំ | បច្ចវេក្ខតិ | ពិចារណាមគ្គ ។ |
| ៤-ផលំ | បច្ចវេក្ខតិ | ពិចារណាផល ។ |
| ៥-និព្វានំ | បច្ចវេក្ខតិ | ពិចារណាព្រះនិព្វាន ។ |

ឯព្រះអរហន្ត មានបច្ចវេក្ខតិញ្ញាណ ៤ គឺ :

| | | |
|---|---|---|
| ១-បហីនកិលេសំ | បច្ចវេក្ខតិ | ពិចារណាកិលេស ដែលលះ |

បង់អស់ហើយ ។

២-មគ្គំ បច្ចវេក្ខតិ ពិចារណាមគ្គ ។

៣-ផលំ បច្ចវេក្ខតិ ពិចារណាផល ។

៤- និព្វានំ បច្ចវេក្ខតិ ពិចារណាព្រះនិព្វាន ។ ព្រោះលោកមិនមានកិលេសនៅសេសសល់ទេ ។

បញ្ញាដែលពិចារណាដឹងច្បាស់ ឃើញច្បាស់ នូវមគ្គផល និព្វាន ដោយបច្ចវេក្ខណញ្ញាណផ្ទាល់ខ្លួនឯងបែបនេះ ជាលោកកុត្តរបញ្ញា ជាបញ្ញាកម្ទេចនាមរូបលែងឱ្យមានជាតិ ជរា ព្យាធិ មរណៈទៀតហើយ ។ នេះហើយ ដែលលោកឱ្យឈ្មោះថា **និព្វាន** ។

*ពាលោ ពាលេខ្លាំង*

*បានធម៌ ហើយចោលទៅ*

*អ្នកប្រាជ្ញប្រែជាខ្លៅ*

*ព្រោះកម្លៅ ពុំជឿបុណ្យ ។*

ព្រះមហាសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយ ចន្ទត្ថេរោ **ជួន ណាត**

# ការរីកចម្រើននៃព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ
(តចប់)

ដោយ : **បណ្ឌិត ខ្លូត ធីតា**

## ៥- ពិធីបុណ្យមួយចំនួននៃព្រះពុទ្ធសាសនា

ចំពោះពិធីបុណ្យក្នុងព្រះពុទ្ធសាសនា អាចយើងមិនពិពណ៌នាឱ្យបានពិស្តារទេនិងមិនបានគ្រប់បុណ្យដែរព្រោះបុណ្យមានច្រើនណាស់ ។ ដូចជាបុណ្យវិសាខបូជា បុណ្យបំបួសនាគ បុណ្យចូលព្រះវស្សា ដាក់បិណ្ឌ បុណ្យភ្ជុំបិណ្ឌ បុណ្យចេញព្រះវស្សា បុណ្យបញ្ចុះសីមា បុណ្យមាឃបូជា ជាដើម ។ ក្រៅពីនេះនៅមានពិធីបុណ្យចូលឆ្នាំ ។ បុណ្យខ្លះៗដូចជាបុណ្យកោរសក់កូន បុណ្យឡើងផ្ទះថ្មី បុណ្យវិវាហមង្គលការកូនប្រុសស្រី និងបុណ្យតាមប្រពៃណីជាច្រើនដូចជា ពិធីអភិសេកព្រះពុទ្ធរូបជាដើម ។

### ១-ពិធីបុណ្យវិសាខបូជា

បុណ្យវិសាខបូជា គឺធ្វើនៅថ្ងៃពេញបូណ៌មី ខែវិសាខព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ដែលទ្រង់ប្រសូតទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ និងទ្រង់ចូលបរិនិព្វាន ។ នៅក្នុងខែតែមួយគឺខែវិសាខ(ពិសាក) ។ នៅខែវិសាខជាខែដែលសម្បូរដោយផ្លែឈើគេច្រើនធ្វើសលាកភត្ត និមន្តលោកសង្ឃឆាន់ដោយចាប់ស្លាក ។ មានគេធ្វើស្លាកតូចៗចារិកនាមព្រះភិក្ខុសង្ឃ ដែលគេបាននិមន្តទៅឆាន់ ។ ពិធីនេះមានធ្វើពីរយ៉ាងគឺលោកសង្ឃចាប់ស្លាក ឬឧបាសក ឧបាសិកាចាប់ស្លាក ។

គេមានតំណាលថា បុព្វហេតុដែលកើតពិធីបុណ្យនេះ មានការទាក់ទង

ដោយរឿងព្រេងគឺ មានយក្ខិណីម្នាក់នាម **"គាលា"** ដោយបុព្វកម្មបានស៊ីបុត្រា បុត្រីនាងកុលធីតាអស់ជាច្រើន ដល់ក្រោយបំផុតនាងកុលធីតាក៏បានបីបុត្ររត់មក សូម ព្រះបរមសម្ពុទ្ធ កាលព្រះអង្គគង់ធរមាននៅឡើយធ្វើជាទីពឹង [១] ។

ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ទេសនាទូន្មាន នាងយក្ខិណី ។ ក្រោយមក នាងយក្ខិណីប្រែជាមានចិត្តជ្រះថ្លាល្អ ហើយទ្រង់ក៏បានបង្គាប់ឱ្យនាងកុលធីតា ទុក នាងយក្ខិណីឱ្យរស់នៅក្នុងផ្ទះរបស់នាងផងចុះ ។

ពេលនោះនាងយក្ខិណីក៏បានចូលជាឧបាសិកាក្នុងព្រះពុទ្ធសាសនា ចេះក្បួន ឧតុនិយមវិទ្យាចេះទាយភ្លៀងឆ្នាំក្រោយៗ ហើយក៏បានទូន្មាននាងកុលធីតាៗ បាន ស្គាល់ពេលវេលាធ្វើស្រែហើយអាចធ្វើបានផលជាអនេកប្បការ ។ ចំណែកអ្នកនៅ ជិតនាងកុលធីតាក៏បានយកជំនូនទៅជូននាងយក្ខិណីៗ ក៏បានយកជំនូនខ្លះទៅប្រគេន ព្រះសង្ឃ ដោយធ្វើសលាកភត្ត បានជាមានធ្វើសលាកភត្ត ជាប់តមករហូតបច្ចុប្បន្ន។

ហេតុនេះហើយទើបមានទំនៀមពិធីបុណ្យសលាកភត្ត និងវិសាខបូជាក៏ត្រូវ ធ្វើព្រមគ្នាក្នុងពេលនោះថែមទៀតផង ។

## ២_ពិធីបុណ្យបំបួសនាគ

ពិធីបុណ្យនេះ គេធ្វើពេលណាក៏បាន ក្រៅពីពេលបីខែ ដែលព្រះសង្ឃចាំ វស្សា ។ ចំពោះបុណ្យនេះមានរឿងព្រេងមួយពោលថាៈ មាននាគក្លែងខ្លួនជាមនុស្ស ហើយបានចូលទៅស្ថិតនៅជាមួយព្រះសង្ឃ ។ មានថ្ងៃមួយព្រះបរមសម្ពុទ្ធទ្រង់បាន ចាត់ឱ្យសាវ័កមួយរូបចូលទៅហៅព្រះភិក្ខុសង្ឃនោះនៅបន្ទប់មួយ ដែលមាននាគ មួយនៅទីនោះផង ។

---

១- វ៉ាយ ប៊ុក ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ភ្នំពេញឆ្នាំ ១៩៥៧ ទំព័រ៩៤

ពេលនោះ ព្រះបរមសម្ពុទ្ធទ្រង់ជ្រាបហើយ ក៏ទ្រង់បណ្តេញនាគនោះចេញពីកន្លែង ព្រោះថា សភាពជាសត្វតិរច្ឆានមិនអាចបួសក្នុងព្រះពុទ្ធសាសនាបាន ។ តាំងពីពេលនោះមកអ្នកបួសគេហៅថានាគ ហើយពិធីបំបួសហៅថា បំបួសនាគ ។

## ៣ - ពិធីបុណ្យចូលព្រះវស្សា

ពិធីនេះផ្តើមធ្វើនៅថ្ងៃ ១ រោច ខែ អាសាធ គឺពេលដែលព្រះភិក្ខុសង្ឃត្រូវចូលព្រះវស្សា ។ រយៈពេលចូលវស្សាគឺ ៣ ខែ គិតពីថ្ងៃ ១រោច ខែ អាសាធ រៀងរហូតដល់ បី ខែ ។

ពិធីបុណ្យនេះមានធ្វើនៅក្នុងព្រះបរមរាជវាំង និងតាមវត្តអារាមក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

ក្នុងពេលចូលព្រះវស្សា ព្រះសង្ឃមិនត្រូវនិមន្តចេញពីវត្តអារាមទេ វៀរលែងតែមានគេនិមន្តទៅធ្វើពិធីបុណ្យ ឬញោមឈឺខ្លាំង ឬគ្រូបាអាចារ្យអាពាធតែមិនត្រូវឱ្យហួសមួយសប្តាហ៍ឡើយ ។

## ៤- ពិធីបុណ្យភ្ជុំបិណ្ឌ

ពិធីនេះ មានពីរយ៉ាងគឺ ពិធីកាន់បិណ្ឌធ្វើពីថ្ងៃ ១ រោច ខែ ភទ្របទ និងពិធីភ្ជុំបិណ្ឌគឺធ្វើដល់ទៅថ្ងៃខែដាច់ ។ រយៈពេល ១៥ ថ្ងៃ គឺរាប់ពីថ្ងៃកាន់បិណ្ឌទី ១ រហូតដល់ចប់ឆ្លង ។

បុណ្យនេះគឺធ្វើឧទ្ទិសផលជូនទៅបុព្វការី មាតា បិតា ជីដូនជីតា ញាតិ៧សន្តានដែលបានមរណភាព ។ ពិធីនេះមាននិមន្តព្រះសង្ឃឆាន់ចង្ហាន់ធ្វើពិធីដារបង្សុកូល ឆាកមហាបង្សុកូល និងមានកិច្ចតូចៗផ្សេងៗថែមទៀត ។

## ៥_ ពិធីបុណ្យចេញព្រះវស្សា

ពិធីបុណ្យនេះ ធ្វើនៅថ្ងៃពេញបូណ៌មី ខែ អស្សុជ គឺថ្ងៃដែលព្រះភិក្ខុសង្ឃចេញព្រះវស្សា ក្រោយពេលដែលស្ថិតនៅក្នុងវត្តអារាមអស់វេលាបីខែគង់ចាំព្រះវស្សា ។ ក្នុងពេលនោះ នៅគ្រប់វត្តអារាមនៃព្រះរាជអាណាចក្រមានធ្វើពិធីសម្ដែងព្រះបរិត្តមានទេសនាមហាជាតក មានពិធីលយប្រទីបជាដើម ។ល។

## ៦_ ពិធីបុណ្យកឋិន

ពិធីបុណ្យនេះ គឺធ្វើតាំងពីថ្ងៃ ១ រោច ខែ អស្សុជ ទៅដល់ថ្ងៃពេញបូណ៌មី ខែកត្ដិក មានការធ្វើចីវរព្រមទាំងប្រដាប់ប្រដាសព្វបែបយ៉ាងរួមមានប្រាក់ថែមទៀតផង ។

## ៧_ ពិធីបុណ្យបញ្ចុះសីមា

ពិធីនេះធ្វើគ្មានកំណត់កាលទេ ព្រះវិហារណាកសាងរួចត្រូវធ្វើបុណ្យបញ្ចុះសីមា ៩ ទើបធ្វើពិធីបុណ្យតទៅទៀតបាន ។

## ៨_ ពិធីបុណ្យអភិសេកព្រះពុទ្ធរូប មាឃបូជា ចូលឆ្នាំ

ជាពិធីបុណ្យ ព្រះពុទ្ធសាសនាដែរ ក្រៅពីនេះនៅមានបុណ្យផ្កាប្រមូលបច្ច័យ សាងកុដិ អារាម សាលាជាដើម ។

## ៩_ ពិធីបុណ្យ ព.ស. ២៥០០ នៃប្រទេសកម្ពុជា

ពិធីបុណ្យនេះ បានធ្វើនៅ ខែវិសាខ ៥៦ ឬ៥៧ ចំពោះប្រទេសដែលកាន់ព្រះពុទ្ធសាសនា ។ បុណ្យនេះមានតែម្ដងគឺនៅ ព.ស ២៥០០ ។

ប្រជាជនរាប់លាននាក់ បានសិក្សារៀនសូត្រព្រះពុទ្ធសាសនា បានប្រព្រឹត្តប្រតិបត្តិតាមហើយបានសេចក្ដីសុខចម្រើន ពុទ្ធបរិស័ទបាននឹករលឹកដល់ព្រះគុណូប -

ការៈ នៃព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ដ៏ឧត្តមហើយក៏បាននាំគ្នាធ្វើពិធីបុណ្យ ព.ស ២៥០០ ។

ពិធីបុណ្យតាំងពីថ្ងៃពេញបូណ៌មីឆ្នាំដដែល ខែវិសាខ នៅមុខស្ថានីយ អយស្ម័យយានភ្នំពេញមានធ្វើពិធីបុណ្យបែបព្រះពុទ្ធសាសនា គ្រប់បែបយ៉ាងមាន ពិធីដាក់បាត្រ សុំសីលស្តាប់ព្រះធម៌ទេសនា បួងសួងព្រះបរមសារីរិកធាតុមានអាគារ តាំងពិព័រណ៍ព្រះពុទ្ធរូប សិល្បៈបែបព្រះពុទ្ធសាសនាមានរឿងរ៉ាវព្រះពុទ្ធសាសនា បែបជាតកបែបពុទ្ធប្រវត្តិ ពិព័រណ៍ ដែលមានផ្ទាំងគំនូរព្រះពុទ្ធសាសនាប្រដាប់ដោយ ស្លឹករុក្ខា ផ្កាឈើគ្រប់ពណ៌រចនាជាក្បាច់ច្រើនសណ្ឋានព្រមទាំងមានការបាញ់ កាំជ្រួច រន្ទាភ្លឺដាលពេញផ្ទៃមហាមេឃ ។

ពេលនោះមានអ្នកតំណាងប្រទេសនានា បានអញ្ជើញចូលរួមប្រជុំក្នុងពិធី បុណ្យនេះ ដូចជាមហាពោធិសមាគមឥណ្ឌា ប្រទេសម៉ាឡាយូ ប្រទេសភូមា ប្រទេសថៃ ប្រទេសចិនប្រជាមានិត ប្រទេសឡាវ ប្រទេសជប៉ុន ប្រទេស វៀតណាម ប្រទេសឥណ្ឌូនេស៊ីជាដើម ។ ក្រៅពីនោះទៅ មានបុរសឧបសម្បទា ជាភិក្ខុជាច្រើន មានបុរសអ្នកកាន់សីល១០ប្រកាន់ អតិរេកសីល ឧបាសក ឧបាសិកា មកពីខេត្តក្រៅ ជនជាតិនានាបាននិមន្តនិងអញ្ជើញមកកាន់ទីបុណ្យនេះ យ៉ាងកង រំពងពាសពេញ ។

ព្រះបរមសម្ពុទ្ធបរមគ្រូជាម្ចាស់ ព្រះអង្គទ្រង់បរិនិព្វាន ២៥០០ ឆ្នាំហើយ ទ្រង់បានទុកព្រះពុទ្ធរូបស្នងព្រះអង្គ ឱ្យសត្វទាំងឡាយគោរពបូជា ព្រះពោធិព្រឹក្សឱ្យ មនុស្សនិងទេវតាធ្វើសក្ការៈ ព្រះបរមសារីរិកធាតុឱ្យមាមកជនសម្តែងសេចក្តីជ្រះថ្លា ចំពោះព្រះពុទ្ធសាសនា ។ ព្រះស្តូបពុទ្ធបូជនីយដ្ឋាន ឱ្យព្រះពុទ្ធសាសនិកជនថ្វាយបង្គំ យកបុណ្យកុសល ។ យើងទាំងអស់គ្នាបានទាន់នូវព្រះរតនវត្ថុទាំងអស់នេះ ទុកជា

មានភ័ព្វសំណាងដ៏ធំ ដោយមានជោគជ័យមង្គល សិរីសួស្តី គ្រប់យ៉ាង ។

បើព្រះពុទ្ធសាសនា មានអនុភាពដូច្នេះ តើយើងជាពុទ្ធបរិស័ទត្រូវធ្វើយ៉ាងណា ? គួររក្សាកេរ្តិ៍តំណែលតទៅទៀត ដើម្បីអប់រំកូនចៅឱ្យចេះស្រឡាញ់ព្រះពុទ្ធសាសនា ពន្យល់បំភ្លឺនូវវិធីប្រតិបត្តិឱ្យបានមាំមួនជាហេតុធ្វើឱ្យព្រះពុទ្ធសាសនាមានវឌ្ឍនភាពតទៅអនាគតយ៉ាងសមរម្យ ។

ព្រោះព្រះពុទ្ធសាសនា ជាឱសថមួយដ៏ថ្លៃថ្លាដែលយើងបានក្រេបបានស្គាល់ ឱជារសដ៏ប្រសើរបានជារោគ លោភៈ ទោសៈ មោហៈ ដោយអន្លើៗ បានជាយើងទាំងអស់គ្នាត្រូវតែរួបរួមគ្នា តស៊ូនឹងអ្នកបំផ្លាញព្រះពុទ្ធសាសនា ដើម្បីរក្សាព្រះកេរ្តិ៍មរតក ព្រះសម្មាសម្ពុទ្ធ ឱ្យបានស្ថិតស្ថេរអស់កាលយូរលង់ទៅអនាគត ។

ម្យ៉ាងទៀតដោយពិនិត្យទៅឃើញថា ជនជាតិខ្មែរមានជំនឿលើព្រះពុទ្ធសាសនាភាគច្រើន បានជាពិធីបុណ្យ ព.ស ២៥០០ នៅប្រទេសកម្ពុជាធ្វើដោយឧឡារិកយ៉ាងអស្ចារ្យពន់ពេកណាស់ គឺដូចជាជនជាតិខ្មែរទាំងអស់រួបរួមគ្នាតែមួយមកធ្វើពិធីនេះ មិនថាអ្នកមាន អ្នកក្រ ក្មេង ចាស់ បព្វជិត គ្រហស្ថ រាស្ត្រ មន្ត្រីនៃប្រទេសកម្ពុជាទាំងមូលបានលះបង់វិជ្ជាជីវៈរបស់ខ្លួន លះបង់ការងារគ្រប់យ៉ាងចូលមកសាមគ្គីធ្វើបុណ្យ។

ពិធីបុណ្យនេះ បានធ្វើដោយចិត្តស្មោះស្ម័គ្រចំពោះព្រះបរមសម្ពុទ្ធ ដែលទ្រង់ជានាយមគ្គុទេសក៍ដ៏វិសេសវិសាល ដឹកនាំសត្វនិករទៅកាន់ត្រើយនាយគឺនិព្វានធាតុលះបង់អាសវក្កិលេស តណ្ហា អវិជ្ជាដើម្បីសេចក្តីសុខស្ថានសួគ៌ព្រហ្ម នឹងលោកុត្តរឯណោះ (ពុទ្ធសាសនិក)។

ពិធីបុណ្យទាំង ៩ ខាងលើនៃព្រះពុទ្ធសាសនា ជាសក្ខីភាពប្រសើរ ក្នុងការញ៉ាំងចិត្តឱ្យជ្រះថ្លា ចំពោះព្រះពុទ្ធសាសនា និងសោមនស្សចំពោះគុណព្រះ

រតនត្រ័យ ធ្វើលោភៈ មច្ឆរិយ (សេចក្ដីកំណាញ់) ឱ្យអស់ ញ៉ាំងសទ្ធា និងសេចក្ដីប្រាថ្នា ឱ្យដុះ ដាលចម្រើនឡើងជាហេតុ ឱ្យធ្វើសីល សមាធិ បញ្ញាបានចម្រើនតទៅទៀត ។

ឯពិធីច្រៀងបទលើកទង់ជ័យព្រះពុទ្ធសាសនា ពិធីនេះទើបនឹងមាននៅសម័យទសវត្សរ៍ ៧០ សតវត្សទី ២០ ដោយការណែនាំពីសម្ដេចព្រះមហាសុមេធាធិបតី **ជួន ណាត** ( ជោតញ្ញាណោ ) សង្ឃនាយកគណៈមហានិកាយ ។ សម្ដេចបានបង្ហាត់ក្មេងៗ ឱ្យស្លៀកពាក់ឯកសណ្ឋានជាង ១០០ នាក់ ល្អស្អាតហើយរៀបជាជួរហែរូចតាំងច្រៀងបទលើកទង់ជ័យដូចខាងក្រោម :

(សម្រាប់សូត្រលើកទង់សាសនា[១])

សូមមើលទង់ជ័យ-ឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណិស ហង្សបាទជាពណ៌ដ៏ភ្លឺផ្ទេក ។
ប្រទេសតូចធំបានស្ម័គ្រស្វាគមន៍ ជំនុំគ្នាច្រើនអនេក
ព្រមយករស្មីព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង ។
ធ្វើជាសញ្ញាទង់ជ័យសាសនា នៃសមុទ្ទធំចម្បង
ចូរយើងរាល់គ្នាយកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។
ទោះជាតិផ្សេងគ្នាក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គីទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស់គ្រប់ៗគ្នា
សូមសាសនាពុទ្ធថ្កុំថ្កើនខ្ពស់ផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជោគជ័យ ផ្សាយពេញលោកា

---

១- ភ័យ-ប៉ុក ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ភ្នំពេញឆ្នាំ ១៩៥៧ ទំព័រ ១០១

ដោយជនជ្រះថ្លារាប់ច្រើនលាន ។

មានចិត្តស្នេហាគោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវតាស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្ដីសុខ ។
យើងខេមរជាតិនាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គីពីនេះទៅមុខ យើងនឹងបានសុខក្សេមសាន្តត្រាណ ។
ព្រមព្រៀងប្រព្រឹត្តតាមធម៌សុចរិត ឆ្ពោះទៅកាន់ស្ថាននិព្វាន
ជាទីផុតទុក្ខបានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា ។

**សន្និដ្ឋាន**

ឆ្លងតាមការបកស្រាយអំពីព្រះពុទ្ធសាសនា ក្នុងជីវិតខ្មែរកន្លងមកយើងឃើញថាអ្វីៗដែលខ្មែរបាននិងកំពុងមានជំនឿយ៉ាងមុតមាំនោះគឺព្រះពុទ្ធសាសនា (ច្រើនជាងជំនឿផ្សេងៗ) ។

ព្រះពុទ្ធសាសនាបានចាក់ឫសគល់ទៅក្នុងសន្តានចិត្តខ្មែរយ៉ាងជ្រាលជ្រៅ គឺតាំងពីកើតរហូតស្លាប់ទៅវិញ ក៏នៅតែប្រើប្រាស់ទស្សនៈព្រះពុទ្ធសាសនា ស្ទើរទាំងអស់ ។ ការប្រើប្រាស់ព្រះពុទ្ធសាសនានៅខ្មែរមានវិសាលភាពធំធេងណាស់ ។ ខ្មែរគិតគូរអំពីព្រះពុទ្ធសាសនា សឹងតាំងពីមុន គ.ស សម័យដើមដំបូងនៃគ្រិស្តសករាជរហូតបច្ចុប្បន្ន លើកលែងតែរបបប៉ុលពត ។ ខ្មែរមានកវីអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាច្រើនបង្ហួរជាងផ្នែកដទៃ ។

ហេតុនេះហើយ បើប្រសិនណាជាការគោរព មិនបានត្រឹមត្រូវល្អទេនោះអាចនាំឱ្យប្រទេសជាតិយើងចុះខ្សោយបាន ព្រោះជំនឿជ្រាលជ្រៅ និងក្លាយជាទស្សនៈរបស់មនុស្ស ពេលមនុស្សដែលមានទស្សនៈភាន់ច្រឡំក្នុងគម្ពីរធម៌អាចដោយប្រការផ្សេងៗ មនុស្សក្នុងសង្គមពិតជាមិនអាចមានលទ្ធភាព ជ្រោមជ្រែង

ជាតិបានត្រឹមត្រូវទេ ។ យ៉ាងណាមិញដូចជាក្នុងអត្ថបទ ដែលបានសរសេរតាមទំព័រលេខទស្សនាវដ្ដីកម្ពុជសុរិយាជាហូរហែមកហើយ ។ ការបកស្រាយទាំងនោះសុទ្ធតែបង្ហាញពីការគោរពស្រឡាញ់របស់ខ្មែរយើងទាំងអស់ ប៉ុន្តែអ្វីដែលសំខាន់គឺពុទ្ធសាសនិកខ្មែរមិនទាន់បានប្រើប្រាស់ព្រះធម៌ឱ្យសមតាមខ្លឹមសារព្រះធម៌ទេ ។

**ទស្សនៈអ្នកនិពន្ធ :**

ទាំងការកត់ត្រាតាមទ្រឹស្ដីដើមក្ដី ទាំងការស្រាវជ្រាវបន្ថែមក្ដី អ្នកនិពន្ធមានបំណងសំខាន់បំផុតគឺចង់រួមចំណែកបម្រើការងារផ្នែកព្រះពុទ្ធសាសនា ក្នុងកំរិតជាតិ និងកំរិតតំបន់ ( ចក្ខុវិស័យជាតិនិងចក្ខុវិស័យតំបន់) ជាពុទ្ធសាសនិកម្នាក់ក្នុងការសម្របសម្រួលខ្លួនផ្ទាល់ក៏ដូចពុទ្ធសាសនិកខ្មែរ និងពុទ្ធសាសនិកក្នុងអន្តរជាតិដែលរួមមាន :

១ ចង់បង្ហាញអំពីការគោរពស្រឡាញ់ចូលចិត្ត របស់ពុទ្ធសាសនិកខ្មែរចំពោះព្រះពុទ្ធសាសនា នាសម័យកាលកន្លងមក ដើម្បីធ្វើជាខ្នាតនិងដើម្បីឆ្លុះបញ្ចាំងអំពីអតីតភាពនៃទំនៀមទម្លាប់ពុទ្ធសាសនិកខ្មែរ ។

២- ចង់ទាញអារម្មណ៍ពុទ្ធសាសនិកមួយចំនួន ដែលមិនទាន់បានពិចារណាដិតដល់ចំពោះការសិក្សាគោរពប្រតិបត្តិនូវបញ្ហានេះ ។ ព្រោះការគោរពមិនមែនសំដៅខ្លាំងទៅអនាគតកាលទេ កាលណាបច្ចុប្បន្នកាលមិនសូវត្រឹមត្រូវមិនសូវល្អអតីតនិងអនាគតពិតជាមិនសូវបានត្រឹមត្រូវល្អដែរ ។ សំខាន់ជាងនេះទៅទៀតគឺគួរចេះផ្សារភ្ជាប់ពាក្យបណ្ដាំរបស់ព្រះពុទ្ធទាំង ៨៤០០០ធម្មខន្ធ រួចមានមេត្តា ករុណាបញ្ញាឱ្យបានត្រឹមត្រូវសមរម្យទៅតាមកាលៈទេសៈ ( ស្គាល់កាលនិងលំហ ) ទៅតាមទីកន្លែង ។ ទើបលទ្ធផលទទួលបានឈានទៅរកការត្រូវព្រមទាំងអាចកាត់បន្ថយភាពភាន់ច្រឡំដោយអន្លើ ។

ឯកសារពិគ្រោះ :

១- ខូត ធីតា តួនាទីព្រះពុទ្ធសាសនានៅកម្ពុជាសាកល្បងពិចារណាតួនាទីព្រះពុទ្ធសាសនានៅកម្ពុជាដោយឆ្លុះបញ្ចាំងតាមទស្សនៈវិទ្យាសាស្ត្រមួយចំនួននៃសាសនាដទៃ ។ និក្ខេបបទថ្នាក់បណ្ឌិតសាកលវិទ្យាល័យហាណូយទី ១ ១៩៩៥

២- ញ៉ុក ថែម ពន្លឺអាស៊ីទ្វីប វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ១៩៧៧

១- ប៉ាង ខាត់ មហាវណ្ណកម្ម វត្តឧណ្ណាលោម ១៩៦៩

២- វ៉ាយ ប៊ុក ព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ភ្នំពេញ ១៩៥៧

៣- ឌិម ណាត្រី ព្រះភិក្ខុ ពនេចរ ភ្នំពេញ ១៩៦៣

*កុំអាងធ្វើកំបាំង*

*ព្រោះជញ្ជាំងមានត្រចៀក*

*មានត្រីមានពន្លៀក*

*កុំខំលាក់មិនជិតឡើយ ។*

សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា

វិជិរប្បញ្ញោ ល្វី ឯម

# សិលាចារឹកថ្មីពីរ នៅថលាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

## Two New Pre-Angkorean Inscriptions found in Thalaborivath, Stung Treng Province

ដោយ ទង់ សុធាវី

*សាស្ត្រាចារ្យសិលាចារឹកសាស្ត្រ និងប្រវត្តិសាស្ត្រខ្មែរ*

*ដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

## ១‑ សិលាចារឹកថលាបរិវ៉ាត់ :

សិលាចារឹកនេះជាប្រភេទថ្មភក់រាងជាសន្លឹកសីមា ដែលមានទំហំកំពស់ ០,៧០ម៉ែត្រ ទទឹង ០,២៩ម៉ែត្រ និង កម្រាស់ ០,០៩ម៉ែត្រ ។ សព្វថ្ងៃផ្ទាំងចារឹកត្រូវបានថែរក្សាទុកនៅមន្ទីរវប្បធម៌ខេត្តស្ទឹងត្រែង។ យើងបានផ្ដិតចម្លងអត្ថបទនេះនៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០០២ ក្នុងឱកាសធ្វើដំណើរកំសាន្តមួយទៅកាន់ខេត្តនេះ ពីថ្ងៃទី ៨ ដល់ទី ១០ ខែ មករា ។ តាមការសាកសួរមន្ត្រីមន្ទីរវប្បធម៌ខេត្តបានឱ្យដឹងថា គេបានយកសិលាចារឹកនេះមកពីស្រុកថលាបរិវ៉ាត់ ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ ទល់មុខទីរួមខេត្តស្ទឹងត្រែង ។ នៅពេលបានទៅទស្សនាទួលប្រាសាទថលាបរិវ៉ាត់ ផ្ទាល់ ខ្ញុំបានស៊ើបសួរដំណឹងស្ដីពីការរកឃើញសិលាចារឹកនេះជាបន្ថែមទៀត ។ សំណាងល្អមានអ្នកស្រុកជាច្រើននាក់ បានដឹងពីសាវតារនៃការរកឃើញយ៉ាងច្បាស់ថា សិលាចារឹកនេះ គេបានប្រទះឃើញនៅពេលមានការជីកគាស់កាយដី លើទួលប្រាសាទចាស់ នៅទិសខាងត្បូងជាប់នឹងអនុវិទ្យាល័យ

ថលាបរិវ៉ាត់ ប្រហែល ៥០ ម៉ែត្រ ដែលទីនោះជាអតីតទីតាំងឈរជើងមួយកន្លែងរបស់កងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ បន្ទាប់ពីនោះ មន្ត្រីវប្បធម៌ស្រុកបានយកទៅរក្សាទុកនៅសាលាស្រុក ដែលស្ថិតនៅខាងត្បូងទួលប្រមាណ ៨០០ ម៉ែត្រ អស់រយៈពេលយ៉ាងយូរ ។ ទើបតែនៅ ឆ្នាំ ២០០១ ប៉ុណ្ណោះ ដែលមន្ត្រីវប្បធម៌ខេត្តយកទៅទុកនៅមន្ទីរវប្បធម៌ខេត្ត ។

អត្ថបទចារឹកមានចំនួន ២០ បន្ទាត់ តែនៅបន្ទាត់ទី១ ទី៣ និងបន្ទាត់ចុងក្រោយមានសភាពរលុបមិនអាចអានបាន។ នេះជាសិលាចារឹកភាសាខ្មែរ នៅសតវត្សរ៍ទី ៧ នៃ គ.ស. ដែលគេបានកត់ត្រាអំពីតង្វាយចំពោះអាទិទេពពីរអង្គ គឺព្រះឥសូរដែលមានរហស្សនាម (epithet) ថា សុវណ្ណលិង្គ និង ចណ្ឌីស្វរៈ នូវទ្រព្យសម្បត្តិ ដូចជា អ្នកបម្រើ សម្ភារៈ ភស្តុភារ ចម្ការដំណាំ និងសត្វពាហណៈ ហើយនៅខាងចុងអត្ថបទ គេចាត់ទុកតង្វាយនេះ ដូចជាទ្រព្យរបស់ព្រះឥសូរមួយអង្គទៀត នាម ទិង្គេស្វរៈ ដែលពីមុនមកគេក៏មិនធ្លាប់ឃើញមានឈ្មោះនេះឡើយ។

## អត្ថបទដើមជាអក្សរខ្មែរសម័យថ្មី:

១- អំនោយស្រុ---------------វស្ន-------ទ្មិយ

២- (ព្វត) ឞ្រះកម្រតាងអញ្ជសុវណ្ណលិង្គ

៣- ----យរង្គោ---វ៉ាកញ្ជន១វ៉ាធម្មិ១វ៉ា

៤- --ប១វ៉ាកប្ញិង១វ៉ាអនរោក១កុយជា១

៥- (កុទ្ធេន១កុ)អំរសប្លេមររស្រេព្ធចំកាមាត្លោ

៦- ង១០ស្រេព្ធ(កំទោត)មាត្លោង៧ស្លាតំ២០០ត្កុរ២០

៧- អំនោយបួញ្ញរាំព្ធតវ្រះកម្រ

៨- តាងអញ្ញគ្រីចណ្ហីត្លូរ ។។[1] កោគប្រក១

៩- មកុដ១ត្រីបា(ទ)[2] លង្គៅ១សងហ្វារមាស១កួស

១០- លង្គៅ១តោងវ៉ាយលង្គៅសម្រុក២ថ្លា

១១- ទនហ៊ុំលង្គៅ១ជគរលង្គៅសម្រុក២

១២- ថាស១ស្រគេះសម្រុក១ភាជនលង្គៅ១

១៣- ក្ដុំវ្រះតសិ វ៉ាកញ្ចៃ១វ៉ាបរោយ១វ៉ាក្រាទ១

១៤- វ៉ាតេង១វ៉ាលោត១វ៉ាអន្លិស១វ៉ាកំវៅ១

១៥- វ៉ាអរស១វ៉ាត្ករ១វ៉ាកំទោត១វ៉ាត្លេង១

១៦- កុកញ្ចុង១កុយេលង១កុកញ្ចិត១កុវៅត១

១៧- កុមានរអញ្ញ១កុយេហ្វាយ១កុយេ

១៨- មាយ១កុត្បោញ្ញ១កុស្តេប១កុយេព្ធ១

---

[1] ស្នាមគំនូសខ្សែបញ្ឈរពីរ ដូចគ្នានឹងលេខ២បុរាណ ។

[2] ស្នាមគំនូសដូចជាអក្សរ "ទ" ផង ដូចជាស្នាមលុបចោលផង ។

១៩- ស្រែឮចំកាត្លោង១មាគុិ២០-១ត្មុរ

២០- ២០-១ ស្លាតេំ២០០-១ តោង១០ គិនេះ

២១- តិរោះតេលប្រតិវទ្ធឮតវ្រះក

២២- ម្រតាងអញគ្រីទិង្គេឝ្វរ ៚០៚

## អត្ថបទជាអក្សររ៉ូម៉ាំង:

1- amṇoy sru..................vasm..............rddey
2- (ai ta) vraḥ kamratāṅ añ suvarṇṇaliṅga
3- .......y raṅko....vā kañcan I vā dharmma I vā
4- ...p I vā ka pliṅ I vā an-rok I ku ya jā I
5- [ku dven I ku] amras ple mar sre ai caṁkā mā tlo
6- ṅ 10 sre ai [kaṃdot] mā tloṅ 7 slā teṃ 100-100 tmur 20
7- amṇoy p-añ rāṃ ai ta vraḥ kamra
8- tāṅ añ śrī caṇḍīśvara // kośa prak I
9- makuṭa I trīpā[da] laṅgau I saṅ-hvār mās I klas
10- laṅgau I toṅ-vāy laṅgau samruk 2 cnā
11- ṅ dan-huṃ laṅgau I jagar laṅgau samruk 2
12- thās I srageḥ samruk I bhājana laṅgau I
13- kñuṃ vraḥ ta si vā kañai I vā paroy I vā kroda I
14- vā teṅ I vā lot I vā antis I vā kaṃvau I
15- vā aras I vā tkar I vā kaṃdot I vā tleṅ I
16- ku kañjuṅ I ku yelaṅ I ku kañcit I ku vot I
17- ku mān ra añ I ku ye hvāy I ku ye
18- māy I ku tpoñ I ku skep I ku ye ai I
19- sre ai caṃka tloṅ I mā gui 20-I tmur
20- 20-I slā teṃ 100-100-1 toṅ 10 gi neḥ
21- ti roḥ ta tel prativaddha ai ta vraḥ ka
22- mratāṅ añ śrī diṅgeśvara //o//

## អត្ថបទបកប្រែៈ

(១‑៦) អំណោយស្រូវ?--------------វស្ន-------ទ្វៃយ (ចំពោះ) ព្រះ(វ្រះកម្រតាងអញ) សុវណ្ណ លិង្គ(លិង្គមាស)---យ អង្គរ--- អ្នកបម្រើប្រុស៥នាក់ (វា៥) ស្រី៣នាក់ (កុ៣) មធ្យោបាយចិញ្ចឹមជីវិត[3] របស់ *មរ?* ស្រែនៅឯកម្ការ (១) មា ១០ត្លោង[4] ស្រែនៅឯ(កំទោត) ១មា ៧ត្លោង ស្លា២០០ដើម គោ២០ក្បាល (៧‑១២) អំណោយ ប្អញ[5] រាំ ចំពោះព្រះ(វ្រះកម្រតាងអញគ្រី) ចណ្ឌីត្វរ[6] : កោគប្រាក់១ ម្កុដ១ ត្រីបា(ទ)ស្ពាន់ (លង្គៅ)១ សង្វារមាស១ ខ្ទស់ស្ពាន់១ អន្លូងស្ពាន់២សម្រាប់? (តង្វាយសម្រុកស្ពាន់២) ថ្លា? គ្រឿង ក្រអូប ស្ពាន់១ ស្គរ? (ជគរ) ស្ពាន់ ២សម្រាប់ ថាស១ ស្រគេះ១សម្រាប់ ភាជន៍ស្ពាន់១ (១៣‑១៨) ក្ញុំបម្រើរបស់ព្រះ ជាបុរស មាន១១នាក់ (១១វា) ជាស្ត្រីមាន១០នាក់ (១០កុ) (១៩‑២២) ស្រែនៅឯចម្ការ ១ត្លោង ២១មា គោ២១ ក្បាល ស្លា ២០១ ដើម ដូង១០ដើម គឺរបស់ទាំងអស់ដូចបានថែងនេះ

---

[3] *ប្ញេ* ដែលលោក សេដេស តែងតែប្រែជាភាសាបារាំងថា Subsistance (See, Georges Cœdès, (1952). *Inscriptions du Cambodge,* vol. IV, EFEO, Paris, pp. 28-30.)

[4] *ត្លោង* ត្រូវនឹងពាក្យសំស្ក្រឹតថា *ខារី* តែពាក្យ *មា* លោក សេដេស ស្មើថា ជាឈ្មោះនៃខ្នាតរង្វាល់មួយផ្សេងទៀត ។ សូមមើល Georges Cœdès, (1954) *Inscriptions du Cambodge,* vol. VI, EFEO, Paris, pp. 32-3.

[5] ពាក្យ *ប្អញ* បែបនេះយើងកម្រដែលបានជួបប្រទះណាស់នៅក្នុងសិលាចារឹកសម័យមុនអង្គរ ។ បើតាមប្រសាសន៍បណ្ឌិត ម៉ាយឃើល វិកឃើរី ថា បច្ចេកពាក្យនេះ ដូចគ្នានឹងពាក្យ *ពោញ* ដែរ ។

[6] ជានាមថ្មីមួយរបស់ព្រះឥសូរ ដែលគេមិនដែលឃើញមាននៅលើសិលាចារឹកសម័យមុនអង្គរ ដែលបានផ្សាយរួច ។

ដែលបានជាប់[៧] ជាដង្វាយចំពោះព្រះទិង្គេស្វរៈ[៨] ។

## ២~ សិលាចារឹកប្រាសាទប្រាំបួនល្វែង[៩] :

សិលាចារឹកនេះត្រូវបានគេចារនៅលើសុំទ្វារធ្វើពីថ្មភក់ នៅប្រាសាទប្រាំបួនល្វែង[១០] ដែលតាំងនៅខាងត្បូង សាលាស្រុកថលាបរិវ៉ាត់ ប្រមាណ២គីឡូម៉ែត្រ ប្របមាត់ទន្លេមេគង្គត្រើយខាងលិច( ស្តាំ) ។ យើងបានផ្តិតសិលាចារឹក នៅថ្ងៃទី ៩ មករា ឆ្នាំ ២០០២ នៅសាលាស្រុក ដែលជាទីរក្សាទុកជាបណ្តោះអាសន្ន។ មេទ្វារដែលគេចារអត្ថបទនេះ មានទំហំកម្ពស់ ១.៧ម៉ែត្រ មុខកាត់ទទឹង ០.៦៣ម៉ែត្រ និងកម្រាស់ ០.២៣ម៉ែត្រ ។

សិលាចារឹកនេះមាន១៣បន្ទាត់ សរសេរជាភាសាខ្មែរ តែវាមានការខូចខាតប្រហែល៥០% នៅត្រង់ភាគខាង ដើម និងចុងបន្ទាត់ ពីបន្ទាត់ទី១ ដល់ទី៦ មាន

---

[7] *ប្រតិវ័ទ្ធ* មានន័យថា ប្រតិព័ទ្ធ ឬ ជាប់ជំពាក់ ។ សូមមើល Georges Cœdès, (1954) *Inscriptions du Cambodge,* vol. VI, EFEO, Paris, pp. 32-3. K. 341N:3.

[8] នេះជារហស្សនាមថ្មីមួយទៀតរបស់ព្រះឥស្វរ ។

[9] នេះប្រហែលជាសិលាចារឹកចាស់ ដែលលោក ហ្សក សេដេស ចុះលេខរួចហើយ តែយើងផ្ទៀងរកនៅក្នុងបញ្ជីមិនឃើញសោះ ទាំងបញ្ជីចាស់ និងថ្មីរបស់លោក Claude Jacques ។

[10] ជាអតីតប្រាសាទដ៏ស្កុកស្តម្ភមួយ ដែលទទួលរងនូវការខូចខាត១០០% ត្បិតតួប្រាសាទនៅសល់តែមេទ្វារធ្វើពីថ្មភក់ពីរគូរដោតក្នុងគំនរឥដ្ឋ។ សព្វថ្ងៃទីទួលប្រាសាទជាដីកម្មសិទ្ធិរបស់អ្នកស្រុក ដែលគ្របដណ្តប់ដោយចម្ការចេក និងព្រៃ។ នៅលើទួលភាគខាងជើង បង្ហាញឱ្យឃើញដានថា នៅទីនោះ ធ្លាប់ជាទីតាំងម៉ាស៊ីនអារឈើដ៏ធំទូលាយមួយ ។ នៅជុំវិញទួល មានបន្សល់ស្នាកស្នាមគូរទឹកព័ទ្ធប្រាសាទ ។

ការខូចខាតខ្លាំង និងចាប់ពីបន្ទាត់ទី៧ ដល់១៣ មានរលុបអក្សរបន្តិចបន្តួច នៅផ្នែកខាងដើម។ ទោះជាមានបាត់អក្សរជាច្រើនតួយ៉ាងនេះក៏ដោយ ក៏យើងអាចយល់បានថា អត្ថន័យនៃសិលាចារឹក គឺជាបញ្ជីឈ្មោះក្ញុំបម្រើប្រុស-ស្រី ដែលគេថ្វាយដល់អាទិទេពមិនស្គាល់នាម។ ក្រៅពីនេះ អត្ថបទចារឹកនេះ បង្ហាញឱ្យឃើញនូវនាមជាច្រើន ដែលគេប្រើប្រាស់លើមូលដ្ឋានវាក្យស័ព្ទខ្មែរចាស់ធម្មតា។ ដូច្នេះថ្វីត្បិតអត្ថបទមិនបានបញ្ជាក់អំពីសកម្មភាព ឬព្រឹត្តិការណ៍ទាក់ទងនឹងអ្វីមួយក៏ដោយ ក៏វាមានសារសំខាន់សម្រាប់អ្នកស្រាវជ្រាវខាងភាសាវិទ្យាណាស់ដែរ ហើយយើងក៏មិនចាំបាច់បកប្រែពន្យល់អត្ថបទចារឹកខាងក្រោមនេះឡើយ។

## អត្ថបទដើមជាអក្សរខ្មែរសម័យថ្មី

១- .....ក្រាំ១ វាក្មៅ(១)វាត្លប...........

២- ....ងវន១វា(ត្ស្វច)១វាក្ទង.......

៣- ....(វ)១វាត្ងៅ១វាភណដៅ១វាទ្រៅ១

៤- ....ភាន១វា(រិ)មមចិត្ត១ក្មេក្មៅ១កុ.....

៥- .....ច(ម)១កុបង្កេត១កុក្លងអ.....

៦- ...ន១(វា)កន្ទិន១កុរណោច្ឆរូ១កុយនោស១វាជ្នាំ១វាត្ករ១កុអសរ......

៧- ...តឯត១កុយធី១កោនកុយចី១កុតងេន១កុយ........

៨- ....ង១វាតឯង១កុយតាង១កុជម្វា១កុអំ(វ)ល១កុម្រតាង្រ.....

៩- ...អញ្ជី១កុយមៃ១កុចន្ទ្រាយ១កុកញ្ជោង១កុយមាង១កុ.....

១០- ...(រ)មាយ១កុក្មេកន្ទត១កុជុន១កុក្មេចនឯរកុមញ្ជរី...

១១- ...វ៉ាយ១កុពេន១កុសំបុះ១វ៉ាត្លេង១កុយ(ហ្វ)ង១កុក្តះ១កុ(រ)ង ១កុម្រតាងវ្រៅ១វ៉ា(គ្រ)...

១២- (វ៉ា)ត្វរ១កុយស្តមាន១វ៉ាកន្និន១កុក្និត១កុប្រិយទត្តិន១កុវ្រៅ១កុ ក្លបិត១វ៉ាស្រ(ច១កុជោ)....

១៣- ហ្វិល១កុត្បាក១កុវ្លចជំនា១វ៉ាកន្រេម១កុកញ្ជោង១វ៉ារំនោ (ចវ្រះ)[១១] ១

## អត្ថបទដើមជាអក្សររ៉ូម៉ាំង

1. ......kroṃ I vā kmau [I] vā tgep.........
2. .......ṅ van I vā t[sva]c I vā kmaṅ I........
3. ........[v] I vā tvau I vā bhan ṭau I vā vrau I..........
4. .......bhān I vā viṣamacitta I ᵃme kmau I ku.......
5. .......ca[m] I ku paṅket I ku klaṅ a.........
6. .......n I vā kandin I ku raṇocc rū I ku ya nos I vā jmāṃ I vā tkar I ku asaru......
7. .....ta et I ku ya dhī I kon ku ya cī I ku ta ṅen I ku ya.........
8. .....ṅ I vā ta eṅ I ku ya tāṅ I ku jamṅā I ku aṃ[va]l I ku mratāṅ -r.....
9. .....añjī I ku ya mai I ku candrāy I ku kañjoṅ I ku ya māṅ I ku........
10. .....[mo]y I ku ᵃme kandat I ku jun I ku ᵃme can er I ku mañjarī [I]...

---

[11] យើងគិតថា ប្រហែលស្មេរភ្លេចអក្សរ "ច" មួយ ។ ពីព្រោះនៅ សិលាចារឹកដទៃទៀត ឈ្មោះអ្នកបម្រើដូចគ្នានេះ គឺ *រំនោចវ្រះ* ។ សូមមើល Cœdès, Georges, (1942). Inscription d'Angkor Borei K. 557 et 600: 7, *ibid.*, vol. II, EFEO, Hanoi, p. 22; Pou, Saveros, (2001), Inscription de Prasat Neang Khmau Ka 3: 8, *Nouvelles Inscriptions du Cambodge*, vol. 2-3, EFEO, Paris, p. 196.

11. ....vāy I ku ben I ku saṃpuḥ I vā tleṅ I ku ya [hva]ṅ I ku tkaḥ I ku [va]ṅ I ku mratāṅ vrau I vā [śra].....
12. [vā] tvar I ku ya[s]ta mān I vā kandin I ku knit I ku priyadarśśana I ku vrau I ku kla pit I vā sra[c I ku jo]...
13. rhval I ku tyāk I ku vlac jaṃnā I vā kanrem I ku kañjoṅ I vā raṃno[c vraḥ] I...

## ផ្ទាំងរូបភាពដើមសិលាចារឹកប្រាសាទប្រាំបួនល្វែង



ផ្ទាំងរូបភាពដើមសិលាចារឹកចលាបរិវ៉ាត់



# ព្រះរាម ឬព្រះរាមចន្ទ្រ

ដោយ : **ឆន់ ហ៊ិន**

ព្រះរាម ឬ ព្រះរាមចន្ទ្រ ជាព្រះរាជបុត្រច្បងរបស់ព្រះបាទទសរថព្រះមហាក្សត្រក្នុងព្រះរាជត្រកូលសុរិយាវង្ស (ត្រកូលព្រះអាទិត្យ) ដែលសោយរាជ្យនៅព្រះរាជធានីអយុធ្យានៃនគរកោសល ។ ព្រះរាមអង្គនេះជាអវតារទី៧នៃព្រះវិស្ណុ ។ ព្រះអង្គមានបេសកកម្មដ៏ធំ ហើយសំខាន់បំផុតមួយដែលត្រូវបំពេញ គឺត្រូវកម្ទេចអស់នូវពូជពួក សភាវៈអាក្រក់ ដែលមានក្រុងរាពណ៍ជាស្ដេច ។ មានរឿងនិទានពីជីវិត និងដំណើរផ្សងព្រេងរបស់ព្រះអង្គនៅក្នុងរឿងរាមាយណៈដែលឥសីវាល្មិកិបានតាក់តែងចងក្រងឡើងជាកំណាព្យក្នុងភាសាសំស្ក្រឹត ដ៏មានការចាប់ចុងចួនយ៉ាងពីរោះក្បោះក្បាយ ឥតអ្វីប្រៀបផ្ទឹមបានឡើយ ។ ដំណើររឿងជាសង្ខេបរបស់ព្រះអង្គមានដូចតទៅ ៖

"ព្រះបាទទសរថ ដែលសោយរាជសម្បត្តិនៅក្រុងអយុធ្យា ជាព្រះមហាក្សត្រប្រកបដោយទសពិធរាជធម៌មួយព្រះអង្គ និងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ សម្រាប់អស់អាណាប្រជានុរាស្ត្ររបស់ព្រះអង្គ ។ ព្រះនគរបានស្គាល់នូវសេចក្ដីសុខក្សេមក្សាន្ត សេចក្ដីសប្បាយ និងសេចក្ដីចម្រើនរុងរឿងជាពន់ពេក ។ ប៉ុន្តែព្រះអង្គទ្រង់ជួបនឹងការសោកស្ដាយមួយ

ក្នុងជីវិតគឺព្រះអង្គពុំមានព្រះរាជបុត្រសោះ ថ្វីបើព្រះអង្គមានព្រះមហេសី ដល់ទៅបីព្រះអង្គហើយក៏ដោយ។ ព្រះអង្គបានសម្រេច ព្រះទ័យប្រារព្ធពិធី បូជាយញ្ញអស្វមេធមួយ ដោយមានការរៀបចំយ៉ាងត្រឹមត្រូវបំផុត និងក្នុង សេចក្ដីសង្ឃឹមមួយថា ព្រះអង្គនឹងបានទទួលព្រះរាជបុត្រជាមិនខាន ។ ភក្ដីភាពរបស់ព្រះអង្គបានញ៉ាំង ពួកទេពតារីករាយណាស់នឹងទទួលយក ដោយសន្យាថា នឹងប្រទានព្រះរាជបុត្របួនព្រះអង្គជាចំណងដៃ ។ ព្រម ពេលជាមួយគ្នានោះដែរ ជួនជាអស់ទាំងទេវតាកំពុងស្ថិត នៅក្នុងសភាព ភ័យព្រួយឥតឧបមា ដោយសារការគំរាមកំហែងមកលើពួកព្រះអង្គ ពី សម្នាក់ក្រុងរាពណ៍ ជាស្ដេចនៃពួកយក្ស ពួកអារក្ស បិសាច អសុរកាយ នៅឯក្រុងលង្កា ។ ក្រុងរាពណ៍បានទទួលតេជានុភាពយ៉ាងខ្លាំងអស្ចារ្យពី ព្រះព្រហ្មា ដោយសារតែវាកាន់វត្តប្រតិបត្តិដ៏តឹងរ៉ឹង និងឧទ្ទិសភក្ដីភាព ចំពោះព្រះព្រហ្មា ។ នៅចំពោះមុខសេចក្ដីភ័យខ្លាចបែបនេះ ពួកទេព្ដាក៏ អំពាវនាវព្រះវិស្ណុជួយរំដោះ ។ ព្រះវិស្ណុក៏សម្រេចព្រះ ទ័យស្ដែងជារូប ចេញមកលើភពផែនដីនេះ ដោយយកព្រះបាទទសរថ ធ្វើជាព្រះបិតា សម្រាប់ព្រះអង្គ ច្យុតិមកយោនយកកំណើតជាមនុស្សលោក។ ក្នុងខណៈ ដែលព្រះបាទទសរថកំពុងប្រារព្ធពិធីបូជាយញ្ញ ព្រះវិស្ណុក៏លេចចេញពីក្នុង ភ្លើងពិសិដ្ឋមកឃើញ នៅចំពោះមុខព្រះបាទទសរថ មានរូបរាងជាជន ម្នាក់ដ៏សែនរុងរឿង រួចប្រទានបាយាសទិព្វមួយផ្ដិលថ្វាយចំពោះព្រះអង្គ ដើម្បីព្រះអង្គប្រទានទៅព្រះមហេសីទ្រង់សោយ។

ព្រះបាទទសរថទ្រង់រំលែកបាយាសទិព្វនោះ ពាក់កណ្ដាលប្រទាន

ទៅព្រះនាងកោសល្យសោយនៅសល់ពីនោះ ពាក់កណ្ដាលទ្រង់រំលែកជាពីរភាគស្មើគ្នា (ត្រូវជាមួយភាគបួន) ប្រទានទៅព្រះនាងសុមិត្រា សោយមួយភាគ ។ ចំណែកដែលនៅសល់ ព្រះអង្គប្រទានទៅព្រះនាងកៃកេយិសោយពាក់កណ្ដាល (ត្រូវជាមួយភាគប្រាំបី) ឯចំណែកដែលនៅសល់ជាចុងក្រោយ ព្រះអង្គប្រទានទៅព្រះនាងសុមិត្រាសោយម្ដងទៀត ជាបង្ហើយ ។ លុះដល់កាលកំណត់ហើយ ព្រះរាមទ្រង់ប្រសូតចេញមកពីព្រះនាងកោសល្យ ព្រះភរតៈប្រសូតចេញមកពីព្រះនាងកៃកេយិ ព្រះលក្ស្មណ៍ និង ព្រះសត្រុឃ្ន ជាព្រះរាជបុត្រភ្លោះប្រសូតចេញពី ព្រះនាង សុមិត្រា ។ នេះគឺដោយសារព្រះនាងសុមិត្រាបានសោយបាយាសទិព្វដល់ ទៅពីរដង ។ ព្រះជេដ្ឋកនិដ្ឋាទាំងបួនព្រះអង្គមានសេចក្ដីស្នេហាស្វាមីភ័ក្តិ រវាងគ្នានិងគ្នាណាស់ ។ នេះគឺដោយសារអានុភាពនៃបាយាសទិព្វ តែមួយផ្ដិលដែលព្រះមាតាបានសោយជាមួយគ្នា ។ ប៉ុន្តែ ព្រះលក្ស្មណ៍មានភក្ដីភាពយ៉ាងពិសេសជាមួយព្រះរាម បីដូចជាព្រះ សត្រុឃ្នជាមួយព្រះភារតៈដែរ ។

ប្រភពខ្លះបានលើកពីមូលហេតុនៃភក្ដីភាពពិសេសរវាងព្រះរាជបុត្រទាំងបួនព្រះអង្គ ដោយសំអាងថា ព្រះបាទទសរថទ្រង់រំលែកបាយាសទិព្វសម្រាប់តែព្រះមហេសីថ្នាក់ខ្ពស់ពីរព្រះអង្គ គឺព្រះនាងកោសល្យ និងព្រះនាងកៃកេយិ ។ លុះព្រះនាងសុមិត្រាសុំសោយខ្លះ ព្រះបាទទសរថក៏សុំមហេសីទាំងពីរព្រះអង្គនោះ រំលែកថ្វាយព្រះនាងសុមិត្រាខ្លះ ។ មហេសីទាំងពីរអង្គក៏រំលែកបាយាស ជាចំណែករបស់ព្រះអង្គផ្ទាល់ ជាពីរចំណែកស្មើៗគ្នា ប្រទានទៅព្រះនាងសុមិត្រាសោយ ។ ដូច្នេះបាយាសទិព្វនោះ

ត្រូវបានរំលែកជាបួនចំណែក ស្មើៗគ្នា ក្នុងនោះ ព្រះនាងសុមិត្រាបាន ទទួលពីរចំណែក គឺពីព្រះនាងកោសល្យមួយចំណែក និងពីព្រះនាង កៃកេយិ មួយចំណែក ។ ព្រោះហេតុនេះហើយ ទើបបានជាព្រះនាងសុមិត្រាប្រសូត បុត្រភ្លោះ គឺបាយាសមួយចំណែក ដែលព្រះនាងបានទទួលពីព្រះនាង កោសល្យ ព្រះនាងសុមិត្រាប្រសូតបានព្រះលក្ស្មណ៍ ដែលជាមិត្តប្រកបដោយភក្តីភាព បំផុតរបស់ព្រះរាម រីឯចំណែកដែលព្រះនាងបានទទួលពីព្រះនាងកៃកេយិ មកព្រះនាងសុមិត្រាប្រសូតបានព្រះសត្រុឃ្ន ដែលជាមិត្តប្រកបដោយភក្តីភាពបំផុត របស់ព្រះភារតៈ។ យោងតាមទស្សនៈ ខាងក្រោយនេះ ព្រះរាជបុត្រទាំងបួនអង្គគួរ តែមានលក្ខណៈជាអាទិទេព និងមានតេជានុភាពស្មើៗគ្នា ប៉ុន្តែ តាមពិតទៅគឺមាន តែព្រះរាមមួយអង្គឯងគត់ ដែលប្រកបដោយលក្ខណៈជាអ្នកមានឧត្តមភាព ឬជា អ្នកមានបុណ្យ មានបារមីលើសគេ ។ ព្រះរាជកុមារទាំងបួនព្រះអង្គទ្រង់ចម្រើន វ័យវឌ្ឍនាការនៅក្នុងព្រះរាជធានីអយុធ្យា ។ ប៉ុន្តែនៅពេលដែលព្រះអង្គមិនទាន់ ធំពេញរូបរាងស្រួលបួលផង ស្រាប់តែឥសីវិស្វាមិត្រនិមន្តមកដល់ព្រះរាជវាំង សុំនាំ យកព្រះរាមទៅជួយការពារព្រះអង្គទល់នឹងពួករាក្សសៈ ។ ព្រះបាទទសរថទ្រង់ពុំ សព្វព្រះទ័យ នឹងព្រះរាជបុត្រនៅក្មេងខ្ចីទៅបំពេញបេសកកម្ម ដ៏គ្រោះថ្នាក់នេះទេ ប៉ុន្តែ ព្រះអង្គត្រូវទទួលការគាបសង្កត់ពីឥសីវិស្វាមិត្រ ក៏ព្រោះតែព្រះអង្គបានមាន ព្រះរាជឱង្ការជាមួយឥសីអង្គនេះជ្រុលហួសផុតទៅហើយ ។ ឥសីវិស្វាមិត្រក៏នាំ ព្រះរាមចេញទៅ ព្រះលក្ស្មណ៍យាងទៅតាមផង សំដៅទៅកាន់អាស្រមរបស់ ឥសីវិស្វាមិត្រ ។ នៅទីនោះ ឥសីវិស្វាមិត្រសុំព្រះរាមសម្លាប់យក្ខិនីមួយរូបឈ្មោះ *តារកា* ។ មុនដំបូងព្រះរាមមានព្រះទ័យអល់ឯកណាស់ ក្នុងការសម្លាប់ជនម្នាក់

ដែលជាស្ត្រីភេទដូច្នេះ ។ ប៉ុន្តែ ឥសីវិស្វាមិត្របានប្រើអស់មធ្យោបាយ ដើម្បីពន្យល់ព្រះអង្គទ្រង់សព្វព្រះទ័យធ្វើតាម ។ ឥសីវិស្វាមិត្របានថ្វាយអាវុធទិព្វ ចំពោះព្រះរាម ព្រមទាំងជួយបង្ហាត់បង្ហាញពីការប្រើអាវុធទាំងនោះចំពោះព្រះអង្គថែមទៀតផង ។ ក្រោយពីនោះមក ឥសីវិស្វាមិត្រក៏នាំព្រះរៀមព្រះអនុជទាំងពីរព្រះអង្គទៅកាន់ព្រះរាជវាំងរបស់ព្រះបាទជនកៈ ក្នុងព្រះរាជធានីមិថិលានៃនគរវិទេហៈ ។ ព្រះមហាក្សត្រនៃនគរនេះ ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គប្រកបដោយរូបឆោមលោមពណ៌ល្អស្រស់ប្រិមប្រិយពន់ពេកណាស់ ។ ទ្រង់ព្រះនាមថាព្រះនាង "សីតា" ។

ព្រះបាទជនកៈជាបិតា ទ្រង់មានព្រះតម្រិះថា ព្រះអង្គនឹងលើកព្រះនាងរៀបអភិសេកជាមួយនឹងជនណាម្នាក់ ដែលអាចយឹតព្រះកៅទណ្ឌជារបស់ ព្រះសិវៈនោះរួច ។ កាលពីមុនមកគ្រប់ក្សត្រ ដែលចូលទៅប្រឡងប្រជែងនុំះពុំមានក្សត្រិយ៍អង្គណាមួយអាចទទួលបានជោគជ័យទេ ។ មានតែព្រះរាមមួយព្រះអង្គគត់ ដែលមិនត្រឹមតែយឹតធ្នូនោះរួចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចកាច់បំបាក់វាបានទាំងឮសូរដូចរន្ទះបាញ់ទៀតផង ។ ព្រះរាមត្រូវទទួលជ័យជម្នះបានម្ចាស់ក្សត្រីធ្វើជាព្រះមហេសី ។ ព្រះនាងជាស្ត្រីប្រកបដោយគុណធម៌ និងមានភក្តីភាពជាទីបំផុតចំពោះព្រះស្វាមី ។ (ក្រោយមកព្រះលក្ស្មណ៍បានរៀបអភិសេកជាមួយម្ចាស់ក្សត្រីជាប្អូនបង្កើតរបស់ព្រះនាងសីតា ឯព្រះភារតៈ និង ព្រះសត្រុឃ្ន ក៏ព្រះអង្គរៀបអភិសេកជាមួយម្ចាស់ក្សត្រីពីរអង្គ ដែលត្រូវជាព្រះអនុជអយ្យកាមួយរបស់ព្រះនាងសីតាដែរ) ។

ការកាច់បំបាក់ធ្នូព្រះសិវៈនៅក្នុងព្រះរាជវាំង នៃព្រះបាទជនកៈ គឺជា

ឧប្បត្តិហេតុមួយគួរកើតមាន ការអស្ចារ្យជាពន់ពេកណាស់ ។ ព្រឹត្តិការណ៍នោះកើតឡើងនៅក្នុងសម័យកាលមួយ ដែលព្រះបរាសុរាម ជា អវតារទី ៦ នៃព្រះវិស្ណុកំពុងមានជីវិតនៅលើផែនដីនេះនៅឡើយ ។ ព្រះអង្គបានយោនយកកំណើតជាព្រាហ្មណ៍ក្នុងគោលដៅមួយ គឺដើម្បីកម្ទេចពូជក្សត្រិយ៍អស់ ។ ព្រះអង្គជាអ្នកប្រតិបត្តិមាតិរបស់ព្រះសិវៈ ចំណែកឯការកាច់បំបាក់ធ្នូរបស់ព្រះសិវៈនោះ គឺជាការប្រមាថកាតទានមួយចំពោះព្រះអង្គ ។ ដោយមិនមានគិតទេថា ព្រះរាមក៏ជាអវតាររបស់ព្រះវិស្ណុដូចព្រះអង្គដែរនុ៎ះ បរាសុរាមក៏បបួលព្រះរាម សាកកម្លាំងគ្នាល្បងមើល ។ ក្នុងការសាកល្បងគ្នានោះ បរាសុរាមទទួលបរាជ័យ ប៉ុន្តែត្រូវព្រះរាមទុកជីវិតថ្វាយដោយសារព្រះអង្គទ្រង់ព្រះតម្រិះថា បរាសុរាមក៏ជាព្រាហ្មណ៍មួយអង្គដែរ ។

នៅឯក្រុងអយុធ្យាមានការរៀបចំពិធីរាជាភិសេក ដើម្បីលើកព្រះរាមសោយរាជ្យស្នងព្រះបិតា ។ ព្រះនាងកៃកេយិជាមហេសីទីពាររបស់ព្រះបាទទសរថ និងជាមាតារបស់ព្រះភារតៈ ជាមហេសីសំណព្វព្រះទ័យបំផុតរបស់ព្រះបាទទសរថ ។ ពីដំបូងឡើយ ព្រះនាងមានព្រះទ័យស្នេហាលើព្រះរាមខ្លាំងណាស់ សឹងតែស្នេហាលើសព្រះរាជបុត្របង្កើតរបស់ព្រះនាងផង ។ ប៉ុន្តែ ព្រះនាងមានស្រីបម្រើម្នាក់ខ្នងគមជាប់ជាបងប្អូន ឈ្មោះនាងមន្ថារ (ឬមន្ថរា) ដែលជាអ្នកចូលចិត្តច្រណែនឈ្នានីស ។ នាងមន្ថារបានលើកគំនិតពីសេចក្ដីស្នេហារវាងមាតានិងបុត្រ ដើម្បីញុះញង់ព្រះនាងកៃកេយិ កើតព្រះទ័យច្រណែនព្រះរាមយ៉ាងខ្លាំងរហូតដល់រំអុកព្រះស្វាមីសព្វព្រះទ័យលើកព្រះភារតៈឡើងសោយរាជសម្បត្តិវិញ ។

រឿងអាស្រូវនេះ បានក្លាយទៅជាការប្រកែកប្រណាំង និងការតស៊ូមួយ

យ៉ាងយូរហើយនៅទីបំផុត ព្រះបាទទសរថត្រូវបង្ខំព្រះទ័យយល់ព្រមតាមការ ទាមទាររបស់មហេសីចុងទៅ ។ ដូច្នេះ ព្រះអង្គត្រូវបំបរបង់ព្រះរាមទៅនៅក្នុងព្រៃសម្រាប់រយៈកាល ១៤ ឆ្នាំ រួចលើកព្រះភារតៈឡើងគ្រងរាជសម្បត្តិបន្តពីព្រះអង្គជាជំនួសព្រះរាមវិញទៅ ។ ព្រះរាមក៏ចាកចេញពីព្រះនគរជាមួយព្រះនាងសីតាជាមហេសី និងព្រះលក្សណ៍ជាព្រះអនុជ ឆ្ពោះទៅទិសខាងត្បូងរួចទ្រង់តាំងព្រះដំណាក់នៅឯភ្នំជេត្រកូតក្នុងព្រៃទណ្ឌកៈ ស្ថិតនៅចន្លោះទន្លេយមុនា និងទន្លេគោទាវរី ។

ក្រោយពីព្រះរាមយាងចេញផុតបានបីថ្ងៃ ព្រះបាទទសរថក៏សោយព្រះទិវង្គតព្រោះតែសេចក្ដីទុក្ខ និងសេចក្ដីសង្រេងសង្រៃខ្លាំងហួសពេក ។ គេក៏បញ្ជូនមហាតលិកទៅតាមព្រះភារតៈ ដែលបានយាងទៅក្រសាលលេងនៅឯនគរកេក័យរបស់ព្រះមាតុលាមកទទួលគ្រងរាជសម្បត្តិ ។ ប៉ុន្តែ ព្រះភារតៈមិនសព្វព្រះទ័យនឹងរាជសម្បត្តិខុសច្បាប់នោះទេ ។ ព្រះអង្គបាននាំកងរេហ៍ពលមួយកងធំអមដោយប្រជារាស្ត្រស្ម័គ្រចិត្តជាច្រើន ឆ្ពោះទៅកាន់ទិសខាងត្បូង ដើម្បីតាមរកព្រះរាម និងសុំព្រះអង្គយាងត្រឡប់មកវិញ ។ ក្នុងពេលដែលព្រះរៀម និងព្រះអនុជបានជួបគ្នាមានការពិភាក្សាខ្វែងយោបល់គ្នាយ៉ាងយូរ គឺព្រះរាមមិនសព្វព្រះទ័យយាងត្រឡប់ទៅព្រះនគរវិញទេ ដរាបណាលក្ខខណ្ឌរបស់ព្រះបិតាមិនទាន់អនុវត្តចប់ ។ រីឯព្រះភារតៈវិញ ព្រះអង្គក៏មិនសព្វព្រះទ័យឡើងសោយរាជសម្បត្តិដែរ ។ ការជជែកតវ៉ាគ្នាទៅវិញទៅមក ក៏បានឈានទៅដល់ការសម្រុះសម្រួលទៅលើរូបមន្តមួយគឺព្រះភារតៈគួរតែត្រឡប់ទៅវិញ ដើម្បីបំពេញកិច្ចរាជការ ក្នុងឋានៈជាព្រះរាជប្រតិភូរបស់ព្រះរាម ។

ដើម្បី ជានិមិត្តរូបនៃបរមានុភាពរបស់ព្រះរាម ព្រះភារតៈ ក៏យកព្រះបាទុកាមួយគូរបស់ព្រះរាមមកជាមួយផង ។ ព្រះបាទុកាមួយគូនោះ ព្រះភារតៈតែងយកចេញមក ដោយសេចក្ដីគោរពបំផុតនៅរាល់ពេលណាដែលព្រះអង្គទ្រង់សម្រេចកិច្ចរាជការផែនដីម្ដងៗ ។ ព្រះរាមរស់នៅក្នុងភាពបំបរបង់អស់ថេរវេលា ១០ឆ្នាំ ដោយដូរព្រះដំណាក់ពីកន្លែងមួយទៅកន្លែងមួយទៀត ។ នៅទីបំផុតព្រះអង្គក៏យាងទៅកាន់ អាស្រមរបស់ឫសីអគស្ត្យ ដែលតាំងនៅជិតភ្នំវិន្ធ្យា ។ ឫសីអង្គនេះបានថ្វាយយោបល់ទៅព្រះរាមថា ព្រះអង្គទៅតាំងព្រះដំណាក់នៅឯទីបញ្ចាវតី ដែលស្ថិតនៅលើដងទន្លេគោទាវរី ។ ក្សត្រាក្សត្រីទាំងបីព្រះអង្គក៏នាំគ្នាយាងទៅកាន់ទីនោះវិញ ។

តំបន់នេះសឹងសម្បូណ៌ដោយពួករក្សសៈណាស់ ។ មានរក្សសៈមួយនោះត្រូវជាប្អូនស្រីរបស់ក្រុងរាពណ៍ផង ដែលមានឈ្មោះថា *សូរបនខា* ។ លុះសូរបនខាបានឃើញព្រះរាមកាលណា វាក៏ចាប់ចិត្តស្នេហាមកលើព្រះអង្គភ្លាម ទាំងប្រញាប់ដើរមករកព្រះអង្គផង ប៉ុន្តែត្រូវព្រះអង្គច្រានវាចេញភ្លាមដែរ ។ ដោយកើតចិត្តប្រច័ណ្ឌពេក វាក៏រត់សំដៅទៅរកវាយព្រះនាងសីតា ។ ព្រះលក្ស្មណ៍ឃើញហេតុដូច្នោះទ្រង់ព្រះពិរោធណាស់ ។ ព្រះអង្គក៏យកអាវុធកាត់ត្រចៀកវាម្ខាង និងកាត់ច្រមុះវាដាច់ទៅ ។

សូរបនខាក៏ទៅនាំបងប្រុសរបស់វាពីរនាក់ ឈ្មោះក្រុងខរមួយ និងខុនទូសន៍មួយដោយមានទាំងរេហ៍ពលយក្សមកជាមួយផង ក្នុងបំណងសងសឹកខ្លួនវា ប៉ុន្តែត្រូវព្រះរាមកម្ទេចអស់ទៅ ។ ដោយសារការឈឺចិត្តនឹងពិការភាពរបស់វាពេក សូរបនខាក៏ទៅរាយរ៉ាប់ប្រាប់ក្រុងរាពណ៍ ជាបងរបស់វានៅក្រុងលង្កា ព្រមទាំង

បញ្ចុះបញ្ចូលក្រុងរាពណ៍កើតចិត្តប្រតិព័ទ្ធ កើតតណ្ហាក្រាស់ទៅលើសម្ផស្សរបស់ព្រះនាងសីតាផង ។ ក្រុងរាពណ៍ជិះវិមានអណ្តែតលើអាកាសហោះសំដៅទៅកាន់ដំណាក់ព្រះរាម ក្នុងពេលដែលអ្នកសមគំនិតរបស់វា គឺមារីចៈកំពុងប្រែកាឡាខ្លួនធ្វើជាប្រើសមាសមួយក្បាល ដើម្បីបញ្ឆោតព្រះរាមដេញតាម កាន់តែឆ្ងាយពីព្រះដំណាក់ ។ ឆ្លៀតឱកាសដែលព្រះរាម និងព្រះលក្ស្មណ៍កំពុងចាញ់បញ្ឆោតមារីចៈនុំះ ក្រុងរាពណ៍ក៏ក្លែងធ្វើជាអ្នកបួសនិមន្តបិណ្ឌបាត ហើយនិយាយល្បួងព្រះនាងសីតាជឿតាមវារហូតដល់វាបានឱកាសបង្ហាញការពិត ។ វាក៏ប្រើកម្លាំងចាប់ព្រះនាងយកទៅក្រុងលង្កាបាត់ទៅ ។ ព្រះរាមទ្រង់ស្ថិតនៅក្នុងក្តីអស់សង្ឃឹម និងទ្រង់ព្រះពិរោធជាខ្លាំង កាលបើបាត់ព្រះមហេសីដែលមានភក្តីភាពបំផុតនេះ ។ ព្រះរាម និង ព្រះលក្ស្មណ៍ក៏នាំគ្នាចេញព្រះដំណើរសំដៅទៅទិសខាងត្បូង ។ នៅតាមដងផ្លូវព្រះអង្គបានសម្លាប់យក្សឥតក្បាលមួយឈ្មោះកព័ន្ធ ។ មុននឹងរ្លោប់វាបានទូលព្រះរាមថា ព្រះអង្គទៅសុំជំនួយពីព្រះបាទសុគ្រីពជាស្តេចពានរ ។ ព្រះរាមបានទទួលការគាំទ្រ ដោយកងរេហ៍ពលទាំងមូលរបស់សុគ្រីព ព្រមទាំងអគ្គសេនា ដ៏វាងវៃរបស់សុគ្រីពផង គឺហនុមាន ដែលជាបុត្ររបស់ព្រះវាយុ ។ ហនុមានបានទៅស៊ើបរកព្រះនាងសីតាឃើញនៅឯកោះលង្កា ។ វាមានតេជានុភាពដ៏អស្ចារ្យខាងលោត និងហោះ ដែលអាចវាបំពេញកិច្ចការស៊ើបអង្កេតនោះបាន ដោយជោគជ័យ ។ ខ្លួនវានិងកងរេហ៍ពលមានកម្លាំងកាយដ៏ខ្លាំងមហាអស្ចារ្យ ដែលអាចវាសង់ស្ពានពីថ្មបណ្តែតទឹកឆ្លងទៅដល់ក្រុងលង្កាបាន ។ ស្ពាននោះមានឈ្មោះថា *"រាមសេតុ"* ឬតាមឈ្មោះមួយទៀតថា *"នលសេតុ"* ។ បន្ទាប់ពីការប្រយុទ្ធគ្នាយ៉ាងរបើងរីងរូសដ៏យូរមក ព្រះរាមក៏មានជ័យជម្នះយកក្រុងលង្កាបាន ។ ក្រុងរាពណ៍ត្រូវស្លាប់នៅ

លើសមរភូមិប្រយុទ្ធ ព្រមជាមួយនឹងមេទ័ពឯទៀតៗផង ។ ព្រះនាងសីតាត្រូវបាន ព្រះស្វាមីរំដោះរួច ។

ថ្វីបើការរំដោះព្រះអគ្គមហេសីបានមកវិញនោះជាការធ្វើ ឱ្យព្រះរាមកើត ព្រះទ័យរីករាយក៏ពិតមែន តែព្រះអង្គមិនបានទទួលព្រះនាង ក្នុងទឹកព្រះទ័យ កក់ក្ដៅឡើយ ។ ព្រះអង្គថែមទាំងមិនព្រមទទួលព្រះនាងត្រឡប់ទៅជាមួយ ព្រះអង្គវិញផង ព្រោះព្រះអង្គនៅទ្រង់ព្រះតម្រិះអំពីកិត្តិយសរបស់ព្រះនាង។ ព្រះនាង សីតាទ្រង់ទូលព្រះស្វាមីជាមួយយប្រើព្រះវាចាដ៏ថ្លៃថ្នូរគួរអាសូរ និងគួរសង្វេគ ជាពន់ពេកណាស់ ដើម្បីញ្ជាក់ពីភក្ដីភាពដ៏បរិសុទ្ធរបស់ព្រះនាងចំពោះព្រះស្វាមី ព្រម ទាំងហ៊ានសម្រេចព្រះទ័យយកព្រះអគ្គីធ្វើជាបន្ទាល់សាក្សីផង ។ នៅចំពោះមុខ មនុស្សម្នា និងទេវតាផងទាំងឡាយ ព្រះនាងសីតាក៏យាងចូលក្នុងអណ្ដាតភ្លើង ។ ព្រះអគ្គីព្រះនាងយាងចូលរួចលើកព្រះនាង ដែលពុំមានរលាកបន្តិចណាសោះ ដាក់ ទៅក្នុងរង្វង់ ព្រះហស្ដរបស់ព្រះរាមទៅ ។ បន្ទាប់មក ព្រះរាមទ្រង់នាំគ្នីគ្នារបស់ ព្រះអង្គត្រឡប់ទៅកាន់ក្រុងអយុធ្យាវិញ ជួបជុំព្រះញាតិវង្សក្នុងបរិយាកាសដ៏សែន រីករាយឥតឧបមា។ព្រះរាមក៏ទទួលរាជាភិសេកគ្រងរាជ សម្បត្តិ ជាព្រះមហាក្សត្រ មួយព្រះអង្គដ៏ឧត្តុង្គឧត្តម ព្រោះតែទ្រង់ប្រកបដោយព្រះគតិបណ្ឌិតទ្រង់សុចរិត ត្រឹមត្រូវ និងជាម្លប់ដ៏កក់ក្ដៅសម្រាប់អស់អាណាប្រជានុរាស្ដ្រគ្រប់វណ្ណៈ ។ ព្រះនគរក៏បានស្គាល់សេចក្ដីសុខ និងសេចក្ដីចម្រើនជាបន្តមកទៀតប្រជារាស្ដ្របាន ជួបភាពសម្បូរណ៍សប្បាយជារៀងរហូតទៅ ។

នៅវគ្គចុងក្រោយនេះ មានការនិទានបន្ថែមទៀតថា នៅក្នុងកណ្ដាប់ដៃ នៃពួកយក្ស ព្រះនាងសីតា បានទទួលការថែទាំប្រសើរជាងអ្វីដែលគេគិតស្មានទុក ។

ព្រះនាងសីតា ទ្រង់មានព្រះសវនីយ៍អះអាងអំពីភក្តី ភាពដ៏បរិសុទ្ធរបស់ព្រះនាងចំពោះព្រះស្វាមី ញ៉ាំងព្រះរាមមានជំនឿទៅលើការពោលអះអាងនេះ ។ ក្នុងពេលដែលព្រះនាងត្រូវក្រុងរាពណ៍បង្ខាំងទុកនៅក្រុងលង្កានោះ ព្រះនាងតែងទទួលការបីបាច់យ៉ាងល្អពីអ្នកថែទាំព្រះនាង ។ ប៉ុន្តែ ដើម្បីជាកិត្តិយសរបស់ព្រះអង្គផង និងជាកិត្តិយសរបស់ព្រះនាងផ្ទាល់ផង ហើយដើម្បីចៀសវាងនូវពាក្យនិន្ទា ពីអស់អាណាប្រជានុរាស្ត្រផង ព្រះអង្គក៏សម្រេចព្រះទ័យបញ្ជូនព្រះនាងទៅកសាងជីវិតចុងក្រោយនៅក្នុងព្រៃ ។ ឫសី វាល្មីកិបានទទួលយកព្រះនាងអាស្រ័យនៅជាមួយក្នុងអាស្រមរបស់ ព្រះអង្គ ។

( *នៅមានត* )

*កុំយកវិជ្ជា ទៅប្រឡង*
*ឬប្រកួត នឹងវាសនា ។*

ព្រះឧត្តមមុនី អ៊ុំ សូ

# ប្រវត្តិបឹងកោះត្នោត

ដោយ : **ជួប យាន**

## ១_ ទីតាំងបឹងកោះត្នោត

បឹងកោះត្នោត ជាបឹងមួយ ក្នុងចំណោមបឹងនានា ដែលស្ថិតនៅលើភូមិសាស្ត្រ ទឹកដីភូមិកោះត្នោត ក្នុងឃុំកោះខ្សែរ ស្រុកសំបូរ ខេត្តក្រចេះ។ បឹងនេះស្ថិតនៅលើទីទួលមួយ ប្រមាណ មួយគីឡូម៉ែត្រកន្លះ ពីមាត់ទន្លេមេគង្គខាងកើតទៅផ្ទៃបឹងនោះ។ បើប្រៀបធៀបមកមាត់ទន្លេខាងកើត ផ្ទៃបឹងនោះស្ថិតនៅទន្ទឹមនឹងភូមិស្វាន (ត្រើយខាងកើត)។

## ២_ ស្ថានភាពបឹង និងការរស់នៅកន្លងមក

តាមបទតំណាលតៗគ្នាមកថា: កាលពីជំនាន់មុនពោធិកំបោរ[១] ប្រមាណ ៥០ឆ្នាំ មានកុលសម្ព័ន្ធខ្មែរលើមួយក្រុម មកតាំងទីរស់នៅប្រកបការងារក្នុងភូមិនេះ មានមុខរបរចិញ្ចឹមជីវិត ដោយធ្វើស្រែចំការ និងបរបាញ់សត្វ។

ក្នុងចំណោមអ្នកប្រមាញ់ទាំងនោះ មានយុវជនកំព្រាម្នាក់ ឪពុកម្តាយស្លាប់ចោលតាំងពីនៅវ័យកុមារ។ ដោយយុវជនកំព្រារស់នៅជាមួយជីដូនចាស់ម្នាក់ ទើបគេឱ្យឈ្មោះយុវជននោះថា "*ចៅយាយ*"។ ចៅយាយ ជាក្មេងជំទង់ម្នាក់ដែលមានទេពកោសល្យ និងឈ្លាសវៃនៅក្នុងការបរបាញ់សត្វ។ រាល់ពេលដែលចៅយាយ វិល

---

១-សកម្មភាពពោធិកំបោរតស៊ូវាយបារាំង ឆ្នាំ ១៨៦៤-១៨៦៥

ត្រឡប់មកពីបរបាញ់វិញតែងតែបានជ្រូកព្រៃ ប្រើស ក្តាន់ ឈ្លូសព្រៃ ជានិច្ចកាល យកមកចិញ្ចឹមខ្លួនឯងផង ចិញ្ចឹមជីដូនជរាផង និងដោះដូរស្រូវ អង្ករ សំពត់ អាវ ស្បៀកពាក់ផង។

អ្នកដែលចេញទៅបរបាញ់សត្វជាមួយចៅយាយ ជួនបាន ជួនមិនបានសត្វទាល់តែសោះ។ ចំណែកចៅយាយ បាន រាល់តែពេលដែលខ្លួនចេញទៅបរបាញ់។ រយៈពេលក្រោយមក ក្រុមអ្នកចេញទៅបរបាញ់ទាំងនោះកើតក្តីច្រណែននិន្ទានឹងចៅយាយ ក៏ជំនុំគ្នាថា: "*បើទុកចៅយាយ ឱ្យរស់នៅជាមួយនឹង ក្រុមយើងៗ ប្រាកដជាឥតលាភហើយ ព្រោះលាភទាំងនោះរត់ទៅខាងចៅយាយរាល់តែលើក*"។ ក្រោយពេលដែលជំនុំឯកភាពគ្នារួចហើយ ស្របពេលដែលមេកន្ទ្រាញ ចាត់តាំងឱ្យក្រុមនោះទៅបរបាញ់សត្វយកមកធ្វើជាម្ហូបក្នុងពិធីជប់លៀងដ៏មហោឡារិក នាពេលលៀងអារក្សថ្ងៃខានស្អែក ក្រុមនោះក៏ទៅបបួលចៅយាយឱ្យទៅបរបាញ់សត្វជាមួយក្រុមខ្លួនដូចសព្វកាលមុនៗដែរ។ លុះចូលទៅដល់ព្រៃជ្រៅឆ្ងាយពីភូមិឋានប្រមាណថ្ងៃរសៀលបន្តិច ក្រុមទាំងនោះក៏ព្រួតគ្នាចាប់ចៅយាយសម្លាប់ ហើយវះកាត់យក ថ្លើម បេះដូងចៅយាយផ្ញើមកឱ្យយាយអាំងបរិភោគដោយប្រាប់យាយថា:"*ចៅយាយរែកសាច់មកតាមក្រោយ វាផ្ញើថ្លើម និងបេះដូងជ្រូកព្រៃមកឱ្យអាំងបរិភោគមុនចុះ*"។

យាយកំសត់នឹកពិភាល់ក្នុងចិត្តខ្លាំងណាស់ ប៉ុន្តែពុំមានមាត់កអ្វីឡើយ។ ក្រោយពេលអាំងសាច់ឆ្អិនហើយក៏មិនទាន់បរិភោគដែរ គាត់រង់ចាំចៅរហូតដល់យប់អធ្រាត្រ។ ដោយការអត់ងងុយខ្លាំងពេក យាយក៏ប្រឹះប្រាណសម្រាន្តលក់ទៅ។ យប់នោះ ព្រលឹងចៅកំសត់បានមកពន្យល់សប្តិប្រាប់ជីដូនថា : "*យាយៗ សាច់ដែលពួកវា យកមកឱ្យយាយ គឺថ្លើម និងបេះដូងខ្ញុំទេ យាយ! នៅរសៀលថ្ងៃខានស្អែកនេះមេកន្ទ្រាញភូមិនេះ គេចាត់តាំងធ្វើពិធីលៀងអារក្ស ដោយជប់លៀងសាច់ខ្ញុំ និង*

*សាច់ប្រើសមួយចំនួន យ៉ាងសប្បាយ ។ ក្នុងពេលនោះ សូមលោកយាយចាប់ ជាស ដាក់សំបុកមាន់ ហើយសាចទឹកដាក់សំបុកមាន់នោះឱ្យខ្លាំង ។ ពេលរសៀលជ្រេ បន្តិចនឹងកើតព្យុះ រន្ទះបាញ់អាប់អួរ ស្រុតផែនដី កើតវឹកវរ នៅកន្លែងនោះ ។ បើមានកើតហេតុយ៉ាងនេះ សូមលោកយាយពន្លៃងមាន់ ស ឱ្យវាហើរទៅ បើមាន់នោះហើរទៅទីណា កន្លែងណា លោកយាយត្រូវរត់ទៅកន្លែងនោះ នឹងបានផុតពីគ្រោះហើយ ។ ចំណែកឯពួកវា ស្រេចតែទៅតាមដំណើរចុះ ។*

ពេលភ្ញាក់ដឹងខ្លួនឡើង លោកយាយកំសត់នឹកខឹងក្តួលក្តៅក្នុងចិត្ត គិតថាៈ "*ពួកវា មិនសមបើ មកសម្លាប់ចៅអញដែលជាមនុស្សគ្មានទោសកំហុសអ្វីសោះ*" នឹកគិតយូរៗទៅ កំហឹងលាយឡំនឹងការនឹកស្តាយចៅកំព្រា កាន់តែពុះកញ្ជ្រោលឡើងៗ ធ្វើឱ្យលោកយាយអត់ទ្រាំពុំបានក៏ដើរទៅជីករន្ធជាស បានជាសមួយយកមកចងដាក់សំបុកមាន់ ហើយសាចទឹកដាក់យ៉ាងខ្លាំង ដោយឧបកិច្ចឱ្យមានភ្លៀងផ្គរជោរជន់នៅពេលដែលពួកវាសប្បាយហ៊ោកញ្ជ្រៀវក្នុងពេលលៀងអារក្សនិងជប់លៀង ។

## ៣. អព្ភូតហេតុក្រោយពេលចាប់ជាសដាក់សំបុកមាន់

រយៈពេលប្រមាណមួយម៉ោងកន្លះ ក្រោយពេលដែលលោកយាយចាប់ជាសដាក់សំបុកមាន់មក អព្ភូតហេតុ ដ៏ចំឡែកមួយបានកើតឡើងភ្លាម គឺនៅពេលនោះមានរន្ទះបាញ់ប្រាវៗ មេឃមីរស្រទំ ខ្យល់ព្យុះបង្កហេតុឡើងភ្លាម ។ ជាមួយគ្នានោះភ្លៀងក៏បង្អុរធ្លាក់ចុះមកខ្វោកៗទឹកពុះពីក្រោមដីខ្វោលៗឡើង ធរណីលាន់រញ្ជួយបាក់ស្រុតស្រ៊ុបៗ ។ ហ្វូងមនុស្សទាំងអស់ដែលកំពុងតែហ៊ោកញ្ជ្រៀវក្នុងការលៀងអារក្សក៏ភ័យស្លន់ស្លោរត់ប្រសេចប្រសាច រកទីជ្រកកោនគ្រប់ៗគ្នា ប៉ុន្តែពុំមានជនណាម្នាក់

អាចរត់រួចពីគ្រោះមហន្តរាយដ៏ចម្លែកនោះឡើយ ។ ផ្ទះជនជាតិទាំងនោះ រិលត្រឡប់គល់សសរផ្ងារឡើងលើទាំងអស់ ។

នៅក្នុងពិធីលៀងអារក្សពេលនោះ មានកំលោះជើងឆើតម្នាក់ សៀតកាំបិតស្នៀតនៅចង្កេះ ជិះសេះទៅចូលរួមក្នុងពិធីនោះដែរ ក្នុងគោលបំណងចាប់យកនារីក្រមុំម្នាក់ដែលខ្លួនលួចស្រឡាញ់យូរហើយ ។ នៅពេលមានអព្ភូតហេតុនេះកើតឡើង នាយកំលោះ ក៏ចាប់នារីនោះដាក់លើខ្នងសេះបំផាយចេញយ៉ាងប្រញាប់ឆ្ពោះទៅទិសខាងត្បូង។ ព្រះធរណី ក៏បានបាក់ស្រុតដេញតាមជើងសេះបុរសនោះប្រកិតៗដែរ ។ ដោយអស់សង្ឃឹមក្នុងការគេចផុតពីគ្រោះមហន្តរាយ ក្នុងទីចម្ងាយប្រមាណជាងមួយគីឡូម៉ែត្រ បុរសនោះក៏ហូតកាំបិតស្នៀត ចាក់ទំលាក់នារីនោះ ពីលើខ្នងសេះនៅទីនោះ ព្រមជាមួយគ្នាព្រះធរណី ក៏បាក់ស្រុតស្រូបយករូបមាណព និងសេះបាត់ទៅ ។ នៅត្រង់កន្លែងនោះគេសន្មតឈ្មោះថា "*បឹងស្នៀត*" រហូតមកដល់សព្វថ្ងៃ[២] ។

កាលពីឆ្នាំ ១៩៦៤-១៩៦៥ បឹងនេះសម្បូរទៅដោយដើមរុន ដើមក្បៀរ បង្គៅ ផ្លែស្លេកស្ពះដុះពទ្ធ័ជុំវិញមាត់បឹង។ បច្ចុប្បន្ន ប្រជាជនរស់នៅទីនោះកាប់ឆ្ការធ្វើស្រែចំការ ស្រឡះ បាត់បង់ទម្រង់ដើមអស់រលីងទៅហើយ នៅសល់តែតួបឹងធំ និងបឹងស្នៀតប៉ុណ្ណោះ។ ឯសសរ នៅសល់មួយដើមបញ្ឈរគល់ឡើងលើស្ថិតនៅត្រង់ពាក់កណ្តាលបឹងធំ ចុងទ្រេតទៅទិសល្វិសាន។

អាស្រ័យដោយមានហេតុភេទយ៉ាងនេះហើយ ទើបអ្នកស្រុកគេសន្មតនាមបឹងនោះថា "បឹងសសរដោត"។ តែដោយបឹងនោះស្ថិតនៅលើដីកោះ គេក៏ហៅថា "បឹងកោះសសរដោត"។ រយៈពេលយូរក្រោយៗមកការហៅ បឹងកោះសសរដោត

២-ខ្លះថាបឹងស្នៀត មូលហេតុមកពីនារីនោះជ្រុះស្នៀតសក់ នៅពេលនោះ

នេះក៏ក្លាយទៅជា "បឹងកោះត្នោត" ។ តួបឹងធំ មានផ្ទៃជិតមួយហិកតាដែរ រីឯបឹងស្មៀតវិញ មានទំហំតូចតែវែង ។

## ៤_ ឥទ្ធិពលបឹងនេះ

កាលពីហុកសិបឆ្នាំមុន បឹងនេះមានក្រពើតូចធំជាច្រើនរស់នៅ ។ ក្រពើទាំងនោះ ពុំមានប៉ះពាល់អ្វីដល់ជីវិតអ្នកស្រុកដែលទៅរកត្រីសាច់នៅទីបឹងនោះឡើយ ។ កាលណាគេចង់ឃើញក្រពើទាំងនោះ គេអុជធូបបន់ស្រន់ថា "*លោកតាអើយ! ខ្ញុំសុំមើលយានជំនិះលោកតាបន្តិច*" ។ នៅពេលភ្លើងធូបឆេះបានពាក់កណ្ដាល ឬមួយក៏អស់មួយភ្លើងធូប ស្រាប់តែឮសូរសន្ធឹក ដូចយន្តហោះងឹលឡើងលើអាកាស ។ មួយសន្ទុះក្រោយមក ក្រពើតូចធំបានផុសឡើងតម្រៀបក្បាលគ្នាឱ្យមើលកន្លះម៉ោងហើយ ក៏មុជទៅក្នុងទឹកវិញអស់ ។

នៅទីផ្ទៃបឹងនោះ ជារៀងរាល់ថ្ងៃសីល គេតែងតែឮសម្លេងភ្លេង ពិណពាទ្យប្រគុំយ៉ាងរងំ គួរឱ្យចង់ស្ដាប់ក្រៃលែង ។

អ្នកទៅរកត្រីនៅទីនោះត្រូវកាន់ត្រណមយ៉ាងតឹងរឹងបំផុត:

*ទីមួយ:* ត្រូវកាន់ពាក្យសច្ចៈទៀងត្រង់បំផុត បើសុំសត្វអ្វីហើយមិនអាចលោភចង់បានសត្វដទៃផ្សេងទៀតឡើយ ។ បើប្រព្រឹត្តខុសពាក្យសច្ចៈ នឹងត្រូវក្រពើដេញត្របាក់ សត្វពស់ដេញខាំ ចឹក ឬត្រូវសត្វឈ្លើង សត្វទាកខាំទាមស្អេកស្កះ មិនអាចចេញទៅរកអ្វីបានឡើយ ។

*ទីពីរ:* ត្រូវស្ងាត់ស្ងៀមកុំមាត់កអ្វី ។ បើអ្នកណាភ្លាត់មាត់ក ដោយ ហួចច្រៀង សើច ឬហៅ អ្នកនោះឯងត្រូវចុកពោះ រាគមូល មួយរំពេច...។ល ។

បើត្រូវការបេះផ្លែភ្សៀវដែលផ្លែស្អេកស្កុះនៅជុំវិញមាត់បឹងនោះ ត្រូវតែមកុំមាត់កអ្វីឡើយ ។ ប្រសិនបើភ្លាត់មាត់ថា "ជូរ" ផ្លែភ្សៀវទាំងអស់ នៅដើមណាមួយក៏ជូរដែរ ។ បើភ្លាត់មាត់ថា "ផ្អែមណាស់" នោះផ្លែឈើទាំងអស់បែរទៅជាមានរសជាតិចត់វិញ ។ ដូចនេះអ្នកទៅបេះ ទោះប៉ះជូរក្តី ផ្អែមក្តី ត្រូវបេះយកទាំងអស់ ហើយបេះប៉ុណ្ណាដែលខ្លួនអាចរែកពុនមកផ្ទះបាន កុំមានចិត្តលោភលន់ឱ្យសោះ ។

បើមានអារម្មណ៍លោភលន់ អ្នកនោះឯងប្រាកដជាវង្វេង រកផ្លូវមកផ្ទះពុំឃើញឡើយ ។ បច្ចុប្បន្ននេះ នៅលើផ្ទៃបឹងមាន បឿនដុះពេញ ។ បងប្អូនអាចដើរលើបឿនពីមាត់បឹងម្ខាង ទៅមាត់បឹងម្ខាងទៀតបាន ។ អ្នកដើរឆ្លងកាត់ ទោះបីផុងជើងបន្តិចបន្តួច ក៏កុំមាត់កអ្វី កាលណាមាត់ក ឬស្រែកដោយឃើញអ្វីមួយ អ្នកនោះត្រូវផុងស្រុត ពាក់កណ្តាលខ្លួនទៅក្នុងបឹងភ្លាម ។

*បើដឹងខ្លួនថាជាមនុស្សប្រាកដហើយ*
*គប្បីតែប្រព្រឹត្តកាន់តាមធម៌របស់មនុស្ស ។*

ព្រះពោធិវង្ស **ហួត តាត**

# ពិធីហៅព្រលឹងស្រូវ

ដោយ : **ជាវ ហ៊ិន**

ពិធីនេះគេតែងនិយមធ្វើបីដង គឺនៅពេលច្រូតយកង៉ៃម្តង (ថ្ងៃ) ពេលដឹកកណ្តាប់ដាក់លានម្តង និងពេលដឹកស្រូវដាក់ជង្រុកម្តងទៀត។

ពិធីនេះមិនត្រូវបានអនុវត្តគ្រប់តែកសិករទេ គឺអាចធ្វើបានចំពោះកសិករណាដែលមានចំណេះដឹងខាងផ្នែកនេះ ហើយគេម្នាក់ៗខំលាក់ទុកមិនបញ្ចេញ ផ្សព្វផ្សាយបន្តទៀតឡើយ។ គេលាក់ពិធីនេះទុកជាអាជីវកម្មអាថិកំបាំងរបស់គេ ដើម្បីលាភសក្ការៈបំពេញអាត្មា និងគ្រួសារ។

## ១-ពេលច្រូតយកថ្ងៃ

ពេលស្រូវទុំល្មមច្រូតកាត់ហើយ គេក៏ធ្វើពិធីហៅព្រលឹងស្រូវដើម្បីយកថ្ងៃសម្រាប់កូនចៅច្រូតកាត់ ឬចុះដៃថ្ងៃក្រោយ។

នៅក្នុងសម័យមុន បុព្វបុរសយើងមានគំនិតយល់ដឹងថាៈ ក្នុងមួយសប្តាហ៍មានថ្ងៃមិនល្អខ្លះ ក្នុង១ខែក៏មានថ្ងៃមិនល្អ៣ថ្ងៃដែរ គឺលោកបានដាក់កំហុសទៅលើថ្ងៃ ២កើត ១២កើត និងថ្ងៃ៧រោច ជាថ្ងៃខ្មោចស៊ី ឬជាថ្ងៃអាក្រក់ផ្តល់ទុក្ខទោសរកស៊ីមិនបាន។ ថ្ងៃល្អក្នុងមួយសប្តាហ៍តាមពាក្យស្លោក " ថ្ងៃសុក្រយកស្រូវដាក់ដី ថ្ងៃព្រហស្បត្តិ៍សំដីយកស្រូវឡើងផ្ទះ " ។

ក្នុងការច្រូតកាត់លោកឱ្យតម្លៃទៅលើថ្ងៃព្រហស្បត្តិ៍ ដែលមានពាក្យស្លោកថែងថា "ថ្ងៃសុក្រច្រូតល្អណាស់ដឹកស្រូវលានឡើងផ្ទះយកថ្ងៃព្រហស្បត្តិ៍ល្អប្រសើរ"

អាស្រយ័ហេតុនេះទើបលោកជ្រើសរើសថ្ងៃព្រហស្បតិ៍ធ្វើការច្រូតកាត់។

បានថ្ងៃល្អហើយ លោករៀបចំពិធីសែនព្រេនឱ្យពរជ័យស្រូវក្រោមពាក្យស្លោកថា " *ច្រូតមួយមុខបានស្រូវមួយជារ ច្រូតមួយងាបានស្រូវមួយជង្រុក* " ។ បន្ទាប់មកលោកសូត្រប្រកាសយ៉ាងនេះ " *អស់លោកចាស់ទុំក្រមុំមេម៉ាយស្តាប់ខ្ញុំនិយាយឱ្យពរសែនស្រូវឆ្នាំនេះឆ្នាំកុរភ្លៀងអុរជោគជាំ ដើមឆ្នាំផ្គរលាន់ពួគៀងគោក្របី រណ្តាប់ខ្សែវល្លិនង្គ័លរនាស់ភ្ជួររាស់ដកស្ទូង ល្បីពួនាងលាស់ ល្បីពួនាងលូន លូនហើយធំដើមផើមហើយរបុស[1] នាងដាក់តួរចុះរបុសហាលផ្កា នាងល្អសោតណាស់ ល្អដូចគុម្ពអំពៅខ្មៅ នាងបែកគុម្ពចេញទៅប៉ុន១កញ្ជើបាយ អញ្ជើញនាងទើបដំណើបខ្សាយ អញ្ជើញនាងកាយប្រពាយឆ្លង អញ្ជើញនាងកងលំអងធ្ងន់ អញ្ជើញនាងគង់ ទុកយ៉ាងងើយ អញ្ជើញនាងពីព្រះភូមិតូចហើយ មកពីកំពែងចក្រវាលសំដីនាងជាទព័សណ្តាប់នាងជាជារ នាងច្រូតមួយងាបានជារ៥រទេះ នាងអស់ទាំងនោះភ្ជួររាស់សាបស្ទូងអញ្ជើញនាងអើយមកពីសេកកំផ្លៅ លលកកំផ្ទួចពីចាបទុច១ប្រវឹកមាន់ទា បាយជាប្រថមនំជាប្រធាន សំពត់សជាពិតាន ចានជាតម្កល់រោងត្រសាលភ្ញៀវពន្លឺ* " ។

សូត្រចប់ហើយឱ្យអ្នកមេផ្ទះចុះច្រូតយកណ្តៀវព្យួរទុកលើស្លាក ។

## ២_ពេលដឹកកណ្តាប់ដាក់លាន

នៅពេលជញ្ជូនស្រូវដាក់លានក៏គេធ្វើពិធីនេះដែរ ហើយយកស្រូវកណ្តាប់ចំនួន ៣កណ្តាប់ដាក់ចំកណ្តាលលាន ទើបឱ្យកូនចៅជញ្ជូនដាក់តាមក្រោយ ។ នៅពេលដឹកស្រូវឡើងផ្ទះ លោកធ្វើពីធីម្តងទៀត តែធំ១ជាពិធីមុន១ទាំងអស់ដោយមានពាក្យថា " *សែនលាន* " មួយមាត់ចូលផង ។

---

១-របុស ជាភាសារបស់ជនជាតិគួយ មានន័យថា បែកល្អ

## ៣-ពេលដឹកស្រូវដាក់ច្រូតយកថ្ងៃ

នៅពេលស្រូវចូលជង្រុកហើយ មិនយកចេញផ្តេសផ្តាសទេ បើសិនជាត្រូវការកើបស្រូវចេញត្រូវយកថ្ងៃ១កើត ខែណាដែលពេញ ដូចជាខែផល្គុនជាដើម។ ឯការកើបស្រូវចេញ ទៀតសោត ត្រូវយកស្នូកអណ្តើកសោម ដែលរាប់ក្រឡានៅលើខ្នង ចំ សំឡាកថា "*ផ្លែត*" គេក៏អាចយកស្នូកអណ្តើកសង្កល់ បានខ្លះៗដែរ។

ពត៌មាននេះលោកតា *ស កែវ* បានផ្តល់ឱ្យខ្ញុំចងក្រងជាឯកសារមានការខុសគ្នាពីខាងសាគ្រាមស្ទោង កាលដែលខ្ញុំនៅទីនោះ។

លោកយាយ *អ៊ិត ឡាញ់* នៅភូមិសាគ្រាមខាងជើង ឃុំសាគ្រាម (កាលណោះនៅក្នុងស្រុករវៀង ឥឡូវនៅក្នុងស្រុកស្ទោងខេត្តកំពង់ធំ) មានប្រសាសន៍ថា: ក្រោយច្រូតកាត់ហើយ តារបស់គាត់(ប្តីលោកយាយឡាញ់) នៅរាល់ពេលយប់ស្ងាត់ គាត់តែងតែដើរពីស្រែរបស់គាត់ទៅស្រែជិតខាងដែលគេច្រូតហើយ ដោយមានកាន់រំពាត់ផ្តៅ១ នៅដៃដើរពទ្ធ័ស្រែដែលគេច្រូតកាត់ហើយនោះ ដោយមាត់សូត្ររអ៊ូៗ រំពាត់វាយវាត់ចូលជានិច្ច មកដល់លានវិញគាត់ដើរក្រឡឹងមួយជុំ ទើបឡើងខ្ទមសម្រាក។ គាត់អនុវត្តន៍យ៉ាងនេះរហូតគេដឹកស្រូវឡើងផ្ទះអស់ គាត់នៅតែក្នុងស្រែនៅឡើយ។ ឯស្រូវរបស់គាត់ចាក់ជាធារតូចធំតាមពូជ យកចំបើងមួយចិបតូច កាត់ប្រវែងមួយចំអាមដោយពីលើជុំវិញជើងធារ យកផេះចំបើងរោយជុំវិញ។ ប្រមាណកន្លះខែក្រោយមកទើបគាត់ដឹកស្រូវទៅផ្ទះ។

គេតែងនិយាយថា លោកតានេះចេះហៅព្រលឹងស្រូវពីស្រែគេឯងរត់មកលានគាត់។ ស្រូវរបស់គាត់បើតាមពិនិត្យ មានធារមិនច្រើនទេ តែម៉េចក៏មានស្រូវដឹករាប់រទេះ (ស្មានថាបានតែ១០រទេះ ប្រែជាបាន១២-១៣ រទេះ)។

# អំពីបាលីស្នេហ៍[១]

ដោយ : មៀច ប៉ុណ្ណ

តាមការសង្កេត បុព្វបុរសខ្មែរយើងប្រើបាលីស្នេហ៍នេះក្នុងគោលបំណងផ្សេងៗពីគ្នា ។ ដូច្នេះហើយបានជាយើងកត់សម្គាល់ឃើញថា នៅក្នុងក្បួនខ្មែរបុរាណមានស្នេហ៍បីប្រភេទ ដែលយកមកប្រើក្នុងទិសដៅបីយ៉ាងដែរ :

## ១_ ស្នេហ៍មុខ :

មុននឹងចូលទៅកាន់កន្លែងធ្វើការរបស់មន្ត្រីធំណាមួយ ឬក៏ទៅកាន់លំនៅឋានរបស់វរជន ដោយមានបំណងសុំពឹងពាក់ ឬសុំក្តីអនុគ្រោះបែបណាមួយនោះ បុព្វបុរសយើងតែងតែប្រើមន្តអាគមសែកសូត្របាលីស្នេហ៍មុខ ផ្លុំទៅលើក្រមួនមាត់ដែលដាក់ក្នុងជន្លាប់ រួចយកមកលាបសក់ ចញ្ចើម ថ្ងាស ។ ព្រមជាមួយនេះដែរ ដូនតាយើង លោករៀបឬកពា សុភាពរាបសា ឱនលំទោនទាំងកាយទាំងវាចាសម្តែងនូវការគោរពប្រណិប័តន៍ ចំពោះវរជនដែលជាមេបា ចៅហ្វាយនាយ ។ ខាងក្រោមនេះ គឺបាលីស្នេហ៍មុខរបស់លោកគ្រូ **សុខ សែម** ដែលមានការខុសប្លែកខ្លះៗអំពីបាលីស្នេហ៍មុខរបស់លោកគ្រូ កិម ផង់ ។ ដូនកាលលោកប្រើបាលីស្នេហ៍មុខនេះដើម្បីកម្រើកទឹកចិត្តឱ្យក្លាហាន មិនឱ្យចាញ់ប្រាបគេ ឱ្យមានសិរីសួស្តី និងមានអំណោយទាន មានតេអាណិត និងឱ្យមានតេជះក្នុងការចូលទៅកាន់ជំនុំចំណោម

---

១- ក្រុមស្រាវជ្រាវយើងខ្ញុំបានជួបសម្ភាសន៍ជាមួយលោកតា សុខ-សែម នៅភូមិខ្វាវអាយុ ៧២ ឆ្នាំ អំពីបាលីស្នេហ៍ ដែលខ្មែរបុរាណធ្លាប់បានប្រើសម្រាប់ទាក់ទាញចិត្តនារីក្រមុំឱ្យស្រឡាញ់ខ្លួន

ប្រជុំមនុស្សធំតូច ។ ត្រូវសែកបាលីនេះ និងក្រមួនមាត់ ឬប្រេងដូងអប់ លម្អងផ្កាក្រអូប : " ឱមសេពមហាសេព ទើបគ្រូប្រើអញសែកប្រេងក្រមួន លាយលាបធ្វើខ្លួនអញអើយ ល្អបីដូចមាស ថ្ពាសអញអើយ ល្អបីដូចប្រាក់ ព្រះភក្រ្តអញអើយ ល្អបីដូចខែពេញបូណ៌ សម្បុរអញអើយល្អបីដូចឃ្មុំពេញឆោម ម្រោមពេញទឹក បងប្អូនទឹករលឹកមកគ្រប់ៗគ្នា ។

**✱បាលីស្នេហ៍មុខទី ២ ហៅថា បាលីស្នេហ៍សារិកា**

"ឱមសារិកាអញអើយ អញទៅត្រង់ណាមិនដែលទំនេរ ពាក្យអញសសិតមាត់អញស្រដី លួងលោមប្រុសស្រី ឱ្យចូលចិត្តនឹងអញ " ។

**✱បាលីស្នេហ៍មុខទី ៣ ហៅថា បាលីស្នេហ៍ក្រពុំរីករាយ :**

"ឱមរីក ឱមរាយ រីកដូចព្រះពាយ រាយដូចព្រះអាទិត្យ"

បាលីស្នេហ៍ទាំងប៉ុន្មានមេនេះ ត្រូវសូត្រសេព ៣ ចប់ ឬ ៧ ចប់ ។

**២- បាលីស្នេហ៍ដាក់ខ្មោច :**

នៅឯកសារមុន ខ្ញុំបានជម្រាបអំពីបាលីដាក់ខ្មោចឱ្យទន់ចិត្ត អាណិតដល់គ្រូ ព្រមទាំងបើកដៃឱ្យគ្រូហ្មព្យាបាលសិស្សគណរបស់ខ្លួន ដោយមិនជំទាស់រករឿងរកហេតុអ្វីឡើយ ។ តាមធម្មតាគេតែងតែប្រើបាលីស្នេហ៍មុខ ឬបាលីស្នេហ៍ដាក់មនុស្ស សម្រាប់ដាក់បន្ទន់ចិត្តខ្មោចជួរជំបូរព្រាយព្រ័ក្សល្បាក់សាផងដែរ ។

**៣- បាលីស្នេហ៍ដាក់មនុស្ស ស្រី-ប្រុសឱ្យស្រឡាញ់**

ខាងក្រោមនេះ ជាបាលីស្នេហ៍របស់លោកតា សុខ សែម មានឈ្មោះថា **"ស្នេហ៍រំជួលចិត្ត "** ។

"ទើបអញ្ជើញស្រីស្រើបរំជួលចិត្ត បើនាងអាណិតថយចេញឱ្យឆាប់ បេះ

ផ្កាស្រឡិត បេះផ្កាមោងគ្រេង បេះមកលួងលេងដោយចិត្តចំណង់ ។ ស្រណោះផ្គរលាន់ ឮដើមឆ្នាំ ស្រីខ្មៅទាំងប្រាំ នាំនាងចេញលេង ផ្គរលាន់គគ្រឹក ឆ្លើយឡើងគគ្រេង នាំនាងចេញលេង ដោយពាក្យអញហៅ ។ អញហៅនឹងប្រេង អញហៅនឹងក្រមួន ឱ្យនាងដឹងខ្លួន នាងនៅក្នុងអង្គ ។ សអើយ ស្រីស ថ្ងៃល្ងាចឮផ្គរ សដេកមិនលក់ ដៃឆ្វេងពរកូន ដៃស្តាំជ្រងសក់ សដេកមិនលក់ សមនាងរលឹកមកបងឬទេ ។ បើនាងរលឹកប្អូននាងកុំនៅ គន់ទៅទឹកស្រះហូរមកថ្លាឈ្វេង ឱ្យនាងងូតលេងជាមួយនឹងបង។

**✱បាលីស្នេហ៍ឈ្មោះហៅថា "ស្នេហ៍ស្រីពៅ"**

"ប្អូនស្រីពន្លក អញហៅនាងមក អញប្រើនាងទៅ អញប្រើនឹងប្រេង អញប្រើនឹងម្សៅ អញប្រើនាងទៅ ឱ្យជួយអញផង ។ ឧម អន្តិ១ ឧមអន្តែ១មន្តផ្កាចំប៉ាដាក់ស្នេហ៍ស្រី មន្តផ្កាចំប៉ីដាក់ស្នេហ៍ព្រាយ ដាក់ទាំងស្នេហ៍អាប ដាក់ទាំងស្នេហ៍ធ្មប់ ទាំងខ្មោចទាំងគ្រប់ ឱ្យចូលចិត្តផងអញ ។ អញមន្តប្រេងម្សៅលាយលាប ប្អូនពៅចំណាំរក្សា ទាំងព្រាយចំណាំ ចូលចាំស្នេហា ចូលជិតស្និទ្ធស្នាល ស្នេហ៍នឹងពៅអញ ។ ស្រណោះស្នេហ៍មិត្ត ស្នេហាប្អូនតន់ ស្រណោះស្នេហ៍មន្ត ដាក់ប្អូនសង្សារ ឧមៈសិទ្ធិផុតឆាប់ប្រញាប់ណាគ្រូអើយ ។

**✱ ទិភាគ** :តាមការសង្កេតយើងកត់សម្គាល់ឃើញថា :

ក/ បាលីស្នេហ៍ ច្រើនលើកឡើងជាពាក្យកាព្យ បទពាក្យប្ញូន ឬកាកគតិ ហើយយ៉ាងហោចណាស់ ក៏លើកជាកម្រងកែវដែរ ។ គេកម្រឃើញបាលីស្នេហ៍ ចងជាពាក្យរាយណាស់ ។

ខ/ បាលីស្នេហ៍ច្រើនលើកកម្ពស់អត្តភាពខ្លួនឱ្យអស្ចារ្យ ឱ្យឧដុង្គ ឧត្តម ដោយអែបទៅនឹងឥទ្ធិពលរបស់គ្រូ (ទើបគ្រូបើអញ..........)ទំនងជាកម្រើកលើកឥទ្ធិពលទឹកចិត្តឱ្យខ្លួនរឹងប៉ឹងក្លាហាន ឱ្យជឿជាក់លើខ្លួន ។

គ/ ច្រើនរំលឹកអំពីសម្រស់ធម្មជាតិ ដែលញ៉ាំងចិត្តឱ្យស្រណោះ ឱ្យព្រឺព្រួច ស្រើបស្រាល ឱ្យស្រងេះស្រងោច ។ គឺជាកាព្យនិពន្ធ (Poésie) បែបអណ្តែតអណ្តូង លន្លង់លន្លោច ( ស្រណោះសូរផ្គរលាន់ ឮដើមឆ្នាំ ........ស្រណោះផ្កាចំប៉ីចំប៉ា...... ។

ច្រើនមានអត្ថន័យជាម្ចាស់លើគោលដៅ ( មុខសញ្ញា ) ឱ្យនាងមើលមក អញល្អបីដូចឃ្មុំពេញឆោម ម្រោមពេញទឹក នឹកមកអញ ១ ថ្ងៃ ៧ ដង ...... ។

ទាំងអស់នេះ សុទ្ធតែប្រមូលផ្តុំទៅលើអត្ថន័យចិត្តសាស្ត្រ គួបផ្សំពាក្យពេចន៍នឹងរូបសាស្ត្របញ្ចូលគ្នា ( ពាក្យកំណាព្យ+ លំអធម្មជាតិ +ប្រេងក្រមួនក្រអូប +រូបរាងសម្បៀកបំពាក់សង្ហា + ទឹកចិត្តខ្ពស់ធ្វើម្ចាស់លើគោលដៅ..........) ។

*មនុស្សល្ងង់ តែងយកពេលទៅធ្វើ*
*អំពើអាក្រក់ ឯអ្នកមានប្រាជ្ញា*
*តែងយកពេលទៅធ្វើអំពើល្អ ។*

ព្រះពោធិវង្ស **ហួត តាត**

# អំពីពាង

ដោយ : **ញ៉ាំង មុិនថន**

ពាងជាទ្រព្យសម្បត្តិដ៏មានតម្លៃរបស់ខ្មែរលើគ្រប់ជនជាតិ នៅខេត្តរតនគិរី។ គេនិយមប្រើពាងនេះសម្រាប់តែធ្វើស្រា ហៅថាស្រាពាង ឬស្រាដើម។

ពាងមាន ៦ ប្រភេទ ជាទ្រព្យសម្បត្តិដែលមានអាយុរាប់រយឆ្នាំហើយ និងមានតម្លៃខុសពីគ្នា:

១-ពាងបាឡាំង មួយមានតម្លៃ ជាមាស ចំនួន ២តម្លឹង ៨ជី។

២-ពាងគ្លាង មួយមានតម្លៃ ជាមាស ចំនួន ១តម្លឹង ២ជី។

រីឯពាងត្រវេញ, ពាងវ៉ាញ, ពាងឡមុះ និងពាងច្រង ពាងនីមួយៗមានតម្លៃជាមាសចំនួន៤ជី ប៉ុណ្ណោះ។ ក្រៅពីនេះមានពាងផលិតថ្មីសព្វថ្ងៃពុំសូវមានតម្លៃទេ។



*ភូមិរបស់បងប្អូនជនជាតិព្នង*

# ម្ហូបស៊ិក

ដោយ : **សម សារឿម**

ម្ហូបស៊ិកជាម្ហូបពិសេសជាងគេដែលប្រជាពលរដ្ឋនៅខេត្តស្ទឹងត្រែងនិយមចូលចិត្ត ។ ម្ហូបនេះគេនិយមធ្វើនៅពេលមានបុណ្យទាន ឬជាលក្ខណៈគ្រួសារ ។

## ១_ គ្រឿងផ្សំ

-សាច់ជ្រូកសុទ្ធ គ្រឿងក្នុងជ្រូក និងឈាមជ្រូកស្រស់ ។

-គល់ស្លឹកគ្រៃ ខ្ទឹមស ខ្ទឹមក្រហម ម្ទេស ត្រប់ មើមរំដេង ស្លឹកក្រូចសើច ត្រប់ពត់ញូង ជីរគ្រប់មុខ ក្រូចឆ្មារ ឬក្រូចភ្លា អង្ករលីងឱ្យខ្មៅ កិនឱ្យម៉ត់ ប្រហុក ប៊ីចេង អំបិល ស្ករ និងទឹកត្រី ។

## ២_ របៀបធ្វើ

-ដំបូងគេយកឈាមជ្រូកឆៅដែលកក មកច្របាច់នឹងស្លឹកគ្រៃដើម្បីឱ្យឈាមនោះវារាវឡើងវិញ ហើយត្រងឈាមនោះឱ្យស្អាតទុកដោយឡែក ។

-ម្ទេស ខ្ទឹមស មើមរំដេង គេយកទៅខ្ចប់ស្លឹកចេក កប់ផេះឱ្យឆ្អិន រួចយកមកបុកឱ្យម៉ត់ ។

-ចិញ្ច្រាំសាច់ជ្រូកឱ្យម៉ត់ រួចហើយច្របាច់ក្រូចឆ្មារ ឬក្រូចភ្លា ឱ្យស្រពាប់ ។

-ស្ងោរគ្រឿងក្នុងជ្រូកនោះឱ្យឆ្អិន រួចហាន់ស្តើងៗដូចសាច់ត្រូវញាំដែរ ។

-ឈាមដែលត្រងស្អាតហើយ យកមកចាក់លាយច្របាច់នឹងសាច់ រួច

យកគ្រឿងក្នុងច្របល់លាយចូលជាមួយគ្នា ។

-ស្ងោរទឹកប្រហុកជាមួយនឹងអង្ករលីង ហើយត្រងដាក់ចូលសាច់ដែលបានច្របល់គ្នារួច ហើយដាក់ស្ករ ប៊ីចេង អំបិល ។

-ត្រប់ពត់ញ្ញងពុះជាពីរ រួចលាយច្របល់ចូលគ្នា ហើយដាក់រំដេង ខ្ទឹមស ម្ទេសដែលបុកម៉ត់នោះ ។

-ហាន់ខ្ទឹមបារាំង ឬខ្ទឹមក្រហម ដាក់ចូលរួចកូរឱ្យសព្វ រួចភ្លក់មើលសាប ឬប្រៃទៅតាមចំណង់ចំណូលចិត្ត ។

-មុននឹងយកទៅពិសារគេត្រូវរោយជីរគ្រប់មុខពីលើ ។

-ចំពោះបន្លែផ្ទាប់ជាមួយរួមមានៈ ស្ពៃក្តោប ត្រប់វែង និងសណ្តែកកួរ ។

## ២- ចំណង់ចំណូលចិត្ត

ម្ហូបសុិកនេះគេអាចហូបឆៅក៏បាន ហូបឆ្អិនក៏បាន ប៉ុន្តែបើចង់ហូបឆ្អិន ត្រូវយកទៅចំអិនមួយសន្ទុះទៀត ។

<u>*បញ្ជាក់បន្ថែម*</u>: ម្ហូបសុិកនេះគេធ្វើបានតែជាមួយសាច់ជ្រូកប៉ុណ្ណោះ ។

អត្ថបទរឿង

# ឆ្នាំប្រាសាទបាយ័ន

ដោយ : ខៀវ បញ្ញាវុឌ្ឍ



មនុស្សខ្មែរបានចារឹកលើថ្ម
នូវទ្រង់ទ្រាយរបស់គេ
បញ្ជាក់យ៉ាងច្បាស់
នូវម្ចាស់ទឹកដីដ៏ជាក់លាក់

*រូបថត-មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ(CEDORECK)*

*"**ឆ្នាំប្រាសាទបាយ័ន**" ជាអត្ថបទរឿងល្ខោននិយាយ ដែលបានជាប់រង្វាន់ជ័យលាភី ថ្នាក់លេខ ២ នៃស្នាដៃតែងនិពន្ធសិល្បៈល្ខោន បម្រើការអប់រំ "វប្បធម៌សន្តិភាព" ឆ្នាំ ២០០០។ ពិធីនេះ បានប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា នាខែមេសា ឆ្នាំ២០០០ ក្រោមអធិបតីភាពឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីទីស្តីការគណរដ្ឋមន្ត្រី និងព្រះអង្គម្ចាស់ព្រះរាម **នរោត្តម បុប្ផាទេវី** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។*

## ឆាកទី ១

*( ឮសូរសម្លេងបុរសឆ្មាំប្រាសាទម្នាក់ ឈ្មោះ គង់ នៅក្នុងប្រាសាទ )*

គង់ – ឱ! កម្មអើយកម្ម សែសិបឆ្នាំតាមប្រចាំ អង្កាល់ទៅទើបគេចផុត? មួយជីវិតខ្ញុំនេះ ជួបតែភាពតក់ស្លុត ភ័យរន្ធត់ ខកបំណង ...

*( បុរសនោះចេញតាមទ្វារប្រាសាទ ចូលមកក្នុងឆាក គាត់ស្ពាយថង់មួយ ដែលក្នុងនោះមាន សំបកកំប៉ុង ក្រដាស....)*

– ពីតូចម៉ែឱ្យស៊ីឈ្នួលគេ គេស្តីគេជេរគ្មានមេត្តា លុះធំដឹងក្តីឡើងកាលណា មានចិត្តហានក្លា ស្មគ្រ័ធ្វើសង្គ្រាម ..... ឥឡូវនេះគេឱ្យចាំប្រាសាទ ..... យាមថ្ម ... តើមានប្រយោជន៍អីទៅ ?

*( គាត់ស្ទុះទៅទាត់សំបកដបទឹកសុទ្ធ ដែលគេបានបោះចោលនៅកណ្តាលឆាកមួយជើង)*

– ស៊ីផឹកគ្មានរបៀប ... ( *រួចដើរទៅរើសដាក់ថង់វិញ* ) តើអ្នកពង្រាយមានបានគិតដល់ខ្ញុំដែរឬទេ ? ម៉េចក៏ចាំបាច់មានអ្នកពង្រាយ ? ម៉េចក៏ចាំបាច់មានអ្នកសំអាត ? ... ភ្នែកបើកឱ្យគ្រលួង មើលមិនឃើញធុងសម្រាម...! ( *គាត់ងើបមើលទៅមុខព្រហ្ម* )... តើព្រហ្មមានបានដឹងរឿងហ្នឹងទេ? ... បិទភ្នែករហូតអ៊ីចឹង មើលឃើញដែរអេះ ? បិទឃើញ ឬបើកឃើញ? បើបើកមើលមិនឃើញផង តើបិទភ្នែកបែបនេះមើលឃើញដែរអេះ ?... ( *គាត់ដើរមកអង្គុយលើដុំថ្មមួយដុំក្បែរភ្នក់ភ្លើង* )

– តើជាតិមុនខ្ញុំបានសាងអ្វីខ្លះ ?

*(ឮសូរសម្លេងបុរសម្នាក់ផ្សេងទៀត ច្រៀងទំនុកបទនគររាជ (បាសាក់) ដើរចូលមក ។ គាត់ជាឆ្មាំប្រាសាទដូចបុរសឈ្មោះគង់ដែរ នៅដៃមានកាន់ដបទឹកសុទ្ធ ដែលក្នុងនោះមាន ស្រា ស ជិតកន្លះដប)*

វ៉ា - ឱខ្លួនខ្ញុំអើយ កើតមកមិនល្អ គេឱ្យយាមថ្ម ប្រាសាទបាយ័ន ...

គង់ - (*ស្រែកសួរ*) នែ! ក្រែង អ្ហែងយាម ជ្រុងខាងត្បូង អ្ហេះ ?

វ៉ា - ចុះ អាហ្អឹង ជ្រុងខាងណា ?

គង់ - ខាងកើត

វ៉ា - អូ លោកអើយ ចេះវង្វេងទៅកើត វ៉ី ... (*វអ៊ូមើលទៅព្រហ្ម*) ......... អញចំណាំ! ... ចំណាំមុខ ... រួចបើងាកទៅខាងណា ក៏ឃើញមុខដូចៗតែគ្នា អញ្ចឹង តើខាងណាលិច ខាងណាកើត ? (*គាត់បែរទៅរកទ្វារប្រាសាទរួចស្រែកសួរ*) ។

-នែ ! អា គង់ អញវង្វេងហើយ ... ឥឡូវ អញបែរមុខទៅរកប្រាសាទ តើអញត្រូវដើរ ទៅខាងស្តាំ ឬខាងឆ្វេង ... ?

គង់ - ខាងឆ្វេង

វ៉ា - ឆ្វេង អ្ហេះ ? ដដែល ... (*ដើរចេញទៅ ដោយស្រែកច្រៀងទៀត*)

*-ឱខ្លួនខ្ញុំអើយ កើតមកមិនល្អ*
*គេឱ្យយាមថ្ម ប្រាសាទបាយ័ន ...*

*(សភាពស្ងាត់ជ្រងំ ឮសូរសម្លេងចង្រិតយំ .... ។ គង់ផ្ទឹះភ្លើងភ្ញក់បណ្តើរនិយាយបណ្តើរ ... )*

គង់ - ឱ ! អាវ៉ាអ្ហើយ អាវ៉ា ឯងនៅតែ អាវ៉ាដដែល ........ អាសំឡាញ់ ឯង

និងអញម៉េចចាំបាច់ខុសគ្នា ? យើងធ្លាប់រស់រងទុក្ខវេទនា ....... ហេតុអីក៏វាសនា អភព្វម្លេះ ... ?

- ហ៊ឺ ! ស៊ីមិនគ្រប់ ដេកយប់មិនលក់ ដូចភ្នក់ដែលគ្មាន ឧស ខ្លឹម....... តើឱ្យសង្ឃឹមលើអ្វីទៅ ! ... រស់ដូចជាស្រមោល តែលតោលដូចចក រសាត់អណ្តែតគ្មានទិសដៅ ... ។ *( គាត់អង្គុយដកដង្ហើមធំរួចដកខ្លួយយកមក ផ្លុំ )*

**ចោល** : ឱ ជីវិតខ្ញុំអើយ ! កើតមកហើយ ម្តេចឡើយអភព្វ ម្ល៉េះ ? ........ ឪពុកម្តាយ និងប្អូនត្រូវភ្លើងឆេះ ទ្រូងណែនស្ទើរប្រេះ ម្តេចជួបប្រទះរឿងទុក្ខា ... ពុក ម៉ែ ប្អូនស្រី ស្លាប់យ៉ាងខ្លោចផ្សា ក្នុងខ្ទមជរាសែនវេទនា...។ មកដល់ពេលនេះម្តេចឡើយ គេចមិនផុតភាពភ័យតក់ស្លុត តើតាមលងខ្ញុំ ដល់ណា? ... ខ្ញុំផ្លុំខ្លុយ ផ្ញើសព្វទិសា ទីណាដែលពុកសោយសុខ ។ *( គាត់ឈប់ផ្លុំ យកដៃជូតទឹកភ្នែក )*

**តង់** - តើពេលណាទៅ ទើបខ្ញុំគេចផុតពីសភាពភ័យខ្លាច តក់ស្លុតនេះបាន ? *( គាត់បែរមើលទៅមុខព្រហ្ម)*

... ខ្ញុំ ស្រក់ទឹកភ្នែក ! ... ខ្ញុំឈឺចាប់ ! ...។ ព្រហ្មអ្នកបានស្តាប់ ម្តេចឡើយក៏អ្នកមិនឆ្លើយប្រាប់ .. ម្តេចអ្នកមិនឈឺចាប់ ដូចខ្ញុំផង .? មុខអ្នកម្តេចនៅតែជដែលអីញ្ចឹង ? ...

*(បរិយាកាសស្ងាត់ ។ ឮសូរសម្លេងមនុស្សស្រីយំខ្សឹកខ្សួលឈឺផ្សា ចេញពីប្រាសាទ ... )*

- *(គង់ សួរ)* អ្នកណា ? ... អ្នកណាហ្នឹង ? យប់ថ្មើរនេះមានមនុស្សស្រីឯណា យំ? ... សម្លេងមនុស្ស ឬសម្លេងថ្ម ... ?

*(សម្លេងយំ ហាក់បីដូចជា ស្ងាត់ទៅវិញ គង់មានអារម្មណ៍រន្ធត់ ...)*

មែន ! ត្រង់ ហ្នឹងហើយ *(យកដៃចង្អុល)* គឺត្រង់ហ្នឹងហើយ ... ជាសម្លេងអប្សរាដែលគេដាប់នោះមែនទេ ? ... *(ឃើញរូបអប្សរាស្នូង ១ នៅក្បែរមាត់ទ្វារប្រាសាទ)*

**សម្លេង** - មែនហើយ ! ខ្ញុំជានារសា ... ជាអ្នកនាំសំណូមពរមនុស្សលោក ថ្វាយទេវតា គ្រប់សម័យកាល ។ អ្នកដែលឆ្លាក់ខ្ញុំមក បានប្រគល់តួនាទីនេះឱ្យខ្ញុំច្បាស់លាស់ណាស់ ... ។ ឥឡូវគេដាប់បំផ្លាញ មុខខ្ញុំ អស់ហើយ ... ។

- ខ្ញុំបម្រើមនុស្សជាតិ តទៅទៀត យ៉ាងម៉េចទៅ? តើខាងលើបានដឹងសច្ចភាពរបស់មនុស្សលោកទេ បើមនុស្សលោកជាអ្នកខ្លាចសច្ចៈ បំភ្លៃសច្ចៈ បំពានសច្ចៈ តើអ្នកណា ជាអ្នករកសច្ចៈឱ្យគេ ? ...

- ព្រោះតែមនុស្សភាគច្រើន ជាអ្នកខ្លាចការពិត ទើបគេដាប់មុខ ខ្វេះភ្នែក បំបែកមាត់ពួកខ្ញុំ ... ។

*( គង់ សម្រុតខ្លួនអង្គុយចុះ ... វ៉ា ដើរ ចូលមករកគង់ ។ វ៉ា សួរ )*

**វ៉ា** - អ្អែង ធ្វើស្អីហ្នឹង ?.*( គង់ងើបក្បាលមើលមួយភ្លែតស្រាប់តែភ័យញ័រ)*

**គង់** - ទេ ខ្ញុំមិនបានដាប់រូបអប្សរានោះទេ ... ខ្ញុំមិនមែនជាអ្នកលួចដាប់រូបនោះទេ ( *គាត់ដង្ហក់មួយសន្ទុះ*) មែន ! ខ្ញុំធ្លាប់លួចគាស់ថ្មប្រាសាទមែន ... តែខ្ញុំមិនបានធ្វើដោយចិត្តឯងនោះឡើយ ខ្ញុំធ្វើទាំងបង្ខំចិត្តត្បិតខ្ញុំ ភ័យ

ខ្ញុំខ្លាច ខ្ញុំចង់រស់ ខ្ញុំមិនសប្បាយនឹងធ្វើអញ្ចឹងទេ! កុំដាក់ទោសខ្ញុំអី ១១

**រ៉ា** - នែ ! អាគង់អញណាំ ! អញអារ៉ាណា ! ...

**គង់** - ( *ដឹងខ្លួន* ) អារ៉ា អារ៉ា ឯ្អង មែនអ្អេះ ?

**រ៉ា** - វាយ៉ាងម៉េចឯងហ្នឹង ? ឯ្អងដល់ថ្នាក់ហ្នឹងអ្អេះ ? អាគង់ ឯ្អងអីក៏កំសាកម្ល៉េះ មិនទាន់ដឹងអីផង សារភាពខ្ទេចអស់ហើយ ...

**គង់** - អញឃើញអម្បាញ់មិញដូចជាមិនមែន ឯ្អង ... ឃើញមាឌធំណាស់...

**រ៉ា** - គ្រាន់តែមាឌអញធំ ឯ្អងធ្វើអញ្ចឹង? កុំនិយាយប្រាប់អញថាឃើញនេះ ឃើញនោះ ឮនេះ ឮនោះទៀត។ ពីមុនថាឃើញព្រហ្មញញឹមដាក់ ... បន្ទាប់មកថាឮសម្លេងសូត្រធម៌ ឥឡូវឯ្អងបានឮអីទៀតបានជា និយាយការពិតចេញមកអស់ ? នែ៎ ធ្វើអីធ្វើទៅ កុំឆ្លើយដាក់អញណា ! ...។

**គង់** - អារ៉ា ! អញឮ អប្សរាយំ ... យំចេញពីថ្ម គឺអប្សរាដែលគេដាប់មុខនោះ ហើយ ( *ចង្អុល* )

**រ៉ា** - ( *សើច* ) អប្សរាថ្មហ្នឹងអ្អេះចេះយំ ? .... ឱ! អាគង់ អ្ហើយ អាគង់ ! ម៉េចបានជាភាសីឯ្អងឥឡូវនេះដាក់សម្បើមម្ល៉េះ? បន្តិចឃើញនេះ បន្តិចឃើញនោះ មិនចេះចប់សោះ ។

- ឯងចាំទេ កាលយើងទៅគាស់ប្រាសាទនៅ ... ( *គង់ស្ទុះទៅខ្ទប់មាត់រ៉ាជាប់* )

ឥង់ - ឈប់និយាយ ! ឈប់និយាយទៅ ! កាលនោះយើងធ្វើទាំងបង្ខំចិត្តទេ មែនទេ ? ... (*គង់ដៀងភ្នែកមើលទៅប្រាសាទ*) អញអង្វរឈប់និយាយរឿងនេះទៅ ... ឯងមើលគេសម្ងឹងពីលើមកណាំក ... ឃើញទេ ភ្នែកច្រើនណាស់ ៗៗ ...

ភាំ -(*បេះដៃចេញ*) អញចង់និយាយថា បើបារមីប្រាសាទពូកែមែន ម៉េចក៏មិនកាច់ អាកេតមេក្លោង ឬក៏ធ្វើឱ្យអញឃើញនេះឃើញនោះដូចឯងផងទៅ ? ស្អែកទៅឱ្យលោកស្រោចទឹកចេញទៅ...(*គាត់លើកដបស្រាផឹក*)

- ល្ងាចមិញអ្នកទេសចរណ៍ គេឱ្យទឹកគ្រូចអញមួយកំប៉ុង (*លូកចេញពីក្នុងហោប៉ៅ*) ណេះ ! ផឹកទៅ ... អញដើរឱ្យស្វាងបន្តិច ... ។

(*ដើរចេញបានបន្តិចគាត់បកក្រោយសម្ងឹងមើលទៅមុខព្រហ្ម*)

- គេថា ញញឹមហ្នឹង ញញឹមសណ្ដោសប្រណីដល់សត្វលោក ... តែខ្ញុំមិនដែលបានទទួលការសណ្ដោសប្រណី សូម្បីតែបន្តិចពីការញញឹមហ្នឹងទេ ... មែនទេ ? ... សូម្បីតែអ្នកនៅក្បែរបំផុតអីចឹងអ្វី ? ... ញញឹមយករួចខ្លួនអត់អើពើនឹងការឈឺចាប់ របស់គេសោះ តើ ករុណា មេត្តា នៅឯណា ? ... ឆ្នាំយាមប្រាសាទ ... បោសសម្រាមជូនខ្ញុំទៅហើយនៅមិនមេត្តាទៀត តើចាំអង្គាល់ទៅ ? នៅពេលណា ? នៅកាលៈទេសៈណា បានមេត្តាធ្លាក់មកដល់ខ្ញុំ ? ...ណ្ហើយ ខ្ជិលគិតតវ៉ាបណ្ដោយតាមវាសនាតទៅទៀតទៅ ... (*ស្រែកច្រៀង*)

ឱខ្លួនអញអើយ កើតមកមិនល្អ

គេឱ្យយាមថ្ម ប្រាសាទបាយ័ន ...

*( សម្លេងរបស់វ៉ារសាត់បន្តិចម្តងៗ សភាពស្ងប់ស្ងាត់កើតមានឡើងវិញម្តងទៀត គង់ ហួតធូបបីសរសៃមកអុជ )*

**គង់** - សូមបារមីប្រាសាទ ... អស់លោកអ្នកដែលជាអ្នកថែរក្សានៅទីនេះ សូមកុំប្រកែប្រកាន់អី ខ្ញុំសូមខមាទោសជំនួសមិត្តខ្ញុំដែលនិយាយខុសអម្បាញ់មិញផង ។ *( ងើបមុខមើលទៅព្រហ្ម*

- ខ្ញុំក៏អីចឹងដែរ សូមលើកទោសឱ្យខ្ញុំផង ខ្ញុំអត់ចង់ធ្វើអាក្រក់ទេ អត់ចង់ធ្វើខុសទេ ខ្ញុំធ្វើខុសដោយអចេតនាទេ ព្រមលើកលែងទោសឱ្យខ្ញុំទៅ *( គាត់មើលនាយមើលអាយម្តងទៀត)*

-ខ្ញុំខ្លាចណាស់ ... គេថានៅម្នាក់ឯងឱ្យប្រយត្ន័អារម្មណ៍ ខ្ញុំគ្មានអ្វីជាទីពឹងទេ ខ្ញុំរស់នៅក្នុងភាពភ័យខ្លាច តក់ស្លុត ញាប់ញ័រជារៀងរហូត ។

*( ពេលនោះ គាត់ស្រមៃឃើញរូបតាបសប្រាកដខ្លួនចេញមកនៅចំពោះមុខគាត់ រួចនិយាយមកកាន់គាត់)*

**តាបស** - ម្នាលឆ្នាំដីកំសត់ ឯងមិនឯកោទេ តានៅក្បែរឯងហើយ ...។ ធ្វើចិត្តឱ្យនឹងនរឡើង ! ... ។ ឯងនឹងរស់នៅក្នុងភាពជ្រួលច្របល់បែបនេះជារៀងរហូត ល្គិកណាឯងមិនបានដឹងច្បាស់ថាខ្លួនឯងកំពុងស្ថិតនៅកន្លែងណានោះ ...

**គង់** - ខ្ញុំដឹងច្បាស់ណាស់ថា .... ថាខ្ញុំ ជាឆ្មាំសែនក្រ ជាឆ្មាំដែលគេប្រើឱ្យមកយាមប្រាសាទថ្មដ៏ចំណាស់នេះ ... ខ្ញុំកំពុងស្ថិតនៅក្នុងប្រាសាទ មិនមែននៅក្នុងទីក្រុង ក្នុងវីឡា សប្បាយហ៊ឺហាចាយប្រាក់ដុល្លារដូចគេនោះទេ ...

**តាបស** - ឱ ម្នាលឆ្មាំដ៏កំសត់អើយ ! ឯងជាមនុស្សគ្មានកម្លាំងនៅក្នុងខ្លួនបន្តិចសោះ ... ត្រកូលឯងខ្ពង់ខ្ពស់ ឯងមានត្រកូលជាអ្នកខ្លាំង មានបញ្ញាបាធីប្រកបទៅដោយ សីល ... ម្ដេច ក៏ ខ្លួនឯងក្លាយទៅជាមនុស្សល្ងង់ខ្លៅ គួរឱ្យអាណិតបែបនេះទៅវិញ ? ...

- មានប្រភពអាថ៌កំបាំងមួយ ដែលគេមើលឯងឃើញ ឯងមើលគេមិនឃើញទេ តែគេទាំងអស់គ្នាគេនៅជុំវិញឯង ... ឯងធ្វើអ្វីក៏គេមើលឃើញដែរ ... គេនឹងបង្ហាញខ្លួននៅពេលឯងដឹងខ្លួនច្បាស់ ... ( *រូបតាបសរលត់បាត់ ... គង់ ស្រឡាំងកាំង ...សម្លេងភ្លេងពិណពាទ្យប្រគុំរណ្ដំក្នុងប្រាសាទឮសម្លេងខ្លាំងឡើងៗ ... ស្រមោលអប្សរាចេញពីជញ្ជាំងប្រាសាទ រាំសែនស្ងប់ប្រកបទៅដោយពន្លឺមេត្តាធម៌ ។ គង់លង់អារម្មណ៍នឹងរូបភាពដ៏មហាស្ចារ្យនោះ ... ។ ខណៈពេលដែលកំពុងតែភ្លេចខ្លួន មានមនុស្សមាឌធំពីរនាក់ ប្រដាប់ទៅដោយ ញញួរ ដែកដាប់ និងការ៉ុងចាប់អូសទាញអប្សរា ដាប់បំផ្លាញ... សម្លេងអប្សរាស្រែករកអ្នកជួយ ...* )

**សម្លេង** - ជួយផង ! ជួយផង ! ជួយខ្ញុំផង ! ...

**គង់** - ( *ស្រែកភ្ញាក់សម្លេងរហូតដឹងខ្លួន* ) ... កុំ ! កុំ ! ... អ្នកណា ?

... ! អ្នកណា ហ្នឹង ? កុំ ! កុំ ! ...

- តើនេះជាការស្រមើស្រមៃ ឬក៏ជាការពិត ? ឱ ! អារម្មណ៍អញអើយ ម្ដេចក៏ហោះហើរឥតឈប់ឈរបែបនេះ ... សូមឯងកុំធ្វើបាបអញខ្លាំងពេក ប្រហែលឯងហើយដែលនាំឱ្យអញស្រមើស្រមៃឥតឈប់ឈរ ជូនកាលឈឺចាប់ ជួបទុក្ខកង្វល់គ្រប់បែបយ៉ាង ... ខ្ញុំនឿយហត់ណាស់ ... ឱ ! នាងទេពអប្សរអើយ បើនាងមានវិញ្ញាណមែននោះ ខ្ញុំសូមសន្យាចំពោះមុខនាងថា ខ្ញុំនឹងរកមុខអ្នកដែលបំផ្លាញមុខនាង ហើយខ្ញុំនឹងកាប់ចិញ្ច្រាំមុខវាវិញ ... ។ ទើបតែថ្ងៃនេះទេ ដែលខ្ញុំបានឃើញសម្រស់របស់នាង ទើបតែថ្ងៃនេះទេ ដែលនាងបង្ហាញ ឱ្យខ្ញុំឃើញនូវភាពទន់ភ្លន់ ស្រគត់ស្រគំ មានសណ្ដោស ... ។ សូមនាង អភ័យទោសចំពោះខ្ញុំផង ដែលមានការធ្វេសប្រហែស បណ្ដោយឱ្យគេធ្វើបាបនាង ... មែន ! ខ្ញុំ សន្យាថានឹងសងសឹកជូននាងវិញ ... !

*( ក្នុងរាត្រីកាលដ៏សែនត្រជាក់នោះ គង់ ឮសម្លេងមនុស្សស្រីឆ្លើយតបនឹងគាត់វិញ )*

**សម្លេងស្រី**- ម្នាលឆ្មាំគួរឱ្យអាណិត ! ខ្ញុំសូមអរគុណអ្នកហើយ ដែលបានឱ្យតម្លៃខ្ញុំ ... តែអ្នកត្រូវយល់ថា ឈាមមិនអាចសងដោយឈាមបានទេ សូមអ្នកកុំយកឈាមទៅលាងឈាម ... នោះវានឹងប្រឡាក់ឈាមកាន់តែខ្លាំងឡើង ដែលទីបំផុតវានឹងនាំឱ្យទៅដល់ការបង្ហូរឈាម តទៅទៀតពុំខានឡើយ ។

អ្នកត្រូវយកសេចក្ដីស្រឡាញ់ ដែលអ្នកកំពុងតែមាននេះ ទៅលាងទោសទាំងឡាយនោះទើបប្រសើរជាង .... ។

- ម្នាលឆ្នាំដ៏ប្រពៃ ! អ្នកកំពុងតែបោសសម្អាតថ្ម អ្នកកំពុងតែជ្រកក្រោមម្លប់ដ៏ត្រជាក់របស់ថ្ម ... កាយអ្នកបានត្រជាក់ដោយម្លប់ថ្ម ... គួរតែពិចារណាឱ្យចិត្តបានស្ងប់នៅក្រោមគតិធម៌របស់ថ្មផង នោះអ្នកនឹងបានត្រជាក់ទាំងកាយ ត្រជាក់ទាំងចិត្ត។

- ម្នាលឆ្នាំអើយ ! មុខយើងឆែប កាយយើងបែកបាក់តែចិត្តរបស់យើងមិនបានរងរបួសឡើយ អ្នកមិនអាចសងសឹកជូសយើងបានទេ ... បើអ្នកព្យាយាមយកគំនុំសងគំនុំ នោះអ្នកមិនអាចស្គាល់សេចក្ដីសុខបានឡើយ ។ អ្នកទាំងឡាយណាដែលបានជីកគាស់ដាប់បំផ្លាញស្នាដៃបុព្វបុរសខ្លួន អ្នកទាំងនោះនឹងភ័យព្រួយជានិច្ច ក្ដៅក្រហាយជានិច្ច មិនប្រាកដថាបានសុខដោយអំពើទាំងនោះឡើយ ។ (*សម្លេង ប៊ុពក ល្វើយៗ*)

**ពោល** - ថ្មអើយ អើយថ្ម មានវិញ្ញាណ

ស្ថិតក្នុងឧទ្យាន ទីឋានស្ងាត់

មានអាថិកំបាំងជ្រៅពេកក្ដាត់

ខ្ពស់មិនអាចកាត់ថ្លៃបានឡើយ ។

-ម្នាលឆ្នាំអើយឆ្នាំអ្នកដឹងទេ ?

នេះគឺជាកេរ ផស់[១] អ្នកហើយ

ព្រលឹងដូនតា កៀកបង្កើយ

កូនចៅខ្មែរអើយជួយការពារ ។

... ធ្លាប់តែជាពូជមានពូជ............ផ្តល់ពូជឱ្យគេលួតលាស់

... ឥឡូវនេះភាពឥតគំនិតឥតមារយាទ ធ្វើឱ្យពូជវិនាសអស់ ក្លាយទៅជាជនឥតពូជ ឥតកំណើត កើតចេញពីការលួតលាស់ពីអ្នកដទៃទៅវិញ ។

**សម្លេងស្នូត** ( *ស្រី* - បើអ្នកភ្លេចភ្លាំងភ្លាត់គំនិត

បំផ្លាញការពិតបង់ទ្រព្យា

អ្នកត្រូវបាត់បង់ពង្សកម្ពុជា

ខ្មែរត្រូវការពារកេរដូនតា ។

*( គង់ដើរទៅក្បែរប្រាសាទ គាត់សម្លឹងមើលមុខព្រហ្មដោយយកចិត្តទុកដាក់)*

(នៅមានត)

១- ផស់នៅទីនេះមានន័យថា របស់

# សម្លេងស្គរធំ

(បទពាក្យប្រាំពីរ)

ដោយ : **ហាម ឆាយលី**

១ - ស្គរធំវត្តខ្ញុំសិតរលីង ពណ៌ខ្មៅដូចព្រីងក្បាច់ភ្ញីផ្កា
ពាសព័ន្ធដោយស្បែកមហិសា គំនូររចនារូបហនុមាន ។
២ - ដំណាលរឿងរុងពង្សយសស័ក្តិ រាមទេពផ្ចាញ់យក្សឫទ្ធិថ្កើងថ្កាន
ដំណាលដល់កូនចៅសន្តាន អតីតកាលក្សេមក្សាន្តខ្មែរថ្លៃថ្លា ។
៣ - ស្គរធំវត្តខ្ញុំទូងភ្ជុំបិណ្ឌ ខ្មែរ យួន ចាម ចិន ត្រៀមអាត្មា
រណ្ដាប់ចង្ហាន់នូវព័ស្ដុភារ រៀបចំបូជាតាមព្រេងព្រឹទ្ធ ។
៤ - ដល់បុព្វការីដែលចែកស្ថាន បួងសួងឱ្យបានមកប្រសិទ្ធ
ឱ្យខ្មែរសន្តិភាពសាមគ្គីស្ថិត សម្បូរដូចចិត្តសប្បាយអើយ ។
៥ - ស្គរធំវត្តខ្ញុំទូងសង្ក្រាន្ត ក្មេងចាស់គ្រប់ប្រាណឥតព្រងើយ
យកខ្សាច់ផ្សំពូនចេតិយហើយ ចូឡាមណីបង្ហើយតាំងភ្ញីផ្កា ។
៦ - ប្រជុំព្រះសង្ឃទាំងគ្រហស្ថ សម្ដែងធម៌ក្បោះក្បាយបាលី
ធម៌បង្សុកូលធម៌ស្មូត្រ ជុំវិញចេតិយក្រោមពោធិព្រឹក្ស ។
៧ - យុវជននារីស្រស់ប្រិមប្រិយ សំពត់ហូលថ្មីសមមានឫក្ស
រាំត្រុដិរាំក្ងោកសួរអធឹក ស្រង់ព្រះដោយទឹកអប់សុគន្ធ ។
៨ - ស្គរធំបន្លឺឮពេញទ្វីប ពេលបុណ្យប្រទីបរំឭកគុណ
នៃព្រះគង្គាប្រពៃធ្ងន់ លោកផ្ដល់ជីពជន្មអស់សត្វលោក ។

៩ - ទីពីររំឭកគុណចម្បង ព្រះធរណីផងផ្តល់ឧបភោគ
ផលានុផលច្រើនគរគោក ធំធាត់រយោករយានច្បាស់ ។
១០- ស្គរធំទូងពិសាខបូជា ខេមរៈគ្រប់គ្នាក្រៀមក្រំណាស់
ថ្ងៃដែលព្រះពុទ្ធជាអម្ចាស់ ចាកស្ថានស្រឡះបរិនិព្វាន ។
១១- ព្រះអង្គបានត្រាស់សព្វភ្លឺស្វាង សព្វធម៌មុិនយាំងទុកទូន្មាន
ឱ្យសត្វខំសាងធម៌សីលទាន សន្សំជាស្ពានជាស្រែបុណ្យ ។
១២- ស្គរធំវត្តខ្ញុំទូងសាមគ្គី អង្រួនសព្វទីពេលអាសន្ន
មានចោរមានខ្មាំងប្រមាថជន្ម ទូងដាស់ផងជនស្រោចស្រង់ញាតិ ។
១៣- ស្គរធំស្គរទិព្វល្អឥតខ្ចោះ ក្រញូងកកោះផ្សំផ្គុំធាតុ
ទូងដាស់សន្តិកុំបីឃ្លាត ភក្តីជ្រោងជាតិទើបខ្មែរថ្កើង ។

# សន្និសីទស្តីពី "ការអភិរក្សសាស្ត្រាស្លឹករឹត និងក្រាំង តាមប្រពន្ធ័ឌីហ្សីតាល់"

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

នៅថ្ងៃទី០១ ដល់ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៣ នៅវិទ្យាស្ថានពុទ្ធ-សាសនបណ្ឌិត្យ បានរៀបចំធ្វើសន្និសីទស្តីពី " ការអភិរក្សសាស្ត្រាស្លឹករឹត និងក្រាំង តាមប្រពន្ធ័ឌីហ្សីតាល់ " ក្រោមកិច្ចជួយឧបត្ថម្ភរបស់សហគមន៍អឺរ៉ុប (Union Européenne) ។

កម្មវិធីនេះរៀបចំឡើង ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ (Institut Budhhique) សង្គមអាស៊ី (Société Asiatique) នៃប្រទេសបារាំង និង Torre do Tombo នៃប្រទេសព័រទុយហ្គាល ។

សន្និសីទនេះប្រព្រឹត្តទៅក្នុងបំណង និងទិសដៅមួយ ដើម្បីប្រមូលចម្លងឯកសារមានវ័យចំណាស់របស់ខ្មែរ នៅមានសេសសល់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលឯកសារទាំងនោះសុទ្ធសឹងជាក្បួនច្បាប់ខ្មែរ ឆ្លុះបញ្ចាំងពីអរិយធម៌ វប្បធម៌ ប្រវត្តិសាស្ត្រ អក្សរសាស្ត្រ សាសនា ។ល។ ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន និងមានអាយុកាលដ៏យូរលង់ព្រមជាមួយនឹងការខូតខាតបាត់បង់ជាបន្តបន្ទាប់ តាមរយៈបាតុភូតធម្មជាតិ សង្គ្រាម ព្រមទាំងខ្វះការយកចិត្តទុកដាក់ ថែរក្សា។

ក្នុងន័យនេះហើយដែលវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ មានគំនិតផ្តួចផ្តើមរៀបចំសន្និសីទនេះឡើង ជាមួយនិងការរីកចម្រើន នៃបច្ចេកវិទ្យាឌីហ្សីតាល់ ដែលជា មធ្យោបាយដ៏ល្អសម្រាប់សម្រេចបំណងខាងលើ។

# សេចក្ដីជូនដំណឹងរបស់
# ពុទ្ធិកសមាគមកម្ពុជរដ្ឋ

អនុលោមតាម លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការនាយកពុទ្ធិកសមាគមកម្ពុជរដ្ឋ (ព.ស.ក) អាណត្តិទី ២ ដែលមហាសន្និបាតបានធ្វើឱ្យសម្រេចឡើងកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៣ កន្លងទៅ ។ សមាជិកសមាជិកាជាប់ឆ្នោត ជាគណៈកម្មាធិការនាយកពុទ្ធិកសមាគមកម្ពុជរដ្ឋ បានប្រជុំពិភាក្សាបែងចែក តួនាទី ភារកិច្ច កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៣ ហើយបានឯកភាពសម្រេចដូចតទៅ :

## <u>គណៈកម្មាធិការនាយកពុទ្ធិកសមាគមកម្ពុជរដ្ឋ</u>

| | |
|---|---|
| ១-ឯកឧត្ដម ចាន់ វ៉ែន | អគ្គលេខាធិការរងនៃរដ្ឋសភា ប្រធាន |
| ២-ឯកឧត្ដម ជា សាវឿន | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អនុប្រធាន |
| ៣-សម្ដេចព្រះពោធិវង្ស នន្ទ ង៉ែត | អគ្គាធិការពុទ្ធកសិក្សា ព្រះមេគណ រាជធានីភ្នំពេញ អនុប្រធាន |
| ៤-លោក ប្រាក់ ម៉ន | អតីតប្រធានការិយាល័យស្ថិត ផែនការ ក្រសួងសុខាភិបាល អគ្គលេខាធិការ |
| ៥-ឯកឧត្ដម ជា គាន | អគ្គលេខាធិការរងគណកម្មាធិការ បុណ្យជាតិនិងអន្តរជាតិ លេខាធិការ |
| ៦-លោក អ៊ុន សំអន់ | អតីតអនុប្រធានមន្ទីរធម្មការ និង |

សាសនារាជធានីភ្នំពេញ លេខាធិការ

៧-លោក ឈួយ យឿង អតីតប្រធានការិយាល័យរដ្ឋបាល គណៈចាត់តាំងក្រុងភ្នំពេញ ហេរញ្ញិក

៨-លោក អ៊ុំ ណាន់ អនុប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ក្រសួងធម្មការនិងសាសនា គណនេយ្យករ

៩-លោកស្រី ហោ ផល្លីន បេឡាធិការ ក្រសួងធម្មការនិងសាសនា បេឡាធិការ

១០-ឯកឧត្តម ឡេង ប៉េងឡុង សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការ គណៈរដ្ឋមន្ត្រី សមាជិក

១១-លោកឧកញ៉ា ចាយ ស៊ាងអ៊ី គ្រូឱសថបូរាណខ្មែររាជធានីភ្នំពេញ សមាជិក

១២-ព្រះធម្មឧត្តម ឡៃ យុវណាត អភិបាលកិច្ចសង្ឃ គណធម្មយុត្តិកនិកាយ សមាជិក

១៣-អ្នកឧកញ៉ាឧបាសិកា ញ៉ឹក ប៊ុនថា អនុប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធយុវពុទ្ធសាសនិកកម្ពុជា និងជាគណៈដឹកនាំធម្មសាកច្ឆា សមាជិក

១៤- លោក យី ធន់ អតីតទីប្រឹក្សាក្រសួងធម្មការនិងសាសនា សមាជិក

១៥-លោក ស្វាយ ហ៊ាង ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងធម្មការនិងសាសនា សមាជិក

១៦-លោក ខ្សៅ បញ្ញាវុឌ្ឍ នាយករងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
សមាជិក
១៧-លោកវរសេនីយ៍ឯក សាវ៉ាយ ផុន អនុប្រធាននាយកដ្ឋានភស្តុភារ និង
សម្ភារៈបច្ចេកទេសក្រសួងមហាផ្ទៃ
សមាជិក

## ការចាត់តាំងគណៈកម្មាធិការនានារបស់គណៈកម្មាធិការនាយក ពុទ្ធិកសមាគមកម្ពុជរដ្ឋ

### ១-គណៈកម្មការឃោសនា និងបោះពុម្ពផ្សាយ

-ឯកឧត្តម ជា គាន ប្រធាន
-ឯកឧត្តម ឡេង ប៉េងឡុង អនុប្រធាន
-លោក យី ធន់ អនុប្រធាន

### ២-គណកម្មការ អប់រំសីលធម៌ និងវប្បធម៌សន្តិភាព

-អ្នកឧកញ៉ាឧបាសិកា ញឹក ប៊ុនថា ប្រធាន
-ព្រះធម្មឧត្តម ឡៃ យុវណាត អនុប្រធាន
-ព្រះឧត្តមសត្ថា សេង សុមុនី អនុប្រធាន

### ៣-គណកម្មការមនុស្សធម៌ ប្រជាសង្គ្រោះ

-លោកឧកញ៉ា ចាយ ស៊ាងអ៊ី ប្រធាន

-លោក ស្វាយ ហ៊ាង អនុប្រធាន

-លោក ខៀវ បញ្ញាវុឌ្ឍ អនុប្រធាន

*៤-គណៈកម្មការទំនាក់ទំនងសាធារណៈ និងហិរញ្ញកិច្ច*

-លោក ប្រាក់ ម៉ន ប្រធាន

-លោក ឈួយ ឃឿង អនុប្រធាន

-លោកវរសេនីយ៍ សារ៉ាយ ឆុន អនុប្រធាន

## ស្នងការគណនេយ្យ

អង្គមហាសន្និបាត ព.ស.ក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៣ បានជ្រើសតាំងស្នងការគណនេយ្យ សម្រាប់តាមដាន ត្រួតពិនិត្យការងារហិរញ្ញកិច្ចពុទ្ធិកសមាគមកម្ពុ ជរដ្ឋ បីរូបដែលមានសមាភាពដូចខាងក្រោម:

១-លោក ម៉ម ភួង សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ប្រធាន

២-លោក ឡុច សារិន ប្រធាននាយកដ្ឋានជំនួយការគណៈកម្មាធិការហិរញ្ញវត្ថុ សមាជិក

៣-លោក ង៉ែត សម គណកម្មាធិការសាលាបឋមសិក្សាបាក់ទូក សមាជិក

ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា



**មិត្តអ្នកអានជាទីមេត្រី !**

កម្ពុជសុរិយា បានទទួលអត្ថបទពីបណ្ដាខេត្តមួយចំនួននៅក្នុងប្រទេស និងមួយចំនួនទៀតមកពីក្រៅប្រទេស ជាអត្ថបទបែបស្រាវជ្រាវ ជាអត្ថបទកំណាព្យ និងអត្ថបទសំណួរ។ កម្ពុជសុរិយា សូមជម្រាបបញ្ជាក់ថា រាល់អត្ថបទទាំងអស់យើងនឹងធ្វើការពិនិត្យ និងសម្រេចបោះពុម្ពទៅបានដោយ ÷

-មានខ្លឹមសារអត្យាក្រិត ទាក់ទងនឹងអក្សរសិល្ប៍ពុទ្ធសាសនា, អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ.

-មិនចម្លងពីច្បាប់ដើមណាមួយ និងមិនលើសពី៥០ទំព័រ

អាស្រ័យហេតុនេះរាល់អត្ថបទ ដែលអស់លោកអ្នកបានផ្ញើមកហើយ ហើយមិនទាន់ឃើញចុះផ្សាយនោះ កម្ពុជសុរិយានឹងបន្តចុះផ្សាយតាមលំដាប់លេខរៀង ឬថៃរក្សាសម្រាប់បោះពុម្ពជាសៀវភៅ ឬជាព្រឹត្តិប័ត្រ ប្រចាំខែនៅអនាគតដ៏ខ្លីខាងមុខ។

**សូមអរគុណ**

# អត្ថបទដែលកម្ពុជសុរិយាបានទទួលក្នុងត្រីមាសទី៣ ឆ្នាំ២០០៣

| ល.រ | នាម និងគោត្តនាម | មកពី | ឈ្មោះអត្ថបទ |
|---|---|---|---|
| ១ | លោក យក់ សាន់ | ខេត្តកំពង់ធំ | -ពុទ្ធសាសនា និងការប្រតិបត្តិនៅកម្ពុជាបច្ចុប្បន្ន<br>-ប្រវត្តិជនជាតិភាគតិចនៅភូមិភាគឥសាន (វប្បធម៌ ទំនៀមទម្លាប់ប្រពៃណី)<br>-កំណាព្យ<br>-គុណសម្ដេចឪ សម្ដេចម៉ែ<br>-ពាក្យទូន្មានរបស់ព្រះពុទ្ធ<br>-តម្លៃរបស់ព្រះពុទ្ធសាសនា |
| ២ | លោក ញ៉ាង ប៊ុនថន | រតនគិរី | -សម្លប្រហុង<br>-ការរៀបចំគូរស្រករបស់ជនជាតិព្រៅ នៅខេត្តរតនគិរី<br>-អំពីពាង<br>-អំពីឧបករណ៍ភ្លេងគង |

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



មហោស្រពអង្គរក្នុងរជ្ជកាលហ្លួង ស៊ីសុវត្ថិ

ឆ្នាំទី ៥៧ លេខ ៤ ខែ តុលា - វិច្ឆិកា - ធ្នូ

ព.ស. ២៥៤៧ គ.ស. ២០០៣

ភ្នំពេញ

រូបក្របខាងក្រៅ :

*បានទទួលពីលោកសាស្ត្រាចារ្យ* ***ទ័ន់ ជុន*** *ធ្វើការនៅនាយកដ្ឋានអភិរក្ស ក្រសួងព្រះបរមរាជវាំង*

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

នាយកការផ្សាយ : **ខួន វ៉ាន់ចន្ធី**

និពន្ធនាយក : **ខៀវ បញ្ញារុឌ្ឍ**

គណៈកម្មការនិពន្ធ

លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង**. លោក **ម៉ែន ប្រាង**

លោក **ទង់ សុធារ៉ា**. លោក **ឆន់ ហ៊ុន**.

លោក **មៀច ប៊ុណ្ណ**. លោក **ពិ ប៊ុន្ធីន**

## គណៈកម្មការពិគ្រោះយោបល់

- លោកព្រឹទ្ធាចារ្យ **នេខ ផុន** ប្រធានមជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា
- ឯកឧត្តម **នុត ណារ៉ាង** ប្រធានមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ
- ឯកឧត្តម **ជា សាវឿន** រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
- ឯកឧត្តម **ឈុន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា
- លោកបណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម** នាយកវិជ្ជាស្ថានជាតិខាងភាសា
- លោកបណ្ឌិតទស្សនវិជ្ជា **ឆយ យីហ៊ាង** ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារអប់រំ. ព្រឹទ្ធបុរសដេប៉ាតឺម៉ង់ទស្សនវិជ្ជា និងក្រុមការងាររាជបណ្ឌិតសភាកម្ពុជា
- លោកបណ្ឌិត **នេត ឆាវ៉ុម** សកលវិទ្យាធិការរង នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

---


- បោះពុម្ពផ្សាយដោយប្រើថវិកាបានពីការលក់សៀវភៅនានា ដែលក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព ( WCRP ) នៃប្រទេសជប៉ុន បានឧបត្ថម្ភ។
- **The puplication of this issue has been made possible by the fund earned the sale of books supported by the WCRP/Japan.**

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ជីវិតមនុស្ស និងបញ្ហា (ត) ............... (ឈន អៀម) ១
- ប្រវត្តិរបស់អដ្ឋកថា ..................... (វ៉ាន់ ចាន់សារ៉ែន) ១៣


## II. អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ :


- ព្រះពុទ្ធសាសនាជាឫសគល់មួយនៃវប្បធម៌ខ្មែរ ... (ខូត ធីតា) ១៩
- សាស្ត្រាខ្មែរនៅភាគឦសានប្រទេសថៃ .. (មីសែលត្រាណេ) ២៩
- ការសរសេរដោយដៃដែលរក្សាទុកនៅ ព.ស.ប.. (ឃីង ហុកឌី) ៤០
- ព្រះរាម ឬរាមចន្ទ្រ (តចប់) ................. (ធន់ ហ៊ិន ) ៤៧
- ពិធីព្យាបាលតាមបែបខ្មែរបុរាណ.. ......... (មៀច ប៉ុណ្ណ) ៥៨
- ពិធីទាក់ដីវីររបស់អ្នកស្រុកភ្នំក្រវាញ ........ (ម៉ៅ សោភ័ណ ) ៦២
- ប្រវត្តិភូមិ (បាយសំណុំ, កំពង់ស្វាយចេក ........ (ជួប ឃាន) ៧៦
- ឆ្នាំប្រាសាទបាយ័ន (តចប់) .............. (ខៀវ បញ្ញាវុឌ្ឍ) ៨០


## III. កំណត់ និងប្រវត្តិការណ៍ :


- សុន្ទរកថារបស់ .... (ព្រះតេជព្រះគុណ គុសុកបាកុឡា រិនប៉ូចេ) ៩០
- ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ២០០៣ .........(សំ ធា) ៩៦


## IV. ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា


- មិត្តអ្នកអានជាទីមេត្រី ................ (ខៀវ បញ្ញាវុឌ្ឍ) ៩៩

# ជីវិតមនុស្ស និង បញ្ហា (ត)

បណ្ឌិត **ក.ស្រីធម្មានន្ទ នាយកមហាថេរ**
បកប្រែ **ឈន-អៀម**

## ការលែងលះគ្នា - គ្រាន់តែជាពំនឹងចុងក្រោយប៉ុណ្ណោះ

ការលែងលះគ្នា គឺជាបញ្ហាមួយដ៏ចម្រូងចម្រាស់ក្នុងចំណោមអ្នកប្រតិបត្តិតាមសាសនាផ្សេងៗ។ មនុស្សខ្លះមានជំនឿថា អាពាហ៍ពិពាហ៍ត្រូវបានកត់ត្រាទុកនៅក្នុងឋានសួគ៌ ហើយដោយហេតុនេះមនុស្សគ្មានសិទ្ធិលែងលះគ្នាទេ។ ប៉ុន្តែបើប្តីនិងប្រពន្ធមិនអាចរស់នៅជាមួយគ្នាបានដោយពិតប្រាកដ ជាជំនួសការរស់នៅដោយវេទនា ហើយមានការប៉ះទង្គិច ខឹងសម្បារនិងគំនុំគុំគួនច្រើនឡើង ប្តីនិងប្រពន្ធគួរមានសេរីភាពបំបែកគ្នា ហើយរស់នៅផ្សេងគ្នាដោយស្ងប់ស្ងៀម។

ការបំបែកគ្នា ឬការលែងលះគ្នាមិនត្រូវបានហាមឃាត់ទេ នៅក្នុងព្រះពុទ្ធសាសនា ថ្វីបើភាពចាំបាច់កម្រនឹងកើតមានក្តី ប្រសិនបើដំបូន្មានរបស់ព្រះពុទ្ធត្រូវបានប្រតិបត្តិតាមដោយម៉ត់ចត់។ បុរស និងស្ត្រីអាចមានសេរីភាពបំបែកគ្នា ប្រសិនណាគេទាំងពីរនាក់មិនអាចចុះសម្រុងជាមួយគ្នាដោយពិតប្រាកដ។ ការបំបែកគ្នាប្រសើរជាងការរងទុក្ខក្នុងជីវភាពគ្រួសារដ៏លំបាកវេទនាអស់រយៈកាលដ៏យូរ។

អ្នកខ្លះអាចចូលចិត្តការបែកគ្នាតាមផ្លូវច្បាប់ ដែលជាប្រភេទការលែងលះគ្នាមួយ វៀរលែងតែថា អាពាហ៍ពិពាហ៍កើតមានឡើងក្នុងនាមសម្រាប់ ហេតុ-ផល

ផ្សេងៗ។

កត្តាទាំងឡាយនាំទៅដល់ការលែងលះគ្នា ខុសៗពីគ្នា។ កាលណា អណ្តាតភ្លើងនៃសេចក្តីស្នេហារលត់ភ្លាមៗ ឬកាលណាសេចក្តីប្តេជ្ញា ដើម្បី " ស្រឡាញ់ ផ្តល់កិត្តិយស ថ្នាក់ថ្នមគ្នាទៅវិញទៅមកអស់មួយជីវិត " ហាក់មិនអាចតាំងនៅបានយូរ ការលែងលះគ្នាលេចឡើងជាដំណោះស្រាយដ៏ប្រសើរបំផុត។ មែនហើយ វាមានកត្តាផ្សេងៗទៀតដែរ រាប់តាំងពីកិច្ចការខាងក្រៅអាពាហ៍ពិពាហ៍ បញ្ហាសាច់ថ្លៃ (in-law problem) ក៏ដូចជាការខ្វែងគំនិតគ្នានៅក្នុងគ្រួសារ ដែលម្តាយជាអ្នកធ្វើការ ត្រូវប្រឈមមុខដើម្បីរក្សាមុខរបរមួយ។ នៅក្នុងចំណុចនេះ. យើងនឹកឃើញដំបូន្មានរបស់ព្រះពុទ្ធថា បុរសចាស់មិនត្រូវយកប្រពន្ធក្មេងទេ ពីព្រោះវាអាចបង្កើតការមិនចុះសម្រុងគ្នា សេចក្តីប្រចណ្ឌ និងសេចក្តីសង្ស័យ (នៅក្នុងបរាភវសូត្រ)។

ក្រោមច្បាប់កំណែទម្រង់ (អាពាហ៍ពិពាហ៍ និងការលែងលះគ្នា) ឆ្នាំ១៩៧៦ ដោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ខែមិនាឆ្នាំ១៩៨២ តុលាការអាពាហ៍ពិពាហ៍ត្រូវបានចាត់តាំងឡើងឱ្យមានទូទាំងប្រទេសម៉ាឡេស៊ីផងដែរ ដោយមានមុខងារដោះស្រាយ និងផ្សះផ្សារគូស្រករទាំងឡាយ ក្រៅពីគូស្រករមូស្លីមទាំងឡាយដែលមានការលំបាករឿងអាពាហ៍ពិពាហ៍។ (គូស្រករជាមូស្លីម ត្រូវបានគ្រប់គ្រងផ្សេងពីនេះដោយច្បាប់ស្យារីយាហ៍ (Syariah Law) ហើយឋិតនៅក្រោមយុត្តាធិការរបស់តុលាការស្យារីយាហ៍ (The Syariah court) ។

តុលាការអាពាហ៍ពិពាហ៍ត្រូវបានគេចាត់តាំងឡើងនៅក្នុងរដ្ឋនីមួយៗ មានរួមទាំងដែនដីសហពន្ធ័នៃកូឡាឡាំពួរផង។ ច្បាប់តម្រូវឱ្យយករឿងទំនាស់អាពាហ៍ពិពាហ៍ទៅដោះស្រាយនៅឯតុលាការអាពាហ៍ពិពាហ៍ចាត់តាំងដោយក្រិត្យ មុនពាក្យ

បណ្តឹងសុំលែងលះត្រូវបានដាក់ជូនតុលាការ ។

ច្បាប់ផ្តល់ពេល៦ខែ ដើម្បីផ្សះផ្សារប្រសិនបើគូស្រករអាចជានាគ្នាបាន ។ គ្រប់តុលាការ ត្រូវកោះប្រជុំបើកសវនាការ ៣ ឬ ៤ដងសម្រាប់រឿងនីមួយៗ នៅក្នុងរយៈពេល៦ ខែ ។ ប្រសិនបើមិនមានសញ្ញាណាមួយអាចផ្សះផ្សារជានាគ្នាបានទេ តុលាការត្រូវចេញវិញ្ញាបនប័ត្រមួយចំពោះរឿងនេះ ទៅអ្នកប្តឹង ។ គឺបន្ទាប់ពីវិញ្ញាបនប័ត្រចេញឱ្យហើយប៉ុណ្ណោះ ទើបអ្នកប្តឹងអាចដាក់ពាក្យប្តឹងសុំលែងលះទៅតុលាការ ជាន់ខ្ពស់ តាមរយៈលោកមេធាវី ។

ជាអកុសល កាលណាឪពុកម្តាយលែងលះគ្នា កូនៗរបស់ពួកគេ ក្លាយទៅជាជនរងគ្រោះឥតកំហុស ដែលទទួលផលវិបាកដ៏អាក្រក់បំផុត នៃអាពាហ៍ពិពាហ៍បរាជ័យនោះ ។ ការលែងគ្នា គឺជាបាតុភូតសង្គមមួយ ហើយជារឿងមួយដែលប៉ះពាល់កូនៗខាងផ្លូវចិត្ត ហើយវាអាចធ្វើឱ្យពួកគេមានអារម្មណ៍មិនកក់ក្តៅ ។ ពួកគេត្រូវជួប និងបញ្ហារាប់មិនអស់ គឺបញ្ហាទទួលយក បញ្ហាកែតម្រូវខ្លួន និងបញ្ហាបាត់ភាពកក់ក្តៅ ។ កូនៗវ័យក្មេងដូចនេះ នឹងត្រូវការដំបូន្មានជាប្រចាំ និងការឧបត្ថម្ភ និងការលួងលោម ផ្លូវចិត្តជាប្រចាំ ដើម្បីចេញផុតពីដំណាក់កាលប៉ះទង្គិចខ្លាំងខាងផ្លូវចិត្តក្នុងជីវិតរបស់ពួកគេ ។

ឪពុកម្តាយដែលលះលែងគ្នា ជាញឹកញយត្រូវបានគេចាត់ទុកជាជន កាមសុខនិយម (hedonists) ដែលជាប់ចិត្តតែក្នុងសេចក្តីសប្បាយផ្ទាល់ខ្លួនប៉ុណ្ណោះហើយមិនគិតដល់សុភមង្គលរបស់កូនៗ ពួកគេទេ ។

ក្មេងៗខ្លះ អាចត្រូវរស់នៅជាមួយឪពុក ឬម្តាយចុង កាលណាឪពុកម្តាយរបស់គេរៀបការជាថ្មី ។ ការលែងលះស្ទើរតែដូចគ្នានឹងការបដិសេធន៍ មិនឱ្យកូនមាន

សិទ្ធិ មានជីវភាពរស់នៅពេញលេញ ជាមួយឳពុក ម្ដាយបង្កើត ទាំងពីរអ្នក ក្រោមដំបូលតែមួយ ។ ដោយសារតែគេមានចិត្តរំខានទើបកូនៗទាំងនោះ អាចបាត់បង់ការផ្ចង់ចិត្តគំនិតហើយជាលទ្ធផលការរៀនរបស់គេនៅសាលា អាចប៉ះពាល់ ។ នេះហើយដែលនាំឱ្យមានក្មេងរត់ចោលសាលារៀន និងបទល្មើសព្រហ្មទណ្ឌយុវវ័យ ។

ជាញឹកញាយណាស់ កាលណាការលែងលះបានកើតឡើងពីការឈ្លោះវាយតប់ ហើយបានរងការឈឺចាប់លើរូបកាយ ក្រោមកណ្ដាប់ដៃឳពុកម្ដាយមានកំហឹង កូនៗដល់ពេលធំពេញវ័យឡើងខ្លាចមិនហ៊ានរៀបអាពាហ៍ពិពាហ៍ខ្លួនឯងទេ ពីព្រោះពួកគេមើលឃើញ អាពាហ៍ពិពាហ៍ ជាការគំរាមកំហែងដល់សុវត្ថិភាពរបស់ពួកគេ ហើយមានសង្ឃឹមតិចតួចណាស់រកឃើញសុភមង្គល ។ ពួកគេបានបាត់បង់ទំនុកចិត្តលើឳពុកម្ដាយ ពីព្រោះអាពាហ៍ពិពាហ៍បែកបាក់ ហើយពួកគេមិនមានទំនុកចិត្តចំពោះមនុស្សមានភេទផ្សេងពីខ្លួនគេទេ ។

ចំពោះក្មេងខ្លះ សេចក្ដីភ័យខ្លាចខាងផ្លូវចិត្ត អាចជាសះស្បើយទៅវិញតាមពេលវេលាកន្លងទៅ ។ ប៉ុន្តែចំពោះក្មេងៗខ្លះវិញ ពួកគេនៅតែបន្តភ័យខ្លាច ។ ព្រោះហេតុនេះការលែងលះគ្នាជាប្ដី-ប្រពន្ធមិនគ្រាន់តែប៉ះពាល់ផ្លូវចិត្តចំពោះមនុស្សពីរនាក់ប៉ុណ្ណោះទេ ប៉ុន្តែវាបានប៉ះពាល់ផ្លូវចិត្តដល់មនុស្សស្លូតត្រង់ឯទៀតជាច្រើន ។ គេត្រូវតែមានហេតុផលច្បាស់លាស់ មុនពេលមនុស្សណាមួយ ឈានទៅដល់ការសម្រេចចិត្តលែងលះគ្នា ។

ក្មេងៗភាគច្រើន ដែលមានឳពុកម្ដាយលែងលះគ្នា ម្ដងម្កាលតែងសង្ឃឹម និងចិញ្ចឹមបំណងប្រាថ្នាដ៏សម្ងាត់ថា ឳពុកម្ដាយរបស់ពួកគេ នឹងជានាគ្នាឡើងវិញ ហើយជីវភាពគ្រួសារ ប្រែក្លាយជាធម្មតាឡើងវិញ ។

គេត្រូវតែផ្តល់ការថែទាំ ដ៏ម៉ត់ចត់បំផុត ដើម្បីធានាថា ការបែកបាក់គ្នា ត្រូវបានធ្វើឡើង ឋិតក្នុងបរិយាកាសនៃសុឆន្ទៈ និងការយោគយល់គ្នា ដោយប្រកាន់យកដំណោះស្រាយ ប្រកបដោយវិចារណញ្ញាណ គឺមិនមែនដោយការបង្កើតគំនុំគុំគួនទេ។ តាមការណ៍ពិត, ពួកគេគប្បីខិតខំឱ្យអស់លទ្ធភាព ដើម្បីចែកផ្លូវដោយមិត្តភាព ទុកគ្នាជាមិត្រ។ ប្រសិនបើ គូស្រករមានកូន, ពួកគេគប្បីខិតខំធ្វើឱ្យការលែងលះគ្នា ប៉ះទង្គិចចេតនារម្មណ៍របស់កូនៗតិចបំផុត ហើយជួយកូនៗឱ្យកែតម្រូវឥរិយាបថរបស់ពួកវាចំពោះស្ថានភាពថ្មី។ ប្រការសំខាន់បំផុត គឺត្រូវធានាថា អនាគតរបស់ពួកគេ និងសុខមាលភាពរបស់ពួកគេ ត្រូវបានគេថែទាំ ។ វាជាអំពើអមនុស្សធម៌ណាស់ ប្រសិនបើអ្នកទាំងពីរ បោះបង់ មិនគិតគូរកូនៗរបស់ខ្លួន ហើយទុកឱ្យពួកវារស់នៅដោយខ្លួនឯង ហើយមានជីវភាពគោកយ៉ាក។

កាលណាបុរសម្នាក់ ទោះជាសំអាងហេតុផលអ្វីក៏ដោយ ដាក់ពាក្យសុំលែងលះប្រពន្ធ,គឺប្រពន្ធហ្នឹងឯងដែលទទួលរងការឈឺចាប់បំផុតនៅក្នុងរឿងនេះ។ សុបិនដែលនាងចិញ្ចឹមទុកដើម្បីមានជីវភាពអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គល ត្រូវបានអណ្តែតត្រសែតឆ្ងាយទៅ ជាពិសេស ប្រសិនបើប្តីមានជាប់ពាក់ពន្ធ័ នឹងកិច្ចការអាពាហ៍ពិពាហ៍ខាងក្រៅណាមួយ ហើយកំពុងខិតខំដោះដៃអំពីចំណងអាពាហ៍ពិពាហ៍ (ចាស់) ដើម្បីរួមរស់ជាមួយ "ស្ត្រីផ្សេង"។ ស្ត្រីដែលកំពុងប្រឈមមុខ នឹងការលែងលះហៀបនឹងមកដល់ ធ្លាប់បានសម្តែងអារម្មណ៍ខកចិត្តជាញឹកញួយ ដែលជារឿងហេតុជាក់ស្តែងនៅក្នុងករណីដ៏សោកសៅ" *ខ្ញុំត្រូវរងវិនាសហិនហោច។សម្រាប់ខ្ញុំ ពិភពលោកត្រូវបានចប់ហើយ ហើយខ្ញុំបានគិតគូរត្រៀមស្លាប់ដើម្បីធ្វើឱ្យគាត់ (ប្តីលែងលះ) មានអារម្មណ៍ស្តាយក្រោយដោយសាររឿងមិនចង់បានខ្ញុំ*" ។

ឧភតោកោដិបញ្ហា ឬបញ្ហាមួយមានចងចំណងពីរ (the dilemma) ដែលស្ត្រីប្តីលែងជាច្រើននៅក្នុងប្រទេសម៉ាឡេស៊ីបានប្រឈមមុខ គឺជារឿងដ៏សោកសៅដែលថានាងមានសិទ្ធិតែមួយគត់គឺថែទាំកូន ប៉ុន្តែគ្មានអំណាចជាអ្នកអាណាព្យាបាលតាមផ្លូវច្បាប់ទេ (legal guardian) ។ ទាក់ទងនឹងស្ថានភាពដ៏ពិបាកនេះ ស្ត្រីជាម្តាយទាំងឡាយដែលជាអ្នកថែទាំកូនត្រូវបង្ខំចិត្តអំពាវនាវឱ្យអតីតស្វាមីប្រគល់សិទ្ធិជាម្តាយពេញលក្ខណៈមកឱ្យខ្លួន។ ចុះបើឪពុកមិនព្រមសហការ ដើម្បីផ្តល់សេចក្តីយល់ព្រមរបស់គេ ឬប្រសិនបើ គេមិនអាចរកឪពុកឃើញ មិនដឹងនៅទីណានោះកូនដ៏អភព្វ ដែលអាចត្រូវការលិខិតឆ្លងដែន ដើម្បីចេញទៅសិក្សានៅបរទេសយកជាឧទាហរណ៍ មុខជាត្រូវធ្លាក់ក្នុង ស្ថានភាពពិបាកមិនអាចចេញរួច ។

ច្រកចេញតែមួយគត់ ដែលម្តាយទទួលបានជារៀងរហូត ក្លាយជាអាណាព្យាបាលតាមផ្លូវច្បាប់លើកូនរបស់ខ្លួនគឺកាលណាឪពុកស្លាប់ កាលណាឪពុកត្រូវបានគ្រូពេទ្យប្រកាសថាឡប់សតិ ឬឆ្កួត ឬកាលណាឪពុកមានឯកសារបញ្ជាក់ថាជាជនឧក្រិដ្ឋ។ ក្រោមកាលៈទេសៈបែបនេះ មេធាវីជាទូទៅតែងណែនាំឱ្យស្ត្រីជាម្តាយដាក់ពាក្យសុំសិទ្ធិថែទាំ និងអាណាព្យាបាលភ្លាម នៅពេលដែលស្ត្រីទាំងឡាយនោះ ត្រូវបានលែងលះអំពីប្តី ហើយមិនឱ្យរង់ចាំរហូតដល់នីតិវិធីចាប់ដំណើរការទេ ប៉ុន្តែរឿងនេះទៀតក៏មិនមែនជាការងារងាយស្រួលឡើយ។

## ការរើសអើងប្រឆាំងស្ត្រី

ព្រះពុទ្ធតែងមានពុទ្ធដិកាថា បើយើងចង់ស្វែងយល់អ្វីមួយ យើងត្រូវរៀន "មើលឱ្យឃើញវត្ថុទាំងឡាយតាមសភាពពិតរបស់វា" ។ គឺក្រោយពេលការសិក្សា

វិភាគបែបនេះអំពីស្ត្រីក្នុងទំនាក់ទំនងទៅនឹងបុរស ទើបព្រះពុទ្ធអង្គបានធ្វើសេចក្តីសន្និដ្ឋានថា គ្មានឧបសគ្គណាមួយនៅក្នុងស្ត្រីទាំងឡាយមិនអាចនាំឱ្យពួកគេប្រតិបត្តិសាសនាបានដូចជាពួកបុរស.ហើយសម្រេចបានស្ថានភាពខ្ពស់បំផុតនៅក្នុងជីវិតដែលជាអរហត្តផល ជាកំរិតខ្ពស់បំផុតនៃបរិសុទ្ធកម្មខាងផ្លូវចិត្តនោះទេ។ ព្រះពុទ្ធ ទ្រង់បានប្រឈមនឹងការជំទាស់ដ៏ខ្លាំងក្លា ក្នុងការផ្តល់សេរីភាពពេញលេញដល់ស្ត្រីទាំងឡាយ ដើម្បីប្រតិបត្តិសាសនា។

នៅសម័យពុទ្ធកាល មុនពេលព្រះអង្គបានរំដោះស្ត្រីទាំងឡាយ ប្រពៃណីនិងទំនៀមទម្លាប់បានកំណត់ថា ស្ត្រីភេទត្រូវបានគេចាត់ទុកជាព្រទ្យសម្បត្តិចលត័ (chattel, ជង្គមធន) សម្រាប់បុរសប្រើប្រាស់បំរើសេចក្តីសប្បាយរបស់គេ។ **មនុ** ជាអ្នកប្រទានច្បាប់ពីបុរាណនៃប្រទេសឥណ្ឌាបានចេញក្រឹត្យកំណត់ថា ស្ត្រីមានឋានៈទាបជាងបុរស។ ដោយហេតុនេះ ទីតាំងរបស់ស្ត្រីនៅក្នុងសង្គមទាបណាស់ហើយត្រូវបានដាក់កំហិតឱ្យនៅតែក្នុងផ្ទះបាយ។ គេមិនអនុញ្ញាតឱ្យស្ត្រី សូម្បីតែចូលទៅក្នុងព្រះវិហារនិងចូលរួមក្នុងសកម្មភាពសាសនាក្នុងបែបណាមួយក៏ដោយក៏មិនបានដែរ។

ដូចយើងបានកត់សម្គាល់ពីខាងដើមក្រោមចំណងជើង " ការពន្យារកំណើត " (Birth Control) ការរើសអើងប្រឆាំងស្ត្រីចាប់ផ្តើមតាំងពីមុនទារកកើតចេញពីផ្ទៃម្តាយទៅទៀត! ការប្រព្រឹត្តិដ៏ទូលំទូលាយទម្លាក់គភ៌ទារកភេទស្រីកំពុងនិយមនៅក្នុងផ្នែកជាច្រើននៃពិភពលោកបច្ចុប្បន្ន គឺជាភស្តុតាងចំពោះហេតុពិតដ៏គួរឱ្យព្រឺខ្លាចនេះ។ បន្តឆ្ងាយមកទៀត នៅក្រោមចំណងជើងថា " ចលនារំដោះស្ត្រីនិងផលរបស់វាមកលើជីវភាពគ្រួសារ" ការរើសអើងប្រឆាំងស្ត្រីក្នុងសង្គមអ្នកមានជាពិសេសសង្គមដែលប្រណាំងគ្នា ដណ្តើមគ្នាយកតំណែងគ្រប់គ្រងកំពូលៗ នៅក្នុង

ផ្នែកសាជីវកម្ម នឹងត្រូវបានលើកយកមកនិយាយយ៉ាងលម្អិត ។

ប៉ុន្តែថា នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ស្ថានភាពនេះអាចត្រូវបានគេពិពណ៌នាថា អាក្រក់ខ្លាំងណាស់ ហើយគួរឱ្យអាណោចអាធម្មដូចសេចក្តីរាយការណ៍ដែលនឹងត្រូវបង្ហាញតទៅនេះ ។

នៅប្រទេសឥណ្ឌានិយមជំនឿបូជា ភេទប្រុសបានគ្របដណ្តប់លើសង្គម ភាពជាស្រីមេម៉ាយគឺជាវាសនាដ៏គួរឱ្យខ្លាចសម្រាប់ស្ត្រី ។ មានករណីស្រីមេម៉ាយជាច្រើន( អ្នកខ្លះទើបតែមានអាយុម្ភៃឆ្នាំ) ដែលត្រូវគេបណ្តេញចេញពីគ្រួសាររបស់ខ្លួន ហើយត្រូវសង្គមបោះបង់ ក្រោយពេលប្តីរបស់ខ្លួនបានស្លាប់ទៅ ។

ក្នុងចំណោមគ្រួសារប្រកាន់ជំនឿខុស( អប្បិយជំនឿ) ស្រីមេម៉ាយ ជាញឹកញាយត្រូវបានឪពុក-ម្តាយក្មេក ស្តីបន្ទោស ទម្លាក់កំហុសទៅលើមរណភាពនៃប្តីរបស់នាង ហើយរហូតដល់លែងរាប់រកថែមទៀត ។ មានជម្រើសតិចតួចសេសសល់សម្រាប់ស្ត្រីមេម៉ាយ ។ ពួកជនកាន់សាសនាហិណ្ឌូមិនបានគាំទ្រឱ្យស្ត្រីមេម៉ាយរៀបការជាថ្មីទេ ប៉ុន្តែមិនមានរបាំងបែបនេះសម្រាប់បុរសផងទេ ។ រហូតមកដល់សម័យថ្មី ស្ត្រីមេម៉ាយទាំងឡាយ នៅតែត្រូវបានគេរំពឹងគិតចង់ឱ្យលោតទៅលើគំនរភ្លើងបូជាសពប្តីរបស់នាង យោងទៅតាមប្រពៃណីមួយដែលគេហៅថា សាតិ (sati) ។ ថ្វីបើការប្រព្រឹត្តិនេះត្រូវបានជនជាតិអង់គ្លេសដាក់ឱ្យនៅក្រៅច្បាប់អស់ច្រើនទសវត្សទៅហើយក្តី ក៏គង់កើតមានករណីចុងក្រោយនាពេលថ្មីៗនេះ ក្នុងឆ្នាំ១៩៩៦នៅឡើយ ។ ស្ត្រីភាគច្រើននៅក្នុងប្រទេសឥណ្ឌា មានសេចក្តីសង្ឃឹមតិចតួចណាស់កាលណាពួកគេប្រែក្លាយទៅជាស្ត្រីមេម៉ាយហើយ ។

គេអាចលើកយកឧទាហរណ៍ដ៏រន្ធត់ចិត្ត ជាគំរូមួយរបស់ស្រីមេម៉ាយម្នាក់ ដែលបានរងគ្រោះដោយត្រូវរៀបការតាំងពីនៅវ័យកុមារី ដែលជាទំនៀមទម្លាប់មួយទៀតត្រូវបានគេនិយមនៅទីជនបទប្រទេសឥណ្ឌា ។ នាងបានទូញយំរៀបរាប់ថា " *ខ្ញុំត្រូវបានគេចាប់បង្ខំឱ្យរៀបការកាលពីខ្ញុំមានអាយុប្រាំឆ្នាំប៉ុណ្ណោះ ។ ប្តីរបស់ខ្ញុំដែលខ្ញុំមិនស្គាល់សោះ មានអាយុដប់បីឆ្នាំ ហើយគាត់បានស្លាប់មួយខែក្រោយពេលរៀបការហើយ ។ ខ្ញុំឥឡូវជាស្ត្រីមេម៉ាយ* " ។

យោងតាមស្ថិតិរបស់ធនាគារពិភពលោក ស្ត្រីជនជាតិឥណ្ឌាចំនួន ៦៥% ដែលមានអាយុចាស់ជាង ៦០ឆ្នាំឡើងទៅគឺជាស្ត្រីមេម៉ាយ ។ តួលេខនេះបានកើនខ្ពស់ដល់ ៨០% ចំពោះស្ត្រីមានវ័យជាង ៧០ឆ្នាំឡើង ។

សមាគមរបស់ស្ត្រីប្រជាធិបតេយ្យទូទាំងប្រទេសឥណ្ឌារាយការណ៍ថា នៅក្នុងប្រទេសឥណ្ឌា អត្តសញ្ញាណរបស់ស្ត្រី ត្រូវបានកំណត់ថាជាខ្នែងបន្ថែមទៅឱ្យបុរស (an appendage to a male) ភាពជាស្ត្រីមេម៉ាយរឹតតែមានន័យវែងឆ្ងាយច្រើនជាងហេតុដែលគ្រាន់តែបាត់បង់ប្តីទៅទៀត ។

ស្ថានភាពនេះ នៅមិនទាន់បានប្រសើរនៅឡើយ សូម្បីនៅក្នុងប្រទេសជិតខាងខ្លះទៀត ។ អស់ពេលជាយូរណាស់ហើយ គ្រួសារទាំងឡាយបានចាត់ទុកកូនស្រីថាទាបជាងកូនប្រុស ហើយការប្រព្រឹត្តិរបស់គេគឺអនុវត្តទៅតាមទស្សនៈនោះ ។ កូនស្រីត្រូវបានគេមើលឃើញជាទូទៅថាសមស្របតែធ្វើកិច្ចការកំប៉ិកកំប៉ុកប្រចាំថ្ងៃនៅផ្ទះ ។ នាងរស់នៅឆ្លងកាត់តាមការប្រព្រឹត្តិរបស់សង្គមជាបន្តបន្ទាប់ ដែលបង្កើតចិញ្ចឹម និងពង្រឹងការរើសអើងប្រឆាំងខ្លួននាង ។ នាងប្រែក្លាយជាបន្ទុកសេដ្ឋកិច្ចមួយ ហើយក៏ជាបំណុលសីលធម៌ផងដែរ ។ ប៉ុន្តែ ខ្លួននាងត្រូវបានគេសង្ឃឹមឱ្យចិញ្ចឹមកូនៗ

ឱ្យមានសុខភាពល្អ, ឱ្យស្រឡាញ់ការងារ និងឱ្យមានការអប់រំរៀនសូត្រល្អ ហើយឱ្យនាងក្លាយជាមាតាល្អ។ ក្មេងប្រុសតូចៗជាច្រើនមានវ័យធំឡើង ចេះតែគិតថា បង-ប្អូនស្រីៗរបស់ពួកគេអន់ថយជាង ដោយបានឃើញបង-ប្អូនស្រីទាំងនោះ ត្រូវបានគេយកចិត្តទុកដាក់តិចតួចជាងពួកខ្លួន។ ជំនឿទាំងឡាយនេះ កាន់តែបានពង្រឹងខ្លាំងឡើងដោយមនុស្សជាច្រើន នៅក្នុងសង្គម រួមមានទាំងស្ត្រីខ្លួនឯងផង។

ប្រហែលរឿងដ៏ធំបំផុត តែមួយគត់គឺកង្វះការគាំទ្រ ហើយនិងការដាក់កំហិតព្រំដែន ដែលយុវតីប្រឈមមុខ ប្រសិនបើពួកគេចង់ធ្វើអ្វីមួយសម្រាប់ជីវភាពរស់នៅរបស់ពួកគេហួសពីតួនាទីជាប្រពៃណី ដែលតម្រូវឱ្យពួកគេ ដូចជាជំនួយកិច្ចការផ្ទះបាយ មេដោះសម្រាប់ថែទាំទារក អ្នកដាំស្ល និងអ្នកបោសសម្អាត។ តាមពិត យុវតីទាំងឡាយរមែងឋិតនៅក្រោមការហ្វឹកហ្វឺនអស់មួយជីវិតដើម្បីបានជាភរិយាដ៏ល្អកាលណាពួកគេធំឡើង។

ដូចយុវតីអាយុ ១៤ឆ្នាំម្នាក់ មកពីរដ្ឋរ៉ាវាល់ពិណ្ឌី បញ្ជាក់ប្រាប់ថា: *"សង្គមរបស់យើងខ្ញុំ មិនយកចិត្តទុកដាក់ត្រឹមត្រូវ ចំពោះពួកយុវតីទេ។ មនុស្សនៅទីនេះមិនផ្តល់ការអប់រំដល់កូនស្រីជាយុវតីរបស់ពួកគេទេ ពីព្រោះថា ចំពោះពួកគេ កូនស្រីជាយុវតីទាំងឡាយ មិនមែនជារបស់ពួកគេទេ។ យុវតីទាំងឡាយ ត្រូវបានគេមើលឃើញថា ជារបស់គ្រួសារឪពុក-ម្តាយក្មេកអនាគតរបស់នាងៗទាំងនោះ ហើយការធ្វើវិនិយោគឯណានីមួយសម្រាប់អនាគតរបស់នាងៗទាំងនោះ គឺជាការខាតបង់ឥតប្រយោជន៍។ យុវតីទាំងឡាយ ទៅនៅផ្ទះរបស់ប្តីនាងតាំងពីវ័យក្មេង តាមធម្មតាចាប់តាំងពីអាយុ១៣ឆ្នាំ។ មួយជីវិតរបស់ពួកគេត្រូវបានចំណាយសម្រាប់ថែទាំគ្រួសារក្មេក, ហើយបង្កើតកូន និងចិញ្ចឹមកូន ដើម្បីបន្ត និងពង្រីកវង្សត្រកូល របស់*

*ប្តីគេ"។*

យុវតីបន្តនិយាយថា: *យើងត្រូវការចាំបាច់លុបបំបាត់ការគ្រិះរិះបែបនេះ ហើយត្រូវដាក់ការអប់រំ ឱ្យទៅជាការតម្រូវ ហើយឥតបង់ថ្លៃ ដើម្បីកុំឱ្យការអប់រំ ប្រែក្លាយទៅជារឿងមួយផ្សេង។ យុវតីទាំងឡាយ ត្រូវតែមានការងារ ធ្វើការនៅទីកន្លែងទាំងឡាយ ដែលគ្មាននរណាជំទាស់ ហើយជាការល្អ គឺធ្វើការជាមួយ យុវតីឯទៀត។ ដើម្បីកុំឱ្យឪពុក-ម្តាយជំទាស់កើត។ ខ្ញុំ តែងបានសោកស្តាយជានិច្ច ដោយហេតុថា ខ្ញុំបានកើតមកជាស្រី។ មានពេលខ្លះ កាលណា គេមិនអនុញ្ញាតឱ្យខ្ញុំធ្វើអ្វីមួយ ខ្ញុំតែងរត់ចូលទៅក្នុងបន្ទប់ ស្រែកយំ ហើយបន់ព្រះឱ្យជួយធ្វើឱ្យខ្ញុំក្លាយទៅជាមនុស្សប្រុស"។*

គំរោងសម្រាប់ក្មេងស្រី (the girl child project) នៅក្នុងប្រទេសទាំងឡាយបែបនេះ កំពុងតែផ្លាស់ប្តូរសន្សឹម១ នូវបាតុភូតទាំងអស់នេះ ដោយការអភិវឌ្ឍន៍ក្រុមស្នូលយុវតី ឱ្យដើរតួជា កតាលិករ (catalysts) ក្នុងការបំផុសស្មារតីភ្ញាក់រឭកក្នុងស្រុក អំពីបញ្ហាទាំងឡាយរបស់យុវតី ហើយនឹងអំពីការរើសអើងដែលក្មេងស្រីកំពុងប្រឈមមុខ។

បញ្ហានៃការអប់រំ កើតមានឡើងស្ទើរតែជានិច្ចកាល។ យុវតីជាច្រើនអ្នកបានប្រយុទ្ធទាមទារសិទ្ធិសម្រាប់ការអប់រំរបស់ខ្លួន។ យុវតីខ្លះ បានទទួលជំនួយក្នុងការប្រយុទ្ធនេះ ដោយម្តាយរបស់ខ្លួនដែលមិនបានរៀនសូត្រសោះ ដែលបានជឿថាជីវភាពផ្ទាល់ខ្លួនរបស់ពួកគេ នឹងមានស្ថានភាពប្រសើរ ប្រសិនបើពួកគេ បានរៀនសូត្រនៅសាលា។

ក្នុងសង្គមជាច្រើន ទីតាំងរបស់ស្ត្រី គឺនៅផ្ទះ ត្រូវធ្វើការ ហើយត្រូវបំពេញ

ករណីកិច្ចរបស់ខ្លួន ដំបូងបង្អស់ជាប្រពន្ធ និងជាម្តាយ។ គ្មានរឿងបែបនេះ ដូចជា "ការរំដោះរបស់ស្ត្រី"(women's lib) នោះទេ។ សូម្បីនៅក្នុងសង្គមជឿនលឿនខ្លះ ស្ត្រីទាំងឡាយត្រូវបានគេបណ្តុះបង្ហាប់។ ជាឧទាហរណ៍ នៅក្នុងទីសាធារណៈនានា ស្ត្រីទាំងឡាយត្រូវបានគេតម្រូវ មិនត្រឹមតែឱ្យអង្គុយដោយឡែកពីពួកបុរសប៉ុណ្ណោះទេ ប៉ុន្តែ តម្រូវឱ្យអង្គុយកំបាំងពីមុខរបស់ពួកគេថែមទៀត គឺឱ្យអង្គុយពីក្រោយខ្នងពួកគេ។ កាលណា ស្ត្រីទាំងឡាយត្រូវបានអង្គុយខាងក្រោយនៃបន្ទប់ឬសាល. ប្រការនេះគឺជាការចង្អុល ប្រាប់យ៉ាងប៊ិនប្រសប់ថា តួនាទីដែលត្រូវរំពឹងទុករបស់ស្ត្រីគឺនៅខាងក្រោយ ហើយ មិនមែនជាមួយនឹងតួនាទីរបស់បុរសទេ។

មនុស្សខ្លះជឿថា មនុស្សស្រី ច្រើនទោរទន់ទៅរកផ្លូវអាក្រក់។ ដោយហេតុនេះ ជាការល្អ ត្រូវតែឱ្យមនុស្សស្រី ធ្វើការងារផ្ទះឱ្យច្រើន ដើម្បីឱ្យមនុស្សស្រីភ្លេច ឥរិយាបថអាក្រក់ជាធម្មជាតិរបស់ខ្លួន។ (នៅមានត)

<u>*ក្រោកឡើង កាលណាយើងបរាជ័យ*</u>

***ជោគជ័យធំបំផុតរបស់យើង មិននៅត្រង់យើង***
***មិនដែលបរាជ័យសោះនោះទេ . ប៉ុន្តែនៅត្រង់យើង***
***ក្រោកឡើង រាល់ពេលដែលយើងបរាជ័យ "។***

**ខុង ហ្វូយ ស៊ីស**

# ប្រវត្តិរបស់អដ្ឋកថា

ដោយៈ ទ៊ាន់ ចាន់សារ៉េន

គម្ពីរក្នុងព្រះពុទ្ធសាសនាមាន ១០ ប្រភេទគឺ ១.ព្រះត្រៃបិដក ២.អដ្ឋកថា ៣. បករណវិសេស ៤. ដីកា ៥.មូលដីកា ៦. អនុដីកា ៧. គន្ថន្តរៈ ៨. គណ្ឋិ ៩. យោជនា ១០. សទ្ទាវិសេស ។

បណ្តាគម្ពីរទាំង ១០ ប្រភេទនេះ អដ្ឋកថាជាគម្ពីរលំដាប់ថ្នាក់ទី២ ដែលមានសារៈសំខាន់បំផុតក្នុងការសិក្សាគម្ពីរព្រះត្រៃបិដក។ ចំពោះការសិក្សាព្រះត្រៃ-បិដក បើមិនមានគម្ពីរអដ្ឋកថានោះទេ អ្នកសិក្សាមិនអាចយល់អត្ថ និងព្យញ្ជនៈបានជ្រាលជ្រៅឡើយ ព្រោះអដ្ឋកថាជាគម្ពីរពន្យល់ពង្រីកសេចក្តីក្នុងព្រះត្រៃបិដក ទាំងព្យញ្ជនៈទាំងអត្ថ ឱ្យអ្នកសិក្សាយល់ក្នុងព្រះត្រៃបិដកយ៉ាងទូលំទូលាយ ។ ពាក្យថា អដ្ឋកថា នេះមកពីពាក្យថា អត្ថ = សេចក្តី កថា = ពោល. វាចាជាគ្រឿងពោលពង្រីក , បូកបញ្ចូលគ្នាទាំងពីរពាក្យទៅជា អត្ថកថា , ផ្លាស់ អត្ថ ទៅជា អដ្ឋ មាន រូបជា អដ្ឋកថា មានសេចក្តីថា **វាចាជាគ្រឿងពោលពង្រីកសេចក្តីក្នុងព្រះត្រៃបិដក** ។ ដូចពាក្យក្នុងសារត្ថទីបនីដីកា ១/២៥[1] ថា ÷

**អត្ថោ កថិយតិ ឯតាយាតិ អត្ថកថា , សាយេវ អដ្ឋកថា ត្ថ-ការស្ស ដ្ឋ-ការំ កត្វា** ។ សេចក្តីតែងពោលដោយគម្ពីរនេះ ព្រោះហេតុនោះ គម្ពីរនោះ

---

១-អានថា សារត្ថទីបនីដីកា ភាគ ឬក្បាលទី១ ទំព័រ២៥។ (សូមអានដូចៗគ្នានៅពេលមានសញ្ញានេះ)

ឈ្មោះថា អត្ថកថា , ក៏ពាក្យថា អដ្ឋកថា នោះឯង លោកធ្វើការផ្លាស់ ត្ថ-អក្សរ ទៅជា ដ្ឋ-អក្សរ ( ទើបមានរូបជា អដ្ឋកថា )ៗ

ខ្ញុំនឹងពោលនូវប្រវត្តិរបស់អដ្ឋកថាទាំងនោះ ជូនអ្នកអានទាំងឡាយដើម្បីជាប្រយោជន៏ដល់ការស្វែងយល់ និងស្រាវជ្រាវនូវគម្ពីរលំដាប់ជាន់ទី២ ដូចតទៅនេះ ÷

អដ្ឋកថានោះចែកជាពីរប្រភេទគឺ :

**១-ពុទ្ធសំវណ្ណិតអដ្ឋកថា** គឺអដ្ឋកថាដែលព្រះពុទ្ធអង្គទ្រង់សំដែងដោយព្រះអង្គឯង និយមហៅ អដ្ឋកថាប្រភេទនេះថា **បកិណ្ណកទេសនា** តមកខាងក្រោយ ព្រះសង្ឃសាវ័កទើបបានកាន់យកជាកថាមគ្គ គឺក្នុងការអធិប្បាយត១គ្នាមកមានការសង្គាយនាជាដើម ។

ដូចបាលីជាគ្រឿងអាងក្នុងដីកាថា ÷

**យទិបិ តត្ថ ភគវតា បវត្តិតា បកិណ្ណកទេសនា អដ្ឋកថា**[២] ។

អដ្ឋកថាជាបកិណ្ណកទេសនា ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងក្នុងទីនោះ ៗ ( ក្នុងក្រុងនោះ ស្រុកនោះ ) ។

**២-អនុពុទ្ធសំវណ្ណិតអដ្ឋកថា** ឬ **សាវកសំវណ្ណិតអដ្ឋកថា** គឺអដ្ឋកថាដែលព្រះសាវ័កទាំងឡាយ មានអគ្គសាវ័កជាដើម ជាអ្នកត្រាស់ដឹងតាមរហូតបាននាមថា "**អនុពុទ្ធ**" អធិប្បាយទុក ។

---

២-សារត្ថទីបនីដីកា ២/៤៥ សីលក្ខន្ធវគ្គដីកា ឈ្មោះ លីនត្ថប្បកាសិនី ១/១៨

អដ្ឋកថានុំះបែងចែកតាមកាលសម័យមានពីរប្រភេទគឺ ÷

-**បោរាណអដ្ឋកថា** អដ្ឋកថាចាស់

-**អភិនវអដ្ឋកថា** អដ្ឋកថាថ្មី ។

**១-បោរាណអដ្ឋកថា**

**ក**-សំដៅដល់ពុទ្ធសំវណ្ណិតអដ្ឋកថា ដែលព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់បានត្រាស់សំដែង ដោយព្រះអង្គឯង ដូចមានមកជាច្រើនក្នុងសុត្តន្តបិដក ដែលព្រះអង្គទ្រង់សម្តែងហើយពង្រីកសេចក្តីដោយខ្លួនព្រះអង្គឯង នេះហៅថា **ពុទ្ធសំវណ្ណិត-អដ្ឋកថា** ។ ខាងក្រោយមកព្រះថេរៈទាំងឡាយ មានព្រះកច្ចាយនៈ ព្រះឧបាលិជាដើមជាអ្នកយល់ពុទ្ធបំណង ក៏ពោលសេចក្តីនោះពង្រីកបន្ថែម ឱ្យជាការងាយយល់ដល់កុលបុត្រទាំងឡាយ មានបទភាជនីយ៍ក្នុងវិនយបិដកជាដើមឈ្មោះថា **អនុពុទ្ធ-សំវណ្ណិតអដ្ឋកថា** ។ ដូចនៅក្នុងវិនយសង្គហដ្ឋកថា ទំព័រ២ បានពោលទុកថា: **ភគវតោ ហិ អធិប្បាយំ ញត្វា ឧបាលិត្ថេរាទីហិ អដ្ឋកថា ឋបិតា ។** មែនពិតព្រះថេរៈទាំងឡាយមានព្រះឧបាលិត្ថេរជាដើម ជាអ្នកដឹងនូវសេចក្តីអធិ-ប្បាយរបស់ព្រះដ៏មានព្រះភាគបានតម្កល់នូវអដ្ឋកថាទុកហើយ ។ ចំពោះអដ្ឋកថានៅក្នុងគម្ពីរបានពោលថាបានលើកឡើងកាន់សង្គាយនាទី១ពេលដែលព្រះមហាកស្សបៈជាប្រធាន បានចងក្រងនូវគម្ពីរព្រះត្រៃបិដកឱ្យមានបែបផែន តាមលំដាប់លំដោយមានផ្នែកខាង ព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្មនោះក៏មានការចងក្រងនូវអដ្ឋកថានោះដែរ ។ អដ្ឋកថានោះហៅថា **មហាអដ្ឋកថា** ។ មហាអដ្ឋកថានោះ ជាអដ្ឋកថាដែលអធិប្បាយដោយភាសាមគធៈដែលព្រះសង្គីតិកាចារ្យ ធ្វើការសង្គាយនាមកដល់បីដង (គឺទី១ កាលព្រះសម្មាសម្ពុទ្ធរំលត់ខន្ធចូលនិព្វានបានបីខែ ព្រះបាទអជាសត្តុ ជាអ្នក

ឧបត្ថម្ភ ។ ទី២ កាល ព.ស. ១០០ ព្រះបាទកាលាសោករាជ ជាអ្នកឧបត្ថម្ភ ។ ទី៣ កាល ព.ស. ២៣៤ ( កន្លែងខ្លះថា ព.ស. ២១៨ ខ្លះថា ២៨៧ ) ព្រះបាទអសោកមហារាជ ជាអ្នកឧបត្ថម្ភ) ។

ក្រោយមក ព្រះមហាមហិន្ទត្ថេរៈ ជាឱរសព្រះបាទអសោក មហារាជ បាននាំអដ្ឋកថាដូចពោលមកហើយអំពីជម្ពូទ្វីប មកផ្សព្វផ្សាយត្រង់កោះសីហឡៈ ឬប្រទេសស្រីលង្កា។ តមកខាងក្រោយព្រះមហាថេរៈ ជនជាតិសីហឡៈបានប្រែអដ្ឋកថា នោះពីភាសាមគធៈ[៣] ទៅភាសាសីហឡៈ ដើម្បីជៀសវាងការបន្លំពីលទ្ធិនិកាយដទៃ ( សារត្ថទីបនីដីកា ១/២៤) ។

តាមគម្ពីរក្នុងពង្សាវតារស្រីលង្កា[៤] បានបញ្ជាក់ថា : នៅក្នុងប្រទេសស្រីលង្កាបានធ្វើសង្គាយនាលើកទី៤ គឺ ព.ស. ៤៣២ ព្រះថេរៈទាំងឡាយ ខ្លាចក្រែងព្រះពុទ្ធវចនៈ មានការបាត់បង់ទៅ ទើបបានរៀបចំសង្គាយនាលើកទី៤ ឡើង ដោយចារគម្ពីរព្រះត្រៃបិដក ជាភាសាមគធៈ ហើយចារគម្ពីរអដ្ឋកថា ជាភាសាសីហឡៈ។ ខាងក្រោយមក ព្រះថេរៈក្នុងកោះសីហឡៈ ឃើញការលំបាកដល់កុលបុត្រសីហឡៈទើបបានរចនានូវអដ្ឋកថា មហាបច្ចរី និងអដ្ឋកថា កុរុន្ទីឡើង ដើម្បីជាប្រយោជន៍ដល់កុលបុត្រសីហឡៈទាំងឡាយ។ លុះ ព.ស.៩៥៦ មានព្រះថេរៈមួយអង្គព្រះនាម **"ពុទ្ធឃោសាចារ្យ"** បាននិមន្តមកពីជម្ពូទ្វីប គឺប្រទេសឥណ្ឌាមកប្រែ មហាអដ្ឋកថាដែលនៅ ជាភាសាសីហឡៈឱ្យទៅជាភាសាមគធៈវិញ ដោយអដ្ឋកថាទាំងនេះមិនមែនជាការរចនាដោយអត្តនោម័តិរបស់ព្រះពុទ្ធឃោសាឡើយ ។ គ្រាន់តែព្រះពុទ្ធ

៣-ភាសាបាលី

៤-មហាវង្ស ១/២៣៥. សង្គីតិយវង្ស-៩១

ឃោសាចារ្យ ប្រែមកនិងលើករឿងសាធកៈខ្លះៗដែលកើតមានមុន និងក្នុងជំនាន់លោកប៉ុណ្ណោះ។ ដូចព្រះពុទ្ធឃោសាពោលទុកនៅក្នុងនិគមនកថារបស់លោក ក្នុងអដ្ឋកថា ដែលលោក រចនាមុនគេបង្អស់គឺ អដ្ឋកថា សមន្តបា្បសាទិកាថា÷

កាមញ្ច បុព្វាចរិយាសភេហិ
ញាណម្ពុនិទ្ធោតមលាសវេហិ
វិសុទ្ធិវិជ្ជាបដិសម្ភិទាហិ
សទ្ធម្មសំវណ្ណនកោវិទេហិ
សល្លេខិយេ នោសុលភូបមេហិ
មហាវិហារស្ស ធជូបមេហិ
សំវណ្ណិតោយំ វិនយោ នយេហិ
ចិត្តេហិ សម្ពុទ្ធវរន្វយេហិ ។
សំវណ្ណនា សីហឡទីបកេន
វាក្យេន ឯសា បន សង្ខតត្តា
ន កិញ្ចិ អត្ថំ អភិសម្ភុណាតិ
ទីបន្តរេ ភិក្ខុជនស្ស យស្មា
តស្មា ឥមំ បាលិនយានុរូបំ
សំវណ្ណនំ ទានិ សមារភិស្សំ
អជ្ឈេសនំ ពុទ្ធសិរិវ្ហយស្ស
ថេរស្ស សម្មា សមនុស្សរន្តោ ។
សំវណ្ណនំ តញ្ច សមារភន្តោ

តស្មា មហាអដ្ឋកថំ សរីរំ
កត្វា មហាបច្ចរិយំ តថេវ
កុរុន្ទិនាមាទីសុ វិស្សុតាសុ
វិនិច្ឆយោ អដ្ឋកថាសុ វុត្តោ
យោ យុត្តមត្ថំ អបរិច្ចជន្តោ
តតោបិ អន្តោគធថេរវាទំ
សំវណ្ណនំ សម្ម សមារភិស្សំ ។

បុព្វាចារ្យអ្នកអង់អាចទាំងឡាយ មានមន្ទិល និងអាសវៈដែលជម្រះហើយដោយទឹកគឺញាណជាអ្នកបរិសុទ្ធិដោយវិជ្ជា និងបដិសម្ភិទាទាំងឡាយឈ្លាសក្នុងការពណ៌នាព្រះសទ្ធម្ម មិនមានអ្នកណាប្រៀបបាន ក្នុងភាពជាអ្នកដុះខាត់បានឡើយ ប្រៀបដូចទង់នៃមហាវិហារ បានពណ៌នានូវវិន័យនេះ ដោយន័យដ៏វិចិត្រ ស្របតាមព្រះពុទ្ធដ៏ប្រសើរ ក៏ពិតមែន ក៏ប៉ុន្តែការពណ៌នានុ៎ះ មិនសម្រេច ប្រយោជន៍អ្វីដល់ជន គឺភិក្ខុអ្នកនៅក្នុងកោះដទៃ ព្រោះការពណ៌នានោះលោកពោល ដោយភាសាអ្នកកោះសីហឡៈ ព្រោះហេតុនោះ ឥឡូវនេះកាលខ្ញុំរឭកដល់ការអារាធនារបស់ព្រះថេរៈឈ្មោះពុទ្ធសិរីដោយប្រពៃ នឹងផ្តើមដោយល្អ នូវការពណ៌នាដ៏ សមគួរតាមបាលីនេះ ។ ក៏លោកអាចារ្យបានពោលនូវសេចក្តីឯណា ក្នុងមហាបច្ចរី និងក្នុងអដ្ឋកថាទាំងឡាយមានអដ្ឋកថាឈ្មោះកុរុន្ទីជាដើម ដែលប្រាកដច្បាស់ដូច្នោះ កាលខ្ញុំផ្តើមការពណ៌នានោះ នឹងធ្វើ មហាអដ្ឋកថា ឱ្យជាគោលធំនៃការពណ៌នានោះ មិនលះបង់សេចក្តីដ៏សមគួរ នឹងធ្វើថេរវាទឱ្យប្រព្រឹត្តទៅខាងក្នុងអំពីការវិនិច្ឆ័យ នោះហើយនឹងផ្តើមដោយប្រពៃនៃការពណ៌នា។ (នៅមានត)

# ព្រះពុទ្ធសាសនាជាឫសគល់មួយនៃវប្បធម៌ខ្មែរ

ដោយ អ្នកស្រីបណ្ឌិត **ខ្លូត ធីតា**

## សេចក្តីផ្តើម៖

គេបានដឹងច្រើនណាស់ថា ព្រះពុទ្ធសាសនាបានផ្តល់វិភាគទានយ៉ាងច្រើនដល់ប្រទេសកម្ពុជា។ ព្រោះព្រះពុទ្ធសាសនាបានស្ថិតស្ថេរយូរលង់ណាស់មកហើយ ហើយក្លាយជាវប្បធម៌ចំណាស់ផងដែរ។ ទាំងព្រះពុទ្ធសាសនា ទាំងមនុស្ស ដែលគោរពព្រះពុទ្ធសាសនា ទាំងសមិទ្ធផលដែលកសាងឡើងបែបបទស្មារតី (spirit) ព្រះពុទ្ធសាសនាក៏មានច្រើនណាស់។ ប្រសិនបើយោលទៅតាមស្ថាប័នទាំងឡាយនៅកម្ពុជាតាំងពីអតីតរហូតដល់បច្ចុប្បន្ន គឺសុទ្ធតែបានផ្សារភ្ជាប់ជាមួយទស្សនៈព្រះពុទ្ធសាសនា។ នេះមិនមែនជាបញ្ហាបន្ទាប់បន្សំនៃការគិតពីបញ្ហានេះទេ គឺវាមានការប្រកួតប្រជែងផ្នែកបញ្ញត្តិកម្មមួយនៅក្នុងកម្រិតខ្លាំង។ ចំពោះបញ្ហាស្តីពីមូលភាពនៃចិត្តសាស្ត្រស្តីពីគំនិត និងវប្បធម៌ ពិតជាមិនងាយដោះស្រាយទេ ស្មុគ្រស្មាញណាស់។ " គំនិតស្មុគ្រស្មាញនេះ មិនត្រឹមតែសម្រាប់អ្នកទស្សនវិជ្ជាម្នាក់ទេ ទាមទារការគិតពីចិត្តវិទូ និងទស្សនវិទូផងដែរ ដែលត្រូវគិតពីវប្បធម៌ក្នុងគំនិត [១] "។ ព្រះពុទ្ធសាសនាប្រហែលជាមិនគ្រាន់តែទុកដាក់ខ្លួនឯងជាវប្បធម៌ខ្មែរទេ ថែមទាំងទុកដាក់មនុស្សខ្មែរ និងសម្ភារៈដែលខ្មែរសាងជាវប្បធម៌បែបព្រះពុទ្ធសាសនា ទៀតផង។ ព្រោះអ្វី ?

---

១-BRADD Shove Culture in mind ,New York Oxford 1995 p.5

## ទំនាក់ទំនងវប្បធម៌ និងការគិតរបស់មនុស្ស :

វប្បធម៌ គឺជាស័ព្ទដែលបានប្រើដោយអ្នកវិទ្យាសាស្ត្រសង្គមសម្រាប់ មធ្យោបាយជីវិតទាំងមូលរបស់មនុស្ស។ នៅក្នុងកិច្ចសន្ទនាប្រចាំថ្ងៃ ពាក្យវប្បធម៌ អាចសំដៅចំពោះសកម្មភាពនានាក្នុងវិស័យទាំងឡាយ ដូចជាសិល្បៈ អក្សរសាស្ត្រ និង តន្ត្រី។ ប៉ុន្តែចំពោះអ្នកវិទ្យាសាស្ត្រ សង្គមវប្បធម៌របស់មនុស្សមានគំនិត ស្មារតី កម្មវត្ថុ និងមធ្យោបាយនានានៃការធ្វើអ្វីៗដែលបានបង្កើតឡើងដោយក្រុម។ វប្បធម៌ រួមមាន សិល្បៈ ជំនឿ ទំនៀមទម្លាប់ ការច្នៃប្រឌិតភាសា បច្ចេកទេស និង ប្រពៃណី។ ស័ព្ទអរិយធម៌មានលក្ខណៈប្រហាក់ប្រហែលគ្នា ប៉ុន្តែវាស្ទើរតែសំដៅចំពោះមធ្យោបាយជីវិតដែលបានធ្វើឱ្យចម្រើនខាងវិទ្យាសាស្ត្រច្រើនជាង។ វប្បធម៌ គឺជាមធ្យោបាយ ជីវិតណាមួយដែលសាមញ្ញ ឬស្មុគ្រស្មាញ។ វប្បធម៌ មានមធ្យោបាយដែលបាន សិក្សានៃទង្វើអារម្មណ៍ និងការគិតពិចារណាជាងមធ្យោបាយ ដែលបានកំណត់បែបជីវវិទ្យា។ សត្វសាមញ្ញមួយចំនួន តាមសភាវគតិដែលបានកាន់នៅក្នុងក្រុមរបស់វា។ ប៉ុន្តែមនុស្សអាចធ្វើពិសោធសិក្សា និងរកមធ្យោបាយដោះស្រាយ ដោយធ្វើឱ្យរបស់ទាំងនេះមានដំណើរមិនចេះចប់។ លោក Sigmund Freud បានធ្វើការប្រៀបធៀប ទៅនឹងឧបករណ៍នានា ដូចជាអវយវៈនិម្មិត វ៉ែនតាកែវ និងធ្មេញនិម្មិត ឧបករណ៍ទាំង នេះជាវប្បធម៌ធ្វើឱ្យមនុស្សអាចធ្វើអ្វីៗនូវកម្លាំង និងឥន្ទ្រីយ៍នានាដោយខ្លួនឯង និង មិនអនុញ្ញាតឱ្យពួកសត្វធ្វើបានទេ។ ឧទាហរណ៍ៈ មនុស្សមិនត្រូវការចង្កូម ប្រសិនបើ គេមានព្រួញពួកគេមិនចាំបាច់រត់លឿន ប្រសិនបើគេជ្យាំងសេះ។ បើគ្មានវប្បធម៌ អាកាសយានិកមិនអាចទៅដល់ឋានព្រះចន្ទ ឬរស់នៅទីនោះបានឡើយ។

រាងកាយមនុស្សត្រូវការ អុកស៊ីសែន និងសីតុណ្ហភាពត្រឹមត្រូវ ដើម្បីរស់នៅ[២] ។

មធ្យោបាយនៃការគិតត្រូវបានចងភ្ជាប់យ៉ាងជិតស្និទ្ធជាមួយបញ្ញត្តិនៃការវិវត្តន៍ដែលនៅក្នុងចំណងបញ្ញត្តិនៃការវិវត្តន៍នេះ មិនគ្រាន់តែមានគំរូខុសៗគ្នា (រូបមន្ត) នៅក្នុងវប្បធម៌មួយៗសម្រាប់ការគិតទេ ក៏ប៉ុន្តែគំរូនៃការគិតនេះវាក៏បានស្តែងឡើងឱ្យឃើញពីភាពខុសគ្នានៃការគិតទៅតាមដំណាក់កាលផ្សេងៗដែរ ។ ដោយយោងទៅតាមអំណះអំណាងស្តីពីការវិវត្តន៍ក្នុងទ្រឹស្តីរបស់លោកដាកវិន (Darwin) បានអះអាងថា : មនុស្សបានវិវត្តមកជាសត្វដែលមានជីវិតស្ថិតក្នុងទម្រង់ថ្នាក់ទាបដូចនេះ សង្គមមនុស្សក៏បានអភិវឌ្ឍពីទម្រង់សង្គមសត្វមានជីវិតថ្នាក់ទាបឈានទៅរកកម្រិតខ្ពស់ដែរ។ សង្គមដែលមានទម្រង់ថ្នាក់ខ្ពស់ គឺជាសង្គមដែលស្តែងឡើងនូវពុទ្ធិ សីលធម៌ ច្បាប់ ...។

នរវិទូសម័យថ្មី បានពន្យល់បង្ហាញពីវប្បធម៌ ដូចជាស្ថាប័នមួយ ដែលមានទំនៀមទម្លាប់ប្រពៃណីជំនឿសាសនា ហើយនិងស្ថាប័នសង្គមផ្សេងៗ ដែលតាមរយៈវប្បធម៌នេះបានញែកលក្ខណៈខុសៗគ្នានៃក្រុមមនុស្ស និងការគិត ។

កាលដើមឡើយ នៅពេលដែលមនុស្សស្ថិតក្នុងអន្តរកាលនៃទម្រង់មនុស្សសត្វ ពុទ្ធិមនុស្សមិនទាន់មានលក្ខណៈជ្រៅជ្រះនៅឡើយទេ។ ពេលគេឮសូរផ្គរ រន្ទះផ្លេកបន្ទោរ ភ្លៀង ទឹកជំនន់ ពន្លឺថ្ងៃ និងយប់ ... មនុស្សតែងតែឆ្ងល់ តែចម្ងល់នោះមិនអាចដោះស្រាយបានដោយពួកគេមានកង្វះពុទ្ធិ។ កង្វះពុទ្ធិនេះ ធ្វើឱ្យគេមានអារម្មណ៍ស្រមើស្រម៉ៃថាមានអ្វីមួយនៅក្នុងធម្មជាតិ ដែលមានឥទ្ធិពលជាងខ្លួនថាជា

---

២- World Book p.490

បុព្វបុរសរបស់ខ្លួនគេ និងជាអ្នកបង្កើតខ្លួនគេមក ដូចនេះការគិតរបស់មនុស្សបាន ធ្វើរូបារម្មណ៍ទៅរកអធិធម្មជាតិ។ ចាប់តាំងពីពេលនោះមក សញ្ញាណនៃជំនឿក៏ចាប់ ផ្ដើមកើតមានឡើង ហើយបានវិវត្តរហូតដល់គេជឿថា ព្រលឹងរបស់មនុស្សស្លាប់ទៅ មិនសាបសូន្យ ពិតជារស់នៅក្នុងពិភពអមនុស្ស ដែលអាចនឹងទៅចាប់ជាតិ សារជាថ្មី ឬមិនទៅចាប់ជាតិ តែនៅតាមថែរក្សាញាតិសន្ដានសាច់សារលោហិតរបស់គេ ឬ ជូន កាលធ្វើទុក្ខបុកម្នេញដល់កូនចៅដែលនៅរស់ទៀតផង ឧទាហរណ៍ដូចជា អ្នកតា លោកយាយ ម្ដាយដើម មេបា ចាស់ទុំ ម្រេញគង្វាល ... សុទ្ធតែតំណាងឱ្យព្រលឹង (អមនុស្ស) ដែលនៅតាមជួយថែរក្សា ឬធ្វើទុក្ខបុកម្នេញដល់មនុស្ស។ ចាប់តាំង ពី៥០០ឆ្នាំមុនគ្រិស្ដសករាជ ពុទ្ធិរបស់មនុស្សមានការវិវត្តន៍យ៉ាងខ្លាំង បដិវត្តន៍នៃការ គិតរបស់មនុស្សនៅតំបន់អាស៊ីផ្ដួចផ្ដើមឡើងដោយព្រះសមណគោតម ខុងជឺ ឡៅស៊ី .តម្រង់ការពិចារណាមកសិក្សាពីមនុស្សពិតៗដោយលែងស្រមើស្រមៃពីអធិធម្មជាតិ ពីពិភពអមនុស្សទៀតហើយ។ ការគិតរបស់ទស្សនវិទូធំៗ ចាប់តាំងពីពេលនោះមក គេសិក្សាពីមនុស្ស សិក្សាពីធម្មជាតិ ដោយយកលោកធាតុ (Cosmo) មកធ្វើជា ទន្និករណ៍មាន: ទឹក ដី ភ្លើង ខ្យល់ជាដើម។ នៅអឺរ៉ុប ទស្សនវិជ្ជាក្រិច ក៏ដូចជាច្បាប់ របស់រ៉ូម៉ាំង ខានបំផុសនូវគំនិតទស្សនវិជ្ជាថ្មីៗ មានទស្សនវិទូខ្លះខិតខំពន្យល់លើក តម្កើងអធិធម្មជាតិ ចងក្រងជាទ្រឹស្ដីទៅជាសាសនាពិតៗ ដោយផ្អែកលើមនោនិយម ដាច់ខាតដូចជា ប្លាតុង (Platon)។ ប្លាតុងខានយល់ថា មនុស្សគឺជាសមិទ្ធផលរបស់ ព្រះអាទិទេព ជាអ្នកបង្កើតស្មារតីនៃការគិតរបស់មនុស្ស អាទិទេពជាអ្នកកំណត់... ដូចនេះអ្វីៗជារបស់អាទិទេព តែចំពោះ អារីស្តូត លោកខិតខំពន្យល់ពីតថភាពនៃ មនុស្សដោយបម្រុងបដិសេធអាទិទេព តែក្រោយមកលោកស្ទាក់ស្ទើរអល់ឯកមិន

ហ៊ានបដិសេធដាច់ណាត់ថាមានអាទិទេពទេ។ លោកជាទ្វិកនិយមទស្សនវិទូ ពេលដែល (Platon) ជឿថា មនុស្សស្លាប់ទៅ រាងកាយស្លាប់មែន តែព្រលឹងមិនស្លាប់ទេ អារីស្តូតអះអាងថាពេលដែលរាងកាយស្លាប់ព្រលឹងក៏ស្លាប់ដែរនេះបញ្ជាក់ថាការគិត របស់ទស្សនវិទូរូបនេះងាកចេញពីអធិធម្មជាតិមកពន្យល់ពីពិភពធម្មជាតិ និងមនុស្ស ដោយផ្អែកលើលោកធាតុដែរ។ ទស្សនវិទូទាំងអស់នៅសម័យនោះបែរឆ្ពោះមក សិក្សាពីគុណធម៌ សីលធម៌ និងច្បាប់ (ក្រិត្យក្រមធម្មជាតិ ក្រិត្យក្រមសង្គម ក្រិត្យក្រមគំនិត) ដែលមាននៅក្នុងតួខ្លួនមនុស្សពិតៗ ។

ដូចនេះយើងឃើញថានៅយុគកូស្មូ (Cosmo era) ផ្ចិតគំនិតរបស់មនុស្សងាកពីជំនឿ លើអធិធម្មជាតិងាកមករកមនោគមវិជ្ជា Cosmo មួយដែលមានសណ្ឋាន ជាសាសនា ជាលទ្ធិ។ **Aristotle** លោកជាទ្វិកទស្សនវិទូ ដោយលោក អល់ឯកថា មានកម្លាំងអ្វីមួយកំណត់ស្មារតី និងការគិតរបស់មនុស្ស ធ្វើឱ្យសាវ័ករបស់លោកបកស្រាយចំណុចខ្សោយនេះហើយបានជំរុញឱ្យសន្ទុះសាសនា (គ្រិស្តសាសនា) មានដង្ហើមរស់ឡើងវិញ ហើយមានឥទ្ធិពលខ្លាំងក្លានៅមជ្ឈិមសម័យទៀតផង។ **St. Thomas Aquinas, St.Thomas d'Aquin** បានបង្វែរការ គិតរបស់មនុស្សងាកចាកពីបញ្ហាលោកធាតុ ដោយពឹងផ្អែកទៅលើ (**God**) ហើយខិតខំពន្យល់ និងបង្ហាញតែពីឥទ្ធិពលអំណាច និងសមិទ្ធផលរបស់ព្រះដោយភ្លេចនូវអ្វីៗដែលជាស្នាដៃរបស់ មនុស្សពិតៗទៅវិញ។

សតវត្សទី១៦ ក្រោយបដិវត្តរបស់ **Copernic, Neqton, Bruno** កំណើតវិទ្យាសាស្ត្របានចាប់បដិសន្ធិ និងមានរូបរាងច្បាស់លាស់ ជនជាតិអឺរ៉ុប បានពង្រីកវិសាលភាពនៃវប្បធម៌ ហើយសរបញ្ជាក់ឱ្យឃើញថាពួកគេមានពុទ្ធិ វិទ្យា

សាស្ត្រ។ ពុទ្ធិវិទ្យាសាស្ត្រឈានមកជំនួសពុទ្ធិសិល្ប៍សាស្ត្របន្តិចម្តងៗ តែមិនអាចលុបបំបាត់សាសនាទាំងស្រុងបានទេ ព្រោះពុទ្ធិវិទ្យាសាស្ត្រនោះ នៅមានផ្នែកខ្លះ មិនទាន់មានលទ្ធភាពពន្យល់បង្ហាញការពិតត្រង់ៗ ដែលសិល្ប៍សាស្ត្របានបង្ហាញនៅឡើយ។

ឧទាហរណ៍-សិល្ប៍សាស្ត្រយល់ថា " ខ្មោចចូលក្នុងខ្លួនមនុស្ស " ការរុករកវិទ្យាសាស្ត្រ ស្រាយបំភ្លឺពីខ្មោចនៅក្នុងខ្លួនមនុស្សគ្មានអ្វីក្រៅពីជម្ងឺខួរក្បាលឡើយ។ ប៉ុន្តែវិទ្យាសាស្ត្រនៅមិនទាន់មានហេតុផលពន្យល់ពីបញ្ហាប៉ាវកុង អន្ទងព្រលឹងខ្មោចងាប់ហើយឱ្យមកចូលរូបអ្នកបញ្ជាន់ខ្មោចឱ្យជួបបងប្អូននៅឡើយ។ ហេតុនេះធ្វើឱ្យនៅ អល់ឯកថា តើពិភពមនុស្ស និងពិភពអមនុស្សទាក់ទងគ្នាមែនឬទេ ?

ព្រះត្រៃបិដកជាបាលីពុទ្ធមាមកជនខ្មែរ មិនអាចក្រេបជញ្ជក់រសជាតិធម៌បានសព្វគ្រប់ទេ។ សេចក្តីមានខ្លះៗដោយអន្លើមិនចប់ចុងចប់ដើម ហេតុនេះហើយបានជាពុទ្ធសាសនបណ្ឌិត្យបានបង្កើតគណៈកម្មាធិការព្រះត្រៃបិដក នៅឆ្នាំ១៩២៩ ដោយមានព្រះសង្ឃរាជទាំងពីរគណៈជាប្រធាន និងសមាជិកប្រហែល៤០ប្លាយនាក់ គឺមានសមាជិកជាព្រះសង្ឃ និងឧបាសកទាំងឡាយ ដែលមានវិជ្ជាខ្ពង់ខ្ពស់ផ្នែកពុទ្ធសាសនា និងភាសាបាលី។ ភាគទី១ នៃព្រះត្រៃបិដកបានមានកំណើតជាសៀវភៅជា ២ភាសា គឺបាលីនៅខាងទំព័រឆ្វេង ខ្មែរនៅទំព័រខាងស្តាំបោះពុម្ពនៅឆ្នាំ១៩៣១ ហើយភាគ១១០ ជាភាគចុងក្រោយបានបោះពុម្ពផ្សាយជាដំបូង នៅឆ្នាំ ១៩៦៨ ក្នុងមួយភាគៗ មានជាទូទៅជាង៤០០ទំព័រ។ ការបកប្រែនេះបានប្រើពេលវេលាយ៉ាងច្រើនទើបធ្វើហើយ គឺជាកិច្ចការរួមដ៏លំបាកធំធេងកើតឡើងដោយគណៈកម្មាធិការ ដែលមានសមាជិកជាអ្នកប្រាជ្ញខ្មែរជាង ៤០ប្លាយនាក់បានធ្វើការ ៣៨ ឆ្នាំ។ ព្រះត្រៃបិដកដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយចំនួន ១១០ភាគនោះ គឺមាន ១៣ភាគ

ស្តីពីវិន័យបិដក៦៤ភាគ ស្តីពីសុត្តន្តបិដក និង ៣៣ភាគស្តីពី អភិធម្មបិដក។ គ្រប់វត្តអារាមនានានៅស្រុកខ្មែរ នៅថ្ងៃទី១ និងទី២ ខែមេសា ឆ្នាំ១៩៦៩ បានសម្ពោធ និងធ្វើបុណ្យឆ្លងព្រះត្រៃបិដក[៣]។

អក្សរសាស្ត្រពុទ្ធសាសនា ដែលជនជាតិខ្មែរស្គាល់ច្រើនជាងគេ "ជាតក" ។ ពាក្យ ជាតកនេះមានន័យថាគម្ពីរ ឬរឿងរ៉ាវដែលស្តីអំពីចរិយានៃព្រះពុទ្ធ កាលទ្រង់យាងយកកំណើតក្នុងជាតិមុន។ គម្ពីរជាតក គឺជាគម្ពីរ ឬរឿងដែលសម្តែងបុព្វចរិយា ឬបុព្វចរិតនៃមនុស្ស ឬតិរច្ឆាន ឬក៏ទេព្តា ច្រើនតែជាពោធិសត្វដែលកើត ហើយក្នុងជាតិមុន ឬភពមុនកន្លងទៅហើយ។ រឿងជាតកដកស្រង់ពីព្រះត្រៃបិដក ផ្នែកខាងព្រះសុត្តន្តបិដក ភាសាបាលី។ រឿងជាតកខ្មែរមានទាំងអស់៥៥០ ហើយក្នុងបណ្តាជាតក២ដែលខ្មែរយើងស្គាល់គ្រប់ៗគ្នា គឺមហាវេស្សន្តរជាតក និងមហោសថជាតក។ ក្នុងចំណោមជាតកទាំង២នេះទៀតសោត មហាវេស្សន្តរជាតកមានទំហំប្រជាប្រិយភាពធំធេងពាសពេញស្រុកខ្មែរ។ រឿងជាតកនេះ វិចិត្រកររយកទៅឆ្លាក់នៅលើហោ-ជាង ឬជញ្ជាំងប្រាសាទខ្មែរបុរាណនានាជាពិសេសនៅរចនាបថបាយ័ន និងយកទៅគូរជាព្រះបត់ផ្សេងៗ។ ព្រះសង្ឃតែងទេសនាមហាជាតកគឺៈមហាវេស្សន្តរជាតកនេះឯងនៅពេលបុណ្យទាននានា បានសេចក្តីថាមហាវេស្សន្តរជាតក សឹងតែក្លាយទៅជាអក្សរសាស្ត្រខ្មែរពិតៗ ហើយយើងឃើញថា មហាវេស្សន្តរជាតកខ្មែរ មានភាពខុសប្លែកពីមហាវេស្សន្តរជាតកបាលីច្រើនអន្លើ[៤]។ អត្ថបទពុទ្ធសាសនាមួយទៀត ដែលបានទទួលឥទ្ធិពលពីព្រហ្មញ្ញសាសនា ហើយបានជះឥទ្ធិពលដ៏ខ្លាំងក្លាទៅលើល្បែង នា-

៣-ឃីង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ ប្រទេសបារាំង ១៩៩៧

៤- ឃីង ហុកឌី ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ ប្រទេសបារាំង ១៩៩៧

នា នៅសម័យកណ្ដាល គឺ គម្ពីរ" **ត្រៃភូមិ** " គឺអត្ថបទទាំង៣ អត្ថបទត្រៃភូមិ កើតនៅស្រុកខ្មែរ និងនៅរាជ្យស្ដេចថៃព្រះនាម"**លីតៃ**"ជាស្ដេចចុងក្រោយបង្អស់សោយរាជ្យនៅ **សុខោទ័យ** ។ នៅសម័យកណ្ដាល ពិតមែនតែពុទ្ធសាសនា រីកដុះដាលវាលគុម្ពយ៉ាងណាក៏ដោយ ក៏នៅមានសេសសល់អត្ថបទព្រហ្មញ្ញនិយមខ្លះៗ នៅរស់រានមានជីវិត ហើយបានបន្តដំណើររហូតមកដល់សតវត្សទី២១នេះទៀតគឺមាន **ត្រៃភេទ** ឬ**ត្រៃវេទ ត្រៃយុត** ឬ**ត្រៃយុគ**[៥] ។ អ្នកនិពន្ធ យើងមិនស្គាល់ឈ្មោះអ្នកនិពន្ធទេ នៅក្នុងចង្កោមអត្ថបទ "ច្បាប់ចាស់" ក៏ប៉ុន្តែក្នុង "ច្បាប់ថ្មី "មានបញ្ជាក់ឈ្មោះអ្នកនិពន្ធខ្លះៗដោយបណ្ឌិត **ម៉ែ** ច្បាប់ស្រី ដោយ **ម៉ឺន ម៉ែ** ច្បាប់ស្រី ដោយ **អង្គឌួង** ច្បាប់សុភាសិត និងច្បាប់ **ក្រម ង៉ុយ** សុភាសិត ច្បាប់ស្រីដោយ **សុត្តន្តប្រីជាឥន្ទ**" ។ល។

ទុកណាមិនស្គាល់ឈ្មោះអ្នកនិពន្ធទាំងអស់ក៏ដោយ ក៏យើងឃើញលក្ខណៈរួមត្រង់ករី ដែលបានតែងច្បាប់នានានេះ សុទ្ធតែជាអ្នកបួសរៀនក្នុងសម្នាក់ព្រះពុទ្ធសាសនា។ លក្ខណៈនេះនាំឱ្យយល់ឥទ្ធិពលសាសនាក្នុងច្បាប់ផ្សេងៗ អាស្រ័យហេតុនេះហើយបានជាច្បាប់នីមួយៗ ច្រើនតែអាងលើធមិព្រះពុទ្ធ ឧទាហរណ៍ : ព្រះបាលីពុទ្ធវចនៈ ។ មិនតែប៉ុណ្ណោះ ន័យសេចក្ដីក៏ច្រើនតែទាក់ទងទៅនឹងវប្បធមិខ្មែរ ដែលដុះដាលក្នុងការសិក្សាអប់រំបែបពុទ្ធសាសនាផងដែរ ។

-ព្រះពុទ្ធសាសនា ជាវប្បធមិខ្មែរ

-មនុស្សវប្បធមិ បែបព្រះពុទ្ធសាសនា

---

៥– ឈន អៀម គ្រឹះអប់រំរបស់ព្រះពុទ្ធសាសនា សមាជជាតិស្រាវជ្រាវសង្គម-វប្បធមិ អំពីកម្ពុជា លើកទី៣ ថ្ងៃ១៧ វិច្ឆិកា ២០០០ សាកលវិទ្យា ល័យភូមិន្ទភ្នំពេញ មណ្ឌល-២

-សម្បត្តិវប្បធម៌ បែបព្រះពុទ្ធសាសនា

ជាការពិតណាស់តាំងពីមុន ឬដើមគ្រិស្តសករាជពិតប្រាកដមែន ទាំងតាមគម្ពីរជិកា សាស្ត្រាស្លឹករឹត ប្រាសាទនានា ប៉ុន្តែអ្វីដែលទាំងអស់គ្នាគួរគិត គួរពិចារណា គួរព្រួយ គួរភ្ញាក់ផ្អើលនោះគឺការថែរក្សា ការសម្រិតសម្រាំង ការរួមចំណែកស្ថាបនាឱ្យបានសមនឹងតួនាទីព្រះពុទ្ធសាសនាដែលជាសាសនាជាតិពិតប្រាកដ ។អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនានៅកម្ពុជាបច្ចុប្បន្នមិនសូវសម្បូណ៌ទេ ។ សង្ឃឹមការជះចំហាយពីអ្នកប្រាជ្ញធំៗនៅបរទេសគេមិនអាចស្គាល់ចិត្តខ្មែរជាងខ្មែរទេ បច្ចុប្បន្នមានមនុស្សច្រើនណាស់ច្រើនជ្រកក្រោមព្រះពុទ្ធសាសនាហើយប្រព្រឹត្តផ្ទុយទៅវិញ ។ ព្រះពុទ្ធសាសនាបានទូន្មានថា " *បុគ្គលដើម្បីរំដោះខ្លួនឱ្យរួចផុតពីភាព វង្វេង ភ្លើតភ្លើនទាំងអស់ ប្រសិនបើគេចង់ភ្លក្ស ឬ ពិសោធរសជាតិបរមសុខ ប៉ុន្តែការរំដោះខ្លួននេះសម្រេចបាន តែតាមរយៈសេចក្តីព្យាយាមផ្ទាល់ខ្លួន និងចេញមក ពីខ្លួនឯងផ្ទាល់* " ។

ឥឡូវនេះសេចក្តីត្រូវការកាន់តែរីកធំធេងណាស់គឺៈត្រូវការយល់ដឹងជ្រាលជ្រៅ ប្រកបដោយសីលធម៌ វិន័យ ទាល់តែច្បាស់លាស់ ដើម្បីដំណើរការសំយោគដោះស្រាយឈានចូលរបត់សង្គមទំនើបបាន ។ ការគិតគូរយ៉ាងនេះ មិនមែនមើលស្រាលនូវវប្បធម៌ ប្រពៃណី ជំនឿ សាសនារបស់យើងទេ ។ ការថែរក្សា ខ្វះការអភិវឌ្ឍន៍ត្រឹមត្រូវ គឺបានត្រឹមតែស្ថិតនៅក្នុង សារៈមន្ទីរ ឬក្នុងគម្ពីរក្បួនខ្នាត តែប៉ុណ្ណោះ វាពុំអាចជ្រួតជ្រាប និងទទួលដោយប្រជាសកលលោក ដែលចេះតែវិវត្តបានឡើយ ។ ម្យ៉ាងទៀត ឧត្តមគតិនៃសាសនាទាំងឡាយបាន និងកំពុងពង្រីកឥទ្ធិពលរបស់គេយ៉ាងខ្លាំងក្លា ។ គេសង្កេតឃើញក្នុងជីវភាពរស់នៅគ្រប់ស្រទាប់ជាន់ថ្នាក់ តែងមានការទាក់ទងដ៏ជិតស្និទ្ធជាមួយនឹងឧត្តមគតិសាសនាទាំងឡាយជាដរាប

ដោយខានពុំបាន ព្រោះឧត្តមគតិទាំងឡាយនៃសាសនា តែងមានកំណើតជាមួយសង្គមជានិច្ច ។ ទីណាមានវិទ្យាសាស្ត្រ ពិចារណាល្អិតល្អន់ ទីនោះជំនឿល្អិតល្អង់ ក៏អន់ថយដែរ ។

យើងគួរកត់សម្គាល់ការរីកចម្រើននៃសង្គមសាសនាផងដែរថាៈតាមហេតុការណ៍ប្រវត្តិសាស្ត្រទូទៅនៃសាសនា ពេលខ្លះការរីកចម្រើននៃសង្គម និងសាសនានេះមិនមែនមានសណ្ដាប់ជាប់គ្នា មិនមានរបៀបព្រមទាំងមិនមានភក្ដីភាពទៀតផង ព្រោះពេលនៃការផ្គុំចូលគ្នា និងរួបរួមគ្នាខាងផ្លូវគំនិតត្រូវផ្លាស់វេនគ្នាជាមួយនឹងពេលនៃការបែកចេញពីគ្នា និងមិនស្របគ្នានៃផ្លូវគំនិត ។ គំនិតមនុស្សមិនស្ថិតនៅដដែលទេ ពេលគំនិតរីកចម្រើន គំនិតវិភាគពីអ្វីៗអាចប្រសើរជាង ។

យើងសង្កេតឃើញថា ការប្រែប្រួលនៃប្រវត្តិសាស្ត្រ តែងតែធ្វើឱ្យ វិនាសនូវសាមគ្គី ឯកភាពនៃការរួបរួមគ្នា សេចក្ដីសុខសាន្តនៃក្រុមពួកកុលសម្ព័ន្ធ ឬសង្គមជាដរាប ។ កាលបើមនុស្សបែកខ្ញែកគ្នាហើយ ផលប្រយោជន៍នៃគំនិត និងពិចារណាដែលមានសាសនា ឬមនោគមវិជ្ជាជាតំណាង ក៏ត្រូវសាបសូន្យជាស្វ័យប្រវត្តិដែរ ។ អ្នកសង្គមវិទ្យា បានចាត់ទុកថារោគនៃសង្គមតែម្ដង ។ រោគសង្គមបណ្ដាលមកពីការរីកចម្រើននៃសង្គមតាមយុគសម័យ ហើយបើកាលណា ហេតុការណ៍នេះបានកើតឡើង អនុញ្ញាតឱ្យវប្បធម៌ និងអារ្យធម៌ថ្មីចូលមកបង្កើតឥទ្ធិពលក្នុងគំនិត និងក្នុងផ្លូវនៃសង្គមសាសនាថែមទៀត ។ យើងអាចពោលថា សង្គមនោះបានផ្លាស់ ឬពិភពលោកចាស់ប្រែទៅជាពិភពលោកថ្មីមួយទៀត ព្រោះគេគនភ័ណ្ឌវប្បធម៌បានបាត់បង់ទៅហើយៗ ទទួលយកវប្បធម៌ថ្មីជំនួសវិញ ។

(នៅមានត)

# សាស្ត្រាខ្មែរនៅភាគឦសាននៃប្រទេសថៃបច្ចុប្បន្ន

ដោយ: **បណ្ឌិត មីសែល ត្រាណេ**

## ១-សេចក្តីផ្តើម

អ្វីទាំងអស់ក្នុងសង្គមមនុស្ស សុទ្ធសឹងតែផ្តើមឡើងដោយជំនួបទាំងអស់។ យ៉ាងណាមិញជំនួបរវាងរូបយើងនឹងវប្បធម៌អារ្យធម៌ខ្មែរ នៅម្ខាងទៀតនៃជួរភ្នំដងរែក បានផ្តើមដោយចៃដន្យ នៅស្ថានីយរថភ្លើងនគររាជសីមា។ ពេលដែលរថភ្លើងឈប់ នៅក្នុងស្ថានីយខេត្តនគររាជសីមា សម្រាប់ឱ្យមនុស្សចុះមុននឹងធ្វើដំណើរបន្តទៅកាន់ ខេត្តអ៊ូប៊ុន រាជធានី។

តាមពិតនៅក្នុងខណៈដែលរថភ្លើងនោះឈប់នៅក្នុងស្ថានីយខាងលើ ដើម្បីដឹកមនុស្សបន្ថែម មានជម្លោះមួយជាភាសាខ្មែរ កើតឡើងរវាងមនុស្សអ្នកធ្វើដំណើរពីរនាក់ (ប្រហែលជាស្រីរឹងស្រាមកពីខេត្តសុរិន្ទ) ដោយប្រើពាក្យជេរប្រទេចផ្តាសាគ្នាយ៉ាងខ្លាំងក្លាគួរឱ្យកត់សម្គាល់។ ច្រើនខែ ឆ្នាំដែលបានកន្លងទៅ ពាក្យពេចន៍ទាំងប៉ុន្មាននៅតែជិតជាប់នៅក្នុងអារម្មណ៍យើងខ្ញុំ។ ចំពោះខ្ញុំ ករណី ដែលនាំឱ្យជនជាតិថៃនិយាយខ្មែរ បានបង្កជារឿងរ៉ាវប្លែកគួរឱ្យឆ្ងល់ ដែលនាំ ឱ្យយើងស្រាវជ្រាវនូវមូលហេតុពិត។ ជាពិសេសគឺករណីពួកខ្មែរសុរិន្ទនេះហើយ ដែលបាននាំយើងទៅកាន់ខេត្តនេះជាញឹកញយ រវាងឆ្នាំ១៩៧៦-១៩៩៣ ដើម្បីសិក្សាស្រាវជ្រាវ។ ម្យ៉ាងវិញទៀតការទៅកាន់ខេត្តនេះ ក៏ដូចនៅខេត្តបុរីរម្យ ស៊ីសាកេត បណ្តាលមកពីបុព្វហេតុផ្សេងៗទៀតដែរ ហើយជាគន្លឹះមួយ បានចូលរួមចំណែកដោះស្រាយបញ្ហាសំខាន់មួយ គឺហេតុដូចម្តេច ខានជាមានជនជាតិខ្មែររស់នៅទីនោះ ហើយតើ ពួកគេខាន

បន្សល់ ស្លាកស្នាមវប្បធម៌នៅទីនោះដែរឬទេ? តើពួកគេមកពីណា?

តាមការស្រាវជ្រាវកន្លងមករបស់យើងខ្ញុំជានិស្សិត ដែលចង់ដឹងចង់ស្គាល់អំពីអនាគតកាលរបស់ជនជាតិខ្មែរ សហគមន៍ជនជាតិខ្មែរ នៅក្នុងភូមិភាគឦសាននៃប្រទេសថៃបច្ចុប្បន្នដែលដើមឡើយជាភាគមួយនៃទឹកដីរបស់អតីតព្រះរាជាណាចក្រកម្ពុជា បញ្ជាក់ថាពួកគេមិនគ្រាន់ តែជាម្ចាស់ទឹកម្ចាស់ដី ដែលបានបន្សល់ទុកនូវមរតកវប្បធម៌រូបីយ៍ ដូចជាចម្រៀង ជំនឿ វិស័យស្ថាបត្យកម្ម និងសិល្បៈជាដើម ក៏ប៉ុន្តែមរតកវប្បធម៌អរូបីយ៍ ដូចជាទំនៀមទម្លាប់ តូរ្យតន្ត្រី ព្រមទាំងអក្សរសាស្ត្រទាក់ទិនទៅនឹងជំនឿសាសនាជាដើម។ សូមបញ្ជាក់ថាវត្តមានរបស់បងប្អូនខ្មែរភាគតិច ក្នុងភូមិភាគឦសាននៃប្រទេសថៃបច្ចុប្បន្ន ដែលមានចំនួនយ៉ាងតិចណាស់ក៏ ៣ ទៅ ៤លាននាក់ដែរ ហើយដែលស្ថិតនៅក្នុងអម្បូរមន-ខ្មែរអាចបញ្ជាក់តាមរយៈស្ថានីយ បុរេប្រវត្តិសាស្ត្រជាច្រើនអនេកកប្បការ មុនការហូរចូលនៃវប្បធម៌ឥណ្ឌា នាំឱ្យមានការបង្កើតរដ្ឋតូច-ធំក្នុងតំបន់ ពីសម័យបុរេអង្គរ និងសម័យអង្គរ។

## ២-ស្ថានភាពនៃសាស្ត្រានៅប្រទេសថៃបច្ចុប្បន្ន

វប្បធម៌ខ្មែរនៅក្នុងភូមិភាគឦសាននៃប្រទេសថៃបច្ចុប្បន្ន គឺជាផ្នែកមួយនៃវប្បធម៌ទូទៅនៃទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាបុរាណ មុនការបង្កើត ជាលើកដំបូង នៃរដ្ឋថៃ និងលាវ ប៉ុន្តែវប្បធម៌នេះមានលក្ខណៈពិសេស ព្រោះបានរក្សានូវលក្ខណៈដើមរបស់វា។

ជាមរតកវប្បធម៌ សាស្ត្រាខ្មែរក្នុងប្រទេសថៃបច្ចុប្បន្ន ដែលមានសហគមន៍ខ្មែររស់នៅយ៉ាងច្រើនកុះករនៅឡើយ ក៏ប៉ុន្តែត្រូវរលត់អាសាបង់បន្តិចម្តងៗ ក្រោម

ឥទ្ធិពលរបស់វប្បធម៌ថៃ នៅចុងសតវត្សទី១៣ ដើមសតវត្សទី១៤ រហូតមកដល់ពេលបច្ចុប្បន្នបើយើងនិយាយពីចំនួន និង បរិមាណរបស់វា។

គេបានប្រទះឃើញ វត្តមានសាស្ត្រាខ្មែរជាច្រើន តាមវត្តចាស់ៗក្នុងភូមិភាគនេះ ពីព្រំដែននៃខេត្តនគររាជសីមា រហូតដល់ព្រំដែនខ្មែរ-ថៃ និងថៃ-លាវបច្ចុប្បន្ន។ ព្រមជាមួយនឹងវត្តមាននៃសាស្ត្រាស្លឹករឹត នៅមានករណីមួយទៀតដែលយើងចាប់អារម្មណ៍គឺសិលាចារឹក ព្រោះគេឃើញថា មានសិលាចារឹកយ៉ាងច្រើនសន្ធឹកសន្ធាប់ជាភស្តុតាងបញ្ជាក់ថា ជនជាតិខ្មែរបានកាន់កាប់ត្រួតត្រា នៅក្នុងភូមិភាគនេះ ពីសម័យបុរេអង្គរ និងអង្គរ នេះឥតនិយាយពីស្ថានីយបុរេប្រវត្តិសាស្ត្រដែលមានចំនួនរាប់រយពាន់។ ក្រៅពីនេះ យើងនៅឃើញមាននូវវត្តមាន អស់ប្រាង្គ ប្រាសាទថ្ម-ឥដ្ឋចំនួនរាប់រយ នៅពាសពេញ ដេរដាស ទូទាំងប្រទេសថៃសព្វថ្ងៃ ថែម ទៀតផង។

## ៣.ប្រភពនៃសាស្ត្រា

តើគេប្រើសាស្ត្រាតាំងពីសម័យណាមក? ថ្វីត្បិតតែប្រភពនៃសាស្ត្រាខ្មែរនៅក្នុងប្រទេសថៃ ក៏ដូចជានៅស្រុកខ្មែរបច្ចុប្បន្ន ត្រូវបានគេគូសបញ្ជាក់ តាមរយៈចម្លាក់បុរាណនៅតាមប្រាង្គប្រាសាទថ្មនាសម័យអង្គរក៏ដោយដូចជានៅប្រាសាទភ្នំរុងជាច្រើនដែលត្រូវបានសាងសង់ឡើងនៅសតវត្សទី១១ នៃគ្រិស្តសករាជ ក៏ប៉ុន្តែមានទិន្នន័យជាវិជ្ជមានមួយចំនួនបង្ហាញបញ្ជាក់ថា ខ្មែរចេះនិយមសាស្ត្រា តាំងពីសម័យបុរេអង្គរ។ ជានិច្ចកាល សាស្ត្រា រមែងតែទាក់ទងនឹងវិស័យសាសនា និងស្ថាបត្យកម្ម ព្រមទាំងសិល្បៈ។ មួយវិញទៀតសោត ព្រះពុទ្ធសាសនាពុំអាចមានជីវិតរស់រានបានទេបើសិនជាគ្មានក្បួនខ្នាត សម្រាប់ការអភិវឌ្ឍន៍។

ម្យ៉ាងវិញទៀតបើយើងមើលផែនទីនៃចក្រភពខ្មែរដែលលោក Henri Parmentier បានរៀបរៀងឡើងនៅឆ្នាំ១៩១០ ដោយសំអាងលើទីតាំងនៃចារឹកខ្មែរ ដែលមានកាលបរិច្ឆេទក្នុងប្រទេសថៃបច្ចុប្បន្ន យើងក៏អាចដឹងអំពីទំហំនៃទឹកដីខ្មែរបុរាណដែរ ឬក៏ជាតំបន់ដែលមានការនិយមប្រើសាស្ត្រាជាយានសម្រាប់ទ្រទ្រង់អភិវឌ្ឍធមិអាចិក្រិត្យក្រម ជំនឿសាសនា។

ចំពោះផែនទីខ្មែរខាងលើនេះរបស់លោក Henri Parmentier ថ្វីត្បិតតែក្នុងគំនូស ផែនទីនេះ លោកមិនបានបញ្ចូលភូមិភាគខាងត្បូង នៃប្រទេសថៃបច្ចុប្បន្ន ដែលជាភាគមួយ នៃទឹកដីនាសម័យនគរភ្នំក៏ដោយ ក៏ប៉ុន្តែវាមានសារៈសំខាន់សម្រាប់យើងណាស់ក្នុងការស្វែងយល់អំពីចំណាស់របស់វប្បធម៌ខ្មែរ និងតួនាទី ជាប្រវត្តិសាស្ត្ររបស់ជនជាតិខ្មែរក្នុងអាស៊ីអាគ្នេយ៍ ជាពិសេសក្នុងទឹកដី នៃព្រះរាជាណាចក្រថៃបច្ចុប្បន្ន។ គឺឈរលើមូលដ្ឋាននេះហើយ អាចសន្និដ្ឋានបានថា: ការនិយមសាស្ត្រា ត្រូវបានប្រព្រឹត្តឡើងនាសម័យអង្គរ ឬមុនអង្គរយ៉ាងពិតប្រាកដ។

សរុបសេចក្តីមក អត្ថបទសាស្ត្រាដែលមានចំនួនច្រើនអនេក ក្នុងភូមិភាគឦសានទាំងមូលបានបញ្ជាក់អំពីនិរន្តរ៍ភាពនៃការប្រើសាស្ត្រា ព្រមទាំងវត្តមានរបស់ជនជាតិខ្មែរ ដែលជាអ្នកស្រុកអាយ ក្នុងតំបន់មុនការមកដល់ នៃជនជាតិអន្តោប្រវេសន៍ថៃ។

## ៤-មូលហេតុនៃការស្រាវជ្រាវ

របហូតមកដល់ពេលបច្ចុប្បន្ននេះ ជនជាតិខ្មែរភាគច្រើនក្នុងប្រទេសកម្ពុជានៅតែមិនទាន់បានដឹងនៅឡើយថា តើហេតុដូចម្តេចបានជាមាន សហគមន៍ខ្មែរមាន

ចំនួនមិនតិចជាង៦លាននាក់ កំពុងរស់នៅក្នុងប្រទេសថៃសព្វថ្ងៃ។ យ៉ាងណាមិញ គេក៏ពុំដឹងដែរថា មានសមិទ្ធផលវប្បធម៌ខ្មែរបុរាណ ដូចជាប្រាង្គប្រាសាទ, សិលាចារឹក, វត្ថុសិល្បៈ និងតួរូបតន្ត្រី ។ល។ នៅក្រៅបង្គោលសីមានៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននោះទេ។ គឺប្រការនេះហើយដែលជំរុញឱ្យករុណាយើងខ្ញុំ ឱ្យខិតខំប្រឹងប្រែងស្វែង យល់អំពី ឫសកែវនៃវប្បធម៌អារ្យធម៌ខ្មែរក្នុងភូមិភាគ ខាង លើនេះ។

មូលហេតុនៃការស្រាវជ្រាវផ្តោតអត្ថិភាពទៅលើបញ្ហាចម្បងដែលមានដូចតទៅ:

១-ដោយសារយើងចង់ឱ្យបញ្ចូវន្តខ្មែរយើង ក៏ដូចជាអ្នកប្រវត្តិសាស្ត្រវិទូបន្តការស្រាវជ្រាវពីការសិក្សារបស់ខ្ញុំ ដែលបានចាប់ផ្តើមនៅឆ្នាំ១៩៧៦ ហើយបញ្ចប់នៅឆ្នាំ២០០០កន្លង ទៅនេះ។

២-ដើម្បីសិក្សា ស្វែងយល់ឱ្យស៊ីជម្រៅថែមមួយកម្រិតទៀត នូវវប្បធម៌ខ្មែរបុរាណ នៅក្នុងប្រទេសថៃបច្ចុប្បន្នដែលមានភាពរុងរឿងថ្កុំថ្កើងនិងសម្បូរបែប។ បញ្ហានេះសំខាន់ណាស់ពីព្រោះយើងពុំអាចបំភ្លេចបាននូវប្រវត្តិសាស្ត្រចាស់របស់ជាតិខ្មែរយើងបានទេព្រោះវាជាប្រភពនៃមោទនភាពជាតិ។ បើសិនជាយើងមិនចាប់អារម្មណ៍ ស្វែងយល់អំពីកំណើត ឬប្រភពនៃវប្បធម៌ អារ្យធម៌ខ្មែរក៏ពិតជាពុំអាចមានលក្ខណៈពេញលេញដែរ។

៣-យើងជឿជាក់យ៉ាងមាំថាមានតែជនជាតិខ្មែរទេដែលអាចបំពេញតួនាទីនេះ ពីព្រោះបរទេសមិនអាចយកចិត្តទុកដាក់នឹងបញ្ហាវប្បធម៌ខ្មែរ ក្នុងប្រទេសថៃបច្ចុប្បន្នបានជាដាច់ខាត។ ហេតុដែលគេមិនអាចធ្វើកិច្ចការនេះជំនួសខ្មែរបាននេះបណ្តាលមកពីគេមិនចង់ឃើញប្រយោជន៍របស់ជាតិគេ ត្រូវខូចខាតអាសារបង់ក្នុង

ប្រទេសថៃឡើយ។

## ៥-លទ្ធផលដំបូងនៃការស្រាវជ្រាវ

ក្នុងបទអន្តរាគមន៏របស់យើងនេះ យើងគ្រាន់តែសូមលើកយក លទ្ធផលនៃការស្រាវជ្រាវក្នុងស្រុកបីតែប៉ុណ្ណោះ គឺតាព្យា (ខេត្តបច្ចឹមបុរី ស្រះកែវ),ស្រុកគោកខន័ (ខេត្តស៊ីសាកេត), ស្រុកប្រាសាទ និងសុរិន្ទ។ ដូចនេះដោយខ្វះមធ្យោបាយ និងពេលវេលា ការស្រាវជ្រាវរបស់ខ្ញុំពុំមានលក្ខណៈ ទូលំទូលាយទេ។

ក្នុងការស្រាវជ្រាវនេះ យើងបានធ្វើការលះបង់ច្រើន ក៏ប៉ុន្តែដូចហេតុផលខាងលើ ពុំបានទទួលនូវលទ្ធផលល្អប្រសើរទេ ព្រោះវត្ត ដែលបានពិនិត្យ មានចំនួនត្រឹមតែជាង១០ វត្តតែ ប៉ុណ្ណោះ។

ឆ្លៀតឱកាសនេះ យើងខ្ញុំក៏សូមឧទ្ទិសមគ្គផលដែលបានមកពីការស្រាវជ្រាវនេះជូនទៅវិញ្ញាណក្ខន្ធរបស់លោក *បុណ្យ ជួយចារីក* ដែលបានជួយយើងក្នុងកិច្ចការធ្វើបញ្ជីនៃច្បាប់សាស្ត្រាខ្មែរទាំងនោះ។ យើងក៏ឆ្លៀតឱកាសនេះដែរ ដើម្បីសម្តែងអំណរគុណដ៏ជ្រាលជ្រៅចំពោះភរិយារបស់យើង និងលោក *មកុដ កណ្ដេវ* ដែលជាប្រិយមិត្តដែលបានជួយឧបត្ថម្ភខ្ញុំខាងកាយ និងចិត្តក្នុងការស្រាវជ្រាវជាជំហាន១។

ជាការពិតណាស់ក្នុងរយៈពេលជិត១៥ឆ្នាំ យើងបាន សន្សៀសន្សំសាស្ត្រាខ្មែរទាំងអស់ បានប្រមាណជា ៣០០ ច្បាប់ ដោយខ្លួនយើងផ្ទាល់ និងដោយជំនួយពីសហការីជាអ្នកខ្មែរសុរិន្ទ និងខ្មែរស៊ីសាកេត។ ក៏ប៉ុន្តែនេះជាលទ្ធផលមួយដ៏តូចស្តួចស្តើងទេ បើយើងប្រៀបធៀបទំហំកិច្ចការនេះទៅនឹងបរិមាណសាស្ត្រាដែលមានក្នុងភូមិភាគ ឦសាន នៃប្រទេសថៃបច្ចុប្បន្ននេះ។

ជាការគួរឱ្យសោកស្តាយណាស់ ដែលយើងពុំអាចទៅដល់ស្រុកភូមិដាច់ស្រយាល ពីទីប្រជុំ ជន ឬស្រុកភូមិដែលស្ថិតនៅកៀនកោះ ។

## ៦-អំពីប្រភេទសាស្ត្រា

យោងទៅលើការស្រាវជ្រាវជាជំហានៗរបស់យើង យើងអាចសង្កេតឃើញថា : សាស្ត្រាស្លឹករឹតក្នុងភូមិភាគព្យសាននៃប្រទេសថៃមានលក្ខណៈជាទូទៅដូចជាសាស្ត្រា នៅប្រទេសកម្ពុជាបច្ចុប្បន្ន ទាំងខ្លឹមសារអត្ថបទ ទាំងប្រភេទស្លឹក ទាំងវិធីសាស្ត្រនិពន្ធ។ ភិនភាគសាស្ត្រាទាំងនោះគឺធ្វើពី ស្លឹករឹត ( ប្រភេទត្នោតម្យ៉ាង) ។

បើយើងពិនិត្យលើពាក្យពេចន៍ដែលចារលើសាស្ត្រា យើងអាចធ្វើការវាយតម្លៃ បានថា:

ទី១ : អ្នកនិពន្ធ ឬអ្នកចម្លងឯកសារទាំងនោះ គឺជាភិក្ខុសង្ឃ ឬជាអ្នកចាស់ទុំដែលធ្លាប់ជាអាចារ្យ ឬអ្នកបានបួសនៅក្នុងវត្ត ហើយមានចំណេះដឹងអំពីសាសនាយ៉ាងជ្រាលជ្រៅ ។

ទី២: ខ្លឹមសារអត្ថបទ មិនខុសប្លែកប៉ុន្មានពីសាស្ត្រាខ្មែរលើកលែងតែច្បាប់សាស្ត្រាខ្លះដែលពុំមាននៅប្រទេសកម្ពុជា ដោយមូលហេតុដែលយើងពុំដឹងច្បាស់នៅឡើយ ។

ទី៣: អត្ថបទខ្លះអាចត្រូវចារឡើងនៅចុងសតវត្សទី១៨ នៃ គ.ស ហើយការចារនេះត្រូវ បន្តរហូតដល់ឆ្នាំ ១៩៧០ ទើបត្រូវបញ្ចប់ ។

ទី៤: សាស្ត្រាទាំងនោះ ដែលយើងបានប្រមែប្រមូល ឬជួបប្រទះ សុទ្ធសឹងតែជាច្បាប់ចម្លង ចេញពីអត្ថបទដើមដែលបានបាត់បង់អស់ទៅហើយដោយអ្នកប្រាជ្ញ

ខាងសាសនា និងកវី បណ្ឌិតនិពន្ធខ្មែរ ។

សាស្ត្រាទាំងនោះគឺជាសមិទ្ធិផលវប្បធម៌ កើតចេញពីសង្គមខ្មែរដ៏ពិតៗ ក៏ប៉ុន្តែ ដោយសារបច្ចុប្បន្ននេះ ស្ថិតក្រោមឥទ្ធិពលនៃការគ្រប់គ្រងរបស់ជនជាតិថៃ ជាហេតុឱ្យឃើញនូវខាងចុង អត្ថបទខ្លះ មានពាក្យពេចន៍ថៃមួយចំនួន ឬក៏អក្សរខ្មែរដែលអានតាមសំនៀងថៃ។ ម្យ៉ាងវិញទៀត ថ្វីត្បិតតែពួកខ្មែរសុរិន្ទ បុរីរម្យ មានសញ្ជាតិជាថៃមែន តែក្នុងចិត្តគេ គេនៅតែសម្គាល់ថា គេជាខ្មែរហើយប្រើភាសាខ្មែរដដែល ។

សាស្ត្រាស្លឹករឹត ជាឯកសារសរសេរដោយដៃ ដែលមានសម័យកាលខុសៗគ្នា និង ប្រភេទ ក៏ខុសៗគ្នាដែរ ។ នៅក្នុងភូមិភាគឮសាន យើងឃើញមាននូវឯកសារសរសេរ. ចារលើថ្ម ចាប់តាំងពីសតវត្សទី៦មក រហូតដល់ចុងសតវត្សទី២០ យើងនេះ ។ រីឯអក្សរថៃចាប់កំណើតដំបូង បង្អស់នៅត្រឹមតែសតវត្សទី១៣ ប៉ុណ្ណោះ ។

ប្រភេទនៃសាស្ត្រាពាក់ពន្ធ័ទៅនឹងវិសយ័សាសនា ក្រិត្យក្រម ច្បាប់ទូន្មាន សុភាសិត ជាតក និងរឿងរ៉ាវមួយចំនួន។ ភាសាដែលគេចារ គឺភាសាខ្មែរ និងភាសាបាលី ។

បន្ថែមពីលើនេះទៀត ក្នុងបណ្តាឯកសារដែលសរសេរដោយដៃ យើងនៅឃើញមាន អត្ថបទសរសេរលើស៊ីម៉ង់ ក្រាំងក្រដាស បន្ទះមាស ប្រាក់ សំណរ ស្ពាន់ ឈើ ក្រណាត់ ជាដើម ។

## ៧-សាស្ត្រានិងសង្គមខ្មែរនៅប្រទេសថៃ

ក្នុងសង្គមមួយដែលប្រជាពលរដ្ឋកាន់ព្រះពុទ្ធសាសនា សាស្ត្រាបានបំពេញ

តួនាទីយ៉ាងសំខាន់នៅក្នុងជីវិតប្រចាំថ្ងៃ : ផ្តល់នូវគោលគំនិត បញ្ញា និងពុទ្ធិនានា ដើម្បីវែកញែករកខុសនិងត្រូវ ហេតុនិងផល បុណ្យ និងបាប ។ល។ ដែលជាប្រភពនៃសុភមង្គល។ បើនិយាយម្យ៉ាងទៀត ការអានសាស្ត្រា ឬស្តាប់លោកទេសនា ពុទ្ធសាសនិកជន មិនគ្រាន់តែស្គាល់ប្រវត្តិរបស់ព្រះតែប៉ុណ្ណោះទេ ក៏ប៉ុន្តែចេះលើកតម្លៃសង្គមឱ្យខ្ពស់ ពត់ចិត្តគំនិត តាមសច្ចធម៌ និងព្រហ្មវិហារធម៌ ប្រយោជន៍នឹងរកសេចក្តីសុខ សេចក្តីចម្រើនក្នុងសង្គមធម៌ថែមទៀតផង។

ដូចសិលាចារឹក ដែលជាប្រភពដើមនៃប្រវត្តិសាស្ត្រកម្ពុជា អត្ថបទសិលាចារឹកខ្មែរ អាចផ្តល់នូវ អត្ថប្រយោជន៍ជាច្រើន។ តាមរយៈសាស្ត្រា យើងអាចលេចធ្លោឡើងនូវរូបភាពជាក់ស្តែងរបស់សង្គម និងជីវិតរស់រវើកប្រចាំថ្ងៃ របស់ជនជាតិខ្មែរ ក្នុងភូមិភាគឰសាននៃប្រទេសថៃបច្ចុប្បន្ន ដូចជាបុណ្យទាន ទស្សនៈអំពីបុណ្យបាប ទស្សនៈអំពីលោក។ សរុបសេចក្តីមក សាស្ត្រាបាន រួមចំណែកយ៉ាងធំធេង ខាងបញ្ញាស្មារតី ក៏ប៉ុន្តែអ្វីដែលសំខាន់ជាងគេ គឺក្បួនខ្នាតទាំងអស់នោះ ពន្យល់ឱ្យយើងនូវទម្រង់ និងលក្ខណៈ ឬស្ថានភាពនៃវេយ្យាករណ៍ខ្មែរ និងភាសាខ្មែរបុរាណ ហើយដោយឡែកទំនាក់ទំនងវប្បធម៌ជនជាតិខ្មែរនៅលើជួរភ្នំដងរែក និងជនជាតិខ្មែរនៅក្នុង ប្រទេសខ្មែរបច្ចុប្បន្ន ដែលមានឈ្មោះថាខ្មែរក្រោម ឬខម តាមសំនៀងថៃ។

## ៨_សំណូមពរ

ដូចនេះ ជាការចាំបាច់ណាស់ ដែលយើងត្រូវយកចិត្តទុកដាក់លើឯកសារទាំងនោះ ដែលជាកេរ្តិ៍ដំណែលវប្បធម៌ខ្មែរសុទ្ធសាធ ទោះបីជាស្ថិតនៅក្នុង ប្រទេសថៃបច្ចុប្បន្នក៏ដោយ ដើម្បីឱ្យមានការអភិវឌ្ឍន៍និរន្តភាព នៃវប្បធម៌ខ្មែរពីសំណាក់

ព្រះសង្ឃថៃ ដើមកំណើតខ្មែរ ។ក៏ប៉ុន្តែបើយើងមិនច្រឡំទេជាការសោកស្តាយណាស់ ដែលពុំទាន់មានការគ្រប់គ្រង ដើម្បីថែរក្សាសាស្ត្រាទាំងនោះឱ្យបានត្រឹមត្រូវគង់វង្ស នៅឡើយ ។ ពីព្រោះជនជាតិខ្មែរភាគតិចទាំងនោះ សព្វថ្ងៃនេះមិនចេះមើលអក្សរ ខ្មែរទៀតឡើយ ពោលគឺគេពុំចេះអានសាស្ត្រាខ្មែរដែលដូនតាគេបានចារទុកថាជាព្រះ បាលី ឬព្រះគម្ពីរ ប្រកបដោយលក្ខណៈពិសេស លើកលែងតែព្រះសង្ឃ ឬអាចារ្យវត្ត មួយចំនួនដ៏តិចតួចប៉ុណ្ណោះ ។

ខឿនវប្បធម៌ដើមរបស់ជនជាតិខ្មែរសព្វថ្ងៃនេះ ត្រូវរង្គោះរង្គើយ៉ាងខ្លាំងគួរ ឱ្យរន្ធត់ចិត្ត ឧទាហរណ៍ៈ ទាំងសម្លៀកបំពាក់ ទាំងប្រពៃណី ទាំងទំនៀមទម្លាប់ របស់ ពួកគេ មានការវិវត្តន៍ប្រែប្រួលយ៉ាងឆាប់រហ័សទៅរកភាពសម័យទំនើប ដូចជនជាតិ ថៃ គួបផ្សំនឹងសាកលភាវូបនីកម្ម និង ថៃរូបនីយកម្ម តាមរយៈប្រពន្ធ័ឃោសនាទៅ លើពួកគេ។ ក្នុងករណីនេះហើយ មិនយូរមិនឆាប់ទេស្លាកស្នាមនៃវប្បធម៌អរិយធម៌ ទាំងនោះនឹងត្រូវរិចរិលបន្តិចម្តងៗ ហើយនៅទីបំផុតក៏រលាយចូលក្នុងពុម្ពវប្បធម៌ថៃ ដែលបានជ្រួតជ្រាបជិត៧សតវត្សមកហើយ ក្នុងសង្គមថ្មី របស់គេ ។

អ្វីដែលទើបពោលគឺគ្រាន់តែជាការត្រួសត្រាយផ្លូវសម្រាប់ការស្រាវជ្រាវត ទៅអនាគតមុនខឿនវប្បធម៌ទាំងនោះរលត់បាត់ស្រមោលអស់ពីផែនដីប៉ុណ្ណោះ ។

ជីវិតយើងពុំមានលក្ខណៈអមតៈទេ ពោលគឺពុំស្ថិតស្ថេរនៅជានិរន្តរ៍ជាមួយ យើងទេ មានតែឯកសារទាំងនោះទេដែលជាកេរ្តិ៍ដំណែល ។ ដូច្នេះហើយបានជាយើង បានធ្វើអំណោយមួយភាគធំនៃសាស្ត្រាទាំងនោះទៅបណ្ណាល័យនៃសារមន្ទីរជាតិ ទុក ជា មរតកសម្រាប់អ្នកស្រាវជ្រាវ ។

សូមជម្រាបថាបងប្អូនខ្មែរនៅប្រទេសថៃ មួយចំនួនដែលខ្ញុំបានស្គាល់ពី ៣០

ឆ្នាំមុន ឥឡូវនេះបានរលត់សង្ខារទៅហើយ ពួកគេគ្រាន់តែបានបន្សល់ទុកជា មរតក ក្បួនខ្នាតទាំងនោះពោរពេញទៅដោយខ្លឹមសារដ៏ល្អប្រពៃ ហើយដែលជា សក្ខីភាព នៃសេចក្តីថ្លៃថ្នូររបស់ពួកគេ ។

ចុងបញ្ចប់នេះ សូមឱ្យមានការបន្តការស្រាវជ្រាវបន្ទាប់ពីយើងខ្ញុំតទៅទៀត កុំខាន ដោយសហការជាមួយសហគមន៍ខ្មែរសុរិន្ទ ដែលទើបតែបង្កើតឡើងថ្មីៗនេះ ។



*លោក មកុដ កណ្តៀវ*
*ឬ មុដពេជ្រ*
*(ថតនៅឆ្នាំ១៩៨៤)*

# ការសរសេរដោយ[1]ដៃដែលរក្សាទុកនៅបណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ មុនឆ្នាំ ១៩៧៥

ដោយ : **ឃីង ហុកឌី**

ការសរសេរដោយដៃខ្មែរ ដែលមានរក្សាទុកនៅបណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យភ្នំពេញចែកចេញជា បីផ្នែកធំៗ គឺ:

១- សាស្ត្រាស្លឹករឹត

២- ក្រាំង គឺជាឯកសារសរសេរលើសន្លឹកក្រដាស ទំនៀមបត់ជាផ្នត់ៗជាប់ៗ គ្នា :

៣- ឯកសារចម្លងលើក្រដាសទំនើប

តែកម្របនៃការសម្តែងក្នុងសន្និសីទនៅពេលនេះ ជាពិសេសគឺស្តីពីឯកសារ សាស្ត្រាស្លឹករឹត ក្រាំង និង ឯកសារចម្លងដៃ ដែលរក្សាទុកនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យមុនឆ្នាំ ១៩៧៥ ប៉ុណ្ណោះ ។ មុននឹងពណ៌នាពីឯកសារទាំងនេះគួរតែផ្តើមបង្ហាញនូវប្រវត្តិសង្ខេប នៃស្ថាប័នពុទ្ធសាសនបណ្ឌិត្យនេះសិន ។

## ១_ប្រវត្តិសង្ខេបពុទ្ធសាសនបណ្ឌិត្យ

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ មានកំណើតឡើងបន្ទាប់ពីការបង្កើតសាលាបាលី ២ គឺមួយនៅភ្នំពេញឈ្មោះ " អរមពុទ្ធវចនបរិយត្តិមន្ទីរ " និងមួយទៀតនៅសៀមរាប ឈ្មោះ " អរមពុទ្ធវចនបរិយត្តិបសាទ " ដោយព្រះរាជប្រកាសព្រះស៊ីសុវត្ថិ នាថ្ងៃទី ១៣ សីហា ១៩០៩ ដើម្បីលើកកំរិតវិជ្ជាផ្នែកភាសាបាលីនៃព្រះសង្ឃ

---

១- ម្ចាស់អត្ថបទសរសេរ *ចាស់នេរ* តែកម្ពុជសុរិយាសុំកែដាក់ថា *ការសរសេរ*វិញ ។

ខ្មែរឱ្យបានខ្ពង់ខ្ពស់ ។ ការបង្កើតសាលាបាលីទាំងពីរនេះ រដ្ឋបាលបារាំងជំនាន់នោះ មានបំណងមិនចង់ឱ្យព្រះសង្ឃចេញទៅរៀនបាលី និងព្រះពុទ្ធសាសនានៅប្រទេសថៃទៀត ពោលគឺ ចង់ឱ្យប្រទេសកម្ពុជាយើងបានឯករាជ្យផ្នែកវប្បធម៌ និងអក្សរសាស្ត្រ ។ តែសាលាបាលី ដែលមានទីតាំងនៅខេត្តពុំមានដំណើរស្រួលបួល ដោយនៅឆ្ងាយពីទីក្រុងក៏រលត់ជីវិតវិញនៅថ្ងៃ ៦ មិថុនា ១៩១១ ដូចមានសេចក្ដីបញ្ជាក់ក្នុងសន្ទរកថា លោករដ្ឋមន្ត្រីក្រសួងអប់រំស្រាប់ ។ ព្រះរាជប្រកាសចុះថ្ងៃ ២៤ វិច្ឆិកា ១៩១៤ ឱ្យបង្កើតនៅក្រុងភ្នំពេញ សាលាបាលីមួយទៀត ដើម្បីជំនួស សាលាបាលីដែលមានទីតាំងនៅអង្គរនៅឆ្នាំ ១៩០៩ ដោយឥតបានជោគជ័យ ។ សាលាបាលីក្រុងភ្នំពេញបានផ្ដើមសម្ពោធនៅថ្ងៃទី ២៤ កក្កដា ១៩១៥[២] ក្រោមអធិបតីភាពព្រះករុណាព្រះស៊ីសុវត្ថិ និងតំណាងរដ្ឋបាលបារាំង ។ សាលាបាលីនេះ ស្ថិតនៅឆ្វេងដៃព្រះរាជារាម ។ តាមសុន្ទរកថាលោកសីដេសថែងថា : " សាលាបាលីនេះជាមួយនឹងបណ្ណាល័យដែលយើងនឹងបង្កើត ដើម្បីប្រមូលឯកសារ ដែលមានសារប្រយោជន៍នៅរាយប៉ាយក្នុងវត្តនានាក្នុងខេត្តស្រុក ។ សាលាបាលីនេះ នឹងក្លាយទៅជាជង្រុកចំណេះដឹងដូចដែលមានមកហើយ នៅប្រទេសថៃ និងប្រទេសភូមា ។ ដោយសង្ឃឹមថាសាលាបារាំងចុងបូព៌ាប្រទេស យល់ព្រមផ្ដល់ជំនួយដល់រដ្ឋបាលអាណាព្យាបាលដើម្បីរៀបចំស្ថាប័ននេះ និងឃ្លាំពិនិត្យឱ្យដំណើរការបានស្រួលបួល ។ ស្ថាប័ននេះនឹងទទួលរង្វាន់ដ៏ធំធេង ប្រសិនបើអប់រំបានជោគជ័យនូវបញ្ញាជនមានលទ្ធភាពធ្វើសហការក្នុងស្នាដៃបែបវិទ្យាសាស្ត្រ ដែលបានផ្ដើមធ្វើឡើងចំនួន ១៦ ឆ្នាំមកហើយ

---

១ - នៅឆ្នាំដដែលនេះ គឺតាមព្រះរាជប្រកាសចុះថ្ងៃ ៤ កញ្ញា ១៩១៥ បញ្ជាឱ្យបង្កើតគណៈកម្មការវចនានុក្រមខ្មែរ ។

នៅឥណ្ឌូចិន ។ ក្នុងនាមស្ថាប័ននេះ ខ្ញុំព្រះករុណាសូមសម្តែងសមានចិត្តនូវកត្តញ្ញូដ៏ខ្លាំងក្លារបស់យើងខ្ញុំ ចំពោះសម្តេចព្រះករុណា ដែលបានព្រះរាជានុញ្ញាតឱ្យសង់សាលាបាលីនេះ នៅក្នុងបរិវេណព្រះបរមរាជវាំង ព្រះអង្គបង្ហាញថាព្រះអង្គឱ្យតម្លៃយ៉ាងធំធេងលើសាលាបាលីនេះ .......” ។

បានគ្រោងទុកតាមព្រះរាជប្រកាស បណ្ណាល័យសាលាបាលីនេះ កកើតឡើងដំបូង ដោយសមូហភាព ឯកសារព្រះរាជទ្រព្យ ដែលព្រះករុណាព្រះស៊ីសុវត្ថិទុកឱ្យសិក្សានិងតាមការជាវទិញ ដោយថវិកាប្រចាំប្រទេសកម្ពុជា ។

ដើម្បីឆ្លើយនឹងសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ព្រះបាទស៊ីសុវត្ថិបានស្ថាបនាព្រះរាជបណ្ណាល័យ (Bibliothèque Royale) នៅឆ្នាំ ១៩២១ និងបង្កើតសាលាបាលីជាន់ខ្ពស់[៣] នៅឆ្នាំ១៩២២ ដែលក្លាយទៅជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតនៅឆ្នាំ ១៩៥៥ ។ នៅថ្ងៃ ១៧ និង ១៨ កក្កដា ១៩៣០ លោកអគ្គអភិបាលបារាំងព្យែរប៉ាស្គីយេរ (Pierre Pasquier) និងលោកក្រូធីម៉ែរ (Krautheimer) ជាអភិបាលឥណ្ឌូចិន បានចេញទៅធ្វើទស្សនកិច្ចនៅខេត្តត្រាវិញ និងស្រុកទ្រាំងនៅកម្ពុជាក្រោម ។ ពេលនោះ លោកអគ្គអភិបាលបារាំង ដែលជូនដំណើរដោយកញ្ញា ស៊ុយហ្សាន ការពើលេស (Suzanne Karpelès) អភិរក្សព្រះរាជបណ្ណាល័យ និងលោកតាត ជាសាស្ត្រាចារ្យបាលី ជាន់ខ្ពស់នៅភ្នំពេញបានជួបប្រជាជនពូជខ្មែរជាច្រើន ។ បាតុកម្មដ៏ឧឡារិកនេះ បានធ្វើឱ្យមានការចាប់អារម្មណ៍ជាខ្លាំង ចំពោះក្រុមជាតិពិន្ទុដ៏សំខាន់នេះ លោកប៉ាតីចេរមានបំណងបញ្ជូនប្រគល់វិញ នូវប្រពៃណីទនៀមទម្លាប់

---

១- នៅឆ្នាំ ៨ មេសា ១៩២៤ តាមព្រះរាជប្រកាសលេខ ២២ អនុញ្ញាតឱ្យសាលាបាលីជាន់ខ្ពស់បោះពុម្ពផ្សាយនូវសៀវភៅទាំងឡាយ ដែលទាក់ទងនឹងព្រះពុទ្ធសាសនា ។

ជនជាតិនេះដោយបង្រួបបង្រួម ចំណងសាសនា និងវប្បធម៌បាលីទៅមាតុប្រទេសបុរាណវិញ ។ ពេលនោះ លោកអគ្គអភិបាលបារាំងចេញប្រកាសថា :

លោកអគ្គអភិបាលយល់ស្របដ៏ខ្ពង់ខ្ពស់ នឹងលោកអភិបាលឥណ្ឌូចិនដែលបានផ្ដត់ផ្ដង់ខ្មែរនៅទីនេះ ដោយបញ្ជាក់ថា :

ឱ្យបញ្ជូនព្រះសង្ឃ ៣០ អង្គ ដែលទទួលអាហារូបករណ៍ មករៀនអានសរសេរនិងនិយាយឱ្យត្រឹមត្រូវតាមភាសាខ្មែរ និងសិក្សាពីទ្រឹស្ដីពុទ្ធសាសនា ដើម្បីមកបង្ហាត់បង្រៀនវិញនៅតាមវត្តរៀងៗ អង្គពេលណាដែលលោកសិក្សាចប់ ។

ឱ្យជាវទស្សនាវដ្ដីកម្ពុជសុរិយា ដើម្បីនាំឱ្យព្រះសង្ឃ និងពុទ្ធបរិស័ទរៀនអានអត្ថបទមានជម្រៅ :

និងផ្ដល់ឱ្យការអប់រំនានា ដើម្បីឱ្យចេះគោរពទំនៀមទម្លាប់ និងសាសនាខ្មែរ ។

នៅកម្ពុជារដ្ឋបាលបារាំងបានបង្កើតជាច្រើនឆ្នាំមកហើយ នូវសាលាបាលីជាន់ខ្ពស់,ពុទ្ធិកបណ្ណាល័យ ដែលបានប្រមូលផ្ដុំគម្ពីរក្រាំងសាស្ត្រាស្លឹករឹតនានា និងបានបោះពុម្ពផ្សាយសៀវភៅទាំងឡាយជាភាសាខ្មែរ ។

ដើម្បីធានារ៉ាប់រងភាសាខ្មែរ កុំឱ្យបាត់បង់នឹងខូចខាត, ដើម្បីឱ្យពុទ្ធសាសនាគង់វង្សជាដរាប និងឱ្យប្រទេសទាំងឡាយនៅឥណ្ឌូចិនបារាំងសែសដែលកាន់ពុទ្ធសាសនា ហីនយាន រៀនចេះស្គាល់គ្នា និងសហការជាមួយគ្នា, លោកអគ្គអភិបាលបានបង្កើតអង្គការមួយ ដែលមាននាមថា " វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឥណ្ឌូចិនបារាំងសែស " ដែលមានភារៈកិច្ចដូចតទៅ :

១- ត្រូវបោះពុម្ពជាអក្សរច្រៀងព្រះត្រៃបិដក ដើម្បីផ្ដល់ឱ្យបានមួយចប់ដល់វត្តអារាមទាំងឡាយ :

២- ត្រូវបកព្រះត្រៃបិដកពីបាលីមកជាខ្មែរ ដើម្បីឱ្យព្រះសង្ឃយល់ធម៌ដែលលោកសូត្រ :

៣- ត្រូវបោះពុម្ពវចនានុក្រមភាសាខ្មែរ[1] ដើម្បីឱ្យយើងយល់ជាក់ច្បាស់ន័យសេចក្ដីពាក្យ ដែលយើងយកមកប្រើ និងសរសេរឱ្យបានត្រឹមត្រូវ ។ យើងអាច និពន្ធសៀវភៅក្នុងភាសាល្អប្រសើរ

៤- ឱ្យបង្កើតសាលានានាក្នុងវត្ត ដើម្បីឱ្យព្រះសង្ឃរៀនសូត្របាលី និងពុទ្ធសាសនា ។ ហេតុនេះ ព្រះសង្ឃប្រកបដោយចំណេះដឹងឡើងវិញដូចពីបុរាណកាល ហើយអាចមានឥទ្ធិពលទៅលើពុទ្ធបរិស័ទទាំងពួង

៥- តាំងនៅក្នុងបន្ទប់ប្រជុំនានា ដោយមានសៀវភៅជាភាសាខ្មែរសម្រាប់ពលប្រដាប់អាវុធទាំងឡាយ ។ ទាំងនេះធ្វើឱ្យពលទាហានខ្មែរគ្មានអារម្មណ៍កំព្រាឯកោ .

៦- ធ្វើឱ្យពុទ្ធសាសនិកជនទាំងអស់ប្រារព្ធពិធីជំនឿផ្សេងៗ និងបុណ្យទានសាសនា ដោយស្ងប់ស្ងៀម និងតាមច្បាប់មាត្រាចារទុកមកហើយ ឱ្យបកប្រែលិខិតរដ្ឋបាលទាំងឡាយជាភាសាខ្មែរ ។

លោកអគ្គអភិបាលបារាំង ព្រះករុណាព្រះស៊ីសុវត្ថិ ព្រះករុណា ស្ដេចហ្លួងព្រះប្រាង អភិបាលឥណ្ឌូចិន លោករេស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា និងលាវ មន្ត្រីរាជការជាន់ខ្ពស់នៅភ្នំពេញនិងលាវការពាររក្សាវិទ្យាស្ថាននេះ ... ។

---

១-វចនានុក្រមខ្មែរបានបោះពុម្ពផ្សាយជាដំបូងភាគ ១ ( ពីអក្សរកដល់ម ) នៅឆ្នាំ ១៩៣៨ ភាគ ២ ( ពីអក្សរ យ ដល់ អ ) នៅឆ្នាំ ១៩៤៣ ។ បោះពុម្ពលើកទី ២ ភាគ ១ ភាគ២ នៅឆ្នាំ ១៩៦៧ ភាគ ២ នាឆ្នាំ ១៩៦៨ ។

ក្រោយមកព្រះបាទស៊ីសុវត្ថិមុនីវង្ស បានព្រះរាជបញ្ជាឱ្យស្ថាបនាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ (Institut Bouddhique) នៅឆ្នាំ ១៩៣០ ហើយបញ្ចូលព្រះរាជបណ្ណាល័យចូលក្នុងស្ថាប័ននេះដែរ ដោយមានការសហការជាមួយរដ្ឋបាលបារាំង ។ ការបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ កាន់តែពង្រឹងជំហរសាលាបាលីជាន់ខ្ពស់ ជំនាន់នោះ ឱ្យកាន់តែមាំថែមទៀត ។ បន្ទាប់មកនា ឆ្នាំ ១៩៥៤ ក្រោយពេលឯករាជ្យជាតិព្រះបាទនរោត្តមស៊ីហនុបានបង្កើតភ្ជាប់ នឹងស្ថាប័នមុននេះនូវពុទ្ធិកសកលវិទ្យាល័យ ។

## ២_នាយកម្មអគ្គលេខាធិការវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៅក្រុងភ្នំពេញ

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យភ្នំពេញ ផ្តើមសម្ពោធនៅថ្ងៃ ១២ ឧសភា ១៩៣០ ។ អគ្គលេខាធិការទី១ គឺកញ្ញា ស៊ុយហ្សាន ការប៉ុឡែស ដែលជាអតីតស្ថាបនិក និងអភិរក្សព្រះរាជបណ្ណាល័យ និងជាតួមួយធំក្នុងការបង្កើតស្ថាប័ននេះនៅឆ្នាំ ១៩៣០ ។ កញ្ញារូបនេះ ស្រឡាញ់រាប់អានខ្មែរ និងព្រះពុទ្ធសាសនាជាទីបំផុត ហើយបានរៀបចំគណៈកម្មការបកប្រែព្រះត្រៃបិដក គណៈកម្មការវចនានុក្រម និងគណៈកម្មការបោះពុម្ពផ្សាយជាដើម ។ កញ្ញា ការប៉ុឡែស កាន់កាប់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យពីឆ្នាំ ១៩៣០ ដល់ ១៩៤១ នាងកញ្ញាបានចូលនិវត្តន៍ ហើយបានទៅរស់នៅប៉ុងឌីសេរី (Pondichèry) ក្នុងអាស្រមស្រីអូរូប៊ិនដូ រហូតដល់ពេលចូលអនិច្ចកម្មនៅឆ្នាំ ១៩៦៩ ។

អគ្គលេខាធិការ ពុទ្ធសាសនបណ្ឌិត្យទី ២ គឺលោកព្យែរ ឌុយប៉ុង (Pierre Dupont) ដែលបានឃើញតួនាទីនេះ នៅចន្លោះទំនេរក៏សុំរដ្ឋបាលបារាំងទទួលភារៈកិច្ច និងមុខងារនេះនៅខែសីហា ១៩៤១ ។ នៅសង្គ្រាមលោកលើកទី២ ជប៉ុនបានចាប់លោកនៅថ្ងៃទី ៩ មិនា ១៩៤៥ ឃុំឃាំងរវាងប្រាំខែ ជាមួយនឹងជន

ជាតិបារាំងឯទៀតនៅភ្នំពេញ ។ ពេលក្រោយសង្គ្រាមលោកនេះមកលោកព្បែរ ឌុយប៉ុង បានមកកាន់តំណែងវិញរហូតដល់ដាច់ឆ្នាំ ១៩៤៦ ។

នៅចន្លោះពីឆ្នាំ ១៩៤៦ ដល់ ១៩៥០ ពុទ្ធសាសនបណ្ឌិត្យឋិតនៅក្រោមការកាន់កាប់រដ្ឋបាលបារាំងៗ បានប្រគល់ជូនរដ្ឋាភិបាលខ្មែរនៅថ្ងៃ ១៤ តុលា ឆ្នាំ ១៩៥០ ដូចមានសេចក្តីបញ្ជាក់ក្នុងបញ្ជីសាស្ត្រា និងក្រាំងនៃស្ថាប័ននេះ ។

អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យខ្មែរ ដែលយើងស្គាល់ជាងគេនៅចន្លោះឆ្នាំ ១៩៥០ ដល់ ឆ្នាំ ១៩៧៥ គឺមានលោក ម៉ាំង បូរី[១] លោក លាង ហាប់អាន[២] និងលោក អ៊ុក សាម៉ន[៣] ។

*(នៅមានត)*

---

១- បិតាលោកជាព្រាហ្មណ៍នៅក្នុងបរមរាជវាំង លោកបានធ្វើអធិការបឋមសិក្សា រួចបានធ្វើជាអគ្គលេខាធិការ ពុទ្ធសាសនបណ្ឌិត្យ ។

២- ជាសាស្ត្រាចារ្យមធ្យមសិក្សាមធ្យមភូមិ លោកមានសញ្ញាប័ត្របរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរបានទទួលតំណែងជានាយកពុទ្ធសាសនបណ្ឌិត្យរវាង ឆ្នាំ ១៩៦៧ ហើយបានទទួលការតែងតាំងជារដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកខាងសាសនា ក្នុងរដ្ឋាភិបាល ដែលដឹកនាំដោយលោក អ៊ិនតាំ នៅថ្ងៃ ២២ តុលា ១៩៧៣

៣- នៅពេលដែលលោក លាង ហាក់អាន បានទទួលដំណែងជារដ្ឋលេខាធិការទទួលបន្ទុកផ្នែកសាសនានាឆ្នាំ ១៩៧៣ លោក អ៊ុក សាម៉ន មានបរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរធ្វើជាសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ បានទទួលតួនាទីជានាយកពុទ្ធសាសនបណ្ឌិត្យជំនួសលោក លាង ហាប់អាន តាំងពីឆ្នាំ ១៩៧៣ រហូតដល់ពេលខ្មែរក្រហមមកកាន់កាប់ប្រទេសកម្ពុជានាថ្ងៃ ១៧ មេសា ១៩៧៥ ។

# ព្រះរាម ឬព្រះរាមចន្ទ្រ

(តចប់)

ដោយ : ឆន់ ហ៊ិន

នៅក្នុងអាស្រមរបស់ឫសីវាល្មីកិ ព្រះនាងប្រសូតបានបុត្រភ្លោះ ដែលព្រះនាងប្រទាននាមថា ព្រះគុសៈ មួយ និងព្រះលវៈមួយ ។ ព្រះរាជបុត្រទាំងពីរព្រះអង្គទ្រង់ប្រកបដោយនូវព្រះលក្ខណសម្បត្តិសំខាន់ៗ ដូចព្រះបិតាជាច្រើន ។ លុះព្រះរាជកុមារទ្រង់ព្រះជន្មបាន ១៥ ព្រះវស្សា ព្រះអង្គទ្រង់ចង់យាត្រាកម្សាន្តលេង។ ទ្រង់យាងទៅដល់ក្រុងអយុធ្យា ជួនជាបានជួបព្រះបិតា ។ ព្រះបិតាទ្រង់ស្គាល់ព្រះរាជកុមារ ថាជាព្រះរាជបុត្របង្កើតរបស់ព្រះអង្គ ។ ព្រះរាមទ្រង់ក៏ទៅនាំព្រះនាងសីតាមកវិញ ដើម្បីព្រះនាងបញ្ជាក់សាជាថ្មី អំពីភក្តីភាពរបស់ព្រះនាងចំពោះព្រះអង្គ ។ ព្រះនាងប្រកាសពីភាពបរិសុទ្ធរបស់ព្រះនាងទាំងអំពាវនាវព្រះធរណីជាព្រះមាតារបស់ព្រះនាងធ្វើជាសាក្សី និងនាំយកព្រះនាងទៅវិញ ។ ព្រះធរណីចាប់ផ្ដើមប្រេះធំឡើងៗ រួចក៏ក្រសោបយកព្រះនាងទៅវិញបាត់ទៅ ។

ព្រះរាមត្រូវបាត់បង់ព្រះជាយាដ៏ជាទីស្នេហាតែមួយគត់របស់ព្រះអង្គ ។ ដោយទ្រង់មិនអាចទ្រាំរស់នៅតទៅទៀតបាន ព្រះអង្គក៏សម្រេចព្រះទ័យថាត្រូវតែក្ស័យព្រះជន្មទៅជាមួយព្រះជាយាដែរ ។ អស់ពួកទេពតាផងក៏ជួយ ព្រះរាជបំណងនេះបានសម្រេច ។ ព្រះកាលលេចចេញជារូបអ្នកសច្ចំមួយអង្គមករួចក៏សួរទៅ

ព្រះរាមថា "តើព្រះអង្គចង់គង់នៅលើផែនដី ឬឡើងទៅគ្រប់គ្រងពួកទេពតា នៅឯស្ថានសួគ៌ា ?" ។

ព្រះលក្ស្មណ៍ ព្រោះតែមានសេចក្ដីស្នេហាចំពោះព្រះរាមខ្លាំងពេកក៏សុំព្រះកាលអនុញ្ញាតិឱ្យព្រះអង្គក្ស័យព្រះជន្មជាជំនួសព្រះរាមវិញ ។ ព្រះលក្ស្មណ៍ក៏បានឡើងទៅកាន់ឋានសួគ៌ជារបស់ព្រះឥន្ទ្រាទៅ ។ ចំណែកឯព្រះរាមវិញព្រះអង្គយាងទៅកាន់ទន្លេសរាយុ ។ ក្នុងភាពដ៏សង្ហានិងឧត្ដុង្គឧត្ដមជាទីបំផុត ព្រះអង្គទ្រង់ឈានព្រះបាទាចូលទៅក្នុងព្រះគង្គា ព្រមជាមួយនឹងសំឡេងស្វាគមន៍របស់ព្រះព្រហ្ម ពីលើឋានសួគ៌ាមករួចក៏ទ្រង់យាងឡើងទៅគង់នៅឯឋានសួគ៌ារបស់ព្រះវិស្ណុវិញទៅ ។

ចំពោះឆាកចុងក្រោយនេះ មានប្រភពមួយនិទានប្លែកពីខាងលើនេះបន្ដិចថា ក្នុងខណៈ ដែលព្រះរាមបានជួបព្រះរាជកុមារទាំងពីរព្រះអង្គនោះ ដោយចៃដន្យ វាហាក់ដូចជាមានអ្វីមួយទូលថ្វាយព្រះអង្គទ្រង់ជ្រាប ។ ព្រះរាមក៏ទទួលស្គាល់ព្រះរាជកុមារថាជាបុត្ររបស់ព្រះអង្គ ។ ចំណែកឯព្រះនាងសីតាវិញក្រោយពីបានទទួលការក្រើនរំលឹកពីឫសីវាល្មីកិ ដែលបានជួយបីបាច់ព្រះនាង និងព្រះរាជបុត្រមក ព្រះនាង ក៏សព្វព្រះទ័យអនុគ្រោះចំពោះព្រះស្វាមី ដែលបានប្រព្រឹត្តមិនគប្បីមកលើព្រះនាង ។ ក្រោយពីក្សត្រទាំងអស់បានយាងត្រឡប់ទៅកាន់ ក្រុងអយុធ្យាវិញ ព្រះរាមទ្រង់ប្រារព្ធពិធីបូជាយញ្ញអស្វមេធមួយ ហើយទ្រង់គ្រប់គ្រងព្រះនគរក្នុងសេចក្ដីសុខសន្តិភាព សេចក្ដីសម្បូរណ៍សប្បាយ និងជាម្លប់ដ៏ត្រជាក់សម្រាប់អាណាប្រជានុរាស្ត្ររបស់ព្រះអង្គគ្រប់ស្រទាប់វណ្ណៈ ។

ការគោរពបូជាព្រះរាមនៅតែជាគ្រឹះដ៏រឹងមាំនៅឡើយ រហូតមកដល់ពេលបច្ចុប្បន្ននេះ ជាពិសេសប្រជាជននៃរដ្ឋពិហារ (**Bihar**)។ គួរកត់សម្គាល់ថា រឿងរបស់ព្រះរាមបានរក្សាទុក នូវភាពបរិសុទ្ធរបស់ខ្លួនជានិច្ច ខុសពីរឿងរបស់ព្រះព្រហ្ម, រឿងរបស់ព្រះសិវៈ ឬរឿងរបស់ព្រះក្រឹស្ណា ។ ហេតុនេះហើយទើបបានជាការគោរពបូជាព្រះរាម មិនបានទទួលការចុះថយនូវឥទ្ធិពលម្តងណា ឡើយ ។ ព្រះរាម និងព្រះជាយាជាជនពោរពេញដោយភាពបរិសុទ្ធបំផុត ដោយហេតុថាព្រះរាមជា *"ស្វាមីរបស់ភរិយាតែម្នាក់គត់"* ។ ព្រះនាមរបស់ព្រះអង្គត្រូវបានប្រជាជនឥណ្ឌាភាគច្រើនឧទានឡើង ដើម្បីជានិមិត្តរូបនៃសេចក្តីគោរព និងជាការបួងសួងចំពោះព្រះជាម្ចាស់ ។ គេតែងឧទានថា "**រាម! រាម!**" (អានតាមភាសា ហិណ្ឌីថា "រ៉ាម! រ៉ាម!") ដែលមានន័យមិនខុសគ្នាពីអ្នកកាន់ព្រះពុទ្ធសាសនាតែងឧទានថា "**ពុទ្ធោ!, ពុទ្ធោ!**" នោះឡើយ ។

រឿងរាមាយណៈ ជាវីរកថាមួយស្តីពីជីវិតផ្សងព្រេងរបស់ព្រះរាម (ព្រះរាមចន្ទ្រ) ដែលឫសីវាល្មិកិ បានចងក្រងឡើងជាពាក្យកាព្យជាភាសាសំស្ក្រឹត ហើយដែលគេចាត់ទុកជាវីរកថាដ៏ចាស់ជាងគេបំផុតនៃ អក្សរសាស្ត្រឥណ្ឌា ។ គេបានសន្មតថា កំណាព្យវីរកថានេះត្រូវបានទទួលការតាក់តែងចងក្រងឡើង ប្រហែលក្នុងសតវត្សរ៍ទី៥មុនគ្រិស្តសករាជ ឬមុននេះបន្តិច ហើយត្រូវបានសម្រេចទៅជារឿងដែលបានជារូបរាងដូចសព្វថ្ងៃនេះ ក្នុងរវាងមួយឬពីរសតវត្សក្រោយមកទៀត

គឺប្រហែលជាក្នុងសតវត្សទី៤ ឬទី៣ មុនគ្រិស្ត សករាជ ។ រឿងរាមាយណៈនិទាន អំពីដំណើរជីវិត និងវីរភាពរបស់ព្រះរាម អំពីសេចក្តីស្នេហាដ៏បរិសុទ្ធរវាង ព្រះរាម និងព្រះនាងសីតា ជាព្រះមហេសី អំពីការបំបរបង់ព្រះរាមឱ្យទៅរស់នៅក្នុងព្រៃអស់រយៈកាល ១៤ ឆ្នាំ អំពីក្រុងរាពណ៍ជាស្តេចយក្ស ស្តេចព្រាយបិសាច ស្តេចអសុរកាយនៅក្រុងលង្កា ចាប់ពង្រត់យកព្រះនាងសីតាទៅកាន់នគរវា អំពីសង្គ្រាមដែលព្រះរាមដឹកនាំឱ្យធ្វើប្រឆាំងនឹងក្រុងរាពណ៍ ដោយមានទ័ពពានរដឹកនាំដោយសុគ្រីពជាសម្ព័ន្ធមិត្តជួយព្រះអង្គផង ហើយសង្គ្រាមនោះត្រូវចប់ជាមួយនឹងការកម្ទេចពួកយក្ស ពួកព្រាយបិសាច និងការរំដោះព្រះនាងសីតាបានមកវិញ អំពីព្រះរាមយាងត្រឡប់ទៅកាន់ព្រះរាជធានីអយុធ្យាវិញ និងការរៀបចំធ្វើរាជាភិសេកថ្វាយព្រះអង្គ ឡើងគ្រងរាជសម្បត្តិ អំពីការប្រចណ្ឌរបស់ព្រះរាមលើព្រះនាង សីតាដែលជាហេតុនាំឱ្យព្រះរាមបំបរបង់ព្រះនាងចេញពីព្រះនគរ អំពីព្រះនាងព្រមទទួលយកការបំបរបង់នេះ ដោយទ្រង់យាងទៅរស់នៅឯព្រៃ ក្នុងសម្នាក់លោកតាឫសីវាល្មិកិ ហើយនៅទីនោះ ព្រះនាងប្រសូតបានបុត្រភ្លោះ ដែលទទួលព្រះនាមថាព្រះ**កុស:**មួយ និងព្រះ**លវ:**មួយ អំពីព្រះរាមទ្រង់ទទួលស្គាល់ព្រះរាជកុមារទាំងពីរព្រះអង្គថាជាបុត្របង្កើតរបស់ព្រះអង្គ អំពីការសុំឱ្យព្រះនាងសីតាយាងត្រឡប់មកក្រុងអយុធ្យាវិញ ដើម្បីឱ្យព្រះនាងសម្តែងពីភក្តីភាពរបស់ព្រះនាងចំពោះព្រះស្វាមី អំពីព្រះនាងសីតាទ្រង់សោយព្រះទិវង្គត ដោយព្រះធរណី ជាព្រះមាតាត្រូវយកព្រះនាងត្រឡប់ទៅវិញ តាមការអំពាវនាវរបស់ព្រះនាង ជាហេតុនាំ

ឱ្យព្រះរាមសព្វព្រះទ័យក្ស័យព្រះជន្មទៅតាមព្រះនាងផងដែរ ។

ឫសីដែលបានចងក្រងរឿងរាមាយណៈនេះ បានឱ្យតម្លៃខ្ពស់ណាស់ទៅលើរស ឬខ្លឹមសារនៃរឿង ។ វីរកថានេះនៅមានប្រជាប្រិយយ៉ាងធំធេងនៅឡើយ ។ នៅក្នុងសេចក្តីផ្តើមនៃរឿងរាមាយណៈ មានអត្ថបទ កំណាព្យរបស់កវីនិពន្ធមួយឃ្លាដែលមានន័យថា ÷

*"នរជនណាបានអាន និងបាននិទានប្រាប់គេ អំពីជីវិតបរិសុទ្ធនៅក្នុងរឿងរាមាយណៈ នរជននោះ នឹងបានរួចរំដោះផុតអស់ពីបាបកម្ម ហើយនឹងបានប្រកបដោយនូវក្តីបរមសុខ ក្នុងឥធលោក និង បរលោក"* ។

មានឃ្លាមួយទៀត ដែលគេចាត់ទុកថាជាបន្ទូលរបស់ព្រះព្រហ្មនុំះគឺ ÷

*"ដរាបណាគីរីបព្វតានៅតែឈរស្កឹមស្កៃ ទឹកទន្លេនៅតែហូរលើផែនដីដរាបនោះ* **រឿងរាមាយណៈ** *នៅតែស្ថិតនៅជាទីស្រឡាញ់ចូលចិត្តនៃមនុស្សលោកគ្រប់គ្នា ព្រមទាំងជួយស្រោចស្រង់មនុស្សលោកឱ្យរួច ផុតពីបាបកម្ម"* ។

ទស្សនៈជាបរម្បរាគតៗគ្នាមកបានឱ្យដឹងថា មហាឫសីវាល្មិកិបានសរសេររឿងរាមាយណៈ នៅក្នុងសម័យកាលដែល ព្រះរាមចន្ទ្រ នៅមានព្រះជន្មាយុ រស់នៅនៅឡើយ ។ ប្រសិនបើគេវិនិច្ឆ័យទៅតាមការពិសោធន៍ជា ប្រក្រតីគេអាចសន្និដ្ឋានបានថា រឿងរបស់ព្រះរាមបានកើតមានឡើងមែន ថ្វីបើមិនទាន់មានជាស្នាដៃសរសេរក៏ដោយ ។ រឿងនេះបានកើតមានតាំងពីយូរលង់ណាស់មកហើយ គឺតាំងពីមុនឫសីវាល្មិកិបានតាក់តែងនិពន្ធ ចងក្រងឡើងនោះផង ។ គេហាក់ដូចជាឃើញថា

លោកវាល្មីកិបានធ្វើឱ្យរឿងនិទានមួយកើតមានជារូបរាងឡើង ដែលត្រូវធ្លាក់ពីដៃមួយទៅដៃមួយទៀត ពីជំនាន់មួយទៅជំនាន់មួយទៀត ។ ព្រោះហេតុនេះហើយទើបបានជាគេមានឃើញវគ្គពិបាកៗខ្លះនៅក្នុងផ្ទៃរឿងទាំងមូល ដូចជាការសម្លាប់ក្រុងពាលី ការបំបរបង់ព្រះនាងសីតា ក្រោមព្រះរាជបញ្ជារបស់ព្រះរាម ។ នៅក្នុងស្នាដៃរបស់ឫសីវាល្មីកិ លោកបានពណ៌នាពីព្រះរាមថា មានលក្ខណៈដូចជាមនុស្សដ៏ឧត្តុង្គឧត្តមតែម្នាក់គត់មិនមែនដូចជាអវតាររបស់អាទិទេពទេ ។ ជាការពិតហើយដែលនៅក្នុងជំពូកខ្លះ គេឃើញមានការរំឭកពីព្រះអង្គថា ហាក់បីដូចជាអវតារមួយអង្គរបស់ព្រះអាទិទេព ។ ប៉ុន្តែ បើគេមើលនៅក្នុងផ្ទៃរឿងគេនឹងឃើញថាតាមការរៀបរាប់របស់ឫសីវាល្មីកិ ព្រះរាមមិនមែនជាអាទិទេពផ្ទាល់ព្រះអង្គឯងទេ ប៉ុន្តែទ្រង់ជាព្រះមហាក្សត្រដ៏ជាធំមួយព្រះអង្គ ដែលទ្រង់ប្រកបដោយលក្ខណៈសម្បត្តិដូចអាទិទេព ។

ទោះបីជានៅក្នុងសម័យ ដែលលោកតាឥសីវាល្មីកិមានព្រះជន្មរស់នៅក៏ដោយ ក៏នៅក្នុងកម្រិតណាមួយនោះ គេតែងគិតដោយភាគច្រើនថាព្រះរាមជាអវតារមួយអង្គ ។ កន្លងពេលអស់ជាច្រើនសតវត្ស ក្រោយមកទៀតលោកកម្ពននិងលោកតុល្សិទាស ក៏បាននិទានរឿងរាមាយណៈនេះឡើងទៀត ។ នៅពេលនោះឯង គេក៏ទទួលស្គាល់ថា ព្រះរាមគឺជាអវតារមួយអង្គរបស់ព្រះវិស្ណុ ។ ព្រះរាមនិងព្រះក្រឹស្នា គឺសុទ្ធតែជាព្រះវិស្ណុ ហើយនិយាយបកទៅវិញគេថា ព្រះវិស្ណុ គឺជាព្រះរាម និង ជាព្រះក្រឹស្នានេះឯង ។

ប្រាសាទទាំងឡាយ ក៏ត្រូវបានគេកសាងឱ្យកើតមានឡើង ព្រមជាមួយនឹងការគោរពបូជាព្រះរាម ដូចជាព្រះអាទិទេពទៅតាមប្រពៃណីនៃសាសនា ។ នៅក្នុងស្ថានភាពមួយដូច្នេះទៅហើយនោះ តើកវីនិពន្ធជំនាន់ក្រោយៗមកទៀតអាចពណ៌នាពីព្រះរាមថា គ្រាន់តែជាវីរជនមួយរូបលេងៗម្ដេចកើត? ការប៉ុនប៉ងពណ៌នាបែបនេះនឹងនាំមកនូវបរាជ័យជាមិនខាន ។ លោកកម្ពូន និងលោកតុល្សិទាសសុទ្ធតែជាអ្នកឧទ្ទិសខ្លួនដល់កម្រិតខ្ពស់ជាងគេបង្អស់ ។ លោកគឺជាមនុស្សដែលខុសស្រឡះពីអ្នកប្រវត្តិសាស្ត្រ និងពីអ្នកនិពន្ធ ប្រលោមលោក ។

រឿងរាមាយណៈបានចាប់បដិសន្ធិឡើង ដូចតទៅនេះ ÷

ក្នុងកាលគ្រាវេលាព្រឹកព្រាងមួយនោះ មហាឫសីនារទៈបាននិមន្តទៅលេងនៅឯអាស្រមរបស់លោកតាឫសីវាល្មីកិ ។ បន្ទាប់ពីទ្រង់បានផ្ដល់ការស្វាគមន៍ចំពោះភ្ញៀវដ៏ឧត្តមនេះតាមទម្លាប់ និងសំណេះ សំណាលលេងបន្តិចមក ឫសីវាល្មីកិក៏សួរថា ÷

"ឱ! លោកមហាឫសីនារទៈ ជាអ្នកយល់ដឹងអស់ទាំងសព្វ ទាំងគ្រប់អើយ! សូមព្រះអង្គមេត្តាប្រាប់អាត្មាមកមើលថា ក្នុងចំណោមវីរជនទាំងឡាយនៃលោកយើងនេះ តើមាននរណាហ្ន៎! ដែលជាជនឧត្តុង្គឧត្តមជាងគេខាងគុណធមិ និងគតិបណ្ឌិតនុ៎ះ?"

ដោយទ្រង់យល់ច្បាស់ តាមឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះអង្គថា ព្រោះហេតុអ្វីក៏បានជាលោកតា ឫសីវាល្មីកិចោទសំណួរនេះឡើង នារទឫសីក៏ឆ្លើយទូលទៅឫសីវាល្មីកិថា ÷

"ពរ! ព្រះរាម គឺជាវីរជនដែលព្រះអង្គទ្រង់សួររកនុ៎ះ ។ ទ្រង់ប្រសូតចេញមកពីក្នុងត្រកូលព្រះសុរិយវង្ស ។ បច្ចុប្បន្ននេះ ព្រះអង្គកំពុងគ្រងរាជសម្បត្តិនៅក្នុងទីក្រុងអយុធ្យា" ។

បន្ទាប់មកនារទឫសីក៏និទានរឿងរបស់ព្រះរាម ដោយត្រួស១ប្រគេនឫសីវាល្មីកិស្តាប់ ។ លុះទ្រង់បានព្រះសណ្តាប់រឿងរបស់ព្រះរាមហើយ ឫសីវាល្មីកិក៏កើតការចាប់ព្រះចិន្តា ជាប់អារម្មណ៍យ៉ាងខ្លាំង ។ ទោះបីជាឫសីនារទបានចាកចេញផុតទៅវិញជាយូរយារណាស់ទៅហើយក៏ដោយ ក៏រឿងនេះនៅតែដិតដាមដក់ជាប់ពេញក្នុងអារម្មណ៍របស់ព្រះអង្គដែរ ។ ព្រះអង្គទ្រង់ចេះតែគិតមមៃទៅដល់រឿងនេះ នៅពេលដែលព្រះអង្គនិមន្តទៅកាន់ស្ទឹងតមាសៈ ដើម្បីនឹងទ្រង់ស្រង់ព្រះគង្គា ជាកិច្ចជម្រះនូវមន្ទិល នាវេលាព្រឹកនោះឯង ។

ក្នុងពេលដែលព្រះអង្គកំពុងនិមន្តតាមបណ្តោយមាត់ស្ទឹង ទ្រង់ក៏ប្រទះនឹងឈើមួយដើមដ៏ធំនៅជិតនោះ មានទាំងសត្វលលកមួយគូកំពុងប្រឡែងគ្នាលេងហើយយំឆ្លើយឆ្លងគ្នា ក្នុងក្តីសប្បាយរីករាយសម្រាប់ឆាកជីវិត និងសេចក្តីស្នេហារបស់ខ្លួន ។ រំពេចនោះ លលកឈ្មោលក៏ស្រាប់តែធ្លាក់ខ្លួនជ្រុះមកដល់ដី ដោយសារត្រូវនឹងព្រួញរបស់ព្រានប្រមាញ់ម្នាក់ ។ រីឯលលកញីកាលបើឃើញគូស្នេហារបស់ខ្លួនរើបម្រះនទៀលលើព្រះធរណីដូច្នោះហើយ វាក៏ទួញយំតាមធម្មជាតិរបស់វាគួរអាណិតអាសូរជាពន់ពេកណាស់ ។ កាលបើព្រះអង្គទ្រង់បានសង្កេតឃើញដូច្នេះហើយ ឫសីវាល្មីកិដោយអត់ទ្រាំមិនបាននឹងអំពើយង់ឃ្នងបែបនេះ ក៏ដាក់បណ្តាសាទៅព្រានប្រមាញ់នោះថា ÷

"ឱ!អ្នកប្រមាញ់! បំណាច់ដែលឯងបាញ់សម្លាប់សត្វលលកមួយក្បាលនេះ ជាគូស្នេហារបស់គេ ដែលកំពុងស្រឡាញ់គ្នាយ៉ាងប្តូរផ្តាច់នុំះ ឯងនឹងត្រូវដើរនិរាស ប្រាសព្រាត់សាត់អណ្តែតសែតអញ្ចង់ដាច់សង្វែង គ្មានផ្ទះសម្បែងនៅនិត្យអស់មួយ ជីវិតរបស់ឯងទៅចុះ!"។

ប៉ុន្តែមួយសន្ទុះក្រោយមក លោកតាបូសីក៏ភ្ញាក់ស្មារតីដឹងខ្លួនឡើងវិញ ។ ព្រះអង្គទ្រង់ព្រះតម្រិះពិចារណាអំពីមូលហេតុអ្វី ដែលញ៉ាំងព្រះអង្គទៅជាខឹងជ្រុល អីចឹងនោះថា ÷

"យី! ត្រូវអីហ្នំ! ដែលអញដាក់បណ្តាសាឱ្យអ្នកប្រមាញ់នោះ ? ហេតុអ្វីក៏បាន ជាអាត្មាអញបែរជាលុះ ក្នុងសេចក្តីរំភើបបែបហ្នឹង?"។

កាលបើព្រះអង្គទ្រង់រំលឹកនឹកឃើញឡើងវិញនូវពាក្យសម្តី នៃបណ្តាសារបស់ព្រះអង្គមកលោកតាបូសី ក៏កើតសេចក្តីចម្លែក អស្ចារ្យក្នុងព្រះទ័យទៅលើចង្វាក់នៃពាក្យពេចន៍នោះជាពន់ពេក ។ ព្រះអង្គយល់ឃើញថាសេចក្តី មេត្តា ករុណារបស់ព្រះអង្គបានកើតចេញជារូបរាងឡើងនៅក្នុងពាក្យស្លោកមួយ ដ៏សែនល្អសក្តិសម ។ ព្រះអង្គទ្រង់ព្រះតម្រិះថាឧប្បត្តិហេតុអម្បាញ់មិញ ទាំង ប៉ុន្មាននេះគឺជាចំណែកមួយនៃចំណង់របស់ព្រះអាទិទេពតែម្តង ។ បន្ទាប់ពីនោះ មកព្រះអង្គក៏បន្តនិមន្តទៅធ្វើចង្ក្រមភាវនា តាមទម្លាប់របស់ព្រះអង្គទៅ ។

នៅពេលដែលព្រះអង្គកំពុងបំពេញវត្តប្រតិបត្តិនេះ ស្រាប់តែព្រះព្រហ្មមុខបួនលេចចេញមកឃើញ ហើយមានព្រះបន្ទូលទៅកាន់ព្រះអង្គថា ÷

"សូមព្រះអង្គកុំខ្លាចអី ។ អ្វីៗទាំងអស់ដែលបានកើតឡើងអម្បាញ់មិញនេះ គឺដើម្បីផ្ដល់ព្រះអង្គ ផ្ដើមនិទានរឿងរបស់ព្រះរាមឡើង ។ ពី **សោក** ចេញទៅជា **ស្លោក** ។ គឺនៅក្នុងក្របខណ្ឌនៃពាក្យទាំងពីរនេះឯងហើយ ដែលព្រះអង្គត្រូវនិទានរឿងនេះឡើង ។ យើងសូមផ្ដល់ឱ្យព្រះអង្គឯងនូវទស្សនវិស័យមួយ ដើម្បីព្រះអង្គមើលឃើញអ្វីៗទាំងអស់ ដែលកើតមានឡើងនុ៎ះអើ! រហូតដល់ព្រះអង្គគិតឃើញ ឬក៏ចាត់ទុកតួអង្គទាំងឡាយថាដូចម្ដេចៗ នុ៎ះច្បាស់ទែងហាក់បីដូចជាមនុស្សម្នាក់កំពុងមើលឃើញរបស់មួយ ដែលកំពុងស្ថិតនៅក្នុងទូកដៃរបស់ខ្លួនអីចឹងណ៎ា! ។ ហើយព្រមជាមួយនឹងពរសព្ទសាធុការរបស់យើងព្រះអង្គត្រូវតែនិទានរឿងនេះឡើង ដើម្បីជាប្រយោជន៍ចំពោះមនុស្សម្នាផងទាំងឡាយ នៅក្នុងលោកនេះ" ។

ឫសីវាល្មិកិនិងសាវ័ករបស់ព្រះអង្គ ក៏នាំគ្នាទន្ទេញពាក្យស្លោកនេះ ទន្ទេញហើយទន្ទេញទៀត ព្រមទាំងបានផ្ចិតផ្ចង់នូវគំរូនៃពាក្យស្លោកនៅក្នុងអារម្មណ៍របស់ខ្លួនផង ។ បន្ទាប់មកឫសីវាល្មិកិទ្រង់ក៏ចាប់ផ្ដើមតាក់តែងចងក្រង **រឿងរាមាយណៈ** ឡើងនៅក្នុងក្របខណ្ឌនោះឯង ។ រួចហើយព្រះអង្គក៏បង្ហាត់បង្រៀនរឿងនេះ ដល់សិស្សគណទាំងអស់របស់ព្រះអង្គទៅ ។

គឺដោយហេតុដូច្នេះឯងហើយ ដែលរឿងរាមាយណៈរបស់លោកតាមហាឫសីវាល្មិកិ បានកើតចេញជារូបរាងឡើង ។ នេះឯងជារឿងព្រេងនិទានអំពីព្រះជាម្ចាស់ដ៏មានបុណ្យបារមី និងអំពីក្រុមព្រះញាតិវង្ស ដែលទ្រង់យោនយកកំណើតមកកើតជាមនុស្សលោក ហើយបានបង្កើតឡើងនូវ " **ឆន្ទៈ**" គឺក្បួនតម្រា

សិក្ខាវិន័យនៅលើភពផែនដី ដែលត្រូវបានលោកតាឫសីនិទានឡើង ដោយប្រើពាក្យពេចន៍ចងជាកំណាព្យដ៏សែន ពីរោះពិសារកអ្វីមកឧបមាប្រៀបផ្ទឹមពុំបាន ។ រីឯព្រះបន្ទូលរបស់ព្រះព្រហ្មក៏បានក្លាយទៅជាការពិត គឺ ÷

*"ដរាបណាគីរីបព្វតាទាំងឡាយនៅតែឈរស្កឹមស្កៃ ទឹកទន្លេទាំងឡាយនៅតែហូរ ដរាបនោះ រឿងរាមាយណៈ នៅតែស្ថិតនៅជាទីស្រឡាញ់ចូលចិត្តនៃមនុស្សលោកគ្រប់គ្នា ហើយនឹងជួយស្រោចស្រង់មនុស្សលោកឱ្យរួចផុតពីបាបកម្ម"* ។

*ការបំពានលើច្បាប់*

*តែងសម្លាប់ ប្រយោជន៍ខ្លួន ។*

ព្រះមហាសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយជោតញ្ញាណោ **ជួន ណាត**

# វិធីព្យាបាលតាមបែបខ្មែរបុរាណ[១]

ដោយៈ **មៀច ប៉ុណ្ណ**

មុនសម័យដែលក្បួនវេជ្ជសាស្ត្រមិនទាន់បានជ្រួតជ្រាប ទៅក្នុងសង្គមខ្មែរ បុព្វបុរសយើងមានវិធីព្យាបាលជំងឺម្យ៉ាង ដែលគួបផ្សំការប្រើឱសថបានមកពីសត្វ រុក្ខជាតិ និងសារធាតុផ្សេងៗទៀត ព្រមទាំងមានមន្តអាគមគាថា បន្ថែមមកលើឱសថទៀត។ មន្តអាគមច្រើនដកស្រង់មកពីព្រហ្មញ្ញសាសនាខ្លះ ព្រះពុទ្ធសាសនាខ្លះ ដែលអាចចាត់ទុកថាជាសម្ដីសក្តិសិទ្ធិរបស់ព្រះអាទិទេព សម្រាប់កម្ចាត់ និងបណ្ដេញពពួកអមនុស្សទាំងឡាយមាន ព្រាយបិសាច ល្បាក់សា អារក្ស អ្នកតា ... ជាដើម។ ការសូត្រសែកមន្តគាថាទាំងនេះជាធម្មតាច្រើនតែមានប្រើធូប[២] ឬទៀនអុជបិទនៅមាត់ផ្តិល និងកូរផ្លុំនៅក្នុងទឹក រួចរលាស់ទៅលើអ្នកជំងឺ។ ក្រៅពីនេះនៅមានរបៀបជាច្រើនទៀតដូចជា ដាំថ្នាំសម្បក ឫស ឬស្លឹកឈើ យកមកឆ្លង់យកជាតិចំហាយផ្សេងដុតកម្លោចស្បែកត្រង់កន្លែងណាមួយត្រាំថ្នាំងូត ដុសថ្នាំសម្បកខ្យងខ្ចៅសមុទ្រ ឫសឈើ សម្បកឈើ បុកកម្ទេចសម្បកផ្លែឬស្លឹករុក្ខជាតិផ្សេងៗយកមកបិទលើផ្នែកណាមួយនៃរាងកាយ។ បុព្វបុរសយើងធ្លាប់ជឿតៗគ្នាមកថា បើប្រើឱសថតែមួយមុខ

---

១-លោកតា គីម ផង់ អាយុ៨៦ឆ្នាំ នៅភូមិខ្ទារ ឃុំព្រៃអំពក ស្រុកគីរីវង្ស ខេត្តតាកែវ គាត់ជាគ្រូព្យាបាលជំងឺបែបឱសថបុរាណ និងបានផ្តល់បទសម្ភាសន៍ដល់យើងខ្ញុំអំពីកលារព្យាបាលជំងឺផ្សេងៗ ដោយប្រើឱសថគួបផ្សំជាមួយមន្តអាគម។

២-ធូប៣ ឬ៥សរសៃ។

ហើយពុំមានបាលីគាថាគួបផ្សំជាមួយទេ ហាក់បីដូចជាបាយគ្មានម្ហូបសម្លដូច្នោះឯង។ ឧទាហរណ៍ មុនដាំថ្នាំឱ្យអ្នកជំងឺ ផឹក គ្រូព្យាបាលតែងតែសូត្របាលី ដាស់ថ្នាំនោះ ឱ្យមានអានុភាពពូកែសក្តិសិទ្ធិមានជាអាទិ៍: **ឱមដាស់គី ដាស់គំ ទើបគ្រូប្រើ អញដាស់ដើមថ្នាំ** ... ។ល។

ជាបន្តទៅនេះ សូមបង្ហាញជូនអំពីបាលី និងឱសថកែរោគមួយចំនួនដូចមានខាងក្រោម :

## ១_ការព្យាបាលជម្ងឺក្តៅផ្សេងៗ

ឱ្យផឹកថ្នាំត្រជាក់ រួចហើយត្រូវសូត្រគាថាអថ៌ន ផ្លុំអ្នកជំងឺឱ្យត្រជាក់ដូច្នេះថា: **ពុទ្ធមធុ ពុទ្ធសាវ នម បានខខេ ឱមិលល**។

## ២_ថ្នាំក្រឡាភ្លើង

-ឈាមទាសម្បុរ ស

-មើមខ្ទឹមស ៧កំពិស

-ម្រេច ៧គ្រាប់

យកមើមខ្ទឹមស និងម្រេចបុកលាយគ្នា រួចយកមកត្រាំនឹងស្រា លាយជាមួយឈាមទា សឱ្យអ្នកជំងឺផឹក ដំបូងឱ្យផឹកតិចៗសិន...។

## ៣_ថ្នាំលាបព្យាបាលរោគតាអក

-ឫសក្អក់ទឹក (ស្មៅប្រាសាទ) បុកលាប។

-ក្បាលប្រហុកត្រីក្រាញ់ (ប្រហុកខួប) កម្លោចលាយប្រេងដូងរួចលាប។

-ស្លឹកស្វាយព្រៃ កម្មោចលាយជាមួយប្រេងដូងរួចលាប ។

ថ្នាំទាំងបីមុខខាងលើនេះ ត្រូវលាបដោយឡែកៗពីគ្នាតាមតែអ្នកប្រើចូលចិត្តថ្នាំណាក៏ប្រើថ្នាំនោះទៅ ។ ខ្ពរស្លា គល់ផ្កាវ ឫសរពាក់ (ដាំផឹក) ។

៤-បាលីសូត្របណ្តេញព្រាយក្រឡាភ្លើង

អដ្ឋិៗ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ បច្ឆសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មត្ថកេ មត្ថលុង្គំ ឧត្តីសាការំ ។

៥-បាលីបរកំរោល

-ឥន្ទទេវា

-ចុតិថានីតិ

៦-បាលីជួយឱ្យប្រសូតបានឆាប់រហ័ស

-សានំ គតទាតិ

-សានំ ពុទ្ធោ គតទាតិ

បាលីមួយបែបទៀត ឧម ហុល មាលា (សូត្រ៣ឬ៧ចប់) ។

៧-ថ្នាំព្យាបាលបូសអន្ទង់

ភក់បាតត្រពាំង. ឫសស្មោអំបោះ ឫសចក គល់រុន គល់ប្រី និងគល់កក់ មកបុកបញ្ចូលគ្នា បិទត្រង់កន្លែងមានកើតបូស ។

**៨- ថ្នាំព្យាបាលបូសអន្ទង (ថ្នាំផឹក)**

ស្លឹកម្រៀនស្រុក ម្ទម ដីអង្កាម ដីក្រសាំងទំហំ យកមកដាំស្ងោរផឹក ។

ក្រៅពីថ្នាំដូចបានរៀបរាប់ ខាងលើនេះ គង់នៅមានថ្នាំសម្រាប់ព្យាបាលរោគប្លែកៗជាច្រើនទៀតដែលខ្ញុំនឹងខិតខំស្រាវជ្រាវបន្ត ហើយសរសេរចងក្រងទុកជាក្បួន ឱ្យកូនចៅខ្មែរជំនាន់ក្រោយបានដឹងតទៅ ។

*លោកថាអាតូច មារយាទប៉ិលប៉ូច*

*បង្ហូចអាធំ ដូចនាយចៅហ្វាយ*

*មានបុណ្យស្តុកស្តម្ភ ខូចបុណ្យរលំ*

*ដោយសារចាវព្រាវ ។*

ព្រះធម្មលិខិត **ម៉ីខ សែស**

# ពិធីទាក់ដំរី របស់អ្នកស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

ដោយ ម៉ៅ សោភណ៍
រស់ សំណាង

ការផ្សាភ្ជាប់គ្នារវាងមនុស្ស និងធម្មជាតិ មនុស្ស និងជំនឿសាសនា ប្រពៃណីទំនៀមទម្លាប់ ចងភ្ជាប់សង្គមខ្មែរ មិនអាចស្រាយបាន។ ជាក់ស្ដែង គ្រាន់តែនៅក្នុងមុខរបរទាក់ដំរីតែមួយប៉ុណ្ណោះមានពិធីជាច្រើន ដែលត្រូវរៀបចំសែនព្រេនទៅតាមកិច្ចជាក់ស្ដែងនីមួយៗ។ ទាំងអស់នេះ បើតាមសម្រង់នៃការរៀបរាប់ត្រួសៗរបស់លោកតា ហ៊ាន ចាន់ ហៅ មឿន បច្ចុប្បន្នជាអាចារ្យវត្តព្រៃក្លុង ក្នុងភូមិព្រៃក្លុង ឃុំរកាត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ត្រូវជាកូនបង្កើតរបស់លោកតាឈ្មោះ ហ៊ាន អ៊ិត ជាហ្មដំរី និងត្រូវជាប្អូនជីដូនមួយនឹងហ្មប៉ៅ (ហ្មឆ្វេង) ហើយគឺជាហ្មជំនិតរបស់ហ្លួងព្រះបាទមុនីវង្ស ដែលគង់នៅក្នុងដំណាក់នាភូមិត្រពាំងជង ស្រុកបាកានខេត្តពោធិ៍សាត់ បានរៀបរាប់ប្រាប់ឱ្យដឹងថា :

នៅក្នុងពិធីទាក់ដំរី ត្រូវមានពិធីសែនព្រេនទៅតាមដំណាក់កាលនីមួយៗផ្សេងៗគ្នាដូចជា ពិធីផ្គាប្រកាំ ពិធីភ្នែនប្រកាំ ពិធីចូលដំណម ពិធីចាប់ទាម ពិធីចក់ប៉ារ៉ាស់ ពិធីចាប់ជើងប៉ារ៉ាស់ ពិធីចុះការ និងពិធីសែនផ្ដាច់ព្រៃ។

## ពិធីផ្គាប្រកាំ

ប្រកាំ គឺជាព្រ័ត្រ ដែលធ្វើឡើងដោយមានការប្រុងប្រយត្ន័ខុសពីព្រ័ត្រធម្មតា ព្រោះជាព្រ័ត្រពិសេស ដូចនេះដើម្បីវេញព្រ័ត្រប្រកាំ គេត្រូវរៀបចំពិធីសែន

ព្រេនអន្ទងព្រលឹងគ្រូ ឱ្យមកសណ្ឋិតថែរក្សាព្រ័ត្រជាមុនសិន ទើបចាប់ផ្តើម ក្នុងការរៀបចំវេញព្រ័ត្រប្រកាំ រីឯរណ្តាប់ក្នុងការរៀបចំសែនព្រេន មាន បង្អែម និងមានចំអាប ពីរស្លក ស្លាធម៌ដៃព្រៃមួយគូរ មាន់ស្ងោរមួយគូ ស្រាស្រេះ ឬដបមួយគូ នំអន្សមជ្រូក និងនំគមរៀបដាក់ថាសមួយគូ ក្រណាត់ស និងពងមាន់។ បន្ទាប់ពីរៀបរណ្តាប់រួចមក ហ្មចំគេយកស្បែកដែលចៀររួចហើយមកដាក់នៅពីមុខគ្រឿងសំណែនហើយអញ្ជើញហ្មឆ្នេង ឬហ្មថាវ ឱ្យមករៀបចំប្រសិទ្ធីពលីការសូត្រផ្លុំ បញ្ចូលគាថាទៅលើស្បែក ដែលត្រៀមនឹងវេញបញ្ចូលធ្លុងជាព្រ័ត្រមួយ។ ក្រោយពីហ្មចំ ហោមពិធីចប់សព្វគ្រប់ គង្វាល និងហ្មធម្មតាទាំងអស់ជួយគ្នាក្នុងការវេញព្រ័ត្រ បញ្ចូលធ្លុងដើម្បីងាយស្រួលក្នុងការវេញធ្លុងឱ្យបានណែនល្អ។ ជាធម្មតាព្រ័ត្រក្នុង មួយកន្ទុយៗគេនិយមប្រើពីប្រវែងម្ភៃទៅសាមសិបម៉ែត្រ។ ក្រោយពីស្បែកទាំងបី ត្រូវគេធ្លួញរួចហើយ ទើបគេចាប់ផ្តើមវេញធ្លួញទាំងបីបញ្ចូលគ្នាទៀត នៅដើមធ្លួញ គេដាក់ពងមាន់ឆៅមួយនៅកណ្តាល ធ្វើរបៀបនេះក្នុងដប់ម៉ែត្រដាក់ពងមាន់មួយ រហូតដល់ព្រ័ត្រត្រូវវេញចូលជាធ្លុងមួយរួចរាល់ជាស្ថាពរ។ ឯថាហេតុអ្វីទើបបានជាគេចាំបាច់ដាក់ពងមាន់ដូច្នេះនោះគឺគ្មានការអះអាងពិតប្រាកដអាចឆ្លើយបានឡើយ គឺធ្វើទៅតាមទម្លាប់ចាស់ៗប្រាប់តៗគ្នាមកតែប៉ុណ្ណោះ។ ចំពោះព្រ័ត្រប្រកាំសម្រាប់ទម័កដំរីនិងគង្វាលគឺគេគោរពបូជាជាទីបំផុត ដូចនេះហើយទើបប្រកាំនេះឯងគេឱ្យឈ្មោះរហូតដល់ទៅបី តាមកាលកំណត់នីមួយៗ ទីមួយនៅពេលមិនទាន់វេញជាធ្លុងគេហៅថាព្រ័ត្រ *ទពរ* នៅពេលវេញបញ្ចូលជាធ្លុងដោយមានហោមពិធីរួចរាល់គេហៅថា *ប្រកាំ* ទីបីនៅពេលគេនាំយកទៅព្រៃដើម្បីទាក់ដំរី គេឱ្យឈ្មោះមួយទៀតហៅថា *លោកគ្រូ*។ ពាក្យថា លោកគ្រូនេះ គឺមានអត្ថន័យបំផុតសម្រាប់ពួកគេគ្រប់ឧបសគ្គ

ដែលកើតមានឡើងនៅក្នុងពេលកំពុងបំពេញភារៈទម័កដំរី ហ្ម និងគង្វាល គេប្រយត្ន័ណាស់ទោះត្រូវប៉ះហ្វូងដំរីស្ដខ្លាំង តដៃប្រវាយទាញអូសព្រ័ត្រយ៉ាងណាក្ដីគង្វាល និងហ្ម ត្រូវតស៊ូការពារក្រាញនទៀល ធ្វើយ៉ាងណាមិនឱ្យដំរីព្រៃ វាទាញយកព្រ័ត្រទាំងកន្ទុយទៅទេ ទោះព្រ័ត្រត្រូវដាច់ជាប៉ុន្មានកំណាត់ក៏ដោយត្រូវតែបានខ្លះត្រឡប់មកវិញ នោះស្មើនឹងពាក្យថាស្មោះស្ម័គ្រនឹងគ្រូ។ ផ្ទុយទៅវិញបើដំរីព្រៃអូសយកព្រ័ត្រទៅបាត់ ហ្ម និងគង្វាលតស៊ូដណ្ដើមមកវិញមិនបាន នោះហ្ម និងគង្វាលនោះគេចាត់ទុកថាមិនបានការ មើលងាយគ្រូ បណ្ដាលឱ្យបាត់ ត្រូវទទួលទណ្ឌកម្មជាយថាហេតុក្នុងពេលក្រោយមិនខាន អាចនៅក្នុងឧបទ្ទវហេតុណាមួយក្នុងមុខរបរនេះ បើមិនស្លាប់ហ្ម ក៏ស្លាប់គង្វាលមិនលែងឡើយដោយគ្មានវិធីណាជួយស្រោចស្រង់ កែកុនបានឡើយ។

## ពិធីភ្នែនប្រកាំ

ក្រោយពេល ដែលប្រកាំត្រូវបាន គេវេញកើតជារូបរាងគ្រប់លក្ខណៈហើយព្រ័ត្រប្រកាំត្រូវរៀបចំឡើងនូវពិធីមួយទៀតឱ្យឈ្មោះថា "***ពិធីភ្នែនប្រកាំ***" ពិធីភ្នែនប្រកាំ គឺជាពិធីបន្ដភ្ជាប់ពីពិធីផ្ដាប្រកាំដែរ។ អំពីព្រ័ត្រប្រកាំសម្រាប់ហ្ម ស្រុកភ្នំក្រវាញគឺគេច្រើនប្រើប្រកាំមានប្រវែងពីម្ភៃម៉ែត្រទៅហាសិបម៉ែត្រ នៅក្នុងពិធីភ្នែនប្រកាំហ្មធំរៀបចំចាត់ចែងហ្មធម្មតានិងគង្វាលដែលមកចូលរួមជួយបន្លាយប្រកាំចែកជាពីរទៅតាមវែង ឬខ្លី ម្ខាងមួយក្រុម ហើយគេចាប់ផ្ដើមភ្នែន (ឆ្វាយរង្វេល) ដោយប្រើរង្វង់មុខកាត់មួយម៉ែត្រ ជាមួយនឹងការសូត្រប្រោះព្រំរបស់ហ្មធំ។ គេភ្នែនប្រកាំដោយការប្រុងប្រយត្ន័បំផុត ព្រោះខ្លាចពន្ទ័គ្នា ឬមិនត្រឹមស្មើល្អ អាចផ្ដល់ការលំបាកនៅពេលលើកដាក់លើខ្នងដំរីធ្លាក់ ម្យ៉ាងអាចមានការលំបាកនៅពេលទាក់ដំរី

ព្រៃ។ សូមបញ្ជាក់ថាប្រកាំនៅខាងកន្ទុយម្ខាងគេមានធ្វើឈើខ្មែងរបៀបស្នែងប្រើស ហៅថាកន្ទុយខ្ទុរ ងាយដាក់ភ្ជួរនឹងដីឱ្យរអូសទាក់ជាប់ទៅនឹងឫសឈើធំនៅពេលដែលដីរព្រៃវាអូសខ្លាំង នេះគឺជាមធ្យោបាយសម្រាប់ការពារមិនឱ្យខាត់គ្រួ។

មុខរបរទាក់ដីរព្រៃ គេច្រើនធ្វើឡើងនៅរដូវរំហើយ ខែកត្តិកមួយខែ និងខែពិសាខមួយខែប៉ុណ្ណោះ បើខុសពីខែនេះកម្រមានគង្វាលណាចេញទៅទាក់ដីរព្រៃណាស់ ព្រោះហ្វូងដីរព្រៃ វាមិនងាយនឹងចេញរកស៊ីទីវាលផ្ដេសផ្ដាសទេ។ ដូច្នេះកាលបើរដូវកាលមកដល់ហើយ ហ្មធំឬក៏ដង្កៅគេផ្ដើមរៀបចំចាត់ចែងឱ្យហ្មធម្មតា ឬគង្វាលបីបួននាក់ចេញទៅស៊ើបព្រៃជាមុនសិនគេមិនចុះព្រាវៗទេក្រោយពីបានទទួលដំណឹងច្បាស់ការហើយនោះ ទើបដង្កៅឬហ្មថាវ ប្រកាសប្រាប់ឱ្យហ្មធម្មតា និងគង្វាលទាំងអស់បានដឹងពីថ្ងៃកំណត់ចេញដំណើរនិងរៀបចំស្បៀងត្រៀមបម្រុងទុកជាស្រេចម្យ៉ាងសម្រាប់ទុកឱកាសឱ្យហ្ម និងគង្វាលទាំងអស់ត្រៀមខ្លួនរៀបចំពិធីចូលកាន់ត្រណម។ នៅក្នុងពិធីចូលកាន់ត្រណម មិនមានរៀបរណ្ដាប់សែនព្រេនអ្វីច្រើន ពោរពាស ឬធំដុំអធឹកអធមនោះទេ គេគ្រាន់តែមានរៀបចំស្លាធមិ ដូងទុំមួយគូរ ស្លាធមិដៃព្រៃមួយគូរ បារីប្រាំ ស្លាប្រាំ ទឹកមួយកែវ រៀបចំទុកដាក់នៅលើហ៊ីងតាមផ្ទះរៀងៗខ្លួន មិនច្រឡូកច្រឡំគ្នាទេ ប្រពន្ធហ្មម្នាក់ៗជាអ្នកថែរក្សាយ៉ាងស្ងៀមស្ងាត់ តឹងរ៉ឹងរហូតដល់ប្ដីត្រលប់មកពីគង្វាលវិញ ទើបធ្វើពិធីសែនចេញលែងកាន់ត្រណមបាន ។ សកម្មភាពទាំងនោះមាន :

**បម្រាមសម្រាប់ប្រពន្ធនៅផ្ទះ :**

-ហាមលាបប្រេងម្សៅ ធ្វើឱ្យព្រ័ត្រប្ដីនៅឯព្រៃរអិលទាក់ដីរមិនជាប់។

-ហាមយករើកជ្រោយបាយគងមាត់ឆ្នាំង ធ្វើឱ្យឆ្មែងដើរទាក់ដីរមិនជាប់។

-ហាមដើរកន្លងទីដំណេកប្ដី( ទាំងប្រពន្ធ និងកូនអ្នកផង) ធ្វើឱ្យជួបសត្វសាហាវ។

-បើភ្ញៀវមកលេង ត្រូវស្រែកហៅពីចម្ងាយ ទើបអនុញ្ញាតឱ្យឡើងផ្ទះ ជៀសវាងឡើងជួបវាក់មុខគ្នាដោយគ្មានដំណឹង ប្ដីនៅឯព្រៃនឹងដើរទៅវាក់ជួបនឹងសត្វសាហាវដោយគ្មានដំណឹងដូចគ្នា។

-ដណ្ដាំបាយមិនត្រូវយករងើកភ្លើងគោះគ្នា ដីរដែលទាក់បានពីព្រៃ នឹងកើតជម្ងឺបាក់ក្រចក។

-ហាមអង្គុយពាំងមាត់ជណ្ដើរ ដូចគ្នានឹងយកវែកបាយគងមាត់ឆ្នាំង។

-ហាមប្រពន្ធមានសាហាយ ហ្មនៅឯព្រៃមិនមានគ្រោះថ្នាក់អ្វីទេ ប៉ុន្តែដីរធ្លាក់វាចេះតែដើរខ្ទុតដី (ធ្វើរបៀបពាក់មេ) ទាំងនេះក៏រំខានដល់ការទាក់ដីរដែរ។

-ហាមប្រពន្ធលេងប្រឡែងគ្នាប្ដីត្រូវជួបហ្វូងដីរព្រៃដេញគ្នាផ្អើលរត់ពពាក់ពពូនរកចូលទៅជិតដើម្បីធ្វើការទាក់មិនបាន។

-ហាមជជែកទល់មុខគ្នា ដីរព្រៃវាមិនខ្លាចហ៊ានឈរទល់មុខនឹងធ្លាក់ដូចគ្នា។

កំហុសឆ្គងទាំងឡាយរបស់ប្រពន្ធ គឺមិនមានវិធានការណាមួយអាចជួយបញ្ចៀសបានឡើយបើកើតហើយគឺត្រូវតែប្រព្រឹត្តទៅតាមដំណើររហូតដល់ទីបំផុត។

**ត្រណមសម្រាប់ហ្ម ឬគង្វាល** (ជាជនស្ម័គ្រចិត្តទៅតាមហ្ម បើមានគ្រោះថ្នាក់អ្វីឪពុកម្ដាយមិនរករឿងទេ):

-ហាមដើរស្រែកច្រៀងជាពាក្យផ្ដោះផ្ដងស្នេហា រឺងរវ៉ាងនៅក្នុងព្រៃ។

-មិនត្រូវប្រើពាក្យច្រងេងច្រងាង សំដីអាសគ្រាម មិនស្គាល់ខ្ពស់ទាបនៅក្នុងព្រៃ។

-ហាមមុជទឹកប្រឡែងគ្នាធ្វើដូចសត្វទាលេងទឹក។

បើមានកំហុសដូចបានរៀបរាប់ទាំងបីចំណុចខាងលើនេះគេឱ្យឈ្មោះថាធ្វើឱ្យចង្រៃវាចូល ព្រោះម្រេញគង្វាល ដែលគេជឿថាជាអ្នកថែរក្សាព្រៃព្រឹក្សានោះគេលង។ កាលបើ វាលងហើយដូចជាអ្នកស្រែកច្រៀង នឹងត្រូវវក់ស្រែកឡូឡាគ្មានឈប់ឈរ បើមុជទឹកវិញគឺវក់វីក្នុងទឹកឈ្លក់ប្រកាច់ប្រកិន តែនៅតែធ្វើរបៀបនេះមិនព្រមឡើងគោកឡើយ អ្នកនិយាយផ្ដេសផ្ដាស នឹងត្រូវប្រកាច់ប្រកិននិយាយវក់វីបែកពពុះមាត់ (បានន័យថាបើខុសគឺឆ្កួត) ដើម្បីកែកុន វិធីដើម្បីស្រោចស្រង់អ្នកជម្ងឺបានគឺហ្ម ដែលជាហ្មធំក្នុងក្រុមចាត់គង្វាល ឬហ្មទៅជាមួយចាប់អ្នកជម្ងឺមកធ្វើឧបកិច្ចដូចជាធ្វើទណ្ឌកម្មវាយនឹងរំពាត់ ជូនវាយមួយរយរំពាត់ ទោសធ្ងន់ត្រូវប្រហារជីវិតសម្មតធ្វើយ៉ាងណាឱ្យអ្នកទោសស្លុតព្រមចុះចាញ់ ហើយហ្មធំប្រោះព្រំគាថា ដាស់ស្មារតី ទើបជាសុខស្រួលឡើងវិញ។ ការធ្វើបែបនេះគឺមានប្រសិទ្ធិភាពបំផុត តែបើមិនធ្វើឧបកិច្ចទេនោះ អ្នកជម្ងឺនឹងត្រូវឆ្កួតរហូតកែលែងបាន។

## របៀប និងដំណើរក្នុងការទាក់ដំរីព្រៃ

កាលបើដល់ថ្ងៃកំណត់ហើយក្រុមទ្រមាក់ដំរីធ្វើដំណើរតាមគ្នាជាក្បួនចេញពីភូមិ ក្នុងដំរីផ្ទាក់មួយក្បាលមានហ្មម្នាក់ និងគង្វាលម្នាក់នៅជាមួយគ្នាដោយភាពស្ងៀមស្ងាត់ បើអផ្សុកគេកម្រស្រែកច្រៀងណាស់ ព្រោះខ្លាចខុសត្រណម ដូចនេះគង្វាលណាក៏ដូចគង្វាលណា ស៊ុងតែចេះផ្លុំប៉ីពក ប៉ីអរ គ្រប់គ្នាដើម្បីកំដរអារម្មណ៍។ នៅពេលទៅដល់ព្រៃដែលជាទីសម្គាល់ថាមានដំរីព្រៃហើយ គេមិនចូលទៅជិតរំខាន

នោះទេ ហ្មធ្វេងគេចាត់ឱ្យរៀបចំបោះជំរុំស្នាក់នៅជាទីប្រាកដប្រាជាសិន ហើយភារកិច្ចទាំងអស់ គឺគង្វាលជាអ្នករ៉ាប់បម្រើដូចជាធ្វើរោងសម្នាក់ គង្វាលធ្លាក់រៀបចំចាត់ចែងដណ្តាំបាយស្លស្លុក បាយហូបក្រោយហ្ម ដេកក៏មិនអាចដេកឱ្យស្មើនឹងហ្មបានដែរ ។ របៀបទាក់ដំរីនៅខេត្តពោធិ៍សាត់គេច្រើនរៀបចំទាក់នៅពេលយប់ ព្រោះស្រួលលបទៅជិតហ្វូងដំរីព្រៃ ម្យ៉ាងទៀតធ្លាក់ក៏ត្រូវជ្រើសរើសយកជើងដែលពូកែៗដែរ ។ ដើមឡើយ នៅខេត្តពោធិ៍សាត់ ធ្លាក់ដែលពូកែ មានតែប្រាំក្បាលគត់គឺ ÷

១-ដំរីធ្លាក់ឈ្មោះ **មេដកម៉ៃ** ធ្លាក់របស់ឈ្មោះ ហ្ម **ហ៊ុន សុគម** មេឃុំរកាត ។

២-ដំរីធ្លាក់ឈ្មោះ **អាស្ពង្ក** ធ្លាក់របស់ឈ្មោះ ហ្ម **ចៅ** ( ជាហ្មថាវ)

៣-ដំរីធ្លាក់ឈ្មោះ **មេភន្ទន់** ធ្លាក់របស់ឈ្មោះ ហ្ម **ចាំល** ( ឪពុកហ្មប៉ៅ)

៤-ដំរីធ្លាក់ឈ្មោះ **អាភេ្សម** ធ្លាក់របស់ឈ្មោះ ហ្ម **ចឹក** ហៅ ដង្កៅកាទឹម

៥-ដំរីធ្លាក់ឈ្មោះ **អាស្រទំ** ធ្លាក់របស់ឈ្មោះ ហ្ម **មឿន** (លោកតាហង់ មឿន) គឺជាធ្លាក់ដូរបានមកពីខេត្តកំពង់ស្ពឺ ដំរីធម្មតាបួនដូរបានដំរីធ្លាក់នេះ១ ។

ពេលយប់ ហ្មទាំងអស់គ្នា និងគង្វាលត្រូវសម្រាករង់ចាំស្តាប់សន្ទឹក និងសម្រែកហ្វូងដំរីព្រៃ កាលបើបានឮហើយ ទើបគេយកជើងឈូសហៅគ្នា ( គេមិនយកដៃកេះទេ) ស្រែកប្រាប់គ្នាថា " **ឆាប់ឡើងឡើយ! លោកមានព្រះឱសហើយ** " នោះទើបហ្ម និងគង្វាលទាំងអស់ចាប់លើកប្រកាំដាក់លើខ្នងធ្លាក់ ហើយស្រូតដំណើរទៅកាន់ទីដែលបានឮសម្រែកមេហ្វូងដំរី ។ ទាំងអស់គ្នាគឺស្តាប់តែហ្មថាវ ឬហ្មធ្វេងដែល ដឹកនាំទៅម្នាក់គត់ ហើយការលបទៅជិតទៀតសោតគេមិនចូលពីលើខ្យល់ទេ គឺគេទៅពីក្រោមខ្យល់ ព្រោះដំរីពូកែស្រង់ខ្លិនណាស់ ។ នៅពេលចូលទៅបានកៀក

ហើយ ហ្មទាំងអស់ត្រូវបញ្ជាផ្ទាក់រៀង១ខ្លួនឱ្យបោលសម្រុកចូលទៅទាក់យកកូនបា-រ៉ាស់ណាមួយ ដែលហ្មមានបំណងចង់បាន គេមិនទាក់យកមេដំរី ឬដំរីធំពេញកម្លាំងពេកនោះទេ ព្រោះវាពិបាកនឹងទាក់ ម្យ៉ាងទាក់បានមកហើយពិបាកនឹងបន្សាំង គេច្រើនទាក់យកដំរីស្ទាវមួយប្អូន។ នៅពេលផ្ទាក់កំពុងគក់សម្ពុតកូនបារ៉ាស់ហ្មត្រូវយក **ខត** រុញប្រកាំបញ្ចូលទៅក្នុងជើងកូនបារ៉ាស់ភ្លាម ពេលនោះអ្វី១គឺមិនប្រក្រតីឡើយ ជូនទាក់ជាប់ជើងកូនបារ៉ាស់ហើយ មេដំរីចូលមកប្រយុទ្ធនឹងផ្ទាក់ដើម្បីដណ្តើមកូនរបស់វាវិញក៏មាន ដូចនេះជាហេតុធ្វើឱ្យកូនបារ៉ាស់ ដែលកំពុងត្រូវផ្ទាក់សម្ពុតប្រាសរត់គេចទៅទាំងប្រកាំនៅជាប់នឹងជើង ពេលនោះគង្វាលត្រូវតែឆ្លាត កាលណាកូនបារ៉ាស់វារត់នាំយកទាំងប្រកាំទៅ គង្វាលត្រូវលោតចុះ ហើយកាន់កន្ទុយខ្នុររត់យកទៅចងនឹងគល់ឈើធំណាមួយ ឬបើគ្មានដើមឈើអាចចងបាន គេត្រូវយកកន្ទុយខ្នុរដាក់ភ្ជួរដីរបួតដល់ទាក់ជាប់នឹងឬសឈើណាមួយ ទើបរកវិធីកែកុនផ្សេងទៀតដើម្បីចងទុកឱ្យបាន នេះគឺជា**វិធីគស្ទដើម្បីការពារគ្រូ** ហេតុការណ៍ទាំងអស់កម្រនឹងកើតមានណាស់ បើមានគឺកើតមកពីការកាន់ត្រណមមិនបានរបស់ប្តីឬប្រពន្ធហ្មនិងគង្វាលណាមួយប៉ុណ្ណោះ។

កាលបើចង ឬទាក់ដំរីបារ៉ាស់ជាប់នឹងគល់ ឬឫសឈើណាមួយហើយ គេបង្ហុកស្នែងប្រមូលគ្នាភ្លាមដើម្បីយកផ្ទាក់មកគាបកូនបារ៉ាស់ធ្វើពិធី **ចាប់ទាម**។ ក្នុងពិធីចាប់ទាម គេមិនរៀបសំណែនសែនព្រេនទេ ព្រោះវាជាកិច្ចការមួយចាំបាច់និងបន្ទាន់ កាលបើផ្ទាក់មកជួបជុំគ្នាហើយ (គេប្រើផ្ទាក់បួន) សម្រាប់ការពារដាក់ជុំវិញកូនបារ៉ាស់ មុខមួយ ក្រោយមួយ ចំហៀងស្តាំមួយ ចំហៀងឆ្វេងមួយ ដើម្បីចាប់ទាមចូលទៅក្នុងកកូនបារ៉ាស់ ហើយដោះយកប្រកាំចេញពីជើង។ ព្រ័ត្រទាម ដែលចងនឹង

កកូនបារ៉ាស់ត្រូវចងមិនឱ្យដោះមិនរួច តែអាចបង្វិលបានធូរល្មម ហើយឱ្យធ្លាក់ទាំងបួន បរកៀងអូសទៅចងទុកនឹងគល់ឈើណាមួយដែលយើងសង្ឃឹមមិនអាចនឹងបាក់ងាយនៅពេលកូនបារ៉ាស់វារើ ។មួយវិញទៀតនៅពេលដែលគេយកកូនបារ៉ាស់ទៅចងជាប់នឹងគល់ឈើហើយ គេផ្តើមពិធីមួយទៀតហៅថា **ពិធីចក់បារ៉ាស់** ពិធីចក់បារ៉ាស់មានន័យថាជាពិធីចងបង្អត់ស្មៅបង្អត់ទឹកចំពោះកូនបារ៉ាស់ ។ គេធ្វើរបៀបនេះចំនួនប្រាំថ្ងៃក្នុងមួយយប់ មួយថ្ងៃ គេធ្វើពិធីប្តូរម្តង គឺប្តូរពីដើមឈើមួយទៅដើមឈើមួយទៀត គេធ្វើរហូតដល់កូនបារ៉ាស់ទន់ ក (ចុះខ្សោយកម្លាំង) នេះសម្រាប់កូនបារ៉ាស់ដែលខ្លាំង. កូនបារ៉ាស់ខ្សោយ អាចតែត្រឹមបីថ្ងៃទេទន់កហើយ ។ នៅពេលកូនបារ៉ាស់ទន់ក ហើយទើបគេអាចប្រើធ្លាក់អូសកូនបារ៉ាស់មកផ្ទះបានភាគច្រើនក្នុងការទាក់ដំរីគេមិនមែនទាក់យកតែមួយហើយត្រឡប់មកផ្ទះវិញនោះទេគេច្រើនទាក់នៅពេលយប់ ហើយយកមកធ្វើពិធីចក់បារ៉ាស់នៅពេលថ្ងៃ លុះដល់យប់គេចេញទៅទាក់ទៀតធ្វើរបៀបនេះរហូតបានដំរីច្រើនតាមប្រាថ្នាហើយទើបគេនាំយកមកផ្ទះម្តងក្នុងម្តងអាចទាក់បាន ពីបួនទៅប្រាំក្បាលចំពោះហ្វូដែលពូកែ ។

កូនបារ៉ាស់ទាំងឡាយ ដែលត្រូវបានគេដឹកយកមកពីព្រៃ មកដល់ស្រុកហើយ គេត្រូវធ្វើពិធីពង្រាបវា ដោយឱ្យឈ្មោះថា **ពិធីចាប់ខឹង** ។ ជាដំបូងគេត្រូវជ្រើសរើសរកទីកន្លែង វាលល្អ ដែលមានដើមឈើពីរដើម ធំល្មមមានចម្ងាយពី ពីរទៅបីម៉ែត្រ បើគ្មានគេគ្រាន់តែរើសរកទីវាលហើយយកសសរពីរដើម មកជីកកប់ឱ្យមាំទាំជនូស រួចគេយកឈើពីរចម្រៀកទៀតទំហំមុខកាត់ ០.១៥ម x ០.១៥ម ចងបណ្តោយធ្វើឃ្នីង (*បង្កាបបណ្តោយឈើមួយ ក្រោមមួយ ដោយបាន់ស្មានតម្រូវមួយដាក់ត្រឹមពោះកូនដំរីបារ៉ាស់ និងមួយទៀតដាក់ត្រឹមខ្នង* " ទីនោះគេឱ្យឈ្មោះថា

ទីបន្សាំង។ បច្ចុប្បន្នទីបន្សាំងគេច្រើនធ្វើថែរក្សាទុកជាស្រេច ហើយកំណត់ជាកម្ម-សិទ្ធិ។ ឧទាហរណ៍ ទីបន្សាំងរបស់ហ្មបោ៉ ។ល។ នៅក្នុងពិធីចាប់កូនបារ៉ាស់គ្រឿងសំណែននៅក្នុងពិធីមាន ស្លាធមិដៃព្រៃមួយគូ មាន់ស្ងោរមួយគូ បាយសម្លពីរស្លុកបង្អែម នំគម នំអន្សមជ្រូក ស្រាតាមលទ្ធភាពដែលមាន។ ប៉ុន្តែប្រសិនបើមានគង្វាលណាម្នាក់ចង់ក្លាយខ្លួនទៅជាហ្ម ដោយចង់ចាប់យកមុខរបរនេះពិតប្រាកដនោះរណ្តាប់រៀបមួយជាពីរ ព្រោះត្រូវអញ្ជើញហ្មធំ (ហ្មចាវ ឬហ្មឆ្វេង) ចូលរួម ដូចនេះគេឱ្យឈ្មោះមួយទៀតថាជា **ពិធីចុះការ** ព្រោះជាពិធីបញ្ចើ និងពិធីនេះធ្វើឡើងស្មើនឹងពិធីធ្វើធ្មេញបំពេញលក្ខណ៍ក្នុងពិធីមង្គលការដែរ ជាពិធីបំពេញសិទ្ធិគង្វាលឱ្យទៅជាហ្មធម្មតា តែខុសត្រង់ថាការរៀបចំបំពេញល័ក្ខណ៍កូនក្រមុំក្នុងពិធីជាមង្គលគេយកលក្តិជុំក្រឡង់បុកលាបលើធ្មេញកូនស្រីឯហ្មដ៏រីវិញគឺហ្មជាធំ យកអាចម៍កូនដំរីបារ៉ាស់ និងបន្លាគ្រប់មុខប្របាច់លាយគ្នា ពូតជាបីពំនូត មកបញ្ចុកក្នុងមាត់ហ្មថ្មីឱ្យទំពារស៊ី ដើម្បីបំពេញកិច្ចបញ្ជាក់ឱ្យហ្មថ្មីដឹងថាចាប់ពីថ្ងៃនេះទៅរស់ជាតិនៃដំរីគឺយើងបានភ្លក់រួចហើយប្រកបដោយបទពិសោធន៍។ ចប់ពិធីចុះការនេះហើយទើបគេចាប់ផ្តើមកិច្ចនៃពិធីចាប់ជើងកូនបារ៉ាស់បន្ត។ របៀបចាប់ជើងកូនបារ៉ាស់ ជាដំបូងគេយកដំរីធ្លាក់ដឹកកូនបារ៉ាស់ចូលមកកន្លែងបន្សាំង ដោយធ្វើយ៉ាងណាឱ្យវាឈរអែបនឹងឈើឃ្នឹង ដើម្បីហ្មងាយនឹងយកព្រ័ត្រចងកូនបារ៉ាស់ភ្ជាប់នឹងឃ្នឹង រួចហើយគេយកព្រ័ត្រខ្លីមួយទៀតមកចងជើងមុខម្តងមួយៗ ហើយធ្លឹងភ្ជាប់គ្នាល្មមអាចដើរបានតិចៗ រួចគេចងជើងខាងក្រោយ ធ្វើរបៀបដូចជើងខាងមុខម្តងទៀត។ ក្រោយពីចងជើងមុខក្រោយរួចរាល់ហើយ គេផ្តើមស្រាយខ្សែព្រ័ត្រនឹងកចេញ ហើយលែងវាឱ្យដើរទៅតាមតែចិត្តវាចង់ទៅ។ ក្នុងរយៈពេលពេញមួយយប់មួយថ្ងៃ ទើបម្ចាស់បរធ្លាក់ចេញ

ទៅរកចាប់កូនបារ៉ាស់មកវិញ ហើយផ្ដើមយកព្រ័ត្រទាក់ក រួចស្រាយទន្នឹងជើងចេញ ម្ដងនេះគេមិនត្រឡប់មកកាន់ទីបន្ទាំងចាស់វិញទេ គេត្រូវរកទីកន្លែងថ្មីនៅក្នុងព្រៃ ដើម្បីធ្វើទីបន្ទាំង ហើយបង្រៀនចាប់ជើងដូចកាលលើកដំបូងគេធ្វើរបៀបនេះពេញ មួយឆ្នាំរហូតទាល់តែវាទៅជាទម្លាប់ គ្រាន់តែហ្មលើកទន្នឹងបង្ហាញ វាលើកជើងដាក់ ចូលដោយខ្លួនវាភ្លាមមិនបាច់បង្ខំ ។ក្នុងការបន្ទាំងសម្រាប់អ្នកស្រុកភ្នំក្រវ៉ាញគឺគេធ្វើ ទៅតាមសម្រួល មិនវាយដំខ្លាំងក្លាទេ តែសំខាន់គឺមិនឱ្យវាស៊ីនិងផឹកច្រើនទេ គេឱ្យ វាស៊ីនៅពេលដែលវាព្រមចូលទន្នឹងដោយស្រួលដើម្បីលើកទឹកចិត្តវា ។ ក្រោយពីដំរី បារ៉ាស់វាសាំងអាចធ្វើអ្វីបានតាមការបង្រៀនហើយនោះ ហ្មដំរីត្រូវរៀបចំពិធីមួយ ទៀតជាពិធីចុងបញ្ចប់នោះគេឱ្យឈ្មោះថា **ពិធីសែនផ្ដាច់ព្រៃ** ។ រាល់ដំរីទាំងឡាយ ដែលទាក់បានមក សម្រាប់អ្នកស្រុកភ្នំក្រវ៉ាញ គេអាចលក់ឬដូរបន្តបានដ៏រាបណាគេ ប្រារព្ធពិធីសែនផ្ដាច់ព្រៃជាមុនទើបយកទៅប្រើការបាន ។ ក្នុងហ្វូងដំរីមានពីរប្រភេទ ចែកដាច់ពីគ្នាគឺ ហ្វូងដំរីស្ដ និងហ្វូងដំរីភ្លុក ដំរីស្ដគឺជាក្រុមដំរីដែលមានដុះត្រឹមចៃ( ដូច ភ្លុកដែរតែខ្លីហើយតូចប្រវែងប្រមាណបីទៅបួនតឹកប៉ុណ្ណោះ) តាំងពីតូចរហូតដល់ធំគឺ មានតែចៃ ឈ្មោលក៏មាន ញីក៏មាន ។ រីឯដំរីភ្លុកក៏ដូចគ្នាដែរ ឈ្មោលក៏មានភ្លុក ញីក៏ មានភ្លុក ភ្លុកគឺដុះចេញមកជាភ្លុកតែម្ដង ។ ចំណែកឯហ្វូងដំរី មេដែលគ្មានកូនវិញគេ ឱ្យឈ្មោះថា **មេគន្ធរលោត** ។ ដំរីធម្មតាមានកូនតពូជពង្ស ដូចគោក្របីដែរគឺវា មិនមានកើតកូនម្ដងច្រើនទេ វាកើតក្នុងម្ដងមួយ១ជាធម្មតា ។

តាំងពីដើមរៀងមក ក្នុងជីវភាពសង្គមខ្មែរគេតែងគិតជានិច្ចពីអំពើអាក្រក់ ឬល្អ ត្រជាក់ត្រជុំ ឬមួយក៏ចង្រៃឧត្បាត គិតចាប់តាំងពីរបស់ប្រើប្រាស់ ផ្ទះសម្បែង ដីធ្លី សត្វធាតុដែលចិញ្ចឹមឡើងទៅយ៉ាងណាមិញសត្វដំរីក៏ដូចគ្នាដែរ ។ វាមិនខុសអំពី

គោឬក្របីទេ វាមានចំណុចសម្គាល់ លក្ខណៈល្អអាក្រក់របស់វាមានជាអាទិ៍។

**លក្ខណៈល្អរបស់ដំរី :**

*១-លក្ខណៈទ្រព្រះបាទ* : គឺដំរីវាមានទម្លាប់កាលណាម្ចាស់ប្រុងឡើងលើខ្នងវា គេស្រែកលើក(បញ្ជាឱ្យលើកជើង) វាលើកជើងមុខឆ្វេង ឬស្តាំ ដើម្បីឱ្យម្ចាស់ជាន់ឡើងលើខ្នងដោយយកប្រមោយ ទៅទល់ទ្របាតជើងវាឡើងទៀតផង។

*២-លក្ខណៈផាត់ប្រមូល* : គឺដំរីវាយកជើងឆ្វេង ឬស្តាំទៅឈូសដី ទៅមុខហើយយកប្រមោយបូងយកដីបោកមកលើខ្លួន បើបោកទៅចំហៀងខាងស្តាំខ្លួន គឺវាវាត់កន្ទុយវាផ្ទុបមកខាងស្តាំដែរ បើវាយកប្រមោយបោកទៅខាងឆ្វេង វាយកកន្ទុយបោកផ្ទុបមកខាងឆ្វេងដែរ។

*៣-នាងពូន* : សំដៅទៅលើស្នាមខ្ចងជ្រៅនៅលើស្បែក គេហៅថា (រណ្តៅខ្មោច) ប៉ុន្តែវាកើតមាននៅត្រង់កន្លែងអាថិកំបាំងណាមួយ ដែលមើលមិនឃើញដូចជា÷ គៀនត្រចៀក ក្រោមពោះ ស្បែកជើងមុខ ឬក្រោយ។

*៤-ក្រចកដប់* : ជាធម្មតាមនុស្សសត្វតែងមានលើស និងខ្វះជាធម្មតាប៉ុន្តែ សម្រាប់សត្វដំរីគេត្រូវរើសមើលដែរ បើមានលក្ខណៈត្រឹមត្រូវគ្រប់ចំនួននោះគឺពិតជាល្អ នាំសុខចម្រើនដល់ម្ចាស់ តែបើលើស ឬខ្វះក៏មិនជាចង្រៃអ្វីខ្លាំងក្លាដែរ។

**អំពីលក្ខណៈអាក្រក់របស់ដំរី :**

*១-កំចាយភាគ* : ជាទម្លាប់ គឺវាធ្វើអាការៈខុសធម្មតាដូចជា វាយកជើងឈូសដី ហើយយកប្រមោយកើបប្រមូលដីជះបាចទៅលើខ្លួន ហើយគ្រវែងរលាស់ខ្លួន (អាការៈគ្រវែងខ្លួនដូចសត្វឆ្កែ)។

*២-រងទុក្ខ* : មានសម្លាកសមួយដុំធំ ឬតូចនៅក្រោមភ្នែកមិនថាឆ្វេង ឬស្តាំទេ។

*៣-គៀងឃ្នាប* : មានស្នាមរណ្តៅនៅលើស្បែក ហៅថាខ្មោចដែរ ប៉ុន្តែវាមានពីរចាក់ស្របគ្នាដូចជា ÷ មានស្នាមរណ្តៅខ្មោចមួយនៅត្រង់ឆ្អឹងជំនីស្តាំ ហើយមានស្នាមរណ្តៅខ្មោចមួយទៀតនៅត្រង់ឆ្អឹងជំនីឆ្វេង ស្របគ្នាដូចស្នាមចាក់ធ្លាយពីម្ខាង ទៅម្ខាងដូច្នេះឯង។

*៤-យោលយក្ស* : នៅពេលត្រឡប់មកពីណាម្តង១ វាមិនឈប់នៅឈរស្ងៀមទេ វាធ្វើខ្លួនយោលទៅមុខបន្តិច ថយក្រោយបន្តិច ហើយក្បាលងាកឆ្វេងស្តាំ១ មិននៅមួយកន្លែងទេ។

*៥-ធាក់ស្រមោល* : នៅពេលឈប់ស្ងៀមម្តង១ វាតែងយកជើងក្រោយធាក់ទៅខាងដែលស្រមោលខ្លួនវាចាំងទៅជានិច្ចយូរ១ម្តង។

*៦-ជាន់លែង* : នៅពេលឈប់ស្ងៀមវាតែងរពឹស លើកជើងដូចបម្រុងឈានទៅមុខ តែវាបោះជើងទៅហើយបម្រុងនឹងដាក់ជាន់ តែវាដកមកវិញ ហើយជន្លធ្វើម្តងទៀតទើបវាជាន់។

*៧-ក្រេបសមុទ្រ* : ជាធម្មតាសត្វជីរ នៅពេលវាផឹកទឹកម្តង១ វាតែងយកប្រមោយបឺតយកទឹកបានហើយទើបវាព្រួសបញ្ចូលទៅក្នុងមាត់ តែវាមិនធ្វើដូច្នេះទេ គឺវាលត់ជង្គង់ឱនបឺតទឹកផ្ទាល់ដីតែម្តង។

## ការព្យាបាល និងជម្ងឺរបស់ដំរី :

ក្នុងដំណើរជីវិតរបស់សត្វដំរី គឺមានជម្ងឺបីប្រភេទ ដែលហ្មនិងគង្វាលចងចាំគ្រប់១គ្នាគឺ ÷

*១-ជម្ងឺរាគ* : ជម្ងឺរាគច្រើនកើតនៅលើដំរី នៅពេលដែលម្ចាស់វាឱ្យស៊ីនេះស៊ីនោះមិនរើស ជាហេតុបណ្ដាលឱ្យទាស់ចំណី ជម្ងឺប្រភេទនេះគេព្យាបាលដោយយកជ័រអាចម៍ល័ក្តជុំក្រឡង់ប៉ុនកូនដៃសៀតក្នុងដើមអំពៅ ឱ្យវាស៊ីនឹងជាហោង ។

*២-ជម្ងឺសា*: សា ជាជម្ងឺប៉ោងពោះ វាតែងកើតលើសត្វគោ ក្របី ដំរី សេះជាធម្មតា សម្រាប់ហ្មស្រុកភ្នំក្រវាញ គេមិនប្រើថ្នាំព្យាបាលទេ គឺគេប្រើអាគមគាថាទំពារ ស្លាស្តោះផ្លុំ ទៅលើសត្វវានឹងភ្ជាក់បាញ់អាចម៍មក ជាភ្លាម (បច្ចុប្បន្នមិនមានអ្នកចេះចាំបាលីនេះនៅសេសសល់ឡើយ) ។

*៣-ជម្ងឺសម្រុត* : សម្រុត គឺជាការស្រុតចុះ ថមថយនៃកម្លាំងសត្វ អាចបណ្ដាលឱ្យស្លាប់ខាន ជម្ងឺនេះច្រើនកើតទៅលើដំរីរបស់ហ្ម ឬដង្ហៅណាដែលចេះតែប្រើហើយមិនយកចិត្តទុកដាក់ថែវា ។ ជាការពិបាកសម្រាប់ការថែរក្សាសត្វដំរី ព្រោះថា បើយើងនឹងបំប៉នវាខ្លាំង វានឹងឡើងកម្លាំងខ្លាំងអាចទៅជាកើតជម្ងឺចុះប្រេងដែលជាការលំបាកក្នុងការបង្ក្រាប តែបើមិនយកចិត្តទុកដាក់បំប៉នវាទេនោះវានឹងកើតជម្ងឺសម្រុតស្លាប់បង់អាសាជាមិនខាន ។ ដូចមានដំរីរបស់ដង្ហៅ ជី ប្រពន្ធឈ្មោះ ដាំ( ទាំងពីរនាក់ស្លាប់) ត្រូវជាឪពុក-ម្ដាយលោកអាចារ្យសេង( បច្ចុប្បន្ននៅរស់) អ្នកដែលត្រូវដំរីដង្ហៅ ជី ចុះប្រេងជាន់ស្លាប់ឈ្មោះប៉ាង ហ៊ាន នៅភូមិរកាតឃុំរកាត ស្រុកភ្នំក្រវាញខេត្តពោធិ៍សាត់នេះគឺមកពីការធ្វេសប្រហែសរបស់ហ្ម និងដង្ហៅហើយដំរីទៀតសោតកាលនោះគ្មានហ្មណាអាចបង្ក្រាបបានឡើយ ក្រៅពីត្រូវទាហាន បារាំងស្ទាក់បាញ់សម្លាប់ ចោលបង់អាសា ។ សរុបសេចក្ដីមកបានន័យថា ការទាក់ដំរី និងប្រើប្រាស់ដំរីមិនមែនអាចធ្វើទៅបាន និងប្រើប្រាស់បានដូចជាសត្វដ៏ទៃៗទៀតឡើយ ។

---

អត្ថបទនេះ អ្នកស្រាវជ្រាវបានផ្ញើជូន អរិយធម៌ខ្មែរ លេខ ៨ មានបោះពុម្ពជាភាសាអាល្លឺម៉ង់

# ប្រវត្តិភូមិ

## បាយសំណុំ-កំពង់ស្វាយចេក-កំពង់ជើងពាត

(នៅឃុំកោះខ្មែរ ស្រុកសំបូរ ខេត្តក្រចេះ)

ដោយ : ជួប យាន

### ១-អំពីភូមិបាយសំណុំ

#### ក. ទីតាំង និងស្ថានភាពភូមិ

បាយសំណុំ ជាភូមិមួយស្ថិតនៅលើទឹកដីឃុំកោះខ្មែរមានចម្ងាយប្រមាណ បីគីឡូម៉ែត្រ ពីទីរួមស្រុកសំបូរ។ បើយើងជិះកង់ ឬម៉ូតូចេញពីវត្តសសរមួយរយ ទៅតាមផ្លូវមាត់ទន្លេឆ្ពោះទៅទិសខាងជើង ដោយឆ្លងកាត់ភូមិសំបូរ និងភូមិដូនមាស យើងនឹងប្រទះឃើញភូមិមួយ ស្ថិតនៅទន្ទឹមនឹងកូនកោះបាយសំណុំ។ ភូមិនោះហៅឈ្មោះថា " *ភូមិបាយសំណុំ* " ។

នៅក្នុងភូមិនេះបច្ចុប្បន្នមានប្រជាពលរដ្ឋរស់នៅប្រមាណ១២៧គ្រួសារ។ មុខរបរមូលដ្ឋានរបស់ប្រជាជននៅក្នុងភូមិនេះក្រៅពីធ្វើស្រែ-ចំការ គឺធ្វើស្ករត្នោត។

#### ខ. ប្រវត្តិនាមភូមិ

ឆ្លងតាមបទដំណាលតៗគ្នារបស់ចាស់ៗព្រឹទ្ធាចារ្យនៅក្នុងស្រុក បានលើកឡើងថា : កាលពីជំនាន់ពោធិ៍កំបោរប្រមាណជាង១០០ឆ្នាំមុននេះ មានកុលសម្ព័ន្ធជនជាតិព្នងមួយក្រុមតូច បានគេចចេញពីកុលសម្ព័ន្ធរបស់ខ្លួនមកតាំងទីរស់នៅកន្លែងនេះ។ ក្រុមនេះដឹកនាំដោយមេកន្ទ្រាញម្នាក់ឈ្មោះតាមី (តាអាំប្រ៊ី) ។ ឯភូមិនេះបានជាឈ្មោះថា បាយសំណុំទៅវិញ ព្រោះមានគេប្រសិទ្ធិនាមតាមកូនកោះតូចមួយ ដែលដុះនៅកណ្ដាលទឹកទន្ទឹមនឹងភូមិនេះ។ កូនកោះនោះឈ្មោះហៅថា " *បាយសំណុំ* " ។

តាមរឿងព្រេងកថាតំណាលថា : " *កូនកោះនេះគឺជាកញ្ចប់បាយរបស់តាព្រហ្ម* "។ កាលនោះ តាព្រហ្មគាត់បានចុះមកពីថ្វាយបង្គំ ព្រះបាទជាន់ទុក នៅមឿងខន នគន ប្រទេសលាវមក គាត់បានមកឈប់សម្រាកនៅទីនេះ ហើយក៏លាបាយកញ្ចប់ហូប។ ក្រោយពេលហូបរួច គាត់បោះកញ្ចប់បាយចោលនៅទីនេះតែម្តង។ តក្រោយមក កញ្ចប់បាយនោះ ក៏ដុះខ្សាច់ ក ពូនទៅជាកូនកោះមួយ ស្ថិតនៅកណ្តាលដៃទន្លេមេគង្គ គួរឱ្យចង់គយគន់ក្រៃពេក។

នៅជុំវិញកូនកោះមូលតូចនេះ មានថ្មល្អៗ មានតម្លៃខ្ពស់ ប្រហាក់ប្រហែលនឹងថ្មសាងអង្គរវត្ត ជាសម្បត្តិធម្មជាតិ ដូចជាថ្មចម្លាក់ព្រះបដិមា ថ្មចម្លាក់ទ្វារមាសនាងឧម្មាភោគវតី ( *ប្រពន្ធព្រះឥសូរ ក្នុងរឿងព្រហ្មញ្ញសាសនាជាដើម* )។

មានរឿងល្បីថា កាលពីសម័យផ្អើលជីកមាស រាវរកមាស រាវរកថ្មល្អៗ នាឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៦ មានប្រជាជនក្នុងភូមិរើសបានថ្មព្រះពុទ្ធបដិមានៅកូនកោះនេះ តែត្រូវជនទុច្ចរិតឆក់ប្លន់យកទៅលក់នៅប្រទេសថៃ។ ក្រោយមកគេរើសបានថ្មបល្ល័ង្ក( ថ្មឆ្លាក់ជាទ្វារមាសនាងឧម្មាភោគវតី ប្រពន្ធព្រះឥសូរ) ។ ថ្មនេះបច្ចុប្បន្នប្រើជាបល្ល័ង្កតម្កល់ព្រះបដិមា នៅក្នុងព្រះវិហារ វត្តវិបស្សនារាម (កំពង់លើ) ឃុំកោះខ្សែរ សព្វថ្ងៃ។

## ២_អំពីភូមិស្វាយចេក

### ក. ទីតាំង និងស្ថានភាពភូមិ

នៅតាមផ្លូវមាត់ទន្លេមេគង្គ ឆ្ពោះទៅទិសខាងជើងដដែល បន្តផុតពីភូមិបាយសំណុំបន្តិច នឹងធ្លាក់ទៅដល់ភូមិមួយទៀត។ ភូមិនោះមាននាមថា " *ភូមិកំពង់ស្វាយចេក* "។ ភូមិនេះជាភូមិកណ្តាលមានចម្ងាយ ៦ គីឡូម៉ែត្រ ពីទីរួមស្រុក

សំបូរ។ ក្នុងភូមិមានសាលាបឋមសិក្សា និងមានវត្តអារាម ស្ថិតនៅលើដីទួលខ្ពស់ ខាងក្រោយសាលារៀន ប្រមាណ៤០០គីឡូម៉ែត្រ។

បច្ចុប្បន្ននៅក្នុងភូមិនេះមានប្រជាជនប្រមាណ ១៦២ គ្រួសាររស់នៅ។ មុខរបរជាមូលដ្ឋានរបស់ប្រជាជនក្រៅពីធ្វើស្រែ និងធ្វើចំការ គឺពួកគាត់ធ្វើស្ករត្នោត នេសាទត្រី និងធ្វើទូក (ទូកមាឌ) អារឈើ( អារដោយរណាចន្ទល់)។

## ខ.ប្រវត្តិនាមភូមិ

តាមបទតំណាលពីលោកតា គិន ចាស់ទុំនៅក្នុងភូមិស្វាយចេក បានលើកថា : " ភូមិនេះនៅប្រមាណជាង១០០ឆ្នាំមុន មានកុលសម្ព័ន្ធជនជាតិព្នងមួយក្រុម ដឹកនាំដោយលោកតា អ៊ូច (អំព្រក់អ៊ូច) ជាមេកន្ទ្រាញ បានមកតាំងទី រស់នៅកន្លែងនេះ។ ភូមិនេះ កាលនោះសំបូរទៅដោយដើមស្វាយចេក តូច-ធំ ច្រើនជាងគេបង្អស់ ចាប់តាំងពីកន្ទុយភូមិដល់ក្បាលភូមិ។ ដោយឡែក នៅផ្ទះលោកតា អំព្រក់អ៊ូច គាត់ធ្វើផ្លូវមួយយ៉ាងស្អាត ចុះទៅកំពង់ទឹក សម្រាប់ទុកឱ្យកូនចៅគាត់ចុះទៅងូតទឹក ដងទឹក...។ល។

ពួកអ្នកនេសាទតាមទូក តែងហៅកំពង់ទឹកនេះថា " កំពង់តាអ៊ូច "។ តែក្រោយមក ប្រែរជាហៅថា " *កំពង់ស្វាយចេក* "ទៅវិញ ដោយកំពង់តាអ៊ូចនេះ មានដុះដើមស្វាយចេកច្រើន។

## ៣-អំពីភូមិកំពង់ជើងតាគ

### ក.ទីតាំង និងស្ថានភាពភូមិ

នៅតាមផ្លូវទន្លេមេគង្គដដែល បន្តផុតពីភូមិស្វាយចេកបន្តិចទៅ ពិសេសចាប់ពីក្បាលស្ពានព្រែកសែនទៅ យើងនឹងបានឃើញភូមិមួយទៀត ដែលមានឈ្មោះ

ថា " *ភូមិជើងពាត* " ។ ភូមិនេះមានចម្ងាយ ៦ គីឡូម៉ែត្រកន្លះ ពីទីរួមស្រុកសំបូរ ។

ប្រជាពលរដ្ឋរស់នៅក្នុងភូមិនេះ មានប្រមាណ១៩០គ្រួសារ ប្រកបរបរចិញ្ចឹមជីវិតដោយធ្វើស្រែ ធ្វើចំការ និងឡើងត្នោត។ ភូមិទីពនេះ បើធ្វើការប្រៀបធៀបជាមួយភូមិពីរខាងដើម ឃើញថាភូមិនេះ ជាភូមិខ្សត់ខ្សោយជាងគេ ។

## ខ.ប្រវត្តិនាមភូមិ

តាមបទតំណាលពីចាស់ទុំនៅក្នុងភូមិបានឱ្យដឹងថា ភូមិនេះក៏ដូចជាភូមិពីរខាងលើដែរ ។ គឺមានជនជាតិព្នងមួយក្រុមតូច ដឹកនាំដោយមេកន្ទ្រាញមួយរូបឈ្មោះ តាកែក (តាអាំព្រែក) ។ តាអាំព្រែកនេះ គាត់មានជើងអាពាធម្ខាង ពេលដើរទៅណាម្តងៗ ច្រើនមានលក្ខណៈលោតៗ។ គាត់សង់ផ្ទះនៅជិតមាត់កំពង់ ហើយកំពង់របស់គាត់មានផ្លូវស្អាតល្អដូចកំពង់តាអ៊ូចដែរ ។

អ្នកនេសាទត្រីទាំងឡាយ តែកាលណាចែវទូកដល់កំពង់នេះហើយ តែងតែសួរគ្នាថា " *នេះជាកំពង់អ្នកណា?* " អ្នកដឹងតែងឆ្លើយថា " *នេះជាកំពង់តាកែក* " អ្នកនេសាទមួយចំនួនដែលពុំស្គាល់នោះតែងសួរទៀតថា " *តាកែកណា?* " អ្នកដឹងឆ្លើយថា " *តាកែក ជើងអាពាធ* " ។ ក្រោយមកកំពង់នេះគេហៅថា " ***កំពង់តាកែកជើងអាពាធ*** " ។ តែដោយពាក្យថា "*កំពង់តាកែកជើងអាពាធ*" វែងពេកពិបាកក្នុងការហៅ, គេក៏នាំគ្នាហៅកាត់ថា "***កំពង់ជើងពាត***" គឺមកពីពាក្យ ថា កំពង់ជើងអាពាធនេះឯង ។

អត្ថបទរឿង

# ឆ្នាំប្រាសាទបាយ័ន

## (តចប់)

ដោយ : **ខៀវ បញ្ញាវុឌ្ឍ**

*( គង់ដើរទៅក្បែរប្រាសាទគាត់សម្លឹងមើលមុខព្រហ្មដោយយកចិត្តទុកដាក់)*

**គង់** - ខ្ញុំយល់ហើយ ... ខ្ញុំបានឮនូវអ្វីដែលអ្នកនិយាយប្រាប់ខ្ញុំហើយ ... ខ្ញុំសប្បាយចិត្តណាស់ ។ ពេលនេះ ទើបខ្ញុំដឹងថា ខ្ញុំមានវាសនា ទទួលការសណ្តោសប្រោសប្រណីពីអ្នក ... អ្នកបានបង្ហាញផ្លូវសុខស្ងប់ ... ខ្ញុំដឹងថាខ្ញុំជាអ្នកណាហើយ ! ហើយត្រូវធ្វើអ្វីហើយ ! ... ខ្ញុំសូមអរគុណចំពោះអ្នក ដែលព្រមលើកលែងទោសឱ្យខ្ញុំ ខ្ញុំសូមអរគុណ ! អរគុណ ! អរគុណ ! ...

- សូមអ្នកកុំព្រួយខ្ញុំសូមប្តេជ្ញាថា ធ្វើតាមមនសិការរបស់កូនខ្មែរ តទៅមុខទៀត ខ្ញុំជឿហើយ ខ្ញុំលែងប្រមាថខ្លួនឯងថាជាឆ្នាំប្រាសាទទៀតហើយ ... ការងារនេះមិនមែនជាការងារថោកទាបទេ ...

*( គាត់សម្លឹងមើលទៅព្រហ្មសែនពេញចិត្ត)*

- មើលព្រះចន្ទចរំលងគងព្រះភ័ក្ត្រ ពន្លឺថ្លាត្រជាក់ ធ្វើឱ្យវង់ភ័ក្ត្រអ្នកញញឹមសែនស្ងប់ ...

- ឱ ! ខ្លួនអញអើយ ម្ដេចឡើយយូរណាស់ហើយរស់ធុញថប់ ឥឡូវទើបបានសុខស្ងប់បានទាំងរម្ងាប់អស់ទុក្ខា។ (*គាត់បានសម្រួលចិត្តមកវិញ*)

...អាវ៉ា អើយអាវ៉ា ឯងនៅឯណា ... ឯងបានទទួលក្ដីមេត្តារបស់ព្រហ្មហើយឬនៅ ... ? អញបានទទួលហើយ ៗ ត្រជាក់ណាស់ ៗៗ ... (*ឮសម្លេងវ៉ាស្រែកហៅពីចម្ងាយ*)

វ៉ា - អា គង់ ! អា គង់ ! នែ៎ ! អញមានដំណឹងល្អមួយ មកប្រាប់ឯង ... (*វ៉ាអូសដៃគង់មកខ្សិប គង់ដើរចេញដោយមិននិយាយអ្វីទាំងអស់*)

- អា គង់ ! អ្ហែងឥឡូវយ៉ាងម៉េចហ្នឹង ? ឆ្កួតទេអ្ហែះ ? គិតមើលទៅ !

ឱកាសល្អ មិនមានច្រើនទេ ត្រូវចេះប្រើឱកាស ឱកាសហុចឱ្យហើយៗ

... ឬមួយក៏អ្ហែងចង់នៅធ្វើឆ្មាំរបៀបនេះជារៀងរហូត ?

គង់ - (*បែរមករកវ៉ា*) អាវ៉ាសម្លាញ់ ! បើអ្ហែងមើលទៅប្រាសាទត្រឹមតែភ្នែកមួយគូយ៉ាងសាមញ្ញនេះ នោះអ្ហែងបានឃើញត្រឹមតែដុំថ្មនិងរូបចម្លាក់ប៉ុណ្ណោះ ... តែប្រសិនបើអ្ហែងសម្លឹងមើលដោយចិត្តអំណត់ពិចារណាតាមចង្វាក់បេះដូងនោះ ដំបូងឯងប្រាកដជាលំបាកទប់ចិត្តមិនឱ្យរំភើប មិនឱ្យតក់ស្លុតបានណាស់ ...

- ឯងដឹងទេ អាថិកំបាំងច្រើនណាស់ដែលបង្កប់នៅទីនេះគឺជារឿងរ៉ាវប្រវត្តិសាស្ត្រ ជាតឹកតាងបញ្ជាក់ច្បាស់ថាឯងនិងអញជាអ្នកណា !

... (*រន្ធើនបញ្ឈាក់ទៅវ៉ា*) គេមានវិញ្ញាណ ! ឯងដឹងទេ ថាគេមាន វិញ្ញាណ ? ....

- គេនឹងនិយាយជាមួយឯង នៅពេលដែលឯងចេះភាសារបស់គេ ។ តើឯងចង់បំផ្លាញគេដល់ណាទៀត ? ។

**វ៉ា** -អញមិនចង់ស្តាប់ទេ អាគង់ ... ឯង ធ្លាប់និយាយប្រាប់អញថាឯងសរសេរអក្សរមួយបន្ទាត់ខុសដប់ឯណោះ មែនទេ ? .... មកដល់ដំណាក់កាលនេះហើយ ទោះបីជាចង់ត្រឡប់ថយក្រោយវិញ ក៏មិនអាចដែរ ... យើងត្រូវការប្រាក់ដើម្បីរស់មិនប្រាថ្នាហួសគេទេ យើង ..... យើងរស់លំបាកណាស់មែនទេអាគង់ ? ...

**គង់** - អាវ៉ា ! គឺមិនមែនប្រាក់ទេ ប្រាក់គ្រាន់តែជាបញ្ហាបន្ទាប់បន្សំប៉ុណ្ណោះ បញ្ហាធំគឺការស្គាល់ខ្លួនឯង ឱ្យច្បាស់ជាមុនសិន ។ ... ការស្គាល់ខ្លួនឯងមិនកំណត់ថា ទាល់តែអ្នកនោះជាអ្នកធំ ជាអ្នកមាន ឬជាអ្នកចេះដឹងខ្ពស់នោះទេ ... មែន ! អញល្ងង់មែន តែអញបានស្គាល់ខ្លួនឯងហើយ អញស្គាល់ថ្មហើយ ថ្មគឺជាវត្ថុដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ។ ពីមុនអញធ្លាប់គិតថា : ហេតុអ្វីបានជាជនបរទេសគេស្ទាត់មកមើលថ្មប្រាសាទខ្មែរ? គេមកគូរ គេមកថត គេមកស្ទាបអង្អែល គេជញ្ជក់មាត់ ... អញធ្លាប់ឆ្ងល់ទៀតថា ហេតុដូចម្តេចបានជាគេហ៊ានចំណាយប្រាក់ ទិញថ្មចម្លាក់ខ្មែររាប់ពាន់រាប់ម៉ឺនដុល្លារ ? គេហ៊ាន យកដុំមាសគេមកដូរនឹងដុំថ្មយើង តើមាស និងថ្ម មួយណាមានតម្លៃជាងមួយណា ? តើគេល្ងង់ឬក៏យើងល្ងង់ ? តើ ឯងខានគិតដូចអញដែរឬទេ ? ... ឥឡូវនេះអញខានគិតច្បាស់ណាស់

ថា យើងបំផ្លាញខ្លួនយើង គឺយើងខ្លួនឯងផ្ទាល់នេះឯងហើយ ជាអ្នកបំបាត់ភស្តុតាងប្រវត្តិសាស្ត្រខ្លួនឯង ។

វ៉ា - អាគង់ ! ស្តាប់ឯងនិយាយនេះ អញអាចយល់ដូចឯង ... ប៉ុន្តែ ឯងដឹងទេ វាគ្រាន់តែជាចំណែកតូចមួយប៉ុណ្ណោះ បើយើងមិនធ្វើក៏មានគេធ្វើដែរ យើងនៅតែបាត់បង់ដដែល ....។ អញត្រូវការប្រាក់ព្រោះអញមានធុរៈនៅក្នុងគ្រួសារ ម្យ៉ាងទៀតជាមួយអាកេត ឯងដឹងហើយ ... បើយើងបដិសេធ វានឹងបំបិទមាត់ហើយ ។

គង់ - អាវ៉ា ! ឯងខ្លាចស្លាប់មែនទេ ? អញបានសច្ចានៅក្នុងចិត្តហើយថា

អញនឹងការពារប្រាសាទ អញទុកទីនេះជាទីសក្ការៈ ជាកន្លែងតម្កល់ធាតុតម្កល់ព្រលឹងរបស់អញ ... អញសុំទោស ... អញមិនព្រមឱ្យឯងធ្វើអ្វីដែលជាអំពើមិនគប្បីទៀតទេ ។ អ្នកណាក៏ដោយមិនអាចប៉ះពាល់ថ្មនេះតទៅទៀតបានឡើយ ។ ( *គាត់ទាញដំបងមកកាន់នៅដៃ* ) អញ ... អញនឹងទៅរាយការណ៍ជូន កម្លាំងមានសមត្ថកិច្ច ...

វ៉ា - ( *និយាយសម្រួល* ) មិនបាច់ដល់ថ្នាក់នេះទេ អាគង់ ! ... អាកេតគ្រាន់តែឱ្យអញមកសួរឯងថា តើឯងចូលរួមដែរឬទេ ? វាមានទាំងផែនទីផង ។

គង់ -អ្ហែងឃើញទេ ! គេចង់បំផ្លាញយើង តែគេមិនអាចបំផ្លាញដោយផ្ទាល់បាន គេឱ្យយើងបំផ្លាញខ្លួនយើង ដើម្បីគេ ... គេយកដៃយើងឱ្យខ្វេះភ្នែកយើង គេខ្ចីដៃយើងយកមកសម្លាប់យើង ...

- គេឱ្យលុយយើងប៉ុន្មាន ? គេខានប៉ុន្មាន ? អ្នកណាងាប់ ? យើងងាប់

ឬគេងាប់ ? តើលុយបានមក អាចសុខស្រួលមួយជីវិតឬទេ ? ... ឬរស់នៅដោយភ័យព្រួយដដែលៗនោះ ? ... សព្វថ្ងៃលុយមិនសម្បូរមែន តែគ្មានអ្នកណាតាមដាន តាមចាប់យើងនោះទេ ....

- អាវ៉ា ! បើយើងទាំងអស់គ្នា មិននាំគ្នាចូលរួមនោះ អាកេត ក៏មិនអាចបំផ្លាញវត្ថុបុរាណតទៅទៀតបានដែរ ។ ឯងសន្យាទៅថាឯងមិនចូលរួមទេ សន្យាទៅ យើងអាចរកប្រាក់តាមមធ្យោបាយផ្សេងបានទេតើ ... ឯងធ្លាប់យួរធុងទឹកកកឱ្យគេ ... ឯងធ្លាប់ជួយពន្យល់ពីប្រាសាទ ប្រាប់គេ ... ឯងធ្លាប់ទទួលទឹកក្រូច និងប្រាក់ដ៏បរិសុទ្ធ ពីសណ្ដានចិត្តរបស់ភ្ញៀវទេសចរណ៍ខ្មែរខ្លះដែរតើ ... គេនឹងឱ្យប្រាក់ឧបត្ថម្ភបន្តបន្ទាប់ទៀតនៅពេលដែលគេដឹងថាឯងជាឆ្មាំដ៏ល្អ ... ជាឆ្មាំដែលស្មោះត្រង់ ... ឯងព្រមនឹង អញទៅអាវ៉ា អញសូមអង្វរ ...

**វ៉ា** - អញគិតមើលសិន ...

**គង់** - មិនបាច់គិតទេអាវ៉ា អ្នែងនឹងជាប់គុកប្រសិនជាឯងហ៊ានប្រថុយ ។ អញមិនចង់ឃើញគេដាក់ទណ្ឌកម្មឯងទេ ។ គេមានវិធានការទប់ស្កាត់តឹងតែងណាស់ ខុសប៉ុណ្ណឹងល្មមដឹងខ្លួនហើយ ស្រុកសន្តិភាពហើយ ... ទុកឱកាសឱ្យជាតិមានជីវិតផងទៅ ....

**វ៉ា** - អាគង់ ! អញក៏បានគិតដូចអ្នែងអញ្ចឹងដែរ ... ប៉ុន្តែពេលខ្លះអញតូចចិត្ត អញច្រណែននឹងអ្នកដទៃ អញខ្មាសខ្លួនឯង ដែលរស់ពិបាកជាងស្លាប់

ទៅទៀតនេះ ... យ៉ាងណាក៏ឯងរស់ស្រួលជាងអញដែរ ព្រោះឯងខ្លួនមួយ ... ឯងទៅមើលផ្ទះអញទៅ ម្ដាយក្មេកឈឺដេកលើកន្ទេល អង្ករបាតពាង ប្រពន្ធមុខជាំ ស្បែកស្ងួត ចាស់មុនអាយុ ជួបគ្នាម្ដងៗញញឹមដាក់គ្នាទាំងសោះកក្រោះ តើសុភមង្គលក្នុងជីវិតអញមាននៅកន្លែងណា ?

- លី ដែកប្រហោង ដេកក្នុងព្រៃ កណ្ដាលព្យុះភ្លៀង គ្មានបានរៀនសូត្រនឹងគេ នេះក៏ព្រោះតែអញស្នេហាជាតិដែរតើ ! តើត្រូវឆ្លើយដាក់ទៅលើព្រេងវាសនាតទៅទៀតអញ្ចឹងអ្ហេះ ? ...

ឥង់ -អាវ៉ា ! ក្នុងសមរភូមិ អញអាចជួយបាញ់ខ្មាំងឯងបាន តែសង្គ្រាមនៅក្នុងចិត្តរបស់ឯង មានតែឯងទេ ដែលអាចពន្លត់វាបាន ... ព្យាយាមទៅ

អាសម្លាញ់ឯងត្រូវចេះអត់ធ្មត់ ពិចារណាឱ្យបានវែងឆ្ងាយ ឯងត្រូវតែជាម្ចាស់ចិត្តឯង មិនត្រូវឱ្យចិត្តរបស់ឯង បញ្ជាឯងទេ ឯងត្រូវតែចេះឱ្យតម្លៃទៅលើអ្វីដែលឯងមាន ដូច្នេះមានតែការស្គាល់ខ្លួនឯងទេ ទើបអាចគ្រប់គ្រងខ្លួនឯងបាន ... (*ឮសូរមាន់រងាវម្ដង*)

- ដេកទៅអាសម្លាញ់ឯងនឿយហត់ពេកហើយ ....

វ៉ា - គ្រប់គ្រងខ្លួនឯងបានអ្ហេះ ? ... ( *លូកហោប៉ៅរាប់លុយ* ) អញខ្ចីប្រាំរយទិញស្រាផឹក ...

ឥង់ - អញគ្មានលុយទេ ... ឈប់ផឹកទៅ អាសម្លាញ់ ស្រាមិនអាចជួយអ្វីអ្ហែងបានទេ ...

ភាំ - តើអញត្រូវឆ្លើយប្រាប់អាកេតថា ម៉េចទៅ ?

គង់ - ប្រាប់ថា មិនចូលរួមទេ ហើយប្រាប់វាផងថាប្រយត្ន័ជាប់គុក ... ឬក៏វាមិនអាចជាប់គុកបាន ? ... បើអីញ្ចឹង អ្អែងប្រាប់វាថា ឈប់លេ្ងង់តទៅទៀតទៅ ...

ភាំ - អ្អែងជឿថាអញហ៊ាននិយាយពាក្យហ្នឹងទេ ? ...

គង់ -អ្អែងត្រូវតែហ៊ាន

ភាំ - ចុះអ្អែងជឿថា អញស្តាប់អ្អែងទេ ?

គង់ - អញជឿថាអ្អែងស្រឡាញ់អញណាស់ យើងធ្លាប់កំសត់កម្រជាមួយគ្នា ទោះជាយ៉ាងណា ក៏អ្អែងពិចារណាដែរ ......

ភាំ - បានហើយៗ អញមិនចង់និយាយឱ្យអ្អែងអស់សង្ឃឹមទេ ( *ថាហើយភាំ ដើរតម្រង់ទៅមាត់ទ្វារ... រួចឈប់សម្លឹងមើលទៅព្រហ្មមុខបួន* )

- មែន ! ធំ ! ខ្ពស់ស្កឹមស្កៃ ... អ្នកណាក៏គេសរសើរ អ្នកណាក៏គេឱ្យតម្លៃដែរ ... តែ .... តែ បុព្វបុរស មិនគួរសាងទុកនាំឱ្យលំបាកគេឯងដូច្នេះទេ ... ។ ដឹងទេ ? ខ្មែររាល់រូបអ្នកណាក៏ថា អ្នកជារបស់គេដែរ ... អ្នកណាក៏ថាគេជាកូនខ្មែរអង្គរដែរ គេថាគេជាខ្មែរពូជអ្នកចម្បាំង ... តើខ្ញុំ .. ! ខ្ញុំអាចថាខ្ញុំ ជាខ្មែរពូជអ្នកចម្បាំងដែរបានទេ ...?

( *គាត់ទាញកន្រ្ទាក់ហែកអាវគ្រវែងចោល រួចត្រដាងដៃន្រ្ទាប់ទៅខាយ័ន* )

មើលទៅ ! ឃើញទេ ! ឃើញទេ !? ឃើញស្នាមរបួសនៅលើខ្លួនខ្ញុំទេ ? គឺដោយសារចម្បាំង គឺដោយសារខ្មែរគ្នាឯង ...

- ខ្ញុំហាក់ដូចជាមានអារម្មណ៍ថា អ្នកកំពុងតែខ្សោះ អស់ឋាមពលដូចខ្ញុំដែរ ព្រោះមានគេ បឺត ជញ្ជក់ យកផលប្រយោជន៍ពីអ្នក ... ចុះខ្ញុំ ខ្ញុំសុំអ្នកមួយដុំលក់ចិញ្ចឹមជីវិតផងបានទេ តើបានទេ?...( *គាត់លើកថ្មប្រាសាទមួយដុំដែលនៅក្បែរនោះឡើងទៅលើ* )

គង់ -( *ស្រែកឱ្យវ៉ា* ) អាវ៉ា ! អ្ហែងឆ្កួតហើយ !... បើគេ សុំ ចៀរសាច់ឯងមួយដុំ ឬឆ្កៀលគ្រាប់ភ្នែកឯងតើឯងព្រមទេ ?...

វ៉ា -ចុះបើគេទុកអវៈយវៈឯង ហើយគេបង្ខូរយកឈាមឯង ឱ្យខ្សោះងាប់ តើអ្ហែងព្រមដែរទេអ្ហាស ?

គង់ -មិនបានទាំងពីរ គ្មានអ្នកណាអាចធ្វើអ្វីបានទេ .... ( *វ៉ាដើរចូលទៅរើសអាវ យកមកពាក់ បណ្តើរ ដើរចូលទៅក្នុងប្រាសាទបណ្តើរ* )

( *បរិយាកាស ស្ងប់ស្ងាត់ គង់ដើរទៅជិតប្រាសាទ* )

- ឱ ! បាយ័នអើយ ខ្ញុំដឹងថាអ្នកមើលឃើញអស់ហើយ ថាអាវ៉ាមិត្តខ្ញុំវាខូចចិត្តប៉ុណ្ណោះ.... អនុគ្រោះឱ្យវាផង ខ្ញុំសន្យាថា នឹងព្យាយាមពន្យល់អូសទាញវាមករកផ្លូវត្រូវវិញ ... សូមលើកលែងទោសឱ្យវាផងចុះ ... ( *គង់លុតជង្គងថ្វាយបង្គំ* )

---

( *ឮសម្លេងដាប់ថ្ម គង់ស្រែករួចរត់ទៅរកប្រាសាទ* )

-អាវ៉ា ! អាវ៉ា ! កុំធ្វើអីញ្ចឹង កុំធ្វើអីញ្ចឹងអាវ៉ា អញសូមអង្វរ កុំឱ្យខុសជាន់លើខុសទៀត ...

( *រត់ទៅដល់មាត់ទ្វារប្រាសាទ ឮស្នូរសម្លេងកាំភ្លើង ផ្ទូង! ផ្ទូង!* )

គង់ - ( *គង់ ដួលលុតជង្គង់* ) អាវ៉ាម៉េចឯងធ្វើអីញ្ចឹង ? ...

( *ឮស្នូរកាំភ្លើង វ៉ារត់ចូល ស្ទុះទៅត្រកងគង់ ផ្ដេកមកលើខ្លួន* )

វ៉ា - អាគង់ អែងយ៉ាងម៉េចហ្នឹង ? ... ម៉េចអីញ្ចឹង ? អ្នកណាធ្វើបាបឯង? អាកេត ! អាកេត ម៉េចឯងសាហាវម្ល៉េះ ? ...

គង់ - អាវ៉ា ! មិនមែនឯងទេអ្ហេះ ! អាវ៉ា ?

វ៉ា - មិនមែនទេ អម្បាញ់មិញអញដើរទៅរកទិញស្រា ... ឮស្នូរកាំភ្លើង ... អញក៏រត់មក មិនអីទេអាគង់ តោះទៅមន្ទីរពេទ្យ ! ទៅពេទ្យៗ ...

គង់ - អញសប្បាយចិត្តណាស់ ... ទុកដូចជាអញ យកជីវិតលប់លាងកំហុសដែលអញបានធ្វើពីមុនមក ... អញសុំលាងជំនួសឯងដែរ ...

វ៉ា - ឈប់និយាយទៅ អាគង់ ! ឯង មិនអីទេ ... តោះ អញនាំឯងទៅមន្ទីរពេទ្យ ... ( *វ៉ាចាប់លើកគង់* )

គង់ -ឈប់សិនអាវ៉ា ! ឯងសន្យានឹងអញមក ថាឯងមិនសាងអំពើអាក្រក់ទៀតទេ ...

វ៉ា - បានៗ ! អញសន្យា ថានឹងយកជីវិតអញដែលនៅសល់នេះ តបស្នង

លាងកំហុសហើយ ...

**ចង់** - កុំភ្លេចណាំ ! ត្រូវធ្វើខ្លួនឱ្យទៅជាកូនខ្មែរដ៏ល្អមួយរូប ... ( *ដាច់ខ្យល់ស្លាប់* )

**រ៉ា** - អាគង់ ! អាគង់ ! ម៉េចក៏ឯងដាច់ចិត្តទៅចោលអញអីញ្ចឹង អាគង់ !... គឺស្មាដៃ អាកេត ! អាកេត ម៉េចក៏ឯងធ្វើអីញ្ចឹង ? ឯងមិនអាចគេចផុតពីទណ្ឌកម្មបានទេ ...

- អាគង់ អញព្រមកែខ្លួនតាមឯងហើយ ... អញព្រមទទួលភារកិច្ចបន្តពីឯងហើយ ... អញមិនឱ្យឯងអស់សង្ឃឹមទេ .......

( *ដាក់សពគង់សម្រួលយកដៃបិទភ្នែក* )

សូមឯងទៅកាន់សុគតិភពចុះ .... ( *គាត់ងើបសម្លឹងមើលទៅប្រាសាទ* )

- ព្រហ្មបាយ័នតើអ្នកឃើញទេ ? តើបណ្តោយឱ្យមនុស្សល្អបន្តស្លាប់អីញ្ចឹងឬ ? ឆ្លើយមក ៗ ( *រ៉ាដឹងខ្លួនវិញ* )

- មែន ( *យកដៃជូតទឹកភ្នែក* ) អាគង់ អញសុំទោស ... អញភ្លេចខ្លួនទៀតហើយ ( *អង្គុយចុះ* ) សប្បាយចិត្តចុះអាសម្លាញ់ អញនឹងខំព្យាយាមអត់ធ្មត់ ... ដើម្បី ធ្វើខ្លួនឱ្យល្អបន្តពីឯង .... ។

**(ចប់)**

# សុន្ទរកថា

ព្រះតេជព្រះគុណ **គុសុកបាកុឡា រិនប៉ូចេ**

ព្រះថេរានុត្ថេរៈ ជាទីគោរព

ឯកឧត្តម លោកស្រី អស់លោក

គឺជាសិទ្ធិ និងសេចក្តីសប្បាយ ដែលមានលទ្ធភាពមកចូលរួមប្រជុំសន្និសីទកំពូលពុទ្ធសាសនាលើកទី៣ ។ ខ្ញុំព្រះករុណា-អាត្មាភាព មានសេចក្តីសោមនស្សអនេកដើម្បីឆ្លៀតយកឱកាសនេះ ចែករំលែកគ្នានូវទស្សនៈរបស់យើងសម្រាប់លើកស្ទួយនឹងផ្សព្វផ្សាយព្រះពុទ្ធធម៌ ។ ខ្ញុំព្រះករុណាអាត្មាភាពសូមនាំមកថ្វាយព្រះករុណាព្រះមហាក្សត្រ ប្រគេនព្រះតេជព្រះគុណ ព្រះករុណាគ្រប់អង្គ និងជូនរដ្ឋាភិបាល និងប្រជាជនកម្ពុជា ព្រមទាំងអស់លោកជាសមាជិក ជាទីគោរព នៃសន្និសីទកំពូលព្រះពុទ្ធសាសនា លើកទី ៣ នូវព្រះអភិវន្ទនកិច្ច និងគារវកិច្ចដ៏កក់ក្តៅបំផុតរបស់ប្រជាជននៃប្រទេសឥណ្ឌា ។

សន្និសីទកំពូលទាំងពីរលើកកន្លងទៅ បានប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ ។ ការជួបជុំគ្នាមិនធ្លាប់មានពីមុន នៃសម្តេចព្រះសង្ឃរាជនៃប្រទេសថៃ និងសម្តេច ដាឡៃ ឡាម៉ា ក្នុងអំឡុងសន្និសីទកំពូលពុទ្ធសាសនា លើកទី១ ក្នុងប្រទេសជប៉ុន បានត្រួសត្រាយផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរក្នុងចំណោមពុទ្ធសាសនិកជនទាំងអស់នៃពិភពលោក ។ ដូចគ្នានេះដែរ សន្និសីទកំពូលពុទ្ធសាសនាលើកទី ២ ក្នុងក្រុងបាងកក ប្រទេសថៃ បានកោះប្រជុំពុទ្ធសាសនិកយ៉ាងច្រើនមកពីគ្រប់ទិសទី ហើយបានផ្តល់ដល់ចលនានោះ នូវវចនាសម្ព័ន្ធចាត់តាំងមួយ ។ ខ្ញុំព្រះ

ករុណា-អាត្មាភាព មានទំនុកចិត្តថា សន្និសីទកំពូលពុទ្ធសាសនា ក្រោមការដឹកនាំព្រះតេជព្រះគុណ បណ្ឌិត ក្សសេ អេនស៊ុនជោះ នឹងដុះដាលឡើងទាំងទំហំ នឹងទាំងកេរ្តិ៍ឈ្មោះ ហើយផ្តល់វិភាគទានដល់ការផ្សព្វផ្សាយ និងការអភិវឌ្ឍន៍ពុទ្ធសាសនាក្នុងពិភពលោកទាំងមូល ។

ខ្ញុំព្រះករុណា-អាត្មាភាព មានសេចក្តីសោមនស្សដោយឡែក ជាមួយនឹងទីកន្លែងការប្រជុំសន្និសីទកំពូលពុទ្ធសាសនា លើកទី៣ ។ ប្រទេសកម្ពុជា ជាដែនដីមួយរបស់អ្នកប្រាជ្ញ និងបណ្ឌិតជាច្រើនរូប ដែលបានបង្ហាញពន្លឺនៃបញ្ញាដល់ពិភពលោកខាងក្រៅ តាមរយៈពាក្យប្រៀនប្រដៅខាងស្មារតី ដ៏មានអានុភាពខ្លាំងក្លា និងការហ្វឹកហាត់ភាវនារបស់ខ្លួន។ ប៉ុន្តែនៅក្នុងពេលកន្លងទៅថ្មីៗនេះ ប្រទេសនេះបានជួបនឹងសោកនាដកម្មបាត់បង់ជីវិតមនុស្ស និងវិនាសកម្មនៃវប្បធម៌ និងអរិយធម៌គ្មានអ្វីប្រៀបផ្ទឹមបាន ។ របបផ្តាច់ការបានបង្កឱ្យមានទុក្ខវេទនាមិនធ្លាប់មានមកលើប្រជាជន ។ ប្រទេសបានជួបគ្រោះប្រល័យពូជសាសន៍ និងវិនាសកម្ម ដែលបានបន្សល់ទុកនូវស្នាមរបួសយ៉ាងជ្រៅលើប្រជាជន ។ ជាភ័ព្វសំណាងល្អ យុត្តិធម៌បានឈ្នះលើអយុត្តិធម៌ ហើយរបបផ្តាច់ការត្រូវទទួលបរាជ័យ ។

ខ្ញុំព្រះករុណា-អាត្មាភាព បានមកធ្វើទស្សនៈកិច្ចភ្លាម ក្រោមការដួលរលំនៃរបបប៉ុលពត ហើយបានឃើញវិនាសកម្ម ។ ខ្ញុំព្រះករុណា-អាត្មាភាព បានឃើញបន្ទប់មរណៈ និងអាគារទាំងឡាយ ដែលមានលលាដ៍ក្បាលមនុស្សរាប់ពាន់ត្រូវបានគេរក្សាទុក ដើម្បីជាការរំលឹកឱ្យមនុស្សជំនាន់ក្រោយៗដឹង ពីព្រឹត្តិការណ៍ឃោរឃៅនៅក្នុងប្រទេស ។ ខ្ញុំព្រះករុណា-អាត្មាភាព នឹកឃើញផងដែរ នូវដំណើរជុំវិញព្រះរាជវាំងដ៏ប្រណីត ដែលកាលនោះ គឺជាសារមន្ទីរ ។ សម័យកាលដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា មិនមែនគ្រាន់តែជាស្នាមកខ្វក់លើផ្ទៃមុខនៃប្រទេសនេះ

ប៉ុណ្ណោះទេ ប៉ុន្តែជាស្នាមកខ្វក់ សម្រាប់ពិភពលោកមានអរិយធម៌ទាំងមូល ។ ខ្ញុំព្រះករុណា-អាត្មាភាព ជឿថា ប្រជាជននៅគ្រប់ទីកន្លែង បានរៀននូវមេរៀនមួយអំពីសោកនាដកម្មដ៏គួរឱ្យខ្លាចនេះ ហើយបានយល់នូវទំហំនៃទុក្ខវេទនា ដែលមនុស្សមានគំនិតបំផ្លិចបំផ្លាញអាចនាំមក ។ សូមយើងទាំងអស់គ្នា បន់ស្រន់កុំឱ្យមានប្រជាជាតិ និងប្រជាជនណា ជួបប្រទះសោកនាដកម្ម និងទុក្ខវេទនាបែបនេះម្តងទៀតឱ្យសោះ ។ ប្រទេសកម្ពុជា ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ និង នាយករដ្ឋមន្ត្រី ឯកឧត្តម ហ៊ុន សែន បានទទួលការប្រែប្រួលមុខមាត់យ៉ាងល្អ ។ ខ្ញុំព្រះករុណា-អាត្មាភាព ជឿថា ឃ្លាំងដ៏ធំទូលាយនៃចំណេះដឹងខាងពុទ្ធសាសនា និងវត្តមានភិក្ខុសង្ឃជាពហុស្សូត និងអ្នកប្រាជ្ញ នឹងកែប្រែប្រទេសកម្ពុជា ឱ្យបានជាតារាមួយដួងនៃទ្វីបអាស៊ី ក្នុងពេលអនាគតកាល ។

ពិភពលោកសព្វថ្ងៃ ប្រឈមមុខការគម្រាមកំហែង និងអំពើហឹង្សាជាប្រចាំ ដែលមនុស្សជាតិមិនធ្លាប់បានស្គាល់ ។ ការវាយប្រហារភេរវកម្មថ្មីៗ បានបង្ហាញថា គ្មានកន្លែងណាមួយនៅលើផែនដីរបស់យើង មានសន្តិសុខទេ ។ ពួកភេរវជន គ្មានសាសនាទេ ។ មនុស្សជាតិមិនធ្លាប់ ដែលឃើញភេរវកម្មពីមុនមកទេ ដែលមានទំហំធំ ដូចឃើញកាលពីថ្ងៃទី ១១ ខែ កញ្ញា ក្នុងទីក្រុងញូវយ៉ក ។ ប្រទេសឥណ្ឌា បានរងការគម្រាមនេះ ជាងមួយទសវត្សមកហើយ ដែលនៅក្នុងការគម្រាមនេះ ជីវិតមនុស្សស្លូតត្រង់រាប់ពាន់អ្នកបានបាត់បង់ ។ ការកំទេចពុទ្ធបដិមាបុរាណនៅបាមីយ៉ាន ក្នុងប្រទេសអាហ្វហ្គានីស្ថាន ដោយពួកតាលិបង់ឥតសាសនា ដោយប្រើសព្វាវុធទំនើបវាយបំផ្លាញ គឺជាឧទាហរណ៍មួយទៀត នៃអំពើខ្វះសេចក្តីអត់ឱនរបស់មនុស្ស និងជំនឿជ្រុលនិយមខាងសាសនា ។ គ្មានពាក្យណាមួយ មានន័យគ្រប់គ្រាន់ ដើម្បីថ្កោលទោសអំពើភេរវកម្មទាំងនេះបានឡើយ ។

អច្ចន្តភាព ( ភាពជ្រុលហួសហេតុ ) ខាងប្រតិបត្តិសាសនា និងការប្រកាន់តាមគម្ពីរយ៉ាងតឹងរ៉ឹង មិនមានកន្លែងណាមួយ ដើម្បីទទួលយកនៅក្នុងពិភពលោកមានអរិយធម៌ទេ ។ ប្រជាជនត្រូវចេះរស់នៅក្នុងសន្តិភាព និងសុខដុមភាព ជាមួយគ្នាទៅវិញទៅមក ហើយពង្រីកសេចក្ដីសន្ដោស និងករុណាធម៌ ។ វាជាការទទួលខុសត្រូវរបស់យើងម្នាក់ៗ ដោយមិនគិតពីជំនឿសាសនារបស់យើង ដើម្បីខិតខំធ្វើឱ្យមានថាមពលថ្មីឡើងវិញ ហើយផ្ចិតជាប់នូវអារម្មណ៍ទាំងឡាយបែបនេះ ក្នុងចំណោមមនុស្ស ហើយសង្គ្រោះពិភពលោកនេះ ឱ្យផុតពីសេចក្ដីវិនាសធ្ងន់ធ្ងរជាងនេះទៀត ។ វាជាការតម្រូវផងដែរថា យើងត្រូវរៀនអំពីគតិបណ្ឌិត និងអរិយធម៌បុរាណរបស់យើង ។ ចូរយើងទាំងអស់គ្នាខិតខំឱ្យខ្លាំង ដើម្បីធ្វើឱ្យពិភពផែនដីនេះជាកន្លែងល្អប្រសើរសម្រាប់រស់នៅក្នុងសន្តិភាព និងសុខដុមភាព ។

មានសារៈសំខាន់ដូចគ្នា គឺសេចក្ដីត្រូវការថែរក្សាអេកូឡូស៊ី ដ៏ផុយស្រួយនៃផែនដីរបស់យើង ។ បែបបទនៃជីវិតនិយមសម្ភារៈ និងការបំផ្លិចបំផ្លាញជីវិតសត្វព្រៃកាន់តែកើនឡើង ហើយប្រព័ន្ធអេកូកំពុងធ្វើឱ្យកខ្វក់នូវចិត្តរបស់យើង ក៏ដូចជាបរិស្ថានពិភពលោកផងដែរ ។ គ្រោះថ្នាក់មកពីកត្តាទាំងនេះ ក៏មិនអន់ជាងមកពីសព្វាវុធប្រល័យមនុស្សទាំងក្រុមៗ និងគ្រាប់បែកបរមាណូដែរ ។ ដោយហេតុនេះគេត្រូវខិតខំថែរក្សាអេកូឡូស៊ីពិភពលោក ដើម្បីជាគុណប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ ។ គេត្រូវយល់ឱ្យបានច្បាស់ថា មនុស្សជាតិ អាស្រ័យលើធម្មជាតិដើម្បីមានជីវិតរស់រាន ដោយហេតុនេះ ត្រូវគោរពធម្មជាតិ ។ ខ្ញុំព្រះករុណា-អាត្មាភាព មានអារម្មណ៍ថា អ្នកដឹកនាំសាសនាទាំងឡាយមានការទទួលខុសត្រូវដ៏ពិសេស ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ ហើយនិងក្នុងការធ្វើឱ្យប្រជាជនយល់ដឹង ។

ពិភពលោកសព្វថ្ងៃ ត្រូវការព្រះធម៌ដ៏ឧត្តមរបស់ព្រះពុទ្ធជាងពេលណាៗ

ទាំងអស់ ។ គេត្រូវព្យាយាមដោយសុទ្ធចិត្ត ធ្វើឱ្យព្រះធម៌របស់ព្រះពុទ្ធចូលជ្រួតជ្រាបក្នុងប្រជាជន ហើយធ្វើឱ្យជីវភាពរបស់យើងសម្បូរសប្បាយ និងបំផុសការយោគយល់ និងតម្លៃមនុស្ស ។ ក្នុងករណីនេះ ខ្ញុំករុណា-អាត្មាភាព ស្នើសុំសន្និសីទកំពូលពុទ្ធសាសនា មេត្តាពិចារណានូវការបង្កើតសកលវិទ្យាល័យពុទ្ធសាសនាពិភពលោកមួយ នៅកន្លែងណាមួយសមស្រម ដែលនៅទីនោះ ទស្សនវិជ្ជា និងប្រពៃណី ហើយនិងចិន្តា (Thoyghts) នៃនិកាយពុទ្ធសាសនាផ្សេងៗ អាចត្រូវបានបង្រៀនដល់មនុស្សក្មេងៗ ។ ស្ថាប័នមួយបែបនេះ នឹងជួយផ្សព្វផ្សាយព្រះពុទ្ធធម៌របស់ព្រះពុទ្ធ ហើយអភិវឌ្ឍការយោគយល់គ្នា និងសហប្រតិបត្តិការបានល្អប្រសើរក្នុងចំណោមនិកាយពុទ្ធសាសនាផ្សេងៗគ្នាខាងទស្សនៈ ។

ព្រះតេជព្រះគុណ លោកស្រី អស់លោក

នេះគឺជាការចូលរួមជាបន្តបន្ទាប់លើកទី៣ របស់ខ្ញុំព្រះករុណា-អាត្មាភាពក្នុងសន្និសីទកំពូលពុទ្ធសាសនា ។ ខ្ញុំព្រះករុណា-អាត្មាភាព សូមយកឱកាសនេះសំដែងការកោតសរសើរ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅដល់ ព្រះតេជព្រះគុណបណ្ឌិត ក្យូសេ អេនស៊ីនជោះ ចំពោះចក្ខុវិស័យ ការដឹកនាំ និងវិភាគទានរបស់លោកហើយនិងចំពោះការផ្តល់ដល់ខ្ញុំព្រះករុណា-អាត្មាភាពទាំងឡាយនូវឱកាសដ៏ត្រកាលនេះ ។ ខ្ញុំព្រះករុណា-អាត្មាភាពសង្ឃឹមថា មនុស្សទាំងឡាយជាពិសេស ពុទ្ធសាសនិកជនក្នុងគ្រប់ទិសទី នឹងទទួលបានអត្ថប្រយោជន៍អំពីការប្រជុំបែបនេះ ។

ខ្ញុំព្រះករុណា-អាត្មាភាព និងប្រតិភូទាំងអស់មកពីប្រទេសឥណ្ឌា សូមអរគុណ រាជរដ្ឋាភិបាល និងម្ចាស់ផ្ទះទាំងឡាយនៃសន្និសីទកំពូលនេះ ចំពោះការរៀបចំ និងការទទួលរាក់ទាក់ដ៏ល្អត្រកាល ។ ខ្ញុំព្រះករុណា-អាត្មាភាព អរគុណយ៉ាងច្រើនសន្ធឹកសន្ធាប់ ចំពោះអគ្គបញ្ជាការដ្ឋាន នៃសន្និសីទកំពូលពុទ្ធសាសនា

ហើយជាពិសេស អរគុណនិកាយណោនបុិតស៊ូស៊ូ នៃប្រទេសជប៉ុន ចំពោះការខិតខំឥតគិតនឿយហត់ក្នុងការផ្សព្វផ្សាយព្រះធម៌របស់ព្រះពុទ្ធ និងក្នុងការនាំយកមេដឹកនាំពុទ្ធសាសនា អំពីប្រទេសផ្សេងៗនៃពិភពលោក មកជួបជុំគ្នា ។

សូមអរគុណ ហើយសូមសន្តិភាព គ្របដណ្តប់លើភពផែនដី ។

*នែក្មេងរាល់គ្នា ! ឯងកុំធ្វើបាបក្តែនេះ*
*ដ្បិតវាជាសត្វកំព្រាអានាថាគ្មានទីសង្ឃឹម.*
*វាមានសេចក្តីស្រេកឃ្លានវេទនា*
*ទទួលរងទុក្ខសុខដូចមនុស្សយើងដែរ*
*ប្លែកគ្នាត្រង់រូបរាងប៉ុណ្ណោះទេ.*
*ឯងរាល់គ្នា កុំស្មានថាធ្វើបាបបន្តិចបន្តួច*
*មិនបានបាបនោះឡើយ ។*

ព្រះមហាវិមលធម្ម ***ថោង***

# ទិវាបុណ្យឯករាជ្យជាតិ

ដោយ : សំ ធា



(ក្បួនព្យុហយាត្រា របស់ ក្រសួងធម្មការនិងសាសនា. ថ្ងៃទី ៩ វិច្ឆិកា ២០០៣)

បុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ១៩៥៣ - ២០០៣ នៃខួបលើកទី ៥០ ប្រព្រឹត្តទៅប្រកបដោយសិរីសួស្តីជ័យមង្គលមហាប្រសើរ ក្រោមព្រះរាជអធិបតីភាព នៃព្រះករុណាជាអម្ចាស់ជីវិតដម្កល់លើត្បូង ចូលរួមដោយឥស្សរជនជាន់ខ្ពស់ជាតិ និងអន្តរជាតិជាច្រើនរូប ព្រមទាំងកងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ បញ្ញវន្ត សិស្ស និស្សិត កងជីវពល ក្រុមកាយរិទ្ធ ប្រជាពលរដ្ឋ ប្រកបដោយទឹកមុខស្រស់ប្រិមប្រិយ ដែលមានកាន់ ព្រះឆាយាលក្ខណ៍ព្រះករុណា ទង់ជាតិ ទង់សាសនា ប៉េងប៉ោង និងបដាដែលសរសេរជាពាក្យស្លោកថា ជ័យយោ! ព្រះបិតា ឯករាជ្យជាតិ ជ័យយោ!

បុណ្យឯករាជ្យជាតិ ខួបលើកទី៥០ទិវា៩វិច្ឆិកា ២០០៣ បានលើកគ្រឿងទទួលព្រះអង្គយាងមកកន្លែងប្រារព្ធអង្គពិធីឯវិមាន ឯករាជ្យ ។

ព្រះមហាក្សត្រដែលអមព្រះរាជដំណើរដោយ ព្រះរាជអគ្គមហេសី និងមន្ត្រីជាន់ខ្ពស់ជាតិនិងអន្តរជាតិ ត្រូវបានទទួលស្វាគមន៍ពីអ្នកចូលរួម យ៉ាងអធិកអធមក្រៃលែង។ នៅក្នុងឱកាសនោះ ព្រះមហាក្សត្រមានព្រះរាជបន្ទូលប្រាប់អ្នកយកពត៌មាននៅវិមានឯករាជ្យថា " ខ្ញុំសប្បាយរីករាយណាស់ដោយបានមកចូលរួមក្នុងពិធីនេះ។ ខ្ញុំមានមោទនភាពចំពោះកូនចៅទាំងអស់របស់ខ្ញុំ និងជាតិរបស់ខ្ញុំ។ សូមឱ្យឯករាជ្យភាព បូរណភាព អធិបតេយ្យភាព និងឯកភាពជាតិរបស់យើង ឋិតនៅជាអមតៈ"។ ព្រះអង្គបានយាងត្រឡប់មកព្រះបរមរាជវាំងវិញ ក្រោយពីបានអុជភ្លើងជ័យ ដើម្បីចូលរួមជាព្រះរាជាធិបតីក្នុងពិធីព្យុហយាត្រា។

នៅខាងមុខព្រះបរមរាជវាំង ដោយមានវត្តមាន ភ្ញៀវជាតិ និងអន្តរជាតិ សិស្សានុសិស្ស និស្សិត បញ្ញវន្ត ប្រជាពលរដ្ឋ ក្រុមកាយរិទ្ធ កងយោធពលខេមរភូមិន្ទកងនគរបាលជាតិ ទាហានប៉ូលីស ព្រមទាំងកងទ័ពជើងទឹកបារាំងសែសផងនោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងសុន្ទរកថាសម្តែងការដឹងគុណដែលមានជាអាទិ៍ថា "រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅថ្វាយព្រះមហាក្សត្រព្រះបាទនរោត្តមសីហនុ និងបុព្វបុរសរបស់យើងដែលលះបង់ជីវិត បញ្ញាញាណ និងកម្លាំងពលំ ដើម្បីឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដី " ។

បន្ទាប់មកព្រះករុណាជាអម្ចាស់ ទ្រង់បានមានព្រះរាជឱង្ការ រំឭកឡើងវិញនូវអនុស្សាវរីយ៍ ដ៏មហាជោគជ័យ នៅក្នុងព្រះរាជបូជនីយកិច្ច ទាមទារ

ឯករាជ្យ ពីអាណានិគមបារាំង ដោយមានព្រះរាជសង្កថា " នៅទីកន្លែងត្រង់ហ្នឹង ដែលកូនចៅកំពុងឈរនៅទីហ្នឹង គឺកងទ័ពបារាំងបានសូមក្រាបថ្វាយបង្គំលាសម្តេចឪ សម្តេចតា សម្តេចតាទួត ។ បារាំងឈប់ត្រឡប់មកវិញ គឺលាជារៀងរហូត " ។ ព្រះអង្គ បានមានព្រះរាជបន្ទូលបន្តទៀតថា " សន្តិភាព ឯករាជ្យបានមកដោយគ្មានការបង្ហូរឈាមទេ ទោះជាឈាមរបស់បារាំងក្តី ឈាមរបស់ខ្មែរក្តី ។ យើងចចារជាច្រើនលើក ច្រើនសារ ដែលពេលខ្លះការចចារមានសភាពស្មុគស្មាញមែនទែន ប៉ុន្តែយើងនៅតែអាចធ្វើឱ្យសម្រេចបានជោគជ័យ ដើម្បីជាតិមាតុភូមិស្នេហានៃយើង" ។

ក្រោយព្រះរាជសង្កថាចប់ មានពិធីព្រលែងព្រាបនិងប៉េងប៉ោងជា សញ្ញាណសុំសេចក្តីសុខ សន្តិភាព និងបានចាប់ផ្តើមក្បួនព្យុហយាត្រា ដំបូងក្បួនព្យុហយាត្រានៃកងយោធពលខេមរភូមិន្ទ កងជីវពល និងក្បួនដង្ហែរបស់ក្រសួងនានា នៃរាជរដ្ឋាភិបាល បានដាក់បង្ហាញនូវ និមិត្តសញ្ញានៃក្រសួងរបស់ខ្លួន ។ មន្ត្រីរាជការស៊ីវិលបានបង្ហាញនូវទឹកមុខស្រស់ស្រាយ ក្នុងការចូលរួមទិវាបុណ្យឯករាជ្យជាតិខួបលើកទី៥០ ក្រោមព្រះរាជាធិបតីភាពព្រះករុណាជាអម្ចាស់ ជាព្រះបិតាឯករាជ្យជាតិ និងជាព្រះអគ្គមគ្គុទេសដ៏ឆ្នើម នៃព្រះរាជាណាចក្រកម្ពុជា ។

**ពុទ្ធសាសនបណ្ឌិត្យ** សូមថ្វាយព្រះពរចំពោះព្រះមហាក្សត្រ ក្នុង ឱកាសបុណ្យចម្រើនព្រះជន្ម ៨១ យាងចូល ៨២ ព្រះវស្សា របស់ព្រះករុណា និង ទិវាបុណ្យឯករាជ្យជាតិ ខួបលើកទី ៥០ នេះ នូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ សូម ទ្រង់គង់នៅជាបរមសុខក្នុងសិរីរាជសម្បត្តិ ដើម្បីថែរក្សា ប្រទេសជាតិ ឱ្យបានសុខ ចម្រើនអស់កាលជាអង្វែងតរៀងទៅ ។

ទំព័រឆ្លើយឆ្លងជាមួយកម្ពុជសុរិយា



**មិត្តអ្នកអានជាទីមេត្រី !**

កម្ពុជសុរិយា បានទទួលអត្ថបទពីបណ្តាខេត្តមួយចំនួននៅក្នុងប្រទេស និងមួយចំនួនទៀតមកពីក្រៅប្រទេស ជាអត្ថបទបែបស្រាវជ្រាវ ជាអត្ថបទកំណាព្យ និងអត្ថបទសំណួរ។ កម្ពុជសុរិយា សូមជម្រាបបញ្ជាក់ថា រាល់អត្ថបទទាំងអស់យើងនឹងធ្វើការពិនិត្យ និងសម្រេចបោះពុម្ពទៅបានដោយ÷

-មានខ្លឹមសារអព្យាក្រិត ទាក់ទងនឹងអក្សរសិល្ប៍ពុទ្ធសាសនា, អក្សរសាស្ត្រទូទៅ និង អក្សរសិល្ប៍ខ្មែរ,

-មិនចម្លងពីច្បាប់ដើមណាមួយ និងមិនលើសពី៥០ទំព័រ

អាស្រ័យហេតុនេះរាល់អត្ថបទ ដែលអស់លោកអ្នកបានផ្ញើមកហើយ ហើយមិនទាន់ឃើញចុះផ្សាយនោះ កម្ពុជសុរិយានឹងបន្តចុះផ្សាយតាមលំដាប់លេខរៀង ឬថែរក្សាសម្រាប់បោះពុម្ពជាសៀវភៅ ឬជាព្រឹត្តិប័ត្រ ប្រចាំខែនៅអនាគតដ៏ខ្លីខាងមុខ។

**សូមអរគុណ**

# អត្ថបទដែលកម្ពុជសុរិយាបានទទួលក្នុងត្រីមាសទី៤ ឆ្នាំ២០០៣

| ល.រ | នាម និងគោត្តនាម | មកពី | ឈ្មោះអត្ថបទ |
|---|---|---|---|
| ១ | លោក ជាវ ហ៊ិន | ព្រះវិហារ | -ទំនីបគ្រួធ្មប់ |
| ២ | មន្ទីរធម្មការ និង សាសនា | រតនគីរី | -ប្រវត្តិអ្នកតាដោះក្រមុំ<br>-ល្បែងប្រជាប្រិយខ្មែរ<br>-កីឡាប្រជាប្រិយខ្មែរ<br>-ឧបករណ៍កសិកម្មខ្មែរ<br>-អំពីនំខ្មែរ<br>-អំពីមុខម្ហូបអាហារខ្មែរ<br>-បន្លែខ្មែរ |
| ៣ | លោក យក់ សាន់ | កំពង់ធំ | -ប្រវត្តិជនជាតិភាគតិចនៅភូមិភាគឦសាន<br>-កំណាព្យៈ<br>-គុណសម្ដេចឪ-សម្ដេចម៉ែ<br>-ពាក្យទូន្មានរបស់ព្រះពុទ្ធ<br>-តម្លៃព្រះពុទ្ធសាសនា |
| ៤ | អ្នកស្រី ហ៊ុយ ឆេងរតនា | វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ | -ការចូលម្លប់ និងការអប់រំស្ត្រីខ្មែរ |

| ល.រ | នាម និងគោត្តនាម | មកពី | ឈ្មោះអត្ថបទ |
|---|---|---|---|
| ៥ | សាន សុមែន | ក្រុងព្រះសីហនុ | -ប្រវត្តិខេត្តកំពង់សោម |
| ៦ | លោក ញ៉ាំង ប៊ុនថន | រតនគិរី | -សម្លប្រូង |
| ៧ | ពៅ ញិប | កណ្ដាល | -ពិធីក្រុងពាលី និងភានទេព្តា<br>-ពិធីសូត្រមន្តបង្កក់ផ្ទះ ក្រោយខ្លែងធ្លាក់នៅលើដំបូល<br>-ពីធីបណ្ដែតកន្ទោងលយសំពៅតាមទន្លេ-ស្ទឹង<br>-ប្រវត្តិភូមិរកាកោង និងភូមិល្វាទេ<br>-ប្រវត្តិសូគ្រាស និងចន្ទ័គ្រាស |
| ៨ | ស៊ី សួន | ស្ទឹងត្រែង | -ល្បែងជល់មាន់ |
| ៩ | លោក ង៉ែត សោភ័ណ | ខេត្តកំពត | -លក្ខណៈពិសេសរបស់សម្ដេចព្រះសង្ឃរាជបីព្រះអង្គ |
| ១០ | មន្ទីរ | | -ប្រវត្តិនិទានរឿងស្រីសល្អសក់ក្រអូប |

# កែពាក្យខុស

| ល.រ | ពាក្យខុស | ពាក្យត្រូវ | បន្ទាត់ | ទំព័រ |
|---|---|---|---|---|
| ១ | គ្រិស្តសករាជ | គ្រិស្តសករាជ | ៩ | ២២ |
| ២ | ខាន | បាន | ១៥ | ២២ |
| ៣ | ខ្លាតុង | ប្លាតុង | ១៧ | ២២ |
| ៤ | ខាន | បាន | ១៦ | ២៩ |
| ៥ | គ្រិស្តសករាជ | គ្រិស្តសករាជ | ១៥ | ៣១ |
| ៦ | ខាន | បាន | ១៩ | ៨៣ |
| ៧ | បន្តិចបន្ទូច | បន្តិចបន្តួច | ៦ | ៩៥ |
| ៨ | ក្សក្រ | ក្សត្រ | ១៥ | ៩៨ |